

Websites: WatKhemaraRatanaram.org or WatKhmers.org

# អធិប្បាយ

# បរាភវសូត្រ

# លំនាំធម៌ទេសនា

## ជំនួយស្មារតី ដល់ធម្មកថិកអង្គថ្មី

ការប្រមូលរៀបរៀង

ដោយ

មហា សោម សុវណ្ណ (វិនយធរោ)

# "ធម្មទេសនាបរាភវសូត្រ"

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
## នមត្ថុ រតនត្តយស្ស វន្ទាមិ

ព្រះករុណា សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ។

លំដាប់បន្ទាប់អំពីបទនមស្ការ ដោយសង្ខេបនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកបរាភវសូត្រមកសំដែងប្រកាសចែកជូនដល់អស់លោកអ្នក លោកយាយ លោកតា ព្រឹទ្ធាចារ្យ ពុទ្ធបរិស័ទទាំងអស់ ដែលបានអញ្ជើញមកជួបជុំក្នុងទីនេះ ដើម្បីជាគ្រឿងភ្ញាក់កំណើត កើតគំនិតនិងជាគ្រឿងប្រដាប់សតិបញ្ញាស្មារតីដោយសង្ខិតន័យសង្ខេបខ្លី ដូចសេចក្ដីតទៅនេះ ។

មុននឹងសំដែងនូវឧប្បត្តិហេតុនៃបរាភវសូត្រ ជូនជាទីសណ្ដាប់ជាខាងដើមសិន ។

## ឧប្បត្តិហេតុនៃបរាភវសូត្រ

មានសេចក្ដីដំណាលថា កាលថា ៖ កាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណឡើងក្នុងលោក

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គទ្រង់សំដែងនូវមង្គល ៣៨ ប្រការមានបទថា **អសេវនា ចពាលានំ** ប៉ុណ្ណោះជាដើម ។

សេចក្តីថា សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត ជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី រៀបក្រុងសាវត្ថី លំដាប់នោះ ឯងមានទេវតាមួយអង្គកាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយមាន រស្មីដ៏ល្អញ៉ាំងវត្តជេនពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះ-ភាគទ្រង់គង់នៅទីណាក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើប ថ្វាយបង្គំ ចំពោះអង្គព្រះដ៏មានព្រះភាគទ្រង់សំដែងនូវមង្គលនោះ ។

សូមបញ្ជាក់ថា កាលទេវតាទូលសួរនូវមង្គល គឺសួរតែម្តង ព្រះអង្គទ្រង់សំដែងនូវមង្គល ១០ គាថា មាន ៣៨ មង្គលរហូតដល់ចប់ ទាំងអស់ ។

ទេវកាលបើបានស្តាប់នូវមង្គលចប់សព្វគ្រប់ហើយ ក៏ធ្វើនិវត្តនា ការ ត្រឡប់ទៅកាន់ស្ថានតាវត្តឹង្សវិញ ពេលនោះព្រះឥន្ទទ្រង់សួរថា ម្នាល ទេវតាអ្នកទូលសួរនូវមង្គល គឺសេចក្តីចំរើន, ចុះអំពីសេចក្តីវិនាស អ្នកបាន ទូលសួរដែរឬទេ? ទេវតាឆ្លើយ មិនបានទូលសួរទេ !

អាស្រ័យហេតុនេះ ទេវតាក៏ត្រឡប់មកទូលសួរនូវសេចក្តីវិនាស ចំពោះព្រះអង្គ, ព្រះអង្គទ្រង់សំដែងអំពីបរាភវសូត្រ, សូត្រដែលនិយាយ អំពីសេចក្តីវិនាស ។

សូមបញ្ជាក់ថា ក្នុងបរាភវសូត្រមាន ១២ គាថា ទេវតាទូលសួរម្តង ព្រះអង្គទ្រង់សំដែងម្តង ជាលំដាប់ហូរហែររហូតគ្រប់ទាំង ១២ គាថា គឺមានន័យប្លែកៗអំពីការសំដែងនូវមង្គល ដែលទេវតាទូលសួរតែម្តង ព្រះអង្គទ្រង់សំដែងចប់នូវមង្គលទាំង ៣៨ ប្រការ ។

លំដាប់តទៅនេះ គឺជាសំនួរដែលទេវតាទូលសួរចំពោះព្រះសាស្តាថា :

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

យើងទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចំរើន វិនាសប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ឆ្ពោះព្រះ-គោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសំដែងឱ្យទាន ធម្មជាតិដូចម្តេចដែលជាប្រធាននាំសត្វវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

អ្នកដែលចំរើនតថាគតដឹងងាយ អ្នកដែលអន្តរាយតថាគតដឹងពិតអ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចំរើន អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើនចំរើន វិនាសទៅមុខ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# អធិប្បាយ

## គាថាទី១

បទគាថាៈ **សុចិវាសោ តវំ ហោតិ** បានសេចក្ដីថា អ្នកមានសេចក្ដីចំរើន តថាគតដឹងងាយ, ពាក្យថា "ចំរើន" ក្នុងន័យនេះ សំដៅយក សុចរិត គឺការប្រព្រឹត្ត ស្អាតដោយកាយ វាចា ចិត្ត ។

ស្អាតមាន ៣ យ៉ាងគឺៈ

**១~ កាយវិសោចេយ្យ** ស្អាតកាយ

**២~ វចីសោចេយ្យ** ស្អាតវាចា

**៣~ មនោវិសោចេយ្យ** ស្អាតចិត្ត

ពាក្យថា " ស្អាតកាយ " បានដល់ការមិនសម្លាប់សត្វ ១, មិនលួចទ្រព្យគេ១, មិនប្រព្រឹត្តកន្លងប្រពៃណីកូន ប្រពន្ធគេ១ ។

"ស្អាតវាចា" គឺមិននិយាយកុហកគេ១ , មិននិយាយចាក់ដោតគេ១ មិននិយាយព្រះញ្ញង់គេ១, មិននិយាយពាក្យឥតប្រយោជន៏១ ។

"ស្អាតចិត្ត" បានដល់ការមិនសំឡឹងរំពៃចង់បានទ្រព្យអ្នកដទៃ ឱ្យបានមកជាទ្រព្យរបស់ខ្លួន១, មិនចង់គំនុំព្យាបាទអ្នកដទៃ ១, មានគំនិតយល់ត្រូវតាមគន្លងធមិ ១ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្អាតទាំង ៣ យ៉ាងនេះ នឹងហៅថា កាយសុចរិត គឺការប្រព្រឹត្តល្អដោយកាយ, វិចីសុចរិត ប្រព្រឹត្តល្អដោយវាចា, មនោសុចរិត ប្រព្រឹត្តល្អដោយចិត្តដូច្នេះវិញក៏បាន ។

សុចរិត ៣ យ៉ាងនេះ បើបុគ្គលណាបានប្រព្រឹត្តល្អហើយ រមែងបាននូវសេចក្ដីសុខចំរើន ចំពោះខ្លួនឯងផង ចំពោះអ្នកដទៃផង ហើយរមែងបានសុខ ក្នុងលោកនេះផង បានសុខក្នុងលោកខាងមុខផង ដោយពិត ។ ផ្ទុយទៅវិញបើនរណាមិនបានប្រព្រឹត្តសុចរិតទាំង ៣ នេះទេ រមែងមិនបានជួបប្រទះនូវសេចក្ដីសុខចំរើនទេ, ម្យ៉ាងទៀត បើនរណាប្រព្រឹត្តមើលងាយប្រមាថកាតទាន ចំពោះអ្នកប្រព្រឹត្តសុចរិត លោកទុកដូចជាមើលងាយចំពោះទេវតា ដូចរឿង កិសវច្ឆតាបស សូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

កាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាកូនបុរោហិតរបស់ស្ដេច ក្រុងពារាណសី មានព្រះនាមថា: ជោតិបាល ។

ក្នុងកាលជាខាងក្រោយមកកុមារនោះ បានសំដែងសិល្បសាស្ត្រធ្នូថ្វាយព្រះរាជា ក៏បែជាមានព្រះនាមថា សរភង្គវិញ ។ ថ្ងៃមួយសរភង្គមិនបានប្រាប់បុគ្គលណាសោះ បានចូលទៅក្នុងព្រៃខ្ចិត បួសជាឥសីតែម្នាក់ឯង អាស្រ័យនៅក្នុងអាស្រមដែលសក្កទេវរាជប្រទានឱ្យ, ព្រៃនោះចម្ងាយ ៣០ យោជន៍ពីក្រុងពារាណសី ក្បែរឆ្នេរស្ទឹងឈ្មោះ គោធាវរី នៅក្នុងទីនោះ

បាន ៧ ថៃ ក៏ញុំាំឈានឱ្យកើតឡើង ។ ថ្ងៃមួយព្រះរាជា ជាច្រើន អង្គ មានព្រះរាជាក្រុងពារាណសី និងអ្នកក្រុងនោះជាដើម នាំគ្នាចូលទៅ បួសក្នុងសំណាក់សារភង្គតាបស ចង្អៀតពាសពេញអាស្រម ឯសារភង្គ តាបសនោះមានសិស្សច្បង១រូបឈ្មោះ កិសវច្ឆ ជាអ្នកពេញចិត្តក្នុងទីស្ងាត់ បានគេចចេញទីអាស្រមនោះ ទៅនៅក្នុងឱទ្យានរបស់ព្រះរាជាទ្រង់ព្រះ- នាម ទណ្ឌកី នានគរកុម្ភវតី ដោយសេនាបតីម្នាក់ជាអ្នកទំនុកបំរុង ។

កាលនោះព្រះបាទទណ្ឌកីទ្រង់មិន សព្វព្រះទ័យនឹងស្ត្រីផ្កាមាស ម្នាក់ បានបង្គាប់ឱ្យរដ្ឋមន្ត្រីដកឋានន្តរពីស្ត្រីនោះចេញ ។ តាំងពីថ្ងៃ នោះមក ស្ត្រីនោះចេះតែដើរសម្ភពដើម្បីឱ្យបានឋានន្តរវិញ , សម័យ មួយបានចូលទៅក្នុងឱទ្យាន ជួបនឹង កិសវច្ឆតាបស ទើបគិតថា អញ ឃើញតាបសនេះ ចង្រៃណាស់ ក៏ស្ដោះទឹកមាត់ ចោលឈើស្ទន់ ចាក់ទឹក លប់មុខទៅលើព្រះកេសតាបសនោះ ហើយចៀសចេញទៅ ។

ក្នុងថ្ងៃនោះព្រះរាជាបានប្រទានឋានន្តរដល់ស្ត្រីនោះវិញ, កន្លងពីរ បី ថ្ងៃមកព្រះរាជាទ្រង់ហូតឋានន្តរពីបុរោហិតម្នាក់ទៀត ។ បុរោហិតក៏ ចូលទៅរកស្ត្រីនោះថានាងធ្វើឧបាយដូចម្ដេច ទើបបានឋានន្តរវិញ? ស្ត្រី នោះក៏ប្រាប់ហេតុសព្វគ្រប់ ។ បុរោហិតតាមក៏បានឋានន្តរវិញ, ជនទាំង ពីរនាក់នឹកស្មានថា ដែលព្រះរាជាឱ្យឋានន្តរវិញ ព្រោះខ្លួនបានទៅខាកស្ដោះ ទឹកមាត់ដាក់ព្រះកេសឥសី មិនមែនបានដោយកុសលពីជាតិមុន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កន្លងទៅពីរបីថ្ងៃមក មានការបះបោរ កើតអសន្តិសុខ ក្នុងបច្ចន្តប្រទេស ព្រះរាជាបានប្រជុំពួកយោធាបំរុងនឹងចេញទៅបង្ក្រាបសត្រូវ ទ្រង់បានជ្រាបថាការស្តោះទឹកមាត់ដាក់លើព្រះកេសកិសវច្ឆតាបស មានជោគជ័យល្អ ក៏នាំទ័ពចូលទៅក្នុងឱទ្យាន ខាកស្តោះទឹកមាត់ដាក់ព្រះកេសគ្រប់ៗគ្នា គ្រាន់តែកំហាក និងទឹកមាត់ប្រឡាក់ជោរជោគគ្របលិចសរីរតាបស ។ ចំណែកខាងសេនាបតីជាឧបដ្ឋានតាបស ដឹងហេតុនោះហើយក៏មីម្មារទៅឱទ្យាន ដងទឹកទៅដុះលាងជំរះមន្ទិលកំហាក និង ទឹកមាត់ស្អាតបាតហើយ ក៏លាន់មាត់ថា មនុស្សទាំងអស់នេះ មិនគួរធ្វើយ៉ាងនេះសោះទើបសួរតាបសថា ៖ លោកម្ចាស់ខឹង ឬទេ? ។ តាបសប្រាប់ថា អាត្មាឥតអាក់អន់ចិត្តខឹងបន្តិចបន្តួចទាល់តែសោះទេ ប៉ុន្តែទេវតាគេខឹងខ្លាំងណាស់ នៅតែ ៧ ថ្ងៃទៀតទេ នរគកុម្ភវតីនេះ និងវិនាសសាបសូន្យអស់ឥតសល់ ។ សេនាបតីបានរៀបចំគឺប្រមូលទ្រព្យសម្បត្តិចេញផុតពីនរគរនោះទៅ ។

ឯសរភង្គតាបសបានប្រើតាបសពីររូប ឱ្យមកនិមន្តកិសវច្ឆតាបសទៅអាស្រមវិញ ។

ព្រះរាជាដែលលើកទ័ពបង្ក្រាបច្ចន្តគ្រាម ក៏មានជ័យជំនះដូចបំណង លុះត្រឡប់ចូលមកនគរវិញ ទេវតាក៏បង្អុរភ្លៀងផ្កាម្លិស ភ្លៀងមាសប្រាក់ ភ្លៀងកែវទាំង ៧ ប្រការ ធ្លាក់ចុះមកគរពាសពេញនរគទាំងមូល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះរាជាព្រមទាំងជនអ្នកប្រព្រឹត្តទុច្ចរិត ទាំងប៉ុន្មាន មានសេចក្ដីត្រេកអរណាស់ បាននិយាយគ្នាថា យើងតាំងពីខាកស្ដោះដាក់ព្រះកេសឥសីនោះមកចេះតែមានជោគជ័យជាប់ជានិច្ច ។

ក្នុងពេលនោះមានបុរសម្នាក់ឈ្មោះ រាម នៅក្នុងនរគពារាណសីជាអ្នកចិញ្ចឹមមាតាបិតា បានមកធ្វើជំនួញក្នុងនគរកុម្ភវតីនោះចំនួន ៩ឆ្នាំមកហើយ, ទេវតាបានជ្រាបថា បុរសនោះជាអ្នកចិញ្ចឹមមាតាបិតាក៏នាំចេញពីនរគនោះទៅ ។ ឯពួកមនុស្សដែលមិនប្រទុស្ដដល់មាតាបិតា និងសត្វតិរច្ឆានទាំងឡាយ ទេវតាក៏បណ្ដោយឱ្យចេញផុតអស់ទៅ ។

លំដាប់នោះស្រាប់តែមានភ្លៀងអាវុធ ភ្លៀងរងើកភ្លើង ភ្លៀងដុំថ្មប៉ុនៗផ្ទះ ភ្លៀងដីខ្សាច់ធ្លាក់ចុះមក មានកំពស់ ៦០ ហត្ថ សម្លាប់មនុស្សទុច្ចរិត និងបំបាក់បំបែកវិមានប្រាសាទផ្ទះសំបែង ធ្វើនគរកុម្ភវតីនោះឱ្យសាបសូន្យវិនាសអស់ទៅ ។

អ្នកប្រព្រឹត្តសុច្ចរិតរមែងបានទទួលនូវអានិសង្ស ៥ យ៉ាងគឺ:

១.**អត្តាបិ អត្តានំ នូបវទតិ** ខ្លួនឯងតិះដៀលខ្លួនឯងមិនបាន ។

២.**អនុវិច្ច វិញ្ញូ បសំសន្តិ** អ្នកប្រាជ្ញរមែងសរសើរ ។

៣.**កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** និងមានកិត្តិស័ព្ទរន្ទឺ ខ្ចាយផ្សាយទៅ ។

៤.**អសម្មូឡ្ហោកាលំ ករោតិ** ពេលដែលជិតស្លាប់មិនវង្វេងស្មារតី ។

**៥-កាយស្ស ភេទា បរម្មរណា សុគតឹ លោកំ ឧបបជ្ជតិ** លុះបែកធ្លាយរាងកាយទៅកាន់សុគតិ ទេវលោក គឺស្ថានសួគ៌ ។

បទថា: **សុទិដ្ឋានោ បរាភវោ** បានសេចក្តីថា អ្នកមានសេចក្តីវិនាសតថាគតដឹងពិត ។

**ព្យសនៈ** សេចក្តីវិនាសមាន ៥ យ៉ាងគឺៈ

**១-រោគព្យសន** វិនាសដោយរោគ

**២-ភោគព្យសន** វិនាសទ្រព្យសម្បត្តិ

**៣-ញាតិព្យសន** វិនាសពួកញាតិ

**៤-សីលព្យសន** វិនាសសីល

**៥-ទិដ្ឋិព្យសន** វិនាសទិដ្ឋិ ។

ពាក្យថា " វិនាស " ក្នុងទីនេះបានដល់មនុស្សទាំងឡាយ ក្នុងលោកសន្និវាសនេះ ជាអ្នកប្រព្រឹត្តនូវអំពើទុច្ចរិត អាក្រក់ដោយកាយ វាចា ចិត្ត ។ អាក្រក់ដោយកាយមាន ៣ យ៉ាងគឺ សម្លាប់សត្វ១, លួចទ្រព្យគេ១, ប្រព្រឹត្តខុសក្នុងកាម ១ ។

អាក្រក់ដោយវាចាមាន ៤ យ៉ាងគឺៈ

និយាយកុហក១, និយាយចាក់ដោត១, និយាយពាក្យញុះញង់១, និយាយពាក្យឥតប្រយោជន៍១ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អាក្រក់ដោយចិត្តមាន ៣ យ៉ាងគឺ រំពៃចង់បានទ្រព្យអ្នកដទៃ១ គិតព្យាបាទអ្នកដទៃ១, ឃើញខុសចាកគន្លងធម៌១ ។

អំពើទុច្ចរិតជាអំពើអាក្រក់ដែលអ្នកប្រាជ្ញទាំងឡាយ មានពុទ្ធាទិបណ្ឌិតជាដើម ទ្រង់ត្មះតិះដៀលអនេកប្បការ, អ្នកប្រព្រឹត្តអំពើទុច្ចរិតរមែងទទួលនូវសេចក្ដីទុក្ខ លំបាកចំពោះខ្លួនឯងផង អាចញ៉ាំងអ្នកដទៃឱ្យដល់នូវសេចក្ដីទុក្ខលំបាកផងដែរ, មួយទៀតរមែងទទួលទុក្ខក្នុងលោកនេះផង លោកខាងមុខផងជាមិនខាន ។

ទោះបីមិនធ្លាក់នរក ក៏គង់កើតជាប្រេតជាមិនខាន ព្រោះតែអំពើទុច្ចរិត, សមដូចនិទាន សូករប្រេត ដែលមានមកក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ ទំព័រ ទី ២ ។

មានសេចក្ដីដំណាលថា ៖ ព្រះថេរនាម នារទបានឃើញប្រេតហើយសួរថា កាយទាំងឡាយរបស់អ្នក មានសម្បុរដូចជាមាស មានរស្មីភ្លឺស្វាងសព្វទិស តើមាត់របស់អ្នកដូចជាជ្រូក តើអំពីភពមនុស្សអ្នកបានធ្វើអំពើដូចម្ដេច?

ប្រេតក៏បានឆ្លើយថា៖ បពិត្រព្រះនារទៈ ខ្ញុំជាមនុស្សបានសង្រួមកាយ តែមិនបានសង្រួមវាចា ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនេះដូចលោកម្ចាស់បានឃើញស្រាប់ហើយ បពិត្រព្រះនារទៈ ខ្ញុំសូមទូលរឿង

Websites: WatKhemaraRatanaram.org or WatKhmers.org

នេះដល់លោកម្ចាស់ រឿងនេះលោកម្ចាស់បានឃើញដោយខ្លួនឯងស្រាប់ហើយលោកកុំធ្វើអំពើបាប ដោយមាត់ កុំមានមាត់ដូចជាជ្រូកឡើយ ។

សូមនាំរឿង បូតិមុខប្រេតមួយមកបញ្ជាក់ទៀត ព្រះនារទត្ថេរបានឃើញប្រេតហើយបានសួរថា អ្នកទ្រទ្រង់នូវវណ្ណធាតុ គឺរាងកាយជាមាត់របស់អ្នកដែលមានក្លិនដ៏ស្អុយ តើអំពើភពមុខ អ្នកបានធ្វើអំពើដូចម្តេច? ប្រេតឆ្លើយថា: ខ្ញុំជាសមណមក មានវាចាអាក្រក់ ប្រព្រឹត្តតបធមិមិនសង្រួមមាត់ ឯវណ្ណធាតុខ្ញុំបានហើយដោយតបធមិ មាត់របស់ខ្ញុំមានក្លិនស្អុយ ព្រោះតែពោលនូវពាក្យញុះញង់ ។

បពិត្រព្រះនារទ អំពើនោះ បានឃើញខ្លួនឯងស្រាប់ហើយ អ្នកឈ្លាស់ទាំងឡាយ ជាអ្នកអនុគ្រោះគប្បីពោលថា : អ្នកកុំពោលពាក្យញុះញង់ កុំពោលពាក្យកុហក ទើបអ្នកពិតជាបានជាទេវបុត្រ មានកាមតាមសេចក្តីប្រាថ្នា ។

អ្នកប្រព្រឹត្តអំពើទុច្ចរិតត្រូវមានទោស ៥ យ៉ាងគឺ:

**១~អត្តាបិ អត្តានំ ឧបវទតិ** ខ្លួនឯងតិះដៀលខ្លួនឯងបាន ។

**២~អនុវិច្ច វិញ្ញូ គរហន្តិ** អ្នកប្រាជ្ញតែងត្មេះតិះដៀល ។

**៣~បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** មានកេរ្តិ៍ឈ្មោះមិនល្អផ្សាយទៅទិសផ្សេងៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**៤-សម្មុឡ្ហា កាលំ ករោតិ** ទៀតស្លាប់រមែងវង្វេងស្មារតី ។

**៥-កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំវិនិបាតំ និរយំ ឧបបជ្ជតិ** លុះទំលាយកាយទៅកាលណា នឹងទៅកាន់អបាយ **ទុគ្គតិ វិនិបាត នរក** ព្រោះមានអារម្មណ៍គឺអំពើអាក្រក់ ដែលខ្លួនធ្វើទុកពីខាងដើមមក និមិត្តឱ្យឃើញទៀបស្លាប់នោះនៅចាំពីខាងមុខ ។

បទថា: **ធម្មកាមោ ភវំ ហោតិ** បានសេចក្តីថា : អ្នកស្រឡាញ់ធម៌ រមែងមានសេចក្តីចំរើន ។ ពាក្យថា "**ធម្ម**" នេះមកអំពី **ធរ** ធាតុ និង **រម្ម** បច្ច័យ លុប **រ** ទីបំផុតធាតុចេញទុកតែ **ធ** ហើយលុបរបស់ **រម្ម** ចេញទុកតែ **ម្ម** សំរេចរូបជា **ធម្ម** បទវិគ្គហៈថា **ធារេតីតិ "ធម្មោ" (សភាវោ)** សភាវទ្រទ្រង់, មួយ បែបទៀតថា : **សត្តេ ធារេតីតិ "ធម្មោ" (សភាវោ)** សភាវ ទ្រទ្រង់នូវសត្វ ។

ធម៌សំដៅយកសេចក្តីពិតមែន ឬ សភាវដែលប្រព្រឹត្តត្រឹមល្អហៅថា ធម៌ ឬ សភាវទ្រទ្រង់សត្វទូទៅ ។

ធម៌ ស័ព្ទនេះមានន័យដែលត្រូវប្រែបាន ច្រើនយ៉ាងណាស់ នឹងប្រែហើយអធិប្បាយដោយសង្ខេបដូចសេចក្តីតទៅនេះ :

**១-ធម្ម** ប្រែ "សភាវៈ" គឺសេចក្ដីពិត ឬចិត្ត និងចេតសិក ខាងកុសល និង អកុសល និង អព្យាកតៈ ដូចបទបាលីថា : **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ។ ល ។**

**២-ធម្ម** ប្រែថា "ប្រាជ្ញា" ដូចបទបាលីថា **សច្ចំធម្មោ ធិតិ ចាគោ** សច្ចៈ ធម្មៈ ធិតិ ចាគៈ នេះជាឃរាវាសធម៌ ពាក្យថា ធម៌ ក្នុងទីនេះជាឈ្មោះនៃប្រាជ្ញា ។

**៣-ធម្ម** ប្រែថា " បុណ្យ " ដូចបទបាលីថា **ធម្មោ ហវេ រក្ខតិ ធម្មចារី** បុណ្យហ្នឹងឯងតែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ។

**៤-ធម្ម** ប្រែថា "បញ្ញត្តិ" ឬលំនាំភាសា គឺ ច្បាប់ដែលគេតាំងទុក នឹងលំនាំសំឡេងដូចបទបាលីថា **បញ្ញត្តិ ធម្មោ និរុត្តិ ធម្មោ** ធម៌គឺ បញ្ញត្តិ, ធម៌គឺលំនាំភាសា ។

**៥-ធម្ម** ប្រែថា " អាបត្តិ " ដូចបទបាលីថា **បារាជិកា ធម្ម** អាបត្តិទាំងឡាយឈ្មោះបារាជិក **សង្ឃាទិសេសា ធម្មា**(១) អាបត្តិទាំងឡាយឈ្មោះសង្ឃាទិសេស ។

**៦-ធម្ម** ប្រែថា " បរិយត្តិ " គឺការសិក្សាដូចបទបាលីថា **ឥធ ភិក្ខវេ ធម្មំ បរិយាបុណាតិ, សុត្តំ គេយ្យំ វេយ្យា ករណំ គាថា ឧទានំ ឥតិវុត្តកំ អព្ភូតធម្មំ វេទល្លំ ។ ល ។** ភិក្ខុក្នុងសាសនា

(១)- អភិធានប្បទីបិកា ។

នេះ រៀនសូត្របរិយត្តិ គឺសុត្តៈ គេយ្យៈ វេយ្យាករណ៍ គាថា ឧទាន ឥតវុត្តកៈ ជាតក អព្ភូតធម្ម វេទល្លៈ ។ល ។

**៧-ធម្ម** ប្រែថា "សំដែង" ដូចបទបាលីថា **ធម្មំ វោ ភិក្ខវេ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយតថាគតសំដែងនូវធម៌ដល់អ្នកទាំង-ឡាយ ។

**៨-ធម្ម** ប្រែថា "និស្សត្តនិជ្ជីវៈ" គឺសភាពមិនមែនសត្វ មិនមែនជាជីវិត ដូចបទបាលីថា : **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ** សភាវៈ មិនមែនជាសត្វ មិនមែនជាជីវិត រមែងមានក្នុងសម័យនោះឯង ។

**៩-ធម្ម** ប្រែថា " ប្រក្រតី " ឬ " ធម្មតា " ដូចបទបាលីថា **អនិច្ចា វត សង្ខារា ឧប្បា ទវយធម្មិនោ** សង្ខារធម៌ទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើងនិងវិនាសទៅវិញជាធម្មតា ។

**១០-ធម្ម** ប្រែថា " វិចារ " គឺរបស់ប្រែប្រួលដូចបទបាលីថា : **វយធម្មា សង្ខារា** សង្ខារទាំងឡាយប្រែប្រួល ឬ សាបសូន្យទៅជាធម្មតា ។

**១១-ធម្ម** ប្រែថា " គុណ " ឬ " ពរ " ដូចបទបាលីថា **នហិ ធម្មោ អធម្មោ ចឧភោសមវិ បាកិនោ, ចត្តារោ ធម្មា វឌ្ឍន្តិ** សភាវៈពីរប្រការគឺ គុណ ១ ទោស ១ ឱ្យផលមិនស្របគ្នា, ពរ ៤ ប្រការរមែងចំរើន ។

**១២.ធម្ម** ប្រែថា " ការប្រព្រឹត្តតាមសណ្តាប់ធ្នាប់ល្អ ឬ ឫកពារ " ដូចបទបាលីថា : **សីលវា កល្យាណធម្មោ** បុគ្គលមានសីលមានសណ្តាប់ល្អ មិនធ្លាក់ចុះ **ពាលា បណ្ឌិតោ ធម្មា** ឫកពារជារបស់ជនពាល, ឫកពារជារបស់ជនជាបណ្ឌិត ។

**១៣.ធម្ម** ប្រែថា "សមាធិ" ដូចបទបាលីថា **ភាវិតធម្មោ កតសមណធម្មោ** មានសមាធិចំរើនហើយ មានសមាធិបរិកម្ម ស្រេចហើយ ។

**១៤.ធម្ម** ប្រែថា "បច្ចុប្បន្ន" ដូចបទបាលីថា **ធម្មដ្ឋិតតា ធម្មនិ-យាមតា** ស្ថិតនៅឬកំណត់នៅក្នុងបច្ចុប្បន្ន ។ **ទិដ្ឋធម្មិ កោ អត្ថោ** ប្រយោជន៍បច្ចុប្បន្ន ។

**១៥.ធម្ម** ប្រែថា "ហេតុ ឬ ប្រពៃណី" ដូចបទបាលីថា **ធម្មប្បដិ-សម្ភិទា ធម្មញ្ញុតា** បែកធ្លាយប្រាជ្ញា ក្នុងហេតុ ដឹងច្បាស់នូវហេតុ **ឯស ធម្មោ សនន្តនោ** , ប្រវេណីនេះជារបស់មានមកយូរហើយក្នុងកាលមុន ។

**១៦.ធម្ម** ប្រែថា "សាសនា ឬ សេចក្តីពិត" ដូចបទបាលីពោលថា : **ស្វាក្ខាតធម្មោ** សាសនាតថាគតសំដែងទុកល្អហើយ **អាទិកល្យាណោ ធម្មោ** សាសនាមានលំអបទដើម ឬ ពិរោះបទដើម **ញេយ្យធម្មោ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**ញាតធម្មោ** សេចក្តីពិតដែលតថាគតដឹងហើយ **ធម្មានុធម្មប្បដិបន្នោ** បុគ្គលប្រតិបត្តិតាមសេចក្តីពិត ដ៏សមគួរដល់សេចក្តីពិត ។

**១៧~ធម្ម** ប្រែថា ពិត (បរមត្ថសច្ច) មគ្គនឹងផលនិព្វាន ដូចបទបាលីថា **ទិដ្ឋធម្មោ មគ្គធម្មោ** បានឃើញបរមត្ថសច្ចៈ បានលុះបរមត្ថសច្ច **អធិគតោ ខោ ធម្មោ** មគ្គផលនិព្វានតថាគតបានហើយ ។

ទាំងអស់នេះជាអត្ថរបស់ពាក្យថា **ធម្ម ឬ ធម៌** ។ ចំណែកខាងបទវិគ្គហៈនៃពាក្យថា "**ធម**" នេះក៏មានច្រើនយ៉ាងដែរ តែក្នុងទីនេះ សូមដកស្រង់យកតែ ៥ យ៉ាងមកជានិទស្សន៍ ៖

**១~ចតូសុ អបាយេសុ សំសារេ វា សត្តេ អបតមានេ ធារេតីតិ~ ធម្មោ** សភាពគឺ សេចក្តីពិចារណា រមែងទ្រទ្រង់នូវសត្វទាំងឡាយមិនឱ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ៤ ឬ ក្នុងសង្សារវដ្ត សភាពនោះឈ្មោះថា ធម៌ ។

**២~សលក្ខណំ ធារេតីតិ ~ ធម្មោ** សភាពណារមែងទ្រទ្រង់នូវលក្ខណៈរបស់ខ្លួន (គឺកុសលទាំង ៤ មានកាមាវចរកុសលជាដើម) សភាពនោះឈ្មោះថា ធម៌ ។

**៣~បាបកេ អកុសល ធម្មោ ធុនាតីតិ ~ ធម្មោ** សភាពណារមែងកំចាត់បង់នូវអកុសលធម៌ ដ៏លាមកចេញចាកខន្ធសន្តាន សភាពនោះឈ្មោះថា ធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**៤.សោតាបន្នាទិហិ អរិយេហិ ធារិយតីតិ = ធម្មោ** សភាព ណាដែលព្រះអរិយទាំងឡាយមានសោតាបន្នបុគ្គលជាដើម តែងទ្រទ្រង់ ទុក (ចាំទុកក្នុងសន្ដាន) សភាពនោះឈ្មោះថា ធម៌ ។

**៥.យថានុសិដ្ឋំ បដិបជ្ជមានេ សត្តេ អបាយេសុ អបតមានេ សត្តេ ភត្វា ធារេតីតិ = ធម្មោ** សភាពណាទ្រទ្រង់នូវសត្វ ដែល ប្រតិបត្តិសមគួរដល់ពាក្យប្រៀនប្រដៅមិនឱ្យធ្លាក់ទៅក្នុងអបាយទាំង ៤ សភាពនោះ ឈ្មោះថា ធម៌ ។

**ធម៌** គឺពាក្យ ប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាសច្ច ជាអកា-លិកធម៌ គឺហេតុផលពិតត្រូវជានិច្ច គ្រប់កាលសម័យ អ្នកបានសិក្សា បាន ស្ដាប់ហើយប្រតិបត្តិតាម លះបង់ផ្នែកអកុសល អនុវត្តតាមផ្នែកកុសល ព្រះធម៌ហ្នឹងឯង នឹងជួយគំពារ អ្នកប្រព្រឹត្តនោះ មិនឱ្យធ្លាក់ទៅក្នុងទី អាក្រក់ ថោកទាប គឺធ្វើកាយវាចាចិត្ត ឱ្យល្អប្រពៃប្រសើរឡើង ។

កាលបើយ៉ាងនេះ អ្នកប្រតិបត្តិនោះនឹងឡើងទៅកាន់សេចក្ដីសុខ ចំរើន រួចចាកទុកក្នុងបច្ចុប្បន្ន មានជាប់គុកច្រវាក់ និងទុក្ខទោសផ្សេងៗ រួចចាកទុក្ខក្នុងកាលអនាគត គឺ បរលោក មាននរក ប្រេត អសុរកាយ តិរច្ឆានជាដើម គឺរួចចាកអាក្រក់ក្នុងលោកទាំងពីរ, បើមានឧបនិស្ស័យ វាសនា ចាស់ក្លាក៏អាចបានសំរេចនូវគុណ គឺឈានសមាបត្តិ មគ្គផលណា មួយជាមិនខាន បានសេចក្ដីសុខយ៉ាងប្រសើរ, ព្រះធម៌រមែងទ្រទ្រង់ យឺត

យោង ជ្រោងស្ទួយ អ្នកប្រតិបត្តិមិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់ មានតែឱ្យទៅកាន់ទីល្អប្រសើរយ៉ាងហ្នឹងឯង ។

ព្រះធម៌មានគុណត្រង់រក្សាសត្វ អ្នកប្រតិបត្តិមិនឱ្យធ្លាក់ទៅកាន់ទីថោកទាប ឱ្យផុតចាកសំសារទុក្ខ ជាសភាវៈ សំរាប់បំភ្លឺសត្វ ដែលមានសេចក្តីល្ងិតល្ងង់ខ្លៅ កំពុងងឹតដោយមោហៈ ឱ្យភ្លឺស្វាងឡើងបានឱ្យស្គាល់គុណទោស ខុសត្រូវ និងផ្លូវប្រតិបត្តិជាដំណើរទៅកាន់ស្ថានសួគ៌ ស្ថានព្រះនិព្វានបាន ជាគ្រឿងបំភ្លឺសត្វឱ្យស្វែងរកសេចក្តីសុខឃើញហេតុនោះបានជាលោក ប្រៀបព្រះធម៌ដូចជាប្រទីបសំរាប់បំភ្លឺសត្វក្នុងលោក ឬ ដូចជាព្រះអាទិត្យ សំរាប់បន្ទោរបង់នូវងងឹត កាលបើងងឹតខ្ចាត់ចេញហើយ សត្វលោករមែងយល់ផ្លូវល្អ ដែលសំរាប់សញ្ចរទៅកាន់ស្ថានដ៏ក្សេម, ព្រះធម៌មានគុណអាចឃើតយោង ឬ ស្រោចស្រង់សត្វឱ្យបានសេចក្តីសុខចំរើនរាល់ទិវារាត្រី កាលសេចក្តីល្អ សេចក្តីប្រពៃ ជាសភាពសែលសត្វគួរប្រព្រឹត្ត ដោយត្រៃទ្វារហៅថា **ធម៌** ។

## ព្រះធម៌មាន ៣ យ៉ាងគឺះ

ព្រះបរិយត្តិធម៌ ១ ព្រះនព្វលោកុត្តរធម៌១ ។ ធម៌សំរាប់ទន្ទេញស្វាធ្យាយហៅថាបរិយត្តិធម៌ បានដល់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់សំដែងពិរោះដោយបទដើម បទកណ្តាល និងបទចុង, ព្រះភគវាជាម្ចាស់ សូម្បីទ្រង់សំដែងតែ គាថា មួយក៏គង់មានពី

ពោះគ្រប់ទាំង ៣ បទ គឺបទដើមពីរោះដោយបឋមបាទ បទកណ្តាលពីរោះដោយទុតិយបាទ និង តតិយបាទ បទចុងពិរោះដោយបច្ឆិមបាទ ។ ព្រះនព្វលោកុត្តរធម៌ បានដល់មគ្គ ៤ ផល ៤ និព្វាន ១ ។ លោកុត្តរធម៌ បានដល់ធម៌ឆ្លងផុតចាកលោក មានបទវិគ្គហៈថា :

**លោកំ ឧត្តរន្តីតិ ≈ លោកុត្តរា** ធម៌ស្រង់ឡើងនូវសត្វលោក
**លោកា ឧត្តរន្តីតិ ≈លោកុត្តរា** ធម៌ស្ទួយឡើងនូវសត្វឆ្លងចាកលោក
**លោកេ អតិរេកាតិ ≈លោកុត្តរា** ធម៌ប្រសើរឯក ក្នុងលោកហៅថា លោកុត្តរធម៌ ។

លោកុត្តរធម៌ បានដល់សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រីយ៍៥ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋអង្គិកមគ្គ៨ អរិយមគ្គ៤ សាមញ្ញផល ៤ និព្វាន ១ ។

ព្រះសទ្ធម្មឯណាជាធម៌ ប្រកបដោយអង្គប្រាំបីប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នា នូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តមជាគុណញ៉ាំងសត្វឱ្យចេញចាកសំសារទុក្ខ ។

ព្រះធម៌បើពោលដោយគូ ផ្នែកកុសល និងអកុសល ចាត់ជាគូៗ មានដូចតទៅនេះ :

Websites: WatKhemaraRatanaram.org or WatKhmers.org

| | |
|---|---|
| **១‿បមានធម៌** | សេចក្ដីធ្វេសប្រហែសស្មារតី |
| **២‿អប្បមានធម៌** | សេចក្ដីប្រយ័ត្នស្មារតី ។ |
| **១‿លោកិយធម៌** | ធម៌របស់បុថុជ្ជន |
| **២‿លោកុត្តរធម៌** | ធម៌របស់ព្រះអរហន្ត ។ |
| **១‿កុសលធម៌** | ធម៌ជាកុសល |
| **២‿អកុសលធម៌** | ធម៌ជាអកុសល ។ |
| **១‿កល្យាណធម៌** | ធម៌ល្អ |
| **២‿បាបធម៌** | ធម៌អាក្រក់ ។ |
| **១‿សង្ខតធម៌** | ធម៌មានបច្ច័យតាក់តែង |
| **២‿អសង្ខតធម៌** | ធម៌គ្មានបច្ច័យតាក់តែង ។ |
| **១‿រូបធម៌** | សភាវមានរូប |
| **២‿អរូបធម៌** | សភាវគ្មានរូប ។ |
| **១‿សុចរិតធម៌** | ការប្រព្រឹត្តល្អ |
| **២‿ទុចរិតធម៌** | ការប្រព្រឹត្តអាក្រក់ ។ |
| **១‿សុក្កធម៌** | ធម៌ស |
| **២‿កណ្ហធម៌** | ធម៌ខ្មៅ ។ |
| **១‿ធម៌** | បានដល់សុចរិត |
| **២‿អធម៌** | បានដល់ទុច្ចរិត ។ |

Websites: WatKhemaraRatanaram.org or WatKhmers.org

| | |
|---|---|
| **១-កុសលធម៌** | ធម៌ដែលញ៉ាប់ញ៉ូវ |
| **២-អកុសលធម៌** | ធម៌ដែលមិនញ៉ាប់ញ៉ូវ ។ |
| **១-មនុស្សធម៌** | ធម៌របស់មនុស្ស |
| **២-អមនុស្សធម៌** | ធម៌របស់អមនុស្ស ។ |
| **១-ភាវេតព្វធម៌** | ធម៌ល្អគួរចំរើន |
| **២-បហានធម៌** | ធម៌អាក្រក់គួរលះបង់ ។ |
| **១-សប្បុរិសធម៌** | ធម៌របស់សប្បុរស |
| **២-អសប្បុរិសធម៌** | ធម៌របស់អសប្បុរស ។ |

ព្រះធម៌ចែកចេញជា ៣ យ៉ាងគឺ បរិយត្តិធម៌ ១, បដិបត្តិធម៌១ បដិវេធធម៌ ១ ។

ព្រះវាចាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនា ប្រៀនប្រដៅវេនេយ្យសត្វ ឬ បន្លឺជាឧទាន និង តែងតាំងជាសិក្ខាបទ ពុទ្ធអាជ្ញាដែលមានមកក្នុងព្រះត្រៃបិដកទាំងមូល ជាធម៌សំរាប់កុលបុត្រពុទ្ធសាសនិករៀនសូត្រអោយចេះដឹង ហៅថាបរិយត្តិធម៌, បរិយត្តិធម៌នេះឯង សំដែងសេចក្តីប្រតិបត្តិគឺ សីល សមាធិ បញ្ញា សីលសមាធិបញ្ញានោះហើយដែលអាចបានសំរេចអរិយមគ្គ អរិយផល ព្រះនិព្វានហ្នឹងឯង ជាបដិ-វេធធម៌ ។

ពុទ្ធសាសនិកជនទាំងឡាយ! បុរសស្ត្រីណា មិនមានធម៌ប្រចាំក្នុងខន្ធសន្តានទេ, បុរសស្ត្រីនោះ លុះលះលោកនេះទៅរមែងជួងប្រទះនឹងសេចក្តីទុក្ខ សមដូចពុទ្ធភាសិតដែលមានមកក្នុងគម្ពីរខុទ្ទកនិកាយជាតកបញ្ចនិបាត ព្រះអង្គសំដែងថា :

**ខត្តិយោ ច អធម្មដ្ឋោ វេស្សោ ចាធម្ម និស្សិតោ, តេ បរិច្ចជ្ជុភោ លោកេ, ឧបបជ្ជន្តិ ទុគ្គតឹ ។**

ក្សត្រមិនតាំងនៅក្នុងធម៌ក្តី វេស្ស មិនអាស្រ័យនូវធម៌ក្តី ជនទាំងពីរនោះលុះលះលោកនេះទៅហើយ រមែងចូលទៅដល់ទុគ្គតិ ។

ពុទ្ធភាសិតមួយកន្លែងទៀតថា :

**យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ, ឯតទរិយា សេវន្តិ ឯតំលោកេ អនាមតំ ។**

សច្ច១ ធម្ម១ អហឹសា១ សញ្ញម១ ទម១ មាននៅក្នុងបុគ្គលណា ព្រះអរិយទាំងឡាយ តែងសេពនូវបុគ្គលនោះ ធម៌ទាំង៥ នោះហៅថា អនាមតធម៌មិនស្លាប់ក្នុងលោក ។

បុគ្គលណាស្រឡាញ់ព្រះធម៌ ប្រតិបត្តិធម៌ ព្រះធម៌តែងនាំសេចក្តីសុខមកប្រគល់ឱ្យ សមដូចពុទ្ធភាសិតថា :

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**

**ឯសានិសំសោ ធម្មេ សុចិណ្ណេ**
**ន ទុគ្គតឹ គច្ឆតិ ធម្មចារី**

ព្រះធម៌ហ្នឹងឯង តែងរក្សានូវអ្នកប្រព្រឹត្តធម៌ ព្រះធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំមកនូវសេចក្តីសុខ នេះអានិសង្សរបស់ធម៌ អ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិឡើយ ។

ព្រហ្មចារី បុគ្គលអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ សុធីរជន អ្នកស្រឡាញ់ធម៌ សូម្បីមានទុក្ខលំបាកក្នុងកាយ ឬ មានគ្រោះថ្នាក់ដល់ជីវិតក៏ដោយ លោកមិនព្រមលះបង់ព្រះធម៌ឡើយ សមដូចពុទ្ធភាសិតក្នុងលោកនីតិប្បករណ៍ថា :

**សុក្ខោតិ ចន្ទចតរុ នជហាតិ គន្ធំ**
**នាគោ គតោ រណមុខេ ន ជហាតិ លីឡំ**
**យន្តេ គតោ រណមុខេ ន ជហាតិ ឧច្ឆុ**
**ទុក្ខោតិ បណ្ឌិតជនោ ន ជហាតិ ធម្មំ ។**

ជាតិខ្លឹមចន្ទន៍ទោះស្ងិតក្រៀមក្រញង់ មិនលះបង់ក្លិនក្លែបសុគន្ធា ដំរីសាទោះចូលសឹកយុទ្ធនាមិនលះបង់លីលាល្អងក្រោយ, ជាតិអំពៅទោះនៅក្នុងយន្តឃ្នាប មិនលះបង់សភាពរសផ្អែមសាយ, ជាតិបណ្ឌិត ទោះមានទុក្ខក្នុងកាយ មិនជិនណាយលះបង់ព្រះធម៌ថ្លៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បុគ្គលអ្នកប្រព្រឹត្តតាមព្រះធម៌ រមែងបានទទួលនូវសេចក្ដីសុខចំរើន ក្នុងលោកទាំងពីរ គឺក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូចជាធម្មិកឧបាសក អ្នកស្រឡាញ់ធម៌ អ្នកប្រព្រឹត្តធម៌ អ្នកគោរពធម៌ សូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

សេចក្ដីដំណាលថា : ធម្មិកឧបាសកនោះ ជាអ្នកបរិបូណ៌ដោយកល្យាណធម៌ ច្រើនយ៉ាង វេលាមានជម្ងឺទ្បើប នឹងអស់សង្ខារ បានឱ្យកូនទៅអារាធនា ភិក្ខុទាំងឡាយមកសូត្រសតិបដ្ឋានសូត្រ, កំពុងតែស្ដាប់ធម៌ បានឃើញទេវតាក្នុងឆកាមាសួគ៌ទាំង ៦ ជាន់ យកទេវរថ ៦ មកអញ្ជើញឱ្យទៅកើតក្នុងពិភពរបស់ខ្លួនៗ ។

លុះច្យុតអំពីមនុស្សលោកនេះទៅបាន ទៅកើតក្នុងឋានតុសិតសួគ៌ សោយទិព្វសម្បត្តិជាសុខ ក្សេមក្សាន្ត ។

បុរសបុគ្គល បានសិក្សានូវព្រះធម៌អំពីគ្រូណា គឺជាធម៌ដែលព្រះ-សម្ពុទ្ធ សំដែងល្អប្រពៃហើយ គប្បីគោរពបូជា ដល់គ្រូនោះ សេចក្ដីនេះសមដូចពុទ្ធភាសិតសំដែងថា :

**យម្ហា ធម្មំ វិជានេយ្យ, សម្មាសម្ពុទ្ធ ទេសិ**
**តំ, សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ**
**ព្រាហ្មណោ ។**

បុគ្គលចេះធម៌ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ អំពីគ្រូណាគប្បីនមស្ការគ្រូនោះគោរព ដូចជាព្រាហ្មណ៍ គោរពបូជាភ្លើងដូច្នោះដែរ ។

ព្រះពុទ្ធដីកានេះ ជាដំបូន្មានរំលឹកឱ្យនឹកគុណ និងធ្វើនមស្ការចំពោះគ្រូអាចារ្យ ដែលខ្លួនបានសិក្សា ចេះធម៌អាថ៌ សិក្ខា វិន័យអំពីលោក។ បុគ្គលណាម្នាក់ ទោះជាភិក្ខុក្តី សាមណេរក្តី ឧបាសកក្តី ឧបាសិកាក្តី ដែលបានទទួលការសិក្សា ចេះដឹងនូវធម៌អាថ៌ សិក្ខាវិន័យ ព្រះត្រៃបិដក ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសត្រាស់សំដែងហើយ អំពីគ្រូអាចារ្យណាក៏ដោយទោះគ្រហស្ថក្តី បព្វជិតក្តី គប្បីរំលឹកនឹកគុណធ្វើសេចក្តីគោរពនមស្សការ ធ្វើសក្ការបូជា ចំពោះគ្រូបាអាចារ្យនោះ ដោយស្មោះអស់ពីពោះព្រោះលោកជាអ្នកមានគុណូបការដ៏ខ្ពង់ខ្ពស់បានយកធម៌ស្ងប់ ធម៌ចំរើនកើនសុខសន្តិភាព ដែលព្រះសម្ពុទ្ធជាកំពូលអ្នកប្រាជ្ញ បានសិក្សាពិសោធន៍ត្រាស់ដឹងសេចក្តីពិត ត្រាស់សំដែងទុកមក ។ ការនមស្សការដោយគោរពចំពោះគ្រូនោះជាករណីយកិច្ច ដែលខ្លួនជាសិស្ស ត្រូវបំពេញផង ជាបុណ្យកុសលផង ជាគំរូល្អចំពោះអនុជនផង ។ ដូច្នេះត្រូវតែនមស្ការគ្រូនោះដោយគោរពជានិច្ច ឱ្យដូចជាព្រាហ្មណ៍គោរពបូជាភ្លើង ជានិច្ចមិនដែលដាច់ដូច្នោះដែរ ។

តាមន័យទូទៅគ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រៀនប្រដៅ វិជ្ជាផ្លូវលោក ផ្លូវធម៌ក្តី ឱ្យខ្លួនបានចេះដឹង បែកប្រាជ្ញាថ្លាគំនិត អាចប្រកប

ការចិញ្ចឹមជីវិត អាចសាងកេរ្តិ៍ឈ្មោះ យសស័ក្តិ ឱ្យកើតមាន និងឱ្យស្គាល់ផ្លូវល្អ អាក្រក់ ហើយប្រព្រឹត្តខ្លួនបានត្រឹមត្រូវ ជូនដល់សុខចំរើនកើនប្រយោជន៍ ក៏ត្រូវគោរពបូជាចំពោះគ្រូនោះ មិនត្រូវបំភ្លេចគុណូបការលោកឡើយ ។

ពុទ្ធបរិស័ទទាំងឡាយ ! អ្នកដឹងគុណគ្រូក្នុងសម័យពុទ្ធកាលឃើញតែព្រះសារីបុត្រ ជាអគ្គសាវ័កស្តាំ កាលលោកនៅមិនទាន់បានបួសក្នុងសាសនា លោកបានជួបនិងអស្សជិត្ថេរ បានស្តាប់ធម៌ លោកបានសំរេចសោតាបត្តិផល ដល់ពេលលោកចូលមកបួសក្នុងសាសនាហើយ បើព្រះ-អស្សជិត្ថេរ លោកសឹងនៅទិសណា ព្រះសារីបុត្រលោកតែងបង្វិលគ្រែសឹងបែរព្រះកេសទៅរកព្រះអស្សជិត្ថេរ ជាគ្រូនោះ នេះគឺលោកគោរពគ្រូរបស់លោក ។

បទថា : **ធម្មទេស្សី បរាភវោ**

បានសេចក្តីថា អ្នកស្អប់ធម៌រមែងមានសេចក្តីវិនាស ។ ពាក្យ "ស្អប់ធម៌" សំដៅយកបុគ្គលអ្នកប្រទូស្ត ចំពោះធម៌ ដែលជាពាក្យប្រៀនប្រដៅដ៏ល្អប្រពៃរបស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ, អ្នកមិនមាន សទ្ធាមិនជឿមិនជ្រះថ្លា អបឥតប្រាជ្ញា មិនជឿចំពោះព្រះធម៌ មិនគោរពមិនបូជា មិនប្រព្រឹត្តប្រតិបត្តិ **ធម្មស្ស អវណ្ណំ ភាសិត**, ហើយព្រមទាំងពោលទោសត្មះតិះដៀលនូវព្រះធម៌ឈ្មោះថាស្អប់ធម៌ ។

បណ្ដាមនុស្សទាំងឡាយដែលរស់នៅក្នុងសន្និវាសនេះ តាមការសង្កេតពិនិត្យ ឃើញថាមានចំនួនមិនតិចទេ ដែលមានចិត្តប្រទូស្តចំពោះព្រះធម៌ព្រមទាំងប្រមាថមើលងាយចំពោះអ្នកប្រព្រឹត្តប្រតិបត្តិផងទៀត ។

ការប្រមាថមើលងាយយ៉ាងនេះ ដោយគេមានឆន្ទជាទុទដ្ឋិនិយមចំពោះព្រះធម៌ ។

ជនប្រភេទខ្លះបាននិយាយថា ព្រះធម៌ធ្វើមនុស្សឱ្យខ្ជិលច្រអូសធ្វើមនុស្សឱ្យក្ររហេមរហាម រហូតដល់ថ្នាក់ដើរ សុំទានគេ ដេកតាមសំយាបផ្ទះ រហូតដល់ធ្វើប្រទេសជាតិឱ្យអាប់ឱន មានឱនភាព, ខ្លះទៀតនិយាយថា ព្រះធម៌គ្រាន់តែជាពាក្យសម្ដីបោកប្រាស់របស់ជនមួយចំនួនដែលមានសំនួនវោហារ ដើម្បីលាភសក្ការៈ ហើយរស់នៅដោយក្រុមបោកប្រាស់គេប៉ុណ្ណោះ ។

ជនខ្លះទៀតមិនត្រឹមតែពោលពាក្យ តិះដៀលដាក់កំហុសចំពោះព្រះធម៌ប៉ុណ្ណោះទេ ថែមទាំងពោលទោសទៅរកព្រះពុទ្ធថា ប្រដៅមនុស្សឱ្យខ្ជិលច្រអូសទ្រមក់លក់ លក់ មិនស្មុះស្មារ ក្នុងការងារសព្វសារពើ ។

អ្នកដែលមានទុទិដ្ឋិនិយម ឬលោកនិយម គេនិយាយអួតលើកជើងតែខាងវិទ្យាសាស្ត្រ បច្ចុប្បន្ន, គេពោលថាវិទ្យាសាស្ត្រគេសព្វថ្ងៃឯណោះវិញទេ ដែលធ្វើឱ្យមនុស្សបំពេញការងារសស្រាក់សស្រាំ លោតផ្លោះ

អស្ចារ្យ រុងរឿង បានផលប្រយោជន៍ឃើញច្បាស់នឹង មំសចក្ខុ ហើយ រឹតតែចំរើនលូតលាស់ឥតឈប់ឈរជាភិយ្យោភាព ។

នៅក្នុងយុគៈសម័យមួយនោះ ជាសម័យអន្ធការខ្លៅងងឹត គេបាន នាំគ្នាពោលថា ព្រះធមិដែលមនុស្សលោកកាន់តាមនេះ មានការបោក ប្រាស់ សង្កត់សង្កិនជិះជាន់ឈ្លេចឈ្លីញាំញី បុកបែររឹបជាន់មកលើប្រជាជន ជាងពីរពាន់ឆ្នាំមកហើយ ហេតុដូច្នោះយើងត្រូវកំទេច កុំឱ្យសេសសល់ ។

ទ្រឹស្តីរបស់អ្នកប្រាជ្ញខ្លះ គេប្រាប់ដល់បរិស័ទគេថា "សាសនាជា គ្រឿងញៀនអ្នកកាន់តាមជាឈ្លើង ឬ ជាសត្វដង្កូវ " ។ ការយល់ឃើញ របស់ជនជំពូកនេះ ផ្ទែកខាងមតិព្រះពុទ្ធសាសនា លោកចាត់ទុកថា ការយល់ឃើញដោយមហន្ធការ ចាត់ទុកជាមោឃទាំងអស់ ។

អ្នកស្អប់ធមិរមែងមានសេចក្តីវិនាស ក្នុងលោកនេះផង និង លោកខាងមុខផង ឧទាហរណ៍ដូចជាមនុស្សពួកខ្លះ ដែលបានកើតទាន់ព្រះ-សម្មាសម្ពុទ្ធ ហើយដែលទ្រង់គង់ជាធរមាននៅឡើយ តែជាមនុស្សគ្មាន ឧបនិស្ស័យព្រោះតែស្អប់ធមិហ្នឹងឯង បានជាត្រូវទទួលទុក្ខលំបាកជាពន្លឹក ដូចជាភិក្ខុទេវទត្តក្តី នាងចិញ្ចាមាណវិកាក្តី នាងមាគន្ទិយាក្តី សុទ្ធតែត្រូវ ទទួលទុក្ខជាទម្ងន់ ។

សាធុសប្បុរសទាំងឡាយ! បុរសស្ត្រីអ្នកស្អប់ធមិ រមែងជួបប្រទះ សេចក្តីទុក្ខលំបាកច្រើនប្រការណាស់, សមដូចពុទ្ធភាសិតសំដែងថា :

**យស្មា ច ហោតិ ធាបិច្ចោ , អហិរិកោ អនាទរោ, តតោ ធាបំ បសវតិ, អបាយំ តេន គច្ឆតិ ៕** អ្នកណាមានប្រាជ្ញាលាមកមិនអៀនខ្មាស មិនអើពើ (ក្នុងធម៌) ព្រោះហេតុនោះតែងដល់អបាយក៏ព្រោះហេតុនោះដែរ ។

ជនណាមានប្រាជ្ញាលាមក គឺអ្នកណាដែលឆ្លាតវាងវៃតែខាងផ្លូវខិលខូច ផ្លូវបាប អកុសល មានកលកិច្ចល្បិច ឧបាយអាក្រក់ ប្រចាំចិត្តគិតឃើញតែខាងផ្លូវបោកប្រាស ឈ្លោះប្រវ៉ែញ ផ្ទាញ់ផ្ទាល់ អ្នកដទៃ ប៉ុចប្រសប់តែខាងយកទុក្ខភ័យចង្រៃឧបទ្រព្យវិបត្តិ អន្តរាយ មកសាបព្រោះចំពោះជនដទៃ ។

ជនមានប្រាជ្ញាអាក្រក់នោះ មិនចេះខ្មាសអៀនន្ទូវអំពើបាប មិនខ្មាសន្ទូវអ្នកដទៃឡើយ ហើយមិនរវល់អើពើក្នុងធម៌ គឺបាបបុណ្យ គុណទោស សុចរិត ទុច្ចរិត យុត្តិធម៌ អយុត្តិធម៌ ធ្វើអ្វីតាមទំនើងចិត្តស្ថិតនៅក្នុងប្រាជ្ញាអាក្រក់របស់ខ្លួន ព្រោះហេតុណាក៏ដោយ ជននោះតែងប្រសប់បាប គឺតែងជួបប្រទះអំពើអាក្រក់ ថោកទាប បាបធម៌ និងជួបផលអាក្រក់ ព្រោះហេតុនោះ ផលនោះតែងដល់អបាយ គឺជួបសេចក្តីទុក្ខវិនាស អន្តរាយ ជាផលផ្តល់មកវិញ ក៏ព្រោះហេតុតែខ្លួនធ្វើអាក្រក់នោះដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុទ្ធមាមិកជនទាំងឡាយ ! ការសំដែងមកក្នុងគាថាទី ១ នៃបរាភវសូត្រ ដែលមានសេចក្ដីថា អ្នកដែលចំរើនតថាគតដឹងងាយ អ្នកដែលអន្តរាយតថាគតដឹងពិត អ្នកប្រាថ្នាធម៌ល្អិតល្អន់ក្នុងចិត្តហើយខំប្រព្រឹត្ត នឹងបានចំរើន អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន ឥតកើនចំរើនវិនាសទៅមុខ ។

ការសំដែងមកនេះ ក៏សន្មត់ថា ចប់តែប៉ុណ្ណោះ ឯវិ

Websites: WatKhemaraRatanaram.org or WatKhmers.org

# "ធម្មទេសនាបរាភវសុត្រ"

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
## នមត្ថុ រតនត្តយស្ស វន្ទាមិ

ព្រះករុណា សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្ដីគោរព ។

លំដាប់បន្ទាប់អំពីបទនមស្ការ ដោយសង្ខេបនេះទៅ ខ្ញុំព្រះករុណា អាត្មាភាព សូមលើកយកបរាភវសូត្រមកសំដែង ចែកជូនដល់លោកតា លោកយាយព្រឹទ្ធាចារ្យ ពុទ្ធបរិស័ទទាំងអស់ ដែលបានអញ្ជើញមកជួបជុំ ក្នុងទីនេះដើម្បី ជាគ្រឿងភ្ញាក់កំណើត កើតគំនិត និងជាគ្រឿងប្រដាប់ សតិបញ្ញាស្មារតីដោយសង្ខិតន័យសង្ខេបខ្លី ដូចសេចក្ដីតទៅនេះ ។

បន្ទាប់ពីនេះទៅសូមលើកយកគាថាទី២ នៃបរាភវសូត្រមកសំដែង

ទេវតាទូលសួរតទៅទៀតថា :

**ឥតិហេតំ វិជានាម បឋមោ សោ បរាភវោ ទុតិយំ ភគវា ព្រូហិ កឹ បរាភតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្ដី វិនាសនោះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១ ទាន់ហន់ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែង ឱ្យទាន វិនាសទី ២ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្ដីវិនាស ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ អសតំ ធម្មំរោចេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា តែនឹងមនុស្សណាអសប្បុរស តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ និងអ្នកសប្បុរសមកធ្វើជាមិត្ត សេចក្តីស្រលាញ់ពេញចិត្ត គំនិត ហើយទៅគប់មិត្តអសប្បុរស គាប់ចិត្តក្នុងធម៌ ឬ មួយរបស់ហេតុនោះទាំងអស់នាំឱ្យវិនាស ។

## **អធិប្បាយ**

## **គាថាទី២**

ពាក្យថា "**សប្បុរស**" គឺមនុស្សប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត មានអាជ្ញាដាក់ចុះ ហើយចំពោះសត្វទាំងឡាយ, មនុស្សមានសន្តានចិត្តដ៏ល្អ ស្គាល់បាបបុណ្យគុណទោស អាក្រក់ល្អ ស ខ្មៅ ប្រយោជន៍ និង មិនជាប្រយោជន៍ ។

សប្បុរសនេះ ជាបុរសក៏មាន ស្ត្រីក៏មាន គ្រហស្ថក៏មាន បព្វជិតក៏មាន ក្មេងក៏មាន ចាស់ក៏មាន សក៏មាន ខ្មៅក៏មាន គឺគ្រប់ភេទគ្រប់វ័យទាំងអស់ អោយតែមានគុណធម៌ប្រចាំនៅក្នុងខន្ធសន្តាន ឈ្មោះថាសប្បុរសទាំងអស់, ម្យ៉ាងទៀតព្រះពុទ្ធទ្រង់សំដែងថា :

**យោវេ កតញ្ញូ កតវេទី ធីរោ**

**កល្យាណមិត្តោ ឡារត្ថី ច ហោតិ ។**
**ទុក្ខិ តស្ស សក្កច្ច ករោតិ កិច្ចំ**
**តថាវិធំ សប្បុរិសំ វទន្តិ ។**

អ្នកណាមានប្រាជ្ញា ជាមនុស្សកត្តញ្ញូកតវេទី ទី ១ មានកល្យាណមិត្តជិតស្និទ្ធស្នាល ១ ជួយធ្វើកិច្ចរបស់មិត្រ ដែលដល់នូវសេចក្តីលំបាក ដោយយកចិត្តទុកដាក់១ លោកហៅអ្នកមានប្រាជ្ញានោះថា ជាសប្បុរស ។

អ្នកណាមានប្រាជ្ញា គឺមានប្រាជ្ញាការឈ្លាសវៃ យល់ស្គាល់ន័យហេតុផលសុខទុក្ខចំរើនវិនាស ជ្រៅជ្រះ ល្អិតល្អន់ ជននោះរមែងស្ថិតនៅក្នុងគុណសម្បត្តិជាច្រើននៃមនុស្សជាតិ មិនឃ្លាតចាកមនុស្សធម៌ គុណធម៌ដែលបណ្ឌិតទាំងឡាយតែងសរសើរ ក្នុងទីនេះ លោកពោលទុក ៣ យ៉ាងគឺ:

១-ជាមនុស្សកត្តញ្ញូកតវេទី គឺជាអ្នកដឹងនូវឧបការគុណ ដែលជនដទៃធ្វើចំពោះខ្លួន មិនបំភ្លេចគុណបំណាច់នោះ ពោលសរសើររំលឹកគុណរឿយៗ ព្រមទាំងធ្វើការតបស្នងសងគុណវិញ ។ នេះជាគុណសម្បត្តិមួយដែលអ្នកមានប្រាជ្ញា ប្រើប្រចាំចិត្ត ប្រព្រឹត្តសំរាប់ជីវិត ដែលជាលក្ខណៈមួយនៃមនុស្សល្អ ព្រោះបុព្វការីបានធ្វើគុណប្រយោជន៍ឱ្យដល់ខ្លួនហើយ ត្រូវតែរំលឹកនឹកគុណតបគុណវិញ ទើបពេញជាមនុស្សល្អ តែការធ្វើខ្លួនទៅជាកត្តញ្ញូកតវេទី ក៏ព្រោះជាអ្នកមានប្រាជ្ញានោះឯង ដែលផ្ទុយពីមនុស្សពាលចូលចិត្តប្រព្រឹត្តខ្លួនជាមនុស្សអកតញ្ញូ អកតវេទី ។

២-មានកល្យាណមិត្តជិតស្និទ្ធគ្នា គឺអ្នកមានប្រីជារមែងស្គាល់យល់ដឹងថាមនុស្សណា ជាមនុស្សអាក្រក់ មនុស្សណាជាមនុស្សល្អ ជាមិត្តជិតស្និទ្ធគ្នា ព្រោះកល្យាណមិត្ត ជាអ្នកស្ថិតនៅក្នុងសុចរិត យុត្តិធម៌ សច្ចរមែងជាគួរពិភាក្សា ក្នុងកិច្ចការទាំងពួង រួមសុខ រួមទុក្ខផង នាំឱ្យសាងនូវប្រយោជន៍សេចក្តីសុខចំរើនផង នាំឱ្យឃ្លាតចាកអបាយមុខ អកុសលធម៌ផ្សេងៗ ដូច្នេះអ្នកមានប្រីជា ទើបចេះរើសតែកល្យាណមិត្ត សំរាប់សេពគប់រាប់រកយកជាគ្នាជិតស្និទ្ធ ដ្បិតកល្យាណមិត្ត មិនដែលអោយទោសទុក្ខឡើយ ។

៣-ជួយធ្វើការរបស់មិត្តដែលដល់នូវសេចក្តីលំបាក ដោយយកចិត្តទុកដាក់នេះជាគុណសម្បត្តិមួយទៀត នៃអ្នកមានប្រីជាគប្បីប្រព្រឹត្ត ព្រោះកាលបើមិត្តមានកិច្ចធុរៈ ជួបវិបត្តិពិបាកហើយត្រូវតែជួយរកនូវមធ្យោ-បាយដោះស្រាយឱ្យធូរស្រាល ឱ្យរួចសេចក្តីលំបាក ទើបឱ្យរក្សាមិត្តភាពនឹងការជួយតបវិញ ពីកល្យាណមិត្តរបស់ខ្លួន ផ្ទុយទៅវិញ មនុស្សពាល ឬបាបមិត្ត ដែលមិនចេះជួយឈឺឆ្អាលក្នុងកិច្ចការសេចក្តីលំបាករបស់មិត្ត ក្នុងបេលវិបត្តទេ មិត្តភាពក៏ត្រូវរលំរលាយពាយរលត់បាត់បង់ ។

កាលបើអ្នកណាមានប្រីជាស្ថិតនៅក្នុងគុណសម្បត្តិ ៣ យ៉ាង ដូចពោលមកនេះហើយលោកហៅ អ្នកមានប្រីជានោះថា ជាអ្នកសប្បុរស

ដែលសំដៅសេចក្តីថា មនុស្សល្អ មនុស្សស្ងប់ចាកសេចក្តីអាក្រក់ មនុស្សស្គាល់ប្រយោជន៍ពិតប្រាកដ ។

សប្បុរសលោកមានលក្ខណៈ ៣ យ៉ាង ជាគ្រឿងសំគាល់ :

**១~សុកជកម្មការី** បើនឹងពោលអ្វី ធ្វើតែអំពើល្អ ( សំដៅយកកាយសុចរិត ) ។

**២~សុភាសិតភាសី** បើនឹងពោលអ្វី ពោលតែវាចាល្អ ( សំដៅយកវចីសុចរិត ) ។

**៣~សុចិន្តិតចិន្តី** បើនឹងគិតអ្វី គិតតែខាងអំពើល្អ ( សំដៅយកមនោសុចរិត ) ។

សប្បុរសលោកមានគុណធម៌ ៣ យ៉ាង ប្រចាំនៅក្នុងខន្ធសន្តានគឺៈ

**១~ ទាន** ការឱ្យ, ចែករំលែក

**២~បព្វជ្ជា** កាន់ភេទបួស (វៀរចាកកាម)

**៣~មាតាបិតុបដ្ឋាន** ទំនុកបំរុងមាតាបិតា ។

សប្បុរសលោកមានសទ្ធា មានទ្រព្យសម្បត្តិ លោកមិនដែលកំ-ណាញ់ស្វិតស្វាញ ត្បិតត្បៀត លាក់លៀមទេ លោកតែងចំណាយទ្រព្យសម្បត្តិធ្វើជាទានបំពេញបុណ្យកុសល គឺឱ្យដល់ស្មូមយាចក អ្នកកំសត់ទុរគត សមណជី ព្រាហ្មណ៍ អ្នកស្ទឹងស្ទាធិខំប្រព្រឹត្តតបៈធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

លោកតែងលះបង់កាមបលិពោធ វៀរចាកកាមពីព្រោះឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងការចេញចាកកាម ។ លោកតែងចិញ្ចឹមបីបាច់ថែរក្សាទំនុកបំរុងផ្គងផ្គើមលោកអ្នកមានគុណគឺ មាតាបិតាមិនដែលធ្វេសប្រហែសឡើយ ។ ពីព្រោះលោកយល់ច្បាស់អំពីអានិសង្សកតញ្ញូកតវេទី ដោយពិតប្រាដ ។

សប្បុរសលោកស្ថិតនៅក្នុងប្រយោជន៍ ៣ យ៉ាងគឺ :

**១-ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍បច្ចុប្បន្ន ឬប្រយោជន៍ទាន់ភ្នែក ។

**២-សម្បរាយិកត្ថ** ប្រយោជន៍បរលោក ប្រយោជន៍ជូនទៅខាងមុខ។

**៣-បរមត្ថៈ** ប្រយោជន៍យ៉ាងបរមគឺព្រះនិព្វានប្រយោជន៍ប្រសើរបំផុត។

ពាក្យថា "ប្រយោជន៍" ដែលលោកបញ្ញត្តិ ប្រើក្នុងភាសាខ្មែរនេះជាពាក្យចេញមកពីភាសាបាលីថា **"បយោជនៈ"** ភាសាសំស្ក្រឹតថា "បយោជន៍" សំគាល់សេចក្តីថា "ផល ឬ កំរៃ " ដែលសមប្រកប ឬផលដែលគួរប្រាថ្នា " ។ ពាក្យនេះក្នុងភាសាបាលីហៅផ្លាស់ប្តូរគ្នាច្រើនស័ព្ទជួនកាលហៅថា " អត្ថ " ប្រែថា "ផល" ឬថា "សេចក្តីចំរើន" ដូចក្នុងពាក្យថា **ទិដ្ឋធម្មិកត្ថ សម្បរាយិកត្ថ បរមត្ថ**, ជួនកាលហៅថា **"ហិតៈ"** ប្រែថាប្រយោជន៍ ឬ ថាគុណ ដូចក្នុងពាក្យថា ទិដ្ឋធម្មិកហិតៈ សម្បរាយិកហិតៈ បរមហិត, ជួនកាលហៅថា "សុ" ប្រែថា "សុខ" ដូចក្នុងពាក្យថា ទិដ្ឋធម្មិកសុខៈ សម្បរាយិកសុខ បរមសុខ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

រួមសេចក្តីទៅថា "ផលប្រយោជន៍ សេចក្តីសុខ សេចក្តីចំរើន ដែលប្រព្រឹត្តទៅក្នុងលោកនេះ " ។ ពាក្យថា អត្ថ ហិតៈ សុខ ទាំងអស់នេះគ្រាន់តែផ្សេងគ្នាដោយតួអក្សរ តែសំគាល់សេចក្តីជាមួយគ្នា សំដៅត្រង់ផលប្រយោជន៍ដែលឱ្យសំរេចសេចក្តីសុខកាយ សុខចិត្ត សមប្រកបដោយសេចក្តីប្រាថ្នាដូចគ្នា ។

ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ទាន់ភ្នែក ធមិដែលជាហេតុអោយសំរេចប្រយោជន៍ទាន់ភ្នែក មាន ៤ យ៉ាងគឺៈ

**១-ឧដ្ឋានសម្បទា** ការបរិបូណ៌ដោយព្យាយាម

**២-អារក្ខសម្បទា** ការបរិបូណ៌ដោយការរក្សា

**៣-កល្យាណមិត្តតា** ការគប់មិត្តសម្លាញ់ល្អ

**៤សមជីវិតា** ការចិញ្ចឹមជីវិតស្មើ ។

មុននឹងអធិប្បាយអំពីសម្បទាទាំង ៤ យ៉ាងនេះ ដែលជាហេតុអោយកើតផលប្រយោជន៍សេចក្តីសុខ សេចក្តីចំរើនទាន់ភ្នែក, គួរពោលអំ-ពីទ្រព្យជាមុនសិន ។ ទ្រព្យសម្បត្តិជារបស់ដែលមនុស្សក្នុងលោកទាំងមូលតែងចង់បានក្រៃពេក ព្រោះជាវត្ថុអោយសំរេចសេចក្តីសុខកាយ សុខចិត្តច្រើនយ៉ាង ។

មនុស្សអ្នកមានទ្រព្យស្តុកស្តម្ភ រមែងមានសេចក្តីរីករាយច្រើនដោយនឹងសង្ឃឹមថា ៖ ទ្រព្យសម្បត្តិរបស់ខ្លួនមាន នឹងចង់បរិភោគ ចាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយកាលណា ក៏បានទាន់ចិត្តកាលនោះ, លុះចាយចិញ្ចឹមខ្លួនប្រពន្ធកូន នឹងដែលគួរទំនុកបំរុងទៅហើយក៏រមែង បានសេចក្តីសុខកាយ សប្បាយចិត្តជាងអ្នកក្រ ។ ព្រោះហេតុនោះបានជាអ្នកមានទ្រព្យសម្បត្តិនេះ ជារបស់គឺបុគ្គលគប្បីប្រាថ្នាក្នុងខាងដើម ។ កាលបើមានទ្រព្យសម្បត្តិដែលជាប្រយោជន៍បច្ចុប្បន្ន បរិបូណ៌ហើយ ដោយងាយស្វែងរកប្រយោជន៍ក្នុងបរលោក និង ប្រយោជន៍ក្នុងព្រះនិព្វានតទៅ ។

ឯទ្រព្យសម្បត្តិរបស់មនុស្ស ក្នុងលោកមានច្រើនបែបច្រើនយ៉ាងជាអនេកប្បការ មិនងាយនឹងស្គាល់ឈ្មោះសព្វគ្រប់បាន, ដែលឱ្យសំរេចសេចក្តីសុខកាយ ស្រួលចិត្តដល់បុគ្គលជាម្ចាស់ឃើញទាន់ភ្នែកក្នុងលោកនេះ នឹងតាមជូនអោយបានសេចក្តីសុខកាយស្រួលចិត្តក្នុងភពខាងមុខតទៅទៀតនោះ មានតែ ៤ ជំពូកគឺ:

**១_ថាវរនិធិ** កំណប់ទ្រព្យនៅនឹងកន្លែង

**២_ជង្គមនិធិ** កំណប់ទ្រព្យដើរបាន

**៣_អង្គសមនិធិ** កំណប់ទ្រព្យនៅក្នុងខ្លួន

**៤_អនុគាមិកនិធិ** កំណប់ជាប់តាមខ្លួនទៅ ។

ប្រាក់ មាស ស្រែចំការ ច្បារដំណាំ ឬ ទ្រព្យណាៗ ដែលជាពួកទ្រព្យឥតវិញ្ញាណ កំរើកឯងៗមិនបាន ហៅថាកំណប់ទ្រព្យនៅនឹងកន្លែង ខ្ញុំកំដរ ឬមនុស្សបំរើប្រុសស្រី គោក្របី ដំរីសេះ លា អូដ្ឋ រហូតដល់ទ្រព្យណាៗដែលជាពួកទ្រព្យ មានវិញ្ញាណ កំរើកឯងៗ បានហៅថា កំណប់

ទ្រព្យដើរបាន ។ ការងារសិល្បវិជ្ជា ឬចំណេះណា១ ដែលរៀនចេះចាំចំណាំទុកក្នុងចិត្តហើយ ជាហេតុឱ្យសំរេចការចិញ្ចឹមជីវិត បានហៅថា កំណប់ទ្រព្យនៅក្នុងខ្លួន ។ ទានសីលភាវនា ឬ បុណ្យកុសលណា១ ដែលជាប់តាមអោយផល ដូចស្រមោលហៅថា កំណប់ទ្រព្យជាប់តាមខ្លួនទៅ ។

កំណប់ទ្រព្យទាំង ៤ ជំពូកនេះ បើបុគ្គលស្វែងរកបានហើយ ជាផលប្រយោជន៍ឱ្យកើតសេចក្តីសុខ ក្នុងលោកនេះ និងលោកខាងមុខ ។

បានជាលោកឱ្យឈ្មោះថាកំណប់ទ្រព្យ ព្រោះជារបស់ដែលបុគ្គលត្រូវជីកគាស់រើឡើងដោយចបជំនីក គឺសេចក្តីប្រឹងប្រែងសង្វាតឱបាតយ៉ាងខ្លាំង ឱ្យដូចជាគេជីកគាស់កំណប់ ដែលកប់ក្នុងផែនដីទើបបាន, បើខ្ជិលច្រអូសមិនអាច និងគាស់យកបានឡើយ, ព្រោះហេតុនោះបានជាព្រះនាវរណញ្ញាណជាបរមគ្រូកាល នឹងទ្រង់ត្រាស់ទេសនាអំពីសម្បទាទាំង ៤ ដែលជាហេតុឱ្យបានកំណប់ទ្រព្យជាប្រយោជន៍ អោយកើតសេចក្តីសុខទាន់ភ្នែក ក្នុងលោកនេះទ្រង់លើកយកឧដ្ឋានសម្បទា ការបរិបូណ៌ដោយសេចក្តីប្រឹងប្រែង, ឡើងសំដែងជាប្រធាននៃសម្បទាទាំងពួង ។

**១~ឧដ្ឋានសម្បទា** កុលបុត្រក្នុងលោកនេះ សំរេចការចិញ្ចឹមជីវិតដោយសេចក្តីប្រឹងសង្វាត, ធ្វើការងារណានីមួយ ទោះស្រែចំការក្តី ជំនួញក្តី ការចិញ្ចឹមគោ ពាហនៈ ឬ គោទឹកដោះ រដ្ឋការខាងទាហានក្តី រដ្ឋការខាងមន្ត្រីក្តី ជាងផ្សេង១ក្តី ក៏ជាមនុស្សខ្នះខ្នែងក្នុងការងារនោះ១ មិនខ្ជិល

ច្រអូស និងប្រកបដោយសេចក្តីក្លៀវក្លាក្នុងឧបាយ ដែលគួរធ្វើគួរចាត់ចែង យ៉ាងនេះហៅថា ឧដ្ឋានសម្បទា ការបរិបូណ៌ដោយសេចក្តីប្រឹងប្រែង ។

សុភាសិតក្នុងលោកនីតិប្បករណ៍ ពោលថា : ការងារទាំងឡាយ សំរេចដោយព្យាយាម មិនមែនបានភ្លាមតាមចិត្តគិត បើដេកព្រងើយផ្សេងបុណ្យពិត ដល់ក្ស័យជីវិត ក៏ឥតសុខ, សត្វម្រឹគមានពាសពេញព្រៃ តែសត្វរាជសីហ៍ដេកស្រមុក សត្វម្រឹគឯណានឹងបោលសំរុក បញ្ចុកក្នុងមាត់អោយខ្លួនស៊ី ។

ពុទ្ធភាសិតសំដែងថា :

**វាយមេថេវ បុរិសោ យាវអត្ថស្ស និប្ផទា និប្ផន្នាសោ-ភិនោអត្ថា ខន្ត្យាភិយ្យោ នវិជ្ជតិ ។**

ធម្មតាមនុស្សដែលមានជាតិបុរស ត្រូវតែព្យាយាមត្រាតែបានសំរេចប្រយោជន៍, ប្រយោជន៍ដែលនឹងសំរេចទៅបាន មិនមានអ្វីក្រៃលែងជាងសេចក្តីអត់ទ្រាំឡើយ ។

ឯសេចក្តីព្យាយាមក្នុងការស្វែងរកទ្រព្យសម្បត្តិ មានច្រើនយ៉ាង មានព្យាយាមធ្វើ ព្យាយាមសន្សំជាដើម, សេចក្តីព្យាយាមធ្វើ និងព្យាយាមសន្សំ ជាគុណជាតិដ៏សំខាន់ក្នុងការបង្កើតទ្រព្យសម្បត្តិ ឱ្យកើនឡើងពីតិចៗ សន្សឹមៗ ទៅរកច្រើន ។ ក្នុងជាតកមានដំណាលអំពីបុរសម្នាក់ជាឧបដ្ឋាកចុល្លកសេដ្ឋីបានរើសកណ្តុរស្លាប់មួយ យកទៅលក់អោយអ្នក

Websites: WatKhemaraRatanaram.org or WatKhmers.org

ចិញ្ចឹមឆ្មា បានកំរៃមួយកាកណិក សន្សំទុកធ្វើជាទុនលក់ដូរតៗទៅ ដរាបដល់បានទ្រព្យ ២ សែនកហាបណៈ ក្នុងទីបំផុតបានឡើងឋានន្តរៈជាសេដ្ឋី។ ព្រោះការព្យាយាមសន្សំមានអានិសង្សដូច្នេះឯង ។

ពុទ្ធភាសិតសំដែងបញ្ជាក់ថា :

**ឧដ្ឋាតា វិន្ទតេ ធនំ** អ្នកមានព្យាយាមរមែងបាននូវទ្រព្យ។

**២_អារក្ខសម្បទា** កាលបើកុលបុត្រស្វែងរកទ្រព្យសម្បត្តិ ដោយកំលាំងកាយគឺប្រឹងធ្វើការងារ បែកញើស ហូរញើស នឹងកម្លាំងគំនិតប្រាជ្ញាខិតខំរកដរាបដល់បានជាទ្រព្យកើតឡើងដោយធម៌ហើយ ក៏ថែរក្សាមិនអោយខូចអន្តរាយដោយភ័យផ្សេងៗ គឺរាជភ័យ ចោរភ័យ អគ្គិភ័យ ឧទកភ័យ និងអ្នករួមមតិក ជាមួយគ្នា ដោយបានគិតប្រុងទុកក្នុងចិត្តជានិច្ចថា "ធ្វើម្តេចហ្ន៎! កុំអោយរដ្ឋការរឹបជាន់អូសយកគឺ កុំអោយលក់ពិន័យ" ឬ (ឡាយឡុង) ទៅបាន កុំអោយចោរលួច ប្លន់យកបាន កុំអោយភ្លើងឆេះបាន កុំអោយទឹកលិចបាន មនុស្សអ្នករួមមតិកជាមួយគ្នា ដែលមិនគាប់ចិត្តគ្នា ដណ្តើមយក ទៅបាន យ៉ាងនេះហៅថា អារក្ខសម្បទា ការបរិបូណ៌ដោយការថែរក្សា " អារក្ខសម្បទានេះមានអានុភាពសំខាន់ខាង ឯធ្វើទ្រព្យសម្បត្តិទាំងពួងគង់នៅ ។

អ្នកដែលមានបំណង នឹងថែរក្សាទ្រព្យសម្បត្តិអោយស្ថិតស្ថេរត្រូវដឹងវិធីរក្សា, ឯវិធីរក្សានោះមាន ៤ យ៉ាងគឺ:

១-ចេះស្វែងរករបស់ដែលបាត់

២-ចេះជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣-បរិភោគល្មមប្រមាណ

៤-មិនតាំងស្ត្រី ឬ បុរសទ្រុស្តសីលជាធំ ។

ធម្មតាទ្រព្យដែលនឹងគង់វង់នៅ ឬនឹងចំរើនឡើងបាន ក៏ដោយសារតែម្ចាស់ទ្រព្យចេះថែរក្សា ចេះចាយ ចេះប្រើ ។ ឯការរក្សានោះគប្បីកំណត់ដោយអាការដូច្នេះគឺចេះទុកដាក់ ចេះថ្នម, ចេះជួសជុល ថែមពេញ, ចេះស្តាយ ចេះធ្វើ ឱ្យមានផលតទៅ ។

និទានដំណាលប្រារព្ធរឿងអ្នកកំណាញ់ជ្រុលពេក ។ មានសេដ្ឋីម្នាក់ឈ្មោះអបុត្តសេដ្ឋីជាសេដ្ឋីឥតកូនមានទ្រព្យច្រើន តែជាមនុស្សកំណាញ់ជ្រុលពេក ស៊ូអត់ស៊ូឃ្លានមិនហ៊ានចាយទ្រព្យសម្បត្តិបរិភោគប្រើប្រាស់ធ្វើខ្លួនអោយថោកទាបដូចអ្នកក្រ, លុះស្លាប់ទៅសម្បត្តិនោះធ្លាក់ទៅជាព្រះរាជទ្រព្យទាំងអស់ ។ ព្រះបាទបសេនទិកោសល ទ្រង់ស្តេចទៅកាន់គាល់ព្រះបរមសាស្តា ទូលរឿងនោះ, ព្រះអង្គក៏សំដែងបុព្វកម្មរបស់សេដ្ឋីនោះ, ថាៈ ដែលបានជាសេដ្ឋី ព្រោះអំណោយទាន ដែលប្រើមនុស្សអោយដាក់បាត្រព្រះបច្ចេកពុទ្ធព្រះនាម តគរសិខិ, ដែលមានទ្រព្យសម្បត្តិហើយមិនបានជាប្រយោជន៏ដល់ខ្លួន ព្រោះទោសនៃសេចក្តីកំណាញ់ អំពីកាលក្រ-

Websites: WatKhemaraRatanaram.org or WatKhmers.org

ឡើកឃើញចង្ហាន់ដែលខ្លួនអោយគេដាក់បាត្រនោះល្អ ក៏នឹកស្តាយថា "មិនគួរយកទៅប្រគេនលោកសោះ គួរទុកអោយខ្ញុំកំដរស៊ីវិញល្អជាង" ។

កាលសេដ្ឋីនោះស្លាប់ទៅៗ រងទុក្ខក្នុងមហារោរុវនរក ព្រោះទោសនៃសេចក្តីកំណាញ់ នឹងសម្លាប់ម្ចាស់ទ្រព្យយកសម្បត្តិគេ ។

ពុទ្ធភាសិតលោកពោលទុកថា :

**ហនន្តិ ភោគា ទុម្មេធំ នោ ចបារគវេសិនោ**

**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគសម្បត្តិទាំងឡាយរមែងសម្លាប់មនុស្ស អ្នកមានប្រាជ្ញាអាក្រក់ តែមិនសម្លាប់មនុស្ស អ្នកស្វែងរកត្រើយគឺព្រះនិព្វានឡើយ មនុស្សអ្នកមានប្រាជ្ញាអាក្រក់ រមែងសម្លាប់ខ្លួនឯង ដូចសម្លាប់អ្នកដទៃ ព្រោះចង់បាននូវភោគសម្បត្តិ ។

**៣-កល្យាណមិត្តា** កុលបុត្រអ្នកអាស្រ័យនៅក្នុងស្រុក ឬនិគមមួយៗ ដែលមានពួកគហបតី ជាមនុស្សក្មេង តែមានកិរិយាមាយាទសណ្តាប់ធ្នាប់បែបចាស់ ឬ មនុស្សដែលមានកិរិយាមាយាទជាមនុស្សចាស់មែនទែន គឺជាមនុស្សបរិបូណ៌ដោយសទ្ធា សីលចាគបញ្ញា ក៏បានគប់ប្រសពរាប់រកនិ-យាយស្តីចរចាប្រឹក្សាសាកសួរសិក្សាគតិលោក គតិធមិចម្លងរបៀបបែបផែនរបស់ជនទាំងអម្បាលនោះ, កាលបើធ្វើដូច្នោះរមែងជាមនុស្សមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

សទ្ធាសីលចាគបញ្ញា ទៅតាមគេ ។ យ៉ាងនេះហៅថា កល្យាណមិត្តាភាពជាបុគ្គលមានមិត្រសម្លាញ់ល្អ ។

ការគប់មិត្តល្អរមែងមានអានិសង្ស អោយកើតត្រៃពិធសម្បត្តិ គឺមនុស្សសម្បត្តិ ទេវសម្បត្តិ និព្វានសម្បត្តិ, ការគប់មិត្តពាលរមែងមានទោសឱ្យវិនាសសម្បត្តិទាំងនេះ នឹងនាំឱ្យប្រព្រឹត្តអបាយមុខមានលេងស្រី លេងស្រា លេងល្បែងភ្នាល់, ការប្រព្រឹត្តអបាយមុខទាំងនេះ ទ្រព្យសម្បត្តិណាដែលមិនទាន់កើត ក៏មិនអាចកើតឡើងបាន ដែលកើតឡើងហើយក៏អន្តរាយទៅ កុំបាច់និយាយដល់ទ្រព្យសម្បត្តិបន្តិចបន្តួច, សូម្បីច្រើនរាប់រយលានក៏សល់នៅមិនបាន លោកប្រៀបដូចបឹងណាដែលមានផ្លូវបញ្ចូលទឹកតែមួយ មានផ្លូវបង្ហូរទឹកចេញច្រើន បឹងនោះរមែងរីងស្ងួតហួតហែងទៅដោយឆាប់រហ័សដរាបដល់អស់រលីង ឥតមានសេសសល់ ត្រង់បទនេះគួរឃើញដល់មនុស្សចេះតែចាយមិនចេះរក ។

សេចក្តីនេះសមដូចសេដ្ឋីបុត្តពីរនាក់ សូមនាំនិទាននេះមកសំដែងដូចតទៅនេះ :

មានសេដ្ឋីបុត្តម្នាក់បានទទួលទ្រព្យសម្បត្តិ ជាសម្បត្តិអំពីមាតាបិតា ដល់ ៨០ កោដិ ខាងប្រពន្ធ ក៏ដូចគ្នា រួមជាង ១៦០ កោដិ តែសេដ្ឋីបុត្តនោះជាមនុស្សកញ្ជះកញ្ជាយ ចាយវាយឥតបទ គប់តែនឹងមនុស្សអ្នកលេងសុរាប្រព្រឹត្តអបាយមុខគ្រប់យ៉ាង រកតែស្រីរបាំមកបំរើខ្លួន អោយរង្វាន់

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្នាក់ៗច្រើនៗ ដល់ទីបំផុតក៏អស់ទ្រព្យ ត្រឡប់ជាអ្នកដើរសុំទានគេ ។ ថ្ងៃមួយព្រះបរមសាស្ដាទ្រង់ទតឃើញ សេដ្ឋីបុត្តទាំងប្ដីប្រពន្ធ កំពុងឈរក្បែរទ្វារសាលា ចាំទទួលអាហារសំណល់ដែលភិក្ខុសាមណេរអោយទាន ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដោយគាថា ថា :

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**
**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

ពួកមនុស្សពាល ដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានខំរកទ្រព្យក្នុងវេលាខ្លួននៅជាកម្លោះក្រមុំ រមែងក្រៀមក្រំដូចជាសត្វក្រៀលចាស់ក្រៀមក្រំនៅលើភក់ដែលអស់ត្រី ។

ពួកមនុស្សពាល ដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានខំរកទ្រព្យសម្បត្តិក្នុងវេលានៅជាកម្លោះក្រមុំ រមែងដេកដកដង្ហើមធំ ស្ដាយទ្រព្យចាស់ដែលអស់ទៅដូចព្រួញដែលគេបាញ់ទៅចាក់បំពង់ ។

ព្រះបោរាណាចារ្យនាំរឿងនេះមកដំណាល ក៏ដើម្បីជាដំណឹងដល់ជនដែលប្រាថ្នារក្សាទ្រព្យសម្បត្តិ អោយដឹងថាការសេពគប់មិត្តពាលនាំអោយប្រព្រឹត្តអបាយមុខ, ការប្រព្រឹត្តអបាយមុខជាហេតុអោយខូចទ្រព្យសម្បត្តិ ដូចពោលមកនោះឯង, ការប្រព្រឹត្តអបាយមុខនោះទោះបីមិនខូច

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រព្យសម្បត្តិអស់រលីង ដល់ទៅដើរសុំទានគេដូចសេដ្ឋីនោះ ក៏គង់តែនាំអោយខូចមានប្រាក់ធ្លាក់ខ្លួនទៅជាមនុស្សជំពាក់គេច្រើន គេទារជុំវិញខ្លួន នាំអោយថោកទាបខ្លួន មិនមានតំលៃម្លោះ, ម្លោះហើយក៏ប្រព្រឹត្តទុច្ចរិតផ្សេងៗ ដើម្បីចិញ្ចឹមជីវិតអោយតែបានរស់ មិនគិតដល់បាបបុណ្យគុណទោសខុសត្រូវឡើយ ។

**៤.សមជីវិតា** កុលបុត្រដឹងហេតុចំរើន និងវិនាសរបស់ទ្រព្យសម្បត្តិ ដូចដឹងថា "សេចក្តីចំរើន និងគ្រប់សង្កត់សេចក្តីវិនាសដោយទំនងនេះ សេចក្តីវិនាសនឹងគ្រប់សង្កត់សេចក្តីចំរើនដោយទំនងនេះ " ហើយក៏សំរេចការចិញ្ចឹមជីវិតដោយសមគួរតាមកម្លាំងទ្រព្យដែលបាន ដែលមាន មិនចាយខ្ជះខ្ជាយពេក មិនរិតត្បិតត្បៀតពេក ។

ព្រះពុទ្ធសាសនាប្រដៅអំពីការចាយទ្រព្យមាន ២ ន័យ គឺ ន័យ១ អោយបែងចែកប្រាក់កាសជា ៤ ភាគ, ទុកសំរាប់បរិភោគ១ ភាគ, ចំណាយជាដើមទុនប្រកបការរកស៊ី១ភាគ , ទុកអោយនៅទំនេរសំរាប់ការពារអន្តរាយ ១ ភាគ, រួមជា ៤ ភាគ ។

ន័យមួយទៀតអោយបែងចែកប្រាក់កាសជា ៤ ភាគដែរ, តែក្នុងភាគមួយៗស្មើគ្នា មិនអោយច្រើនម្ខាងៗ ហើយចាយក្នុងភាគទាំង ៤នោះ អោយបានផលប្រយោជន៏ទាំងជាតិនេះ និងជាតិខាងមុខគឺ :

១-មួយភាគដោះបំណុលចាស់

Websites: WatKhemaraRatanaram.org or WatKhmers.org

២-មួយភាគបុលបំណុលថ្មី

៣-មួយភាគបោះទៅក្នុងជ្រោះជ្រៅ

៤-មួយភាគកប់ទុកជាកំណប់ព្រេង ។

ការចែកចាយទ្រព្យសម្បត្តិជា ៤ ចំណែកដូចបានពណ៌នាមកនេះ ហៅថា សមជីវិតា ។ ការចិញ្ចឹមជីវិតសម, ចិញ្ចឹមជីវិតស្មើ ។

**សម្បរាយិកត្ថ** ប្រយោជន៍ជូនទៅខាងមុខជនដែលត្រូវការ ដោយសេចក្ដីសុខ ក្នុងលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ, កាល បើស្វែងរកប្រយោជន៍ក្នុងលោកនេះ បានសមគួរដូចសេចក្ដីប្រាថ្នាហើយគួរ ស្វែងរកប្រយោជន៍ ក្នុងលោកខាងមុខតទៅទៀត ។

ធម៌ដែលអោយប្រយោជន៍ក្នុងលោកខាងមុខមាន ៤ យ៉ាងគឺៈ

**១.សទ្ធាសម្បទា** ការបរិបូណ៌ដោយសទ្ធា

**២.សីលសម្បទា** ការបរិបូណ៌ដោយសីល

**៣.ចាគសម្បទា** ការបរិបូណ៌ដោយបរិច្ចាគ

**៤.បញ្ញាសម្បទា** ការបរិបូណ៌ដោយបញ្ញា ។

**ក/សទ្ធាសម្បទា** កុលបុត្រជាអ្នកមានសទ្ធា ជឿការត្រាស់ដឹង របស់ព្រះតថាគតថា"ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ឆ្ងាយចាកសេចក្ដីសៅ ហ្មងគ្រប់យ៉ាង, ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះ ព្រះអង្គ, ទ្រង់បរិបូណ៌ដោយវិជ្ជា និងក្រិត្យដែលគួរប្រព្រឹត្តទ្រង់មានព្រះ-

ដំណើរល្អ យាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក, ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណា មួយស្មើគ្មានទ្រង់ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន, ទ្រង់ជាសាស្ត្រាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត យ៉ាងនេះហៅថា អ្នកបរិបូណ៌ដោយសទ្ធា ។

**សទ្ធា** ប្រែថា សេចក្ដីជឿ ជាឈ្មោះរបស់ចេតសិក១, ក្នុងចំណោមសោ-ភណចេតសិកគឺ ចេកសិកខាងដែលល្អៗ ជាប្រមុខនៃចេតសិកទាំងពួង ជាសហជាតធម៌ កើតព្រមរលត់ព្រម ជាមួយនឹងចិត្ត អាចដឹកនាំចិត្តអោយជំនឿក្នុងហេតុដែលគួរជឿលោកចែកជា ៤ ប្រភេទគឺៈ

**១‑កម្មសទ្ធា** សេចក្ដីជឿកម្ម

**២‑វិបាកសទ្ធា** សេចក្ដីជឿផលរបស់កម្ម

**៣‑កម្មស្សកតាសទ្ធា** សេចក្ដីជឿថា សត្វមានកម្មដែលខ្លួនធ្វើជារបស់ខ្លួន

**៤‑តថាគតពោធិសទ្ធា** សេចក្ដីជឿញាណរបស់ព្រះតថាគត ។

ចេតនា សេចក្ដីផ្ដើមជាតំបូងបំផុតឈ្មោះថា " កម្ម " កាលបើកើតពីសេចក្ដីលោភសេចក្ដីក្រោធ សេចក្ដីមិនលោភ សេចក្ដីមិនក្រោធ សេចក្ដីមិនវង្វេងចាត់ជា " កុសលកម្ម " ។

ការដែលត្រិះរិះពិចារណាមើលអោយដឹងថា" ចំណែកនេះជាកុសល ចំណែកនេះជាអកុសលហើយជឿស៊ប់ថា "ចំណែកនេះជាកម្មល្អ ចំណែកនេះជាកម្មអាក្រក់ ដូច្នេះហៅថា កម្មសទ្ធា ។

សេចក្ដីលំបាកកាយ លំបាកចិត្ត ដែលសត្វមិនប្រាថ្នា សត្វមិនគាប់ចិត្ត កើតឡើងអំពីផលរបស់បាបអកុសល ឬ សេចក្ដីសុខកាយ សុខចិត្ត ដែលសត្វប្រាថ្នា សត្វគាប់ចិត្ត កើតឡើងអំពីផលរបស់បុណ្យកុសលហៅថា "វិបាក" ប្រែថា "ផល" ការដែលត្រិះរិះពិចារណាមើលអោយដឹងច្បាស់នូវកម្មជាហេតុ និងសុខទុក្ខជាផល ល្មមសមគួរដល់ហេតុ និងផល ហើយជឿស៊ប់យ៉ាងនេះហៅថា វិបាកសទ្ធា ។

ពពួកសត្វសុទ្ធតែមានកម្ម គឺអំពើដែលខ្លួនធ្វើទាំងល្អ ទាំងអាក្រក់ ជារបស់ជាប់តាមជានិច្ច ទាំងអស់គ្នា ជាអ្នកទទួលយកសុខនិងទុក្ខ ដែលជាផលរបស់បុណ្យនឹងបាបនោះ ។ សេចក្ដីជឿរថា សត្វមានអំពើ ដែលខ្លួនធ្វើទាំងល្អទាំងអាក្រក់ ជារបស់ខ្លួនៗ យ៉ាងនេះហៅថា កម្មស្សកតាសទ្ធា ។ សេចក្ដីជឿញាណ ការត្រាស់ដឹងរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ថា ព្រះអង្គសំបូរដោយព្រះគុណជាអនេកប្បការមានព្រះវិសុទ្ធិគុណ ព្រះ-ករុណាគុណ និងបញ្ញាគុណ ជាដើម ហៅថា តថាគតពោធិសទ្ធា ។

**ឱរោ បុញ្ញញ្ចបាបញ្ច យំមច្ចោ កុរុតេ ឥធ តណ្ហិ តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ តញ្ចស្ស អនុគំ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**ហោតិ ឆាយាវ អនុបា យិនិ,** មនុស្សសត្វបានធ្វើកម្មឯណាទាំងពីរប្រការក្នុងលោកនេះ ទោះជាបុណ្យក្តី ជាបាបក្តី កម្មទាំងពីរប្រការនោះជារបស់គេ គេរមែងកាន់យកកម្មនោះទៅក្នុងលោកខាងមុខ កម្មនោះរមែងជាប់ប្រកិតតាមគេទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

ពុទ្ធភាសិតមួយ កន្លែងទៀតបញ្ជាក់ថា :

**នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ**
**អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។**

សភាព ២ ប្រការគឺ កុសលធម៌១ អកុសលធម៌១ អោយផលមិនស្មើគ្នា, អកុសលធម៌តែងនាំ សត្វទៅនរក, កុសលធម៌តែងនាំសត្វទៅកើតឋានសួគ៌ ។

សំដែងមកនេះដើម្បីបញ្ជាក់ អំពីវិបាករបស់កម្មអោយច្បាស់លាស់

ក្នុងព្រះសូត្រមានសំដែងរឿងមួយថា : កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ គង់នៅក្នុងវត្តជេនពន ជិតក្រុងសាវត្ថី មានមាណពម្នាក់ឈ្មោះ **សុភមាណព** ជាបុត្រតោទេយ្យព្រាហ្មណ៍ ចូលទៅក្រាបបង្គំទូលសួរព្រះអង្គថា : បពិត្រព្រះគោតមដ៏ចំរើន ! ហេតុបច្ច័យដូចម្តេច ដែលនាំអោយមនុស្សថោកទាប និងខ្ពង់ខ្ពស់ ខុសគ្នាគឺ មនុស្សពួកខ្លះមានអាយុខ្លីពួកខ្លះមានអាយុវែង, ពួកខ្លះមានរោគតិច ពួកខ្លះមានរោគច្រើន, ពួកខ្លះមានរូបអាក្រក់ ពួកខ្លះមានរូបល្អ ពួកខ្លះឥតយសស័ក្តិ ពួកខ្លះមានយស

Websites: WatKhemaraRatanaram.org or WatKhmers.org

ស័ក្តិ, ពួកខ្លះមានយសស័ក្តិ ពួកខ្លះមានភោគសម្បត្តិតិច, ពួកខ្លះមានភោគសម្បត្តិច្រើន ពួកខ្លះមានត្រកូលទាប ពួកខ្លះមានត្រកូលខ្ពស់ ពួកខ្លះមានបញ្ញាតិច ពួកខ្លះមានបញ្ញាច្រើន ។

ព្រះអង្គត្រាស់ថា : " ម្នាលមាណព ! សត្វទាំងឡាយមានកម្មជាបុណ្យ ជាបាបដែល ធ្វើហើយជារបស់ខ្លួន ជាមតិក ជាកំណើតជាផៅពង្ស ជាគ្រឿងរលឹក ព្រោះកម្មនេះជាអ្នកចាត់ចែងរំលែកសេចក្តីអាក្រក់ ល្អ អោយពួកសត្វតាមសមគួរ ដល់ចេតនាដែលសត្វផ្តើមធ្វើបានជាពួកសត្វមានសភាពថោកទាប នឹងខ្ពង់ខ្ពស់គ្នាគឺៈ

បុគ្គលណាសម្លាប់ បុគ្គលនោះរមែងធ្លាក់ទៅកើតក្នុងអបាយ គឺនរក ប្រេត អសុរកាយ តិរច្ឆាន បើមិនដូច្នេះ រមែងកើតមកមនុស្សអាយុខ្លី បុគ្គលណា វៀរចាកសម្លាប់គេ បុគ្គលនោះរមែងទៅកើតក្នុងគតិសួគ៌ទេវលោក, បើមិនដូច្នោះ រមែងកើតជាមនុស្សមានអាយុវែង, បុគ្គលណាបៀតបៀនគេ ដោយដំបងព្រនង ឬដោយគ្រឿងសាស្ត្រាវុធ ផ្សេងៗ បុគ្គលនោះរមែងទៅ កើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សមានជម្ងឺដម្កាត់ច្រើន, បុគ្គលណាមិនបៀតបៀនគេ, បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើមិនដូច្នោះ រមែងកើតមកជាមនុស្សមានជម្ងឺដម្កាត់តិច, បុគ្គលណាមានកំហឹងច្រើន ចងគំនុំ បុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងទៅកើតជាមនុស្ស មានរូបអាក្រក់ បុគ្គល

ណាមិនមានកំហឹង មិនចងគំនុំ បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើមិនដូច្នោះរមែងកើតជាមនុស្សមានរូបល្អ , បុគ្គលនោះមានចិត្តឈ្នាសនិសគេ បុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សឥតយសស័ក្តបរិវារ បុគ្គលណាមិនឈ្នានិសគេ បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើមិនដូច្នោះរមែងកើតជាមនុស្សមានយសស័ក្តបរិវារច្រើន, បុគ្គលណាមានសេចក្តីកំណាញ់មិនអោយទាន បុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សមានភោគសម្បត្តិតិច បុគ្គលណាលះសេចក្តីកំណាញ់អោយទាន បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើមិនដូច្នោះរមែងកើតជាមនុស្សមានភោគសម្បត្តិច្រើន បុគ្គលណារឹងត្អឹង មើលងាយគេ បុគ្គលនោះរមែងកើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សមានត្រកូលទាប, បុគ្គលណាមិនរឹងត្អឹងមិនមើលងាយគេ បុគ្គលរមែងទៅកើតសុគតិ បើមិនដូច្នោះរមែងកើតជាមនុស្សមានត្រកូលខ្ពស់ បុគ្គលណាមិនឧស្សាហ៍សួរអ្នកប្រាជ្ញមិនរៀនសូត្រ បុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សអប្បឥតប្រាជ្ញា បុគ្គលណាឧស្សាហ៍សាកសួរអ្នកប្រាជ្ញ បានរៀនសូត្រ បុគ្គលនោះរមែងកើតសុគតិសួគ៌ទេវលោក បើមិនដូច្នោះកើតជាមនុស្សមានប្រាជ្ញាច្រើន ។

**ខ/សីលសម្បទា** កុលបុត្រក្នុងលោកនេះ វៀរចាកការសម្លាប់សត្វ វៀរចាកលួចទ្រព្យ គេដែលមិនបានអោយដោយកាយ ឬ ដោយវាចា, វៀរចាកប្រព្រឹត្តខុសក្នុងកាម, វៀរចាកការនិយាយកុហក, វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទយ៉ាងនេះ ហៅថា សីលសម្បទា ។

**សីល** ប្រែថា ប្រក្រតី សំគាល់សេចក្តីថា : ការរក្សាកាយវាចាអោយរៀបរយជាប្រក្រតីប្រាសចាកទោស ដែលជាបាប គួរតិះដៀលតាំងពីប្រព្រឹត្តកាយវាចាអោយមានកិរិយាមាយាទទន់ភ្លន់ សុភាពរាបសាល្អ មិនបៀនបៀនអ្នកដទៃ អោយបានសេចក្តីក្តៅក្រហាយ ជាដើមនោះឯងជាលក្ខណៈរបស់សីល ។

**គ/ចាគសម្បទា** កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ស្វិតស្វាញនៅគ្រប់គ្រងផ្ទះ មានចាគរួចហើយ មានដៃលាងហើយ បំរុងចាំតែបរិច្ចាគទាន ត្រេកអរក្នុងកាល គួរដល់ការសូមត្រេកអរក្នុងកាល គួរដល់ការសូមត្រេកអរក្នុងការអោយនិងការចែករំលែក, យ៉ាងនេះហៅថា ចាគ ។

**១~អាមិសចាគ** ការលះវត្ថុមានបាយទឹកជាដើមអោយដល់អ្នកដទៃ ។

**២~ធម្មចាគ** ការលះធមិចែកធមិដល់អ្នកដទៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឃ/បញ្ញាសម្បទា** កុលបុត្រក្នុងលោកនេះជាមនុស្សបញ្ញាដឹងចំពោះហេតុជាទីកើតទីរលត់នៃសង្ខារ ជាបញ្ញាប្រសើរ អាចចាក់ធ្លុះកំចាត់បង់កិលេសដោយមិនសេសសល់ អោយដល់នូវកិរិយា អស់ទៅនៃទុក្ខដោយប្រពៃ ។ ធម្មជាតិជាគ្រឿងពិចារណាឃើញវិសេស ឃើញច្បាស់ចំពោះការកុសលហៅថាបញ្ញា ។

ធម៌ ៤ យ៉ាងគឺ សទ្ធា សម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទាជាធម៌ មានគុណានុភាពអាចញ៉ាំងកុលបុត្រអោយសំរេចប្រយោជន៍ក្នុងបរលោក សមគួរតាមសេចក្តីសេចក្តីប្រាថ្នា ។

**បរមត្ថ** : ប្រយោជន៍ប្រសើរបំផុនព្រះនិព្វាន អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា ចាត់ជាបរមត្ថប្រយោជន៍ ព្រោះជាផលដ៏ខ្ពង់ខ្ពស់បំផុតដែលលោកអ្នកមានវាសនា សាងខ្ពស់ៗ តែងបានសំរេច រកផលអ្វីៗលោកនេះ និងលោកខាងមុខ ប្រៀបផ្ទឹមគ្មាន, ព្រះពុទ្ធទាំងឡាយទ្រង់សរសើរថា " ព្រះនិព្វានជាគុណជាតិប្រសើរបំផុត ពេញប្រៀបដោយដោយបរមសុខ មិនចេះអស់មិនចេះសូន្យ ជាផលបំផុតដែនរបស់បុថុនជ្ជន" ព្រោះព្រះនិព្វានជាគុណជាតិរំលត់បង់កងកិលេសទាំងមូលបាន ។

បុគ្គលណាកាន់យកប្រយោជន៍ទាំងនេះបាន បុគ្គលនោះឈ្មោះ "សប្បុរស" សមនិងពុទ្ធភាសិតដែលព្រះអង្គទ្រង់សំដែងថា :

Websites: WatKhemaraRatanaram.org or WatKhmers.org

**ទិដ្ឋេ ធម្មេ ចយោ អត្ថោ យោ ចត្ថោ សម្បរាយិកោ**
**អត្ថាភិសមយា ធីរោ សប្បុរិសោតិ វុច្ចតិ ។**

សេចក្ដីថា ប្រយោជន៍ឯណា ដែលជាប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ប្រយោជន៍ឯណា ដែលជាប្រយោជន៍បរលោក បុគ្គលដែលលោកហៅថា សប្បុរស មានប្រាជ្ញាខ្ជាប់ខ្ជួន ព្រោះកិរិយាដឹងនូវប្រយោជន៍ទាំងនេះឯង ។

ពុទ្ធភាសិតមួយទៀតបញ្ជាក់ថា :

**ហិរិឱត្តប្ប សម្បន្នា សុក្កធម្មសមាហិតា សន្តោ**
**សប្បុរិសា លោកេ ទេវធម្មាតិវុច្ចរេ ។**

សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិនឹងឱត្តប្ប ជាអ្នកមានចិត្តដំកល់ក្នុងធម៌ស អ្នកប្រាជ្ញលោកពោលថា ជាបុគ្គលមានទេវធម៌ក្នុងលោក ។

សាធវោ ហៃសាធុសប្បុរសទាំងឡាយ ! សប្បុរសលោកតែងញ៉ាំងប្រយោជន៍ខ្លួនលោកអោយសំរេច ហើយនិយាយដឹងនាំចង្អុលបង្ហាញ ហើយញ៉ាំងប្រយោជន៍អោយសំរេច ដល់សាមញ្ញជនទូទៅ ដោយមិនរើសវណ្ណៈសោះឡើយ នរជនណាបានធ្វើគុណ នឹងសប្បុរស បុគ្គលនោះរមែងមិនសាបសូន្យដោយពិតប្រាកដ ។

សប្បុរសស្ថិតនៅក្នុងធម៌ ៧ យ៉ាងគឺ:

**១.ធម្មញ្ញុតា** ភាពជាអ្នកស្គាល់ហេតុ ដូចជាស្គាល់ថា "នេះជាហេតុនៃសេចក្តីសុខ នេះជាហេតុនៃសេចក្តីទុក្ខ " ជាដើម ។

**២.អត្ថញ្ញុតា** ភាពជាអ្នកស្គាល់ផល ដូចជាស្គាល់ថា " សេចក្តីសុខជាផល កើតអំពីហេតុនេះជាហេតុនោះជាដើម ។

**៣.អត្តញ្ញុតា** ភាពជាអ្នកស្គាល់ខ្លួនថា "អាត្មាអញនេះមានជាតិត្រកូលយសស័ក្តិ សម្បត្តិបរិវារ សេចក្តីចេះដឹង នឹងគុណធម៌ ដែលមានក្នុងខ្លួន ត្រឹមតែប៉ុណ្ណោះ ហើយប្រព្រឹត្តតាមគួរដល់ឋានៈរបស់ខ្លួន " ។

**៤.មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុងការបរិភោគជាដើម ។

**៥.កាលញ្ញុតា** ភាពជាអ្នកស្គាល់វេលាដែលគួរនឹងប្រកបកិច្ចការងារនោះៗ ។

**៦.បរិសញ្ញុតា** ភាពជាអ្នកស្គាល់ប្រជុំជន និងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះថា " ពួកនេះកាលចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយយ៉ាងនេះ ៗ " ។

**៧.បុគ្គលបរោបរញ្ញុតា** ភាពជាអ្នកស្គាល់បុគ្គលថា " អ្នកនេះជាមនុស្សល្អ គួរគប់រក អ្នកនេះជាមនុស្សមិនល្អ មិនគួរគប់រកជាដើម ។

សប្បុរសតែងស្ថិតនៅក្នុងគុណធម៌ ៧ យ៉ាង ផ្សេងទៀតគឺ :

**១-មានសទ្ធា** មានសេចក្តីខ្មាស់បាប ខ្លាចបាប ជាអ្នកបានឮ បានស្តាប់ច្រើន ជាអ្នកមានសេចក្តីព្យាយាម ជាអ្នកមានសេចក្តីខ្ជាប់ខ្ជួន ជាអ្នកមានបញ្ញា ។

**២-** នឹងព្រឹក្សាអ្វីជាមួយអ្នកណា ក៏មិនប្រឹក្សា ដើម្បីបៀតបៀនខ្លួននឹងអ្នកដទៃ ។

**៣-** នឹងគិតអ្វីក៏មិនគិត ដើម្បីបៀតបៀនខ្លួន និងអ្នកដទៃ ។

**៤-** នឹងពោលអ្វីក៏មិនពោល ដើម្បីបៀតបៀនខ្លួន នឹងអ្នកដទៃ ។

**៥-** នឹងធ្វើអ្វីក៏មិនធ្វើដើម្បីបៀតបៀនខ្លួន នឹងអ្នកដទៃ ។

**៦-** មានសេចក្តីឃើញប្រពៃ មានឃើញថាធ្វើល្អ បានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ។

**៧-** អោយទានដោយគោរព គឺអើពើនឹងរបស់ដែលខ្លួនអោយ អើពើដល់អ្នកទទួលទានមិនធ្វើអាការដូចជាបោះចោល ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូ ព្រះអង្គសំដែងពន្យល់ណែនាំអោយសេពគប់តែនឹងជនជាសប្បុរស ហាមឃាត់មិនអោយសេពរាប់រកជនជាអសប្បុរស, ព្រោះជនជាសប្បុរសតែងចង្អុលបង្ហាញ ដឹកនាំប្រាប់នូវ សេចក្តីចំរើនគ្រប់យ៉ាង ។ ឯជនជាអសប្បុរសតែងដឹកនាំអោយជួបប្រទះ នូវសេចក្តីទុក្ខលំបាកច្រើនប្រការណាស់ សមដូចពុទ្ធភាសិតថា **អសន្តេ នូប- សេវេយ្យ សន្តេ សេវេយ្យ បណ្ឌិតោ អសន្តោ និរយំ**

**នេតិ សទ្ធោ បាបេន្តិ សុគតឹ ។** បណ្ឌិតមិនគប្បីចូល ទៅសេពគប់អសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរសតែងអោយដល់សុគតិ ។

ពុទ្ធភាសិតមួយទៀតបានបញ្ជាក់ថា :

**តគរំវ បលាសេន យោនរោ ឧបនយ្ហតិ**
**បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូប សេវនា។**

នរជនខ្ចប់គ្រឿស្មាដោយស្លឹកឈើ ទាំងស្លឹក ឈើគង់ មានក្លិនក្រអូបផ្សាយទៅដែរ យ៉ាងណាមិញ, ការចូលទៅសេពគប់នឹងអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ។

ពុទ្ធភាសិតមួយកន្លែងទៀតបញ្ជាក់ អំពីការសេពគប់ថា :

**បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ**
**កុសាបិ បូតិវាយន្តិ ឯវំ ពាលូបសេវនា ។**

នរជនខ្ចប់ត្រីស្អុយដោយស្លឹកស្គា ទាំងស្លឹកស្គាគង់មានក្លិនស្អុយផ្សាយទៅដែរ យ៉ាងណាមិញ ការចូលទៅសេពគប់ និងជនពាល់យ៉ាងនោះដែរ ។

នរជនខ្ចប់ត្រីស្អុយដោយស្លឹកស្គា ឬ ខ្ចប់ដោយស្លឹកឈើអ្វីក៏ដោយ ឬខ្ចប់ដោយក្រដាស ទោះស្លឹកស្គា ស្លឹកឈើ ឬ ក្រដាសនោះ មិនមានក្លិនស្អុយមកពីមុន ក៏ត្រឡប់ក្លាយជាស្អុយទៅវិញ មកពីយកទៅខ្ចប់ត្រីស្អុយនោះឯង ត្រីស្អុយក៏ផ្សាយផ្សព្វ ភ្ជាប់ក្លិនស្អុយ ជាតិស្អុយទៅស្លឹកស្គា ស្លឹក

ឈើផ្សេងៗ ឬ ក្រដាសដែលគេខ្ចប់ត្រីស្អុយនោះ យ៉ាងណាមិញ? ការចូលទៅសេពគប់ រាប់រកយកជាមិត្តនូវមនុស្សពាល (អសប្បុរស) គឺមនុស្សមានកាយវាចាចិត្ត ពុកផុយស្អុយរលួយ ក្នុងសង្គមក្រុមមនុស្ស លុះតាមអំ-ណាចលោភៈ ទោសៈ មោហៈ ញាក់ តាមសេចក្តីអាក្រក់, លុះសេពគប់ហើយជនពាលនោះនឹងបណ្តុះធម៌ពាល បាបទុច្ចរិត កាយវាចាចិត្តអាក្រក់ថោកទាប សាបព្រោះទៅលើអ្នកសេពគប់អោយមានអាកប្ប កិរិយាពាលោ ប៉ោឡៃ ទុច្ចរិតដូចវាដែរ គឺទៅជាស្អុយពុករលួច ដោយទុច្ចរិតអយុត្តិធម៌ បាបធម៌ អមនុស្សធម៌ ដូចជនពាល (អសប្បុរស) នោះបើទោះជាពីដើមខ្លួនជាមនុស្សស្អាតស្អំ ត្រឹមត្រូវយ៉ាងណាក៏ដោយកាលបើសេពគប់ពាលហើយ កិរិយាកាយវាចាចិត្ត ក៏ទៅជាទុច្ចរិត ដូចជនពាលដែរ ។

អ្នកស្គាល់យល់ន័យនេះ គប្បីវៀរចាកងាកចេញ គេចខ្លួនពួនអាត្មាគឺថាមិនត្រូវសេពគប់ជនពាលអោយសោះ បើមិនដូច្នោះទេ មុខជាប្រឡាក់ក្លិនស្អុយដូចជនពាល ទៅជាជនពាលមិនខានឡើយ ។

សប្បុរសលោកបរិបូណ៌ដោយគុណធម៌ ដូចបានពោលមកហើយពីខាងដើមនោះ ហេតុដូច្នេះសូមពុទ្ធបរិស័ទទាំងឡាយ គប្បីសេពគប់តែនឹងលោកសប្បុរស ទើបបានជួបប្រទះនឹងសេចក្តីសុខចំរើន គ្រប់ពេលវេលាឥតអាក់ខានឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ពាក្យថា **"អសប្បុរស"** សំដៅយកមនុស្សដែលមានសន្តានចិត្ត អាក្រក់អាក្រីអប្រិយ សាមាន្យសន្តានចិត្ត មិនតាំងនៅក្នុងសីលធម៌ ជាជនកន្ត្រឹស ឬស្បាទ្រីស្ទ ជូរជាតិ មារយាទមិនថ្លៃថ្នូរ ជាអ្នកប្រព្រឹត្តអា-ក្រក់ដោយកាយវាចាចិត្ត គ្មានអាណិតអាសូរករុណា ចំពោះមនុស្សទូទៅ ជាអ្នកចូលចិត្តប្រព្រឹត្តតែអំពើឥតផលប្រយោជន៍ ដែលជាសមុដ្ឋាននាំអោយមានសេចក្តីទុក្ខលំបាកចំពោះខ្លួនផង ចំពោះជនដទៃផង, ជាអ្នកកាត់បង់នូវប្រយោជន៍ពីរយ៉ាង គឺប្រយោជន៍លោកនេះ និងលោកខាងមុខ ។

អសប្បុរស ចូលចិត្តប្រព្រឹត្តនូវអំពើពាលាអាវ៉ាសែ ខុសពីសង្គមដែលមានការរស់នៅប្រកបដោយសុជីវធម៌ ។ ជាមនុស្សថោកទាបលើកតំកើងដំឡើងតម្លៃខ្លួនឯង ថាប្រសើរថ្លៃថ្លា ខ្ពង់ខ្ពស់ជាងអ្នកដទៃ ដោយចិត្តជោរជំនោរ ខាងការរឹងត្អឹង ក្រអឺតក្រអោង កុំប៉ុតកំប៉ោង កោងព្រ-ហើន ឈ្លើនពើន មើលទៅអ្នកដទៃថាមិនគ្រាន់បើ ប្រសើរស្មើខ្លួន ហើយកើតចិត្តគិតមើលងាយ បន្ទាបបន្ថោកបន្ថយអ្នកដទៃដោយទឹកចិត្តក្តី ដោយសម្តីមើលងាយ និយាយបន្ថោកមានប្រការផ្សេងៗក្តី ហើយឡើងអំនួតអួតដំកើងខ្លួនឯងថា : គ្មាននរណាដល់ គេគប្បីដឹងនឹងយល់ថាប្រភេទនេះជាមនុស្ស អសប្បុរស ។

ជនអសប្បុរសមានលក្ខណៈ ៣ យ៉ាងគឺ:

Websites: WatKhemaraRatanaram.org or WatKhmers.org

**១-ទុក្កដកម្មការី** បើនឹងធ្វើអ្វីធ្វើតែអំពើអាក្រក់ ( សំដៅយកកាយទុច្ចរិត ) ។

**២-ទុព្ភាសិតភាសី** បើនឹងពោលអ្វី ពោលតែវាចា អាក្រក់ ( សំដៅយកវចីទុច្ចរិត ) ។

**៣-ទុច្ចិន្តិតចិន្តី** បើនឹងគិតអ្វីគិតតែនឹងផ្លូវអាក្រក់ ( សំដៅយកមនោទុច្ចរិត ) ។

អសប្បុរស តែងប្រព្រឹត្តនូវអបាយមុខហេតុជាគ្រឿងវិនាស ៤ យ៉ាងគឺៈ

**១-ឥត្ថីធុត្តោ** ជាអ្នកលេងស្រី

**២-សុរាធុត្តោ** ជាអ្នកលេងសុរា

**៣-អក្ខធុត្តោ** ជាអ្នកលេងល្បែងភ្នាល់

**៤-បាបមិត្តោ** ជាអ្នកយកមនុស្សអាក្រក់ជាមិត្ត ។

**បាបមិត្តានុយោគ** ការសេពគប់ មនុស្សអាក្រក់ជាមិត្រមានទោស ៦ យ៉ាងគឺៈ

**ក**/ នាំអោយជាអ្នកលេងល្បែងភ្នាល់ ឬ ល្បែងស៊ីសង

**ខ**/ នាំអោយជាអ្នកលេងស្រី

**គ**/ នាំអោយជាអ្នកបោកប្រាស់គេ ដោយរបស់ក្លែងក្លាយ ។

**ឃ**/ នាំអោយជាអ្នកបោកប្រាស់គេចំពោះមុខ ។

ឲ/ នាំអោយជាអ្នកលួចប្លន់ឆក់ដណ្តើមយកទ្រព្យសម្បត្តិគេ ។

ពុទ្ធបរិស័ទទាំងឡាយ ! ធម៌របស់សប្បុរស និង ធម៌របស់អសប្បុរសឆ្ងាយពីគ្នាណាស់ ឧបមាដូចជាមេឃ និង ដី ឬ ដូចត្រើយសមុទ្រម្ខាង ទៅត្រើយសមុទ្រម្ខាង ។

ការយកមនុស្សអសប្បុរសជាមិត្ត រមែងតែងតែបានទទួលនូវសេចក្តីទុក្ខលំបាកវេទនា ច្រើនប្រការណាស់ ដូចជាព្រះបាទអជាតសត្រូវសេពគប់ជាមួយភិក្ខុទេវទត្ត ទីបំផុតហ៊ានសម្លាប់ព្រះបាទពិម្ពិសារ ជាព្រះ-វរបិតា ព្រោះប្រាថ្នាសោយរាជ្យជាស្តេចក្នុងក្រុងរាគ្រឹះនោះ ។

ការសេពគប់ជាអសប្បុរស ជាហេតុនាំអោយមានសេចក្តីវិនាសដូចបានសំដែងមកខាងលើនេះ ។

ការសំដែងមកក្នុងទីគាថាទី២ នៃបរាភវសូត្រ ដែលមានសេចក្តីថា

អ្នកដែលស្រឡាញ់ពេញចិត្ត ស្នេហាតែនឹងមនុស្សណាអសប្បុរសតែមិនស្រឡាញ់ពេញចិត្តទាំងអស់ និងអ្នកសប្បុរសមកធ្វើជាមិត្ត សេចក្តីស្រឡាញ់ពេញចិត្តគំនិត ហើយទៅគប់មិត្តអសប្បុរស គាប់ចិត្តក្នុងធម៌មួយរបស់ហេតុនោះទាំងអស់ នាំអោយវិនាស ។

ការសំដែងមកនេះក៏សន្មត់ថា

**ចប់តែប៉ុណ្ណេះ ឯទំ**

# "ធម្មទេសនាបរាភវសូត្រ"

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមត្ថុ រតនត្តយស្ស វន្ទាមិ**

ព្រះករុណា សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

លំដាប់បន្ទាប់អំពីបទនមស្ការ ដោយសង្ខេបនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកបរាភវសូត្រមកសំដែង ចែកជូនដល់លោកតាលោកយាយព្រឹទ្ធាចារ្យ ពុទ្ធបរិស័ទទាំងអស់ ដែលបានអញ្ជើញមកជួបជុំក្នុងទីនេះដើម្បី ជាគ្រឿងភ្ញាក់កំណើត កើតគំនិត និងជាគ្រឿងប្រដាប់សតិបញ្ញាស្មារតីដោយសង្ខិតន័យសង្ខេបខ្លី ដូចសេចក្តីតទៅនេះ ។

បន្ទាប់ពីនេះទៅសូមលើកយកគាថាទី ៣ នៃបរាភវសូត្រមកសំដែង :

ទេវតាទូលសួរតទៅទៀតថា :

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ,**

**តតិយំ ភគវា ព្រូហិ កឹ បរាភវតោមុខំ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

យើងទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនេះឈ្មោះទី ២ ទាន់ហន់ ។ បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងអោយទាន វិនាសទី ៣ អ្វីជាប្រធាន នាំសត្វអោយមានសេចក្តីវិនាស :

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**

**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើន១, និយាយច្រើន១, និងអ្នកឥតព្រួយឥតគិតប្រឹងប្រែង អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែងខឹងច្រើនសំដែងអោយគេឃើញបាន, ហេតុធមិទាំងនោះមិនជាកល្យាណ នាំអោយខកខានខូចប្រយោជន៏មានជាប្រធានតិចច្រើន ដោយហោចនាំបង់ប្រយោជន៏ហើយឱ្យវិនាស ។

## អធិប្បាយ

## គាថាទី ៣

បទថា **និទ្ទាសីលី** បានសេចក្តីថា អ្នកដេកច្រើន, បានដល់បុគ្គលអ្នកល្មោភក្នុងការដេក, ការដេកច្រើននាំអោយខូចខាតប្រយោជន៏ច្រើនណាស់ ។

បើផ្នែកខាងបព្វជិត ពុទ្ធសាសនាវិញ ការដេកច្រើននាំអោយខាតក្នុងការសិក្សានូវត្រៃសិក្សា គឺសីល សមាធិបញ្ញា ឬ ក៏ជាហេតុអោយខាត

ការសិក្សា ព្រះបរិយត្តិធម៌ ពោលគឺព្រះត្រៃបិដកទាំងផ្នែកខាងគន្ថធុរៈ និង វិបស្សនាធុរៈ ។ សប្បុរសជនអ្នកមានប្រាជ្ញា មាននិព្វិទា គឺមានចិត្តធុញទ្រាន់នឿយណាយចំពោះបញ្ចកាមគុណារម្មណ៍ ប្រកបដោយនេក្ខម្ម គឺការចេញបួសជាភិក្ខុសាមណេរ ក្នុងព្រះពុទ្ធសាសនា លះបង់នូវបញ្ចវេរាហើយ ត្រូវមានអជ្ឈាស្រ័យធម៌ ប្រចាំនៅក្នុងខន្ធសន្តានជានិច្ច ។

អជ្ឈាស្រ័យធម៌ ៦ យ៉ាងនោះគឺៈ

**១-អលោភជ្ឈាស្រ័យ** មានអធ្យាស្រ័យមិនលោភគឺមានទឹកចិត្តមិនគិតឃើញតែចំណែកដែលបានមកដល់ខ្លួន តែម្យ៉ាងឡើយ ជាអ្នកគិតតែលៃលកក្រប្រយោជន៍ដើម្បីខ្លួនឯង ដើម្បីសាធារណៈជនផង បានដល់ការមានចាគចេតនាប្រចាំនៅជានិច្ចក្នុងចិត្ត ។

**២-អទោសជ្ឈាស្រ័យ** មានអធ្យាស្រ័យជាអ្នក មិនក្រេវក្រោធ គឺមានការរារាំងចិត្ត មិនឆុលឆេះឆេវឆាវ វេលាដែលមានសេចក្តីក្រោធកើតឡើងក៏រម្ងាប់អោយស្ងាត់បាត់ទៅវិញ ភ្លាមដោយឧបាយដ៏ល្អ តួយ៉ាងដូចជាព្រះវេស្សន្តរ កាលជូជកវាយព្រះរាជបុត្រចំពោះព្រះភ័ក្រ និងឮស័ព្ទសូរសំ-ឡេងសង្រែសង្រៃហោយំរបស់ព្រះរាជបុត្រ ទ្រង់ក៏រន្ធត់ព្រះហឫទ័យមានសេចក្តីក្រោធកើតឡើងចាប់ព្រះខ័នបំរុងនឹងកាប់តាជូជកចោល តែមានស្រមោលមេត្តាចិត្តកើតឡើង ទ្រង់ក៏រម្ងាប់សេចក្តីក្រោធនោះចេញទៅ បានដល់ការមានមេត្តា ករុណា ប្រចាំនៅក្នុងចិត្ត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**៣-អមោហជ្ឈាស័យ** មានអធ្យាស្រ័យមិនវង្វេងភាន់ វង្វេង គឺមិនលេងផេង មិនខ្លៅល្ងង់ មិនព្រមជឿងាយៗ លុះតែឃើញហេតុផលជាក់លាក់ច្បាស់លាស់ជាមុនទើបជឿ បានដល់ការមានបញ្ញាវិចារណញ្ញាណប្រចាំនៅក្នុងចិត្ត ។

**៤-នេក្ខម្មជ្ឈាស័យ** មានអធ្យាស្រ័យចេញ សំដៅដល់ការចេញបួសដែលធ្វើខ្លួនអោយចេញចាកសេចក្តីស្រឡាញ់ ចូលចិត្តរកផ្លូវ រកឧបាយចេញចាកសេចក្តីស្រឡាញ់ជានិច្ច ។

**៥-បវិវេកជ្ឈាស័យ** មានអធ្យាស្រ័យស្ងប់ស្ងៀម បានដល់ការចូលចិត្តស្ងាត់ចាកពួកប័ក្ស គណៈនិកាយ មិនចូលចិត្តនៅច្រឡូកច្រឡំ ច្របូក-ច្របល់ និងអ្នកដទៃ១ ចូលចិត្តធ្វើអោយស្ងាត់អោយបាត់សេចក្តីស្រឡាញ់រូបរឹតនៅក្នុងចិត្ត ១។

**៦-និស្សរណជ្ឈាស័យ** មានអធ្យាស្រ័យរលាស់ខ្លួន គឺ ចូលចិត្តរកឧបាយចេញចាកលោករកវិធី នឹងដោះខ្លួនចាកកិលេស នឹងកងទុក្ខផ្សេងៗដែលមាននៅក្នុងលោក ។

បព្វជិតបួសក្នុងសាសនា បើរវល់ខ្វល់តែល្មោភក្នុងការដេក តើមានពេលវេលា ឬ ឱកាសឯណានឹងសិក្សា នូវពុទ្ធវចនៈអោយបានចេះចាំទៅកើត បើដូច្នោះឈ្មោះថា ការបួសនោះធ្វើខ្លួនអោយល្ងង់ខ្លៅដដែល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ផ្នែកខាងគ្រហស្ថ បើល្មោភក្នុងការដេក ហើយឈ្មោះថា ធ្វើអោយខូចខាត ខកខាន មិនបាននូវពេលវេលាដែលត្រូវប្រកបអាជីវកម្ម ដើម្បីអោយបាននូវទ្រព្យសម្បត្តិ និងល្បៀងជីពជន្ម អោយបានរស់នៅដោយស្រួល ប្រកបដោយធមិ បើរវល់តែល្មោភក្នុងការដេក តើមានពេលវេលាឯណា នឹងប្រកបនូវកិច្ចការផ្សេងៗ មានកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម វេជ្ជកម្ម គោរក្ខកម្មជាដើម , កាលបើដូច្នោះក៏នឹងនាំមកនូវសេចក្ដីវិនាសដោយពិត ព្រោះតែការដេកច្រើន ។

បទថា **សភាពសីលិ** បានសេចក្ដីថា "អ្នកនិយាយច្រើន" បានដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ ច្រើនតែនិយាយប៉ប៉ាច់ប៉ប៉ោច បែកជាអូរហូរជាស្ទឹង ហុយជាផ្សែង ចូលចិត្តនិយាយពាក្យលែង មិនមានផលប្រយោជន៍ ច្រើនលើកយករឿងពិតខ្លះ មិនពិតខ្លះ មកនិយាយ,អ្នកនិយាយច្រើនតែពោលនូវពាក្យមុសាវាទ គឺពាក្យភូតភរកុហកបិសុណាវាទ ពាក្យចាក់ដោត ផរុសវាទ ពាក្យញុះញង់ និងសម្ផប្បលាប ពាក្យរោយរាយឥតប្រយោជន៍ គឺតិរច្ឆានកថា ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម ព្រោះជាវាចានាំអោយខូចផលប្រយោជន៍ ។ បើអង្គុយតែនិយាយពីនេះពីនោះ តើនឹងមានពេលវេលាឯណា នឹងសិក្សារៀនសូត្រ នូវចំណេះវិជ្ជាផ្សេងមាន :

**១. យុទ្ធវិជ្ជា** ចំណេះខាងចំបាំង

**២. យន្តវិជ្ជា** ចំណេះខាងគ្រឿងចក្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

**៣-វេជ្ជវិជ្ជា** ចំណេះខាងពេទ្យ

**៤-នីតិវិជ្ជា** ចំណេះខាងច្បាប់សំរាប់រដ្ឋ

**៥-កេស្រ្តវិជ្ជា** ចំណេះខាងកសិកម្ម (ធ្វើស្រែចំការ) ។

ម្យ៉ាងទៀតតើនឹងមានពេលវេលាឯណា នឹងប្រកបការងារ ដើម្បីប្រយោជន៍ជាតិ និងប្រយោជន៍សាសនា ។ បុគ្គលអ្នកនិយាយច្រើន តាមការសង្កេតពិនិត្យ ច្រើនតែលើកយករឿងដែលមានមកហើយខ្លះ តែរឿងឥតប្រយោជន៍ និងរឿងខ្លះទៀតកើតមកពីការស្រមើលស្រមៃឆ្មៃប្រឌិត ចុះក្នុងអត្ថថា ពោលនូវពាក្យកុហក បើពោលកុហកញយៗ ក៏ជាហេតុអោយហ៊ានពោលនូវពាក្យចាក់ដោត និងពាក្យញុះញង់ ។ ការពោលនូវពាក្យញុះញង់ ជាអាវុធដ៏ក្លាហាន បំផុតក្នុងលោក, សមដូចជារឿងសត្វហង្សក្បាលពីរ សូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

ក្នុងសាសនាព្រះសម្ពុទ្ធ ព្រះនាមកស្សប មានស្រីម្នាក់មានចិត្តស្មោះត្រង់ស្នេហា ចំពោះស្វាមីរបស់ខ្លួន តែងគោរពប្រតិបត្តិចំពោះស្វាមីដូចជាស្រ្តីទេពអប្សរ គោរពបំរើព្រះឥន្ទ្រាធិរាជ ពុំដែលអោយឆ្គងម៉ងត្រង់កិច្ចណាមួយឡើយ ។ ថ្ងៃមួយស្រ្តីនោះបាន បំរើ និងនាំស្វាមីចាត់ចែងទានថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយតាំងសេចក្តីប្រាថ្នាថា ក្នុងជាតិខាងមុខៗ បន្ទាប់អំពីជាតិនេះទៅ សូមអោយបានកើតជាបុរសរាល់ៗជាតិ ហើយសូមអោយកើតជាបងប្អូនរួមផ្ទៃ ជាមួយនឹងស្វាមីរបស់ខ្ញុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្យ៉ាងទៀតបើយើងខ្ញុំទាំងពីរនាក់ភ្លាត់គតិទៅកើតសត្វតិរច្ឆាន សូមអោយមានខ្លួនជាប់គ្នា មានក្បាលពីរពុំខាន ។

ព្រះសម្មទ្ធទ្រង់ធ្វើភត្តានុមោទនាហើយ ស្តេចត្រឡប់ទៅអារាមជាមួយនឹងព្រះសង្ឃជាបរិវារវិញ ។ ឯជនទាំងពីរនាក់ស្វាមីភរិយា លុះដល់ក្ស័យជីវិតបានទៅកើតជាកុមារក្នុងត្រកូលមហាសេដ្ឋីមួយជាតិ, ព្រាហ្មណ៍មហាសាលមួយជាតិ, ខត្តិយមហាសាលមួយជាតិ, កើតរួមផ្ទៃជាមួយគ្នាជាកូនភ្លោះ គឺនាងភរិយាកើតជាប្អូនប្រុស ស្វាមីជាបងប្រុស, កុមារទាំងពីរមានសេចក្តីរាប់អានស្រឡាញ់គ្នាជាទីបំផុត ។ បន្ទាប់ពីជាតិនោះមកភ្លាត់គតិទៅកើតហង្សមាស មានខ្លួនព្រែកជាប់គ្នា មានក្បាលពីរ ស្លាប ៤ ជើង៤ នៅអាស្រ័យក្នុងព្រៃហេមពាន្ត ក្បែរស្រះបោក្ខរណីមួយ តែងទៅរកចំណីអាហារជាមួយគ្នា ពុំដែលទាស់ទែងខ្វែងគនិតគ្នាឡើយ ។ ថ្ងៃមួយមានថ្មើរព្រៃម្នាក់ បានឃើញហង្សមាសក្បាលពីរនោះ ក៏កើតសេចក្តីអស្ចារ្យពន់ពេក ទើបត្រឡប់ទៅក្រាបទូលដល់ព្រះបាទពារាណសី ។ គ្រានោះព្រះ-ពោធិសត្វទ្រង់សោយព្រះជាតិជាព្រះបាទពារាណសី ទ្រង់បានព្រះសណ្តាប់ពាក្យនោះហើយ ក៏ប្រើថ្មើរព្រៃអោយទៅចាប់ហង្សក្បាលពីរនោះមកថ្វាយ ។ ថ្មើរព្រៃក៏បានទៅចាប់បានយកមកថ្វាយ ដូចព្រះរាជបំណង ស្តេចទ្រង់សព្វព្រះទ័យណាស់ បានប្រទានរង្វាន់ដល់ថ្មើរព្រៃនោះជាច្រើន ទើបប្រគល់ហង្សមាសក្បាលពីរនោះ អោយអគ្គមហេសីយកទៅចិញ្ចឹម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអគ្គមហេសី បានអោយជាងធ្វើទ្រង់មានដាក់ហង្សនោះ ហើយទ្រង់ប្រទានលាជ និងទឹកឃ្មុំដាក់លើថាសមាសអោយស៊ីតែរាល់ថ្ងៃ ។ ក្នុងកាលជាខាងក្រោយមក ព្រះនាងទេវីក៏ចូលទៅក្រាបទូលព្រះបាទពារាណសីថា ហង្សមាសក្បាលពីរនោះ ប្រសិនបើបំបែកអោយដាក់ពីគ្នាបាន ហង្សមួយទុកចិញ្ចឹមក្នុងព្រះរាជវាំង ហង្សមួយទៀតយកទៅទុកក្នុងសួនសត្វសំរាប់អោយមហាជនមើលជាការប្រពៃណាស់ ។ ព្រះ-បាទពារាណសីទ្រង់យល់តាមមាត់របស់ព្រះនាងទេវី ទើបបង្គាប់អោយអាមាត្យទាំងឡាយ មកប្រជុំគ្នា ហើយត្រាស់សួរថា អ្នកណាអាចបំបែកហង្សនេះអោយបែកចេញពីគ្នាបាន ដោយឥតមានគ្រោះថ្នាក់ យើងនឹងអោយរង្វាន់ជាច្រើន ដល់អ្នកនោះ ពេលនោះមានអាមាត្យម្នាក់ ជាអ្នកឈ្លាសវៃក្នុងឧបាយកល បានថ្វាយដំណឹងដល់ព្រះរាជាថា ខ្ញុំព្រះអង្គអាចបំបែកបាន, ព្រះរាជាក៏ប្រគល់ហង្សនោះអោយទៅ ។

ថ្ងៃមួយអាមាត្យនោះរៀបតាក់តែងខ្លួន ចូលទៅក្នុងវាំង មុននឹងទៅបានបង្ហាញខ្លួនអោយហង្សទាំងពីរដឹងថា ទៅគាល់ព្រះរាជា, លុះត្រ-ឡប់មកវិញទៅឱនខ្សឹបជិតក្បាលហង្សម្ខាងនិយាយខ្សាវៗតិចៗ ធ្វើហាក់ដូចជាប្រាប់រឿងកំបាំងអ្វីមួយ ហើយចៀសចេញទៅ ។ ឯហង្សម្ខាងឃើញដូច្នោះហើយ មានសេចក្ដីសង្ស័យណាស់ ទើបសួរទៅហង្សជា សម្លាញ់ថា អម្សាញ់មិញនេះអាមាត្យខ្សឹបប្រាប់រឿងកំបាំងអ្វីដល់អ្នក ?

ចូរប្រាប់គ្នាផង ហង្សម្ខាងប្រាប់ថា ឥតបានការអ្វីទេ គ្រាន់តែពួខ្សាវៗមិន ដឹងជាគេថា ដូចម្តេច ។

ហង្សម្ខាងតូចចិត្តណាស់ ទើបនិយាយថា ឱ ! សម្លាប់ឯងមិនគួរ លាក់នឹងគ្នាសោះ គ្នាពិតជាឃើញអាមាត្យនិយាយប្រាប់ឯងនឹងភ្នែក, ទោះ ហង្សម្ខាងនិយាយប្រាប់យ៉ាងណាក៏មិនជឿ ចេះតែទទួលសួរជាញឹកញយ ។

ថ្ងៃក្រោយ អាមាត្យទៅខ្សឹបក្បែរត្រចៀកហង្សម្ខាងនោះទៀត ហង្សម្ខាងសង្ស័យ ក៏សួរដូចមុន, ហង្សម្ខាងប្រាប់ថាមិនពួអ្វីទេ ហេតុដូច ម្តេចចេះតែមកសួរខ្ញុំ ។ ចាប់តាំងពីពេលនោះមក ហង្សទាំងពីរក៏ឈ្លោះ ប្រកែកគ្នា កាន់តែខ្លាំងឡើងៗ ដរាបដល់ជេរប្រទេច ហើយទទះស្លាបចឹក គ្នាជាខ្លាំង, ដោយអំណាចសេចក្តីក្រោធ សរីរកាយនៃហង្ស ក៏រហែកចេញ ពីគ្នាជាពីរចំណែក ។ អាមាត្យឃើញដូច្នោះហើយ ក៏នាំងយកហង្សទាំងពីរ ទៅថ្វាយព្រះបាទពារាណសី, ព្រះអង្គបានទតឃើញ មានសេចក្តីសោមនស្ស ពន់ពេកទើបព្រះរាជទាន ស្រុកសួយអោយជារង្វាន់ ហើយទ្រង់ត្រាស់សួរ ថា អ្នកធ្វើដូចម្តេច បានជាហង្សបែកចេញពីគ្នា ? សូម្បីតែយកទៅដាក់ ជិតគ្នាមិនបាន ។ អាមាត្យក្រាបទូលតាមដែលខ្លួនបានធ្វើ ទ្រង់ព្រះសណ្តាប់ ពាក្យនោះហើយក៏មាន ព្រះទ័យតក់ស្លុតសង្វេកពន់ពេក ទើបមានព្រះ- រាជឱង្ការថាឱហ្ន៎! អារុំធគឺពាក្យញុះញង់ក្លាហានណាស់តើ ! អាចពុះបំបែក

រូបធម៌ និងអរូបធម៌ អោយបែកចេញពីគ្នាបាន ក្នុងនេះឥតមានអាវុធណា ក្លៀវក្លាស្មើនឹងពាក្យព្រះពុទ្ធនេះឡើយ ។

ប្រជុំជាតក ផ្ទើរព្រៃក្នុងកាលនោះគឺ ឆន្នត្ថេរ ហង្សមាសទាំងពីរគឺ គិរីមានន្ទត្ថេរ និងកាឡុទាយិត្ថេរ អាមាត្យអ្នកឈ្លាសវៃក្នុងឧបាយកលគឺ សារីបុត្តត្ថេរ ព្រះបាទក្រុងពារាណសីគឺ ព្រះសម្មាសម្ពុទ្ធ ។

នាំនិទាននេះមកដើម្បីបញ្ជាក់អោយឃើញច្បាស់ថា ការនិយាយច្រើនៗតែជ្រុលជ្រួលហួសរហូតដល់ពាក្យព្រះពុទ្ធ ពាក្យចាក់ដោតដែលនាំមកនូវសេចក្តីវិនាស, អាស្រ័យហេតុនេះពុទ្ធបរិស័ទទាំងឡាយ កុំគប្បីជាអ្នកនិយាយច្រើនឡើយ ។

បទថា **អនុដ្ឋាតា** បានសេចក្តីថា មិនប្រឹងប្រែង មិនខ្នះខ្នែង មិនក្រវើនតើន មិនក្រទីក្រទា ស្រូតរូត ដំអក់ ទម្រន់ច្រអូស មិនខ្មីឃ្មាត សង្វាតឧស្សាហ៍ ព្រងើយកន្តើយ ចំពោះ កិច្ចការទូទៅ, ពោលដល់បព្វជិត ពុទ្ធសាសនា បើមិនយកចិត្តទុកដាក់ ប្រឹងប្រែងសិក្សាសូត្ររៀននូវបាវចនាទេ រមែងមិនចេះ មិនដឹង មិនយល់មិនស្គាល់ ច្បាប់ ឧទាហរណ៍ដូចជាភិក្ខុក្នុងសាសនមណ្ឌលនេះ មានសីល ៤ គឺ បាតិមោក្ខសំវរសីល ១, ឥន្ទ្រិយសំវរសីល ១, អាជីវបារិសុទ្ធិសីល១, បច្ចយសន្និស្សិតសីល១, បើគិតជាសិក្ខាបទ មានដល់ទៅ ២២៧ សិក្ខាបទ បើមិនប្រឹងសិក្សាទន្ទេញស្វាធ្យាយទេធ្វើម្តេច នឹងចេះចាំទៅបាន, បើមិនចេះចាំ មិនដឹង មិនយល់

ហើយធ្វើម្តេច និងប្រតិបត្តិទៅកើត ដើម្បីអោយបានដឹងនូវពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាត បើយ៉ាងហ្នឹងតើការប្រតិបត្តិនឹងដូចម្តេចទៅវិញ? ច្បាប់ជា ប្រព្រឹត្តប្រតិបត្តិស្មានៗ បើប្រតិបត្តិស្មានបានទទួលផលក៏ស្មានដែរ សមដូច ពុទ្ធភាសិត ព្រះអង្គទ្រង់ត្រាស់ថា :

**យោ គាវំ ន វិជានាតិ ន សោ រក្ខតិ គោគណំ, ឯវំ សីលំ អជានន្តោ កឹ សោ រក្ខតិ សំវរំ ។**

បុគ្គលណាមិនស្គាល់គោ បុគ្គលនោះនិងរក្សាហ្វូងគោដូចម្តេចបាន យ៉ាងណាមិញភិក្ខុមិនស្គាល់សីល តើនឹងរក្សាសេចក្តីសង្រួមក្នុងសីលដូចម្តេច បាន ។

ចំណែខាងសាមណេរ មានសិក្ខាបទ ១០ ទណ្ឌកម្ម ១០ នាសនង្គៈ ១០, សេក្ខិយវត្ត ៧៥ លោកវិជ្ជសិក្ខាបទ ៤៩, បើមិនប្រឹងឧិហាតសង្វាត ឧស្សាហ៍ទន្ទេញរៀនសូត្រអោយបានចេះពិតប្រាកដ ដើម្បីកុំអោយច្រឡំ ភាន់ ក្នុងការប្រតិបត្តិ បើមិនដូច្នោះទេ ច្បាស់ជារកសេចក្តីចំរើនមិនឃើញ ជួបប្រទះតែនឹងសេចក្តីវិនាសមិនខានឡើយ ។

ចំណែកខាងគ្រហស្ថឃរាវាសវិញដល់ពេលវេលាដែលត្រូវធ្វើស្រែ ចំការហើយមិនប្រឹងប្រែង បណ្តែតបណ្តោយ ឡូយថូយ ធ្វេសប្រហែល ចំ-ពោះកិច្ចការកសិកម្ម ឧទាហរណ៍ ដូចជាដល់ពេលភ្ជួររាស់សាបព្រោះបណ្តុះ ពូជ ហើយបែរទៅឧបករណ៍គឺប្រដាប់ប្រដារសំរាប់ធ្វើស្រែ មានគោ ក្របី

Websites: WatKhemaraRatanaram.org or WatKhmers.org

រទេះសាលី នង្គ័ល រនាស់ មិនដឹងជានៅឯណា បើយ៉ាងហ្នឹង តើនឹងប្រកប កសិកម្មកើតដែរឬទេ ? ឆ្លើយថាមិនកើតទេ ! ព្រោះហេតុអ្វីបានជាមិនកើត ? បានជាមិនកើតព្រោះខ្លួនទ្រមក់ លង់លក់មិនប្រឹងប្រែងអោយបានរួសរាន់ ទាន់ពេលវេលា ដែលត្រូវធ្វើ បណ្តោយអោយពេលវេលាកន្លងហួសទៅដោយការមិនយកចិត្តទុកដាក់ ។

អាស្រ័យហេតុជាអាទិ៍ សប្បុរសជនទាំងឡាយ ! គប្បីប្រឹងប្រែងខ្នះខ្នែងអោយណាស់ ទើបសំរេចជាប្រយោជន៏បាន, ដូចពាក្យភាសិតលោកពោលថា កើតមកជាប្រុសត្រូវតែ ប្រឹងព្យាយាមអោយតឹងកុំបន្ធូរប្រះប្រាណដេកទៅ កុំដេកយូរក្រោកឡើងគិតគូរធ្វើការទៀត ។ សុភាសិតមួយលោកពោលថា កុំបង្អង់ចាំស្អែកសិន ទ្រព្យនឹងវិនាសហិនខូចទទេ កុំចាំថ្ងៃក្រោយសឹមរិះរេ លាភយសបានគេអាសាបង់ ។

**ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោវិធានវា សមំ កប្បេតិ ជីវិតំ សម្ភតំ អនុរក្ខតិ ។**

អ្នកមានព្យាយាមវាសរវៃ ក្នុងនាទីការងារមិនប្រមាទ ចូលចិត្តចាត់ការចិញ្ចឹមជីវិតស្មើៗគ្នា ទើបរក្សាទ្រព្យដែលរកមកទុកបាន ។

អ្នកមានព្យាយាមរៀសរវៃក្នុងនាទីការងារ គឺអ្នកមានសេចក្តីប្រឹងប្រែង ខ្នះខ្នែង រហ័សរហួន ញាប់ដៃញាប់ជើង ទៀងទាត់ម៉ត់ចត់ធ្វើការមិនដាច់ ធ្វើហើយធ្វើទៀត ស្រឡាញ់ពេញចិត្តស្អិតជាប់ក្នុងនាទី

Websites: WatKhemaraRatanaram.org or WatKhmers.org

ការងារគឺ បើស្ថិតនៅក្នុងមុខតំណែងនាទីការងារអ្វី ក៏ស្គាល់នាទីការងាររបស់ខ្លួនដូចបើជាកសិករ កម្មករ ក៏វវៀសវវៃក្នុងកសិកម្ម ហត្ថកម្ម បើពាណិជ្ជករ ក៏ប្រឹងប្រែងញាប់ដៃ ញាប់ជើង ក្នុងពាណិជ្ជកម្ម បើជាអ្នករដ្ឋការ គឺបើស្ថិតនៅក្នុងនាទីការងារអ្វី ក៏ឃ្លាតខ្មីប្រឹងប្រែងក្នុងមុខការងារនាទីនោះ ជាមួយគ្នានោះក៏មិនប្រមាទ គឺមិនធ្វេសប្រហែស ប្រុងប្រយ័ត្នមិនអោយភ្លាំងភ្លាត់ បាប់បង់ខុសខូចការទាំងចូលចិត្តចាត់ការដែលត្រូវចាត់ចែងយ៉ាងណា អោយបានរៀបរយចំរើនកើនឡើង ។ ប៉ុណ្ណោះក៏នៅមិនទាន់សព្វគ្រប់ទេ គឺត្រូវចេះចិញ្ចឹមជីវិតស្មើៗ ពោលគឺចេះគិតតែលៃលកចាយវាយបរិភោគ ប្រើប្រាស់ល្មមល្មៃ សមគួរតាមផលប្រយោជន៍ដែលរកបាន មកគឺមិនត្បិតត្បៀតពេក មិនកញ្ជះកញ្ជាយទូលាយដៃពេក ស្គាល់ប្រមាណក្នុងការបាន នឹងការចាយវាយ គឺលៃអោយល្មម នឹងចំណូលចំណេញនឹងចំណាយ ព្រមទាំងស្គាល់ប្រមាណខ្លួន ។ កាលបើបុគ្គលមានព្យាយាម វវៀសវវៃ ក្នុងនាទីការងារផង មិនប្រមាទចូលចិត្តចាត់ការផង ចិញ្ចឹមជីវិតស្មើៗផង លោកប្រាប់លទ្ធផលថា បើយ៉ាងនេះទើបរក្សាទ្រព្យដែលរកមកទុកបាន គឺទ្រព្យដែលរកមកគពូននោះ អាចគង់វង់នៅចំរើនឡើយបាន ។

បញ្ជាក់សេចក្តីខាងលើ ផ្នែកខាងពាណិជ្ជដែលត្រូវប្រកប របរពាណិជ្ជកម្ម គឺត្រូវទិញចូលលក់ចេញ ត្រូវមានស្មារតីអោយណាស់រហ័សរហួន

ញាប់ជើងញាប់ដៃ សម្តីថ្មីមាត់ គួរសមរាក់ទាក់ ចៅរៅនឹងភ្ញៀវអ្នកដែលជាញាតិមិត្រ ត្រូវការចូលមកទិញដូរ ប្រាស្រ័យទាក់ទង បើមិនខ្មីឃ្មាត យើងមិនអាចដឹងរបស់នេះឡើងថ្លៃរបស់នេះ ចុះថ្លៃលក់ស្មាន១ ច្បាស់ជាខាតទុនឡុងចុង លិចលង់ ផុងកញ្ជើរ ខូចឃីហោច ដួលហាង ជាមិនខាន ។

ខេមរសុភាសិតបានពោលថា ពេញយប់ចេញផ្សេង ពេលថ្ងៃចេញភ្លើង ។

បើផ្នែកខាងព្រះពុទ្ធសាសនាវិញ ក៏គប្បីប្រឹងប្រែងបំពេញបុណ្យកុសល មានធ្វើទានរក្សាសីល ចំរើនមេត្តាភាវនា កុំធ្វេសប្រហែស បណ្តែតបណ្តោយ អោយពេលវេលា ដ៏មានតំលៃកន្លងហួសទៅទទេ១ ដោយមិនបានបំពេញសេចក្តីល្អណាមួយទុកក្នុងខ្លួនសោះ បូរាណលោកពោលថា : "ពេលវេលា ជាមាសជាប្រាក់ " ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទ្រង់សំដែងដាស់តឿនថា : **ភាជម្ណ តស្សមេ រត្តិន្ទិវា ចិតិមតន្តិ,** ថ្ងៃនឹងយប់កន្លងទៅ១ ឥឡូវនេះអាត្មាអញបានធ្វើអ្វីខ្លះហើយ ។ ការអោយគិតរំពឹងយ៉ាងនេះ ដើម្បីកុំអោយកើតសេចក្តីប្រមាទ គឺ ការធ្វេសប្រហែល ។

ពុទ្ធភាសិតមួយកន្លែងទៀតក្នុងគម្ពីរខុទ្ទកនិកាយទ្រង់សំដែងថា : **ចក្ខុមា វិសមានិវ វិជ្ជមានេ បរក្កមេ បណ្ឌិតោ ជីវលោកស្មឹ បាបានិ បរិវជ្ជយេ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលបើមានសេចក្តីប្រឹងប្រែង បុគ្គលគប្បីជៀសវាងបាបទាំង- ឡាយក្នុងជីវិតលោក ដូចបុរសមានចក្ខុជៀសវាងផ្លូវ ដែលមិនរៀបស្មើ ដូច្នោះដែរ ។

កាលបើមានសេចក្តីប្រឹងប្រែងប្រកបកិច្ចការងារជាមុខ របរផ្សេងៗ ក្តី ព្យាយាមមុតស៊ូប្តូរផ្តាច់ ក្នុងការធ្វើអោយសំរេចគោលបំណងអ្វីមួយក្តី ដែលទាន់ទងនឹងការងារកសាង ជីវិតអោយស្ថិតនៅក្នុងភាពស្តុកស្តម្ភ ដោយទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ យសស័ក្តិ ថ្នាក់ធំ ថ្មីថ្មោង ក៏បុគ្គលគប្បីព្យា- យាម ប្រឹងប្រែងប្រកបតែការងារល្អ មុខរបរត្រឹមត្រូវ ផ្លូវសច្ច សុចរិត យុត្តិធម៌ ដោយជៀសវាងបាបទាំងឡាយ ក្នុងជីវលោក ពោលគឺវៀរចាក ងាយចេញអំពីសច្ច ទុច្ចរិត អយុត្តិធម៌ ដែលជាអំពើបាបថោកទាប ព្រោះ បើសេចក្តីព្យាយាមរបស់បុគ្គលដែលជាប់ជាមួយនឹងអកុសលកម្ម សេចក្តី ព្យាយាមនោះ ទោះសំរេចតាមបំណង ក៏ជាប់ទាក់ទងនឹងសេចក្តីអាក្រក់ ដែលហៅថា រកសុខលើសេចក្តីទុក្ខ ក្តៅក្រហាយរបស់ជនដទៃ មិនមែន ជាសេចក្តីសុខល្អ ហុចផលផ្តល់ប្រយោជន៍វែងឆ្ងាយឡើយ ផលនៃសេចក្តី អាក្រក់មុខជាហុចអោយវិញមិនខាន ។

ដូច្នេះការប្រឹងប្រែងប្រកបការងារអ្វី បុគ្គលគប្បីវៀរចាកពីសេចក្តី អាក្រក់ទាំងឡាយ ក្នុងជីវិលោកនេះ អោយដូចមនុស្សមានភ្នែកមើល

Websites: WatKhemaraRatanaram.org or WatKhmers.org

ឃើញ ជៀសវាងផ្លូវដែលរដិបរដុប ក្រហេងក្រហូង មិនរាបស្មើ ឬផ្លូវដែលមានបន្លាដូច្នោះដែរ ។

ពុទ្ធភាសិតមួយកន្លែងទៀតទ្រង់ត្រាស់សំដែងថា :

**អប្បកេនបិ មេធាវី បាភតេន វិចក្ខណោ សមុដ្ឋាបេតិ អត្តានំ អណុំ អណុំ អគ្គឹវ សន្ធមំ ។**

អ្នកប្រាជ្ញ មានប្រាជ្ញាឆ្នើម រមែងតាំងខ្លួនបាន ដោយដើមទុន សូម្បីបន្តិចបន្តួច ដូចគេបង្កាត់ភ្លើង តូចអោយធំបានដូច្នោះឯង ។ អ្នកប្រាជ្ញគឺជាអ្នកមានគំនិតគិតជ្រៅដៅឆ្ងាយ ស្គាល់យល់ឧបាយផ្លូវ ចំរើនកើនប្រយោជន៍ ឬ ផ្លូវហិនហោចខ្លោចផ្សារយ៉ាងណា១ ចេះពិចារណារកហេតុផលត្រឹមត្រូវល្អិតល្អន់ គឺជាអ្នកមានប្រាជ្ញាឆ្នើម រមែងស្គាល់យល់ដឹងថាអ្វី១ដែលចំរើនឡើង ឬ វិនាសទៅវិញក៏មកពីរបស់បន្តិចបន្តួចជាមុនយ៉ាងពិតប្រាកដ ។

ដូច្នេះក្នុងការតាំងខ្លួនអោយមាំមួន ស្តុកស្តម្ភ ចំរើនកើនឡើងដោយទ្រព្យសម្បត្តិនោះ អ្នកប្រាជ្ញរមែងសាងខ្លួន តាំងពីដើមទុនបន្តិចបន្តួចឡើងទៅគឺមានសម្ភារៈ ដូចប្រាក់កាស តិចតួចក្តី ប្រដាប់ប្រដាតិចតួច បើមិនល្អក្តី ក៏ចេះផ្សែផ្សំលៃលក ធ្វើរបស់តិចតួចនោះ អោយចំរើនកើនឡើងដោយស្ថិតនៅក្នុងគុណធម៌ជាគ្រឿងកសាងខ្លួន តាមក្បួនពុទ្ធសាសនា គឺ

ប្រឹងប្រែងឧស្សាហ៍ក្រលើនក្រតើន បំពេញកិច្ចការងារ ដោយយកចិត្តទុកដាក់ មិនខ្ជិលច្រអូស គឺព្យាយាមមុតមាំក្នុងការងារអ្វីមួយ ។

ចេះប្រយ័ត្នប្រយែង រក្សាការងារនោះទុកក្តី រក្សាផលប្រយោជន៍ដែលបានពីការងារនោះក្តី សូម្បីតិចតួចអោយគង់វង់មិនអោយវិនាសបាត់បង់ទៅវិញ ១ ចេះសេពគប់រាប់រកមិត្តល្អ ដើម្បីជាគូពិភាក្សា ក្នុងផ្លូវចំរើនសតិ បញ្ញា ១ ការចេះលៃលកចាយអោយល្មមល្មៃ តាមលទ្ធភាពរបស់ខ្លួន ១ ។

អ្នកប្រាជ្ញដែលស្ថិតនៅក្នុងគុណធម៌ ៤ យ៉ាងនេះ សូម្បីមានដើមទុនតិចតួច ក៏អាចកសាងខ្លួនអោយមាំមួនដោយទ្រព្យសម្បត្តិបាន ដូចគេបង្កាត់ភ្លើងតិចតួចអោយឆេះធំសន្ធោសន្ធៅឡើងបាន ឬដូចការគរពូននៃសត្វកណ្តៀរ ដូចជាការស្រក់តក់ៗនៃទឹកត្នោត ដូចជាការរៀនអក្សរពីស្រះព្យញ្ជនៈ មួយពីរ ជាបឋម ដូចការធ្វើដំណើរមួយជំហានម្តង ក៏អាចទៅជាដំបូក ជាទឹកត្នោតពេញបំពង់ ជាការចេះអក្សរ និងការដល់ទីដៅ យ៉ាងណាមិញ ? ការឆ្លាតវាងវៃនៃអ្នកប្រាជ្ញ រមែងតាំងខ្លួនបានដោយដើមទុនសូម្បីបន្តិចបន្តួច ក៏យ៉ាងនោះដែរ ។

បទថា **អលសោ** បានសេចក្តីថា "ខ្ជិល" មិនខ្នះខ្នែង មិនប្រឹងប្រែង មិនខ្មីឃ្មាត ក្រលើនក្រតើន ស្រួតរូត ដំអកទ្រមក់ លង់លក់ អែនអនមិនពតបណ្តែបណ្តោយ, សេចក្តីខ្ជិលច្រអូសជាអកុសលធម៌ គួរកំចាត់បង់

អោយអស់ពីខន្ធសន្តាន ។ កោសជ្ជៈ សេចក្តីខ្ជិលច្រអូសជាវេចនៈ និង ពាក្យថា **អលសោ** បុរសស្រ្តីក្នុងលោក បើអោយសេចក្តីខ្ជិលច្រអូសជិះជាន់ សង្កត់សង្កិនបានហើយ រមែងដល់នូវសេចក្តីវិនាស ដោយពិតប្រាកដ បើទុកជាបុរសស្រ្តីនោះ មានជីវិតរស់នៅរាប់រយឆ្នាំ ក៏ពុំប្រសើរឡើយ សមដូចពុទ្ធភាសិតថា :

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។**

ជនណាមួយខ្ជិលច្រអូស មានព្យាយាមថោកទាប គប្បីរស់នៅអស់រយនៃឆ្នាំ ពុំប្រសើរស្មើរនឹងការរស់នៅតែមួយថ្ងៃ របស់អ្នកប្រារព្ធនូវសេចក្តីព្យាយាមដ៏មាំមួន ។ ជនណាមួយមានការខ្ជិលច្រអូស គឺទំរន់ទ្រមក់ ខ្ជីខ្ជាក្នុងការងារដែលត្រូវធ្វើ, ត្រែតត្រត ទ្រែលទ្រោលនៃលនល ឥតប្រឹងប្រែងក្នុងការងារ ជានាទីរបស់ខ្លួន គឺបើសិក្ខាកាមខ្ជិលច្រអូសក្នុងការសិក្សា បើជាគ្រហស្ថខ្ជិលច្រអូសក្នុងការងារទាំងឡាយ មានកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ជាដើម បើខាងបព្វជិតខ្ជិលច្រអូសក្នុងការសិក្សា ធម៌វិន័យ និងខ្ជិលប្រព្រឹត្តតាមធម៌វិន័យ បើទុកជាធ្វើក៏ធ្វើ ឬប្រឹងប្រែងថោកទាប លើបរលាបច្បិចច្បើម ញញើតញញើមឡេះៗលេងៗ សោះតែខាន ឬ គ្មានប្រឹងប្រែងដោយខ្លាំងខ្លា មិនឧស្សាហ៍ដោយទៀងទាត់ ។ ជនកំជិល

នោះទោះមានអាយុយឺនយូរអស់មួយរយ ពីររយ បីរយឆ្នាំក៏ដោយក៏ពុំប្រសើរឡើយ ព្រោះជាជីវិតឥតប្រយោជន៍ ។

ជនមួយប្រភេទទៀត ជាអ្នកមានសេចក្តីប្រឹងប្រែងខ្នះខ្នែង ម៉ឹងម៉ាត់ក្នុងមុខការនាទីរបស់ខ្លួន ចាប់ផ្តួចផ្តើម ព្យាយាមយ៉ាងមុតមាំ បោះជំហានឈានទៅមុខ រកសេចក្តីសំរេចប្រយោជន៍ជាលោកិយ ឬ លោកុត្តរ គឺព្យាយាមក្នុងការប្រុងប្រយ័ត្នមិនអោយទោសកំហុស សេចក្តីអាក្រក់ការឥតប្រយោជន៍ កើតឡើងបាន១, ព្យាយាមក្នុងការលះបង់ទោសកំហុសការឥតប្រយោជន៍ សេចក្តីអាក្រក់ដែលកើតឡើងហើយ១, ព្យាយាមធ្វើគុណប្រយោជន៍ សេចក្តីល្អ ទ្រព្យសម្បត្តិ ចំណេះវិជ្ជា កេរ្តិ៍ឈ្មោះ យសស័ក្តិ ឬ គុណធម៌មគ្គផល សេចក្តីល្អ ដែលកើតឡើង ហើយអោយគង់វង់នៅ ១ ការរស់នៅ សូម្បីតែមួយថ្ងៃរបស់អ្នកមានសេចក្តីព្យាយាមមាំមួនយ៉ាងដូច្នេះ ប្រសើរជាងការរស់នៅរាប់រយឆ្នាំ នៃអ្នកមានសេចក្តីព្យាយាមថោកថាប ខ្ជិលច្រអូស ក្នុងការងារទាំងឡាយ ។

ព្រះពុទ្ធដីកាមួយកន្លែងទៀតទ្រង់សំដែងថា :

**កោសជ្ជំ ភយតោ ទិស្វា វីរិយារម្ភញ្ច ខេមតោ**

**អារទ្ធវីរិយោ ហោថ ឯសា ពុទ្ធានុសាសនី ។**

អ្នកទាំងឡាយ ឃើញសេចក្ដីខ្ជិលថាជាភ័យ ទាំងឃើញការប្រារព្ធសេចក្ដីព្យាយាមថាជាធមិក្សេម (ចាកភ័យ) ចូរប្រារព្ធសេចក្ដីព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ។

ព្រះពុទ្ធដីកាមួយកន្លែងទៀតទ្រង់សំដែងថា :

**អមោឃំ ទិវសំ កយិរា អប្បេន ពហុកេន វា**

**យំ យំ វិវហតេ រត្តិ តទូនន្តស្ស ជីវិតំ ។**

បុគ្គលគួរធ្វើថ្ងៃយប់ កុំអោយទទេចាកប្រយោជន៍តិច ឬច្រើន ព្រោះថ្ងៃយប់កន្លងបុគ្គលណាទៅ ជីវិតរបស់បុគ្គលនោះ រមែងខាតចាកប្រយោជន៍នោះ ។

ពុទ្ធភាសិតខាងលើនេះ បំភ្លឺរំលឹកយ៉ាងល្អិតល្អន់ អោយមនុស្សមានសេចក្ដីប្រឹងប្រែង កសាងប្រយោជន៍តិច ឬ ច្រើនអោយបានកុំអោយពេលវេលាកន្លងហួសទៅ ដោយឥតប្រយោជន៍ ដូចអធិប្បាយតទៅនេះ :

បុគ្គលគួរធ្វើថ្ងៃយប់ កុំអោយទទេចាកប្រយោជន៍តិច ឬច្រើន បានសេចក្ដីថា មនុស្សម្នាក់ៗ មិនត្រូវបណ្ដែតបណ្ដោយអោយថ្ងៃ យប់ ពេលវេលា ២៤ ម៉ោង កន្លងផុតទៅទទេៗ ដោយមិនបានបំពេញកិច្ចការណាមួយអោយកើតប្រយោជន៍ទោះតិច ឬ ច្រើននោះឡើយ ត្រូវនាទី , វិនាទី ថ្ងៃយប់ដែលកន្លងផុតជាមួយនឹងការ បានបំពេញកិច្ចការ ជាប្រ-

Websites: WatKhemaraRatanaram.org or WatKhmers.org

យោជន៍ ធ្វើអ្វីមួយជាប្រយោជន៍អោយកើតឡើង ក្នុងជំហានទី១ក្តី ទី២ ក្តី សេចក្តីសំរេចផលចុងក្រោយបង្អស់ក្តី ។

ប្រែថា ថ្ងៃយប់និមួយៗ ត្រូវបានធ្វើការងារជាប្រយោជន៍ក្នុងផ្លូវល្អ មិនត្រូវបណ្តោយអោយដៃជើង នៅស្ងៀម ឬ ទៅជាអ្វីដែលឥតប្រយោជន៍ ទៅវិញ ទោះប្រយោជន៍តិចក្តី ច្រើនក្តី ត្រូវតែធ្វើអោយបាន អោយកើតខ្លះ ដែលស្របនឹងខេមរ ភាសិតថា "រពិសដៃផ្ទៃឆ្អែត" តួយ៉ាងក្នុងថ្ងៃយប់ និមួយៗ ភិក្ខុសាមណេរ ដែលបំពេញគន្ថធុរៈ ត្រូវបានសិក្សាស្តាប់មើលអាន គម្ពីរដីកា ឬ ទន្ទេញ ឬ សូត្រ រំលឹកនូវធម៌វិន័យ អោយបានមួយចំនួន ឬ បើបំពេញវិបស្សនាធុរៈ ក៏ត្រូវខំចំរើនវិបស្សនា ធ្វើចិត្តអោយស្ងប់យ៉ាង ហោច ក៏មួយម៉ោងដែរ ។

បើជាគ្រហស្ថ កសិករ ក៏ត្រូវបានបំពេញការកាប់ដី អោយបាន មួយចំនួន ឬ ស្រោចទឹកដាក់ជីរ ដំណាំអោយបានមួយចំនួនជាដើម, បើជា អ្នកនិពន្ធ ក៏ត្រូវបានសរសេរចងក្រងយ៉ាងហោចណាស់មួយទំព័រ ពីរទំព័រ ដែរ ។ ល ។ រួមមកអ្នកកាន់កាប់មុខការនាទីអ្វី ត្រូវបំពេញមុខនាទីនោះ យ៉ាងហោចណាស់មួយក៏រិត មួយចំនួន ដែលមានលក្ខណៈឈានទៅមុខ កើនឡើងនូវកិច្ចការងារ ឬ អោយបានឆិតជិត សំរេចផល កុំអោយថ្ងៃ យប់កន្លងហួសទៅទទេៗ ដោយគ្មានបានធ្វើអ្វីជាប្រយោជន៍សោះនោះ ឡើយ ។

ព្រោះហេតុអ្វី ! ព្រោះថ្ងៃយប់កន្លង បុគ្គលណាទៅ ជីវិតរបស់បុគ្គលនោះរមែងខាតចាកប្រយោជន៍នោះ ពោលគឺថ្ងៃយប់កន្លងឆ្លងផុតបុគ្គលណាទៅដោយបុគ្គលនោះ មិនបានធ្វើប្រយោជន៍អ្វីមួយអោយកើតឡើងជីវិត គឺការរស់នៅរបស់បុគ្គលនោះ រមែងខាតចាកប្រយោជន៍របោចរោចចុះ ទៅនូវប្រយោជន៍ ដែលខ្លួនចង់បាន គឺមិនចាកប្រយោជន៍នោះឡើយ ។

សុភាសិតក្នុងលោកនីតិប្បករណ៍ពោលថា :

ការងារទាំងឡាយសំរេចដោយព្យាយាម មិនមែនបានភ្លាមតាមចិត្តគិត បើដេកព្រងើយផ្សងបុណ្យពិត ដល់ក្ស័យជីវិតក៏ឥតសុខ ។ សត្វម្រឹគមានពាសពេញព្រៃ តែសត្វរាជសីហ៍ដេកស្រមុខ សត្វម្រឹគឯណានឹងបោលសំរុក បញ្ចុកក្នុងមាត់អោយខ្លួនស៊ី ។

ផ្នែកខាងសាសនា បានដល់បព្វជិតអ្នកបួសមិនត្រូវអោយខ្ជិលជិះជាន់បាន ត្រូវមានការប្រឹងប្រែងរៀនសូត្រនូវព្រះពុទ្ធវចនៈអោយបានចេះចាំស្ទាត់ជំនាញ បើខ្ជិលច្រអូសដោយអាងថា អញបួសរួចហើយ បើអាងដូច្នោះការបួសនោះ ឈ្មោះថាបួសឧបមុយ្ហិកា បួសល្ងង់ខ្លៅ មិនរៀនសូត្រមិនចេះមិនដឹង មិនយល់ ព្រោះតែសេចក្ដីខ្ជិល ជាសមុដ្ឋាន ។ម្យ៉ាងទៀតកុំអាង ឬកុំមើលងាយនូវសតិស្មារតីរបស់ខ្លួន ថាឱនថយរៀនសូត្រមិនចាំមិនចេះនោះអោយសោះ ព្រោះមានសុភាសិតមួយពោលថា :

កុំមាក់ងាយថាបញ្ញាខ្លួនតិច រៀនទៅក្រែងភ្លេចមិនចំរើន សុតម័យបញ្ញា បើប្រឹងក្រវើន យូរទៅគង់ច្រើនពេញហឫទ័យ ប្រៀបដូចក្អមដាក់លើក្បាលដំបូក ភ្លៀងអុរខ្ទោកៈជាអចិន្ត្រៃ ដំណក់តក់ៗជារាល់ៗថ្ងៃ អាស្រ័យយូរទៅគង់ពេញបាន ។

សុភាសិតមួយកន្លែងទៀតថា ៖

ចំណេះវិជ្ជាមិនដែលកើតឡើងឯង ដែលឥតគេស្វែងគេប្រាថ្នា ចំណេះវិជ្ជាមិនដែលមានដល់អ្នកណា ដែលមិនប្រាថ្នាឥតស្វែងរក ។

សុភាសិតមួយកន្លែងទៀតថា ៖

កើតមកជាមនុស្សត្រូវតែចេះ វិជ្ជាចំណេះក្នុងសន្ដាន កុំធ្វើខ្លួនដូចតិរច្ឆាន គ្មានខ្លឹមក្នុងប្រាណបន្តិចសោះ ។

ផ្នែកគ្រហស្ថឃរាវាស អ្នកនៅគ្រប់គ្រងផ្ទះ បើខ្ជិលច្រអូសមិនឧស្សាហ៍ប្រកបការងារ តើនឹងបានទ្រព្យសម្បត្តិមកពីណា ? បើមិនមានទ្រព្យសម្បត្តិហើយ ច្បាស់ជាជួបប្រទះតែនឹងទុក្ខលំបាកជាមិនខាន ។

អាស្រ័យហេតុនេះ កុលបុត្រ កុលធីតាទាំងឡាយ ! អ្នកស្ថិតនៅក្នុងបឋមវ័យត្រូវប្រឹងប្រែងចំពោះការសិក្សា នូវចំណេះវិជ្ជា សព្វសារពើអោយមានប្រចាំនៅក្នុងខ្លួន ។

សុភាសិតមួយក្នុងលោកនីតិប្បករណ៍ពោលអះអាងថា៖

**អលសស្ស កុតោ សិប្បំ អសិបស្ស កុតោ ធនំ**

**អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សិវំ ។**

បើខ្ជិលច្រអូសហើយតើនឹងមានចំណេះវិជ្ជាមកពីណា ?

បើគ្មានចំណេះវិជ្ជាហើយតើនឹងមានទ្រព្យសម្បត្តិមកពីណា ? គ្មានទ្រព្យសម្បត្តិហើយតើនឹងមានមិត្តមកពីណា ? បើគ្មានមិត្តហើយ តើនឹងមានសេចក្តីសុខមកពីណា ? បើគ្មានសេចក្តីសុខហើយ តើនឹងមានបុណ្យមកពីណា ? បើគ្មានបុណ្យហើយសិរីមោក្ខយោគព្រះនិព្វានក៏គ្មានដែរ ។

បុរាណសុភាសិតលោកពោលថា :

កុំដេកចាំស្លាប់ អង្គុយចាំមាន ខ្ចាស់ល្ងង់ទើបចេះ ខ្ចាសក្រទើបមាន ដឹងខ្លួនថាល្ងង់គង់បានជាប្រាជ្ញ ។

**អលសស្សានុយោគ** ខ្ជិលធ្វើការងារមានទោស ៦ យ៉ាងគឺ

**១~អតិសីតំ** អាងថារងាណាស់ ហើយមិនធ្វើការងារ ។

**២~អតិឧណ្ហំ** អាងថាក្តៅណាស់ ហើយមិនធ្វើការងារ ។

**៣~អតិសាយំ** អាងថាល្ងាចណាស់ ហើយមិនធ្វើការងារ ។

**៤~អតិធាតោ** អាងថាព្រឹកណាស់ ហើយមិនធ្វើការងារ ។

**៥~អតិច្ឆាតោ** អាងថាឃ្លានណាស់ ហើយមិនធ្វើការងារ ។

**៦~អតិបិបាសិតោ** អាងថាស្រេកណាស់ ហើយមិនធ្វើការងារ ។

សាធុជនទាំងឡាយ កុំគប្បីអាងដល់ហេតុទាំង ៦ យ៉ាងនេះអោយសោះ បើអាងហេតុ ៦ យ៉ាងនេះ ច្បាស់ជាជួបប្រទះនឹងសេចក្ដីវិនាសដោយពិតដូចជាកុសីតមាណព សូមនាំនិទាននោះមកដំណាលដូចតទៅនេះ :

មានមាណពម្នាក់ឈ្មោះកុសីតមាណព ប្រែថាកម្លោះកជិល,ថ្ងៃមួយអ្នកភូមិផងរបងជាមួយបានបបួលគ្នាជាច្រើនទៅរកឧសឯព្រៃ លុះទៅដល់ព្រៃហើយ គេគ្រប់គ្នាខំប្រឹងប្រែងស្រវាស្រទេញ រកកាប់ឧស មិនបង្អែបង្អង់ដៃសោះ កុសីតមាណព ឃើញដើមថ្នាន់មួយដើមជ្រុះស្លឹកអស់ហើយប្រាស់ប្រាណដេកគងអន្ទាក់ខ្លាធ្វើអាំងអើយនៅក្រោមដើមថ្នាន់នោះដោយគាត់នឹងសង្ឃឹមថា អញភ្ញាក់ពីដេកនឹងកាច់មែកថ្នាន់នោះធ្វើឧសពិតជាបានមួយអំរែកធំ, តែផ្ទុយទៅវិញដើមថ្នាន់នោះដល់ខែជ្រុះស្លឹកអស់មានងាប់ឯណា មែកវានៅស្រស់ញញឹម, លុះដល់ពេញល្ងាចជិតត្រឡប់មកផ្ទះវិញ អ្នកផងគេបានឧសមួយអំរែកធំ គ្រប់ៗគ្នា កុសីតមាណព លុះក្រទីក្រទាឡើងទៅកាច់មែកថ្នាន់ទាញចុះទាញឡើង បាក់មែកថ្នាន់នោះបុកចំឯភ្នែកខ្វាក់ទៅ ឱ ! គួរអាសូរកុសីតមាណព ឧសក៏មិនបានភ្នែកក៏ខ្វាក់ ។

នាំនិទាននេះមកដើម្បីបញ្ជាក់អោយឃើញច្បាស់ថា សេចក្ដីខ្ជិលច្រអូសអោយទោសច្រើនប្រការដូចបានពណ៌នាមកខាងលើនេះ ។

សេចក្តីនេះសមដូចសុភាសិតដែលលោកនិពន្ធទុកមកថា ខ្ជិលបង្អិនលោក ខ្ជិលបានទុក្ខសោក ខ្ជិលអប្បប្រាជ្ញា ខ្ជិលធ្លាក់នរក ខ្ជិលអត់វិជ្ជា ខ្ជិលថោកសាសនា ខ្ជិលជាតិលិចលង់ ។

វិធីកំចាត់បង់នូវសេចក្តីខ្ជិលមាន ១១ យ៉ាង :

**១-អបាយភយប្បច្ចវេក្ខណា** ត្រូវពិចារណានូវភ័យក្នុងអបាយ ។

**២-អានិសង្សទស្សាវី** ជាអ្នកឃើញនូវអានិសង្សនៃសេចក្តីឧស្សាហ៍ ។

**៣-គមនវិថីប្បច្ចវេក្ខណា** ឧស្សាហ៍ពិចារណានូវផ្លូវនៃដំណើរព្រះពុទ្ធអង្គ និងអរិយសង្ឃ ។

**៤-បិណ្ឌបាតាបចាយនៈ** គោរពចំពោះបិណ្ឌបាតដែលគេអោយ ។

**៥-ទាយជ្ជមហត្តប្បច្ចវេក្ខណា** ឧស្សាហ៍ពិចារណានូវមតិកដ៏ប្រសើរ គឺអរិយទ្រព្យទាំង ៧ ។

**៦-សត្ថុមហត្តប្បច្ចវេក្ខណា** ឧស្សាហ៍ពិចារនាថា ព្រះបរមសាស្តាជាបុគ្គលដ៏ប្រសើរ ។

**៧-ជាតិមហត្តប្បច្ចវេក្ខណា** ឧស្សាហ៍ពិចារណានូវជាតិដ៏ខ្ពង់ខ្ពស់របស់ព្រះសាស្តា ។

**៨-សព្រហ្មចារិមហត្តប្បច្ចវេក្ខណា** ឧស្សាហ៍ពិចារណានូវគុណធម៌ខ្ពង់ខ្ពស់របស់ព្រហ្មចារីបុគ្គល ។

**៩-កុសីតបុគ្គលបរិវជ្ជនៈ** វៀរចាកបុគ្គលដែលខ្ជិលច្រអូស ។

**១០.អារទ្ធវិរិយបុគ្គលសេវនៈ** សេពគប់តែនឹងបុគ្គលអ្នកមានព្យាយាម ។

**១១.តទធិមុត្តតា** បង្អោនចិត្តទៅក្នុងវិរិយសម្ពោជ្ឈង្គ ។

ពុទ្ធភាសិតមានមកក្នុងខុទ្ទកនិកាយធម្មបទព្រះអង្គសំដែងថា :

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយមានការមិនស្វាធ្យាយទន្ទេញជាមន្ទិល ផ្ទះមានការមិនប្រក់បិទបាំងជាមន្ទិល សេចក្ដីខ្ជិលជាមន្ទិលនៃការថែរក្សា ។

ពាក្យថា "មន្ត" ទាំងឡាយសំដៅយកចំណេះវិជ្ជា សព្វសារពើ បានដល់វិជ្ជាសិល្ប៍ សាស្ត្រទាំង ១៨ ប្រការ ។

| | |
|---|---|
| **១.សុតិ** | សេចក្ដីចេះសព្វ |
| **២.សម្មុតិ** | ការចូលចិត្តរបៀន |
| **៣.សង្ខ្យា** | ការរាប់ចំនួន |
| **៤.យោគយន្តរៈ** | ការសិក្សា |
| **៥.នីតិ** | នីតិសាស្ត្រា |
| **៦.វិសេសិកា** | វិជ្ជាជំនួញ |
| **៧.គន្ធព្វា** | វិជ្ជារបាំ |
| **៨.គណិកា** | វិជ្ជាកំលាំងកាយ |

**៩. ធនុព្វេធា** វិជ្ជាបាញ់ធ្នូ

**១០. តិកិច្ឆា** វិជ្ជាពេទ្យ

**១១. បុរាណា** វិជ្ជាបុរាណ

**១២. ឥតិហាស** វិជ្ជាកាព្យឃ្លោង

**១៣. ជោតិ** វិជ្ជាតារាសាស្ត្រ

**១៤. មាយា** វិជ្ជាសង្គ្រាម

**១៥. កេតុ** វិជ្ជានិយាយ

**១៦. មន្តា** វិជ្ជាមន្ត

**១៧. សទ្ទា** វេយ្យាការណ៍

**១៨. ពុទ្ធវចនៈ** វិជ្ជាពុទ្ធវចនៈ ។

មន្តទាំងអស់នេះ ដែលចេះចាំទៅបាន ដោយសេចក្តីប្រឹងប្រែង ទន្ទេញស្វាធ្យាយ ទើបចាំចេះទៅបានបើមិនទន្ទេញស្វាធ្យាយទេនោះ រមែងជាមន្ទិល ពាក្យថា មន្ទិល គឺមិនចាំ មិនចេះដឹង មិនយល់ ។ វិជ្ជាទាំងអស់នេះ បើចេះចាំពិតប្រាកដហើយ តែងតែបានទទួលយសស័ក្តិឋានៈថ្កុំថ្កើង ជាមិនខាន សមនឹងសុភាសិតថា :

ចេះមួយ ចេះពី អោយតែចេះស្ទាត់ ប្រកបប្រាកដនៃអ្នកចំណាន ជាហេតុចិញ្ចឹមជីវិតខ្លួនបាន សន្តានជួលពឹងពំនឹងអើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះពុទ្ធអង្គទ្រង់សំដែងថា ៈ

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។**

យសស័ក្តិដែលចំរើន ដល់បុរសស្រ្តីក្នុងលោក ដោយគុណធមិ៧ ប្រការគឺៈ អ្នកមានការពិចារណាហើយទើបធ្វើមួយ១, អ្នកសង្រួម១, អ្នករស់នៅប្រកបដោយធមិ១, អ្នកមិនប្រមាថ១ ។

បុរសស្រ្តីក្នុងលោកនេះ ចង់បាននូវកេរ្តិ៍ឈ្មោះ កិត្តិយស កិត្តិគុណ កិត្តិនាម កិត្តិស័ព្ទ ត្រូវកុំខ្ជិលច្រអូស ហើយខំប្រព្រឹត្តប្រតិបត្តិនូវធមិទាំង ៧ ប្រការដូចពោលមកនេះ រមែងជួបប្រទះមិនខានឡើយ ។

បទថា **កោធបញ្ញាណោ** បានសេចក្តីថា (អ្នកខឹងច្រើន) ។ បណ្តាលមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាបុរសស្រ្តីទេ, មនុស្សជំពូកខ្លះ ដោយខ្វះខន្តីធមិ គឺសេចក្តីអត់ទ្រាំ និងមេត្តាធមិ គឺសេចក្តីស្រណោះ អាណិតចិត្តទន់ ជាអ្នកឆាប់ក្រោធខឹង អោយតែមានហេតុទាស់អារម្មណ៏ភ្លាម ក៏ឆាប់ខឹងឆេវឆាវ ឥតគិតពិចារណាដេញដោល ស្ទាបស្ទង់រកហេតុផល ពាក្យចាស់ពោលតែងពោលថា " មនុស្សចិត្តអាវេស " គឺមនុស្សឆាប់ខឹង ។ មនុស្សណាតែឆាប់ក្រោធខឹង ញាតិមិត្តជិតឆ្ងាយទាំង-ឡាយតែងចៀសវាងខ្លាចនូវមនុស្សនោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះពុទ្ធដីកាត្រាស់សំដែងថា :

**ញាតិមិត្តា សុហជ្ជា ច បរិវជ្ជេតិ កោធនំ**

ញាតិមិត្តទាំងឡាយ តែងចៀសវាងនូវបុគ្គលហៃក្រោធ, គឺមនុស្សចិត្តស្រាលឆាប់ខឹង ។

សេចក្តីក្រោធខឹងជាកិលេសធម៌ ហើយជាបហានធម៌ ត្រូវកំចាត់បង់អោយអស់ពីខន្ធសន្តាន ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា :

**កោធំ ឃត្វាសុខំ សេតិ**,សម្លាប់សេចក្តីក្រោធបានទើបដេក ជាសុខ។

**កោធំ ឃត្វា នសោចតិ**, សម្លាប់សេចក្តីក្រោធបាន ទើបមិនសោយសោក ។

**អប្បោ ហុត្វា ពហុ ហោតិ វឌ្ឍតេ សោ អខន្តិជោ** , សេចក្តីក្រោធនេះកើតឡើងព្រោះ មិនមានសេចក្តីអត់ធន់ តែងចំរើនឡើងទោះបីតិចក៏ទៅជាច្រើនបាន ។

**កោធនោ ទុព្វណ្ណោ ហោតិ**,អ្នកក្រោធជាអ្នកមានសម្បុរអាក្រក់ ។

ទោសនៃសេចក្តីក្រោធ :

អ្នកមានសេចក្តីក្រោធ ស្លាប់ទៅច្រើនទៅកើតក្នុងអបាយ បើមិនដូច្នោះទេ បើកើតជាមនុស្សច្រើនមានរោគ សម្បុរអាក្រក់ កើតក្នុងត្រកូលថោកទាប ។

អានិសង្សនៃសេចក្ដីមិនក្រោធៈ អ្នកមិនក្រោធ ស្លាប់ទៅច្រើនទៅកើតក្នុងឋានសួគ៌ទេវលោក បើមិនដូច្នោះ បើកើតជាមនុស្ស ច្រើនមិនមានរោគ មានសម្បុរស្អាតល្អ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ។ កោធៈ សេចក្ដីក្រោធ កាលបើកើតឡើងហើយក៏សមុដ្ឋាននៃទោស ព្រះពុទ្ធដីកាថា **ទោសោ កោធ សមុដ្ឋានោ** ទោសៈមានសេចក្ដីក្រោធជាសមុដ្ឋាន។

កោធៈ សេចក្ដីក្រោធ កើតនាំអោយកើតទោសប្រទូស្តចំពោះសត្វនឹងសង្ខារ ។

តែបើជនណាមួយ បានប្រទូស្តចំពោះជនណាមួយនោះ ហើយគេមិន ប្រទូស្តតបក៏រាប់ថាជាសិរីក្នុងលោក ។ ការសំដែងមកក្នុងគាថាទី ៣ នៃបរាភវសូត្រ ដែលមានសេចក្ដីថា ៈ

អ្នកដេកច្រើន១, និយាយច្រើន១, និងអ្នកឥតព្រួយឥតគិតប្រឹង-ប្រែងអ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង ខឹងច្រើនសំដែងអោយគេឃើញបាន។

ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំអោយខកខានខូចប្រ-យោជន៍ មានជាប្រធានតិចច្រើនដោយហោច នាំបង់ប្រយោជន៍ហើយអោយវិនាស ។

ការសម្ដែងមកនេះក៏សន្មត់ថា

ចប់តែប៉ុណ្ណេះ ឯវំ ។

# ធម្មទេសនា បរាភវសូត្រ

## នមោ តស្ស

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

**អរហំ សម្មាសម្ពុទ្ធោ ភគវាពុទ្ធំ ភគវន្តំ អភិវាទេមិ** ព្រះពុទ្ធជាម្ចាស់ ព្រះអង្គឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវធម៌ប្រពៃដោយព្រះអង្គឯងទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគអង្គនោះ ។

**ស្វាក្ខាតោ ភគវតោ ធម្មោ ធម្មំ នមស្សាមិ,** ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងប្រពៃហើយ, ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះធម៌ ។

**សុបដិបន្នោ ភគវតោ សាវក សង្ឃោ សង្ឃំ វន្ទាមិ,** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិតាមប្រពៃហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះធម៌ ។

បទនមស្ការ សូមសង្ខេបបែបខ្លីតែប៉ុណ្ណេះ បន្ទាប់មកអំពីនេះទៅ សូមលោកយកគាថាទី៤ នៃបរាភវសូត្រមកបកស្រាយអធិប្បាយពន្យល់ន័យ ជូនជាទីសណ្តាប់ ដល់ពុទ្ធមាមិកជនទាំងអស់ ដែលបានអញ្ជើញមកសន្និបាត ជួបជុំប្រមូលផ្តុំក្នុងទីនេះ ដោយមានបំណងប៉ងនិងស្តាប់នូវព្រះ-ធម៌វិសេសទេសនា ខ្ញុំព្រះករុណាអាត្មាភាព ខ្ញុំនិងបានសំដែងដូចតទៅនេះ:

ទេវតាទូលសួរតទៅទៀតថា ៖

**ឥតិហេតំ វិជានាម តតិយោ សោ បរាភវោ ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ វិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៣ ទានហន់ ។ បពិត្រព្រះ-អង្គព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងអោយទាន វិនាសទី៤ អ្វីជាប្រធាននាំសត្វអោយមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះ ទេវតាថា ៖

**យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ បហុសន្តោ ននភរតិ តំ បរាភវតោ មុខំ ។**

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចិញ្ចឹមរក្សាមាតាបិតា ដែលចាស់ជរា ហេតុនោះទៅជានាំអោយវិនាស ។

## អធិប្បាយ

## គាថាទី ៤

តាមសេចក្តីបរមត្ថ ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា ៖

**អយំ កាយោ រូបី ចាតុម្មហាភូតិកសម្ភវោ ឱទនកុម្មាសុបចយោ,** ប្រែថា រូបកាយ ដែលមានមហាភូតរូបទាំង ៤ នេះកើតឡើងអំពីមហាភូតរូបរបស់មាតាបិតា ដែលចំរើនឡើងដោយបាយទឹកនំចំណី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដែលមាតបិតាចិញ្ចឹម ។ មនុស្សក្នុងលោក សុទ្ធតែកើតអំពីអាហារដែលមាតាបិតាបរិភោគហើយកើតជាសាច់ឈាម នោះទាំងអស់គឺ មាតាបិតាបរិភោគអាហារណា អាហារនោះឯង តែងកើតទៅជាសាច់ឈាម ហើយសាច់ឈាមអ្នកទាំងពីរនោះ ផ្សំគ្នាទើបបានកើតមកជាកូន កើតបានជាកូនហើយមាតាបិតាចិញ្ចឹមកូន ចិញ្ចឹមកូនដោយបាយទឹកនំចំណីថែមទៀតទើបលោកពោលថា កូនជាកូនបំណុល ។ ដូច្នេះកូនៗដែលបានបុលបំណុលណាពីមាតាបិតា ត្រូវតែសងបំណុលនោះ គឺត្រូវចិញ្ចឹមលោកវិញ ។ កូនណាមិនបានសងបំណុលឈ្មោះថា អកតញ្ញូ អកតវេទី ជំពាក់បំណុលលោក កូនណា បានសងហៅថា កតញ្ញូ កតវេទី រួចបំណុលលោក ។

កិច្ចដែលកូនត្រូវសងបំណុលឈាមរបស់មាតាបិតានោះ ដោយខ្លីគឺមាតាបិតាចិញ្ចឹមកូនដោយបច្ច័យណាមួយ កូនត្រូវតែចិញ្ចឹមមាតាបិតាដោយបច្ច័យនោះវិញ ។

បច្ច័យនោះមាន ៤ យ៉ាងគឺៈ

**១.ចីវរប្បច្ច័យ** គ្រឿងស្លៀកពាក់

**២.បិណ្ឌបាតប្បច្ច័យ** គ្រឿងបរិភោគ

**៣.សេនាសនប្បច្ច័យ** គ្រឿងដេកអង្គុយ

**៤.ភេសជ្ជប្បច្ច័យ** គ្រឿងថ្នាំរោគ

Websites: WatKhemaraRatanaram.org or WatKhmers.org

មាតាបិតាណាបានទទួលសំណោងជាបច្ច័យ ៤ យ៉ាងនោះពីកូន ពេលណាហើយ មាតាបិតានោះតែងបាននូវឋានៈ ៥ យ៉ាងគឺៈ

**១.អាយុ** ធម្មជាតិគ្រឿងរស់ដោយយូរ

**២.សុខៈ** សុខកាយសប្បាយចិត្ត

**៣.វណ្ណៈ** ពណ៌សម្បុរកាយស្រស់ល្អ

**៤.ពលៈ** កម្លាំងកាយ កម្លាំចិត្ត

**៥.បដិភាណៈ** គំនិតប្រាជ្ញាឈ្លាសវៃ ។

កូនណាបានចិញ្ចឹមមាតាបិតាដោយបច្ច័យ ៤ កូននោះបានឈ្មោះថា អោយនូវឋានៈ ៥ យ៉ាង ដល់មាតាបិតា ក្នុងជាតិបច្ចុប្បន្ន ហើយកូននោះរមែងតែងបានទទួលនូវឋាន ៥ យ៉ាងដល់ខ្លួនវិញក្នុងជាតិជាបរលោក បើការចិញ្ចឹមនោះខ្ពង់បំផុត នឹងបានផលជាទិដ្ឋធម្មវេទនី ឃើញទាន់ភ្នែកក្នុងជាតិបច្ចុប្បន្ន យ៉ាងពិតប្រាកដ ដូចក្នុងជាតកមានរឿងមួយដូចតទៅនេះ :

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ ជាមនុស្សចេះលៃលកចាយទ្រព្យសម្បត្តិត្រូវតាមគន្លងធម៌ ។

កាលបិតាស្លាប់ទៅ បុរសចិញ្ចឹមមាតា ព្រមទាំងកូនប្រពន្ធដោយការកាប់ឧសលក់ ។ ថ្ងៃមួយបុរសនោះបររទេះគោទៅកាប់អុសក្នុងព្រៃ បានឧសផ្ទុកពេញកំពុងរទេះ ហើយហេតុតែចង់បានឧសច្រើន ក៏ដឹកគោដឹក

ឧស ហើយខ្លួនរែកឧស មួយអំរែកដើរពីមុខរទេះ ។ គាប់ជួនពេលនោះ ព្រះរាជា ស្តេចចេញប្រពាធព្រៃ ទ្រង់ទតឃើញប្លែក ពីគេទ្រង់អោយហៅ បុរសនោះមកទ្រង់សួរថា: នែបុរសអ្នកឯងខុសពីគេអ្វីម្លេះ ដឹកឧសពេញ រទេះហើយ ម្តេចក៏រែកឧសដើរមុខគោថែមទៀត យកឧសទៅធ្វើអ្វីខ្លះ ?

បុរសនោះទូលថា ឧសនេះទូលព្រះបង្គំយកទៅលក់បានកហាបណៈ មកយកមកបែងចែកជា ៤ ភាគគឺ :

**ភាគទី១** បុលបំណុលចាស់ គឺចិញ្ចឹមមាតាបិតា

**ភាគទី២** ដោះបំណុលថ្មីគឺចិញ្ចឹមបុត្រ

**ភាគទី៣** កប់ទុកក្នុងផែនគឺធ្វើទាន

**ភាគទី៤** បោះចោលទៅក្នុងជ្រោះជ្រៅ គឺបង់ក្នុងទ្វារទាំង៦ មាន ទ្វារមាត់ជាដើមរបស់ខ្លួន និងភរិយាដែលមានទំហំតូចទេ តែមានជំរៅជ្រៅ ក្រៃពេក មិនអាចបំពេញបាន ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ ស្ងើចទ្រង់ព្រះរាជទានទ្រព្យសម្បត្តិ និងយសស័ក្តិ ដល់បុរសនោះ ។ បាន សេចក្តីសុខចំរើន ក្នុងបច្ចុប្បន្នទាន់ភ្នែកនាលោកនេះ លុះលះលោកយើង ទៅបុរសនោះបានទៅកើតក្នុងទេវលោក សោយសម្បត្តិទិព្វអស់កាលជា យូរអង្វែង ។

ព្រះពុទ្ធសាសនា ចែកបុគ្គលជាគូគ្នា មាន ៣ ពួកគឺ

១-មាតា បិតា ជាគូនឹងបុត្រ

២-ព្រះពុទ្ធ ជាគូនឹងពុទ្ធបរិស័ទ

៣-គ្រូជាគូនឹងសិស្ស ។

មាតាបិតា ជាបុព្វការី អ្នកធ្វើឧបការមុន , បុត្រជាអ្នកកតញ្ញូ កតវេទី អ្នកដឹងគុណដែលមាតាបិតា បានធ្វើដល់ខ្លួន ហើយបានសងគុណលោកវិញព្រះពុទ្ធជាបុព្វការី ពុទ្ធបរិស័ទ ជាកតញ្ញូ កតវេទី ។ គ្រូជាបុព្វការី សិស្សជា កតញ្ញូកតវេទី ។

បុគ្គលជាគូគ្នា ៣ ពួកនេះ មានសេចក្តីអធិប្បាយវែងឆ្ងាយណាស់តែក្នុងទីនេះ សូមអធិប្បាយតែចំពោះគូទី១ មាតាបិតា ជាគូគ្នានឹងបុត្រធីតា ដោយសង្ខេបដូចតទៅនេះ លោកអោយឈ្មោះមាតាបិតាថា :

ជាព្រហ្មរបស់បុត្រព្រោះមានព្រហ្មវិហារធម៌ ៤ យ៉ាងចំពោះបុត្រ ។

ព្រហ្មវិហារធម៌ ៤ យ៉ាងនោះគឺ :

**១-មេត្តា** សេចក្តីរាប់អានបុត្រ

**២-ករុណា** សេចក្តីអាណិតអាសូរបុត្រ

**៣-មុទិតា** ចិត្តទោរទន់ទៅរកបុត្រ

**៤-ឧបេក្ខា** ចិត្តព្រងើយកន្តើយចំពោះបុត្រ,

**មេត្តា** របស់មាតា បិតា មានប្រាកដចំពោះបុត្រ ក្នុងពេលបុត្រជាទារកនៅក្នុងផ្ទៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ករុណា** របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលប្រសូត្រហើយ **មុទិតា** របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលបុត្រមានវ័យធំឡើង **ឧបេក្ខា** របស់មាតាបិតា មានប្រាកដចំពោះបុត្រក្នុងពេលរៀបចំបុត្រអោយមានគូស្រករហើយ ។

**បុព្វាចារ្យ** គ្រូដើមរបស់បុត្រ ព្រោះជាអ្នកបង្ហាត់បង្រៀនច្រើនយ៉ាង មានបង្ហាត់អោយចេះនិយាយស្តី ភាសាជាតិ នឹងបង្ហាត់ក្នុងឥរិយាបថទាំង ៤ អោយចេះ ដេក ដើរ ឈរ អង្គុយ ជាដើម, ឯគ្រូដែលបង្រៀនអក្សរលេខជាដើម នោះហៅថា បច្ឆាចារ្យ "គ្រូចុង" គ្រូក្រោយ ។ ពោលដោយសង្ខេប ដោយហេតុមាតាបិតាជាព្រហ្មរបស់បុត្រ ព្រោះមានព្រហ្មវិហារធម៌ចំពោះបុត្រ និងជាគ្រូដើមមុនរបស់បុត្រ ដូចពោលមកនេះបានជាលោកថា មាតាបិតាគុណធ្ងន់គុណធំ គុណច្រើនជាទីបំផុតលើបុត្រធីតា រកអ្វីប្រៀបពុំបាន ។

បើនិយាយពីធ្ងន់ និងយកទម្ងន់មហាប្រិថពី ឬ ភ្នំព្រះសុមេរុមកថ្លឹងផ្ទឹមគ្នា ក៏ធ្ងន់ពុំស្មើ បើនិយាយពីធំ និងយកទំហំក្រឡាមហាប្រឹថពី ឬ ភ្នំព្រះសុមេរុមកវាស់ផ្ទឹមគ្នាក៏ពុំធំស្មើរ បើនិយាយពីច្រើន និងយកគ្រាប់ខ្សាច់ក្នុងមហាសមុទ្រក្នុងលោកមកពណិនា ត្រារាប់ផ្ទឹមគ្នាក៏ច្រើនពុំស្មើ ។

ជាពិសេសលោកថា មាតាបិតា ជាព្រះអរហន្តរបស់បុត្រធីតា ជាព្រះក្នុងផ្ទះ សំរាប់បុត្រធីតា ធ្វើសក្ការបូជានៅផ្ទះ ។ ព្រះអរហន្តទាំងនេះ

ជាព្រះអរហន្តខាងក្រៅ ។ ការបូជាដោយទេយ្យវត្ថុដល់ព្រះអរហន្តខាងក្នុង និងព្រះអរហន្តខាងក្រៅបានបុណ្យប៉ុនគ្នា តែព្រះអរហន្តក្នុងខាយបូជាជាងព្រះនៅក្នុងផ្ទះ ជាមួយគ្នា ឬជិតគ្នា តែមិនដូច្នេះបុត្រធីតាដែលខ្វះវិចារណញ្ញាណច្រើនតែមើលមាតា បិតាមិនឃើញ មិនបូជាបែរទៅជាឃើញ ទៅបូជាមាន លើកដៃសំពះជាដើម ដល់អ្នកដទៃ ក្រៅទៅវិញ ។

ឯមាតាបិតាឯង ដូចជាស្ពាយទេយ្យវត្ថុណាស់ បូជាមិនកើតដូចជាធ្ងន់ដៃណាស់ លើកដៃសំពះមិនរួច ។

បោរាណបណ្ឌិត លោកឃើញពិត ឃើញមែនដូចនិយាយមកនេះ ទើបលោកចងជាសុភាសិតថា :"បង់ព្រះទៅសំពះប្រយ៉ាបបង់បញ្ចមហា-ប្រាសាទទៅនៅឯព្រៃភ្នំ " មួយទៀតឆ្អឹងធាតុមាតាបិតារបស់ខ្លួន កូនមិនហ៊ានទុកនៅក្នុងផ្ទះ យូរថ្ងៃទេ តែបើខាងឆ្អឹងធាតុសត្វ មានស្នែងគោ ស្នែងក្របី ស្នែកប្រើស ក្តាន់ កុយ ភ្លុក ជាដើម បែរជាយកមកតាំងទុកជាលំអសក្ការ លើផ្ទះឥតខ្លាចទៅវិញ ។

ដោយហេតុពួកបុត្រធីតា ដែលមានមោហគ្របសង្កត់ ខ្វះវិចារណ-ញ្ញាណ ច្រើនតែយល់ខុសចំពោះគុណមាតាបិតា ដូចពោលមកនេះ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនាថា " បុគ្គលពីរពួកគឺ បុព្វការីអ្នកធ្វើគុណដល់គេមុន១ កតញ្ញូកតវេទី អ្នកដឹងនូវគុណគេ ១, ជាបុគ្គលរកដោយកម្រក្នុងលោក " ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ជនដែលមានវិចារណញ្ញាណ ដឹងគុណគេនឹករលឹកគុណគេនោះ កុំថាឡើយដល់ទៅទទួលពីគេច្រើនណាស់នោះ សូម្បីតែទទួលនូវបាយមួយវែកពីនរណា ក៏នឹកឃើញគុណអ្នកនោះហាក់ដូចជាធំដុំណាស់ ដូចព្រះសារីបុត្រជាអគ្គសាវ័កនៃព្រះបរមគ្រូលោកជាអ្នកដឹងគុណជាទីបំផុត មានសេចក្តីដំណាលថា ៖ រឿងរពះសារីបុត្រ កាលព្រះសម្មាគង់នៅក្នុងវត្តជេនពនមានព្រាហ្មណ៍ចាស់ម្នាក់ឈ្មោះរាធៈ ជាអ្នកក្រីក្រចង់បួសក្នុងព្រះពុទ្ធសាសនា បានចូលទៅថ្វាយបង្គំព្រះបរមសាស្តា សុំបួសព្រះអង្គត្រាស់ថា ធម្មតាមនុស្សចាស់ជរា លុះតែមានគេ ឧបត្ថម្ភទើបបាន ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកសួរថា " ភិក្ខុណាអាចទទួលចិញ្ចឹមរក្សា ព្រាហ្មណ៍ចាស់នេះបានទេ ! បើគាត់បួសហើយ ? គ្រានោះព្រះសារីបុត្រក្រាបបង្គំទូលថា "ខ្ញុំព្រះអង្គអាចចិញ្ចឹមបាន ព្រោះព្រាហ្មណ៍នេះ គាត់មានគុណលើកខ្ញុំព្រះអង្គដោយបានប្រគេនចង្ហាន់ដល់ខ្ញុំព្រះអង្គមួយវែកម្តង " ។ ព្រះអង្គមានព្រះពុទ្ធដីកាថា "បើដូច្នោះចូរអ្នកយកព្រាហ្មណ៍នេះទៅបំបួស ហើយចិញ្ចឹមគាត់អោយបានសុខសប្បាយព្រមទាំងទូន្មានធម៌វិន័យអោយគាត់បានសម្រេចមគ្គផលផង ។ ព្រះសារីបុត្រក៏ទទួលយកព្រាហ្មណ៍នោះទៅបំបួសហើយចិញ្ចឹមរក្សាប្រដៅធម៌វិន័យអោយបានសំរេចមគ្គផលដោយរហ័ស ។ ភិក្ខុទាំងឡាយសរសើរព្រះសារីបុត្រថា ជាកំពូលនៃអ្នកកតញ្ញូកតវេទិបុគ្គល ដឹងគុណអ្នកមាន

គុណ បានសងគុណ អ្នកមានគុណលើខ្លួន ដោយរីករាយ មិនបំភ្លេចគុណគេឡើយ ។

មង្គលត្ថទីបនីអដ្ឋកថាមង្គល សូត្រអធិប្បាយ ភិក្ខុសាមណេរ ក៏ត្រូវតែគោរពប្រណិប័តន៏មាតាបិតា ចិញ្ចឹមរក្សាដោយអាហារភោជន៏ ដោយថ្នាំសង្កូវ ដោយគត់ច្របាច់កាន់លើកដាក់ ចំណែកខាងមាតាមិនចាំបាច់ធ្វើកិច្ចគត់ច្របាច់ ចាប់កាន់ពាល់ត្រូវទេ ព្រោះជាបព្វជិតចាប់កាន់ពាល់ត្រូវពុំបាន, កិច្ចក្រៅពីនេះចាប់កាន់ពាល់ត្រូវធ្វើបានទាំងអស់ ។

ក្នុងវិន័យមានពុទ្ធប្បញ្ញត្តិថា អាហារថ្មោងថ្មី ដែលភិក្ខុទើបនឹងទទួលពីភាជន៏មក បើខ្លួនមិនទាន់ឆាន់ទេ នឹងចាប់អោយនរណាបរិភោគមុនខ្លួនពុំបាន បើចាប់អោយមុនត្រូវអាបត្តិទុក្កដ បើមាតាបិតាចាប់អោយបាន ឈ្មោះថាចិញ្ចឹមមាតាបិតា បានផលច្រើនណាស់ទៅវិញ ។

ព្រះពោធិសត្វ ដែលបានសាងពោធិសម្ភារតែងមានកតញ្ញូ កតវេទីតាធមិ ជាដរាបរាល់ព្រះអង្គ ដូចព្រះពោធិសត្វ គឺព្រះពុទ្ធជាម្ចាស់នៃយើងកាលដែលមានព្រះជាតិជាសុវណ្ណសាមទ្រង់ដឹងគុណមាតាបិតាណាស់ ។

បន្ទាប់ពីនេះសូមនាមរឿង កុលបុត្រភិក្ខុគឺ ភិក្ខុចិញ្ចឹមមាតាបិតាដើម្បីបញ្ជាក់អោយច្បាស់ថា ភិក្ខុសាមណេរ ក៏អាចបំរើមាតាបិតាបាន ។

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេនពន មានភិក្ខុ១ រូបចេញចាកវត្តទៅចំរើនធមិក្នុងព្រៃជាយូរឆ្នាំ ។ ថ្ងៃមួយមានភិក្ខុទៅពីស្រុក

មាតាបិតារបស់លោក ទៅជួបនឹងលោក។ សួរដំណឹងពីមាតាបិតា ។ ភិក្ខុនោះប្រាប់ថា "មាតាបិតារបស់លោក ឥឡូវនេះចាស់ជរាណាស់ហើយ ធ្លាក់ខ្លួនជាអ្នកក្រ សព្វថ្ងៃកាន់អំបែងដើរសុំទានគេបរិភោគ " ។ កាលបើបានឮដំណឹងនោះ ភិក្ខុនោះក៏ស្លុតចិត្តអាណិតមាតាបិតាជាខ្លាំង ហើយចេញដំណើរពីក្នុងព្រៃជាប្រញាប់ ដើម្បីទៅរកមាតាបិតា ។

លុះលោកទៅជិតវត្តជេតពន មានផ្លូវបែកជាពីរ ផ្លូវមួយទៅវត្តជេនពន ផ្លូវមួយទៅចំផ្ទះមាតាបិតាលោក។ ឈរគិតថា " អញត្រូវសឹកជាគ្រហស្ថទៅចិញ្ចឹមមាតាបិតាតែម្តង ឬទៅថ្វាយបង្គំព្រះបរមគ្រូសិន" លោកគិតឃើញថា ទោះបីយ៉ាងណាអញត្រូវតែទៅវត្តស្តាប់ព្រះធម៌ពុទ្ធអង្គសិន ហើយលោកក៏ចូលទៅវត្តជេតពន ថ្វាយបង្គំព្រះអង្គ អង្គុយស្តាប់ព្រះធម៌ជាមួយភិក្ខុទាំងឡាយ ។

វេលានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទាន ឱវាទថា "ភិក្ខុដែលមាតាបិតាចាស់ជរាត្រូវចិញ្ចឹមដោយចង្ហាន់បិណ្ឌបាតជាដើមបាន " ។

លុះចប់ព្រះធម៌ទេសនា ភិក្ខុនោះចេញចាកវត្តជេនពន ទៅរកមាតាបិតាលោក ហើយលោកឃាត់មាតាបិតាមិនអោយដើរសុំទានគេអោយចាំទទួលបាយ និងម្ហូបចំណីពីលោក ។ លំដាប់ពីថ្ងៃនោះ ភិក្ខុនោះក៏ត្រាច់បិណ្ឌបាតតាមចន្លោះភូមិនានាបានចង្ហាន់មកហើយ យកទៅជូនមាតាបិតាបរិភោគជាមុនសិន ទើបលោកឆាន់ជាក្រោយ ជួនកាលលោក

Websites: WatKhemaraRatanaram.org or WatKhmers.org

បានអាហារតិច លោកជូនមាតាបិតាទាំងអស់ ហើយត្រាច់ទៅបិណ្ឌបាតទៀតយកមកឆាន់ខ្លួនឯង ជូនកាលថ្ងៃណាទៅបិណ្ឌបាត លើកក្រោយមិនបាន លោកអត់ចង្ហាន់មួយថ្ងៃក៏មាន ជួនកាលលោកបានសំពត់អាវ លោកយកទៅជូនមាតាបិតាលោក ។

ភិក្ខុទាំងឡាយកាលឃើញដូច្នោះ ភិក្ខុខ្លះ ក៏សរសើរ ភិក្ខុខ្លះក៏ពោលទោស ពួកភិក្ខុពោលទោសបាននាំសេចក្ដីនោះទៅក្រាបបង្គំទូលព្រះ-សម្ពុទ្ធថា "នៅទីឯណោះមានភិក្ខុមួយរូបផ្គាប់ផ្គន់បុរសស្រ្ដីទាំងពីរដោយញាំុងដុំបាយដែលទាយក អោយដោយសទ្ធាអោយធ្លាក់ក្នុងដៃបុរសស្រ្ដីនោះ" ព្រះដ៏មានបុណ្យទ្រង់អោយហៅភិក្ខុនោះមកទ្រង់សួរថា " នែភិក្ខុអ្នកអោយបាយថ្នាំងថ្មីដែលទាយកគេអោយដោយសទ្ធា ទៅបុគ្គលណាបុគ្គលនោះត្រូវជាអ្វីនឹងអ្នក ? ភិក្ខុនោះទូលថា " បុគ្គលនោះជាមាតាបិតារបស់ខ្ញុំព្រះអង្គ គាត់ចាស់ជរាណាស់ហើយ ដើរសុំទានគេបានជាខ្ញុំចិញ្ចឹមគាត់ " ។ ព្រះអង្គមានព្រះបន្ទូលថា "នែភិក្ខុ ! អំពើដែលអ្នលបានធ្វើនោះល្អណាស់ ត្រូវតាមប្រពៃណី ដែលបោរាណបណ្ឌិតលោកធ្លាប់បានធ្វើមកហើយ ហៅថាកតញ្ញូកតវេទិតាធម៌ តថាគតកាលនៅជាពោធិសត្វ ក៏បានប្រព្រឹត្តធម៌នោះយ៉ាងម៉ត់ចត់ ។ ដោយផលានិសង្សនៃកត្តញ្ញូកតវេទិតាធម៌នេះហើយទើបតថាគត បានត្រាស់ជាព្រះពុទ្ធឃើញប្រាកដដូច្នោះមែន ។

ផ្ទុយទៅវិញ បុរសស្ត្រីមានទ្រព្យសម្បត្តិហើយ មិនចិញ្ចឹមបីបាច់ថែរក្សា មាតាបិតា ហើយប្រព្រឹត្តខុសចំពោះមាតាបិតា បុរសស្ត្រីនោះរមែងចូលទៅកាន់ទុគ្គតិ សមដូចព្រះពុទ្ធដីកាត្រាស់សំដែងថា :

**ឯវំ កិច្ចាភតោ បោសោ បិតុ អបរិចារកោ**
**បិតរិ មិច្ឆាចរិត្វាន និរយំ សោ ឧបបជ្ជតិ ។**

បុរសស្ត្រីណា ដែលមានមាតាបិតាចិញ្ចឹមមកបានដោយលំបាក យ៉ាងនេះ មិនបំរើនមាតាបិតា ប្រព្រឹត្តខុសចំពោះមាតាបិតា បុរសស្ត្រីនោះរមែងចូលទៅកាន់នរក ។

បុរសបុគ្គលណា ដែលមាតាបិតាបានអោយកំណើតមកហើយ លោកប្រកបដោយព្រហ្មវិហារធម៌ តាំងពីនៅភគ៌ រហូតប្រសូត្រមកក៏បីបាច់ថែរក្សាការពារ ចិញ្ចឹម ថ្នាក់ថ្នមយ៉ាងអស់សមត្ថភាព តាមនាទីជាឪពុក-ម្តាយ គឺលោកទាំងពីរនាក់ រមែងមានសេចក្តីលំបាក់នឿយហត់ទ្រាំចំពោះបង្គុយ ទ្រាំនឹងមូត្រគូថ (អាចម៏) នោម ទ្រាំលំបាកគ្រប់យ៉ាងក្នុងរឿងកូនរហូតទូន្មានប្រៀបប្រដៅ ដឹងខុសត្រូវជ្រៅរាក់ ។

បញ្ជូនទៅកាន់សាលារៀន អោយរៀនសូត្រចំណេះវិជ្ជាទាំងឡាយ ដោយចំណាយប្រាក់កាសទំនុកបំរុង ដែលកើតពីញើស ក្អែលហាលថ្ងៃហាលខ្យល់ ក៏មាន, លុះមដល់ពេលមានគ្រួសារ ក៏រៀបចំអោយមានគ្រួសារ

បើមានទ្រព្យសម្បត្តិជាដើម ក៏រមែចែកអោយកូនជាកេរ្តិ៍មរតក ។ ការចិញ្ចឹមថែរក្សាទំនុកបំរុងផ្គុងផ្គើម កូនមួយនៃមាតាបិតា មិនមែនជាការងាយស្រួលឡើយ ប្រាកដជាលំបាកពេកណាស់ ។

ដូច្នេះមាតាបិតា ឈ្មោះថាជាអ្នកមានគុណ អនន្តអនេក ចំពោះកូនប្រុសស្រីទាំងឡាយ, កូនប្រុសស្រីឈ្មោះថា ជាអ្នកជាប់ជំពាក់គុណម៉ែឪច្រើនណាស់ ដែលត្រូវតែរកឱកាសតបស្នងគុណលោកវិញ តាមសមត្ថភាពដែលអាចតបស្នងសងគុណវិញបានត្រឹមណា ។

ដូច្នោះ បើបុរសបុគ្គលណា មិនបំរើមាតាបិតា ដូចជាការជួយធ្វើកិច្ចការលោកមួយដងមួយកាល, ការគក់ច្របាច់ ការព្យាបាលលោក ពេលមានជម្ងឺដម្កាត់ ការជួយឈឺឆ្អាលក្នុងកិច្ចធុរៈផ្សេងៗ ការជួយទំនុកបំរុងលោកដោយអាហារ និងសំលៀកបំពាក់ជាដើម ព្រមទាំងប្រព្រឹត្តខុសចំពោះលោក ដោយអាកប្បកិរិយាច្រលើសបើស ព្រហើនកោងកាច សម្តីធំ ឬកឈ្លើនពើន ចំពោះលោកជាដើម បុរសបុគ្គលនោះឈ្មោះថា ជាអ្នករមិលគុណ មនុស្សក្រពើវង្វេងបឹង មនុស្សមានសភាពអន់ជាងសត្វ តិរច្ឆានគ្មានគុណធមិ, កាលបើយ៉ាងនេះ បុរសបុគ្គលនោះឈ្មោះថា ចូលទៅដល់នរកក្នុងបច្ចុប្បន្ន គឺធ្លាក់ចុះក្នុងរណ្តៅនៃចិត្តថោកទាប មនុស្សទាំងឡាយរមែងនិន្ទាជានិច្ច គេនាំស្អប់ខ្ពើម មិនចង់សេពគប់រាប់រក គ្រោះថ្នាក់អាក្រក់វិបត្តិ នឹងធ្លាក់ប៉ះទៅលើមនុស្សអកតញ្ញូ ថ្ងៃណាមួយ នាំអោយក្តៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្រហាយស្តាបក្រោយមិនខាន កាលបើរស់អកតញ្ញូនោះស្លាប់ទៅ ក៏មិនអាចទៅកើតក្នុងភពល្អបានឡើយ ច្រើនទៅកើតក្នុងរណ្តៅទុក្ខ គឺនរក ប្រេត អសុរកាយ តិរច្ឆាន ឬកើតជាមនុស្ស ប្រកបដោយគុណវិបត្តិខ្វាត់សុភមង្គលផ្សេងៗ ។

បុរសស្ត្រីក្នុងលោក កុំគប្បីប្រមាថមើលងាយចំពោះមាតាបិតាអោយសោះ ព្រោះលោកចាត់ទុកមាតាបិតា ដូចជាភ្លើងៗធម្មតាកាលបើលូកដៃទៅប៉ះចាប់ច្បាស់ជារលាកមិនខានបាលីថា **មាតាអគ្គិ** ភ្លើងគឺមាតា **បិតាអគ្គិ** ភ្លើងគឺបិតា, បើរលាកភ្លើងយើងធម្មតា គេអាចរកថ្នាំព្យាបាល មានលេបលាប ឬ បិទទៅអាចជាសះស្បើយទៅបានភ្លាមៗ បើរលាកពោលគឺទោស ដោយការប្រមាថ មើលងាយ ឬក៏រហូតទៅដល់ផ្តើជីវិតរបស់គាត់អោយបាត់បង់ដោយហេតុណាមួយនោះ នឹងមានទោសនោះឯងធ្ងន់ណាស់ យូរអង្វែងណាស់, ដូចជារឿង មាតុឃាតករ : (បុរសក្នុងលោកុំគប្បីជឿពាក្យភរិយាគ្រប់ម៉ាត់ ) ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់នៅក្នុងដែនកាសី ។ កាលបើបិតាធ្វើមរណកាលទៅហើយ ក៏ទំនុកបំរុងបំរើមាតាដោយគោរព ឯមាតាបានឃើញកូនមានវត្តប្រតិបត្តិល្អក៏នាំយកស្រីមានរូបល្អស្រស់ប្រិមប្រិយម្នាក់ មករៀបចំអោយកូននោះ។ ចំណែកខាងនាងនោះ បិតាស្លាប់ចោលតាំងពីក្មេង នៅសល់តែមាតា ទើបនាំមកនៅរួមក្នុងត្រកូលស្វាមី ហើយទំនុកបំរុងដល់មាតាទាំងពីរដោយ

គោរព ។ តមកខាងក្រោយនាង ក៏មានចិត្តនឿយណាយធុញទ្រាន់ចំពោះមាតាទាំងពីរ ហើយក៏ស្រាប់តែមានគំនិតអាក្រក់កើតឡើង គិតសម្លាប់ម្តាយក្មេកចោល, បាននិយាយញុះញង់ស្វាមីថា ឥឡូវនេះយើងគិតសម្លាប់ម្តាយយើងចោល ព្រោះចាស់ចង្រៃនេះខុសអស់នឹងចាស់ទាំងពួង តែបន្ទោរបង់មូត្រលាមកដាក់ពេញផ្ទះ សម្បែងហើយច្របាច់លេងដូចកូនក្មេង ទើបនឹងកើត, បើឯងមិននៅពេលណា ហើយគាត់ធ្វើបាបតែអញអោយវេទនារាប់មិនឈ្នះ បើដូច្នេះយើងគិតសម្លាប់គាត់ទៅឬ ? ។ បុរសជាស្វាមីបានឮភរិយារ៉ាយរ៉ាប់ប្រាប់ជាញយៗ ហើយក៏និយាយថា ការសម្លាប់មនុស្សនិមួយៗមិនងាយទេ ក្រណាស់ ។ ភរិយានោះនិយាយតបវិញថា បពិត្រស្វាមី ! ការសម្លាប់នោះងាយទេ មើលតែគាត់ដេកលក់ យើងចងគ្រែសែងគាត់ទៅសំលាប់ក្នុងស្ទឹងខាងក្រោយផ្ទះអោយឆ្លាមមករទំពារស៊ី ។ បុរសជាស្វាមីសួរថា ម្តាយអញគាត់ដេកកន្លែងណា? ម្តាយឯងគាត់ដេកកន្លែងណា? ភរិយាប្រាប់ថា ម្តាយអ្នកសំរានខាងនេះ ម្តាយខ្ញុំសំរាកខាងនោះ ។ ស្វាមីប្រាប់ថា បើដូច្នោះចូរនាងចងគ្រែម្តាយអញអោយស្រេចទៅ ដល់យប់ ជ្រៅយើងនឹងសែងទៅទម្លាក់ក្នុងស្ទឹង ។

ភរិយាត្រេកអរណាស់ ក៏ធ្វើតាមបង្គាប់ស្វាមី ហើយដេកលក់ទៅ ។ បុរសជាស្វាមីបានដឹងថា ភរិយារបស់ខ្លួនដេកលក់ហើយ ក៏ចូលទៅស្រាយចំណងពីគ្រែម្តាយខ្លួនចេញ យកខ្សែទៅចងគ្រែម្តាយក្មេកវិញ លុះចងសព្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រប់ហើយក៏ដើរចូលទៅដាស់ភរិយា នែ! ក្រោកឡើង យើងល្មមសែងដូនចាស់ទៅទំលាក់ចោលហើយ ជនទាំងពីរនាក់ក៏ម្ទីម្ទាសែងគ្រែយកទៅទំលាក់ក្នុងទឹកស្ទឹងខាងក្រោយផ្ទះ ដោយប្រញាប់ប្រញាលខ្លាចក្រែងជនទាំងឡាយមើលឃើញ ។ ពួកសត្វសាហាវជាច្រើនមានសត្វមករជាដើមក៏ដណ្តើមប្រជែងគ្នាស៊ី យាយចាស់នោះអស់ទៅ ។ លុះព្រឹកឡើងនាងភរិយាបានដឹងច្បាស់ថាម្តាយខ្លួនស្លាប់ហើយ ក៏នឹកតូចចិត្តក្តៅក្រហាយអន្ទះសារពន់ពេក ទើបប្រាប់ស្វាមីថា យើងគិតសម្លាប់ដូនចាស់ម្នាក់ទៀត។ បុរសជាស្វាមីក៏ទទួលព្រមថាល្អហើយ ទើបនាំគ្នាទៅធ្វើជើងថ្ករក្នុងព្រៃស្មសាន ដល់យប់ជ្រៅម្តាយដេកលក់ក៏នាំគ្នាសែងទាំងគ្រែយកទៅដាក់លើជើងថ្ករប្រារព្ធនឹងដុតភ្លើង, ជួនជាពេលនោះភ្លេចដាក់ភ្លើងទៅ, ក៏នាំគ្នាត្រឡប់មកយកភ្លើងវិញ ។ កាលជនទាំងពីររូបត្រឡប់មកផ្ទះវិញហើយយាយចាស់នោះក៏ភ្ញាក់ឡើងក្រោកអង្គុយ ដោយត្រូវសន្សើមត្រជាក់ខ្លាំងលុះមើលសព្វគ្រប់ដឹងខ្លួនថា គេយកមកសំលាប់ ក៏ចុះចេញទៅបានយកសាកសពខ្មោចពពែមួយ ទៅដាក់លើគ្រែគ្របសំពតពីលើហើយចៀសចេញទៅពីទីនោះ ដើរចូលទៅក្នុងគូហារមួយ, បានរំពឹងគិតថា ឱ ! អាត្មាអញ នឹកស្មានថា បានកូនប្រសារជាទីពឹង ឥឡូវនេះវាធ្វើអញអោយភ័យយ៉ាងក្រៃលែង ។

ចំណែកខាងបុរសប្តីប្រពន្ធ យកភ្លើងបានមក ក៏ដុតសាកសពពពែនោះទៅ ដោយសំគាល់ថាជាម្តាយរបស់ខ្លួនពិត ។ ឯគូហារដែលយាយចាស់ចូលទៅអង្គុយ មានចោរម្នាក់យកបង្វិចមាសប្រាក់ទៅលាក់ទុកក្នុងទីនោះជាច្រើន ។ យាយចាស់បានឃើញមានប្រាក់នោះហើយ ក៏នឹងដល់កូនថា ឱ ! កូនសម្លាញ់អញ ប្រសិនបើបានមាសប្រាក់ច្រើនយ៉ាងនេះប្រហែលជាត្រេកអររីករាយណាស់ កំពុងតែគិតដូច្នោះ ស្រាប់តែចោរទៅដល់ ។ ចោរនោះបានឃើញយាយចាស់ហើយ ក៏ភ្ញាក់ភ័យញ័ររន្ធត់មិនហ៊ានចូលទៅជិតឡើយ ដោយនឹកស្មានថាយក្ស ក៏ត្រឡប់មកវិញបានហៅពេទ្យខ្មោចម្នាក់អោយចូលទៅសង្កេតមើល, ពេទ្យខ្មោចនោះក៏រាយមន្តវិជ្ជាហើយ ដើរចូលទៅកាន់គូហារ ។ ចំណែកខាងយាយចាស់ បានឃើញពេទ្យខ្មោចនោះ ក៏និយាយថា យើងមិនមែនជាយក្សទេ អ្នកចូរចូលមក យើងទាំងពីរនាក់នឹងចែកទ្រព្យគ្នា ។ ពេទ្យខ្មោចនោះនិយាយថាយើងមិនជឿទេ យាយចាស់ថាបើឯងមិនជឿយើង ចូរអ្នកលៀនអណ្តាតមកដាក់លើអណ្តាតយើងចុះ នឹងដឹងច្បាស់យើងជាមនុស្សពិត ។ ពេទ្យខ្មោចក៏ធ្វើតាមពាក្យយាយចាស់នោះទៅ ។ យាយចាស់ក៏ខាំអណ្តាតពេទ្យខ្មោចជាប់ដោយចង្កូម១ យ៉ាងចំណាប់ ពេទ្យខំបំរះរើរួចហើយក៏ស្រែកប្រាប់គ្នាថា យក្សទេរើយ យក្សទេ ! ទើបនាគ្នារត់ចេញទៅ ។ លុះដល់

ជិតភ្លឺច្បាស់ឡើង យាយចាស់ក៏ប្រមូលមាសប្រាក់វេចស្ពាយយកទៅអោយកូន ។

ចំណែកខាងកូនប្រុសារក្រឡេកឃើញម្ដាយ ស្ពាយបង្វិចទ្រព្យមកដូច្នោះ ក៏ចុះទៅទូលរាក់ទាក់បដិសណ្ឋារ គួរសមយ៉ាងអស្ចារ្យហើយនិយាយថា ! លោកម្ដាយគេយកទៅដុតក្នុងព្រៃខ្មោច ត្រឡប់ជាបានមាសប្រាក់មកអោយកូន បើដូច្នោះខ្ញុំសូមអោយលោកម្ដាយយកខ្ញុំទៅដុតម្ដងវិញចុះ ខ្ញុំនឹងកើបវេចយកមាសប្រាក់អោយច្រើនជាងនេះទៅទៀត ។ ស្ត្រីនោះជាស្ត្រីពាលចណ្ឌាលកាឡកិណ្ណី លោភចង់បានទ្រព្យមិនគិតវែងខ្លីបានអោយស្វាមីយកទៅដុតក្នុងព្រៃស្មសាន, ស្វាមីក៏នាំយកទៅដុតឆេះខ្ទេចខ្ទី ស្លាប់ទៅកើតក្នុងនរកទៅ, ឯស្វាមីដល់អស់អាយុ ក៏បានទៅកើតក្នុងនរកជាមួយគ្នា ។

**សារធរ** សាធុសប្បុរសទាំងឡាយ ! កុំគប្បីប្រមាថមើលងាយឬប្រទូស្តចំពោះលោកអ្នកមានគុណ គឺមាតាបិតា ត្រូវតែទំនុកបំរុងគោរពបូជាចំពោះលោក ការឧបត្ថម្ភទំនុកបំរុងដល់មាតាបិតាអ្នកប្រាជ្ញទាំងឡាយមានពុទ្ធបណ្ឌិតជាដើម លោកតែងជួយត្រេកអរ ហើយលោកតែងពោលសរសើរ ហើយលុះធ្វើមរណកាលទៅកាន់លោកខាងមុខ រមែងចូលទៅកាន់សុគតិភពដោយពិត សមដូចពុទ្ធភាសិត ដែលមានមកក្នុងគម្ពីរខុទ្ទកនិកាយជាតក មហានិបាតថា :

Websites: WatKhemaraRatanaram.org or WatKhmers.org

**យោ មាតរំ បិតរំ វា មច្ចោ ធម្មេន បោសតិ**
**ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។**

អ្នកណាចិញ្ចឹមមាតាបិតាដោយធម៌ ពួកបណ្ឌិតតែងសរសើរ អ្នកនោះក្នុងលោកនេះ, អ្នកនោះខាងមុខរមែងរីករាយ ក្នុងឋានសួគ៌ ។

អ្នកណាចិញ្ចឹមមាតាបិតាដោយធម៌ គឺទំនុកបំរុង បំរើតបស្នងសងគុណ ឪពុកម្ដាយ ដោយគោរពត្រឹមត្រូវតាមផ្លូវតំរាយ តំរាប់ទំនៀមទម្លាប់ច្បាប់ល្អ ដែលសប្បុរស ឬកូនកតញ្ញូទាំងឡាយធ្លាប់ធ្វើមក ដូចជាការទំនុកបំរុង ដោយអាហារចំណិសំពត់ អាវសារ៉ៃស្បៃ កន្លែងនៅ ថ្នាំសង្កូវកែរោគ ជួយឈឺឆ្អាលចាត់ចែងកិច្ចការងារ ដែលឪពុកម្ដាយមាន មួយដងមួយកាល ជួយកំចាត់បង់សេចក្ដីទុក្ខព្រួយ គក់ច្របាច់បំរើដោយទឹកក្ដៅទឹកត្រជាក់ សំរាប់ងូត ឬផឹក ពិសេសទៅទៀត បើឪពុកម្ដាយមិនបានសេពគប់ស្ដាប់ធម៌សប្បុរស ក៏នាំអោយបានសេពគប់ស្ដាប់ធម៌សប្បុរស បើលោកមិនទាន់រក្សាសីល ធ្វើបុណ្យសុន្ទរីទាន ក៏ជួយណែនាំអោយបានរក្សាសីលប្រព្រឹត្តសុចរិត ធ្វើបុណ្យសន្ទរីទានឡើងយ៉ាងនេះ ជាអាទិ៍ឈ្មោះថា ចិញ្ចឹមមាតាបិតាដោយធម៌ ។

អ្នកប្រាជ្ញបណ្ឌិតជាទីគោរពសក្ការ នៃមនុស្សក្នុងលោករមែងសរសើរ ក្នុងបំរើចិញ្ចឹមមាតាបិតានោះថា ជាមនុស្សល្អ គួរសេពគប់រាប់រកជាកូនកតញ្ញូ ជាអ្នកស្ថិតនៅក្នុងមនុស្សធម៌ ជាគំរូល្អដល់អ្នកដទៃទៀត ។

អ្នកបំរើចិញ្ចឹមមាតាបិតា ដែលរាប់ថាជាអំពើតបស្នងសងគុណ ជាបុណ្យកុសលនោះ លុះស្លាប់ចាកមនុស្សភាពនេះទៅ រមែងទៅរីករាយក្នុងឋានសួគ៌មិនខាន ព្រោះឋានសួគ៌ជាកន្លែងសំរាប់ទទួលអ្នកធ្វើអំពើល្អ ក្នុងមនុស្សលោក មានធ្វើបុណ្យសន្ទីទាន មានការដឹងគុណចិញ្ចឹមមាតាបិតាជាដើម អោយបានទទួលផលរីករាយក្នុងទីនេះ ។

## រឿងស្តេចសេក

## គុណនៃការបំរើមាតាបិតា

ក្នុងកាលកន្លងទៅហើយ មានព្រាហ្មណ៍គ្រាមមួយឈ្មោះ សាលិ-ន្ទិយៈ តាំងនៅទិសឦសាន ពីទីក្រុងរាជគហ ។ តពីព្រាហ្មណ៍គ្រាមនោះមានស្រែនៃជនក្នុងដែនមគធៈមួយនៅទិសឦសានដូចគ្នា ។ ក្នុងទិសឦសាន តពីមគធក្ខេត្តនោះដលែមានដើមរកាមួយយ៉ាងធំ ដុះទៀបញ្ញកភ្នំ ។ ពេលនោះព្រះពោធិសត្វកើតជាស្តេចសេក មានសិរីធំប៉ុនដុំរទេះ តែងតែហើរទៅពាំនាំយកចំណីព្រៃហេពាន្ត មកចិញ្ចឹមមាតាបិតា ។ គ្រានោះមានព្រាហ្មណ៍ម្នាក់ជាកោសិយគោត្រ នៅអាស្រ័យក្នុងស្រុកសាលិន្ទិយនោះបានសាបព្រោះស្រូវសាលីក្នុងស្រែមួយ មានពាននៃករិសជាប្រមាណហើយអោយបុរសម្នាក់ជាអ្នកថែទាំមើលការខុសត្រូវ ។ ស្តេចសេក និងបរិវារតែងតែហើរទៅចុះក្នុងស្រែនោះជានិច្ចកាល ។ ឯខេត្តបាលបុរសដេញមិនឈ្នះសោះ ព្រោះហ្វូងសេកច្រើនហួស ។ អស់សេកទាំងនោះស៊ី

ត្រឹមស៊ីត្រឹមតែឆ្អែតក៏ហើរទៅ ។ ប្លែកតែអស្ចារ្យណាស់ មានតែស្តេចសេក មួយទេ ដែលស៊ីឆ្អែតហើយ ឆ្លៀតពាំគួរស្រូវនោះជាច្រើនយកទៅទៀត ។

ខេត្តបាលបុរស ក៏ទៅជំរាបព្រាហ្មណ៍ៗពោលថា បើដូច្នោះចូរអ្នក វេញរោមកន្ទុយសេះ ធ្វើជាអន្ទាក់ទៅដាក់ត្រង់កន្លែងស្តេចសេកនោះវាចុះ។ បើចាប់បានត្រូវនាំយកមកទាំងរស់កុំខានណា ! ។ ខេត្តបាលបុរសធ្វើតាម បង្គាប់ព្រាហ្មណ៍ ក៏ចាប់បានស្តេចសេកនោះហើយយកទៅទាំងរស់ ។ ព្រាហ្មណ៍គ្រាន់តែឃើញស្តេចសេកភ្លាម មានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ហើយអោយឈរទុំលើភ្លៅខ្លួន សួរថានែ ! សេកអ្នកស៊ីស្រូវសាលីដ៏រាប ដល់ឆ្អែតហើយ ហើយពាំនាំទៅដោយចំពុះទៀត, យើងឆ្ងល់ណាស់ជង្រុក របស់អ្នកមានឬទេ ! ឬអ្នកចង់ចងពៀរជាមួយយើង ? ស្តេចសេកឮនូវ សំនួរនោះ ក៏ពោលគាថាដ៏ផ្អែមល្ហែមជាភាសាមនុស្សថា :

**នមេទេរំ តយា សទ្ធឹ កោដ្ឋំ មយ្ហំ នវិជ្ជតិ**

**ឥណំ មុញ្ចាមិណំ ទម្មិ សម្បត្តោ កោដិសិម្ពលឹ**

**និធិម្បិ តត្ថ និទហាមិ ឯវំ ជានាហិ កោសិយ។**

ខ្ញុំមិនធ្វើពៀរចំពោះអ្នកទេ ជង្រុករបស់ខ្ញុំក៏គ្មាន ខ្ញុំនាំស្រូវទៅដើម នោះវិញនោះ ព្រោះសងបំណុលចាស់ បំណុលថ្មី ទាំងកំណប់ក៏ខ្ញុំកប់ទុកទី នោះ ម្នាលកោសិយព្រាហ្មណ៍ចូរដឹងយ៉ាងនេះចុះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ដើម្បីដោះស្រាយសំនួរព្រាហ្មណ៍ និងធ្វើសេចក្ដីនេះអោយច្បាស់លាស់ទើបពោលគាថាដទៃទៀតថា :

**អជាតបក្ខា សកុណា មយ្ហំ កោសិយ តេ មំ**

**ភតា ភរិស្សន្តិ តស្មា តេសំឥណំ ទទេ ។**

ហៃកោសិយៈ សកុណជាតិតូចខ្ញុំ មិនទាន់ដុះស្លាបទេ ខ្ញុំចិញ្ចឹមវា វាមុខជាចិញ្ចឹមខ្ញុំវិញ ហេតុនោះខ្ញុំត្រូវអោយបំណុលដល់ពួកវានោះ ។

**មាតាបិតា ចមេ វុឌ្ឍា ជិណ្ណកា តេ យោព្វនា**

**តេសំ ករោន្ត ហារន្ត មុព្ពេ កតំ ឥណំ ។**

ឯមាតាបិតាខ្ញុំសោក មានវ័យចំរើនណាស់ទៅហើយ ខ្ញុំពាំស្រូវដោយចំពុះ នឹងយកទៅសងបំណុលចាស់នោះ ។

**អញ្ញេបិ តត្ថ សកុណា ខីណបក្ខា សុទុព្វលា**

**តេសំ បុញ្ញត្ថិកោនម្ហិ តំនិធិ អាហុ ពិណ្ឌតា ។**

លើដើមរកានោះ មានពួកសត្វស្លាបដទៃ មានស្លាបរិចរិល និងមានកម្លាំងអន់ថយណាស់ហើយ ខ្ញុំជាអ្នកចំណូលដោយបុណ្យ និងអោយដល់សត្វទាំងឡាយនោះទៀត ពួកបណ្ឌិតពោលនូវបុញ្ញកម្មនោះថាជាអនុគាមិកនិធិ ។

ព្រាហ្មណ៍ ឮគាថានោះជ្រះថ្លាណាស់ បានប្រគល់ស្រែអោយហើយពោលថា ចាប់ពីថ្ងៃនេះទៅអ្នក និងញាតិចូរទំពារស៊ីនូវស្រូវនោះចុះ ទើប

ស្រាយចំណងជើង ។ សេកពោធិសត្វ ជាសត្វដឹងប្រមាណ ក៏ទទួលយកតែត្រឹម ៨ កិរិសប៉ុណ្ណោះ សល់ពីនោះក៏ប្រគល់អោយព្រាហ្មណ៍វិញ ទើបអោយឱវាទជាដំបូន្មានដ៏ប្រសើរឆ្នើមទេមួយមាត់ថា មហាព្រាហ្មណ៍ អ្នកកុំប្រមាទអោយសោះ ហើយពាំនូវគួរស្រូវសាលី ហើយហើរឆ្ពោះទៅកាន់សំណាក់មាតាបិតាទៅ ។ ព្រាហ្មណ៍បោះនូវគោលក្នុងស្រែ ៨ កិរិសនោះ ហើយពោលប្រាប់ខេត្តបាលបុរសថា អ្នកកុំឃាត់ឃាំងពួកសេកទៀតចាប់តាំងពីថ្ងៃនេះទៅ ។

ហ្វូងសេកបានសេចក្តីសុខកាយ សប្បាយចិត្ត ដោយសារតែស្តេចរបស់ខ្លួន មានបញ្ញាយ៉ាងពិច័ត្ត ហើយតែងហើរទៅពាំនាំយក មកបរិភោគនូវស្រូវក្នុងស្រែ ៨ កិរិសនោះជាប់ជានិច្ច ។

ផ្ទុយទៅវិញបើបុរសស្ត្រីណាមួយក្នុងលោក មិនទំនុកបំរុង បំរើមាតាបិតារបស់ខ្លួនទេ ទុកអោយគាត់ដែលចាស់ជរារស់នៅដោយឯកឯងដូចពាក្យពោលថា រស់នៅ "ឯកោអនាថោ " លោកប្រៀនប្រដៅដូចថា បុត្រធីតានោះ អន់ជាងឈើច្រត់ទៅទៀត ពីព្រោះឈើច្រត់អាចទប់ខ្លួនអាចការពារខ្លួនរបស់គាត់បាន មិនអោយដួលទ្រេតទ្រោត មិនអោយសត្វកាចសាហាវ មានឆ្កែ ឬសត្វពាហនខ្លះៗ មានគោក្របីជាដើម ។

ម្យ៉ាងទៀតលោកទុកបុត្រធីតា នោះថាជាអ្នករមិលគុណ កូនមិនដឹងគុណ មាតាបិតាអន់ជាងឈើច្រត់ ដូចរឿងព្រាហ្មណ៍ចាស់ សូមនាំរឿងនោះមកសំដែងដូចតទៅនេះ :

ក្នុងសម័យពុទ្ធកាល មានព្រាហ្មណ៍មហាសាលម្នាក់ នៅក្នុងក្រុងសាវត្ថ មានទ្រព្យ ៨ សែន កហាបណ មានកូនប្រុស ៤ នាក់ ។

កាលកូននោះមានវ័យធំឡើង បានរៀបចំអាវាហមង្គលការហើយបានចែកទ្រព្យសម្បត្តិអោយកូនម្នាក់ៗ មួយសែនកហាបណៈ ។ ខាងក្រោយមកនាងព្រាហ្មណីជាភរិយា របស់ព្រាហ្មណ៍នោះស្លាប់ទៅ គាត់នៅពោះម៉ាយតែម្នាក់ឯង ។ កូនទាំង ៤ នាក់បានប្រឹក្សាគ្នាថា បើឪពុកយើងមានប្រពន្ធទៀត មុខជាមានកូនមិនខាន ទ្រព្យ ៤សែននិងគ្រឿងអាករផ្សេងៗ ដែលនៅសល់ក្នុងកណ្តាប់ដៃគាត់ៗ មុខជានឹងចែកអោយកូនចុងទាំងអស់ បើដូច្នោះគួរតែយើងទៅនាំយកគាត់មកចិញ្ចឹមជប់លៀងគាត់ ។

ថ្ងៃមួយព្រាហ្មណ៍ក្រោកពីដំណេកក្នុងវេលាថ្ងៃ កូនទៅជួបជុំគ្នាហើយនិយាយអំពីទោសនៅគ្រប់គ្រងផ្ទះដោយឡែកពីគ្នា រួចនិយាយអង្វរថា លោកឪពុក! យើងខ្ញុំជាកូនទាំងអស់គ្នា នឹងបំរើទំនុកបំរុងលោកឪពុកដោយគោរព ដរាបដល់អស់ជីវិត សូមលោកឪពុកប្រគល់ទ្រព្យ សម្បត្តិដែលនៅទាំងប៉ុន្មាន មកយើងខ្ញុំទាំងអស់គ្នា អោយអស់មក កុំអោយរវល់នឹងទុកដាក់ថែរក្សា ព្រោះពីលោកឪពុកចាស់ហើយ ។

ព្រាហ្មណ៍ក៏ប្រគល់ទ្រព្យអោយកូនទាំង ៤ នាក់ម្នាក់ៗត្រូវបាន ១សែនកហាបណៈថែមទៀត ខ្លួនឯងនៅសល់តែសំពត់មួយចង្កេះប៉ុណ្ណោះ ទៅនៅជាមួយនឹងកូនច្បងបង្អស់ មិនយូរប៉ុន្មានកូនប្រសារ កើតសេចក្ដីធុញទ្រាន់ និងនិយាយដៀមដាមថា : លោកឪពុកប្រហែលជាមិនស្គាល់ផ្លូវទៅផ្ទះកូនដទៃទៀតទេដឹង ? បានជាក្រាញនៅតែនឹងផ្ទះខ្ញុំ ។ ព្រាហ្មណ៍ឮដូច្នោះ តូចចិត្តណាស់ ក៏ទៅកាន់ផ្ទះកូនមួយនាក់ទៀត មិនយូរប៉ុន្មានកូនប្រសារទាស់ចិត្ត ក៏និយាយបណ្ដេញទៀត ទៅនៅគ្រប់ផ្ទះកូនទាំង ៤ នាក់ គេចេះតែបណ្ដេញគ្រប់គ្នា គាត់ទ្រាំនៅមិនបាន ក៏ចេញទៅដើរសុំទានគេតាំងពីច្រកល្ហកផ្ទះបុគ្គលដទៃទៅជាស្គាំស្គម ព្រោះបរិភោគអាហារ និងដេកមិនស្រួល ទើបនឹងអាណិតអាសូរខ្លួនថា : ឱអាត្មាអញ ! ចាស់ឡើងកាន់តែលំបាកខ្លាំងឡើង មិនសមបើកូន អញវាមិនដឹងអាណិតអញបន្តិចបន្តួចសោះ វាលះបង់ចោលអញដូចជាគោចាស់ បើដូច្នេះអញចូលទៅរកព្រះសមណគោតមចុះ ក្រែងសុខស្រួលបន្តិច, លុះគិតដូច្នោះហើយក៏ទៅកាន់សំណាក់ព្រះពុទ្ធៗត្រាស់សួរថានែ ! ព្រាហ្មណ៍ ហេតុអ្វីបានជាស្គមស្លេកស្លាំងម្លេះ? បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំព្រះអង្គមានកូនប្រុស ៤ នាក់ ឥឡូវនេះវាត្រូវគំនិត នឹងប្រពន្ធវា បណ្ដេញខ្ញុំព្រះអង្គចោលម្នាលព្រាហ្មណ៍ បើដូច្នោះអ្នកចូររៀនមន្តពីតថាគត ហើយសូត្រក្នុងទីប្រជុំជន ដែលមានកូនរបស់អ្នកអង្គុយនៅជាមួយផង, មន្តនោះថា : ខ្ញុំត្រេកអរដោយកូន

ឯណា ដែលកើតហើយផង ប្រាថ្នានូវសេចក្ដីចំរើនដល់កូនឯណាផង, កូននោះផ្សំគំនិតជាមួយប្រពន្ធវាហើយបណ្ដេញខ្ញុំចោល ដូចជាឆ្កែបណ្ដេញជ្រូក, កូនជាអសប្បុរសលាមកគ្រាន់តែហៅថាឪៗប៉ុណ្ណោះ វាលះបង់ខ្ញុំដែលមានវ័យចំណាស់ជ្រុលហើយ, កូនខ្ញុំនោះប្រៀបដូចអារក្សទឹក មានក្លែងធ្វើជាកូន, ឪពុកចាស់របស់កូនពោលតែងដើរសុំទានប្របផ្ទះអ្នកដទៃ ដូចជាសេះចាស់ប្រើមិនកើត គេនាំចេញចាកចំណី, ឈើច្រត់របស់ខ្ញុំនេះប្រសើរឯកូនដែលមិនស្គាល់បង្គាប់ មិនប្រសើរឡើយ ។ ដ្បិតឈើច្រត់នេះ អាចការពារគោកាច ឆ្កែកាចក៏បាន ច្រត់ទៅខាងមុខក្នុងទីងងឹតក៏បាន ស្ទង់ចុះទៅក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិលគង់ទប់ខ្លួនបាន ដោយអានុភាពនៃឈើច្រត់ ។ លុះព្រាហ្មណ៍ចាស់រៀនចេះមន្តនេះពីសំណាក់ព្រះមានព្រះ-ភាគចប់ហើយក៏ចូលទៅកាន់ទីប្រជុំ ដែលមានកូន ៤ នាក់ អង្គុយនៅទីនោះផង ហើយសូត្រវាយមន្តនោះ ។

សេចក្ដីដំណាលថា សម័យនោះទំនៀមទំលាប់របស់អ្នកស្រុកប្រ-កាន់ថា:បើកូនណាបានទទួលមរតកពីមាតាបិតាហើយ មិនចិញ្ចឹមមាតាបិតាវិញ ត្រូវអ្នកស្រុកប្រហារជីវិតចោល ។ គ្រាន់តែព្រាហ្មណ៍ចាស់សូត្រមន្តចប់មហាជនផ្អើលឆោឡោរកដំបងព្រនង់ប្រុងវាយកូនទាំង ៤ នោះសម្លាប់ចោល ។ កូនព្រាហ្មណ៍ទាំង៤ ភ័យខ្លាំងស្ទុះទៅក្រាបទៀតបបាទាបិតា សូមខមាទោស រ៉ាប់រងទំនុកបំរុងដោយគោរពទៅ ហើយកូនម្នាក់ៗបានជូន

សំពត់១គូ និងនិច្ចភត្តទៀត ។ ព្រាហ្មណ៍ចាស់កាលបើបានសុខហើយនឹកឃើញគុណព្រះសាស្តា ទើបនាំសំពត់ ៣គូ និងនិច្ចភត្តជាច្រើនទៅថ្វាយព្រះសាស្តា។ ទ្រង់ក៏ទទួលដោយសេចក្តីអនុគ្រោះ ។

នរជនប្រុសស្រីឯណាមួយ ដែលមានទ្រព្យសម្បត្តិធនធាន ហើយប្រមាទ គឺប្រហែលធ្វេស មិនបានទំនុកបំរុងចិញ្ចឹមមាតាបិតា ដែលស្ថិតនៅក្នុងបរិជិណ្ណកវ័យចាស់ជរា នរជនប្រុសស្រីនោះ ជាប្រធាននៃសេចក្តីវិនាសដោយពិតប្រាដ ដូចបានសំដែងមកហើយ ។

ការសំដែងមកក្នុងគាថាទី ៤ ដែលមានសេចក្តីថា :

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចិញ្ចឹមរក្សា មាតាបិតាដែលចាស់ជរា ហេតុនោះទៅជានាំអោយវិនាស ។

**ការសំដែងមកនេះក៏សន្មត់ថា**

**ចប់តែប៉ុណ្ណេះ ឯវំ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសូត្រ

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕**

**អរហំ សម្មា សម្ពុទ្ធោ ភគវា ពុទ្ធំ ភគវន្តំ អភិវាទេមិ, ស្វាក្ខាតោ ភគវតា ធម្មោ ធម្មំ នមស្សាមិ, សុបដិបន្នោ ភគវតោ សាវកសង្ឃោ សង្ឃំ នមាមិ ៕**

ព្រះពុទ្ធជាម្ចាស់ព្រះអង្គឆ្ងាយចាកកិលេសត្រាស់ ដឹងនូវព្រះធម៌ដ៏ប្រពៃ ហើយដោយព្រះអង្គឯង ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ ដ៏មានព្រះភាគអង្គនោះ ។ ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងប្រពៃហើយ, ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះធម៌ ។ ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិតាមប្រពៃហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃ ។

បទនមស្សការ សូមសង្ខេបបែបខ្លីតែប៉ុណ្ណេះ, បន្ទាប់អំពីនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកគាថាទី៥ នៃបរាភវសូត្រ មកអធិប្បាយបកស្រាយលាតត្រដាង ចង្អុលបង្ហាញ ពន្យល់ប្រាប់ជូនជាទីសណ្ដាប់ដល់ពុទ្ធសាសនិកជនទាំងអស់ ដែលបានលះបង់នូវបលិពោធ ហើយអញ្ជើញមកជួបជុំក្នុងទីនេះ ដើម្បីនឹងបានជាគ្រឿងប្រដាប់សតិ

បញ្ញាស្មារតី និងដើម្បីជាគ្រឿងភ្ជាក់កំណើត កើតគំនិត និងជាវត្តប្រតិបត្តិ ខ្ញុំព្រះករុណា អាត្មាភាពនឹងបានសំដែងដូចតទៅនេះ ៖

ទេវតាទូលសួរតទៅទៀតថា ៖

**ឥតិហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**

**បញ្ចមំ ភគវាព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះ បើរាប់សង្គ្រោះវិនាសនោះឈ្មោះទី៤ ទាន់ហន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងអោយទាន វិនាសទី៥ អ្វីជាប្រធាននាំសត្វអោយមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា ៖

**យោ សមណំ ព្រាហ្មណំ វា អញ្ញំ វាបិ វនិព្វកំ**

**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

ជនបញ្ឆោតព្រាហ្មណ៍ ឬ មួយសមណៈ ពួកស្មូម ឬអ្នកដទៃៗ ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស ។

## អធិប្បាយ គាថាទី ៥

បទថា **មុសាវាទ** បានសេចក្តីថា ពាក្យកុហក ពាក្យថា "កុហក" បានដល់ពាក្យសំដីដែលមិនពិត មិនទៀងត្រង់ ឃើញថាមិនឃើញ ដឹងថា

មិនដឹង ឮថាមិនឮ មែនថាមិនមែន មានថាមិនមាន បានថាមិនបាន ប៉ុណ្ណោះជាដើម ហៅថាមុសាវាទ គឺពាក្យកុហក ។

ពាក្យកុហកនេះទោះបីនិយាយទៅហើយ អ្នកដទៃជឿក្តី មិនជឿក្តី ក៏ឈ្មោះថា ពោលពាក្យកុហក សម្តីកុហក ជាសម្តីដែលអ្នកប្រាជ្ញទាំង-ឡាយមានពុទ្ធាទិបបណ្ឌិតជាដើម ត្រង់ត្អូញតិះដៀល ព្រមទាំងហាមមិនអោយនិយាយនូវពាក្យនេះទៀតផង ។ បុគ្គលណាមួយក្នុងលោកនេះទម្លាប់អាក្រក់និយាយតែកុហក រមែងធ្វើអោយគេខូចប្រយោជន៍ ខូចខាតទ្រព្យសម្បត្តិ ជួនអាចធ្វើអោយគេខូចលាភសក្ការ ប្រាក់កាស ឬក៏អោយបាត់បង់ទាំងជីវិត ដោយពាក្យមិនពិតនេះ អោយដល់នូវសេចក្តីលំបាកវេទនា ដោយប្រការផ្សេងៗក៏មាន ជួនកាលអោយទោសចំពោះខ្លួនឯងក៏មាន ដូចជារឿងនាង **អស្សមុខីយក្ខិនី** មុខសេះ, ទោសផឹកសុរានិយាយកុហក និងក្បត់ចិត្តស្វាមី, សូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

ក្នុងកាលកន្លងទៅហើយ មានអគ្គមហេសីនៃព្រះរាជាមួយព្រះអង្គសោយរាជសម្បត្តិក្នុងក្រុងពារាណសី ជាអ្នកផឹកស្រានិយាយកុហក និងក្បត់ចិត្តស្វាមី ។ អគ្គមហេសីនោះ លុះធ្វើមរណកាលទៅ បានកើតជាយក្ខិនីប្លែកអំពីត្រកូលយក្សធម្មតា មានខ្លួនជាយក្ស មុខជាសេះ ហៅថា **អស្សមុខីយក្ខិនី** ស្ថិតនៅក្នុងលេណគូហានាបាទភ្នំមួយ បានចូលទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

បំរើស្តេចវេស្សវ័ណ អស់រយៈ ៣ ឆ្នាំ ស្តេចទ្រង់ប្រទានគោចរភ័ក្ស មួយ មានបណ្តោយ ៣០ យោជន៏ ទទឹង ៥ យោជន៏ ដើម្បីចាប់សត្វម្រឹគ នឹងមនុស្សទាំងឡាយបរិភោគជាអាហារ ។ ថ្ងៃមួយយក្ខិនីមុខសេះនោះចាប់បានព្រាហ្មណ៏កម្លោះម្នាក់ មានរូបឆោមសម្ផស្សល្អ លើកដាក់អោយដេកលើខ្នង នាំយកទៅទុកក្នុងរូងគុហា ដើម្បីធ្វើជាស្វាមី ។ ចាប់ដើមតាំងពីថ្ងៃនោះមក យក្ខិនីតែស្វះស្វែងរកចាប់មនុស្សដើម្បីយកវត្ថុផ្សេងៗ មានសំពត់អាវ និងអង្ករស្លឹកគ្រៃ ម្ហូបចំណីដែលមានរសជាតឆ្ងាញ់ពិសារ ទៅចិញ្ចឹមព្រាហ្មណ៏ជាស្វាមី នោះតែរាល់ៗថ្ងៃ ។

ក្នុងពេលដែលយក្ខិនី ចេញទៅរកចំណីអាហារ បានយកដុំថ្មមួយដុំធំខ្ទប់មាត់ទ្វារ ព្រោះខ្លាចព្រាហ្មណ៏នោះរត់ចោល ។ ក្នុងគ្រានោះព្រះពោធិសត្វ បានសោយព្រះជាតិនៅក្នុងភគិនៃនាងយក្ខិនីមុខសេះនោះ, លុះគ្រប់ទសមាស ក៏ប្រសូត្រ មកមានរូបល្អស្រស់ប្រិមប្រិយ, នាងមានសេចក្តីស្នេហាចំពោះកូន និងបិតាយ៉ាងក្រៃលែង តែងទំនុកបំរុងដោយភោជនាហារ មានរសឆ្ងាញ់ផ្សេងៗ ។ លុះព្រះពោធិសត្វមានវ័យចំរើនឡើង ក៏ប្រមៀលដុំថ្ម ដែលមាតាបិទទ្វារគុហានោះចេញ ហើយនាំបិតាមកអង្គុយលេងកំសាន្តខាងក្រៅ ដល់យក្ខិនីជាមាតាត្រឡប់មកវិញ ព្រះពោធិសត្វក៏ប្រាប់ភ្លាមថាខ្ញុំប្រមៀលដុំថ្មនេះចេញ ហើយព្រោះងងឹតអផ្សុកណាស់ យក្ខិនីហេតុទៃស្រឡាញ់កូន ក៏នៅស្ងៀមគ្មានថាអ្វីឡើយ ។

ថ្ងៃក្រោយព្រះពោធិសត្វមានសេចក្តីងឿងឆ្ងល់ នឹងមាតារបស់ខ្លួនថាហេតុអ្វីបានជាមាតាគាត់មានមុខដូចជាសេះ ទើបសួរទៅបិត។ប្រាប់ថា ម្តាយបាងងជាយក្សទេ យើងទាំងពីរនាក់ជាមនុស្ស ។ ព្រះពោធិសត្វបានដឹងហេតុនោះសព្វគ្រប់ ហើយក៏នាំបិតារត់ចេញពីទីនោះទៅ ។ យក្ខិនីជាមាតាដល់ត្រឡប់មកវិញ មិនឃើញកូន និងស្វាមី ក៏ហោះទៅតាមមានសន្ទុះលឿនដូចជាខ្យល់ទៅទាន់ពាក់កណ្តាលផ្លូវ ក៏នាំយកមកវិញ, ថ្ងៃក្រោយបាននាំបិតារត់ទៅទៀត យក្ខិនីតាមទាន់ទៀត ។ ថ្ងៃក្រោយព្រះ-ពោធិសត្វបានគិតថា មាតារបស់អញមានឱកាសទីស្ថាន បរិច្ឆេទកំណត់ពីត្រឹមណាទៅដល់ត្រឹមណា? លុះគិតដូច្នោះហើយ ក៏សួរទៅមាតា។ បានប្រាប់ទីស្ថាន ខែត្រដែនរបស់ខ្លួន ដោយសព្វគ្រប់ដល់ព្រះពោធិសត្វ ។ ថ្ងៃក្រោយព្រះពោធិសត្វបានឱកាសស្វាត់ល្អ ក៏បញ្ជិះបិតាលើក នាំរត់ទៅដោយសន្ទុះយ៉ាងលឿនដូចជាខ្យល់ បានដល់ឆ្នេរស្ទឹងជាទីបំផុតនៃព្រំដែនរបស់យក្ខិនីជាមាតាហើយ នាំបិតាឆ្លងស្ទឹងនោះទៅ, លុះដល់ពាក់កណ្តាលស្ទឹង មាតាទៅតាមទាន់ ប៉ុន្តែមិនហ៊ានចាប់យកមកវិញឡើយ ព្រោះហួសព្រំដែនរបស់ខ្លួន, ក៏ខំនិយាយអង្វរកូន និងស្វាមីនោះអោយត្រឡប់មកវិញ ដោយអាការផ្សេង។ ដឹងថាជនទាំងពីរនាក់មិនត្រឡប់វិញហើយ ក៏មានសេចក្តីខ្សឹកខ្សួលយំសោកបោកខ្លួន ព្រោះស្រឡាញ់កូនយ៉ាងក្រៃលែង ទើបស្រែកហៅព្រះពោធិសត្វថា នែកូន ! សម្លាញ់មាសម្តាយ បើអ្នក

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនត្រឡប់មកវិញទេ ចូរអ្នករៀនយកមន្តវិជ្ជាឈ្មោះចិន្តាមណីពីម្តាយទៅចុះព្រោះមនុស្សលោក បើគ្មានសីលហើយរស់នៅបានដោយកម្រពេកណាស់, ឯមន្តវិជ្ជាឈ្មោះចិន្តាមណីនោះ មានតម្លៃកាត់មិនបាន ព្រោះមានអានុភាពយ៉ាងពិសេស បើទុកជាចោរនាំយកនូវភណ្ឌៈទៅលាក់ទុកអស់ ១២ ឆ្នាំ ក៏អាចតាមដានជើង ចាប់បានចោរនោះភ្លាម ចូរកូនយកទៅរក្សាទុកអោយល្អចុះ ។ ព្រះពោធិសត្វឈរនៅពាក់កណ្តាលស្ទឹង បានស្តាប់មាតាថ្លែងនូវវិសេសនៃមន្តវិជ្ជាឈ្មោះចិន្តាមណីនោះរួចហើយ ក៏ថ្វាយបង្គំព្រះ-មាតារៀនយកមន្តនោះដោយសព្វគ្រប់ហើយ លាមាតាថា " សូមលោកម្តាយអញ្ជើញត្រឡប់ទៅវិញចុះ ខ្ញុំសូមថ្វាយបង្គំលាហើយ ។ ចំណែកខាងនាងយក្ខិនី ក៏ប្រហារដើមទ្រូង បែកហឫទ័យស្លាប់ក្នុងទីនោះទៅ ។ ព្រះ-ពោធិសត្វឃើញមាតាស្លាប់ហើយ ក៏នាំបិតាចាត់ចែងធ្វើជើងថ្ករបូជាសព លុះបូជាហើយ បានបេះផ្កាវុក្ខជាតិផ្សេងៗ យកទៅបូជាធាតុ ថ្វាយបង្គំលានាំបិតាទៅកាន់ក្រុងពារាណសីទៅ ។

ពាក្យមុសាវាទ ការចេញស្តីនិយាយហើយ តែងអោយផលអា-ក្រក់ ផ្សេងៗជាអាទិ៍គឺ កាលអ្នកស្តាប់គេដឹងថា នរណានិយាយភូតភរហើយ ទុកជាថ្ងៃក្រោយនិយាយត្រង់ក៏គេលែងជឿង ។ តាមពិតពាក្យកុហក សូម្បីនិយាយលេងដើម្បីដោះខ្លួនអោយរួចចាកភ័យ ឬដើម្បីបង្រួបបង្រួមអ្នកដទៃអោយមានសាមគ្គីគ្នា ក៏មិនត្រូវនិយាយ ត្រូវនិយាយ

ពាក្យពិតទៅចុះ ព្រោះសំនួយវោហាដែលត្រូវនិយាយ អោយគេស្តាប់នោះមានច្រើន ល្មមប្រើដែរ មិនអោយខ្វះទេ, ទុកភូតលែង ក៏មិនត្រូវនិយាយ ដ្បិតនាំអោយផ្លាក់មាត់ និងនាំអោយស្តាប់ស្និទ្ធស្នាល ហើយនាំគ្នានិយាយលេងតៗទៅ ។

ពាក្យភូតកុហក បើមានកម្លាំងច្រើន អាយអោយទោសក្នុងជាតិនេះ បើមានកម្លាំងតិចអោយទោសក្នុងជាតិខាងមុខ ។ លោកសំដែងថា នរណានិយាយភូតកុហក អ្នកនោះកើតក្នុងជាតិណា១ តែងជាមនុស្សវៀចមាត់ ឆែបមាត់ នឹងច្រើនមានអ្នកដទៃបោកបញ្ឆោត ចោទប្រកាន់ដោយពាក្យមិនពិតផ្សេង១ ។

ដោយពាក្យភូតភរកុហក មានផលអាក្រក់ក្នុងឥធលោក និងបរលោក ដូចពោលមកនេះ ទើបហៅថាបាបជាអំពើអាក្រក់ គួថភាណើសំដីលាមក មិនគួរនិយាយ ។

បុរសស្ត្រីក្នុងលោកមិនពោល ពាក្យមុសាវាទ រមែងបានទទួលអានិសង្ស ១៤ យ៉ាងគឺៈ

**១_វិប្បសន្និន្ទ្រិយតា** ភាពជាបុគ្គលអ្នកមានឥន្ទ្រិយថ្លាយង់ ឬ ស្រស់បស់ស្អាតបាត ។

**២_វិស្សត្ថមធុរភាណិតា** ភាពជាបុគ្គលអ្នកមានសម្តីពីរោះ ។

**៣-សមតិកសុទ្ធទន្តតា** ភាពជាបុគ្គលមានធ្មេញរាបស្មើជិតស្និទ្ធល្អ ។

**៤-នាតិថូលតា** ភាពជាបុគ្គលអ្នកមិនធាត់ពេក ។

**៥-នាតិកិសតា** ភាពជាបុគ្គលជាអ្នកមិនស្គមពេក ។

**៦-នាតិរស្សតា** ភាពជាបុគ្គលជាអ្នកមិនទាបពេក ។

**៧-នាតិទីឃតា** ភាពជាបុគ្គលជាអ្នកមិនខ្ពស់ពេក ។

**៨-សុខសម្ផស្សតា** ភាពជាបុគ្គលជាអ្នកមានសម្ផស្សស្រួល ។

**៩-ឧប្បលគន្ធមុខតា** ភាពជាបុគ្គលជាអ្នកមានក្លិនផ្កា ឧប្បលក្នុងមាត់ គឺមានមាត់ក្រអូបដូចជាផ្កា ឧប្បល ។

**១០-សុស្សូសកបរិជនតា** ភាពជាបុគ្គលអ្នកមានជនជាបរិវារ ឬ អ្នកកំដររំហែហម, អ្នកស្តាប់បង្គាប់ ។

**១១-ទាទេយ្យវចនតា** ភាពជាបុគ្គលអ្នកមានពាក្យដែលអ្នកផងគួរពោល ។

**១២-កមសុម្បលទលសទិសមុទុលោហិតតន្ទុជិវ្ហតា** ភាពជាបុគ្គលអ្នកមានអណ្តាត ស្តើងក្រមទន់ ប្រហែលនឹងត្របកផ្កាឈូក ឬផ្កាឧប្បល ។

**១៣-អនុទ្ធតតា** ភាពជាបុគ្គល អ្នកមិនរើរះ ឬ មិនសើរើ រវើរវាយ ។

**១៤_អបគមម្ហតា** ភាពជាបុគ្គលជាអ្នកប្រាសចាកភាសានិយាយជាប់ៗ ឬតជិត ។

ចំណែកខាងលើនេះ ជាអានិសង្សនៃអ្នកមិនពោលនូវពាក្យមុសាវាទ គឺពាក្យកុហក នរជនណាពោលនូវពាក្យកុហក , នរជននោះលោកចាត់ទុកថា ជាមនុស្សថោកទាបបំផុតក្នុងលោក, សមនឹងព្រះពុទ្ធដីកាដែលមានមកក្នុងខុទ្ទកនិកាយ សុត្តនិបាតថា :

**យោ អត្តហេតុ បរហេតុ ធនហេតុ ចយោ**
**នរោ សក្ខិបុដ្ឋោ មុសាព្រូហិ តំ ជញ្ញា វសលោឥតិ៍ឋ**

នរជនណាជាសាក្សី ដែលគេសួរហើយ និយាយកុហក ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុទ្រព្យក្តី គប្បីដឹងថា នរជននោះជាមនុស្សថោកទាប ។

ព្រះពុទ្ធដីកាខាងលើនេះ និយាយពីមនុស្សដែលឈ្មោះថាថោកទាបព្រោះតែធ្វើសាក្សី ទុច្ចរិតនិយាយកុហក ។ ជនខ្លះដែលទទួលខ្លួនធ្វើជាសាក្សីបុគ្គលដទៃ ក្នុងតុលាការក្តី ក្នុងសភាពដទៃក្តី កាលបើគេសួរសាករកសេចក្តីពិត នៃហេតុផលរឿងរ៉ាវយ៉ាងណាៗ ដើម្បីនឹងវិនិច្ឆ័យរកយុត្តិធម៌ក៏និយាយកុហកខុសចាកសេចក្តីពិត មិនឃើញថាឃើញ មិនឮថាឮ ឃើញឮមិនឃើញមិនឮ ឃើញឮយ៉ាងនេះ ថាឃើញឮយ៉ាងនោះទៅវិញ ឃើញត្រឹមតែប៉ុណ្ណេះ ថាប៉ុណ្ណោះទៅវិញ រឿងយ៉ាងនេះបង្វែរកែថា យ៉ាង

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះទៅវិញ ពង្វាងអោយខុសពីហេតុពិត ។ ការធ្វើសាក្សីវៀចវេយ៉ាងនេះ ព្រោះដើម្បីគេចខ្លួន អោយរួចចាកពីទោសទណ្ឌកម្មក្តី ព្រោះដើម្បីសង្គ្រោះ រំដោះអ្នកដទៃក្តី ព្រោះការកុហកនេះ ដើម្បីអោយទ្រព្យព្រោះតែអ្នកកើតក្តីមួយខាងណានោះ សូកប៉ាន់ខ្លួនក្តី អំពើកុហកពង្វាងវង្វេរការពិតទាំងនេះ ឈ្មោះថា ជាអំពើថោកទាប អ្នកប្រព្រឹត្តក៏ឈ្មោះថា ជាមនុស្សថោកទាបដែរ ព្រោះប្រព្រឹត្តថោកទាប គឺនិយាយកុហកភូតភរនោះឯង ។

ព្រះពុទ្ធដីកាមួយកន្លែងទៀត បានពោលបញ្ជាក់អំពីការប្រើសម្តីថា :

**តមេវ វាចំ ភាសេយ្យ យាយត្តានំ នតាបយេ**
**បរេ ចន វិហឹសេយ្យ សាវេ វាចា សុភាសិតា ។**

បុគ្គលគប្បីពោលវាចានោះឯង ដែលមិនញុំាងអោយខ្លួនក្តៅក្រ-ហាយ ទាំងមិនបៀតបៀនអ្នកដទៃវាចានោះឯងជាសុភាសិត ។

អណ្តាតតែមួយ ដែលគ្រលាស់ចេញពីសំដីមកនោះ រមែងអោយគុណ បើគេប្រើសំដីល្អ តែអាចអោយទោសទុក្ខក្តៅក្រហាយ ទាំងខ្លួនឯងនឹងអ្នកដទៃ ។ សំដីល្អពិរោះ បើនិយាយចេញមក សូម្បីតែមួយម៉ាត់ក៏មានតម្លៃស្មើនគរមួយ, អាចធ្វើអោយបានផ្ទះ អោយបានស្រុក អោយបាននគរ អោយបានមាសប្រាក់ សុខសន្តិភាព អោយកើតសេចក្តីស្រុះស្រួល មានមេត្រីចិត្តមិនភាពលាភផលយ៉ាងប្រសើរ ។ សំដីអាក្រក់បើគេនិយាយ

ចេញមកត្រឹមតែមួយម៉ាត់ ក៏នាំអោយមានរឿងនាំអោយកើតភ័យធំ នាំអោយកើតវិវាទទាស់ទែង ឬកើតចលាចលកោលាហលដល់គ្នា និងគ្នាវឹកវរ ឬ នាំអោយខូចស្រុកទេស ខូចមាសប្រាក់ ធ្លាក់ទោសទុក្ខក៏មាន ។ **សុភាសិតខ្មែរ** លោកបានពោលថា "អណ្តាតជាអាទឹកន្លង បានសុខទុក្ខផងពីព្រោះអណ្តាត " ។

អាស្រ័យសំដីមានឥទ្ធិពល អោយផលល្អ ឬអាក្រក់បានយ៉ាងនេះហើយ ទើបលោកប្រៀនប្រដៅ អោយពោលតែវាចា ដែលមិនញ៉ាំងខ្លួនអោយក្តៅក្រហាយទាំងមិនបៀតបៀនអ្នកដទៃ ។

តើវាចារប្រភេទនេះដូចម្តេច? វាចារដែលល្អត្រូវធម៌ ត្រូវវិន័យត្រូវច្បាប់ទម្លាប់មិនមែនដឹកនាំអោយប្រើប្រាជ្ញា មិននាំអោយចាស់ស្រ្តាវុធ មិននាំអោយកើតសេចក្តីប្រគួតប្រកាន់ មិននាំអោយកើតជម្លោះ មិនញុះញង់អោយគេឈ្លោះគ្នាទេ គឺវាចារដឹងនាំអោយអ្នកស្តាប់ចូលចិត្ត គាប់ចិត្ត ពេញចិត្តតែម្យ៉ាង ។

ព្រោះសម្តីល្អនោះ មានលំអរទាំងខាងដើម ទាំងកណ្តាល ទាំងខាងចុង,មានការនិយាយជារបៀប មានការនិយាយជាធម៌មានការនិយាយគួរជាទីស្រលាញ់ មានការនិយាយពិត មានការនិយាយត្រូវពេលវេលា មានការនិយាយពិរោះផ្អែមល្ហែម មានការនិយាយជាប្រយោជន៍ និងមានការនិយាយដោយចិត្តមេត្តាជាលក្ខណៈ ។ រួមមកគឺវចីសុចរិត ស្ថិតនៅក្នុង

Websites: WatKhemaraRatanaram.org or WatKhmers.org

វាចាពិត១ វាចាផ្អែះផ្អា១ វាចាពីរោះ១ វាចាមានប្រយោជន៍១ ឈ្មោះថា សំដីដែលមិនញ៉ាំងខ្លួនអោយក្តៅក្រហាយ ទាំងមិនបៀតបៀនអ្នកដទៃ វាចាទាំងបួនផ្នែកនេះឯងឈ្មោះថា " សុភាសិត " គឺសំដីល្អ ពំនោលល្អ ដែលមនុស្សគប្បីយកមកប្រើ ក្នុងកាលដែលត្រូវនិយាយ ។

អ្នកប្រាជ្ញទាំងឡាយលោកមើលឃើញ ទោសនៃសំដីកុហក អាក្រក់ ខ្មោះខ្ទរ មិនគួរស្តាប់ដូចបានពោលមកហើយពីខាងដើម ទើបលោកមិន និយាយពាក្យកុហកភូតភរសោះ, លោកពោលតែពាក្យសច្ចៈ ។

ពាក្យសច្ចៈជាពាក្យមានរសជាតិ មានគុណភាពខ្ពង់ខ្ពស់ ថ្លៃថ្នូរ អាចនាំអ្នកនិយាយអោយបានសុខចំរើន ឥតមានមោះម៉ៃ ភយន្តរាយក្នុង លោកនេះ និងលោកខាងមុខ ។

ពុទ្ធភាសិតលោកពោលថា **សច្ចំ វេ អមតាវាចា**, ពាក្យ ពិតជាវាចាមិនស្លាប់ ។ សំដៅយកការមិនស្លាប់នូវប្រយោជន៍ដែលត្រូវបាន ជាវាចារមិនសាបរលាប នាំអ្នកនិយាយអោយបានសុខចំរើន មានកេរ្តិ៍ឈ្មោះ ល្អជាដរាប ។ ជនដែលពោលនូវពាក្យសច្ចៈ តែងមានអ្នកទទួលស្តាប់ថា ជាមនុស្សប្រាកដប្រជា អាចអោយអ្នកផងយកតំរាប់តាម និងយកធ្វើជា មុខជាបាវ ។

កាលបើជនណាមួយ បានទទួលកិត្តិយសដូច្នោះហើយ លាភយស និងសេចក្តីសរសើរ ព្រមទាំងសេចក្តីចំរើន ក៏ហូរចូលមកដល់ជននោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឃើញប្រាកដ ទាន់ភ្នែកក្នុងបច្ចុប្បន្នកាល ។

សច្ចៈចែកចេញជា ៦ យ៉ាងគឺៈ

**១.វាចាសច្ចៈ** ពិតខាងសម្ដី

**២.សម្មតិសច្ចៈ** ពិតដោយសន្មត

**៣.សភាវសច្ចៈ** ពិតខាងសភាវៈ

**៤.អរិយសច្ចៈ** ពិតដ៏ប្រសើរ

**៥.បរមត្ថសច្ចៈ** ពិតខាងបរមត្ថ

**៦.និព្វានសច្ចៈ** ពិតខាងព្រះនិព្វាន ។

វាចាសច្ចៈ ពិតខាងសំដី បានដល់ការនិយាយទៀងត្រង់មិនវៀចវេរ ។ សម្មតិសច្ចៈ ពិតដោយសន្មត ដូចគេសន្មតថា ប្រុសស្រីមនុស្សសត្វជាដើម សភាវសច្ចៈ ពិតខាងសភាវៈ បានដល់ព្រះត្រៃលក្ខណ៍ ទាំង ៣ គឺ អនិច្ចំ ទុក្ខំ អនត្តា សង្ខារទាំងឡាយមិនទៀងជាទុក្ខ មិនមែនខ្លួនប្រាណ ។ អរិយសច្ចៈ ពិតដ៏ប្រសើរ បានដល់ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ចៈ បើពោលអំពីទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើម ក៏ឃើញថាទុក្ខមែន ។ បរមត្ថសច្ចៈពិតខាងបរមត្ថ បានដល់ចិត្ត ចេតសិក រូបនិព្វាន គឺទៀងជានិច្ចចិត្ត ចេតសិករូបនិព្វាន ឥតមានអ្នកណាអាចផ្លាស់ប្ដូរចិត្តជា ចេតសិក ជាចិត្ត រូបជានិព្វាន និព្វានជារូបដូច្នេះបានឡើយ ។

និព្វានសច្ចៈ ពិតខាងព្រះនិព្វាន បានដល់ការរលត់នូវកងទុក្ខ អស់ឥតមានសេសសល់ ទោះបីព្រះពុទ្ធអង្គដែលបានត្រាស់ដឹងឡើងក្នុងលោក

ក៏ព្រះអង្គសំដែងថា និព្វានពិតជារលត់អស់ នូវកិលេសសាសវ ដោយពិតប្រាកដឥតមានផ្លាស់ប្តូរកែប្រែឡើយ ។

សមដូចពុទ្ធភាសិត ដែលមានមកក្នុងគម្ពីរខុទ្ទកនិកាយថេរគាថាថា:

**យំ ពុទ្ធោ ភាសតី វាចំ ខេមំ និព្វានបត្តិយា**
**ទុក្ខស្សន្តកិរិយាយ សាវេ វាចានមុត្តមា ។**

ព្រះពុទ្ធត្រាស់វាចាណា ជាវាចាក្សេម ដើម្បីលុះព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ, ព្រះវាចានោះឯងខ្ពង់ខ្ពស់ជាងវាចាទាំងឡាយ ។

ពុទ្ធភាសិតមួយកន្លែងទៀតពោលថា :

**សច្ចំ វេ អមតាវាចា ឯសធម្មោ សនន្តនោ**
**សច្ចេ អត្ថេ ច ធម្មេ ច អាហុសន្តោបតិដ្ឋិតា ។**

ពាក្យសច្ចៈនឹងឯងជាវាចាមិនចេះស្លាប់ ធម៌នេះជាធម៌ជាន់ចាស់ សប្បុរសទាំងឡាយជាអ្នកតាំងមាំ ក្នុងពាក្យសច្ច ដែលជាអត្ថ ជាធម៌ ។

សច្ចធម៌ បើបុគ្គលណាបានកាន់ពិតប្រាកដ ស៊ូរបង់ជីវិតមិនអោយដាច់ ដូចភាសិតខ្មែរថា "សូរស្លាប់ទៅកាប់ រសធម៌កុំបីបង់" នោះឯងបុគ្គលនោះទោះ បីមានភយន្តរាយដល់ជីវិត ក៏អាចរំដោះខ្លួនរួចដោយសុវត្ថិភាព អ្នកប្រាជ្ញបុរាណបាននិទាន ទុកក្នុងសាស្ត្រាព្រះអភិធម្ម ៩ បរិច្ឆេទថា :

# រឿងមេគោ កូនគោ និងខ្លា

កាលបីព្រេងនាយ មានសត្វ ៣ គឺមេគោ ១ កូនគោ ១ ខ្លាធំ ១ ត្រាចស្វែងរកអាហារក្នុងព្រៃ ជាមួយគ្នា ខ្លាឃើញមេគោក៏លបសង្គ្រប់ចាប់បានប៉ងនឹងស៊ីជាចំណី តែមេគោអង្វរថា : " សូមអ្នកអាណិតខ្ញុំ បើកអោយខ្ញុំទៅបំបៅកូនតូចសិន បំបៅហើយខ្ញុំនឹងត្រឡប់មកអោយអ្នកស៊ីពុំខាន ខ្លាក៏បើកអោយទៅ ។ មេគោទៅបំបៅកូនហើយលាកូនថា " ម៉ែត្រូវទៅអោយខ្លាស៊ី ព្រោះគេប្រុងនឹងខាំស៊ីតែម៉ែអង្វរគេថា មកបំបៅកូនឯងសិន ហើយនឹងត្រឡប់ទៅអោយគេស៊ីវិញ " ។ កូនគោថា "ខ្ញុំទៅដែរ ! ហើយមេគោក៏បណ្តើកូនគោទៅជួបនឹងខ្លា តាមពាក្យសន្យារបស់ខ្លួន មេគោកូនគោទៅជួបនឹងខ្លា ។ ប្រារព្ធនឹងខាំមេគោ កូនគោស្ទុះចូលទៅនិយាយថា "ម៉ែខ្ញុំមានគុណលើរូបខ្ញុំណាស់ ខ្ញុំសូមសងគុណគាត់ សូមអ្នកខាំស៊ីខ្ញុំជាកូនចុះ ទុកម៉ែខ្ញុំអោយរស់ទៅវិញ តាមពាក្យសន្យានឹក ឃើញកូនគោដឹងគុណម៉ែជាអស្ចារ្យដូច្នោះ ក៏មានចិត្តអាណិតអាសូរ ស៊ូទ្រាំអត់សំរេកគំលាន ឈប់ខានស៊ី មេគោនោះ ហើយសត្វទាំង ៣ ក៏យកគ្នាជាមិត្តសម្លាប់ ត្រាច់ស្វែងរកអាហារក្នុងព្រៃជាមួយគ្នា ជាសុខសាន្តរហូតដល់អស់ជីវិតរៀងខ្លួន ។

ពាក្យថា "បញ្ជិតប្រែថា អ្នកវៀរចាកបានដល់អ្នកបួសទាំងអស់ទូទៅ ទោះបីជាជាតិណាសាសន៍ណា ក៏ដោយចុះដែលបានវៀរចាកអំពើ

Websites: WatKhemaraRatanaram.org or WatKhmers.org

អាក្រក់ដោយត្រៃទ្វារ ។ ប៉ុន្តែបើអ្នកបួសរូបណាសម្លាប់សត្វ ឬ បៀត បៀន ឬធ្វើទុក្ខបុកម្នេញមនុស្សសត្វដទៃ នោះមិនឈ្មោះថា បព្វជិតទេ ដូចបទបាលីថា **នហិ បព្វជិតោ បរូបឃាតី ។**

ពាក្យថា "សមណៈ ប្រែថា អ្នកស្ងប់រម្ងាប់" ចាកអំពើអាក្រក់គ្រប់ ជំពូក ។ បុគ្គលអ្នកស្ងប់រម្ងាប់តាមធម្មតា លោកហៅថា សមណៈ ក៏គឺបព្វ ជិតហ្នឹងឯង ប៉ុន្តែបើសមណៈ នៅតែបៀតបៀន មនុស្សសត្វដទៃ ក៏មិន ឈ្មោះថា សមណដែរ ដូចបទបាលីថា : **សមណោ ហោតិ បរំ វិហេឋយន្តោ ។**

បុគ្គលដែលបានឈ្មោះថា សមណៈ មិនមែនសំគាល់ដោយការពារ នូវសីលៈ នោះទេ, លុះតែបុគ្គលណាបានលះបង់នូវអំពើអាក្រក់ ចេញដោយ កាយវាចាចិត្តទើបឈ្មោះថា សមណៈ ។

សមដូចពុទ្ធភាសិត ដែលមានមកក្នុងធម្មបទដ្ឋកថា ភាគទី៦ទំព័រ ៧៦ ទ្រង់សំដែងថា :

**ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ ឥច្ឆា លោភសមាបន្នោ សមណោ កឹ ភវិស្សតិ យោច សមេតិ បាបានិ អណុំ ថូលានិ សព្វសោ សមិតត្តា ហិបាបានំ សមណោតិ បវុច្ចតិ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

បុគ្គលឈ្មោះថា ជាសមណ ដោយភាពជាអ្នកមានក្បាលត្រងោល មិនទាន់បានទេ, បុគ្គលអ្នកមិនមានវត្ត ពោលតែពាក្យលះលោះប្រកប ដោយសេចក្ដីចង់បាន និងសេចក្ដីលោភ ឈ្មោះថាសមណៈ ដូចម្ដេចបាន ? លុះត្រាតែបុគ្គលណារម្ងាប់បាបទាំងឡាយ ទាំងតូចទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ បុគ្គលនោះរម្ងាប់បានហើយ ។

ពាក្យថា "សមណ" ជាឈ្មោះនៃបព្វជិត គ្រប់ប្រភេទ ។ សមណៈប្រភេទណាក៏ដោយច្រើនតែកោសក់មានសីលៈ ត្រងោលប៉ុន្តែព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា បុគ្គលដែលបានឈ្មោះថា ជាសមណៈ មិនមែនដោយហេតុត្រឹមតែក្បាលត្រងោលប៉ុណ្ណោះទេ, ។

បើបុគ្គលដែលប្រាសចាកសីលវត្ត និងធុតង្គវត្ត គឺមិនមានសីលបរិសុទ្ធ មិនប្រព្រឹត្តធុតង្គផង ពោលពាក្យលេះលោះ ពុំពិតប្រាកដផង ប្រកបដោយសេចក្ដីចង់បាន នូវអារម្មណ៏ទាំងឡាយ ដែលមិនទាន់ដល់មកផង ប្រកបព្រមដោយសេចក្ដីលោភនូវអារម្មណ៏ទាំងឡាយ ដែលមកដល់ផង នោះនឹងជាសមណៈដូចម្ដេចបាន ? លុះតែបុគ្គលណារម្ងាប់បង់នូវបាបទាំងឡាយ ទោះបីតូចក្ដីធំក្ដី បានសព្វគ្រប់ បុគ្គលនោះទើប លោកហៅថា សមណៈ ព្រោះបាបទាំងនោះបានរម្ងាប់ហើយ ។

បើបុគ្គលណាបានប្រព្រឹត្តវត្ត ដោយត្រឹមត្រូវ និងលះបង់នូវបាបទាំងពួងបាន តែងជួបប្រទះបាននូវសេចក្តីសុខ ហៅថា "សមណៈ" ពាក្យថា " សុខ " នេះ ជាឈ្មោះឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នា ជាទីគាប់ចិត្តរបស់មនុស្សសត្វទូទៅ ។

សេចក្តីស្រួលកាយសប្បាយចិត្ត របស់មនុស្សសត្វ គ្រប់រូបគ្រប់សញ្ជាតិក្នុងលោក ហៅថាសុខ គឺសភាពណាមួយដែលនាំចិត្តមនុស្សសត្វអោយត្រេកអរ រីករាយគួរត្រូវការចង់បានចង់ជួបប្រទះ ។

សេចក្តីសុខនេះ បើចែកតាមប្រភេទនៃបុគ្គលមាន ២ យ៉ាង

**១_គិហិសុខ** សុខរបស់គ្រហស្ថ

**២_សមណសុខ** សុខរបស់សមណៈ ។

សមណៈសុខមាន ៨ យ៉ាងគឺៈ

**១_ធនធញ្ញ បរិគ្គហាភាវោ** ភាពនៃការមិនមានសេចក្តីហួងហែងចំពោះទ្រព្យសម្បត្តិ និងស្រូវអង្ករ ។

**២_អនវជ្ជបិណ្ឌបាត បរិយេសនភាវោ** ភាពនៃការស្វែងរកចំពោះបិណ្ឌបាត ដែលឥតទោសគឺ បិណ្ឌបាតដោយធម៌ ។

**៣_និព្វុតបិណ្ឌបាតភុញ្ជនភាវោ** ភាពនៃការបរិភោគអាហារបិណ្ឌ-បាតដ៏ត្រជាក់ ។

**៤_រដ្ឋបីឡនាភាវោ** ភាពនៃការមិនមានសេចក្តីបៀតបៀននៃរដ្ឋ ។

**៥-ឧបករណេសុ និច្ឆរាគតាវោ** ភាពនៃសមណៈមិនមានឆន្ទរាគក្នុងឧបករណ៍ ។

**៦-ចោរវិលោបេ និព្ភយតាវោ** ភាពនៃសមណៈមិនភ័យក្នុងការលួចប្លន់នៃចោរ ។

**៧-រាជរាជ មហាមត្តេហិ អសំសដ្ឋតាវោ** ភាពនៃសមណៈមិនជាប់ជំពាក់ដោយស្តេច និង មហាអាមាត្យនៃស្តេច ។

**៨-ចតូសុ ទិសាសុ អប្បដិហតតាវោ** ភាពនៃសមណៈមិនទើសទាក់ចំពោះទិសទាំង៤ ។

សូមលើកគិហិសុខទុក្ខមិនបានអធិប្បាយក្នុងទីនេះ សូមសំដែងចំពោះតែសមណៈសុខ ។

## អធិប្បាយពាក្យសេចក្តី

ពាក្យថា " មិនមានសេចក្តីហួសហែងចំពោះទ្រព្យសម្បត្តិ និងស្រូវអង្ករ" ដោយហេតុថា សមណៈបព្វជិត ក្នុងព្រះពុទ្ធសាសនា ជាអ្នកមានករណីកិច្ចផ្សេងដោយឡែកពីគ្រហស្ថ មិនត្រូវមានការខ្វល់ខ្វាយ ស្វែងរកទ្រព្យសម្បត្តិ និងធញ្ញជាតិផ្សេងៗ មានស្រូវអង្ករជាដើមទេ បើទុកជាបានទ្រព្យសម្បត្តិសមណៈបរិក្ខារដោយសទ្ធាជ្រះថ្លារបស់គ្រហស្ថ ក៏មិនត្រូវហួងហែង ទុកដាក់លាក់លៀម ថែរក្សាប្រើប្រាស់តែម្នាក់ឯង ដែលប្រកបដោយមច្ឆរិយទេ ។

ការហួងហែង មានការលាក់លៀម, ការបំបិទបំបាំងដោយការ ដាក់នេះ លោកថា ជាហេតុមួយនាំមកនូវសេចក្តីទុក្ខរឿយៗ ព្រោះជា ហេតុនាំអោយមានសេចក្តីទុក្ខព្រួយភ័យបារម្ភជានិច្ច ចំពោះទ្រព្យសម្បត្តិ ដោយខ្លាចក្រែងអន្តរាយផ្សេងៗ មានចោរលួចប្លន់ជាដើម ។ ត្រង់ការ ដែលគ្មានសេចក្តីហួងហែងនេះឈ្មោះថា ជាសុខរបស់សមណៈ ដោយមិន មានទុក្ខព្រួយក្នុងការថែទាំង ។

ពាក្យថា " ការស្វែងរកបិណ្ឌបាតដែលឥតទោស " បានដល់ការ ស្វែងអាហារដែលប្រកបដោយធម៌វិន័យ ដែលជាការស្វែងរកប្រាប់ចាក អនេសនធម៌ ។ ការរស់នៅរបស់សមណៈតែងជាប់ទាក់ទងដោយគ្រហស្ថ ដែលមានសទ្ធាដោយពិត ប៉ុន្តែមិនមែនរបស់ដោយកិច្ចទាក់ទង នឹងគ្រហស្ថ ក្នុងផ្លូវ ពាណិជ្ជកម្ម កសិកម្ម ឬ វេជ្ជកម្មជាដើមឡើយ ។ ការស្វែងរក របស់សមណៈ ដើម្បីជីវភាពរបស់ខ្លួន ត្រូវប្រកបដោយផ្លូវបរិសុទ្ធវិសេស ជាងគ្រហស្ថ ទើបសមគួរដល់ឋានៈនៃខ្លួនជាសមណៈ ក្នុងព្រះពុទ្ធសាសនា មិនត្រូវបណ្តោយអោយការរស់នៅច្រឡូកច្រឡំ ដោយផ្លូវទុច្ចរិតទេ ។ ការ ស្វែងរកបិណ្ឌបាត ប្រាសចាកបាបធម៌ និងអនេសនៈ ឈ្មោះថាជាសុខ របស់សមណៈដោយអាជីវបរិសុទ្ធ ដែលគេអាចចាប់ថ្នាក់បាន ។

ពាក្យថា " ការបរិភោគអាហារបិណ្ឌបាតដ៏ប្រសើរ" ដោយហេតុថា សមណៈដែលស្ម័គ្រចិត្តទទួលភ្នួស ក្នុងព្រះពុទ្ធសាសនា ត្រូវជាអ្នកសុខចិត្ត

ព្រមទទួល អាហារបិណ្ឌបាតតាមតែប្រទះ គឺជួនកាលបានត្រជាក់ ជួនកាលបានអាហារក្តៅ ប៉ុន្តែធម្មតាអាហារបិណ្ឌបាត ដែលទាយក ទាយិកា ដោះដួសបំរុងទុកដាក់បាត្រនោះ បើទើបនឹងដោះថ្មីៗ ហើយភិក្ខុសាមណេរបានទៅទទួលជាដំបូង ក្នុងកាលដែលនៅក្តៅ ក៏ជាភ័ព្វរបស់ភិក្ខុសាមណេរ ដែលទទួលបិណ្ឌបាតមុននោះម្តងៗ ។ តាមពិតអាហារបិណ្ឌបាតសំរាប់ដាក់បាត្រចំពោះ ព្រះសង្ឃច្រើនតែត្រជាក់ ព្រោះគេដោះទុកយូរដើម្បីព្រះសង្ឃដែលនិមន្ត មកបិណ្ឌបាតដែលឃ្លាតពេលពីគ្នា គឺជួនកាលព្រះសង្ឃពីរ ឬបី រូបមកទទួលបិណ្ឌបាតជាមួយគ្នា ជួនកាលព្រះសង្ឃ ១រូបៗ មកទទួលរយាលអំពីគ្នា ម្លោះហើយអាហារបិណ្ឌបាតនោះក៏ទៅជាអាហារត្រជាក់ ។ ត្រង់កាលដែលព្រមសុខចិត្តបរិភោគត្រជាក់នេះរាប់ថាជាតបៈធម៌មួយ សំរាប់ញ៉ាំងចិត្តអោយស្ងប់រម្ងាប់ថា ជាសុខស្រួលរបស់សមណៈក្នុងការទូន្មានចិត្ត មិនបណ្តោយចិត្តអោយហើររហាធរលោភលាំក្នុងរសនៃអាហារ ។

ពាក្យថា "មិនមានការបៀនបៀននៃរដ្ឋ" ដោយហេតុថា សមណៈមានភាពជាអ្នកស្លូតបូត មានកាយវាចាចិត្តស្ងប់តាម ត្រៃសិក្ខាសំរាប់សមណៈ មិនមានការបៀតបៀនប្រើអំណាច យសសក្តិជិះជាន់សង្កត់សង្កិនរឹងអូសយកទ្រព្យសម្បត្តិ របស់មហាជនអ្នកនៅក្នុងដែនណាមួយទេ ពុំមែនដូចជាមនុស្សទុច្ចរិត ដែលមានយសសក្តិអំណាច ហើយបៀតបៀន

ដោយឧបាយណាមួយ ដើម្បីអោយបានទ្រព្យសម្បត្តិមាសប្រាក់ជាដើម អំពីអ្នកដែនទោះឡើយ ។ ការមិនប្រព្រឹត្តបៀតបៀន ញាំញី អ្នកដែននេះ ឈ្មោះថា ជាសុខរបស់សមណៈ ដោយពុំមានគេចោទប្រកាន់ ព្រោះប្រ-ព្រឹត្តគន្លងច្បាប់សំរាប់រដ្ឋ ដែលនាំអោយមានឈ្មោះសៅហ្មងនោះឡើយ ។

សមនឹងពុទ្ធភាសិតដែលមានមកក្នុងគម្ពីរសំយុត្តនិកាយសគាថវគ្គ ព្រះអង្គទ្រង់សំដែងថា :

**សមណីធ អរណា លោកេ**, ពួកសមណៈ ក្នុងសាសនានេះ មិនមែនជាសឹកសត្រូវក្នុងលោកទេ ។

ពាក្យថា "មិនមានឆន្ទរាគក្នុងឧបករណ៍" នោះសំដៅយកភាពនៃសមណៈ មិនមានសេចក្តីប្រាថ្នា ប៉ុនប៉ង ត្រេកអរ រវេះរវាមចំពោះគ្រឿងប្រើប្រាស់មានចីវរជាដើមនោះទេ ។ គ្រឿងឧបករណ៍ផ្សេងៗមានចីវរ និងសេនាសនៈ ជាដើមដែលសមណៈ បានទទួលមកហើយប្រកបដោយធមិជារបស់ខ្លង់ខ្ពស់ក្តី ថោកទាបក្តី មិនត្រូវជាប់ជំពាក់ ឬរិះគន់ ចំពោះឧបករណ៍នោះឡើយ ត្រូវតាំងចិត្ត ជាឧបេក្ខាក្នុងគ្រឿងជាឧបករណ៍ជាដរាប ។

គ្រឿងឧបករណ៍ដែលមិនទាន់បានមក ក៏មិនត្រូវប្រាថ្នារវះរវាមហួសហេតុ ដើម្បីរក្សាភាពនៃខ្លួន ជាសមណៈអោយតាំងនៅល្អ ។ ត្រង់

ដែលមិនមានឆន្ទរាគ គឺសេចក្តីប្រាថ្នារហើរហោច ក្នុងឧបករណ៍ឈ្មោះថា ជាសុខរបស់សមណៈ ដោយពុំមានរិះគន់ពេបជ្រាយឡើយ ។

ពាក្យថា " មិនមានភ័យក្នុងការលួចប្លន់នៃចោរ " បានដល់ភាពនៃសមណៈមិនមានភិតភ័យព្រួយបារម្ភអំពីចោរដែលលួចប្លន់ ព្រោះសមណៈជាអ្នកមិនសន្សំទ្រព្យសម្បត្តិ ដែលគរអោយចោរមានបំណងមកលួចប្លន់បានទេ ។ ការលួចប្លន់នេះចោរនេះ ជាទុក្ខភ័យមួយរបស់មនុស្សអ្នកមានទ្រព្យក្នុងលោក ការមិនមានភ័យអំពីចោរលួចប្លន់ឈ្មោះថា ផុតពីសេចក្តីទុក្ខព្រួយអំពីចោរហើយ ទើបលោកចាត់ថា ជាសុខរបស់សមណៈ ។

ពាក្យថា " មិនជាប់ជំពាក់ដោយស្តេច និងអាមាត្យនៃស្តេច" សំដៅយកភាពនៃសមណៈមិនត្រូវច្រឡូកច្រឡំ ទាក់ទង ញឹកញយដោយការចុះឡើងច្របូកច្របល់រឿយៗ ជាមួយស្តេច ឬ អាមាត្យ លោកអ្នករដ្ឋការរបស់ស្តេចទេ ព្រោះថាស្តេច និងអាមាត្យ ដែលមានកិច្ចការក្នុងប្រទេស ជាច្រើនយ៉ាង សមណៈជាអ្នកមានភេទផ្សេងមានករណីកិច្ចផ្សេង មិនត្រូវបណ្តោយខ្លួនអោយមាន ការប្រព្រឹត្តជាប់ទាក់ទង ច្រឡូកច្រឡំជាមួយ ដោយញឹកញយទេ ព្រោះថាការជាប់ជំពាក់ដោយឥស្សរជនមានស្តេចជាដើមនោះ ជាហេតុនាំអោយឥស្សរជន ដែលមានកិច្ចការរវល់តែបែរមកធ្វើបដិសណ្ឋារៈ ចំពោះសមណផង នាំអោយមានហេតុការណ៍មួយ ពុំសមគួរដល់សមណៈភាពផង ។ ការមិនជាប់ជំពាក់នេះ ឈ្មោះថា

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាសុខរបស់សមណៈ ដ្បិតសមណៈត្រូវមានឱកាសទំនេរ អំពីកិច្ចការរបស់គ្រហស្ថហើយ ។

ពាក្យថា " មិនទើសទាក់ចំពោះទិសទាំង ៤ " បានដល់ភាពនៃសមណៈដែលត្រាស់ទៅក្នុងទិសណាមួយ បណ្ដាទិសទាំង ៤ ឬទិសទាំង ៨ ចេះតែអាចទៅបានទាំងអស់មិនសូវមានចិត្តជាប់ជំពាក់ ចំពោះទីកន្លែងមួយៗទេ ដោយហេតុថា សមណៈជាអ្នកមិនមានទ្រព្យសម្បត្តិទុកជាកម្មសិទ្ធិរបស់ខ្លួននោះទេ ទោះបីនឹងចង់ត្រាច់ទៅកាន់ទិសណាមួយក៏អាចទៅបានដោយងាយ មិនលំបាកក្នុងការដោះចេញដូចគ្រហស្ថនោះទេ ។

ឋាវរវត្ថុជាកម្មសិទ្ធរបស់សមណៈក្ដី ការឃាត់ឃាំងនៃរដ្ឋការចំពោះសមណៈក្ដី ក៏ពូវសូវមាន ព្រោះហេតុនោះ សមណៈអាចចេញដើរទៅកាន់ទីណាមួយ ក៏ចេះតែទៅបានដោយស្រួល ឥតមានទើសទាក់ជាប់ជំពាក់ដូចគ្រហស្ថនោះឡើយ ។ ការមិនមានទើសទាក់ក្នុងទិសរបស់សមណៈនោះឈ្មោះថាជាសុខរបស់សមណៈ ដោយហេតុមានផ្លូវទូលាយក្នុងការកែអផ្សុកមិនជាប់នៅក្នុងទទីនិមួយៗ ។

បុគ្គលដែលជាបព្វជិត ឬក៏សមណៈ មិនមែនសំគាល់ត្រឹមតែស្លៀកដណ្ដប់ នូវសំពត់អម្ពត់ ប៉ុណ្ណោះទេ គឺត្រូវមានគុណធម៌ស្ថិតនៅក្នុងខន្ធសន្តានជានិច្ច សមដូចព្រះពុទ្ធដីកា ដែលមានមកក្នុងខុទ្ទកនិកាយ ធម្មបទ ខុទ្ទកនិកាយជាតក ខុទ្ទកនិកាយថេរគាថា ទ្រង់សំដែងថា **អរហេតោ**

**ទមសច្ចេន នសោ កាសាវ មរហតិ ។** បុគ្គលណាប្រាកចាក ទម និងសច្ច បុគ្គលនោះមនគួរស្លៀកដណ្ដប់សំពត់កាសាវៈឡើយ ។

**ឧបេតោ ទមសច្ចេន សវេ កាសាវ មរហតិ,** បុគ្គលប្រកបដោយទម និងសច្ច បុគ្គលនោះឯងទើបគួរស្លៀកពាក់ដណ្ដប់សំពត់កាសាវៈបាន ។

**សញ្ញតោ បព្វជិតោ ន សាធុ,** បព្វជិត ឬសមណៈមិនសង្រួមពុំប្រសើរឡើយ ។

**សមណោ អស្សុ សុស្សមនោ ។** សមណៈគប្បីជាសមណៈល្អ ។ ដែលបានឈ្មោះថា សមណៈល្អ ត្រូវមានបធមិ កាលញ្ញូដឹងពេលវេលាមត្តញ្ញូ ដឹងប្រមាណក្នុងការបរិភោគនូវអាហារ ព្រមទាំងដឹងប្រមាណក្នុងការស្វែងរក ត្រូវមានខន្តី សេចក្ដីអត់ធន់ និងហេតុផ្សេងៗដែលគួរអត់ទ្រាំ សេចក្ដីនេះនឹងព្រះពុទ្ធដីកា មួយកន្លែងដែលមានមកក្នុងខុទ្ទកនិកាយជាតក ទសនិបាត ព្រះអង្គទ្រង់សំដែងថា ៖

**ឧនោទរោ យោ សហតេ ជិឃច្ឆំ**
**ទន្តោ តបស្សី មិត្តបានភោជនោ**
**អាហារហេតុ នករោតិ បាបំ តំ វេ**
**នទំ សមណំ អាហុ លោកេ ។**

នរណាមានពោះធូរ អត់ទ្រាំសេចក្តីស្រេកឃ្លានបាន ជាអ្នកទូន្មានខ្លួន មានសេចក្តីព្យាយាម មានការដឹង និងការបរិភោគល្មមប្រមាណ មិនធ្វើបាបព្រោះហេតុតែអាហារ លោកហៅនរនោះឯងថាសមណក្នុងលោក ។

បុគ្គលបុគ្គលណា បានបៀតបៀន ឬ ប្រទូស្តចំពោះសមណៈ ដែលជាអ្នកមិនប្រទូស្តតបទោសកំហុសនោះតែឯង ធ្លាក់មកលើបុរសបុគ្គលនោះវិញ ដូចជាព្រានឆ្កែឈ្មោះ កោកៈ សូមនាំរឿងនោះមកសំដែងដូចតទៅនេះ :

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់សំដែងព្រះធម៌ ទេសនា ចំពោះព្រានឆ្កែឈ្មោះកោកៈ ។

មានសេចក្តីដំណាលថា ថ្ងៃមួយព្រានឆ្កែនោះកោកៈ បានកាន់យកនូវធ្នូហើយបណ្តើរឆ្កែមួយហ្វូង ដើម្បីចូលទៅកាន់ព្រៃ បានជួបភិក្ខុមួយអង្គត្រង់ពាក់កណ្តាលផ្លូវ ដែលលោកនិមន្តទៅ ដើម្បីបិណ្ឌបាត, ព្រានឆ្កែឃើញហើយក៏ស្រាប់តែខឹង ហើយមានគំនិតថា ថ្ងៃនេះអញជួបមនុស្សកាឡកិណ្ណីប្រាកដជាមិនបានអ្វីទេ ។ ព្រះថេរនិមន្តចូលទៅក្នុងភូមិ ដើម្បីបិណ្ឌបាតលុះត្រឡប់មកវិញដើម្បីទៅកាន់វត្ត, ព្រានឆ្កែត្រាច់ចូលទៅក្នុងព្រៃហើយមិនបាននូវសត្វអ្វីមួយសោះ ដល់ពេលត្រឡប់មកវិញបានជួបនឹងព្រះថេរៈនោះ បានអោយសញ្ញាដល់ឆ្កែ ហើយបានពន្យុះឆ្កែទាំងឡាយ ដោយមាន

គំនិតថា ក្នុងថ្ងៃនេះអញឃើញមនុស្សកាឡកិណ្ណី ហើយបានចូលទៅកាន់ព្រៃ មិនបាននូវអ្វីសូម្បីបន្តិចបន្តួច អញនិងអោយឆ្កែខាំនូវមនុស្សនេះ ។

ព្រះថេរបាននិយាយអង្វរថា ម្នាលឧបាសក ! អ្នកកុំធ្វើយ៉ាងនេះឡើយ, ព្រាននោះពោលថា អញថាអញមិនបាននូវអ្វីមួយ ព្រោះហេតុតែជួបនូវមនុស្សនេះ បានចូលទៅក្នុងព្រៃដល់ចេញមកវិញបានជួបម្តងទៀត, ហើយបានពន្យុះឆ្កែអោយខាំនូវព្រះថេរនោះ ។ ព្រះថេរបានស្ទុះទៅឡើងដើមឈើកំពស់មួយជំហរបុរស ដោយប្រញាប់ ហើយស្ថិតនៅក្នុងទីនោះ ឆ្កែក៏បានទៅចោមរោមជុំវិញដើមឈើ ព្រានឈ្មោះកោកៈ ទៅកាន់ដើមឈើហើយនិយាយថា ច្បាស់ជាមិនរួចខ្លួនទេ ! រួចចាក់នូវបាតជើងព្រះថេរដោយចុងលំពែង, ព្រះថេរក៏បានអង្វរថា អ្នកកុំធ្វើយ៉ាងនេះឡើយ, ព្រានមិនអើពើនឹងពាក្យអង្វរហើយចាក់ព្រះថេរថែមទៀត ។

ព្រះថេរកាលបើព្រានចាក់នូវបាតជើងម្ខាង ក៏លើកឡើងនូវជើងម្ខាង លើកម្ខាងដាក់ម្ខាងៗ ក្តៅក្រហាយញ័រសព្វសាច់ ដោយការមុតនឹងចុងលំពែងដែលព្រាននោះចាក់ គួរអោយអាសូរព្រះថេរក្រៃពេក ! ឯចីវរក៏បានរបូតចេញពីស្មា លោកហើយគ្របទៅលើក្បាលព្រាននោះ ឆ្កែស្មានថាព្រះថេរក៏នាំគ្នាខាំនូវព្រាននោះ, ព្រះថេរក៏កាច់មែកឈើស្ងួតបង្អើលឆ្កែនោះ ឆ្កែច្រឡំខាំម្ចាស់ឯងដូច្នោះ ហើយក៏ចៀសចេញទៅ ។ ព្រះថេរមានសេចក្តីសង្ស័យខ្លាចខូចនូវសីលរបស់ខ្លួន បានចូលទៅកាន់សំណាក់ព្រះ-

សាស្ដាក្រាបទូលនូវរឿងរ៉ាវសព្វគ្រប់, ព្រះសាស្ដាទ្រង់ត្រាស់ថា ភាពជាសមណៈនៅដដែលមានខូចសីលទេ ឥតដាច់ ឬ សៅហ្មងអ្វីឡើយ រួចទ្រង់ត្រាស់ថាព្រាននោះ មិនមែនតែក្នុងកាលឥឡូវនោះទេ កាលពីដើមក៏ប្រទូស្តចំពោះ អ្នកមិនប្រទូស្តតបដូច្នោះដែរ រួចទ្រង់នាំអតីតនិទានមកដំណាលថា :

ក្នុងកាលកន្លងទៅហើយ មានពេទ្យម្នាក់បានត្រាច់ចូលទៅកាន់ស្រុកភូមិ ដើម្បីប្រយោជន៍ដល់ភរិយាមើលជំងឺ នឹងបានថ្លៃឈ្នួល ដើម្បីកំចាត់បង់នូវសេចក្ដីស្រេកឃ្លាន ។ បានឃើញនូវកុមារទាំងឡាយកំពុងលែងជុំៗគ្នា ក្បែរភូមិ, គាត់មានគំនិតអាក្រក់កើតឡើងថា អញនឹងយកពសមានពិតទៅដាក់ក្នុងរូងឈើមួយ ហើយប្រាប់កុមារទាំងឡាយនោះថា " កូនសត្វសារិកា " ។ កាលឃើញពស់ចិកនូវកុមារនេះហើយ អញនឹងបានព្យាបាល បានថ្លៃឈ្នួល ហើយនឹងបាននូវអាហារ ។ គ្រានោះមានកុមារម្នាក់បានលូកដៃទៅចាប់ចំកពស់ដឹងថាមិនមែនជាកូនសារិកា ក៏គ្រវែងពស់មកលើក្បាលពេទ្យនោះវិណក ហើយចឹកនូវពេទ្យដែលឈរនៅទីនោះដែរ ។ ហើយក៏ដល់នូវកិរិយាអស់ទៅនៃជីវិត ។

ព្រានឆ្កែឈ្មោះកោកៈ បានប្រទូសចំពោះអ្នកមិនប្រទូស្តតបហើយ បានដល់នូវសេចក្ដីវិនាស យ៉ាងនេះឯង ។ បុគ្គលណាមួយក្នុងលោកនេះបានប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ទោសកំហុសនឹងធ្លាក់មកលើបុគ្គល

នោះវិញ ដូចគេបាចដីខ្សាច់ទៅលើអាកាស ដល់ដីខ្សាច់មកវិញ គឺធ្លាក់ទៅលើបុគ្គលនោះឯង យ៉ាងណាមិញអ្នកប្រទូស្តគេៗ មិនប្រទូស្តតប អ្នកប្រទូស្តគេនោះ ក៏ដល់នូវសេចក្តីវិនាស ដោយហេតុផ្សេងៗ យ៉ាងហ្នឹងឯង ។

អ្នកប្រទូស្តគេៗមិនប្រទូស្តប ត្រូវបានទទួលទោស ១០ យ៉ាងគឺៈ

**១.វេទនំ ផរុសំ** ត្រូវបានទុក្ខវេទនាយ៉ាងខ្លាំង,

**២.ជានឹ** ត្រូវវិនាសទ្រព្យសម្បត្តិ

**៣.សរីរស្សេវ ភេទនំ** ត្រូវបែកធ្លាយ ឬបែកបាក់សរីរាង្គកាយ

**៤.គរុកំវាបិ អាពាធំ** ត្រូវមានអាពាធជទម្ងន់

**៥.ចិត្តក្ខេបំវបាបុណោ** ត្រូវត្រឡប់ចិត្ត (ខូចសតិ)

**៦.រាជតោវា ឧបសគ្គំ** ត្រូវរិបជាន់អំពីស្តេច

**៧.អព្ភក្ខានំ វទារុណំ** ត្រូវគេពោលបង្កាច់យ៉ាងអាក្រក់

**៨.បរិក្ខយំ វញាតីនំ** ត្រូវវិនាសពួកញាតិ

**៩.ភោគានំ វ បភង្គុណំ** ត្រូវខូចខាតទ្រព្យសម្បត្តិ

**១០.អថវស្ស អគារានិ អគ្គិ ឌហតិ បាវកោ,** ពុំនោះសោតត្រូវភ្លើងឆេះផ្ទះ ។

ពាក្យថា " យាចក " ប្រែថា "អ្នកសូម" ឬថា "អ្នកអង្វរ" ដូច្នោះក៏បានខ្មែរយើងច្រើននិយាយថា ស្មូមយាចក, កបណៈ អ្នកកំព្រា អទ្ធិក អ្នកដំណើរ វណិពូកៈ អ្នកនិយាយសរសើរសូម បានដល់អ្នកកំសត់ ទុគ៌តអត់

ឃ្លាន គឺអ្នកដែលជរាពិការ កំបុតដៃកំបុតជើង គមគាក់ ថ្លង់គ ខ្វាក់ខ្វិន, អ្នកដែលខូចខាតនូវអវៈយវៈណាមួយ មិនអាចប្រកបរបរអាជីវកម្មកើត, អ្នកនោះឯងមានជីវិតរស់នៅបានដោយការសុំទាន ។ អ្នកពិការខ្លះចេះច្រៀង ខ្លះចេះដេញចាប៉ី ខ្លះចេះកូតទ្រ ខ្លះចេះស្មូតធមិបទ, ខ្លះសុំគេត្រង់ៗតែម្តង ។

សប្បុរសជនអ្នកមានសទ្ធា មានចិត្តសប្បុរស ក៏បានជូនជាប្រាក់កាស ជាអង្ករ ត្រីសាច់ ជាផ្លែឈើ អាហារ នំចំណី គ្រប់យ៉ាងតាមដែលមាន ។ នរជនណាបានពោលនូវពាក្យសច្ចពិត ត្រង់រមែងបាននូវសេចក្តីសុខចំរើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះផង លោកខាងមុខផង ដោយពិតប្រាកដ ។

ផ្ទុយទៅវិញបើលះបង់នូវពាក្យសច្ចៈ ហើយពោលតែពាក្យអាក្រក់កុហក ភូតភត ឆបោកបញ្ឆោត ចំពោះព្រាហ្មណ៍ អ្នកប្រព្រឹត្តព្រហ្មចរិយធមិ ឬក៏សមណៈ អ្នកមានតបធមិ ប្រព្រឹត្តប្រតិបត្តិដើម្បីស្ងប់រម្ងាប់ចាករាគទិក្កិលេស មានលោភៈ ទោសៈ មោហៈ ជាដើម ឬមួយយកពួកវណិ ពួកស្មូមយាចក អ្នកកំសត់អត់ឃ្លាន ដទៃៗ ដោយពាក្យមុសាវាទ វវាទឃ្លាតចាកពាក្យពិតត្រង់ ពាក្យប្រពៃ នោះជាប្រធាននៃសេចក្តីវិនាសប្រាកដជាក់ស្តែង ដូចបានសំដែងមកពីខាងដើមហើយនោះ ។

Websites: WatKhemaraRatanaram.org  or  WatKhmers.org

ការសំដែងមកក្នុងគាថាទី ៥ នៃបរាភវសូត្រ ដែលមានសេចក្តីថា ៖

ជនបញ្ឆោតព្រាហ្មណ៍ ឬមួយសមណៈពួកស្មូម ឬអ្នកដទៃៗ ដោយមុសាវាទឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស ។

ការសំដែងមកនេះ ក៏សន្មត់ថា

ចប់ តែប៉ុណ្ណេះ ឯវ ។

# ធម្មទេសនា បរាភវសូត្រ

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

**នមាមិ ពុទ្ធំ គុណសាគរន្តំ**

**នមាមិ ធម្មំ សុគតេន ទេសិតំ**

**នមាមិ សង្ឃំ អរិយំ សុខេត្តំ**

**តស្សានុភាវេន សុខី សិរីសទា ។**

ខ្ញុំព្រះករុណាសូមនមស្ការចំពោះព្រះពុទ្ធ ជាទក្ខិណេយ្យដ៏ប្រសើរ សូមនមស្ការចំពោះព្រះសទ្ធម្មជាធម៌ គឺព្រះសុគតសំដែង ហើយដោយប្រពៃ, សូមនមស្ការចំពោះ ព្រះអរិយសង្ឃជាស្រែបុណ្យដ៏ល្អ ។ ដោយអានុភាពនៃកិរិយានមស្ការ ចំពោះព្រះត្រៃរតន៍នោះ សូមអោយសេចក្តីសុខចំរើន និងសិរីសួស្តីកើតមានសព្វៗកាល ។

បន្ទាប់អំពីនមស្ការ ដោយសង្ខេបបែបខ្លីនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមលើកយកគាថាទី៦ នៃបរាភវសូត្រមកសំដែងចែកជូនដល់អស់លោកអ្នក ជាពុទ្ធបរិស័ទទាំងឡាយ ដែលមានបសាទសទ្ធាជ្រះថ្លា ហើយបានលះបង់បលិពោធ គ្រឿងកង្វល់ ចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកជួបជុំគ្នាក្នុងទីនេះ ដើម្បីស្តាប់នូវព្រះសទ្ធម្មវិសេសទេសនា ដែលខ្ញុំព្រះករុណាអាត្មាភាព និងបានសំដែងក្នុងកាលឥឡូវនេះ :

ទេវតាទូលសួរតទៅទៀតថា :

**ឥតិហេតំ វិជានាម បញ្ចមោ សោ បរាភវោ**

**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះ បើរាប់សង្គ្រោះវិនាសនោះឈ្មោះទី៥ ទាន់ហន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងអោយទាន វិនាសទី៦អ្វីជាប្រធាននាំសត្វអោយមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**

**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

បុរសអ្នកមានទ្រព្យធនធានច្រើន មានប្រាក់ចំរើន នឹងគ្រឿងអាហារ លបលាក់របស់ដែលឆ្ងាញ់ពិសារ ស៊ីម្នាក់ឯងណា ប្រធានវិនាស ។

## អធិប្បាយ

## គាថាទី ៦

បុរសស្ត្រីក្នុងលោក ដែលមានឧដ្ឋានភាពប្រឹងប្រែង ខ្នះខ្នែងស្វែងរក ទ្រព្យធនបានមកហើយដែលប្រកបដោយសម្មាអាជីវោ ហើយបានទាំងចៀសវាងនូវជំនួញខុសទាំង ៥ យ៉ាង ។

ជំនួញខុសទាំង ៥ យ៉ាងនោះគឺ:

**១-សត្ថវណិជ្ជា** ជួញគ្រឿងសាស្ត្រាវុធ សាស្ត្រាបានដល់គ្រឿងផ្លាស់ដៃ មានដាវជាដើម អាវុធបានដល់គ្រឿងប្រយោល មានកាំភ្លើងជាដើម ។

**២-សត្តវណិជ្ជា** ជួយសត្ត គឺជួយមនុស្ស

**៣-មំសវណិជ្ជា** ជួយសាច់គឺ ចិញ្ចឹមជ្រូកជាដើម (ដូចជាចុន្ទសូករបុរស) ។

**៤-មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺសុរា និងមេរ័យ ។

**៥-មជ្ជវណិជ្ជា** ជួយថ្នាំពិស គឺថ្នាំសំរាប់បំពុល មិច្ឆាវណិជ្ជា ជំនួយខុសទាំង៥ប្រការនេះ ឧបាសកឧបាសិកា មិនគប្បីជួញឡើយ ។

ពាក្យថា "ទ្រព្យ" សំដៅយកវត្ថុដែលអាចសំរេចនូវកិច្ចការផ្សេងៗបានតាមបំណង, ទ្រព្យមាន ២ យ៉ាងគឺ **វិញ្ញាណកទ្រព្យ**, ទ្រព្យដែលមានវិញ្ញាណ បានដល់ទាសា ទាសី គឺខ្ញុំប្រុស ខ្ញុំស្រី គោក្របី ដំរីសេះ ជ្រូកក្ដាន់ មាន់ ទា ជាដើម ១ **អវិញ្ញាណកទ្រព្យ** ទ្រព្យឥតវិញ្ញាណបានដល់មាសប្រាក់ កែវកង ពិទូរ្យសូរ្យកាន្ត ត្បូង ពេជ្រនិល ស្រែចំការច្បារដំណាំង ជាដើម ១ ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គទ្រង់សំដែងថា បុរសស្ត្រីក្នុងលោក បើស្វែងរកទ្រព្យសម្បត្តិ បានមកហើយ ត្រូវលះបង់នូវមច្ឆរិយៈ ពោលគឺសេចក្ដីកំណាញ់ស្ថិតស្ថាញក្នុងសន្ដានចេញ ហើយត្រូវ

បំពេញបុណ្យកុសល គឺការអោយទាន ដល់សមណៈជីព្រាហ្មណ៏ ស្មូមយាចក អ្នកកំសត់ទុគ៌ត ។

**ទាន** ប្រែថា "ការអោយ" ឬ "អំណោយ" វត្ថុអ្វីក៏ដោយ ល្មមបដិគ្គាហអ្នកទទួលយកទៅបរិភោគ ប្រើប្រាស់បាន ហៅថា ទានៈ ប្រែថា "ការអោយ" ។

ទានបើចែកតាមគោលដើម មាន ២ យ៉ាងគឺៈ **អាមិសទាន១, ធម្មទាន១ ៗ**

សូមលោកទុកធម្មទាន នឹងអធិប្បាយចំពោះតែអាមិសទានមួយ ។ អាមិសទានសំដៅយកការអោយនូវបច្ច័យទាំងអស់ ៤ យ៉ាងគឺៈ

**១-ចីវរប្បច្ច័យ** សំពត់ស្បង់ត្រៃចីវរ ឬសំពត់សារ៉ុងអាវស្បៃ ។

**២-បិណ្ឌបាតប្បច្ច័យ** អាហារភោជនទំចំណីបង្អែមចំអាប ។

**៣-សេនាសនប្បច្ច័យ** ពូកគ្រែខ្នល់ខ្នើយ កុដិសាលាព្រះវិហារ ។

**៤-គិលានភេសជ្ជប្បច្ច័យ** ថ្នាំសំរាប់កែរោគផ្សេងៗ ។

## ចីវរទាន

គ្រឿងស្លៀកដណ្តប់គ្រប់បែបដែលដេរ ភ្ជាប់ដោយចេស តាមព្យញ្ជនៈក្នុងភាសាបាលីហៅថា ចីវរ ។ ពាក្យថា ចីវរស្តាប់ទៅ ដូចជាសំដៅយកតែស្បង់ចីវរ ដែលជាបរិក្ខាររបស់បព្វជិតតែមួយយ៉ាងប៉ុណ្ណោះ , ប៉ុន្តែអត្ថដែលចែងពីចីវរប្បច្ច័យនោះ លោកថាសូម្បីតែគ្រឿងស្លៀកដណ្តប់របស់

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រហស្ថ ទូទៅដែលជារបស់ដែរ ភ្ជាប់ដោយចេសដូចគ្នា ក៏ចាត់ចូរក្នុងចីវរបច្ច័យដែរ ។

ធម្មតាមនុស្សក្នុងសកលលោក ទោះជាគ្រហស្ថក្តី បព្វជិតក្តី សុទ្ធតែត្រូវអាស្រ័យដោយចីវរបច្ច័យដូចគ្នា បើគ្មានចីវរបច្ច័យជាគ្រឿងអាស្រ័យទេ មិនមានរស់នៅជាសុខបាន ព្រោះមានសេចក្តី អន្តរាយច្រើនជំពូកណាស់ មានក្តៅត្រជាក់ជាដើម តែបើរស់នៅបាន ក៏បានដោយវេទនា ដូចជាមនុស្សព្រៃ និងស្វា ដែលមិនមានសំពត់អាវស្លៀកពាក់វាការពារក្តៅត្រជាក់ ដោយសារតែរោមវាតែប៉ុណ្ណោះ ទើបវាមានសាច់គគ្រាត់គគ្រើម សំបុរអាក្រក់ គ្រឿងការពារអាកាសក្តៅត្រជាក់, ព្រោះហេតុចីវរបច្ច័យជាគ្រឿង ការពារក្តៅត្រជាក់ របស់មនុស្ស អោយមនុស្សបានរស់នៅជាសុខស្រួល ដូចពោលមកនេះបានជាទាន ដែលទាយកបានយកអោយចីវរបច្ច័យ គឺអោយសំពត់អាវដល់បដិគ្គាហកជាគ្រហស្ថដោយសង្គ្រោះ ឬបានជូនសំពត់អាវដល់មាតាបិតា ដោយបូជាគុណលោក ឬបានប្រគេនត្រៃចីវរដល់បដិគ្គាហកជាបព្វជិតដោយ បូជាគុណធម៌របស់លោក នោះជាទានមាន ផលានិសង្ស ច្រើនទាំងបច្ចុប្បន្ន ទាំងអនាគត គឺអាចអោយបដិគ្គាហក (អ្នកទទួលទាន) បានសម្បុរល្អក្នុងបច្ចុប្បន្ន ហើយអោយទាយក (អ្នកអោយទាន) បានសម្បុរសល្អ សម្បូណ៌ គ្រឿងស្លៀកពាក់ក្នុងកាលជាអនាគត ។ គម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត

ថែងថាកាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានទេវតាចូលសួរព្រះអង្គថា បពិត្រព្រះដ៏មានបុណ្យដ៏ចំរើន ! អោយរបស់អ្វីជាទាន ទើបបានឈ្មោះថា អោយពណ៌សម្បុរស ? ព្រះអង្គត្រាស់តបថា **វត្ថទោ ហោតិ វណ្ណទោ** ការអោយសំពត់ជាទានឈ្មោះថា អោយពណ៌សម្បុរជាទាន គឺបានឈ្មោះថា អោយទានដល់អ្នកទទួលទាន ក្នុងជាតិនេះជាបច្ចុប្បន្ន ហើយអ្នកម្ចាស់ទាននោះ តែងបានជាអ្នកមានសម្បុរល្អ ពណ៌ស្អាត សម្បូណ៌គ្រឿងស្លៀកពាក់ និងទ្រព្យសម្បត្តិ ក្នុងអនាគត ដូចនាងឧម្មាទន្តី ។

សូមនាំរឿងនោះ មកសំដែងបញ្ជាក់ដូចតទៅនេះ :

**អតីតេ** ក្នុងដែលកន្លងទៅហើយ នៅក្នុងក្រុងពារាណសី មានស្រីកំសត់ម្នាក់ បានឃើញពួកស្រីអ្នកបរិបូណ៌ដោយបុណ្យ ស្លៀកដណ្តប់សំពត់ មានពណ៌ក្រហម ដូចជាផ្កាសិរមាន់ ដើរលេងក្នុងថ្ងៃមានមហោស្រព ក៏ចង់ស្លៀកពាក់សំពត់បែបនោះលេងនឹងគេ ក៏រំអុកប្រាប់មាតាបិតា១ថា នាងអើយ! យើងជាអ្នកកំសត់ តើនឹងមានសំពត់បែបនេះមកពីណា? នាងធីតាថា បើដូច្នោះខ្ញុំនឹងទៅធ្វើការឈ្នួលអោយអ្នកស្តុកស្តម្ភម្នាក់ គេនឹងអោយសំពត់ដល់ខ្ញុំ, ថាហើយក៏ចូលទៅរកត្រកូល១, ខំធ្វើការឈ្នួលដើម្បីយកសំពត់នោះ ត្រកូលនោះប្រាប់ថា នាងចូរធ្វើការ, គ្រប់ ៣ ឆ្នាំ ទើបយើងអោយនាងទទួលព្រមហើយក៏ ខំធ្វើការដោយយក

ចិត្តទុកដាក់ លុះគ្រប់១ឆ្នាំ ត្រកូននោះបានអោយសំពត់មានពណ៌ក្រហមដូចផ្កាសិរមាន់ ថែមទាំងសំពត់ដទៃដល់នាងទៀត លុះបានហើយនាងយកទៅដាក់ក្បែរផ្ទេរស្ទីង ទុកសំពត់ហើយចុះទៅងូតទឹក ។

ខណៈនោះសាវ័ករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ១ព្រះអង្គ ចោរលួចយកចីវរអស់ បិទបាំងអវៈយវៈ ដោយស្លឹកឈើនៅនាប្រទេសនោះ, នាងឃើញហើយគិតថា លោកម្ចាស់អង្គនេះ ពិតជាចោរលួចចីវរ ចំណែកអាត្មាអញរកសំពត់ស្លៀកបាន ដោយកម្រណាស់ ព្រោះកាលអំពីដើមអញលួចសំពត់អ្នកដទៃ, គិតដូច្នោះហើយហែកសំពត់របស់ខ្លួនពាក់កណ្តាលប្រគេន១, ចំណែកទៅ លោក៧ឈរក្នុងទីកំបាំងហើយចោលស្លឹកឈើស្លៀកជាយសំពត់ម្ខាង ដណ្តប់ម្ខាំង ហើយនិមន្តចេញទៅ ។ គ្រានោះសរីរៈទាំងអស់របស់ព្រះថេរ មានពន្លឺតែមួយកំណាត់ដូចព្រះ-អាទិត្យទើបឡើងដោយអានុភាពនៃពន្លឺសំពត់នោះ នាងឃើញហើយគិតថា លោកម្ចាស់របស់អញពីដើមមិនសូវសមរម្យទេ ឥឡូវនេះរុងរឿងដូចព្រះអាទិត្យ ដូច្នេះអញ នឹងប្រគេនសំពត់ចំណែកទី២នេះទៀត គិតហើយប្រគេនភ្លាម រួចតាំងសេចក្តីប្រាថ្នា ថាបពិត្រលោកម្ចាស់ដ៏ចំរើន ! ខ្ញុំនៅអន្ទោលទៅក្នុងភព សូមអោយមានរូបល្អ បុរសណាមួយឃើញខ្ញុំហើយកុំអោយទប់សេចក្តីស្នេហា បានឈ្មោះថា ជាស្រ្តីមានរូបល្អលើសលែងឥតស្រ្តី ដទៃ ប្រៀបផ្ទឹមបាន ព្រះថេរធ្វើអនុមោទនាហើយនិមន្តចៀស

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេញទៅ ។ ធីតានោះអន្ទោលទៅក្នុងទេវលោក លុះច្យុតចាកទេវលោក មកបានទៅកើតជាធីតាសេដ្ឋីឈ្មោះ តិរិដិវច្ឆ មានសម្បត្តិ ៨០ កោដិ ក្នុងអរិដ្ឋបុរីដែនសិវិធីតា នោះមានរូបឆោមលោមពណ៌ល្អល្អះ លើសលែងស្រីទាំងអស់ក្នុងនគរ, បុរសណាឃើញហើយទៅជាវង្វេងភ្លេចស្មារតី គិតអ្វីពុំឃើញ បានគេហៅនាង "ឧម្មាទន្តី" នាងមានអាយុ ១៦ ឆ្នាំ មានពណ៌សម្បុរល្អ ដាច់មនុស្សទាំងអស់ ហាក់ដូចជាស្រីទេពអប្សរ, ពួកមនុស្សបុថុជ្ជនណាឃើញនាងហើយ ហេតុតែស្រវឹងវង្វេងភ្លេចដោយកិលេសដូចជាអ្នកស្រវឹងស្រា ។

តិរិដិវច្ឆសេដ្ឋី ចូលទៅគាល់ព្រះបាទសិវិរាជហើយក្រាបទូលថា បពិត្រព្រះសម្មតិទេពក្នុងផ្ទះ របស់ខ្ញុំព្រះអង្គមានឥត្ថីរតន៍ កើតឡើងហើយ សូមព្រះអង្គត្រាស់បង្គាប់អោយហោរ ទាយលក្ខណពិនិត្យមើលឥត្ថីរតន៍នោះសមគួរដល់ព្រះរាជាទេ ? ព្រះរាជាទ្រង់ត្រាស់ប្រើពួកព្រាហ្មណ៍អោយទៅមើល សេដ្ឋីបានធ្វើសក្ការ និងសេចក្ដីរាប់អាន តាមសមគួរ ។

ខណៈនោះនាងឧម្មាទន្តី ទៅកាន់សំណាក់ព្រាហ្មណ៍ ទាំងនោះៗ ឃើញហើយក៏ភាន់ភាំងស្មារតី ហេតុតែស្រវឹងដោយកិលេសលែងដឹងខ្លួន ទៅជាបាច់សាចភោជនអោយរាត់រាយពាសពេញទីនោះ អ្នកខ្លះហកាន់ពំនូតបាយដាក់លើក្បាលសំគាល់ថា ដាក់ក្នុងមាត់អោយបរិភោគខ្លះប្រហារជញ្ជាំង ខ្លះដាក់បាយក្នុងចន្លោះក្លៀកទៅជាឆ្កួតទាំងអស់គ្នា ឥតមានសល់

ម្នាក់, នាងឃើញព្រាហ្មណ៍ទាំងនោះធ្វើដូច្នោះហើយគិតថា ព្រាហ្មណ៍ទាំងនោះក្រែងមកពិនិត្យមើលលក្ខណៈអញ ម្ដេចក៏ធ្វើអាកប្បកិរិយាដូច្នេះ, ហើយក៏បង្គាប់អោយទាសកម្មករអូសចេញទៅខាងក្រៅ, ពួកព្រាហ្មណ៍ទាំងនោះអៀនខ្មាស់នាង ក៏ទៅក្រាបទូលព្រះរាជាដោយពាក្យមិនពិតថា នាងឧម្មាទន្តីនោះជាស្រីកាឡកិណ្ណី ពុំសមគួរដល់ព្រះអង្គឡើយ, ព្រះរាជាទ្រង់ជ្រាបថា ជាកាឡកិណ្ណីដូច្នោះ ក៏អាក់ខានពុំបានអោយនាំមក, ចំណែកខាងឧម្មាទន្តីបានដឹងពត៌មាននោះហើយ បានចងគំនុំចំពោះព្រះរាជា ។

លុះដល់កាលជាខាងក្រោយ សេដ្ឋីបានអោយនាងឧម្មាទន្តីទៅសេនាបតីម្នាក់ឈ្មោះ អភិបារកៈ ជាសម្លាញ់ នឹងព្រះរាជា ថ្ងៃមួយក្រោយមកសេនាបតីបានរៀបចំដំណើរទៅកាន់ការងារ ក្រសួងរបស់ខ្លួន ហើយបានផ្ដាំភរិយារបស់ខ្លួនថា នែប្អូនដ៏ចំរើន ថ្ងៃពេញបូណ៌មីខែកត្តិកនេះ ព្រះរាជាទ្រង់ធ្វើដំណើរប្រទក្សិណនគរ នឹងយាងមកតាមទ្វារផ្ទះយើងនេះ ជាដំបូងនាងកុំបង្ហាញខ្លួនអោយព្រះអង្គឃើញឡើយ ព្រោះថាបើស្ដេចទ្រង់ទតឃើញប្អូនឯងហើយ មុខជាភាន់ភាំងស្មារតីពុំខាន ។ លុះដល់ព្រះ-អាទិត្យអស្ដង្គតហើយ ព្រះចន្ទពេញវង់រះឡើង ព្រះរាជាទ្រង់ធ្វើទក្សិណនគរដោយមហន្តយស, ដំបូងឡើងព្រះអង្គទ្រង់យាងចេញតាមទ្វារផ្ទះសេនាបតីទ្រង់ទតឃើញនាងឧម្មាទន្តី ស្ថិតនៅត្រង់បង្អួចស្រោប់តែវង្វេងដោយកិលេស ភ្លេចស្មារតីលែង ទឹកនាការធ្វើប្រទក្សិណនគរឈប់ត្រឡប់

អំពីទីនោះទៅកាន់ប្រាសាទទ្រង់ផ្ចិប្រារព្ធនឹកនាងឧម្មាទន្តី រវើរវាយដោយប្រការផ្សេងៗ សេនាបតីដឹងហេតុថា ព្រះរាជាមានព្រះទ័យប្រតិព័ទ្ធចំពោះនាងឧម្មាទន្តីហើយ ។

បើព្រះអង្គពុំបាននាងទេ មុខជានឹងទិវង្គត គួរអោយអាត្មាអញថ្វាយជីវិតដល់ព្រះអង្គចុះ ហើយបង្គាប់បំរើម្នាក់ថា ឯងចូរទៅឯចេតិយព្រឹក្ស មានប្រហោងឯណោះ ហើយអង្គុយក្នុងប្រហោងឈើនោះ កុំអោយអ្នកណាមួយដឹងអោយសោះ អញនឹងទៅកន្លែងនោះធ្វើពលីកម្មហើយនិយាយយ៉ាងនេះ ឯងចូរនិយាយយ៉ាងនេះមក, បុរសនោះបានទទួលពាក្យហើយទៅភ្លាមធ្វើដូច្នោះ លុះព្រឹកឡើងសេនាបតីទៅឯចេតិយព្រឹក្សធ្វើពលីកម្មហើយ តាំងបន់ស្រន់សួរថា ព្រះរាជារបស់យើងហេតុអ្វីបានជាមិនទ្រង់ក្រសាលមហោស្រព ? ហើយផ្ចង់រវើរវាំប្លែកម្លេះ ? អ្នកបំរើក៏ឆ្លើយមកពីក្នុងប្រហោងឈើថា នែសេនាបតី ! ព្រះរាជារបស់អ្នកមានព្រះទ័យប្រតិព័ទ្ធនឹងឧម្មាទន្តីជាភរិយារបស់អ្នក បើប្រសិនណាព្រះអង្គបាននាងនោះមិនទិវង្គតទេ បើមិនបាននាងទេ មុខជាទិវង្គត់ហើយ ហេតុនេះអ្នកឯងត្រូវថ្វាយនាងឧម្មាទន្តី ទៅព្រះរាជាទៅ, សេនាបតីឆ្លើយថាស្រួលប្រពៃហើយលោក រួចចូលទៅកាន់ព្រះរាជាក្រាប ទូលដំណើរនោះថា :

បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គ, ព្រះរាជាសួរបញ្ជាក់ថា នែអភិបាលរកសម្លាញ់ ! យក្សដឹងថាយើងរវើរវាយ

ព្រោះមានចិត្តប្រតិព័ទ្ធ នឹងនាងឧម្មាទន្តីមែនឬ ? សេនាបតីក្រាបទូលថា បពិត្រព្រះសម្មតិទេព រឿងនេះពិតមែន, ព្រះរាជាទ្រង់ពិចារណាថា : យីអើ! អំពើលាមករបស់អញលោកទាំងមូលដឹងហើយតើ គិតដូច្នោះ ហើយទ្រង់អៀនខ្មាស់ ដំកល់ព្រះទ័យអោយស្ថិតនៅក្នុងធម៌ បន្ទោរបង់នូវបដិព័ទ្ធចិត្តចោលចេញ មិនព្រមទទួលយកនាងឧម្មាទន្តីដែលអភិបារកសេនាបតីថ្វាយនោះឡើយ ។

**បុច្ឆា** មានពាក្យចោទដណ្តឹងសួរថា :

ចីវរទានមានអានិសង្សដូចម្តេច ខ្លះ ?

**វិសជ្ជនា** មានអានិសង្សដូច្នេះ បើជាបុរសដល់មច្ឆិមជាតិបាន សំរេចជាឯហិភិក្ខុ ត្រៃចីវរកើតឯង, បើជាស្ត្រីនឹងបានសំរេច គ្រឿងលតាមហាប្រាសាទធំ បើមិនទាន់បានដល់ព្រះនិព្វានទេ ទៅកើតក្នុងភពណា ៗ មានពណ៌ មានពណ៌សម្បុរសល្អ នឹងសំរេចបាននូវសំពត់ទិព្វ ។ នាំនិទាននេះមកសំដែងដើម្បីសសេចក្តីអោយឃើញថា អានិសង្សចីវរទានមានដូច្នេះឯង ។

## បិណ្ឌបាតទាន

ដុំនៃអាមិស គឺអាហារមានបាយ បបរចំណីជាដើម ដែលដាក់ចូលទៅក្នុងមាត់ ទំពារលេបចុលទៅបាន តាមព្យញ្ជនៈក្នុងភាសាបាលីហៅថា បិណ្ឌបាត ដែលយើងអ្នកកាន់ព្រះពុទ្ធសាសនា ធ្លាប់ស្គាល់ពាក្យនេះថាជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ចង្ហាន់របស់ព្រះសង្ឃ តែតាមអត្ថដែលថែងពីបិណ្ឌបាតប្បច្ច័យនោះ លោកថាសូម្បីតែ អាហាររបស់គ្រហស្ថ ឬរបស់សត្វទូទៅ ដែលជាគ្រឿងលេបចូលទៅតាមផ្លូវមាត់ដូចគ្នា ក៏លោករាប់ចូលក្នុងពួកបិណ្ឌបាតប្បច្ច័យដែរ ។

ធម្មតាមនុស្សសត្វក្នុងសកលលោក សុទ្ធតែត្រូវអាស្រ័យដោយបិណ្ឌបាតប្បច្ច័យទាំងអស់ បើគ្មានបិណ្ឌបាតប្បច្ច័យជាគ្រឿងអាស្រ័យទេ មិនអាចរស់នៅបានជាដាច់ខាត ។ រឿងនេះព្រះសម្ពុទ្ធទ្រង់បញ្ជាក់ថា **សព្វេសត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយទាំងពួង ទាំងជីវិតរស់នៅបានដោយអាហារ ។ ពាក្យថា អាហារមិនសំដៅតែ បាយបបរនំចំណីជាគ្រឿងបរិភោគរបស់មនុស្សទ សូម្បីតែស្មៅ និងស្លឹកឈើជាដើម ជាគ្រឿងបរិភោគរបស់សត្វតូចធំ ក៏ហៅថា អាហារដូចគ្នា មានសេចក្ដីអធិប្បាយសង្ខេបដូចតទៅនេះ :

មនុស្សសត្វក្នុងពិភពលោក សុទ្ធតែរស់នៅដោយសារអាហារទាំង-អស់ បើគ្មានអាហារបរិភោគ ឬមានដែរ តែបរិភោគពុំកើត ព្រោះឈឺថ្កាត់ ក៏ដល់នូវសេចក្ដីស្លាប់ ទោះបីមិនស្លាប់ក៏គ្មានកម្លាំង ។

ព្រោះហេតុនោះ បានជាអាហារដែលទាយកបានអោយដល់គ្រហស្ថដោយសង្គ្រោះ ឬ ដោយបូជាគុណ មានបូជាមាតាបិតាជាដើម ឬដល់បព្វជិត ជាទានមានផលានិសង្សច្រើន ជាអនេកទាំងពីរខាង គឺអាចអោយខាងអ្នកទទួលទាន មានកម្លាំងក្នុងពេលទទួលនាបច្ចុប្បន្ន ហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

អោយអ្នកម្ចាស់ បានជាអ្នកមានរូបល្អ មានកម្លាំងពលំ និងទ្រព្យសម្បត្តិច្រើនក្នុងកាលជាអនាគត ។

វិន័យបិដក មហាវគ្គ ទុតិយភាគ សំដែងថា ការអោយទានបបរ មានផលានិសង្ឃ ១០ យ៉ាងគឺៈ

**១~យាគុំ ទេន្តោ អាយុំទេតិ,** បុគ្គលកាលអោយបបរឈ្មោះថាអោយនូវអាយុ ។

**២~វណ្ណំទេតិ,** ឈ្មោះថាអោយនូវពណ៌សម្បុរ ។

**៣~សុខំ ទេតិ,** ឈ្មោះថាអោយនូវសេចក្តីសុខ ។

**៤~ពលំ ទេតិ** ឈ្មោះថាអោយនូវកំលាំង ។

**៥~បដិភាណំ ទេតិ** ឈ្មោះថាអោយនូវប្រាជ្ញា ។

**៦~យាគុ បីតា ខុទំ បដិហនតិ,** បបរដែលហុតទៅហើយ រមែងឃាត់នូវសេចក្តីឃ្លាន ។

**៧~បិបាសំ វិនោទេតិ** បន្ទោរបង់នូវសេចក្តីស្រេក ។

**៨~វាតំ អនុលោមេតិ,** ញ៉ាំងខ្យល់អោយដើរស្រួល ។

**៩~វត្ថិំ សោធេតិ,** ញ៉ាំងសរសៃអោយស្អាត ។

**១០~អាមាវសេសំ បាចេតិ,** ញ៉ាំងអាហារថ្មីដ៏សល់អោយរលួយ ។

គម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត សំដែងថា កាលព្រះបរមសាស្តា គង់ព្រះជន្មនៅឡើយ មានទេវតាចូលទៅទូលសួរព្រះអង្គថា :

**កឹំ ទទោ ពលទោ ហោតិ,** បពិត្រព្រះអង្គដ៏ចំរើន អោយរបស់អ្វី ជាទាន ទើបបានឈ្មោះថា ជាអ្នកអោយកម្លាំង ? ព្រះអង្គឆ្លើយថា **អន្នទោ ពលទោ ហោតិ,** អោយបានជាទានមានឈ្មោះថា អោយពលទាន គឺអោយកម្លាំងដល់អ្នកទទួលទាន ក្នុងជាតិជាបច្ចុប្បន្ន ហើយអ្នកម្ចាស់ទាន តែងបានសប្បុរទ្រព្យសម្បត្តិក្នុងជាតិជាអនាគត ដូច នាងមល្លិកា សូមនាំរឿងនោះមកសំដែងដូចតទៅនេះ :

ក្នុងក្រុងសាវត្ថី មានធីតានៃនាយមាលាការម្នាក់ ជាស្ត្រីរូបល្អ មានបញ្ញាច្រើន មានអាយុ ១៦ ឆ្នាំ ។

មានកាលមួយនាងធីតានោះ យកនំ ៣ ដុំដាក់ក្នុងកញ្ច្រែងសំរាប់ ដាក់ផ្ការដើរទៅកាន់ច្បារផ្កា នាងក៏បានឃើញព្រះសាស្តា ព្រះទាំងភិក្ខុសង្ឃ កំពុងនិមន្តចូលទៅកាន់នគរដើម្បីបិណ្ឌបាត នាងមានចិត្តត្រេកអរ យកនំ ទៅដាក់បាត្រព្រះសាស្តា ហើយថ្វាយបង្គំ ញុាំងបីតិមានព្រះពុទ្ធជាអារម្មណ៍ អោយកើតឡើងហើយឈរនៅក្នុងទីដ៏សមគួរ ។ ព្រះសាស្តាទ្រង់រមិល មើលនាងធីតានោះទ្រង់ធ្វើព្រះភ័ក្ត្រញញឹម ព្រះអានន្ទត្ថេរ ក្រាបបង្គំទូល សួរអំពីហេតុដែលទ្រង់ញញឹម ព្រះអង្គមានព្រះបន្ទូលថា ម្នាលអានន្ទ នាង កុមារនេះ និងបានជាអគ្គមហេសីនៃព្រះបាទកោសលរាជ ក្នុងថ្ងៃនេះ ដោយអំណាចផលទាននំនេះមិនខានឡើយ ហើយទ្រង់យាងចៀសចេញ ទៅ ។ ឯនាងធីតានោះដើរចូលទៅកាន់ច្បារផ្កា ស្រែកច្រៀងបណ្តើរ

បេះផ្កាបណ្តើរ ។ ជួនជាក្នុងថ្ងៃនោះឯង ព្រះបាទកោសលរាជទ្រង់ច្បាំងគ្នានឹងព្រះបាទ អជាតសត្តុរាជ ចាញ់ទ័ពព្រះបាទអជាតសត្តុរាជ ក៏រត់ចេញមកទ្រង់គង់លើព្រះទីនាំង សេះបរមបានឮសំឡេងនាងធីតា នោះច្រៀងក៏មានព្រះរាជហឫទ័យប្រតិព័ទ្ធទ្រង់យាងចូលទៅកាន់ច្បារផ្កា ទ្រង់ជ្រាបថានាងនោះមិនទាន់មានប្តី ហើយទ្រង់អោយនាងនោះឡើងជិះលើខ្នងសេះមានពួកពលចោមរោមជាបរិវា ហែហមចូលទៅកាន់ព្រះនរគ ទើបទ្រង់បញ្ជូននាងនោះអោយត្រឡប់ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនវិញ វេលាថ្ងៃរសៀលទ្រង់អោយហែហមនាំយកអំពីត្រកូលនោះមកវិញ ដោយគ្រឿងសក្ការដ៏ថ្កុំថ្កើង ហើយទ្រង់អភិសេកលើគំនរកែវតាំងជាមហេសីធំក្នុងព្រះ-នរគ ។ ឯមហេសីនោះជាទីស្រឡាញ់ពេញព្រះរាជឫទ័យរបស់ព្រះរាជាជាស្រ្តីស្និទ្ធស្នាលនិងព្រះរតនត្រ័យមានព្រះពុទ្ធជាដើម មាននាមប្រាកដថា "មល្លិកា ទេវី" ។

នាំរឿងនាងមល្លិកាទេវីនេះមក ដើម្បីញ៉ាំងសាធុជនអោយជនជ្រាបក្នុងបិណ្ឌបាតទាន ដែលបុគ្គលបានធ្វើដល់ព្រះពុទ្ធជាម្ចាស់នៃមហន្តអតុលក្ខេត្ត ។

សូមនាំរឿងព្រះបាទ ចណ្ឌប្បជោតមក ដើម្បីបញ្ជាក់អំពីអានុសង្សបណ្ឌិតបាតទាន :

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្នុងសម័យមុនពុទ្ធកាល នៃព្រះសក្យមុនី គោតមបរមគ្រូជាម្ចាស់នៃយើងនេះ មានមន្ត្រីម្នាក់ចេញពីគាល់ព្រះរាជាក្នុងព្រះរាជវាំងមកដល់ជិតផ្ទះរបស់ខ្លួន បានឃើញព្រះបច្ចេកពុទ្ធ១អង្គ ឈរបិណ្ឌបាតចង្ហាន់នៅទីនោះ ។ មន្ត្រីនោះបានឃើញលោកឈរស្ងៀម ក៏ចូលទៅបើកគ្របបាត្រលោកឃើញបាត្រទទេ ពុំទាន់មានចង្ហាន់សោះ ហើយថែមទាំងពេលនោះថ្ងៃជិតត្រង់ទៀតផង ក៏ស្ទុះប្រញាប់ចូលទៅក្នុងផ្ទះ យកអហារដែលអ្នកផ្ទះរៀបទុកបំរុងខ្លួន ប្រើអោយកម្មករម្នាក់យកទៅដាក់បាត្រលោកដោយពោលថា " ចូរអ្នកយកចង្ហាន់នេះទៅដាក់បាត្រលោកចុះ យើងចែកផលបុណ្យស្មើគ្នា " ។ បុរសជាកម្មករ បានឮដូច្នោះក៏ស្ទុះរត់យកចង្ហាន់ទៅដាក់បាត្រព្រះបច្ចេកពុទ្ធ ដោយសេចក្តីត្រេកអរ ។ លុះដាក់បាត្រហើយបុរសនោះសូមប្រាថ្នាថា " ដោយផលនៃចង្ហាន់ដោយរត់ទាំងកណ្តាលថ្ងៃត្រង់យកមកដាក់បាត្រព្រះអង្គនេះ សូមអោយខ្ញុំជាតិខាងមុខមានកម្លាំងច្រើនមានយាន្តជំនិះសុទ្ធតែលឿនៗ និងបានអំណាចរុងរឿងដូចព្រះអាទិត្យឋិតនៅកណ្តាលនភាល័យ ។

ដោយអានិសង្សនោះ លុះបុរសនោះស្លាប់ទីមនុស្សទៅ បានទៅសោយសុខក្នុងឋានសួគ៌អស់១ ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធមួយព្រះអង្គ) លុះដល់មកពុទ្ធកាលនៃព្រះសក្យមុនីគោតម បរមគ្រូនៃយើងនេះ ទើបចុះមកកើតក្នុងមនុស្សលោក ជាស្តេចព្រះនាម ចណ្ឌប្បជោត នៅក្នុងជម្ពូទ្វីប ទ្រង់មាន

យានជំនិះ សេះដ៏រ សុទ្ធតែលឿន ៧ រត់បាន ១២០ យោជន៍ក្នុង ១ ថ្ងៃ ។ នឹងទ្រង់មានអំណាចរុងរឿងដូចព្រះអាទិត្យ ចែងចាំងកណ្ដាលនភាល័យ ។

## សេនាសនៈទាន

ទីជ្រក ទីដេក ទីអង្គុយ ទីនៅតាមព្យញ្ជនៈ ក្នុងភាសាបាលីហៅថា សេនាសនៈ ដែលយើងជាពុទ្ធបរិស័ទធ្លាប់សំគាល់ពាក្យនេះ ថាជាទីលំនៅរបស់ព្រះសង្ឃមាន កុដិសាលាវិហារ ឬបង្គន់ តុ តាំង កៅអី ពូក កន្ទេលខ្នើយជាដើម តែតាមអត្ថដែលលោកអធិប្បាយពីសេនាសនប្បច្ច័យ ក្នុងបច្ច័យ ៤ នោះថា សេនាសនៈ មិនមែនសំដៅយកតែត្រឹមកុដិ សាលាព្រះវិហារ ឬ តុ កៅអី ពូក គ្រែ កន្ទេល ខ្នើយ របស់ព្រះសង្ឃទេ សូម្បីផ្ទះសំបែង ខ្ទម លំហរ តុ កៅអី ទូកគ្រែ ជាទីនៅទីដេក ទីអង្គុយ របស់គ្រហស្ថ ក៏រាប់ចូលក្នុងពួកសេនាសនប្បច្ច័យដែរ ។ ទាំងមនុស្សទាំងសត្វ ដែលកើតមកក្នុងសកលលោក តែងអាស្រ័យដោយ សេនាសនប្បច្ច័យ ជាទីជ្រកកោនដេក ពួនដូចគ្នា គ្មាននរណាចៀសរួចបាន បើគ្មានសេនាសនប្បច្ច័យ ជាទីអាស្រ័យ មនុស្សនិងសត្វ មិនអាចរស់នៅជាសុខបានឡើយ សូម្បីសត្វទឹកសត្វគោក មានជើងក្ដី ឥតជើងក្ដី ក៏ត្រូវមានទឹកមានដី មានរូងមានរន្ធជាទីសេនាសនៈ ស្នាក់អាស្រ័យនៅតាមភាពជារបស់វាដែរ ទើបវារស់នៅជាសុខបាន ។

ព្រោះហេតុនោះ បានជាទីសេនាសនៈ ដែលទាយកបានអោយដល់គ្រហស្ថអ្នកកំសត់ទុគ៌ត ឬបព្វជិតអ្នកមានសីល បរិសុទ្ធមានផលានិសង្ឃច្រើនទាំងពីរខាង គឺទាំងខាងអ្នកទទួលទាន បានជ្រកនៅជាសុខស្រួលក្នុងបច្ចុប្បន្ន ទាំងខាងអ្នកម្ចាស់ទាន នឹងបានជាអ្នកមានទ្រព្យសម្បត្តិ ផ្ទះសម្បែងប្រាសាទ វិមាន នៅជាសុខ ក្នុងកាលជាអនាគត ។

គម្ពីរសំយុត្តនិកាយត្រង់ទេវតាសំយុត្ត សំដែងថា កាលព្រះដ៏មានបុណ្យគង់ព្រះជន្ម នៅឡើយមានទេវតាចូលទៅទូលសួរថា :

**យោ ច សព្វទទោ ហោតិ,** បពិត្រព្រះអង្គដ៏ចំរើន ! អ្នកអោយរបស់អ្វី ទើបបានឈ្មោះថា អោយគ្រប់មុខ? ព្រះអង្គត្រាស់តបថា : **សោ ច សព្វ ទទា ហោតិ យោ ទទា តិ ឧបស្សយំ,** អ្នកណាបានអោយទីលំនៅជាទាន អ្នកនោះឈ្មោះថា អោយគ្រប់មុខ ។

មួយទៀតគម្ពីរសំយុត្តិកនិកាយ ជាមួយគ្នានោះថែងថា មានទេវតាចូលទៅទូលសួរព្រះសម្មាសម្ពុទ្ធថា **តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ,** បពិត្រព្រះអង្គដ៏ចំរើន ! បុណ្យតែងចំរើនទាំងយប់ទាំងថ្ងៃ សព្វកាលដល់ពួកជនណា ?

ព្រះសាស្តាត្រាស់ថា :

**អារាមរោបា វនរោបា យេជនា សេតុការកា បបញ្ច ឧទបានញ្ច យេទទន្តិ ឧបស្សយំ តេសំ ទិវាច**

Websites: WatKhemaraRatanaram.org or WatKhmers.org

## អត្ថោ ច សតា បុញ្ញំ បចចវន្តេតិ ៦

ម្នាលទេវតា ! ជនទាំងឡាយណាបានដាំសួនឈើផ្កា ដាំសួនឈើស្លឹកជាម្លប់ សង់ស្ពាន សង់រោង ដាក់ទានទឹក សាងអណ្តូងទឹក និងសាងទីលំនៅជាទានបុណ្យរបស់ជនអំបាលនោះ តែងចំរើនទាំងថ្ងៃ ទាំងយប់សព្វកាលទាំងពួង ។

មួយទៀតផលបុណ្យនានា ដែលជនទាំងឡាយបានធ្វើហើយ រមែងរងចាំទទួលពួកជនដែលធ្វើបុណ្យនោះ ក្នុងលោកខាងនាយដូចជាញាតិមិត្តដែលស្រឡាញ់គ្នា ទន្ទឹងរង់ចាំទទួលគ្នាដូច្នោះ ។

ដូចរឿងនន្ទិយឧបាសក សូមនាំនិទាននោះមកសំដែងដូចតទៅនេះ:

## រឿងនន្ទិយឧបាសក

ចំពោះផលបុណ្យដែលទន្ទឹងរង់ចាំអ្នកធ្វើបុណ្យនោះ ក្នុងអដ្ឋកថាធម្មបទមាននិទានរឿង នន្ទិយឧបាសកថា :

សម័យមួយព្រះបរមសាស្តាជាម្ចាស់ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី គ្រានោះមានមាណពម្នាក់ ឈ្មោះនន្ទិយជាអ្នកមានសទ្ធា ក្នុងព្រះពុទ្ធសាសនា បានបំរើព្រះសង្ឃតាមវង្សត្រកូលជាអ្នកមានសទ្ធា ចំពោះព្រះរតនត្រ័យ ។ លុះមាតាបិតាក្ស័យជីវិតទៅនន្ទិយមាណព ក៏បានជាមហាទានាធិបតី បានថ្វាយទានចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន និងអោយទានដល់មនុស្សកំសត់ទុគ៌ត អនាថា

បានសាងសាលា ៤ ល្វែង ១ ខ្នង ព្រមទាំងគ្រឿងសេនាសនៈ ជាប្រដាប់សំរាប់សាលានេះនៅព្រៃ សេនាសនៈ មិគទាយវ័ន ត្រង់កន្លែងដែលព្រះ-ពុទ្ធអង្គទ្រង់សំដែងព្រះធម្មចក្រកប្បវត្តនទេសនា ។

លុះសាងស្រេចហើយ បានវេរសលានេះថ្វាយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ក្នុងដែលដែលនន្ទិយវេរសាលាបានច្រួចទឹកទក្ខិណោទកលើបាទព្រះហស្តតថាគតនោះ ប្រាសាទវិមានទិព្វប្រកបដោយកែវ៧ ប្រការទំហំ ១២ យោជន៏កំពស់ ១៧ យោជន៏ ផុះឡើងក្នុងឋានសួគិ គឺឋានតាវត្តិង្ស ព្រមទាំងនាងទេព្យអប្សរចាំទទួលគាត់ ។

ថ្ងៃបន្ទាប់មកនោះ ព្រះមហាមោគ្គល្លានត្ថេរ និមន្តទៅកាន់ទេវចារិក បានឃើញប្រាសាទទិព្វនោះ ក៏សួរទេពធីតាទាំងឡាយដែលរង់ចាំនៅទីនោះ ថាប្រាសាទនេះជារបស់អ្នកណា ? នាងទេពធិតាពិតថេរវាចាថា : ជារបស់នន្ទិយឧបាសក ហើយនាងផ្តាំនឹងលោកថា សូមមេត្តាប្រាប់នន្ទិយឧបាសកផង អោយគាត់ប្រញាប់ទៅកើតនៅទីនោះ ។

លុះព្រះមោគ្គល្លានត្ថេរត្រឡប់មកកាន់មនុស្សលោកវិញ បានទទួលព្រះបរមគ្រូតាមដំណើរនោះ ព្រះអង្គទ្រង់ត្រាស់សំដែងថា :

**ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ**
**ញាតិមិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ**
**តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ**

## បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតិវ អាគតំ ។

សេចក្ដីថា ពួកជនជាញាតិមិត្ត ឬ ក្លើម្រាក់ដែលរាប់អានគ្នាគេ រមែងមានចិត្តត្រេកអរនឹងបុរសជាញាតិសន្ដាន ដែលព្រាត់ប្រាស់គ្នាអស់កាលជាយូរហើយ ដែលគេជាពាណិជ្ជ ឬ នាម៉ឺន ដ៏មានសិរីសួស្ដី មកពីចម្ងាយចាំទទួលគ្នារាក់ទាក់យ៉ាងណាមិញ , បុណ្យទាំងឡាយរមែងចាំទទួលជនអ្នកធ្វើបុណ្យក្នុងលោកខាងនាយ ដូចគេទទួលស្គាល់ញាតិដែលស្រឡាញ់គ្នាយ៉ាងនេះដែរ ។

សូមនាំរឿងព្រះពោធិសត្វមកបញ្ជាក់ ថែមមួយទៀត អំពីអានិសង្សសេនាសនទាន :

### "រឿងព្រះពោធិសត្វ"

ក៏ក្នុងសម័យនោះ ក្នុងសាសនាកាលព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈទ្រង់មានព្រះជន្មាយុនៅឡើយ មានព្រះថេរ១អង្គ គង់នៅក្នុងព្រៃជារវត្ត ។

ព្រះបរមពោធិសត្វកើតក្នុងត្រកូលគហបតី, ថ្ងៃមួយព្រះបរមពោធិសត្វចូលទៅកាន់ព្រៃដោយការងាររបស់ខ្លួន បានឃើញព្រះថេរនៅក៏ចូលទៅជិតថ្វាយបង្គំហើយ រមិលមើលទីកន្លែងដែលព្រះថេរអង្គុយ និងចង្រ្កមជាដើម ហើយទូលសួរព្រះថេរថា លោកម្ចាស់មកគង់នៅក្នុងទីនេះឬអ្វី ? ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះថេរឆ្លើយថា ! អើឧបាសក អាត្មាមកគង់នៅក្នុងទីនេះ ។ ព្រះ-ពោធិសត្វ គិតពិចារណា បើអាត្មាអញធ្វើបណ្ណសាលាប្រគេនលោកម្ចាស់ក្នុងទិនេះ យល់ជាការប្រពៃណាស់ លុះគិតដូច្នោះហើយ ក៏លះបង់ការងាររបស់ខ្លួនចោលចេញ ចាត់ចែងគ្រឿងទព្វសម្ភារសាង ជាបណ្ណសាលាមួយប្រក់ហើយស្រេច យកដីស្អិតមបុកលាបជាជញ្ជាំង ហើយធ្វើអោយមានទ្វារ បើកបិទចេញចូលក្រាល ដោយរនាបឈើ ហើយអង្គុយក្នុងទីដ៏សមគួរដោយសេចក្តីត្រិះរិះថា លោកម្ចាស់នឹងប្រើប្រាស់សាលានេះ ឬក៏មិនប្រើប្រាស់ទេ ។ គ្រានោះព្រហាថេរលោកក៏និមន្តមកពីខាងក្នុងនៃស្រុក ហើយចូលទៅកាន់បណ្ណសាលាគង់នៅលើរនាបឈើ ។ ឯឧបាសកគឺពោធិសត្វក៏មកថ្វាយបង្គំហើយ អង្គុយជិតព្រះថេរ ទូលសួរថាលោកម្ចាស់បណ្ណសាលានេះសប្បាយ ឬទេ ។ ព្រះថេរឆ្លើយថា ម្នាលអ្នកមានមុខស្រស់បស់បណ្ណសាលានេះសប្បាយណាស់ ហើយសមគួរដល់អ្នកបួសផង ។ ឧបាសកទូលសួរថា លោកម្ចាស់មុខជានៅគង់ក្នុងទីនេះ ឬអ្វី ? ។ ព្រះថេរឆ្លើយថា អើឧបាសកមើលទៅអាត្មាប្រហែលជានៅក្នុងទីនេះហើយ ឧបាសកនោះដឹងច្បាស់ថា ព្រះថេរទទួលនិមន្តហើយ ក៏និយាយប្តេជ្ញានឹងព្រះថេរថាសូមលោកម្ចាស់ និមន្តទៅកាន់ទ្វារផ្ទះខ្ញុំជានិច្ច ហើយសូមពរពីព្រះថេរថាសូមលោកម្ចាស់ប្រទានរមួយដល់ខ្ញុំ ។ ម្នាលឧបាសធម្មតាអ្នកបួសមានពរកន្លងអស់ហើយគឺ ថាឥតមានពរអ្វីឡើយ ។ បពិត្រលោកម្ចាស់

ពរណាដែលគួរ ពរណាដែលឥតទោស ខ្ញុំសូមពរនោះឯង ម្នាលឧបាសក អ្នកចូរនិយាយចុះ, បពិត្រលោកម្ចាស់មនុស្សទាំងឡាយ រមែងប្រាថ្នាចង់អោយលោកម្ចាស់និមន្តទៅក្នុងលំនៅរបស់ខ្លួន ក្នុងកិច្ចជាមង្គលក្តី មិនមែនជាមង្គលក្តី កាលបើលោកមិននិមន្តទៅគេក៏ខឹង ព្រោះហេតុនោះបើទុកជាលោកម្ចាស់ទៅកាន់ទីដែលគេនិមន្តដទៃ ក៏សូមនិមន្តទៅកាន់ផ្ទះខ្ញុំសំរេចភត្តកិច្ច ក្នុងផ្ទះខ្ញុំកុំខាន ។ ព្រះថេរក៏ទទួលនិមន្តស្រេច ។ ទើបឧបាសកនោះ យកកន្ទេលផែងទៅក្រាល យកគ្រែតាំងទៅរៀបចំក្នុងសាលាហើយ ដាក់ភ្នាក់ដៃ ដំកល់ទុក គ្រឿងសំរាប់ជូតជើង ជីកស្រះបោក្ខរណី១, ធ្វើទីចង្ក្រម១, យកដីខ្សាច់ទៅរោយរាយក្នុងទីនោះ កាលបើឃើញពួកសត្វម្រឹគមកត្រដុះជញ្ជាំងធ្វើដីស្អាតអោយធ្លាក់ចុះក៏យកឈើមានបន្លាមកធ្វើជារបងព័ទ្ធជុំវិញ, កាលបើឃើញពួកសត្វម្រឹគចុះទៅក្នុងព្រះបោក្ខរណី ធ្វើទឹកអោយល្អក់រឹករវ ក៏យកថ្មទៅរៀបចំក្នុងស្រះ យកឈើមានបន្លាមកធ្វើជារបង ព័ទ្ធអំពីខាងក្រៅជុំវិញ ហើយដាំដើមឈើ គឺដើមត្នោតជាជួររៀងគ្នា ខាងក្នុងរបង កាលបើឃើញពួកម្រឹគចូលមកក្នុងទីចង្ក្រមធ្វើទីកន្លែងរលីងស្អាត អោយខូចខាតរឹករវ ក៏ធ្វើរបងព័ទ្ធជុំវិញទីចង្ក្រមហើយដាំដើមត្នោតជាជួររៀងគ្នាខាងក្នុងរបង ឧបាសកញ៉ាំងសេនាសនៈទានអោយសំរេចយ៉ាងនេះហើយ ក៏ប្រគេនត្រៃចីវរ ចង្ហាន់បិណ្ឌបាត ថ្នាំកែរោគភាជនៈសំរាប់ប្រើប្រាស់ដែកស្មាន កាំបិតតូច កាំបិតសំរាប់កាត់ក្រចក

ម្ជុល ឈើច្រត់ ស្បែកជើង ល័ក្ខ ចានសំរាប់ដាក់ទឹក ឆត្រ អំបែង ប្រទីប វត្ថុសំរាប់ជំរះទន្លូវមន្ទិលគឺ ច្រែះ ក្អែល បាត្រ សៀនទឹក សំពត់តម្រង ធម្មក្រក នឹងប្រគេនបរិក្ខាឯទៀតៗ ដែលជាគ្រឿង ប្រើប្រាស់របស់អ្នកបួសដល់ព្រះថេរ ។ បរិក្ខារអ្វីដែលព្រះពោធិសត្វមិនបានប្រគេនដល់ព្រះថេរនោះមិនមានឡើយ ។ ព្រះពោធិសត្វនោះក៏រក្សានិច្ចសីល ធ្វើឧបាសថកម្ម បំរើព្រះថេរៈ អស់មួយជីវិត ។ ព្រះថេរក៏បានសំរេចព្រះអរហន្ត ហើយបរិនិព្វានក្នុងទីនោះ ។ ព្រះពោធិសត្វខំសន្សំកសាងបុណ្យដរាបដល់អស់អាយុ បានទៅកើតក្នុងទេវលោក ច្យុតអំពីទេវលោកមកកាន់មនុស្សលោកវិញ បានមកកើតក្នុងក្រុងសាវត្ថី រាជធានីបាន សោយរាជ្យជាស្តេចទ្រង់ព្រះនាមថា "មហាសុទស្សនចក្រព័ត្តិនោះឯង " ។

អានិសង្សដែលកើតអំពីអាវាសទានជាដើម ដែលព្រះពោធិសត្វបានធ្វើ មានសេចក្តីអស្ចារ្យផ្សេងៗដូចមានក្នុងមហាសុទស្សនៈ សូត្រគម្ពីរទីឃនិកាយមហាវគ្គ ។

សំដែងរឿងនេះ ដើម្បីញ៉ាំងសាធុជនអោយជ្រាបក្នុងរឿងសេនា-សនទាន ដែលបុគ្គលបានធ្វើដល់ភិក្ខុក្នុងព្រះពុទ្ធសាសនា ដែលមានសេចក្តីប្រតិបត្តិ បែរមុខទៅរកមគ្គផលព្រះនិព្វាន ។

**គេសជ្ជនាន**

ថ្នាំសំរាប់ព្យាបាលរោគគ្រប់ជំពូក ភាសាបាលីហៅថា គិលានភេសជ្ជ ដែលក្នុងបច្ច័យ៤ លោកហៅថា ភេសជ្ជប្បច្ច័យ ជាគ្រឿងអាស្រ័យព្យាបាលជម្ងឺ បានទាំងគ្រហស្ថ ទាំងបព្វជិត ហើយទូទៅទាំងសត្វផង ។ មនុស្សសត្វក្នុងលោក តែងមានជម្ងឺដម្កាត់គ្រប់គ្នា បើមិនច្រើន ក៏តិចតាមធម្មតា ស្ទើរតែរាល់ថ្ងៃ ហើយត្រូវអាស្រ័យដោយថ្នាំកែរោគនោះ ៗ ជារាល់ពេលដែលឈឺ ទើបជម្ងឺនោះៗ ជាសះស្បើយបាន ។

ក្នុងវិន័យបិដក មហាវគ្គទ្រង់ភេសជ្ជបានថែងថា :

កាលព្រះដ៏មានព្រះភាគទ្រង់នៅក្នុងវត្តជេនពន ទ្រង់ជ្រាបថាពួកភិក្ខុ មានរោគាពាធគ្រុណ ស្រៀវស្រាញ ក្នុងសរទរដូវ ។ មុនដំបូងទ្រង់អនុញ្ញាតអោយភិក្ខុទទួលក្នុងការគួរក៏បាន កាលមិនគួរក៏បាន គោរស ៥ យ៉ាងគឺ ទឹកដោះស្រស់ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅដែលជាភេសជ្ជផង ជាអាហាររបស់មនុស្សលោកផង ។

លំដាប់តៗមកទ្រង់ អនុញ្ញាតនូវភេសជ្ជច្រើន ជំពូកទៀតគឺ:

ពួកខ្លាញ់ : មានខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ជាដើម

ពួកឫសមើម : មានមើមរមៀត មើមខ្ញីជាដើម

ពួកទឹកចត់ : មានទឹកចត់កើតពីស្លឹកស្ដៅជាដើម

ពួកស្លឹក : មានស្លឹកស្ដៅជាដើម

ពួកផ្លែ : មានផ្លែដៃប្លី ម្រេចជាដើម

ពួកជ័រ មានជ័រ ហិង្គុជាដើម ។

ទ្រង់អនុញ្ញាតអោយឆាន់ ក្នុងវេលាវិកាលនូវបានទឹក ៨ យ៉ាងគឺៈ

**១.អម្ពបានំ** ទឹកដែលគេធ្វើដោយផ្លែស្វាយ

**២.ជម្ពុបានំ** ទឹកដែលគេធ្វើដោយផ្លែព្រីង

**៣.ចោចបានំ** ទឹកដែលគេធ្វើដោយផ្លែចេកគ្រាប់

**៤.មោចបានំ** ទឹកដែលគេធ្វើដោយផ្លែចេកឥតគ្រាប់

**៥.មធុកបានំ** ទឹកដែលធ្វើដោយផ្លែស្រគំ

**៦.មុទ្ទិកបានំ** ទឹកដែលគេធ្វើដោយផ្លែចន្ទ

**៧.សាលុកបានំ** ទឹកដែលគេធ្វើដោយផលជាតិមានព្រលិត ក្រហមជាដើម ។

**៨.ផារុសបានំ** ទឹកដែលធ្វើដោយផ្លែម៉ាក់ប្រាំង ។

បានៈ ទឹក ៨យ៉ាងទៀត គឺៈ

**១.កោសម្ពបានំ** ទឹកធ្វើដោយផ្លែសង្ឃ័រ

**២.កោលបានំ** ទឹកធ្វើដោយផ្លែពុទ្រាតូច

**៣.ពទរបានំ** ទឹកធ្វើដោយផ្លែពុទ្រាធំ

**៤.ឃតបានំ** ទឹកធ្វើដោយទឹកដោះរាវ, ទឹកដោះថ្លា

**៥.តេលបានំ** ទឹកធ្វើដោយប្រេងល្ងជាដើម

**៦.បយោបានំ** ទឹកធ្វើដោយទឹកដោះស្រស់

**៧.យាគុបានំ** ទឹកធ្វើដោយបបរ

**៨.រសបានំ** ទឹកធ្វើដោយរសជាតិមានផ្លែជាដើម ។

ទឹកទាំង ៨ យ៉ាងនេះ ជាខុទ្ទកផល ផ្លែតូចៗ ទទួលឆាន់ក្នុងវេលាកាលបាន ។ ផ្លែឈើដែលព្រះអង្គទ្រង់ហាមបានដល់មហាផលទាំង ៩ យ៉ាងគឺះ

**ធញ្ញជាតិស្រូវ ៧ យ៉ាងទៀតគឺះ**

**១.សាលី** ស្រូវស (ស្រូវសាលី)

**២.វីហី** ស្រូវដំណើប (ស្រូវធម្មតា)

**៣.យវោ** ស្រូវក្រហម

**៤.គង្គុ** ល្ពៅ, ពោត ឬ កន្ទុយដំរី

**៥.កុទ្រូសកោ** ស្រងែ

**៦.និវារោ** ស្កួយ

**៧.វរកោ** ស្ពៅគែលលក ។

ក្រៅអំពីមហាផលទាំង ៩ យ៉ាង និងធញ្ញជាតិស្រូវ ៧ យ៉ាងនេះ ចេញព្រះពុទ្ធទ្រង់អនុញ្ញាតអោយធ្វើភេសជ្ជឆាន់បានទាំងអស់ ។ ទឹកត្នោតទ្រង់អនុញ្ញាតអោយភិក្ខុឆាន់ ក្នុងវេលាវិកាលបាន ។ តែទឹកដូងមិនត្រង់អនុញ្ញាតអោយភិក្ខុឆាន់ក្នុងវេលាវិកាលទេ ។ ឯស្លា ម្លូ បារី ទឹកតែ កាហ្វេ

ទឹកក ទឹកក្រូច ស្ករសរ ស្ករត្នោត ស្ករក្រាម ស្កតាំងសិន លោករាប់ចូលក្នុងអនុលោមភេសជ្ជៈ ភិក្ខុឆាន់ក្នុងវេលាទាំងពីរបាន ។

អដ្ឋបានទាំងអស់នេះ ជាភេសជ្ជសំរាប់ភិក្ខុមានជម្ងឺ ចាត់ចូលក្នុងយាមកាលិក ភិក្ខុឆាន់បានក្នុងវិកាលទទួលទុកដាក់បាន១យប់យ៉ាងយូរតែទុកអោយហួសកំណត់នេះទៅ យកមកឆាន់ត្រូវអាបត្តិទុក្កដ ។

ទាយកអ្នកមានសទ្ធាបានអោយ ឬ ប្រគេនភេសជ្ជ ដូចពោលមកហើយនេះក្តី ថ្នាំពេទ្យគ្រប់យ៉ាងក្តី ដល់ព្រះសង្ឃ ឬ ដល់គ្រហស្ថដែលមានជម្ងឺ ហៅថាធ្វើភេសជ្ជទាន ។ ភេសជ្ជៈដែលមានសទ្ធាបានប្រគេនដល់ព្រះសង្ឃ ឬបានអោយដល់គ្រហស្ថអ្នកមានជម្ងឺដោយសង្គ្រោះ ឬដោយប្រគេន អ្នកអោយគឺខាងបដិគ្គាហក អ្នកទទួលបានជាជម្ងឺមាន អាយុវណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ក្នុងពេលដែលទទួលនាបច្ចុប្បន្ន មានសេចក្តីសុខកាយ សប្បាយចិត្ត មានកម្លាំងកាយ កម្លាំងចិត្ត និង មានបដិភាណប្រាជ្ញាឈ្លាសវៃ ក្នុងអនាគតកាល ។

បណ្តាបច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ទាយកទាយិកា អ្នកមានសទ្ធាជ្រះថ្លា បានប្រគេនភិក្ខុសង្ឃ និងជូនគ្រហស្ថអ្នកមានសីលគុណមានសលក្ខណៈខុសគ្នា បើជូនគ្រហស្ថអ្នកមានសីល សំពត់មានផ្កា ឬមានពណ៌យ៉ាងណាៗនោះ អាចយទៅប្រើប្រាស់ បានឥតមានទាស់ខុសនិងពុទ្ធ-

ប្បញ្ញត្តិទេ ។ ឯចំណែកខាងភិក្ខុសង្ឃត្រូវវៀរចាកសំពត់មានផ្កា មានពណ៌ផ្សេងៗ មានក្រហម ខៀវ ខ្មៅ ព្រោះសំពត់នេះមិនគួរដល់សមណៈធ្វើជាចីវរប្រើប្រាស់ទេ ។

ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតអោយប្រើសំពត់ ៦ យ៉ាង :

**១-ខោមំ** សំពត់ធ្វើពីសរសៃឈើ

**២-កប្បាសិក** សំពត់ធ្វើអំពីកំបោរ

**៣-កោសេយ្យំ** សំពត់ធ្វើពីសូត្រ

**៤-កម្ពលំ** សំពត់ធ្វើពីរោមសត្វ

**៥-សាណា** សំពត់ធ្វើពីសម្បកធ្មៃ

**៦-ភង្គំ** សំពត់ត្បាញលាយចំរុះ ។

ឯចំណែកបិណ្ឌបាតបច្ច័យ ទាយកទាយិកាមានសទ្ធាជូនចំពោះគ្រហស្ថអ្នកមានសីល ឥតមានកំណត់ ឬហាមអ្វីទេ អោយតែភោជនអាចបរិភោគបាន, ចំណែកព្រះភិក្ខុសង្ឃត្រូវវៀរចាកនូវសាច់ ១០ យ៉ាង ។

**មំសសាច់ ១០ យ៉ាងនោះគឺ :**

១-សាច់មនុស្ស

២-សាច់សេះ

៣-សាច់ដំរី

៤-សាច់ឆ្កែស្រុក

៥-សាច់ឆ្កែព្រៃ

៦-សាច់រាជសីហ៍

៧-សាច់ខ្លាធំ

៨-សាច់ខ្លារខិន

៩-សាច់ខ្លាឃ្មុំ

១០-សាច់ពស់ ។

សាច់ទាំង ៩ យ៉ាងបើភិក្ខុឆាន់ត្រូវអាបត្តិទុក្កដ, ចំពោះសាច់មនុស្សមួយ បើភិក្ខុឆាន់ត្រូវអាបត្តិ ថុល្លច្ច័យ ។ ព្រះពុទ្ធត្រង់អនុញ្ញាតអោយភិក្ខុ ទទួលភត្តជាអតិរេកលាភ មាន ៧ យ៉ាងគឺៈ

**១-សង្ឃភត្តំ** ភត្តដែលគេប្រគេនដល់សង្ឃ

**២-ឧទ្ទេសភត្តំ** ភត្តដែលគេឧទ្ទិសចំពោះភិក្ខុ២រូប ឬភិក្ខុ៣រូប

**៣-និមន្តនភត្តំ** ភត្តដែលគេនិមន្តអោយឆាន់

**៤-សលាកភត្តំ** ភត្តដែលទាយកអោយចាប់ស្លាក

**៥-បក្ខិកភត្តំ** ភត្តដែលគេប្រគេនតាមបក្ស គឺខ្នើត ឬរនោច ។

**៦-ឧបោសថិកភត្តំ** ភត្តដែលគេប្រគេនក្នុងថ្ងៃឧបោសថ,

**៧-បាដិបទិកភត្តំ** ភត្តដែលគេប្រគេនក្នុងថ្ងៃ១កើត ១រោចនៃខែ

ព្រះពុទ្ធទ្រង់អនុញ្ញាតអោយបព្វជិតនៅអាស្រ័យក្នុងទី៥យ៉ាងគឺៈ

**១-វិហារោ** កុដិ ឬសាលាធំ

Websites: WatKhemaraRatanaram.org or WatKhmers.org

**២. អឌ្ឍយោគោ** កុដិតូច ៗ ដូចជាខ្ទមជាដើម

**៣. បាសាទោ** កុដិមានជាន់

**៤. ហម្មិយំ** ប្រាសាទធំ ឬកុដិថ្មធំៗ

**៥. គុហា** រូងភ្នំ ឬរូងដែលគេធ្វើនៅនិងភ្នំលាយដោយថ្ម ។

ព្រះពុទ្ធទ្រង់អនុញ្ញាតិដល់បព្វជិតនូវភេសជ្ជ ៥ យ៉ាងគឺះ

**១. សប្បិ** ទឹកដោះរាវ

**២. នវនីតំ** ទឹកដោះខាប់

**៣. តេលំ** ប្រេង

**៤. មធុ** ទឹកឃ្មុំ

**៥. ផាណិតំ** ស្ករ ឬទឹកអំពៅនិងវត្ថុដទៃទៀត ដែលគេសង្រ្គោះចូលក្នុងពួកផាណិតនោះ ។

**ឯវំ ចតុប្បច្ចយទាយកោ សុខំ វិន្ទតិ តស្មា ធនំ សយម្បិ បវឌ្ឍេតព្វំ ។** បុគ្គលអ្នកអោយបច្ច័យ ៤ តែងបានសេចក្ដីសុខ ដោយរបការយ៉ាងនេះ ព្រោះហេតុនោះអ្នកមានប្រាជ្ញាគួរញុំាងទានអោយប្រព្រឹត្តទៅដោយខ្លួនឯង ។

**សាធវោ** សាធុសប្បុរសទាំងឡាយ ! នរណាមានទ្រព្យធនធានមានមាសប្រាក់ និងគ្រឿងអាហារគ្រប់គ្រាន់ហើយ បានបរិច្ចាគជាទានដល់សមណព្រាហ្មណ៍ ស្មូមយាចក អ្នកកំសត់ទុគិត អត់ឃ្លាន មិនមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

មច្ឆរិយៈកំណាញ់ស្វិតស្វាញ លាក់លៀមនូវទ្រព្យសម្បត្តិនោះទុក, នរជន នោះរមែងបានសេចក្ដីសុខចំរើនក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដោយពិតប្រាកដ ។

ផ្ទុយទៅវិញ បើបុរសស្ត្រីណាមានទ្រព្យសម្បត្តិ សម្បូណ៌ហើយមាន ចិត្តកំណាញ់ស្វិតស្វាញលាក់លៀមនូវទ្រព្យសម្បត្តិនោះ, បុរសស្ត្រីនោះ រមែងមិនបាននូវសេចក្ដីសុខចំរើន និងសុភមង្គលទេ សមនឹងពុទ្ធភាសិតថា **នេកាសី លភតេ សុខំ,** អ្នកបរិភោគតែម្នាក់ឯង តែងមិនបានសេចក្ដី សុខ បើមិនបានសេចក្ដីសុខ សេចក្ដីចំរើនហើយ នោះឯងជាប្រធាននៃ សេចក្ដីវិនាស ។

ការសំដែងមកក្នុងគាថាទី ៦ នៃបរាភវសូត្រដែលមានសេចក្ដីថា : បុរសអ្នកមានទ្រព្យធនធានច្រើន មាសប្រាក់ចំរើននឹងគ្រឿងអាហារលប លាក់របស់ដែលឆ្ងាញ់ពិសារស៊ីម្នាក់ឯងណាប្រធានវិនាស ។

ការសំដែងមកនេះក៏សន្មត

ថាចប់តែប៉ុណ្ណេះ ឯវ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសូត្រ

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

**នមត្ថុ រតនយស្ស វន្ទាមិ ។**

សូមនមស្សការថ្វាយបង្គំ ប្រជុំបីនៃព្រះរតនគឺ ពុទ្ធរតន១ ធម្ម-រតន១ សង្ឃរតន១ ដោយសេចក្តីគោរព ។

**ឥតោ បរំ ធម្មទេសនំ អារព្ភិស្សាមិ,**

ដទៃអំពីបទនមស្សការនេះទៅ ខ្ញុំព្រះករុណា អាត្មាភាព សូមលើកយកធម៌ គឺគាថាទី៧ នៃបរាភវសូត្រ មកសំដែងវែកញែក ប្រកាសចែកជូនដល់ពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា ដ៏មុតមាំ ក្នុងវរពុទ្ធសាសនា ហើយបានលះបង់នូវគ្រឿងកង្វល់ សព្វបែបយ៉ាង មកជួបជុំក្នុងទីនេ□ដើម្បីនឹងត្រងត្រាប់ស្តាប់យកអត្ថរស នៃព្រះសទ្ធម្មវិសេសទេសនា ដែលខ្ញុំព្រះករុណា អាត្មាភាពសំដែងដូចតទៅនេះ :

ទេវតាទូលសួរតទៅទៀតថា :

**ឥតិហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**

**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី៦ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងអោយទាន វិនាស ទី៧ អ្វីជាប្រធាន នាំសត្វអោយមាន សេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ចយោ នរោ**

**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល ហើយមិនប្រមូលសាច់ញាតិ សន្តានមើលងាយជាតិខ្លួនដោយអាងខ្លួនមាន នេះជាប្រធានសេចក្តីវិនាស ។

## អធិប្បាយ

## គាថាទី ៧

ពាក្យថា "មានៈ" ប្រែថា សេចក្តីប្រកាន់, ដំណើរប្រកាន់ខ្លួន សេចក្តីរឹងត្អឹង, ការរឹងរូស, ការរបញ្ញរបុញ្ញ, ការប្រតិបត្តិចចេស, ការឆ្មើងឆ្មៃ, ការឆ្មើងកន្ទ្រើង, ការប្រកាន់ឬកកក្រអឺតក្រទម, មកពីសព្ទដើមគឺ មនៈ និងណៈ កិរិយាសំគាល់ កិរិយាដឹងដោយបំណង នៃហេតុមានហេតុ ថាអញប្រសើរជាងគេជាដើម ដូចបទវិគ្គហថា **សេយ្យោ ទិវសេន មញ្ញតំ** ជា **មនោ** មានសេចក្តីប្រកាន់ ។

### មានៈធម៌នេះ កើតដោយហេតុ ៣ យ៉ាងគឺៈ

១-កើតដោយអ្នកនោះឯងសំអាងទៅលើសិល្បវិទ្យាថា អញជាអ្នកចេះដឹងជ្រៅជ្រះជាងគេ, មានគេស្គាល់ច្រើន មានគេរាប់អានច្រើន

មានសិស្សគណច្រើន ឬមួយសំអាងថាអញ មានសញ្ញាប័ត្រ ដុកទ័រ ដុតូរ៉ា លីសង់ អង់តូា អាគ្រេសេ, មានតែអញទេ ចេះដឹងច្រើនជាងគេ នៅក្នុងទីនេះ ប៉ុណ្ណោះជាដើម ។

២-កើតដោយសំអាងទៅលើវ័យ ថាអញចាស់ជាងគេ អញធ្លាប់ រស់នៅមុនគេ មានតែអញទេ ដែលធ្លាប់មានការពិសោធន៏ ច្រើនជាងគេ, ហើយក៏អំនួតមិនព្រមស្តាប់គេ ។

ជួនកាលមាននិយាយអាងថា អញនិងនៅយូរប៉ុន្មាន បន្តិចនឹង ស្លាប់ចោលទៅហើយ សេចក្តីនេះសមដូចពាក្យគេតែងពោលថា "ចាស់ អាងស្លាប់ ពាលអាងកាប់ តូចអាងយំ " គឺមិនព្រមជឿ មិនព្រមស្តាប់ គេខ្លះៗផងទេ ប៉ុណ្ណោះជាដើម ។

៣-កើតឡើងដោយអាងទៅលើរូបសម្បត្តិ អ្នកដែលមានរូបល្អ ក៏ច្រើនប្រកាន់ថា អញមានវណ្ណៈពណ៌សម្បុរល្អឆើតឆាយ វិសេសវិសាល ជាងគេ អញមិនត្រូវការ និងសេពគប់ សម្គព សមព្រមត់រាប់រក រាប់អាន មនុស្សដែលមានរូបរាង្គសម្បត្តិមិនស្អាតស្អំ ទោះបីក្នុងឥរិយាបថណាក៏ ដោយ ព្រោះយល់ឃើញថា វាជាសមុដ្ឋាន នាំអោយថោកទាប ខូចតម្លៃ ឋានៈ ឬយសស័ក្តិរបស់ខ្លួន ប្រកាន់វណ្ណៈទេ ភាគច្រើនលោកពោលថា ច្រើនតែពួកស្រីៗ រាប់ថាជាអ្នកមានវណ្ណមច្ឆរិយ គឺកំណាញ់ពណ៌សម្បុរ ប៉ុណ្ណោះជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

មានធម៌នេះកើតដោយហេតុ ៣ យ៉ាងទៀត ដូចមានបទបាលីនៅខាងដើមជាភស្តុតាងស្រាប់គឺៈ

**១-ជាតិត្ថទ្ធោ** ប្រកាន់ជាតិ

**២-ធនត្ថទ្ធោ** ប្រកាន់ទ្រព្យសម្បត្តិ

**៣-គោត្តត្ថទ្ធោ** ប្រកាន់គោត្រត្រកូល ។

ពាក្យថា " ប្រកាន់ជាតិ " បានដល់ការសំអាងថាខ្លួនជាអរិយជាតិ, ជាខត្តិយជាតិ, ជាក្សត្រជាគហបតី, ជាសេដ្ឋី, ជាកុដុម្ពីក៏ ជាព្រាហ្មណ៏ ឬព្រាហ្មណ៏មហាសាល ។ ដូចយ៉ាងពួកក្សត្រដែលថាជាព្រះញាតិរបស់ព្រះ-អង្គចំនួន ប្រាំបីម៉ឺនបួនពាន់ មានព្រះបាទសុទ្ធោទនៈ ជាប្រធាន ដោយមានបំណងចង់ឃើញ ចង់យល់ព្រះសម្មាសម្ពុទ្ធ បានចាត់បំរើអោយទៅនិមន្តព្រះអង្គអោយស្តេចយាងមកកាន់ ក្រុងកបិលព័ស្តុ, លុះស្តេចយាងមកដល់ក៏បានចាត់ចែងរៀបកន្លែងឋានលំនៅទីនោះ ។ ដំណាលអំពីពួកសក្យរាជសឹងតែមានរឹងត្អឹងមហិមា ដោយគិតពិចារណាថា ៖ ព្រះសិទ្ធត្ថកុមារគាត់នៅក្មេងទេ ហើយត្រូវជាប្អូន ជាកូនក្មួយ ជាចៅយើងនឹងទៅសំពះគាត់យល់ថាពុំសមគួរ ។

សក្យរាជខ្លះឮហើយក៏ឆ្លើយថាទេ ! យើងមិនសំពះគាត់ឯណាក៏បាន ព្រោះគាត់ជាអ្នកបួស ទោះគាត់ចាស់ក្តី ក្មេងក្តី ត្រូវតែសំពះគាត់

ដដែល, បើយើងមិនសំពះគាត់ហើយ តើគាត់មិនថាយើងមានអំនួតទៅហើយ ហ: !

អ្នកខ្លះឆ្លើយថា ទេ ! យើងអោយកុមារប្រុសស្រី មានដៃកាន់ទៀនធូប គន្ធមាលាភ្ញី ផ្កាបូជាថ្វាយ បង្គំប្រណម្យគាត់ទៅមុន យើងទាំងអស់គ្នា ដើរចន្លោះ ៧ លង្វែកដើម្បីអោយច្រឡំនឹងក្មេងទាំងនោះ តែថាយើងកុំសំពះគាត់ឡើង ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបនៅអធ្យាស្រ័យ នៃព្រះញាតិវង្ស មិនថ្វាយបង្គំ ព្រះអង្គដូច្នោះហើយ ទើបទ្រង់យាងចូលចតុត្ថជ្ឈាន អភិញ្ញាសមាបត្តិ ធ្វើបាដិហារ្យ ដើម្បីបំបាត់នូវអស្មិមានៈ នៃសក្យរាជទាំងនោះ ។

ពាក្យថា " ប្រកាន់ទ្រព្យសម្បត្តិ " បានដល់ការសំអាងថាអញមានទ្រព្យស្តុកស្តម្ភ ប្រសើរវិសេសជាងគេ ចង់ស៊ីចាយសប្បាយហ៊ឺហាយយ៉ាងណាៗ ក៏មិនភ័យព្រួយអស់ទ្រព្យសម្បត្តិ ឬ មួយប្រាថ្នាបុណ្យសក្តិឋានៈមុខដំណែងណាមួយ ចាយតែទ្រព្យសម្បត្តិទៅ ក៏បានសំរេចដូចបំណង ។

ពាក្យថា "ប្រកាន់គោត្រត្រកូល"បានដល់ការសំអាងថា អញត្រកូលក្សត្រ អញត្រកូលព្រាហ្មណ៍ អញជាវេស្ស អញជាសូទ្រជាដើម ។ នរជនណារឹងត្អឹង គឺក្រអឺតក្រអោងចំកោងឫក នឹកស្មាថានរណាថ្លៃថ្លាប្រសើរស្មើខ្លួន ព្រោះតែខ្លួនមានជាតិកំណើតកើតមកពីជនជាតិ ដែលចំរើនខ្ពង់ខ្ពស់ ឬ ប្រកបដោយសម្បុរស្បែក បែបណាមួយ ដែលគេសន្មត់ថាល្អ រួមទាំង

ការប្រកាន់វណ្ណៈថាខ្ពង់ខ្ពស់ ថោកទាប ព្រោះជាតិកំណើតយ៉ាងនេះ ដែលហៅថារឹងត្អឹងព្រោះជាតិគឺ ជាតិនេះជាតិនោះ សម្បុរស្បែកបែបនេះបែបនោះ វណ្ណៈនេះ វណ្ណៈនោះ យ៉ាងនេះក្តី រឹងត្អឹងក្រអឺតក្រអោងកោងព្រហើន ព្រោះតែរកទ្រព្យសម្បត្តិ បានស្តុកស្តម្ភមាំមួន ឬខ្លួនបានទទួលនូវមតិក យ៉ាងច្រើនពីវង្សត្រកូល ហើយកើតចិត្តជោរជ៉ោងក្រអោង រឹតត្អឹងថាខ្លួនថ្លៃថ្លា ប្រសើរជាងអ្នកដទៃក្តី, រឹងត្អឹងក្រអឺតក្រអោងកោងព្រហើនឬកពាករឈ្លើនពើន ព្រោះអាងតែខ្លួន កើតក្នុងគោត្រ គឺពូជត្រកូលខ្ពស់យសធំ មានត្រកូលក្សត្រ ត្រកូលព្រាហ្មណ៏ ត្រកូលនាម៉ឺន ជំទាវខុនណាងជាដើមក្តី ។

ការរឹងត្អឹង ក្រអឺតក្រអោងកោងព្រហើន ឈ្លើនពើន ដែលកើតឡើងព្រោះអាងជាតិក្តី ទ្រព្យសម្បត្តិក្តី គោត្រត្រកូលក្តី ដូចសំដែងមកហើយៗ មើលងាយពេបជ្រាយ បន្ទាបបន្ថោក ប្រមាថកាតទាន គ្មានសីលធម៌ មនុស្សធម៌ ចំពោះញាតិ គឺអ្នកជិតខាងរបស់ខ្លួន ដោយសំគាល់ថាពួកនេះទាបទន់អន់ខ្សោយថយថោកជាងខ្លួន ក្នុងរឿងជាតិកំណើតក្តីទ្រព្យសម្បត្តិក្តី គោត្រត្រកូលក្តី ធ្វើអោយអ្នកទាំងនោះឈឺចាប់ ក្តៅក្រហាយព្រោះការមើលងាយនោះៗ ។ លោកប្រាប់ថាការរឹងត្អឹងប្រកាន់ប្រកួត ហើយមើលងាយញាតិគឺ អ្នកជិតខាងប្រទេសជិតខាងរបស់ខ្លួនហេតុការណ៍បែបនេះ ជាប្រធាននៃសេចក្តីវិនាស នៃអ្នករឹងត្អឹងមើលងាយ

គេនោះ យ៉ាងណាមិញ, យ៉ាងនេះគឺ ញាតិឬអ្នកជិតខាង កាលបើបាន ទទួលសេចក្តីមើលងាយបន្ទាប បន្ថោកពីអ្នករឹងត្អឹង ប្រកានប្រកួតអួត ជាតិកំណើតទ្រព្យ ឬត្រកូលនោះហើយរមែងឈឺចាប់ចិត្តឥតត្រជាក់ត្រជុំ កើតគំនិតគិតគំនុំគុំបៀតបៀន បំផ្លិចបំផ្លាញអ្នករឹងត្អឹងមើលងាយ ខ្លួន អោយវិនាសហិនហោចខ្លោចផ្សារ ក្នុងថ្ងៃណាមួយ កាលបើឱកាសបើក អោយក៏សងគំនុំចិត្តមិនខាន ។

ដូច្នេះលទ្ធផលអាក្រក់រមែងកើតឡើង ចំពោះរឹងរូសព្រោះជាតិក្តី ទ្រព្យក្តី គោត្រត្រកូលក្តីនោះឯង ដោយពិតប្រាកដ ។

ព្រះពុទ្ធដីកាដែលបានសំដែងមកហើយនេះ មានគោលបំណងនឹង បង្ហាញហេតុការណ៍នៃសេចក្តីវិនាសមួយ ក្នុងចំណោមនៃសេចក្តីវិនាសច្រើន ទៀត គឺការរឹងរូសក្រអឺតក្រអោង ព្រហើនឈ្លើនពើន មើលងាយអ្នកដទៃ ព្រោះអាងជាតិកំណើតទ្រព្យសម្បត្តិ ឬពូជត្រកូល មិនមែនជាផ្លូវដែលត្រូវ យកមកអនុវត្តឡើយ ព្រោះជាផ្លូវវិនាសហិនហោចខ្លោចផ្សា ដែលព្រះបរម សាស្តាចារ្យ ទ្រង់ត្រាស់សំដែងមក ។

ពុទ្ធបរិស័ទទាំងឡាយ ! ការប្រកាន់ដោយអាងចំពោះវិជ្ជា ដោយអាងវ័យ ដោយអាងជាតិ ទ្រព្យសម្បត្តិ គោត្រត្រកូលទាំងអស់នេះ ហើយមានចិត្តប្រមាថមើលងាយដល់មនុស្សជាតិដូចគ្នា ដល់ពួកបក្សគណៈ ក្រុមសង្គម គ្រួសារឬអ្នកភូមិផងរបងជាមួយ, ព្រះសម្មាសម្ពុទ្ធជាម្ចាស់

នៃយើងទ្រង់សំដែងថា សុទ្ធតែជាសមុដ្ឋាន នៃសេចក្តីវិនាសទាំងអស់ ហើយអ្នកដែលប្រកាន់នោះជាមនុស្សថោកទាបបំផុត សមនឹងព្រះពុទ្ធភាសិតមួយកន្លែង ដែលមានមកព្រះអង្គទ្រង់សំដែងថា :

**យោ ចត្តានំ សមុក្កំសេ បរេច អវជានតំ**
**និហីនោ សេន មានេន តំ ជញ្ញា វសលោ ឥតិ ។**

អ្នកណាជាមនុស្សថោកទាបលើកតំកើតខ្លួនឯង មើលងាយអ្នកដទៃ គេគប្បីដឹងអ្នកនោះថា ជាមនុស្សថោកទាប ព្រោះមានរបស់ខ្លួន ។

អ្នកណាដែលមានទ្រព្យសម្បត្តិក្តី ខ្សត់ក្រក្តី មានវិជ្ជាក្តី ល្ងង់ខ្លៅក្តី តែជាមនុស្សមានចិត្តថោកទាប លើកតំកើនតំឡើងតម្លៃខ្លួនឯង ថាប្រសើរថ្លៃថ្លា ខ្ពង់ខ្ពស់ជាងអ្នកដទៃ ដោយចិត្តជោរជំនោខាងការរឹតត្បឹង ក្រអឺតក្រអោង កំប៉ិងកំប៉ោង ព្រហើនឈ្លើនពើន មើលទៅអ្នកដទៃថា មិនគ្រាន់បើប្រសើរស្មើខ្លួន ហើយកើតចិត្តគិតមើលងាយបន្ទាបបន្ថោក អ្នកដទៃដោយទឹកចិត្តក្តី ដោយសម្តីក្តី មើលងាយនិយាយបន្ថោកមានប្រការផ្សេងៗក្តី ហើយឡើងអំនួតអួតតំកើង តែខ្លួនឯងថា គ្មាននរណាដល់ គេគប្បីដឹងយល់ថាមនុស្សប្រភេទនេះ ជាមនុស្សថោកទាប ព្រោះមានរបស់ខ្លួនគឺថារឹងត្អឹងក្រអឺតក្រអោង របស់ខ្លួននោះ នាំអោយកើតគំនិតថា ខ្លួនប្រសើរជាងអ្នកដទៃ ហើយមើលងាយអ្នកដទៃ ធ្វើឫកធំហួសមាឌ សម្តីខ្ពស់ហួស

ចន្ទោល ក្នុងគោលបំណងអោយគេឃើញថាខ្លួនប្រសើរ និងក្នុងដំណើរ មើលងាយ គេប៉ុណ្ណោះ ចុះក្នុងតម្រាថា " អង្គុយលើចង្អេរលើកខ្លួនឯង" ។

មនុស្សប្រភេទនេះ ជាមនុស្សមិនស្គាល់ប្រមាណខ្លួន ធ្វើអោយអ្នកដទៃកើតសេចក្តីធុនទ្រាន់ជិនឆ្អន់ មិនចង់សេពគប់រាប់រក ធ្វើអោយអ្នកដទៃផ្ទុយផ្ទាល់តបវិញ, ធ្វើអោយអ្នកដទៃមួម៉ៅក្តៅក្រហាយ ។ ដូច្នេះ មនុស្សក្រអឺតក្រអោង លើកតំកើនខ្លួនឯង មើលងាយអ្នកដទៃ ឈ្មោះថា ជាមនុស្សថោកទាប ព្រោះប្រកបដោយចិត្តថោកទាប កិរិយាឬកពារថោកទាប ដែលកើតពំធមិថោកទាបគឺមានះនេះឯង ។ មានះធមិនេះបើកើតមានដល់មនុស្សសត្វណាហើយ ទោះបីអ្នកនោះធ្លាប់ជួបប្រទះ ឬធ្លាប់មានបុណ្យស័ក្តិឋានៈខ្ពង់ខ្ពស់ ក៏គង់ទាញអ្នកនោះឯងអោយធ្លាក់ចុះក្នុងហីនភាពទាបថោញ ជាមិនខានឡើយ, សមដូចជានិទាន **សត្វបង្គួយ** សូមនាំនិទាននោះមកសំដែងបញ្ជាក់ដូចតទៅនេះ :

មានសេចក្តីដំណាលថា :សម័យថ្ងៃមួយព្រះបាទវិទេហរាជ ស្តេចសោយរាជ្យក្នុងនរគរមិថិលា ព្រះអង្គយាងទៅក្រសាលឧទ្យាន, ទ្រង់បានទស្សនាការ ឃើញសត្វបង្គួយមួយ ចុះពីក្លោងទ្វារមកធ្វើក្បាលងឹកងើុក១ ងាក់ងើុក១ ទ្រង់ក៏ត្រាស់សួរថា បង្គួយនេះវាធ្វើអ្វី ? ព្រះមហោសថក្រាបបង្គំទូលថា សត្វបង្គួយនេះ វាគោរពព្រះអង្គ ។ ទ្រង់មានព្រះរាជហឫទ័យត្រេកអរ បង្គាប់អាមាត្យ អោយទិញសាច់អោយបង្គួយនោះបរិភោគ

Websites: WatKhemaraRatanaram.org or WatKhmers.org

រាល់៧ថ្ងៃ ។ ក្នុងសីលអាមាត្យរកទិញសាច់មិនបាន ក៏យកប្រាក់មួកាក ណិក តម្លៃស្មើនឹងសាច់មកចោះដោតខ្សែចងបំពាក់ ព្ធដ៏កបង្គួយ ។ បង្គួយបានគ្រឿងអលង្ការពាក់ហើយគិតថា : អញមានគ្រឿងអលង្ការពាក់ស្តេចក៏មានអលង្ការពាក់ដូចគ្នា ចាំបាច់គោរពស្តេចធ្វើអ្វី ? ។

សម័យខាងក្រោយមក កាលព្រះរាជាទៅដល់ទីនោះ បង្គួយតម្លើងមានះក្រអឺត ។ ព្រះរាជាទ្រង់ព្រះកង្ខា ក៏ត្រឡប់មកទ្រង់សួរព្រះ-មហោសថ ។ ព្រះពោធិសត្វទោះបីមិនបានឃើញអាមាត្យបំពាក់គ្រឿងអលង្ការសោះក៏ក្រាបទូលថា សត្វបង្គួយនេះ វាមើលងាយព្រះអង្គ ព្រោះប្រហែលជាអាមាត្យ បំពាក់គ្រឿងអលង្ការអោយវាទេដឹង ? ព្រះរាជាទ្រង់ព្រះពិរោធ ទើបទ្រង់បង្គាប់អោយគេដេញសត្វបង្គួយចាក់ពីនោះ ។ សត្វបង្គួយដល់នូវសេចក្តីវិនាសចាកលាភ ព្រោះតែតម្លើងឋានៈប៉ុណ្ណោះ ។

**អោវាទធម៌** ហៃសាធុសប្បុរសទាំងឡាយ ! កាលបើឃើញទោសនៃមានះធមិនេះ ដូច្នោះហើយគប្បីលះបង់ ឬ រៀនលះអោយបានអស់ពីខន្ធសន្តាន កុំបីមានសេសសល់ដល់តិចតួចឡើយ ។

**អស្មិមានៈ** ចែញចេញជា ៩ យ៉ាងទៀតគឺៈ

១-អ្នកប្រសើរជាងគេ ប្រកាន់ថាអញប្រសើរជាងគេ

២-អ្នកប្រសើរជាងគេ ប្រកាន់ថាអញស្មើនឹងគេ

៣-អ្នកប្រសើរជាងគេ ប្រកាន់ថាថោកទាបជាងគេ

Websites: WatKhemaraRatanaram.org or WatKhmers.org

៤-អ្នកស្មើនឹងគេ ប្រកាន់ថាអញប្រសើរជាងគេ

៥-អ្នកស្មើនឹងគេ ប្រកាន់ថាអញស្មើនឹងគេ

៦-អ្នកស្មើនឹងគេ ប្រកាន់ថាអញស្មើនឹងគេ

៧-អ្នកថោកទាបជាងគេ ប្រកាន់ថាប្រសើរជាងគេ

៨-អ្នកថោកទាបជាងគេ ប្រកាន់ថាស្មើនឹងគេ

៩-អ្នកថោកទាបជាងគេ ថាថោកទាបជាងគេ

សេចក្តីប្រកាន់ខ្លួនថា ជាអ្នកថោកទាបជាងគេនោះលោកកំណត់ដោយជាតិ គោត្រត្រកូលរូបសម្បត្តិ ទ្រព្យសិល្បវិទ្យា ។ មានៈនេះលោករាប់ថាជាកិលេសជាតិមួយ ដែលអាចញ៉ាំងចិត្តរបស់មនុស្សសត្វ អោយមានសេចក្តីសៅហ្មងរវាំងគ្នា និងគ្នា ជាហេតុអោយបែកសាមគ្គី ធម៌របស់ជនរួមជាតិក្តី របស់ជនជាតិបរទេសក្តី ជាកិលេសប្រព្រឹត្តទៅដើម្បីបង្ខូចនូវប្រយោជន៍របស់ជាតិសាសនា បានដោយពិតប្រាកដ ។

មានៈទាំង ៩ នេះ ជាត់ជាបហាតព្វធម៌គឺជាផ្នែកខាងធម៌ដែលព្រះយោគាវចរត្រូវលះបង់អោយអស់ពីក្ខន្ធសន្តាន ។ មានៈទី១ ទី៤ ទី៧ ចាត់ចូលក្នុងលក្ខណៈនៃបុគ្គលជា បុគ្គលជាមនុស្សទ្រនង់គឺ ជាមនុស្សដណ្តើមល្អ ដណ្តើមជាខ្លួន ប្រសើរជាងគេ ។

មានទាំង ៣ នេះ ច្រើនកើតឡើងចំពោះឥស្សរៈជន នឹងបព្វជិត ដោយហេតុថា បើមានសេចក្តីប្រកាន់រឹងត្អឹងដូច្នេះជាហេតុអោយរារាំងមិនងាយនឹងជឿស្តាប់អ្នកណាមួយឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

មានៈទី២ ទី៥ ទី៨ ចាត់ចូលក្នុងលក្ខណៈនៃបុគ្គល ជាមនុស្សប្រកាន់ឫកស្មើនឹងគេដោយ សេចក្ដីប្រកាន់ថា ខ្លួនប្រសើរជាងគេពិតមែន ប៉ុន្តែដាក់ខ្លួនថា ស្មើនឹងគេវិញ, ទោះបីខ្លួនថោកទាបជាងគេ ក៏ប្រកាន់ថាស្មើនឹងគេ ។ មានៈទាំង ៣យ៉ាងនេះ ច្រើនតែកើតឡើងចំពោះឥស្សរជនដែរ ។ មានៈទាំងនេះ ក៏នាំមិនអោយជឿស្ដាប់ក្នុងសំណាក់លោកអ្នកចេះដឹង ។

មានៈ ទី៣ ទី៦ ទី៩ ចាត់ចូលក្នុងលក្ខណ នៃបុគ្គលជាអ្នកបន្ថោកខ្លួនឯង ។ សេចក្ដីប្រកាន់ដោយការដាក់ខ្លួន បន្ទាបខ្លួន ហួសហេតុពេកខុសអំពីច្បាប់សីលធម៌ សំរាប់ឋានៈរបស់មនុស្សនេះ បើគិតដោយស្មើៗហាក់ដូចជាពុំចាត់ជាមានៈ ជាសេចក្ដីប្រកាន់ខុសទេ ប៉ុន្តែតាមដោយពិតការប្រកាន់ដូច្នោះ ក៏នាំអោយខូចប្រយោជន៍របស់ខ្លួនជាប្រាកដ ព្រោះថាមានៈទាំង ៣ ប្រការនេះ កាលបើមានកម្លាំងបរិបូណ៌ក្នុងសន្ដាន បុគ្គលណា អាចញ៉ាំងបុគ្គលនោះមិនអោយចូលទៅជិត កាន់សំណាក់លោកអ្នកប្រាជ្ញ ដើម្បីនឹងបានទទួលស្ដាប់ធម៌អាថ៌ ឬ ច្បាប់ទម្លាប់ណាមួយបានទេ, ដោយហេតុតែសេចក្ដីប្រកាន់ថាខ្លួនអញ ជាមនុស្សថោកទាប ដោយជាតិក្ដី ដោយយសស័ក្តិក្ដី ឬ ទ្រព្យសម្បត្តិក្ដី ក៏ថោកទាបទៅចុះ ធ្វើម្ដេចខ្លួនឯងបានជាថោកទាបទៅហើយ មិនខ្វីចូលទៅជិតឱនលំទោន ក្រាបលុតស្ដាប់បង្គាប់ ចុះចូលនឹងអ្នកណាមួយទេ ។ ដំណើរនៃសេចក្ដីប្រកាន់នេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឃើញថាជាទោស ជាសេចក្ដីប្រកាន់ខុស គួរចូលក្នុងលក្ខណៈនៃមានៈបាន ដោយពិតប្រាកដ ដូចគ្នានឹងមានៈ ថ្នាក់ទី១ ទី២ ដូច្នោះដែរ ។

សប្បុរសទាំងឡាយ ! បុគ្គលណាក្នុងលោកនេះ បានបន្សាត់បង់នូវអស្មិមានៈនេះ ចេញចាកសន្ដានហើយ បុគ្គលនោះរមែងទទួលនូវសេចក្ដីសុខដោយពិត សមដូចព្រះពុទ្ធដីកាទ្រង់ត្រាស់ថា :

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ អស្មិមានស្ស វិនយោ ឯតំ បរមំសុខំ ។**

ប្រែថា ភាវប្រាសចាករាគ គឺកិរិយាកន្លងនូវកាមទាំងឡាយនាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើអោយវិនាសនូវអស្មិមានៈ នេះឯងនាំមកនូវសេចក្ដីសុខដ៏ឧត្ដម ។

ព្រះពុទ្ធដីកាមួយកន្លែងមានមកក្នុង គម្ពីរសំយុត្តនិកាយ សគាថវគ្គទ្រង់សំដែងថា

**មានំ បហាយ សុសមាហិតត្តោ**
**សុចេតសោ សព្វធិ វិប្បមុត្តោ ឯកោ**
**អរញ្ញេ វិហរំ អប្បមត្តោ ស មច្ចុ**
**ធេយ្យស្ស បារគូ សិយា ។**

អ្នកណាលះមានៈ មានខ្លួនមាំល្អ ហើយមានចិត្តល្អ រួចស្រឡះក្នុងទីទាំងពួង នៅក្នុងព្រៃតែម្នាក់ឯង ជាអ្នកមិនប្រមាទ, អ្នកគប្បីឆ្លងត្រើយនៃដែនមច្ចុបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះពុទ្ធដីកានេះផ្ទុយនឹងព្រះពុទ្ធដីកាខាងលើ

**ន មានកាមស្ស ទមោ អត្ថិ**

**ន មោនមត្ថិ អសមាហិតស្ស**

**ឯកោ អរញ្ញេ វិហរម្បមត្តោ ន**

**មច្ចុធេយ្យស្ស តរេយ្យ បារំ ។**

ក្នុងពេលនេះ អ្នកស្រឡាញ់មានះ រមែងមិនមានការទូន្មានខ្លួន, អ្នកមានចិត្ត មិនតម្កល់មាំ រមែងមិនមានសេចក្ដីដឹង, អ្នកប្រមាថសូម្បី នៅក្នុងព្រៃម្នាក់ឯង ក៏មិនគប្បីឆ្លងនូវត្រើយ នៃដែនម្រឹត្យុ បានឡើយ ។

អ្នកស្រឡាញ់មានះធមិ ហើយមិនមានការទូន្មានខ្លួន មានចិត្តមិនដំកល់មាំ បណ្ដោញអោយមានះ ជិះជាន់បានហើយ អាចដឹងនាំទៅកាន់ហាយនភាពថោកទាបក៏មាន រមែងវិនាសខ្លួន ប្រាណបានទុក្ខលំបាកក៏មាន សានសូន្យពូជពង្សវង្សាក៏មាន ព្រោះតែស្រឡាញ់នូវមានះ ដូចរឿងសាក្យរាជ និងវិឌូឌភៈ សូមនាំនិទាននោះមកសំដែង ដោយសង្ខេបដូចតទៅនេះ

រឿងវិឌូឌភៈនេះ មានមកក្នុងធម្មបទដ្ឋកថាភាគ ៣ ទំព័រ ទី ៧ ។

មានសេចក្ដីដំណាលថា ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ធរមាននៅឡើយ ព្រះបាទបសេនទិកោសល មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បាននិមន្តព្រះសម្មាសម្ពុទ្ធព្រមទាំងព្រះភិក្ខុសង្ឃចំនួន ៥០០ អង្គ ដើម្បីទទួលនូវភត្តាហារជារៀងរាល់ថ្ងៃ ដែលព្រះរាជាបាន

ចាត់ចែងនូវក្នុងកន្លែងរបស់ព្រះអង្គ ។ ព្រះសម្មាសម្ពុទ្ធមានព្រះដីកាថា មហារាជ ! តថាគតមិនទទួលភត្តតែមួយកន្លែងជារៀងរាល់ថ្ងៃបានទេ ពីព្រោះជាប់ពុទ្ធកិច្ចប្រោសសត្វគ្រប់ទិសទី ។ ព្រះសម្ពុសម្ពុទ្ធទ្រង់ចាត់ព្រះអានន្ទអោយទៅទទួលភត្តជំនួសព្រះអង្គជាមួយនឹងភិក្ខុ ៥០០ អង្គ ។ ក្នុងការអង្គាសភត្តាហារដល់ព្រះសង្ឃចំនួន ៥០០ អង្គនោះ យូរៗទៅរាជបំរើកើតសេចក្តីប្រមាថប្រហែសធ្វេស មិនសូវគោរព មិនអើពើ,ព្រះសង្ឃក៏ឈប់មកទទួលភត្តម្តង ១ អង្គ ២អង្គ ៣អង្គ រហូតនៅសល់តែព្រះអានន្ទ ១អង្គ ។

ក្នុងថ្ងៃមួយព្រះរាជាបសេនទិកោសល ស្តេចយាងចូលទៅកាន់កន្លែងអង្គាសភត្តាហារដល់ព្រះសង្ឃនោះ ស្រាប់តែឃើញអស់ព្រះភិក្ខុសង្ឃឃើញនូវតែព្រះអានន្ទ ១ រូប, ព្រះរាជាបានសាកសួរចំពោះព្រះអានន្ទបានដឹងសេចក្តីសព្វគ្រប់ ហើយព្រះរាជាមានព្រះតំរិះថា ហេតុតែព្រះអង្គមិនជាប់សាច់ញាតិជាសក្យ នឹងព្រះសម្មាសម្ពុទ្ធ បានជាយ៉ាងហ្នឹង ។ ព្រះបាទបសេនទិកោសលទ្រង់ព្រះតំរិះថា គួរតែផ្ញើព្រះរាជសារទៅស្តីដណ្តឹងធីតានៃសក្យត្រកូល ដើម្បីធ្វើជាអគ្គមហេសី ភ្ជាប់សាច់ឈាមជាព្រះញាតិ។ បានចាត់រាជអាមាត្យ អោយនាំសារ ទៅថ្វាយព្រះមហានាម នានគរកបិលព័ស្តុ ព្រះមហាក្សត្រក្នុងកបិលព័ស្តុ ដោយមានមានះ ប្រកាន់មិនចង់អោយសក្យត្រកូលទៅជាប់ញាតិនឹងស្តេចបសេនទិកោសល តែដោយ

នឹកឃើញស្ទឹងកម្នាក់ឈ្មោះ វាសភខត្តិយដែលព្រះអង្គបានរួមសង្វាស រហូតដល់មានបុត្រីមួយ តែព្រះអង្គលាក់បិទបាំងមិនអោយនរណាដឹងរឿងនេះព្រមទាំងបានលះបង់ចោល មិនដែលនឹកនាបន្តិចបន្តួចសោះឡើយ ។

ព្រះរាជាបានលើកធីតានៃស្ទឹងកនោះ ថ្វាយមកព្រះបាទបសេនទិ-កោសល ក្នុងដែនកាសី ។

មិនយូរប៉ុន្មាន អគ្គមហេសីនៃព្រះបាទកោសេនទិកោសលមានគិតគ្រប់ខែហើយ បានប្រសូត្រព្រះរាជបុត្រមួយ, ព្រះរាជាបានចាត់អាមាត្យចាស់ម្នាក់ នាំដំណឹងនោះទៅថ្វាយព្រះមហានាម ដែលត្រូវជាព្រះអយ្យកោ ថ្វាយព្រះនាមដល់ព្រះរាជនត្តានោះ, ព្រះរាជាមិនសព្វព្រះទ័យបានពោលថា គេមិនអើពើ គេមិនរាប់រក មិនរាប់អាន ចេះតែមក ពាក្យបាលីថា **វល្លភៈ** ដោយអាមាត្យថ្លង់ ស្តាប់ច្រឡំថា ព្រះរាជាថ្វាយព្រះនាមដល់ចៅថា **វិឌូឌភៈ** ហើយយកពាក្យនោះទៅថ្វាយដល់ព្រះបាទបសេនទិកោសលថា ព្រះអយ្យកោ ថ្វាយព្រះនាមដល់ព្រះរាជបុត្ររបស់ព្រះអង្គថាវិឌូឌភៈទៅវិញ ។

លុះដល់ វិឌូឌភៈ មានវ័យវឌ្ឍនាការធំចំរើនឡើង បានសួររកព្រះ-ញាតិ ព្រះមាតាបាននិយាយប្រាប់ថា ព្រះញាតិនៅនគរកបិលព័ស្តុ វិឌូឌភៈដោយចង់ស្គាល់ព្រះញាតិ ទើបសុំលាព្រះមាតា ដើម្បីទៅសួរសុខទុក្ខព្រះ-ញាតិ បានផ្ញើសារ ទៅព្រះរាជាអោយដឹងមុន, ព្រះរាជាមានការទើស

ទាលនឹងមាន មានៈប្រកាន់ថា ព្រះអង្គជាសក្យត្រកូលមិនអោយត្រកូលដទៃមកប្រឡាក់ប្រឡូកលាយឡំ តែដោយយល់ទៅលើព្រះបាទបសេនទិកោសល បើមិនអើពើ មិនទទួលខ្លាចព្រះបាទបសេនទិកោសល ព្រោះព្រះអង្គពូកែខាងច្បាំង ។

ពួកសក្យត្រកូល បានព្រឹក្សាគ្នាថអោយមកទទួលតែសក្យចាស់ៗ ដើម្បីអោយវិឌូឌភៈធ្វើអភិវាទន៍ថ្វាយបង្គំ ពួកក្មេងៗមិនអោយមកជិត ។ វិឌូឌភៈ មានការសង្ស័យ តែមិនហ៊ានសួរនាំអ្វី ។ លុះដល់ពេលវិឌូឌភៈលាត្រឡប់មកនគរវិញ ដល់ពាក់កណ្តាលផ្លូវ ភ្លេចដាវបានប្រើអាមាត្យអោយទៅយក ស្រាប់តែឃើញសក្យក្មេងៗជាច្រើន ហើយគេបានយកទឹកដោះលាងត្រង់កន្លែងដែលវិឌូឌភៈអង្គុយ ឬ ឈរពីព្រោះគេមិនចង់អោយត្រកូលថោកទាបជាប់សែស្រឡាយ នឹងសក្យត្រកូល ។

លុះអាមាត្យទៅដល់បានថ្វាយដំណឹងនោះដល់វិឌូឌភៈ ក៏ទ្រង់ពិ-រោធ ហើយបានចងគំនុំនឹងសក្យទាំងនោះថា ចាំមើលអញបានសោយរាជ្យពួកសក្យ យកទឹកដោះលាងកន្លែង ដែលអញអង្គុយ ឬឈរមិនអីទេ អញនឹងយកឈាមក្នុងបំពង់ករបស់សក្យទាំងនោះ មកលាកន្លែងដែលអញអង្គុយវិញមិនខាន។ ចំណេរមកវិឌូឌភៈ បានផ្ញើរសារទៅសក្យត្រកូលដើម្បីលើកទ័ពមកច្បាំងគ្នា លុះទៅដល់ពាក់កណ្តាលផ្លូវវិឌូឌភៈ បានបញ្ឈប់ទ័ពនៅទីនោះ ។

ដំណាលពីព្រះសម្មសម្ពុទ្ធ បរមគ្រូព្រះអង្គប្រមើលមើល ឧប-និស្ស័យរបស់សត្វឃើញថា សក្យត្រកូលនឹងត្រូវវិនាសដោយដៃវិឌូឌភៈ ទើបព្រះអង្គស្តេចយាងទៅឃាត់ក្នុងទីនោះមានដើមឈើពីរដើម មួយដើមមានស្លឹកម្លប់ត្រឈឹងត្រឈៃ មួយដើមទៀតអត់មានស្លឹក វិឌូឌភៈបានទៅថ្វាយបង្គំព្រះសម្ពុទ្ធហើយពោលថា ព្រះអង្គមិនគង់ក្រោមដើមឈើដែលមានម្លប់ ព្រះអង្គគង់ក្រោមដើមឈើដែលអត់ម្លប់ទៅវិញ ព្រះអង្គមិនក្តៅទេឬ ?

ព្រះអង្គមានព្រះពុទ្ធដីកាថា ក្តៅអីប៉ុណ្ណេះ គំនុំចងពៀរអាឃាតដល់គ្នានិងគ្នា ក្តៅជាងនេះទៅទៀត ព្រះអង្គឃាត់វិឌូឌភៈបាននាំទ័ពត្រឡប់ទៅកាន់នគរវិញលើកទី១ លើកទី២ លើកទី៣ បានជួបនឹងព្រះ-សម្មសម្ពុទ្ធព្រះអង្គទ្រង់ឃាត់ លើកទី៤ ព្រះអង្គពិចារណាប្រមើលឃើញនូវបុព្វកម្មរបស់ពួកសក្យទើបទ្រង់មិនទៅជួបមិនឃាត់ ។

វិឌូឌភៈបានលើកទ័ពមកចាប់ កាប់សម្លាប់ពួក សក្យត្រកូលអស់ឥតសេសសល់ នៅសល់តែមហានាមដែលត្រូវជាព្រះអយ្យកោ ដោយពាក្យអង្វររបស់មាតាថា អោយទុកជីវិតព្រះអង្គ ។ ដោយមានៈជាខ្លាំងរបស់សក្យ សូម្បីតែទទួលព្រះក្រយាររួមជាមួយគេក៏មិនព្រម ដេកដើរឈរ អង្គុយរួមមិនព្រម ។

ពួករាជអាមាត្យក៏ប្រើអាជ្ញាបានចាប់ចងបណ្តើរទៅ ដល់ធូចំណោង ហើយរួចរត់ទៅលោតចូលក្នុងស្រះនាគបានទទួលយកទៅកាន់ភុជង្គនាគទៅ ។

ពួកសក្យរាជដែលដល់នូវសេចក្តីវិនាសជីវិតអស់យ៉ាងនេះ ក៏ព្រោះតែមានះ ប្រកាន់ពូជសាសន៍ហួសហេតុពេក ។

**អស្មិមានះ** នេះជាកណ្ហធម៌ ធម៌ខ្មៅជាអកុសលធម៌ សុទ្ធជាក្រុមបបញ្ចធម៌ ជាធម៌ធ្វើដំណើរ គឺការប្រតិបត្តិរបស់សត្វ លោកអោយយឺនយូរក្នុងការសំរេចនូវមគ្គផល ។ បើមាននៅក្នុងខន្ធសន្តានរបស់បុរសស្ត្រីណាហើយ គប្បីក្តិច ឬកាត់ចេញកុំអោយដុះ ពេលលេចពន្លកតទៅទៀត **បបញ្ចធម៌** ប្រែថា ធម៌សំរាប់ធ្វើសត្វដែលត្រាច់អង្គត់ក្នុងវាលវដ្តសង្សារអោយយឺនយូរ, អោយទទាក់ទទាម, អោយរអាករអួល, អោយខកពេលវេលា, អោយស្ទុនដំណើរ, អោយពន្យាពេល, ឬប្រែថា ធម៌ធ្វើសត្វមិនអោយមានឧបនិស្ស័យល្អ មិនអោយនិស្ស័យរបស់សត្វដែលមានមកខ្លះហើយនោះអោយចាស់ក្លាទៅកើត, បទវិគ្គហថា : **បបញ្ចយតេតិ** ជា**បបញ្ចោ ។**

**បបញ្ចធម៌** មាន ៣ យ៉ាងគឺៈ

**១-មានះ** សេចក្តីប្រកាន់

**២-តណ្ហា** សេចក្តីប្រាថ្នា

**៣-ទិដ្ឋិ** សេចក្តីយល់ឃើញ ។

ពាក្យថា តណ្ហា ប្រែថា សេចក្តីប្រាថ្នា, ការចង់បាន, សេចក្តីអន្ទះអន្ទែង, បំរះនទៀល, មកពីស័ព្ទដើមគឺ **តស + ណ្ហ + អាត,** សេចក្តីស្រេកឃ្លាន, សេចក្តីប្រាថ្នា,សេចក្តីចង់, ចំណង់, ឬធម្មជាតិជាគ្រឿងញ៉ាំងសត្វអោយតក់ស្លុត បទវិគ្រោះថា **តសតិ ឯតាយាតិ** ជា **តណ្ហា** ។

តណ្ហាចែកចេញជា ៣យ៉ាងគឺ:

**១.កាមតណ្ហា** សេចក្តីប្រាថ្នាក្នុងភព

**២.ភវតណ្ហា** សេចក្តីប្រាថ្នាក្នុងភព

**៣.វិភវតណ្ហា** សេចក្តីប្រាថ្នាក្នុងការប្រាសចាកភព ។

សេចក្តីសោកក្តី ភ័យក្តី តែងកើតអំពីតណ្ហា ព្រះពុទ្ធដីកាក្នុងធម្មបទដ្ឋកថា ភាគ៦ ទំព័រ២២១ ទ្រង់សំដែងថា :

**តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេភយំ**
**តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោក កើតពីតណ្ហា ភ័យកើតពីតណ្ហា សេចក្តីសោកមិនមាន ដល់បុគ្គលអ្នករួចស្រឡះចាកតណ្ហា ភ័យនឹងមានមកពីណាបាន ។

ពាក្យថា **ទិដ្ឋិ** ប្រែថា សេចក្តីយល់ឃើញ តែមិនទាន់ចាត់ល្អអាក្រក់នៅឡើយ គឺនៅជាពាក្យកណ្តាល បើអាក្រក់ថែមមិច្ឆា ស័ព្ទខាងដើមដែលប្រែថា "ខុស" រួមស័ព្ទទាំងពីរចូលគ្នាជាមិច្ឆាទិដ្ឋិ ប្រែថា យល់ខុស, ឃើញខុស, បើផ្អែកល្អ ថែមសម្មាស័ព្ទ នៅខាងដើមដែលប្រែថា

ប្រពៃ, រួមស័ព្ទទាំងពីរចូលគ្នា សម្មាទិដ្ឋិប្រែថា យល់ត្រូវ ឬ ឃើញត្រូវ យល់ប្រពៃ ឬ ឃើញប្រពៃ ។

បណ្តាមនុស្សទាំងអស់ក្នុងសកលលោក មិនថាមនុស្សថ្នាក់ណា បែបណាសាសន៍ណា ជាតិណាទេ អោយតែឈ្មោះថាជាមនុស្សហើយ សុទ្ធតែមានការយល់ឃើញ នឹងមានអធ្យាស្រ័យផ្សេងៗពីគ្នាដរាប, ទិដ្ឋិនេះជាកិលេសជាតិមួយយ៉ាងល្អិត ដែលដេកត្រាំនៅក្នុងសន្តានរបស់សត្វ ធ្វើចិត្តគំនិតរបស់សត្វ អោយឃ្លាតចាកសេចក្តីពិត ។

ទិដ្ឋិចែកចេញជា ២ យ៉ាងគឺ :

**១.សស្សតទិដ្ឋិ** សេចក្តីយល់ឃើញថាទៀង

**២.ឧច្ឆេទទិដ្ឋិ** សេចក្តីយល់ឃើញថាសូន្យ ។

បុគ្គលអ្នកមានតបៈធម៌ ដុតកំលោច ឬ កំទេចនូវឧបក្កិលេសទាំងអស់បានទើបឈ្មោះថា បានដល់នូវសេចក្តីសុខចំរើន សមនឹងព្រះពុទ្ធដីកា ដែលមានមកក្នុងគម្ពីរ ខុទ្ទកនិកាយ សុត្តនិបាត ទ្រង់សំដែងថា :

**បហាយ បញ្ចាវរណានិ ចេតសោ**

**ឧបក្កិលេស ព្យបនុជ្ជ សព្វេ**

**អនិស្សិតោ ឆេត្វា សិនេហទោសំ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ឌិតលះគ្រឿងរារាំងចិត្តទាំង ៥ កំទេចឧបក្កិលេសទាំងអស់ កាត់សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ ដែលមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។

ពាក្យថាបណ្ឌិតក្នុងផ្ទៃនៃគាថានេះ សំដៅយកអរិយបណ្ឌិត ដែលស្ថិតនៅក្នុងអរិយធម៌ ជាគុណធម៌ជាន់ខ្ពស់, អរិយៈបណ្ឌិតបានលះគ្រឿងរារាំងចិត្តទាំង ៥ ដែលហៅថា នីវរណធម៌ ជាធម៌រាំងរាចិត្តមិនអោយសំរេចសេចក្តីល្អ គឺពេញចិត្តស្អិតស្រឡាញ់ក្នុងអារម្មណ៍ដែលគាប់ចិត្តមានរូបជាដើមហៅថា កាមច្ឆន្ទ១, ចង់ទម្រន់ទ្រមក់ និងងោកងុយហៅថា ថិនមិទ្ធ១ ចិត្តរវើរវាយរាយមាយហៅថា ឧទ្ធច្ចកុក្កុច្ច១, អល់អែកមិនដាច់ស្រេចហៅថា វិចិកិច្ឆា ១, លោកលះធម៌ទាំង ៥ នេះស្រឡះថែមទាំងកំទេចផ្តាច់បង់នូវឧបក្កិលេសទាំងអស់មាន អភិជ្ឈាវិសមលោភ ទោសៈ កោធៈ ឧបនាហ ជាដើម មានបមាទជាទីបំផុត, ពោលគឺលោកមានចិត្តបរិសុទ្ធផុតមន្ទិលសៅហ្មង មិនជាប់ចំណងមារគឺកិលេស កាលបើយ៉ាងនេះចិត្ត លោកស្ថិតនៅជាកណ្តាលៗ ក្នុងចន្លោះសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ គឺមិនស្រឡាញ់ មិនស្អប់ នូវបុគ្គលឬវត្ថុអ្វីៗ ក្នុងលោក ទោះជាឥដ្ឋារម្មណ៍ក្តី អនិដ្ឋារម្មណ៍ក្តី ព្រោះមានចិត្តជាឧបេក្ខា មិនប្រកបដោយតណ្ហា គឺសេចក្តីប្រាថ្នា សេចក្តីញាប់ញ័រ និងមិច្ឆាទិដ្ឋិឡើយ លោកអាចត្រាច់ទៅតែម្នាក់ឯង ក្នុងទីកន្លែងណាក៏បាន បើទោះជាមានគ្នាច្រើនក៏មិនជាប់ចិត្ត

ជិតជំពាក់ទៅលើបុគ្គល ឬវត្ថុអ្វីឡើយ ព្រោះចិត្តស្អាតទៅរកព្រះនិព្វាន តែមួយយ៉ាង ដូចកុយរមាសដែលមានតែមួយគត់ដូច្នោះដែរ ។

មួយកន្លែងទៀត ទ្រង់សំដែងថា :

**តំព្រូមិ ឧបសន្តោតិ កាមេសុ អនបេក្ខិនំ**

**គន្ថា តស្ស នវិជ្ជន្តិ អតារិ សោ វិសត្តិកំ ។**

តថាគតហៅអ្នកមិនអាលោះអាល័យ ក្នុងកាមទាំងឡាយនោះថា អ្នកស្ងប់, កិលេសជាគ្រឿងចងស្រែះ ទាំងឡាយមិនមានដល់អ្នកនោះ អ្នកនោះឈ្មោះថា បានឆ្លងវិសត្តិកាតណ្ហាបានហើយ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហៅអ្នក ដែលទូន្មានប្រៀនប្រដៅចិត្តដោយ សីល សមាធិ បញ្ញា មិនមានសេចក្តីអាឡោះអាល័យ គឺថាមិនជាប់ចិត្ត ជិតអារម្មណ៍ក្នុងកាម គឺក្នុងចំណង គឺរូប សំឡេង ក្លិន រស សម្ផស្ស ដែលជារបស់មនុស្សក្តី ជារបស់ទេព្តាក្តី ថាជាអ្នកស្ងប់ ព្រោះចិត្តមិនជាប់ជំពាក់ទាក់ចំពើស ខ្ជួតជិតនឹករលឹកដល់កាមរម្មណ៍ទាំងឡាយ មិនអន្ទះអន្ទែងទៅរកអារម្មណ៍នោះៗ ម្លោះហើយចិត្តក៏មានសេចក្តីស្ងប់ ទើបឈ្មោះថាអ្នកស្ងប់ ។

កិលេសជាគ្រឿងចងស្រែះ វិតរួតទាំងឡាយរសាយរសាត់ មិនមានដល់អ្នកស្ងប់នោះទៀតឡើយ អ្នកនោះឈ្មោះថា បានឆ្លងរបងកំពែងចំរូងវិសត្តិកាតណ្ហា បានជ្រះស្រឡះហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តណ្ហាក្តី ទិដ្ឋិ មានក្តី ជាបបញ្ចធម៌ ធម៌ធ្វើដំណើរ គឺការប្រតិបត្តិ ដើម្បីបន្ទះ មគ្គផលរបស់សត្វអោយយឺតយូរ មានន័យ ដូចបានសំដែងមក ហើយ ។

មានះធម៌នេះ បើដេកត្រាំនៅក្នុងសន្តាននៃសត្វ លោកហើយ រមែងធ្វើចិត្តគំនិត ឬ អធ្យាស្រ័យមិនសមស្របក្នុងការរស់នៅក្នុងសង្គម ដូចជាព្រះឆន្នត្ថេរ សូមនាំនិទាននោះមកសំដែងបញ្ជាក់តទៅនេះ ៖

ក្នុងសម័យពុទ្ធកាលយើងនេះ មានភិក្ខុមួយរូបឈ្មោះ ឆន្នៈ កាល ដើមឡើយឆន្ននេះ ជាអាមាត្យ ដែលពុទ្ធបរិស័ទធ្លាប់ស្គាល់មកហើយ , លោកកើតក្នុងថ្ងៃជាមួយនឹងព្រះសិទ្ធត្ថកុមារ រាប់ថាជាសហជាតវត្ថុ ។ ពេល ក្រោយមកព្រះសិទ្ធត្ថកុមារ មានព្រះជន្ម ២៩ ឆ្នាំ ទ្រង់កើតនិព្វិទាធុញទ្រាន់ ទ្បើយណាយនឹងរាជសម្បត្តិ ក៏ទ្រង់ចេញព្រះផ្នួស, ក្នុងពេញចេញសាង អភិនិស្រ្កមណ៍ កាលនោះមានឆន្នអាមាត្យតោងកន្ទុយសេះ ។

ថ្ងៃក្រោយបានចូលមកបួសក្នុងសាសនា ភិក្ខុអង្គនេះមានអស្មិ មានះយ៉ាងសំបើម ចចេសរឹងរូស មិនព្រមស្តាប់បង្គាប់ ព្រះថេរដែល ចាស់ៗជាង ជាពិសេសមិនព្រមចុះសំរុងនឹងព្រះភិក្ខុសង្ឃផងគ្នា ។

ភិក្ខុអង្គនេះបានពោលអាងថា កាលព្រះសិទ្ធត្ថចេញបួស ឥតឃើញ មានអ្នកណាម្នាក់អើតក្បាលមកទេ, ឥឡូវនេះស្រាប់តែចេញមុខមកថា អញសារីបុត្ត អញមោគ្គល្លាន អញអានន្ទ អញអនុរុទ្ធដូច្នេះជាដើម ។ ក្នុង

ន័យនេះគឺលោកអាងថា ព្រះរាជាព្រះរបស់គាត់ ពោះគាត់ជាអ្នកជូនដំណើរព្រះទៅបួស បានជាឆន្នភិក្ខុនេះមានមានៈប្រកាន់ខ្លាំង មិនព្រមស្តាប់អ្នកណាមួយសោះ ។

មានៈ ជាសំយោជនកិលេសដែលរឹតរួត ចងឆ្វាក់ ឬចងក្រៀកនូវទឹកចិត្តរបស់សត្វលោក, លុះត្រាតែអរហត្ត ទើបកំចាត់បង់បាន បើកំចាត់បង់បានហើយ ទើបឆ្លងចាកវដ្ដសង្សារបាន ផុយទៅវិញ បើកំចាត់បង់មិនទាន់បានទេ ក៏ត្រូវតែជាប់ជំពាក់វាក់វិន អន្ទោលអន្ទោលទៅមកៗ ហែបហែលអង្អែលអង្អែ ក្នុងសមុទ្រជលស័យ ពោលគឺវដ្ដសង្សារ រកទីបំផុតចប់មិនឃើញសោះឡើយ ។

សេចក្ដីនេះសមនឹងពុទ្ធភាសិតទ្រង់សំដែងថា :

**មានុបេតា អយំ បជា មានគន្ថា មានវិនពន្ធា**
**ទិដ្ឋេសុ ព្យារម្ភគតា សំសារំ នាតិវត្តតិ ។**

ប្រែថាពួកសត្វនេះប្រកបដោយមានៈ មានមានៈជាគ្រឿងចងស្រែះត្រូវមានៈចងឆ្វាក់ទុក ផ្តើមធ្វើខុសព្រោះទិដ្ឋិរមែងកន្លងសង្សារទៅមិនបាន ។

មួយកន្លែងទៀតទ្រង់សំដែងថា :

**ឧន្នឡស្ស បមត្តស្ស ពាហិរស្ស ភិក្ខុនោ**
**សីលំ សមាធិ បញ្ញា ចបារិបូរឹ ន គច្ឆតិ ។**

កាលភិក្ខុតម្លើងមានៈ ដូចដើមបបុសប្រមាទហើយ មានសេចក្ដីប្រាថ្នាខាងក្រៅ, សីល, សមាធិ, បញ្ញា រមែងមិនដល់នូវសេចក្ដីបរិបូណ៌ ។

ទោស និងអសង្សនៃមានៈ ធមិ :

ព្រះសម្មាសម្ពុទ្ធមកុដត្រៃលោកទ្រង់សំដែងថា :

**ចិត្តេ បរិសុទ្ធេ សុគតិ បាដិកង្ខា ៗ**

បើចិត្តលះបង់នូវមានៈធមិ ដែលជាផ្នែកអកុសលបានហើយ គឺចិត្តលះបង់នូវមានៈធមិដែលជាផ្នែកអកុសលបានហើយ គឺចិត្តបរិសុទ្ធ រមែងសង្ឃឹមថា នឹងបាននូវសុគតិដោយពិតប្រាកដ ។

**ចិត្តេ សង្កិលិដ្ឋេ ទុគតិ បាដិកង្ខា ៗ** បើចិត្តប្រកបព្រម គឺសម្បយុត្ត ដោយមិច្ឆាទ្រឹស្ដីមានអស្មិមានៈ ជាអកុសលធមិហើយ គឺចិត្តមិនបរិសុទ្ធ តែងបាននូវគតិដោយពិតប្រាកដ ។

សាធុ សប្បុរសទាំងឡាយ ! មានៈនេះជាកិលេសធមិ បើកើតមាននៅក្នុងនរជនណាហើយ អាចដឹកនាំអោយនរជនប្រព្រឹត្តអាក្រក់ដោយកាយចាវាចិត្ត, បើប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តដូច្នោះហើយ ឈ្មោះថាឈានជើងឈមមុខទៅរកហាយនភាព សេចក្ដីវិនាសដោយបពិតប្រាកដ។

ការសំដែងមកក្នុងគាថាទី ៧ នៃបរាភវសូត្រដែលមានសេចក្ដីថា អ្នកដែលប្រកាន់ជាតិទ្រព្យ ត្រកូលហើយមិនប្រមូលសាច់ញាតិសន្ដានមើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធានសេចក្ដីវិនាស ។

ការសំដែងមកនេះក៏សន្មត់ថា

ចប់តែប៉ុណ្ណេះ ឯវំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសូត្រ

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

**សារណំ សារណំ ហន្តុវិហិតា វិហិតា មយា**

**វន្ទនា វន្ទនា មាន ភាជនេ រតនត្តយេ ។**

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណា បានធ្វើប្រកបដោយប្រជុំបីនៃព្រះរតនៈមាន ពុទ្ធរតនជាដើម, កិរិយាថ្វាយបង្គំនោះជាអំពើដ៏វិសេសវិសាល អាចញ៉ាំងសម្បត្តិជាលោកិយ និងលោកុត្តរអោយសំរេចបានសមតាមបំណង សូមញ៉ាំងសេចក្តីក្រវល់ក្រវាយ ដែលកើតមានឡើងអោយវិនាសបាត់បង់ទៅ ។

បទនមស្សការសូមសង្ខេបបែបខ្លីតែប៉ុណ្ណោះ

**ឥតោ បរំ ធម្មទេសនំ អារព្ភិស្សាមិ ។**

លំដាប់បន្ទាប់អំពីបទនមស្សការ ដោយសង្ខេបនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកព្រះគាថាទី៨ នៃបរាភវសូត្រ មកសំដែងចែកជូនដល់អស់លោកសប្បុរសទាំងឡាយ ដែលបានអញ្ជើញមកជួបជុំគ្នាក្នុងទីនេះ ដោយមានបសាទសទ្ធាជ្រះថ្លា ប្រាថ្នាស្តាប់នូវព្រះសទ្ធម្មវិសេសទេសនា ដែលខ្ញុំព្រះករុណាអាត្មាភាពនឹងបានសំដែងដូចតទៅនេះ :

ទេវតាទូលសួរតទៅទៀតថា :

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឥតិហេតំ វិជានាម សត្តមោ សោ បរាភវោ អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះ បើរាប់សង្គ្រោះវិនាសនោះឈ្មោះទី៧ ទាន់ហន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងអោយទាន វិនាសទី៨ អ្វីជាប្រធាននាំសត្វអោយមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមានអោយអន្តរាយ ការល្បែងទាំងឡាយនាំអោយវិនាស ។

**អធិប្បាយ**

**គាថាទី៨**

បទថា **ឥត្ថីធុត្តោ** បានសេចក្តីថា អ្នកលេងស្រី ។ កាមភោគីបុគ្គលអ្នកបរិភោគកាម ល្មោភកាម, ស្រេកឃ្លានកាម, ប្រាថ្នាក្នុងកាម មិនចេះឆ្អែតឆ្អន់ ចំពោះបញ្ចកាមគុណគឺមិនមានសេចក្តីសន្តោស បានហើយចង់បានទៀត មិនចេះគ្រប់គ្រាន់ មិនល្មម មិនឈប់ឈរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បុរសក្នុងលោកមានទ្រព្យសម្បត្តិច្រើន គួរណាស់តែចំណាយទ្រព្យនោះ ដើម្បីប្រយោជន៍ជាតិ ប្រយោជន៍សាសនា មិនគួរយកទ្រព្យសម្បត្តិដែលខំប្រឹងរកបានមកហើយនោះ ទៅប្រព្រឹត្តអបាយមុខ គឺយកទៅបំពេញបំប៉នស្រីពេស្យា ផ្កាមាសចោលទទេៗ ។ អ្នកល្បែងស្រីច្រើនកើតរោគ គឺធ្វើអោយកម្លាំងខ្សោយ ប្រាសចាកការងារ អន្តរាយទ្រព្យសម្បត្តិមានទោសច្រើនប្រការ រហូតដល់មានការឈ្លោះទាស់ទែងខ្វែងយោបល់គ្នា មានការគុំគួនគ្នា ចាក់កាប់សំលាប់សំឡេះ ជីវិតគ្នា នឹងគ្នា ជាទីបំផុត ។

បុគ្គលអ្នកប្រព្រឹត្តញៀនញ៉ាមក្នុងកាម រមែងទៅកាន់ហាយនភាពសមដូចពុទ្ធភាសិតព្រះអង្គទ្រង់សំដែងមានមកក្នុងខុទ្ទនិកាយជាតក សដ្ឋិនិបាតថា :

**កាមេ គិទ្ធា កាមរតា កាមេសុ អធិមុច្ឆិតា**
**នរា បាបានិ កត្វាន ឧបបជ្ជន្តិ ទុគ្គតឹ ។**

ពួកនរជនចូលចិត្តក្នុងកាម គឺមានចិត្តទទឹកជោក ញៀនញ៉ាមក្នុងចំណងទាំងឡាយ មានរូប សំឡេង ក្លិន រស សម្ផស្ស ត្រេកអរីករាយពេញចិត្ត ស្អិតស្រឡាញ់ ចាញ់ឥទ្ធិពលនៃចំណង់ ងុលងប់ទន់ទោរ ធ្លាក់ចុះក្នុងជ្រោះចំណង់ទាំងឡាយ កាលបើជក់ចិត្តស្អិតចង់ញៀនញ៉ាម ងុលងប់ជាប់ជំពាក់ទាក់ទិន នឹងកាមយ៉ាងនេះហើយរមែងធ្វើអំពើបាប ទាបថោកទាំងឡាយដោយកាយវាចាចិត្ត ដ្បិតតាមទាញញាក់អោយប្រព្រឹត្តទៅ

ឈប់គិត បាបបុណ្យ គុណទោស កាលបើយ៉ាងនេះ លោកប្រាប់ថា នរជន នោះរមែងចូលដល់ទុគ្គតិ គឺស្ទុះលិចចុះទៅក្នុងដំណើរអាក្រក់ ទាំងក្នុង បច្ចុប្បន្ន ពោលគឺមានទុក្ខទោស ក្តៅក្រហាយ អន្តរាយក្នុងគ្រួសារ ខូចកេរ្តិ៍ ឈ្មោះ អស់តម្លៃ រកសេចក្តីសុខចំរើនគ្មានគឺធ្លាក់ចុះទៅក្នុងទីទាប ទុក្ខទោស ទាំងក្នុងអនាគតជាតិ គឺទៅកើតក្នុងអបាយភូមិ នរកប្រេត អសុរកាយ តិរច្ឆាន ឬក៏កើតជាមនុស្សប្រកបដោយគុណវិបត្តិ ។

ពុទ្ធដីកាមួយកន្លែងទៀតមានមកក្នុងគម្ពីរ សំយុត្តនិកាយសគាថ វគ្គទ្រទ្រង់សំដែង :

**សារត្តា កាមភោគេសុ គិទ្ធា កាមេសុ មុច្ឆិតា**
**អតិសារំ នពុជ្ឈន្តិ មច្ឆា ខិប្បំវ ឱឌ្ឌិតំ ។**

ពួកសត្វត្រេកអរខ្លាំងក្នុងកាម និងភោគទាំងឡាយ ល្មោភជ្រុល ជ្រប់ងប់ក្នុងកាមទាំងឡាយ រមែងមិនដឹងទោសដែលប្រព្រឹត្តល្មើស ដូចត្រី មិនស្គាល់លបដែលគេដាក់ ។

ពួកសត្វ គឺមនុស្សទាំងឡាយ ត្រេកអរខ្លាំង និងពេញចិត្តស្អិតជាប់ តែក្នុងកាម គឺចំណង់ចង់ចំពោះ បញ្ចកាមគុណជាសំខាន់ មិនមានកាល បំណងប៉ងរំលៀកសំរាលចាកកាមខ្លះសំគាល់ យល់ដាច់ខាតថា មានតែ កាមប៉ុណ្ណោះដែលជាសេចក្តីសុខសប្បាយឯក និងយល់ថាមានតែភោគ ប៉ុណ្ណោះ ដែលសំរាប់អោយសំរេចនូវកាមតាមបំណង, ដោយត្រេកអរខ្លាំង

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្នុងកាម និងភោគទាំងឡាយ លោភជ្រុលពុលជ្រប់ងប់ចិត្ត ជាប់តែក្នុងកាម និងភោគ ដោយសំឡឹងឃើញ បញ្ហាពីរប៉ុណ្ណោះ ជាកំពូលនៃសេចក្ដីសុខ ម្លោះហើយ ក៏រវង្វេងងងឹតគិតតែធ្វើយ៉ាងដូចម្ដេច អោយបានកាម និងភោគ ទោះការប្រព្រឹត្តដើម្បីបាននោះខុសច្បាប់ទុច្ចរិត អយុត្តិយធម៌ បង្កសេចក្ដីទុក្ខទោស ក្ដៅក្រហាយ អោយកើតឡើងចំពោះនរណាក៏ដោយរមែងមិនដឹងទោសដែលប្រព្រឹត្តល្មើស ព្រោះតែលោភកាម និងភោគទាំង-ឡាយឡើយ, លោកប្រៀបដូចត្រីដែលមិនស្គាល់លប ឬមិនស្គាល់នុយដែលគេបិទនៅចុងសន្ទូច រមែងជួបប្រទះសេចក្ដីទុក្ខ ក្ដៅក្រហាយស្ដាយក្រោយពិតប្រាកដ ។

## ទោសរបស់កាម ១០ យ៉ាងគឺ:

**១. អដ្ឋិកង្កលូបមា** ឧបមាដូចជារាងឆ្អឹង

**២. មំស បេសូបមា** ឧបមាដូចជាដុំសាច់ ដែលក្អែក ឬខ្លែងប្រញ្ឆយដណ្ដើមគ្នាស៊ី ។

**៣. តិណុក្កូបមា** ឧបមាដូចជាគប់ភ្លើង ដែលបុគ្គលកាន់ហើយដើរច្រាលខ្យល់ ។

**៤. អង្គារកាសូបមា** ឧបមាដូចជារណ្ដៅដែលពេញដោយរងើកភ្លើង ។

**៥. សុបិនកូបមា** ឧបមាដូចជាយល់សប្តិ ។

**៦. យាចិតកូបមា** ឧបមាដូចជារបស់ខ្ចីគេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**៧-រុក្ខផលូបមា** ឧបមាដូចឈើមានផ្លែ ។

**៨-សត្តិសូលូបមា** ឧបមាដូចលំពែងមានមុខដ៏ស្រួច ។

**៩-អសិសូនូបមា** ឧបមាដូចជ្រញ់ចិញ្ច្រាំសាច់ ។

**១០-សប្បសិរូបមា** ឧបមាដូចក្បាលពស់វែក ។

ទោសរបស់កាមទាំងដប់ប្រការនេះ មានសេចក្តីអធិប្បាយដូចតទៅនេះ :

**១-អដ្ឋិកង្ខលូបមា** ឧបមាដូចជារាងឆ្អឹង សេចក្តីថាកាមគុណដូចរាងឆ្អឹងដែលសរសៃប្រទាក់ឆ្វាក់ទងនូវឆ្អឹង ៣០០ កំណាត់អោយបានគ្រាន់តែជារាង ឬ ពុំនោះទេ ដូចជារាងឆ្អឹងដែលគេចោលរាត់រាយ, អ្នកបរិភោគកាមដូចឆ្កែដែលអង្កៀមឆ្អឹងនោះ ឥតមានរសជាតិអ្វីអំពីឆ្អឹងទេ លេបតែទឹកមាត់របស់ខ្លួនឯង ដែលប្រឹងអង្កៀមទំពៀរឆ្អឹងនោះយ៉ាងណា អ្នកបរិភោគកាម ក៏ឥតបានប្រយោជន៍អ្វីអំពីកាមក៏យ៉ាងនោះដែរ ។

**២-មំសបេសូបមា** ឧបមាដូចជាសាច់តាមគុណនោះគឺ គ្រាន់តែជាដុំសាច់ដែលពាល ឬលាបលនក្រឡៃ ដោយស្បែកអំពីខាងក្រៅ អោយល្មមសំដល់មំសចក្ខុ នៃបុថុជ្ជនគួរដណ្តើម ប្រជែងគ្នា, ក្អែក ឬ ខ្លែងដែលប្រជែងគ្នាឆាបយកនូវសាច់ដុំ ដែលប្រដាក់លាបលនដោយសាច់ឈាមមានពណ៌ក្រហម ដោយសេចក្តីសំគាល់ថា ជាទីស្រឡាញ់យ៉ាងណា, អ្នកបរិភោគកាម ក៏សំគាល់នូវកាមគុណ ថាជារបស់ឆ្ងាញ់ពិសា ហើយដណ្តើម

Websites: WatKhemaraRatanaram.org or WatKhmers.org

ឈ្មោះប្រកែកជជែកជវាបដល់កាប់សំលាប់គ្នា ព្រោះហេតុនេះក៏មាន យ៉ាងនេះដែរ ។

**៣_តិណុក្កូបមា** ឧបមាដូចជាអ្នកកាន់គប់ភ្លើង ហើយរត់ច្រាស់ខ្យល់ បុគ្គលអ្នកកាន់នូវគប់ភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅ ហើយរត់ច្រាស់ខ្យល់ ខ្យល់បង់ផាត់អណ្តាតភ្លើខ្លះ រងើកភ្លើងខ្លះ មកទង្គិចប៉ះដល់ខ្លួន រលាក ពុះពងក្តៅ ក្រហាយអន្ទះអន្ទែងដោយសារភ្លើង ដែលកាន់ខ្លួនឯងហើយ រត់ច្រាស់ខ្យល់យ៉ាងណា ? អ្នកបរិភោគកាមក៏មានសេចក្តីក្តៅក្រហាយ អន្ទះអន្ទែងដោយភ្លើងកាមដុតអោយអន្ទះសាររសាប់រសល់ ក៏យ៉ាង នោះដែរ ។

**៤_អង្គារកាសូបមា** ឧបមាដូចជារណ្តៅដែលពេញដោយរងើកភ្លើង, សេចក្តីដែលថារណ្តៅដែលគេជីកហើយ គេដាក់អោយពេញដោយរងើក ភ្លើង ដែលឆេះរន្ទាលច្រាលឆ្អៅក្តៅគួរជាទីឆេះរលាករលួយដល់អ្នកដែល ធ្លាប់ចុះក្នុងរណ្តៅនោះនោះយ៉ាងណា ? កាមគុណជារបស់ក្តៅដល់បុគ្គល អ្នកដែលចូលទៅគ្រប់គ្រងអស់កាលជានិច្ច ដោយទុក្ខទោសទោមនស្ស សេចក្តីក្រវល់ក្រវាយ និងសេចក្តីព្រាត់ប្រាស់ គ្មានពេលទំនេរ ដោយ សេចក្តីក្តៅក្រហាយ យ៉ាងនោះដែរ ។

**៥_សុបិនកូបមា** ឧបមាដូចជាយល់សប្តិ, សេចក្តីថា មនុស្សដែលយល់ សប្តិថា បានរតនវត្ថុណាមួយ មានមាសពេជ្រ ឬគ្រឿងប្រើប្រាស់ណាមួយ

ជាដើម ក៏ដោយ លុះភ្ញាក់ឡើងក៏របស់ដែលឃើញបាននោះ បាត់សូន្យអស់ទៅវិញ មិនបានជាប់មកនៅនឹងដៃយ៉ាងណា ? ចំណែកអ្នកបរិភោគកាមក៏ឥតបានអ្វី ជាប់មកដោយសារកាម ក៏យ៉ាងនោះដែរ ។

**៦.យាចិតកូបមា** ឧបមាដូចជារបស់ខ្ចីគេ, សេចក្ដីថា ធម្មតារបស់គេគ្រាន់តែបានប្រើការមួយពេលមួយខណៈប៉ុណ្ណោះ បើម្ចាស់គេត្រូវការបេលណា គេត្រូវតែយករបស់គេទៅវិញ ខកខានបានប្រើប្រាស់តទៅទៀតយ៉ាងណា? អ្នកបរិភោគកាម តែងបានប្រើប្រាស់គ្រឿងកាម នោះតែមួយពេលមួយខណៈ ហើយក៏វិនាសខូចខាត ខានបានប្រើប្រាស់យ៉ាងនោះដែរ ។

**៧.រុក្ខផលូបមា** ឧបមាដូចជាឈើមានផ្លែ, សេចក្ដីថាឈើណាដែលមានផ្លែតែងជាទីត្រូវការសាធារណ៍ដល់សត្វបក្សាបក្សី និងមនុស្សឡើងទំជាន់ប្រឡេះបេះផ្លែ រមែងបាក់ជ្រុះមែកតូច និងមែកធំ ឬកាប់រំលំទាំងដើមទៀតក៏មាន បានដល់នូវសេចក្ដីវិលរេច វិនាសព្រោះតែផ្លែរបស់ខ្លួនយ៉ាងណា ? អ្នកបរិភោគកាមតែងរិចរិលព្រាត់ប្រាសវិនាសចាកកុសល ធមិនិងទទួលរ៉ាប់រងនូវទុក្ខទោសគ្រោះថ្នាក់ច្រើនបែប ច្រើនយ៉ាងដែលកើតឡើងដោយសារការបរិភោគកាម ក៏យ៉ាងនោះដែរ ។

**៨.សត្តិសូលូបមា** ឧបមាដូចជាលំពែង មានមុខដ៏ស្រួច សេចក្ដីថាលំពែងដែលមានមុខដ៏ស្រួល, មុខគួរព្រឺស្ញើបរអាខ្លាច នឹងការមុតរបស់មុខលំពែង កាំបិតនោះ ឬលំពែងកាំបិតមានមុខដ៏ស្រួចមុត នឹងជាគួសត្រូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់អ្នកដែលកាន់យកមកប្រមៀលឱបផ្ទឹម នឹងខ្លួន ឬមុខស្រួច ស ដែលគេលាបលនដោយទឹកឃ្មុំ បុគ្គលសំគាល់ថាទឹកឃ្មុំ ក៏លិទ្ធជញ្ជក់ដោយអណ្តាត មុតដាច់រហែកដោយសារសំគាល់ខុស ឬប្រាថ្នាខុសត្រង់ទឹកឃ្មុំផ្អែម តែម្យ៉ាងប៉ុណ្ណោះ ត្រង់មុខលំពែង កាំបិត ឬ សរព្រួញ ដែលជារបស់ជាតួនៃទោសទុក្ខ មិនដឹងសោះយ៉ាងណា ? អ្នកបរិភោគកាមបាននូវសេចក្តីខ្លោចផ្សារចុកចាប់ដោយសារតែការបរិភោគកាម ក៏យ៉ាងនោះដែរ ។

**៩.អសិសូនូបមា** ឧបមាដូចជាជ្រុញចិញ្ច្រាំសាច់ សេចក្តីថាជ្រុញចិញ្ច្រាំសាច់តែងរេចរបេះមុត រសាំដោយមុខកាំបិតដែលគេកាប់ចុះទៅ ឬប្រឡាក់ដោយឈាមខ្លាញ់គួរជាទីខ្ពើមរអើមយ៉ាងណា ? កាមគុណក៏ជារបស់ពេញពោរហូរហៀរទៅដោយមូត្រលាមកខ្ទុះ ឈាម ខ្លាញ់ រំអិលគួរខ្ពើមរអើមយ៉ាងនោះ ។

**១០.សប្បសិរូបមា** ឧបមាដូចជាពស់មានពិស, សេចក្តីថាធម្មតាក្បាលពស់មានពិស ជាសត្វជាតិពេញទៅដោយកំដៅពិស បើបុគ្គលណាមួយកាន់ចាប់យកនូវក្បាលពស់នោះ ហើយមុតដោយធ្មេញពស់នោះក្តីពុំទាន់មុតក្តី បុគ្គលនោះឈ្មោះថាឱបក្រសោបនូវក្បាលពស់មានពិសគង់ដល់នូវសេចក្តីចុកចាប់ ដោយកំដៅពិសពស់នោះយ៉ាងណា ? អ្នកបរិភោគកាមក៏ដូចជាបុគ្គល យកក្បាលពស់មានពិសមកប្រមៀលឱបក្រសោបអោយជិតដល់ខ្លួនយ៉ាងនោះដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# រឿង ពាណិជ្ជបុរស

ទោសនៃការជាប់ជំពាក់ក្នុងកាមគុណ កាលពីអតីតក្នុងតម្ពបណ្ណិទ្វីប (ទ្វីបរបស់ជនអ្នកមានបាតដៃក្រហមនៅអាស្រ័យ) មាននរគយក្សមួយឈ្មោះសិរីសវត្ថុ ។ យក្ខិនីទាំងឡាយក្នុងនគរនោះតែងអោយនូវវត្ថុមានបបរ និងបាយជាដើម ដល់ពួកពាណិជ្ជដែលមានសំពៅបែកហើយមកក្នុងទីនោះទើបសួរថា អ្នកទាំងឡាយមកក្នុងទីនេះ តើដោយកម្មដូចម្តេច? សំពៅយើងបែកកណ្តាលសមុទ្រ ទើបមកក្នុងទីនេះ ។ យក្ខិនីទាំង-ឡាយនោះពោលថា " ប្រពៃហើយអ្នកទាំងឡាយ ស្វាមីនៃយើងខ្ញុំទាំង-ឡាយ ទៅជួញអស់រយៈកាល៣ឆ្នាំ មិនឃើញមកសោះ ប្រហែលជាស្លាប់បាត់បង់ហើយមើលទៅ, អ្នកទាំងឡាយសុទ្ធតែនាយពាណិជ្ជ, យើងទាំង-ឡាយនឹងបានគ្នាជាគូកំសត់ទៅ, ហើយប្រលោមយកពាណិជទាំងឡាយនោះ ដោយអាការផ្សេងៗទើបនាំទៅនគរយក្ស ។ ប្រសិនបើមនុស្សទាំង-ឡាយវាចាប់បានមុនៗវាចងដោយចំណង ហើយរុញបញ្ចូលទៅក្នុងផ្ទះសំរាប់ធ្វើការ និងយកមនុស្សដែលវាចាប់បានក្រោយធ្វើជាស្វាមីទៀត , បើចាប់មនុស្សទាំងឡាយមិនបានក្នុងសំពៅៗ ត្រាច់ទៅក្នុងឆ្នេរសមុទ្រគឺនាងនាយនគរឈ្មោះកល្យាណី ខាងអាយទ្វីបរបស់នាគ ។ សេចក្តីដែលបាននិយាយបរិយាយមកក្នុងខាងលើទាំងប៉ុន្មាននេះជាធម្មតា ឬជាប្រពៃ-ណីរបស់យក្ខិនីទាំងឡាយនោះ ។

ថ្ងៃមួយមានពាណិជ្ជ ៥០០ នាក់ បែកសំពៅត្រង់ទីជិតនគរយក្ខិនីទាំងឡាយនោះ ។ យក្ខិនីទាំងឡាយនោះ ក៏ប្រឡោមល្បួងលួងលោមនាយពាណិជទាំងឡាយនោះ តាមរបៀបរបបអន្លលលម្បួងហើយនាំមកនគរខ្លួន ទើបចងមនុស្សដែលចាប់បានមុនៗនោះ រុញបញ្ចូលទៅក្នុងផ្ទះសំរាប់ធ្វើការ ។ យក្ខិនី ច្បងយកនាយពាណិជ្ជជាលំដាប់ៗធ្វើប្តីដែរ លុះនាយពាណិជ្ជទាំងឡាយនោះ ចុះស៊ប់កាន់និទ្រានារាត្រីកាលវាក៏ក្រោកសន្សឹមៗទៅស៊ីមនុស្សក្នុងផ្ទះសំរាប់ធ្វើការ ហើយត្រឡប់មកវិញ ។

ពាណិជ្ជច្បងៗចាំឃ្លាំមើល បានដឹងថាប្រពន្ធខ្លួនជាយក្ខិនី ទើបប្រាប់សេចក្តីនោះដល់ពាណិជ្ជទាំងអស់ ហើយបបួលថាមកយើងទៅ ។

បណ្តាលពាណិជ្ជទាំង៥០០នោះ ពាណិជ្ជ២៥០នាក់ពោលតបថាទេ ! យើងមិនអាចរត់ចោលស្ត្រីទាំងនោះ ដែលសម្ផស្សទន់ភ្លន់ត្រជាក់ដល់ចិត្តយើងបានឡើយ ណ្ហើយអញ្ជើញទៅចុះ យើងមិនបានទៅទេ ។ ពាណិជ្ជចម្បងក៏នាំពាណិជ្ជ ២៥០ នាក់ដែលធ្វើតាមពាក្យរបស់ខ្លួនរត់ទៅ ។ អើគ្រានោះព្រះពោធិសត្វ របស់យើងទ្រង់សោយព្រះជាតិជាស្តេចសេះវលាហកៈ មានសព៌ាង្គកាយសត្រសុសមានឫទ្ធិអស្ចារ្យ អាចហោះហើរដើរដោយអាកាសវេហាស៍ បានតាមចិត្តចង់ ហោះមកពីព្រៃហេមពាន្ត មកកាន់តម្ពបណ្ណិទ្វីប ទំពារស៊ីស្រូវសាលីដែលដុះឯងកើតឡើង ហើយហោះត្រឡប់ទៅវិញ បានឃើញពាណិជ្ជទាំងនោះ ក៏ស្រែកសួរដោយសេចក្តី

ករុណាអស់វារៈបីដងថា មានអ្នកណាចង់ទៅកាន់ជនបទដែរឬទេ ? ពាណិជ្ជទាំងនោះ ឮនូវសំរែកស្តេចសេះ ក៏ផ្គងអញ្ជលីពោលថា យើងទាំង-ឡាយនឹងទៅ ។ ស្តេចសេះក៏បន្ទាប់ខ្នងហើយពោលថាបើដូច្នោះ ចូរឡើងលើខ្នងខ្ញុំមក ។

លំដាប់នោះមួយពួកឡើងជិះលើខ្នង មួយពួកទៀតកាន់កន្ទុយ ពួកទៀតឈរផ្គងអញ្ជលី ដោយហោចទៅស្តេចសេះអាចនាំនូវពាណិជ្ជដែលឈរផ្គងអញ្ជលី ដោយអានុភាពរបស់ខ្លួនទៅ កាន់លំនៅរៀង១ខ្លួនបាន ទើបហោះត្រឡប់ទៅឋានខ្លួនវិញ ។ ឯពាណិជ្ជ ២៥០ នាក់ ដែលជាប់ចិត្តស្រឡាញ់ក្នុងរូប សំឡេង ក្លិន រស់ សម្ផស្ស ដ៏ទន់ភ្លន់ត្រជាក់របស់យក្ខិនីទាំងឡាយនោះក៏បានជាចំណីរបស់យក្ខិនីទាំងនោះទៅ ។

បុរសណាដែលឈ្លក់ជ្រមុជងប់ងល់ក្នុងកាមទាំងឡាយ ប្រកបដោយបមាទធម៌ បុរសនោះរមែងជួបប្រទះនូវសេចក្តីទុក្ខវេទនា អស់កាលដ៏យូរអង្វែង សមដូចព្រះពុទ្ធត្រាស់សំដែងថា :

**កាមាកដុកា អសីវិសូបមា យេសុ មុច្ឆិតា ពាលា**

**តេ ចិរំ រត្តំ សមប្បិតា ហញ្ញន្តេ ទុក្ខិតា ។**

ជនពាលជ្រប់ចិត្តក្នុងកាមទាំងឡាយ កាមទាំងនោះក្តៅផ្សារដូចអាសិរពិស លុះជនពាលទាំងនោះឆ្អែតស្កប់ស្កល់ហើយ ត្រូវគេបៀតបៀនក្នុងនរកអស់កាលដ៏យូរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុទ្ធបរិស័ទទាំងឡាយ ! ល្បែងស្រីនោះមិនមែនទ្រង់សំដែងចំពោះតែបុរសទេ សូម្បីស្ត្រីមានស្វាមីហើយ ប្រព្រឹត្តក្បត់ក៏ត្រូវមានទោសដែរ ។

កាមមានសេចក្តីទុក្ខច្រើនប្រការណាស់ ទុក្ខដទៃស្មើនឹងកាមនេះពុំមាន សមដូចព្រះពុទ្ធដីកាក្នុងគម្ពីរខុទ្ទកនិកាយជាតកឯកាទសកនិបាតទ្រង់សំដែងថា :

**អប្បស្សាទា ទុក្ខា កាមា នត្ថិ កាមា បរំ ទុក្ខំ**

**យេ កាមេ បដិសេវន្តិ និរយន្តេ ឧបបជ្ជរេ ។**

កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន ទុក្ខដទៃក្រៅអំពីកាមមិនមានអ្នកណាសេពកាម អ្នកនោះរមែងចូលដល់នរក ។

ព្រះពុទ្ធដីកាមួយកន្លែងទៀត មានន័យប្រហាក់ប្រហែលគ្នា នឹងព្រះពុទ្ធដីកាខាងលើ :

**អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ អបិ ទិព្វេ កាមេសុ រតឹសោ នាធិគច្ឆតិ ។**

កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន បណ្ឌិតដឹងដូច្នោះហើយ ទោះបីក្នុងកាមដ៏ជាទិព្វ ក៏លោកមិនទទួលត្រេកអរដែរ ។

ឯសេចក្តីប្រាថ្នា ដែលទេវតា ទូលសួរព្រះអង្គ ហើយព្រះអង្គដោះស្រាយប្រស្នានោះថា : សេចក្តីប្រាថ្នារមែងភើច កន្ទ្រាក់នរជននោះយកទៅ សេចក្តីប្រាថ្នានោះរមែងកម្របុគ្គលលះបានក្នុងលោក, សត្វមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

កិលេសក្រាស់ រមែងជាប់ជំពាក់នៅក្នុងសេចក្ដីប្រាថ្នា, សេចក្ដីប្រាថ្នានោះ ហើយតែងដឹងនាំនរជន ទៅកាន់ភពតូច ភពធំ ម្ដងភើចកន្ទ្រាក់ ទៅកាន់ទីទាប ម្ដងភើចកន្ទ្រាក់ទៅកាន់ទីខ្ពស់ រាប់ជាជាតិកំណើតមិនបាន ព្រោះតែសេចក្ដីប្រាថ្នា ។

ព្រោះហេតុនោះ បានជាព្រះអរហំបរមគ្រូទ្រង់ត្រាស់ទេសនា ថា សេចក្ដីប្រាថ្នារមែងភើចកន្ទ្រាក់នរជនយកទៅ តាមចំណង់ខ្លួនមិនកំណត់ពេលកាលណាទេ បានជាសត្វលោកកម្រលះបង់បាន ព្រោះសេចក្ដីប្រាថ្នានេះ ជាកិលេសជាតិមួយស្ថិតនៅក្នុងសន្ដានសត្វលោក ជាអជ្ឈត្តិកសមុដ្ឋានមានដែលកើតខាងក្នុង សំរាប់ឆ្លួត ឬ ដឹងនាំមុខសត្វ លោកអោយប្រាថ្នាត្រេកត្រអាល គ្រប់ទិវារាត្រីកាល "យប់ហុយដូចជាផ្សែង ថ្ងៃឡើងឆេះជាភ្លើង " មិនថាអាការរបស់សត្វនោះតាំងនៅក្នុងវ័យណាទេ, ចេះតែត្រូវការប្រាថ្នាទាំងអស់ លើកលែងតែព្រះអរិយបុគ្គលទាំងឡាយមាន ព្រះ-អរហំសម្មទ្ធជាដើមទេ ដែលមិនជាប់ជំពាក់ក្នុងអន្ទាក់ គឺសេចក្ដីប្រាថ្នាក្រៅពីនោះសុទ្ធតែចំណងកាម ចងភ្ជាប់ដូចជាសកុណជាតិ ជាប់អន្ទាក់ មិនងាយនឹងរើខ្លួនអោយរួចដូច្នោះ ប្រសិនបើរូបសត្វនោះមិនប្រាថ្នា នឹងរើអោយរួចផង ក៏ចំណងនោះរឹងរឹតតែត្រួតច្រើនឡើង១ជាភិយ្យោភាព ។

ម្យ៉ាងទៀត សេចក្ដីប្រាថ្នានេះ បើមានច្រើនលើនរជនណាហើយ នរជននោះមានឈ្មោះថា ប្រាថ្នាហួសមាន ប្រាថ្នាច្រើនបានឈ្មោះថា ស្ថិត

Websites: WatKhemaraRatanaram.org or WatKhmers.org

នៅក្នុងអតិច្ឆតា ឬ មហិច្ឆតា តែងបានផលអាក្រក់គឺ សេចក្តីក្តៅក្រហាយ ស្តាយក្រោយ ព្រោះបុគ្គលនោះឯង មានសេចក្តីប្រាថ្នាមិនចេះស្កប់ស្កល់ ក្នុងចិត្ត ការប្រាថ្នាមិនចេះស្កប់ស្កល់នេះ ទុកជាបានវត្ថុណាប្រណិតបញ្ចុក ដែលខ្លួនបានដោយធម៌ល្អ ក៏មិនពេញចិត្ត បែរទៅជាចង់បានរបស់ដែល លាមអាក្រក់ ដែលបុគ្គលដទៃបានវិញ បើបានបែបនោះឈ្មោះថា បានមិន ប្រកបដោយធម៌ គង់ស្តាយក្រោយយ៉ាងដាច់ខាត, សមដូចព្រះរាជបុត្រ ព្រះបាទពារាណសី ដែលព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងក្នុង អសិតាភូជាតក នវមវគ្គ ទុកនិបាត ដែលដកស្រង់មដោយខ្លីៗថា : ក្នុងកាលកន្លងហើយ ព្រះរាជបុត្រព្រះបាទពារាណសី ត្រូវព្រះរាជបិតា បំបរបង់ចាក ព្រះរាជ ទិវេសន៍ ហើយបាននាំព្រះរាជទេពីរបស់ទ្រង់ព្រះនាម អសិតាភូ ចូលទៅ ក្នុងព្រៃហេមពាន្ត សោយត្រីសាច់ និងផ្លែឈើទាំងឡាយ ។

ព្រះទេពីនោះគិតថា ព្រះរាជបុត្រមិនអើពើ និងអញស៊ូរទៅតាម នាងកិន្នរីវិញ ហើយចូលទៅរកតាបសម្នាក់ សុំរៀននូវការចំរើន កសិណ ញ៉ាំងឈាននិងភិញ្ញាអោយកើតឡើង ទើបមកនៅក្នុងបណ្ណសាលារបស់ ខ្លួនវិញ ។ ព្រះរាជបុត្រនោះទៅតាមនាងកន្នរីរកផ្លូវដែលនាងកិន្នរីនោះ ទៅមិនឃើញ ក៏អស់សង្ឃឹមហើយត្រឡប់វិញ ។ ព្រះទេពីឃើញព្រះរាជ បុត្រនោះមកដូច្នោះ ក៏ហោះទៅលើអាកាសទៅ នៅក្នុងទីដទៃទៀត

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះរាជបុត្រនោះ លុះព្រះទេពីទៅបាត់ដូច្នោះ ក៏ខ្សឹកខ្សួលទួញយំ សង្រែងសង្រែងគួរអោយអាណោចអធមណាស់ហើយពោលគាថា :

**អត្រិច្ឆំ អតិលោភេន អតិលោភមទេន ច**

**ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ។**

ប្រែថា បុគ្គលកាលប្រាថ្នាហួសពេក ព្រោះចង់បានពេកផង ព្រោះការស្រវឹងដោយចង់បាន ពេកផងរមែងសាបសូន្យចាកប្រយោជន៍ យ៉ាងណា ខ្ញុំកាលប្រាថ្នាហួសពេកទៅ ជាអ្នកសាបសូន្យចាកព្រះទេពីឈ្មោះអសិតាភូយ៉ាងនេះដែរ ។

ព្រះរាជបុត្រនោះ តាំងពីថ្ងៃនោះមក នៅក្នុងព្រៃតែម្នាក់ឯង លុះអំណើះអំពីព្រះវរបិតាទៅ បានវិលមកសោយរាជ្យជាស្តេច ។ គ្រានោះមានទេវតាមួយអង្គអាស្រ័យនៅលើដើមឈើមួយដើម បានពោលថានេះក្នុងអដ្ឋកថាវិភង្គថា :

**អត្រិច្ឆំ អតិលោភេន អតិលោភមទេន ច ឯវំ**

**សោ ហាយ តត្ថានំ ចន្ទំវ អសិតាភូយា ។**

ប្រែថា បុគ្គលកាលប្រាថ្នាហួសពេក ព្រោះចង់បានពេកផង ព្រោះការស្រវឹងដោយចង់បានពេកផង បុគ្គលនោះរមែងញ៉ាំងប្រយោជន៍របស់ខ្លួនអោយសាបសូន្យយ៉ាងនេះដូចជាព្រះរាជបុត្រកាលប្រាថ្នា នូវនាងកិន្នរីឈ្មោះចន្ទាហើយជាអ្នកសាបសូន្យចាកព្រះទេពីឈ្មោះអសិតាភូ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រោះហេតុហ្នឹងហើយ បានជាព្រះបរមគ្រូទ្រង់ដោះបញ្ហាកម្មនឹងទេវតាថា : សេចក្តីប្រាថ្នារមែងភើចកន្ទ្រាក់នរជនយកទៅហើយ កម្របុគ្គលលះបង់បានក្នុងលោក សត្វមានកិលេសក្រាស់រមែងជាប់នៅក្នុងកាម គឺសេចក្តីប្រាថ្នាដូចជាមេបក្សីជាប់អន្ទាក់ដូច្នោះឯង ។

**នេក្ខម្មានិសំស** អានិសង្សចេញចាកនេក្ខម្មប្រែថា ការចេញចាកកាមពេលគឺការមិនបរិភោគកាម ជាការចេញចាកដ៏ប្រសើរខ្ពង់ខ្ពស់បំផុត, ព្រោះថាការចេញចាកកាមនេះឈ្មោះថា ជាអ្នករួចខ្លួនអំពីទោសកំហុសទាំង ១០ យ៉ាងដែលជាសត្រូវ ឬថ្នាំពិសជាភ្លើង តែងដុតរោលកំ-ដៅអោយសត្វបានសេចក្តីក្តៅក្រហាយ អន្ទះអន្ទែងសញ្ជប់សញ្ជឹង ឥតស្រាកស្រាន្តគ្មានអស់ហើយ រកកោះត្រើយមិនឃើញ លិចលង់រងទុក្ខក្នុងវដ្តសង្សារ ហើយដើម្បីនឹងបំប្រួញ ឬជាឧបាយនឹងផ្តាច់ផ្តល់នូវសេចក្តីទុក្ខនោះៗបានហៅថា "នេក្ខម្ម" ។

បទថា **សុរាធុត្តោ** អ្នកលេងស្រា, បានសេចក្តីថា អ្នកសេពសុរា ឬផឹកសុរា ។

ពាក្យថា **សុរា** មានន័យថា ទឹកស្រវឹង គឺគេផ្សំដោយវត្ថុធាតុផ្សេងៗ មានម្សៅ ឬសឈើ មើមឈើ ផ្លែឈើ ផ្កាឈើ ជាដើម ។ សុរាជាទឹកស្រវឹង បើផឹកចូលទៅក្នុងពោះកាលណា តែងស្រវឹងឥតដឹងខុសត្រូវនិយាយដដែលៗខ្វះនូវសីលធម៌ សុជីវធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បុរសស្ត្រីក្នុងលោក កាលបើស្វែងរកភោគទ្រព្យបានមកហើយ ដោយផ្លូវល្អ គប្បីបំពេញបុណ្យកុសល មានទានសីលជាដើម ឬ ក៏ចំណាយដើម្បីប្រយោជន៍ដល់ជាតិ និង សាសនា កុំចាយវាយក្នុងផ្លូវអបាយមុខផ្សេងៗ ។

សុរាមានឈ្មោះ ៥ យ៉ាង

**១-បិដ្ឋសុរា** សុរាដែលគេដាក់ម្សៅក្នុងភាជនអោយទឹកល្វះដល់ម្សៅនោះហើយធ្វើ ។

**២-បូវសុរា** សុរាដែលគេដាក់នំក្នុងភាជនះលាយទឹកអោយល្វមដល់នំនោះហើយធ្វើ ។

**៣-ឱទនសុរា** សុរាដែលគេធ្វើដោយបាយ ។

**៤-កិណ្ណបក្ខិត្តា** សុរាដែលគេដាក់មេហើយធ្វើ ។

**៥-សម្ភារសំយុត្តា** សុរាដែលគេផ្សំផ្សំដោយគ្រឿងផ្សំផ្សេងៗ មានផ្លែស្រម៉រ និងគ្រាប់ស្លៃជាដើម ។ អាសវ ឬ មេរ័យទឹកញ៉ាំងសេចក្តីស្រវឹងអោយកើត, អាសវៈទឹកជាហេតុហូរមកនូវអកុសលធម៌គឺមានះ មានបុរិសមានះ ជាដើមរាប់តាមឈ្មោះមាន ៥ យ៉ាងគឺ :

**១-បុប្ផាសវោ** អាសវៈ ដែលគេធ្វើដោយរស នៃផ្កាមានផ្កាម៉ាក់ប្រាងជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**២‿ផលសវោ** អាសវៈ ដែលគេច្របាច់នូវផ្លែមាន ផ្លែចន្ទន៍ ផ្លែទំពាំងបាយជូរជាដើម ហើយធ្វើដោយរសនៃផ្លែទាំងនោះ ។

**៣‿មធ្វាសវោ** ឬ **មធាសវោ** អាសវ ដែលគេធ្វើដោយជាតិផ្លែចន្ទន៍ ( អាចារ្យខ្លះថាធ្វើដោយទឹកឃ្មុំ) ។

**៤‿គុឡាសវោ** អាសវៈដែលគេធ្វើដោយទឹកអំពៅ ។

**៥‿សម្ភារសំយុត្តោ** អាសវៈដែលគេធ្វើដោយគ្រឿងផ្សំផ្សេងៗ មានផ្លែស្រម៉រ កន្ទួតព្រៃ និងគ្រឿងហើរជាដើម ហើយធ្វើដោយរសទឹកនោះៗ ។

**មជ្ជបានៈ** ការផឹកទឹកស្រវឹងមានទោស ៦ យ៉ាងគឺៈ

១-នាំអោយខូចខាតទ្រព្យសម្បត្តិ

២-នាំអោយបង្កបង្កើតសេចក្តីឈ្លោះទាស់ទែងគ្នា

៣-ជាអណ្តូងកើតនូវរោគ

៤-ញុំាងសេចក្តីនិន្ទាអោយកើត

៥-ញុំាងកេរ្តិ៍ខ្មាស់អោយប្រាកដមិនអៀនអន់

៦-ធ្វើបញ្ញាអោយទន់ខ្សោយ

**អបាយមុខ** ហេតុដែលធ្វើអោយវិនាសមាន ៦ យ៉ាងគឺៈ

**១‿មជ្ជបាន** ផឹកទឹកស្រវឹង

**២‿វិកាលចរណៈ** ដើរលេងយប់

Websites: WatKhemaraRatanaram.org or WatKhmers.org

**៣-សមជ្ជាភិចរណៈ** ដើរលេងល្បែងមហោស្រព

**៤-ជូតានុយោគ** លេងល្បែងភ្នាល់គ្នា ឬល្បែងស៊ីសង

**៥-បាបមិត្តានុយោគ** សេពគប់មនុស្សអាក្រក់ជាមិត្រ

**៦-អាលស្សានុយោគ** ខ្ជិលធ្វើការងារ ។

បុរសស្ត្រីណាប្រព្រឹត្តសេពសុរា ឬវារុណឃើញថាមានទោសច្រើនប្រការណាស់ ពីព្រោះធ្វើអោយគ្រួសារនីមួយៗ អន្តរាយសម្បត្តិអាចធ្វើអោយមានរោគ ខូចស្មារតី បញ្ញាទន់ខ្សោយ ធ្វើអោយគ្រួសារទន់-ខ្សោយ ធ្វើសង្គមអោយទន់ខ្សោយ ធ្វើអោយកេរ្តិ៍ឈ្មោះ ខូចកិត្តិយសកិត្តស័ព្ទកិត្តិនាំ កិត្តិគុណ ធ្លាក់បុណ្យ ធ្លាក់ស័ក្តិ បង្កបង្កើត អោយមានការឈ្លោះទាស់ទែងខ្វែងគំនិតដល់គ្នា និងគ្នា អោយបែកសាមគ្គី រវាងគ្នានឹងគ្នា លះបង់ការងារប្រកបដោយសេចក្តីប្រមាទ ធ្វើអោយឈមមុខទៅរកហាយនភាព ឬធ្វើអោយទន់ខ្សោយដល់ប្រទេសជាតិ ក៏សឹងមាន ដូចរឿងថ្មើរព្រៃឈ្មោះសុរៈសូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

## **ការកើតឡើងនៃសុរាក្នុងលោក**

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះមានថ្មើរព្រៃម្នាក់ឈ្មោះសុរៈ នៅក្នុងដែនកាសិករដ្ឋ ។ គាត់បានទៅព្រៃហេមពាន្ត ដើម្បីប្រកបកិច្ចការផ្សេងៗ ។ នៅព្រៃហេមពាន្តនោះ មានឈើមួយដើមកំពស់ មួយជំហរបែកមែកជាបី

ក្នុងប្រទ្បោះប្រគាបនោះមានរណ្ដៅធំប៉ុនពាង, លុះដល់ភ្លៀងធ្លាក់មកទឹកដក់ នៅក្នុងរណ្ដៅនោះហើយមានដើមស្រម៉រកន្ទួតព្រៃ និងម្រេច ជាដើមដុះក្បែរ ដើមឈើនោះតែងជ្រុះផ្លែទៅក្នុងរណ្ដៅនោះ មិនតែប៉ុណ្ណោះសត្វបក្សីទាំងឡាយតែងពាំស្រូវសាលី ទៅទំពារស៊ីហើយជ្រុះទៅក្នុងរណ្ដៅនោះទៀត ។

ទឹកក្នុងរណ្ដៅនោះក៏មានពណ៌ក្រហម មានរស់ជាតិខ្លាំង ។ ដល់រដូវក្ដៅសត្វបក្សីទាំងឡាយមានសេចក្ដីស្រេកឃ្លានបានផឹកទឹកនោះ ក៏ស្រវឹងបំរះនទៀលដួលជ្រប់ នៅទ្បេបគល់ឈើ បន្ដិចក៏ស្រែកយំកញ្ជ្រៀវខ្សៀវខ្វាហើយហើរចេញទៅ, សូម្បីសត្វកំប្រុក ស្វាកង្ហែនជាដើម ដែលបានផឹកនោះ ក៏មានទំនងដូចគ្នាដែរ ។ ថ្វើរព្រៃបានឃើញហើយក៏គិត ទឹកនេះមិនមែនពុលទេ បើជាទឹកពុល សត្វដែលផឹកទាំងប៉ុន្មាន មុខជាស្លាប់អស់ឥតសល់ ក៏ដងទឹកនោះផឹកដរាបដល់ស្រវឹង ហើយបង្កាត់ភ្លើងចាប់សត្វដែលដួលជ្រួលជ្រប់ ក្រាបក្បែរគល់ឈើសម្លាប់បោចអាំងស៊ីផឹកទឹកនោះស់ពីរបីថ្ងៃ ។

សម័យនោះមានតាបស មួយរូបឈ្មោះវរុណ នៅក្នុងទីជិតនោះ ។ ថ្វើរព្រៃដងទឹកនោះមួយបំពង់ឫស្សី និងដុំសាច់ដែលចំអិនស្រេចមួយចំកាត់ដើរទៅកាន់សំណាក់វរុណតាបស ហើយនិយាយថា សូមលោកម្ចាស់ឆាន់ទឹក និងសាច់នេះលេងមើល ។ តាបស និងថ្វើរព្រៃក៏នាំគ្នា

ទំពារស៊ីដុំសាច់ ផឹកទឹកនោះអស់ កាលជាយូរថ្ងៃ ទើបទឹកនោះមានឈ្មោះថាសុរាផង វរុណផង ព្រោះថ្មើរព្រៃមានឈ្មោះថាសុរៈ និងតាបសឈ្មោះថាវរុណ បានឃើញ បានផឹកមុនគេ ។ អ្នកទាំងពីរគិតគ្នាថា ទឹកនេះសំខាន់ណាស់ ក៏ដងចាក់ពេញបំពង់ឫស្សីជាច្រើន រែកទៅស្រុកបច្ចន្តគ្រាម អោយអ្នកស្រុកក្រាបបង្គំទូលព្រះមហាក្សត្រថា មានអ្នកចេះធ្វើទឹកស្រវឹង យ៉ាងវិសេសវិសាលទើបនឹងមកដល់ ។

ព្រះមហាក្សត្រ ទ្រង់ត្រាស់បង្គាប់អោយអ្នកទាំងពីរចូលទៅគាល់ អ្នកទាំងពីរក៏ចូលយកទឹកនោះទៅថ្វាយព្រះរាជា ៗ ទ្រង់សោយក៏ស្រវឹងស្រួលមែន លុះអស់ទឹកនោះទៅ បានត្រាស់បង្គាប់អោយដងយកទៅថ្វាយទៀត ។ ជនទាំងពីរនាក់ ទៅនាំទឹកនោះបានពីរបីថ្ងៃ ទើបគិតគ្នាថា យើងមិនអាចទៅយកជានិច្ចបានទេ ហើយក៏កំណត់យកគ្រឿងផ្សំគ្រប់មុខ មកផ្សំធ្វើសុរា ក្នុងនគរនោះ ។ អ្នកនគរនាំគ្នាផឹកសុរាតែរាល់ៗគ្នា ក៏ទៅជាអ្នកមានសេចក្តីប្រមាថក្នុងការងារ ធ្លាក់ខ្លួនទៅជាអ្នកកំសត់ទុគ៌ត នគរនោះក៏សាបសូន្យចាកសេចក្តីចំរើនគ្រប់យ៉ាង ។ អ្នកធ្វើសុរាក៏នាំគ្នារត់ទៅនៅក្នុងនគរពារាណសី អោយអ្នកនគរក្រាបទូលព្រះបាទពារាណសីៗទ្រង់បង្គាប់អោយហៅមក ហើយទ្រង់ព្រះរាជទានស្បៀងអាហារអោយធ្វើសុរាថ្វាយ ។ នគរនោះក៏វិនាសដូចមុនទៀត ។ អ្នកធ្វើសុរារត់ចេញពីទីនោះទៅនៅក្នុងនគរសាកេត ចេញពីនគរសាកេតទៅនគរសាវត្ថី ។ គ្រា

នោះព្រះចៅក្រុងសាវត្ថី ទ្រង់ព្រះនាមព្រះបាទសព្វមិត្ត ព្រះអង្គបានធ្វើសេចក្ដីសង្គ្រោះដល់អ្នកធ្វើសុរា ទាំងពីរនាក់នោះ ទ្រង់ព្រះរាជទេយ្យវត្ថុផ្សេងៗដល់អ្នកទាំងពីរៗ ក៏បានធ្វើសុរានៅក្នុងនរគសាវត្ថីនោះ អស់កាលដ៏យូរ, ការធ្វើសុរាក៏ចេះតែកើតៗពីត្រឹមនោះមក ។

ពុទ្ធបរិស័ទទាំងឡាយ គប្បីពិចារណាមើលនូវនិច្ចសីលត្រង់ ខទី៥ ព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងពន្យល់ មិនអោយសេពសុរា និងមេរ័យ គឺប្រៀនប្រដៅអោយវៀរចាកផឹកសុរា មេរ័យ និងទឹកស្រវឹងផ្សេងៗ ដែលជាការបៀតបៀនខ្លួនឯង ។ សីលខនេះជាទីទំនាស់ទាស់ចិត្ត ដល់អ្នកប្រមឹកផឹកស៊ីទាំងឡាយពេកណាស់, ជនប្រភេទខ្លះ ដល់ពេលទទួលសីលព្រមទទួលគ្រប់ខ ទាំងអស់ លុះដល់ខ ទី៥ ត្រឡប់ជាអង្គុយប្រណម្យដៃ ធ្វើឆើយព្រងើយស្ងៀមទៅក៏មាន, យ៉ាងណាក៏ដោយ ការផឹកសុរាជាការប្រព្រឹត្តទៅដើម្បីដុតកំដៅបៀតបៀនខ្លួនឯងដោយពិត តាំងតែពីធ្វើអោយវិនាសហិនហៃ ហិនហោចអន្តរាយទ្រព្យសម្បត្តិ ជាដើមហេតុអោយធ្វើអំពើផ្សេងៗ ដែលមនុស្សធម្មតាមិនគួរធ្វើ មនុស្សដែលមានប្រាក់ចាយមិនគ្រប់គ្រាន់ ព្រោះហេតុប្រើទៅក្នុងផ្លូវផឹកសុរា ក៏មានចិត្តតិច មនុស្សដែលធ្វើខុសច្បាប់សំរាប់រដ្ឋ ព្រោះឫទ្ធិរបស់សុរាក៏មាន ជាច្រើនដោយឫទ្ធីសុរានេះ បុគ្គលអាចលក់ម៉ែលក់ឪទាំងអស់ ព្រោះក្នុងវេលានោះ សេចក្ដីដឹងខុសត្រូវទាំងឡាយ បានធ្លាក់ទៅក្រោមអំណាចរបស់សុរាអស់ហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្លះធ្លាក់ជាមនុស្សនឹងនួនត្រឹមត្រូវនិយាយតិច លុះសុរាចូលដល់កាលណា ក៏ក្លាយទៅជាមនុស្សហេហោ និយាយពាសវាល ពាសកាល ផ្ដេសផ្ដាស វាលដាលមិនបានការ ប្រហែលគ្នានឹងមនុស្សឆ្កួត សមនឹងពាក្យថា " សុរានិយាយ មិនមែនមនុស្សនិយាយទេ សុរាមិនមែនមនុស្សធ្វើទេ " ។

ហេតុនេះការវៀរចាកសុរា គឺការកាច់បំបាក់ដើម ហេតុនៃសេចក្ដីអាក្រក់គ្រប់យ៉ាង ។ មនុស្សខ្លះអាងថា ផឹកល្មមតែប្រមាណ មិនជាអ្វីទេ តែបើសង្កេតមើលអោយល្អហើយ នឹងឃើញបានថា មនុស្សទាំងអស់ធ្វើអ្វីៗសុទ្ធតែតិចៗ ឬដឹងប្រមាណ ជាមុនទាំងអស់ លុះយូរៗមក សេចក្ដីដឹងប្រមាណក៏ភ្លេចភ្លាំងអស់ទៅ ប៉ុន្មានៗក៏មិនល្មមប៉ុន្មានៗពែង ក៏មិនចេះឆ្អែត ប៉ុន្មានៗកែវក៏មិនចេះគ្រាន់នេះ គឺការច្រើនមកពីតិច ការធ្លាប់អំពីហាត់ , សុមដូចពាក្យលោកពោលថា "លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក ផឹកស្រាធ្លាប់ស្រេក ជជែកធ្លាប់មាត " ។

ពាក្យកាព្យរបស់បណ្ឌិត ឱម-ណាត្រ៉ី ពោលថា អ្នកប្រមឹកផឹកសុរា និងមេវ័យ តែងហិនហោច ខូចហិនហៃ ទ្រព្យសម្បត្តិ រលត់ប៉ើងរលើងខ្ចាយ រលាយខ្ចាត់ វិនាសបង់ វិនាសបាត់ ឥតសេសសល់ ។

បទថា **អក្ខធុត្តោ** បានសេចក្ដីថា អ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសង ។ ពាក្យថាល្បែងភ្នាល់បានដល់ល្បែងជល់មាន់, ជល់ត្រីក្រឹម លែងភ្នាល់ទឹកភ្លៀង ។ ល ។ ល្បែងស៊ីសង បានដល់ល្បែងបៀរបៀ អាប៉ោង

ខ្លាឃ្មោក ប៊ូលបាល់ ឡូតូ កូនក្រមុំ (ហៅ ៣សន្លឹក) ល្បែងគ្រប់ជំពូកទាំងអស់នេះ រាប់ថាជាអបាយមុខ នាំអោយវិនាសទ្រព្យសម្បត្តិ ។

**អបាយមុខ** ហេតុដែលនាំអោយវិនាស ៧ យ៉ាងគឺ :

**១-ឥត្ថីសោណ្ឌ** លេងស្រីផ្កាមាស

**២-សុរាសោណ្ឌ** លេងផឹកសុរា

**៣-អក្ខសោណ្ឌ** លេងស៊ីនំ

**៤-អក្ខធុត្ត** លេងល្បែងស៊ីសង

**៥-អលស្ស** ខ្ជិលច្រអូស

**៦-បាបមិត្ត** សេពគប់មិត្តអាក្រក់

**៧-រត្តិយា វិចរណៈ** ដើរលេងល្បែងមហោស្រព ។

**វិកាលចរណៈ** ដើរលេងយប់មានទោស ៦ យ៉ាង

១-មិនរក្សាខ្លួន

២-មិនរក្សាកូនប្រពន្ធ

៣-មិនរក្សាទ្រព្យសម្បត្តិ

៤-ជាទីរង្កៀសរបស់មនុស្សទាំងឡាយ

៥-ច្រើនត្រូវគេប្រកាន់ទោស

៦-បានសេចក្តីលំបាកច្រើន ។

**សមជ្ជាភិចរណៈ**ការដើរលេងមើលលេងមហោស្រពមាន៦យ៉ាងគឺៈ

១-រាំនៅទីណាទៅកាន់ទីនោះ

២-ច្រៀងនៅទីណាទៅកាន់ទីនោះ

៣-ដេញដំប្រគំផ្លុំកូតនៅទីណា ទៅកាន់ទីនោះ

៤-គេនិយាយលេងសើចនៅទីណាទៅកាន់ទីនោះ

៥-ល្បែងច្រៀងទះដៃនៅទីណាទៅកាន់ទីនោះ

៦-ពិណពាទ្យនាតគងនៅទីណាទៅកាន់ទីនោះ

**ជូតានុយោគ** ការលេងល្បែងភ្នាល់មានទោស ៦ យ៉ាងគឺ :

១-ការឈ្នះរមែងបង្កអោយកើតពៀរ

២-ការចាញ់រមែសោយស្តាយទ្រព្យ

៣-ទ្រព្យរមែងវិនាស

៤-មិនមានអ្នកណាមួយជឿពាក្យ

៥-ជាទីមើលងាយរបស់ញាតិមិត្ត

៦-មិនមានអ្នកណាមួយត្រូវការ នឹងរាប់រកផង ។

ពុទ្ធសាសនិកជនទាំងឡាយ ! ជនណាវឹកវរនឹងស្រី ផ្កាមាស ជននោះហៅថា ឆ្កួតស្រី ជនណាវឹកវរ នឹងស្រា ជននោះគេហៅថា ឆ្កួតស្រា ជនណាវឹកវរនឹងល្បែងស៊ីសង ជននោះគេហៅថា ឆ្កួល្បែងស៊ីសង ។

បោរាណបណ្ឌិតទាំងឡាយ ! លោកបានពិនិត្យរិះគិតពិចារណា ដោយវិចារណញ្ញាណ មើលឃើញទោសក្នុងល្បែងទាំង ៣ នេះ ហើយទើប

Websites: WatKhemaraRatanaram.org or WatKhmers.org

លោកពោលទុកក្នុងសាស្ត្រាស្លឹករឹតថា : លោកថាឆ្គុតបី ឆ្គុតមួយនឹងស្រី ឆ្គុតមួយនឹងស្រា ឆ្គុតមួយនឹងល្បែង អំពើពាលាឆ្គុតនេះ ហៅថា ឆ្គុតក្រៃពេកហោង ។

ពុទ្ធមាមិកជនទាំងឡាយ ! កាលបើឃើញទោសដ៏ច្រើន នៃល្បែងទាំងបីនេះហើយ ក៏គប្បីលះបង់អោយជ្រះស្រឡះ ពីខន្ធសន្តានកុំគប្បីប្រព្រឹត្តឡើយ, ពីព្រោះអំពើទាំងអស់នេះ នាំអោយអ្នកប្រព្រឹត្តនោះទៅកាន់ហាយនភាពដោយពិតប្រាកដ ។

ការសំដែងមកក្នុងគាថាទី ៨ នៃបរាភវសូត្រ ដែលមានសេចក្តីថា ជនអ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់ទាំង-ឡាយធ្វើទ្រព្យខ្លួនមានអោយអន្តរាយ ការល្បែងទាំងឡាយ នាំអោយវិនាស ។

ការសំដែងមកនេះក៏សន្មត់

ថាចប់តែប៉ុណ្ណេះ ឯវំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសូត្រ

## នមោ តស្ស

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមថ្វាយបង្គំព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គប្រកបដោយគុណគឺ វិសុទ្ធិគុណ ករុណាគុណ និងបញ្ញាគុណ សូមថ្វាយបង្គំចំពោះព្រះធម៌ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ។ សូមថ្វាយបង្គំចំពោះព្រះសង្ឃទាំងពីរ ក្រុមគឺសម្មតិសង្ឃ និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

បទនមស្សការសូមសង្ខេបបែបខ្លីតែប៉ុណ្ណេះ

កំណត់អំពីបទនមស្សការដោយសង្ខេបនេះទៅ សូមដកស្រង់នូវព្រះគាថា ទី ៩ នៃបរាភវសូត្រ មកដោះស្រាយរំគាយសេចក្តីអធិប្បាយពន្យល់ន័យរំលែកចែកជូនដល់ពុទ្ធបរិស័ទទាំងឡាយ ដែលបានអញ្ជើញមកកុះករ មីរដេរដាសកកកុញ ត្រៀបត្រា ក្នុងធម្មសភាសាលា ដោយមានប្រាថ្នា ដើម្បីនឹងត្រង់ត្រាប់ស្តាប់រងយកនូវអត្ថរសព្រះធម៌វិសេសទេសនា ដើម្បីជាឧបនិស្ស័យវាសនាអនាគតជាតិ ។

ទេវតាទូលសួរតទៅទៀតថា ៖

**ឥតិហេតំ វិជានាម អដ្ឋមោ សោ បរាភវោ នវមំ ភគវា ព្រូហិ កឹ បរាភតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះបើរាប់សង្គ្រោះវិនាសនោះឈ្មោះទី៨ ទាន់ហន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ៕**

បុរសមិនត្រេកអរ និងប្រពន្ធខ្លួន ហើយទៅជាប់ជួន និងស្រីពេស្យា ទ្រុស្តនិងប្រពន្ធកូនកូនជននានា ហេតុនោះទៅជា នាំអោយវិនាស ។

## អធិប្បាយ

## គាថាទី៩

បណ្តាបុរសក្នុងលោក បុរសពួកខ្លះ ជាអ្នកមិនមានសេចក្តីសន្តោស មិនត្រេកអរនឹងភរិយារបស់ខ្លួន ទៅជាមានចិត្តធុញទ្រាន់ធ្លើយណាយចំពោះភរិយារបស់ខ្លួន ហើយទៅជាមានចិត្តស្នេហ៍ស្និទ្ធប្រតិព័ទ្ធសហាយស្មន់ និងស្រីពេស្យាផ្កាមាស ។ បុរសណាល្មោភកាម មិនឆ្អែតឆ្អន់ស្កប់ស្កល់ និងកាម ហើយទៅជាប់ជួននឹមន្ទួនពេស្យា បុរសនោះឈ្មោះថា ធ្វើខ្លួនអោយខូចតំលៃ ខូចកេរ្តិ៍ឈ្មោះ ខូចកិត្តិយស ហិនហាយន៏អន្តរាយទ្រព្យសម្បត្តិ បណ្តាលអោយកើតរោគផ្សេងៗ ច្រើនជំពូក ។

បុរសអ្នកប្រព្រឹត្ត ក្បត់ប្រពន្ធរបស់ខ្លួន ទៅសេពសម្ពាគប់សម្ពស្ស រសកាម និងស្រីផ្កាមាស ឬនឹងប្រពន្ធជនអ្នកដទៃ រមែងដើរសំដៅតំរង់ទៅរកសេចក្តីវិនាស អ្នកដែលមានប្រពន្ធហើយ បែរទៅជានឿយណាយរសាយចិត្ត ឥតត្រេកអរនឹងប្រពន្ធរបស់ខ្លួន ដោយល្មោភ លោភល្មើសលើសល្មម ក្នុងកាមារម្មណ៍ គ្មានចិត្តសន្តោស ចំពោះភរិយា របស់ខ្លួន ក៏ទៅជាប្រព្រឹត្តផិតក្បត់ ក្រៅចិត្តទៅស្និតស្នេហាសេពសម នឹងស្រីពេស្យាផ្កាមាស ឬ ទៅខូចកាច នឹងប្រពន្ធជនដទៃទៅវិញ លោកប្រាប់ថា ហេតុការណ៏នោះជាប្រធាននៃសេចក្តីវិនាស យ៉ាងណាមិញ យ៉ាងនេះគឺសេចក្តីសុខសាន្តចំរើន ឡើងនៃគ្រួសារ ក្រៅពីបញ្ហាដទៃ សេចក្តីទៀងត្រង់មិនប្រព្រឹត្តក្រៅចិត្តគ្នា ជាមធ្យោបាយនៃសេចក្តីសុខ សាន្តមួយដែរ, ផ្ទុយទៅវិញការប្រព្រឹត្តក្រៅចិត្តទៅស្និទ្ធ នឹងស្រីដទៃ គឺជាភ័យវិបត្តិខ្ទាត់សេចក្តីសុខ មួយទៀតនៃគ្រួសារដែរ គឺនាំអោយអាក់អន់ចិត្ត នាំអោយកើតតែជម្លោះទាស់ទែងលែងលះ ភាពរកាំរកូសនៃគ្រួសារ ។ ស្រីពេស្យាផ្កាមាសជាពួកលក់កាយ ចំណាយប្រាណ ចំពោះបុរសមិនរើសមុខ ដើម្បីទាក់ទាញយកប្រាក់ ម្លោះហើយស្រីពេស្យាជាសំបុក ឬ អណ្តូងកើតនៃកាមរោគ ។ អ្នកមិនត្រេកអរ នឹងប្រពន្ធរបស់ខ្លួន ចូលចិត្តជួបជួននាងនួនពេស្យា ឈ្មោះថាប្រព្រឹត្តក្រៅចិត្តភរិយា ជាហេតុនាំអោយវិបត្តិក្នុងគ្រួសារ ឈ្មោះថាដើរទៅរកសេចក្តីវិនាស ប្រាសចាកសុខភាពនៃរាងកាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

អស់ប្រាក់កាសសំរាប់ចិញ្ចឹមគ្រួសារ នាំអោយកើតកាមរោគ និងបន្តកាមរោគដល់ប្រពន្ធកូន ជូនដល់ផៅពង្សទៅអនាគតទៀត ។

ឯការទៅស្ម័គស្នេហ៍អន្ទករ ជាមួយនឹងប្រពន្ធជនដទៃ ក៏ជាភ័យវិបត្តិខ្ចាត់សេចក្តីសុខចំរើនដូចគ្នាដែរ ព្រោះប្រពន្ធគេ ហួងស្រឡាញ់ការពារថែរក្សា កាលបើបុរណាទៅប្រព្រឹត្តខូចកាច និងនាង ប្តីនាងនឹងបៀតបៀន ដោយសំលាប់កាប់សំឡេះក្តី ត្រូវទទួលទោសទណ្ឌកម្ម ជាប់គុកច្រវាក់ អន្ទាក់ណែងណង នឹងការបង់ពិន័យជាដើម ។ ដូច្នោះអាចឃើញបានថា អ្នកមិនត្រេកអនឹងប្រពន្ធរបស់ខ្លួន ចូលចិត្តទៅជួបជួនរួមរស់នឹងស្រីពេស្យា ផ្កាមាស នឹងប្រពន្ធជនដទៃក្តី ប្រាកដជាជួបជួននូវសេចក្តីវិនាសមានប្រការផ្សេងៗ ដូចពោលមកហើយ ។

សេចក្តីសោកខ្សឹកខ្សួលអួលអាក់ ឬ ភ័យទាំងអស់នេះមកតែពីកាម ដូចព្រះពុទ្ធដីកាក្នុងធម្មបទដ្ឋកថា ភាគទី៦ ទំព័រ ២១៨ ព្រះអង្គសំដែងថា :

**កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

ប្រែថា សេចក្តីសោក កើតអំពីកាម, ភ័យកើតអំពីកាម សេចកីសោកមិនមានដល់បុគ្គលអ្នករួចស្រឡះចាកកាម ភ័យនឹងមានមកទីណាបាន ។

សេចក្ដីសោកក្ដី ភ័យក្ដី ដែលជាគ្រឿងទុក្ខព្រួយយ៉ាងធំ កាលកើតឡើងរមែងកើតព្រោះអាស្រ័យនូវកាម ២ យ៉ាងនេះគឺវត្ថុកាម ១ កិលេសកាម១ ។ ពាក្យថា " កាម " ប្រែថា សេចក្ដីប្រាថ្នា ឬការចង់បាននូវលោកិយវត្ថុគឺ នូវអំពើដ៏លាមក ។ កាមដែលកើតអំពីវត្ថុ ៥យ៉ាងគឺ រូប សំឡេង ក្លិន រស សម្ផស្ស ហៅថា វត្ថុកាម ។ កាមដែលកើតអំពីកិលេស ៣ យ៉ាង កិលេស ១០ យ៉ាង ហៅថា កិលេសកាម ។

កិលេសនោះបើរាប់ដោយបំព្រួញមាន ៣ យ៉ាងគឺ :

**១-លោភ** សេចក្ដីជាប់ជំពាក់ចិត្តក្នុងអារម្មណ៍

**២-ទោស** សេចក្ដីខឹង ប្រទូស្ដចំពោះអារម្មណ៍

**៣-មោហ** សេចក្ដីវង្វេងក្នុងអារម្មណ៍ ។

បើរាប់អោយពិស្ដាបន្ដិចទៅទៀតមាន ១០ យ៉ាងគឺ:

**១-លោភោ** សេចក្ដីជាប់ជំពាក់ក្នុងអារម្មណ៍

**២-ទោសោ** សេចក្ដីប្រទូស្ដចំពោះអារម្មណ៍

**៣-មោហោ** សេចក្ដីវង្វេងភាន់ក្នុងអារម្មណ៍

**៤-មានោ** សេចក្ដីប្រកាន់ខ្លួន ( ម្នោម្នះ)

**៥-ទិដ្ឋិ** សេចក្ដីយល់ខុស

**៦-វិចិកិច្ឆា** សេចក្ដីសង្ស័យមិនដាច់ស្រេច

**៧-ថីនំ** សេចក្ដីងងុយជ្រប់ស្រពោន

Websites: WatKhemaraRatanaram.org or WatKhmers.org

**៨~ឧទ្ធច្ចំ** សេចក្តីរាយមាយចិត្ត

**៩~អហិរិកំ** សេចក្តីមិនខ្មាស់អំពើបាប

**១០~អនោត្តប្បំ** សេចក្តីមិនខ្លាចអំពើបាប ។

បើចែកអោយល្អិត ដោយពិស្តារមាន ១៥០០ គឺ លោករាប់ចិត្ត សង្ខេប ៨៩ រាប់ថា១ យកចេតសិក ៥២ និងនិប្ផន្នរូប ១៨ និងទុក្ខ ៤ គឺ ជាតិ ជរា ព្យាធិ មរណៈ មកបូកជា ៧៥ ចាត់ជានាមធម៌ខាងក្នុង ៧៥ រូបធម៌ខាងក្រៅ ៧៥ រួមជា ១៥០ យកកិលេសខងលើ ១០ មក គុណជា ១៥០០ ។

ម្យ៉ាងទៀតកិលេស ១៥០០ នោះ លោករាប់យកលោកិយចិត្ត ៨១ នោះថា ១ យកចេតសិក ៥២ និប្ផន្នរូប ១៨ អាកាសធាតុ ១, ជាតិ១ ជរា១ ភវង្គ១ ផ្សំគ្នាជា ៧៥ កិលេសខាងក្នុង ៧៥ ខាងក្រៅ ៧៥ ផ្សំចូលគ្នាជាកិលេស ១៥០ យកកិលេស ១០ គឺ លោភោ១ ទោសោ ១ មោហោ១ មានះ១ ទិដ្ឋ១ វិចិកិច្ឆា១ ថិនមិទ្ធ១ ឧទ្ធច្ច១ អហិរិត១ អនោត្តប្ប១ មកគុណនឹង ១៥០ ត្រូវជាកិលេស ១៥០០ ។

ក្នុងកាម និងកិលេសកាមទាំង២យ៉ាងនេះជាដែន ជាទីកើតនៃ សេចក្តីសោក និងភ័យ ។ បុគ្គលដែលរួចចាកស្រឡះអំពីវត្ថុកាម និង កិលេសកាម ហើយនិងមានសេចក្តីសោក និងភ័យមកអំពីណា ។ បុរស ដែលមានភរិយាហើយ ទៅស្រឡាញ់ស្រីដទៃ ឈ្មោះថាសាហាយស្មន់

អន្ទករ គឺក្បត់ចិត្តភរិយា ឯភរិយាវិញ បើបានបុរសណាជាស្វាមីហើយ ទៅខូចជូរជាមួយនឹងប្រុសដទៃឈ្មោះថា សាហាយស្មន់ គឺក្បត់ចិត្តស្វាមី ។ នៅក្នុងសង្គហធម៌ដែលព្រះសម្ពុទ្ធទ្រង់សំដែងទុកមក ក៏ឃើញថាមានហាមស្វាមីមិនអោយក្បត់ចិត្តភរិយា ហាមភរិយាមិនអោយក្បត់ចិត្តស្វាមីដែរ ។

**សង្គហធម៌នោះគឺៈ**

ស្វាមីត្រូវទំនុកបំរុងភរិយា ដោយធម៌ ៥ យ៉ាងគឺ

**១_សម្មាននាយ** រាប់អានលើកមុខថាជាភរិយា

**២_អវិមាននាយ** មិនមើលងាយភរិយា

**៣_អនតិចរិយាយ** មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា

**៤_ឥស្សរិយវោស្សគ្គេន** ប្រគល់ភារៈជាធំក្នុងផ្ទះ

**៥_អលង្ការានុប្បទានេន** អោយគ្រឿងតែងខ្លួន ។

ភរិយាត្រូវទំនុកបំរុងស្វាមីដោយធម៌ ៥ យ៉ាងគឺ :

**១_សុសំវិហិតកម្មន្តា** ចាត់ចែងការងារដោយល្អ

**២_សុសង្គហិតបរិជនា** សង្គ្រោះញាតិខាងស្វាមី

**៣_អនតិចារិនី** មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្តី

**៤_សម្ភតញ្ច អនុរក្ខតិ** រក្សាទ្រព្យដែលស្វាមីរកបានមកហើយ

**៥_ទក្ខាចហោតិ អនលសា សព្វកិច្ចេសុ** ជាអ្នកឧស្សាហ៍មិនខ្ជិលក្នុងកិច្ចការងារទាំងពួង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុទ្ធបរិស័ទទាំងឡាយ ! បើយើងពិនិត្យសង្កេតទៅឃើញថា ក្នុងសង្គហធម៌គឺ ខទី៣ ទាំងខាងស្វាមី ទាំងខាងភរិយា ព្រះពុទ្ធអង្គទ្រង់សំដែងហាម មិនអោយស្វាមីក្បត់ចិត្តភរិតយា។ក្បត់ចិត្តស្វាមី ។

ការប្រព្រឹត្តក្បត់ចិត្តគ្នា និងគ្នា ឃើញថាមានទោសច្រើនប្រការណាស់ ដូចរឿងមារុត្តព្រាហ្មណ៍ សូមនាំនិទាននោះមកសំដែងដូចតទៅ : ចិញ្ចឹមសត្វតិរច្ឆានប្រសើរ ជាងចិញ្ចឹមភរិយាក្បត់ "

កាលកន្លងទៅហើយមានព្រាហ្មណ៍ម្នាក់ឈ្មោះមារុត្ត នៅក្នុងស្រុកមួយក្បែរស្ទឹងចន្ទភាគា ។ ថ្ងៃមួយមារុត្តព្រាហ្មណ៍ បានចេញទៅជួញឯនគរតក្កសិលា, លុះត្រឡប់មកវិញដល់កណ្ដាលផ្លូវ បានឃើញឆ្កែមួយស្គមនៅតែឆ្អឹង អង្គែស៊ីជ្រុះរោមអស់ ដេកក្រោមសាលាដំណាក់មួយ ក៏មានសេចក្ដីករុណាអាណិត អាសូរដល់ឆ្កែនោះពន់ពេក បានផ្សំថ្នាំអោយផឹកបានជាមួយរំពេច ។ ឆ្កែក៏មានសេចក្ដីស្រឡាញ់ បានដើរតាមព្រាហ្មណ៍នោះទៅ ព្រាហ្មណ៍បានចិញ្ចឹមឆ្កែនោះ ដោយសេចក្ដីសង្គ្រោះ ។ ក្នុងកាលជាខាងក្រោយមក ភរិយារបស់ព្រាហ្មណ៍សំរាលកូនមិនរួច ពេទ្យក៏យកកាំបិទកាត់កូននោះជា កំណាត់តូចធំ យកចេញមកក្រៅផ្ទៃ ។ ឯមារុត្តព្រាហ្មណ៍ជាស្វាមីបានឃើញដូច្នោះ ក៏កើតសេចក្ដីសង្វេគនឿយណាយក្នុងការគ្រប់គ្រងផ្ទះ បានលាភរិយាបួសជាតាបសនៅក្នុងព្រៃម្នាក់ឯង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯភរិយាមារុត្តព្រាហ្មណ៍ មិនយូរប៉ុន្មានក៏បែកចិត្តទៅរួមជាមួយនឹងបុរសដទៃទៀត ហើយបានចង់គំនុំប្រទូស្ត នឹងព្រាហ្មណ៍ជាប្ដីដើម ដោយគិតថា ៖ មារុត្តព្រាហ្មណ៍មានចិត្តអាក្រក់ណាស់ លះបង់ចោលអញរត់ទៅបួសយកសុខតែម្នាក់ឯង ឥតគិតគួរដល់អញបន្តិចបន្តួចឡើយ ។

គិតដូច្នោះហើយ ក៏និយាយប្រាប់ប្ដីចុងថា បពិត្រអ្នកស្វាមី ! អ្នកត្រូវសំលាប់មារុត្តព្រាហ្មណ៍កំណាចចោលចេញ ក្រែងថ្ងៃក្រោយវាត្រឡប់មកវិញ ។ ឯសត្វឆ្កែបានស្ដាប់ពាក្យរបស់នាងនោះហើយ ក៏រត់ទៅក្នុងព្រៃជាមួយមារុត្តព្រាហ្មណ៍ ដែលបួសជាតាបស ។

ថ្ងៃមួយបុរសជាប្ដីចុងនាង បានកាន់ធ្នូ នឹងបំពាក់ព្រួញចូលទៅក្នុងព្រៃជាអាស្រមរបស់តាបស ។ គ្រានោះតាបសចេញទៅរកផ្លែឈើ និងមើមឈើ ជាអាហារបាត់ទៅ នៅតែឆ្កែដេកចាំអាស្រម ។ ឯបុរសនោះកាលមិនឃើញតាបសក្នុងអាស្រមនោះ ហើយក៏អង្គុយពួនចាំក្បែរគុម្ពឈើមួយ ឆ្កែក៏លបចូលទៅខាំបន្លោះធ្នូបុរសនោះដាច់អស់ទៅ ។ បុរសនោះបានឃើញបន្លោះធ្នូដាច់ ក៏បានធ្វើអោយជាប់ឡើងវិញ ឆ្កែលបទៅខាំបន្ទាច់ម្ដងទៀត អស់វារៈជាច្រើនដង ។ លុះដល់តាបសត្រឡប់មកកាន់អាស្រមវិញ បុរសនោះចងខ្សែធ្នូ ផ្ទាប់ព្រួញបំរុងនឹងបាញ់ ឆ្កែក៏ស្ទុះចូលទៅខាំទាញកន្ទ្រាក់អោយដួលដេកលើផែនដីដរាបដើរពុំរួច ។

Websites: WatKhemaraRatanaram.org or WatKhmers.org

លំដាប់នោះតាបស ឬសំឡេងឆ្កែក៏ដើរចូលទៅ ដោយរួសរាន់ បានឃើញវិប្បការដូច្នោះ ហើយមានសេចក្តីអាណិតអាសូរបានថែទាំង ដំបៅបុរសនោះ ដរាបដល់ជាសះស្បើយ ហើយបញ្ជូនបុរសនោះត្រឡប់ទៅ ផ្ទះវិញ ។

ឯតាបសនោះបាននៅក្នុងព្រៃនោះជាសុខក្សេមក្សាន្ត ខំចំរើនឈាន និងអភិញ្ញាអោយកើតឡើងដល់អាយុ ក៏បានទៅកើតក្នុងព្រហ្មលោក ។

ព្រះពុទ្ធដីកា មានមកក្នុងគម្ពីរ ខុទ្ទកនិកាយ សុត្តនិបាត ព្រះអង្គ ទ្រង់សំដែងថា

**យោធ កាមេ អច្ចគា សង្គំ លោកេ ទុរច្ចយំ**

**នសោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោ ។**

ប្រែថា អ្នកណាឆ្លងផុតចាកកាម និងគ្រឿងជំពាក់ដែលឆ្លងបាន ដោយលំបាកក្នុងលោកនេះ អ្នកនោះឈ្មោះថា កាត់ខ្សែតណ្ហាបាន មិនមាន ចំណង ទើបមិនសោកស្តាយ មិនត្រេកអរ ។

ក្នុងរឿងព្រះមាលេយ្យទេពថេរ មានសំដែងអំពីយមលោកនរក មានលោហកុម្ភីនរកដែលប្រែថា " នរកខ្ទះទង់ដែង " គឺនរកនេះមានទឹក ទង់ដែងពេញខ្ទះ ពុះខ្ទោលកខាចឥតឈប់ឈរ សត្វនរកទៅកើតក្នុងខ្ទះ ទង់ដែងនោះ គ្រាន់តែលិចទៅដល់បាតខ្ទះចំនួន ៣ ម៉ឺនឆ្នាំ ផុះឡើងដល់ មាត់ខ្ទះចំនួយ៣ម៉ឺនឆ្នាំ ហើយតែងផុះនិងលិចចុះយ៉ាងនេះត្រូវ ទឹកទង់ដែង

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្តៅ ពេញទំហឹងរាល់ៗថ្ងៃ ។ ទោសធ្លាក់នរកលោកុម្ភីនេះ មកពីអំពីលបលួចខសង្កត់សង្កិន ប្រព្រឹត្តអានាចារខុសឆ្គង ប្រព្រឹត្តបទារកកម្មរំលោភកូនប្រពន្ធ ប្តីរបស់គេ ហួងហែងថែរក្សា ធ្វើបាបអ្នកមានគុណ តប់ទាត់ចាក់ជាស ដើម្បីទំលាយព្រហ្មចារិយកូនប្រពន្ធជនដទៃ, ព្រោះការសប្បាយភ្លេចខ្លួនព្រោះកាម ត្រូវទទួលរងទុក្ខជាយូរអង្វែង ។

កាមេសុ មិច្ឆាវៀរស្ត្រី ២០ ជំពូកគឺ :

**១-មាតុរក្ខិតា** ស្ត្រីដែលមាតាគ្រប់គ្រងរក្សា

**២-បិតុរក្ខិតា** ស្ត្រីដែលបិតាគ្រប់គ្រងរក្សា

**៣-មាតាបិតុរក្ខិតា** ស្ត្រីដែលមាតាបិតាថែរក្សា

**៤-ភាតុរក្ខិតា** ស្ត្រីដែលបងប្រុស ឬប្អូនប្រុសរក្សា

**៥-ភគនិរក្ខិតា** ស្ត្រីដែលបងស្រី ឬប្អូនស្រីថែរក្សា

**៦-ញាតិរក្ខិតា** ស្ត្រីដែលញាតិថែរក្សា

**៧-គោតរក្ខិតា** ស្ត្រីដែលគោត្រជាមួយគ្នាថែរក្សា

**៨-ធម្មរក្ខិតា** ស្ត្រីដែលបព្វជិតពួកណាមួយអ្នកប្រព្រឹត្តធមិត្រូវគ្នាគ្រប់គ្រងថែរក្សា

**៩-សារក្ខា** ស្ត្រីដែលប្រកបដោយការរក្សា គឺស្ត្រីដែលមានស្វាមីហើយឬមានគេប្រកាន់ទុកហើយ ។

**១០-សបរិទណ្ឌា** ស្ត្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែល

ព្រះរាជដាក់ព្រះរាជអាជ្ញា មិនអោយប្រព្រឹត្តកាម អំពើចិត្ត ឬមិនអោយបុរសណាមួយទៅប្រព្រឹត្តកន្លង ។

**១១_ធនក្កីតា** ស្រីដែលគេទិញ ឬលោះយកដោយទ្រព្យយកមកធ្វើជាភរិយា ឬត្រឹមតែលោះប៉ុណ្ណោះ មិនបានយកធ្វើជាភរិយាទេ ។

**១២_ឆន្ទវាសិនី** ស្ត្រីដែលរត់តាមទៅនៅធ្វើជាភរិយារបស់បុរសដោយសេចក្តីពេញចិត្តរបស់ខ្លួន ខាងបុរសក៏ទទួលព្រមផង ។

**១៣_ភោគវាសិនី** ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរសព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈ យ៉ាងហោចត្រឹមតែអង្រែ និងត្បាល់ជាដើមអំពីបុរសណាក៏ទៅធ្វើជាភរិយារបស់បុរសនោះ ។

**១៤_បដវាសិនី** ស្ត្រីទៅនៅធ្វើជាភរិយារបស់បុរស ព្រោះតែសំពត់ គឺស្ត្រីអ្នកកំសត់ដែលគ្រាន់តែគេអោយសំពត់ ស្លៀកដណ្តប់ប៉ុណ្ណោះ ក៏ព្រមចូលទៅនៅធ្វើជាភរិយា ។

**១៥_ឱទបត្តកិនី** ស្ត្រីដែលគេផ្ទោមនៃជាមួយនឹងបុរស ជ្រលក់ទៅក្នុងពាងទឹក ឬផ្តិលទឹកមួយហើយគេពោលថា អ្នកនាងទាំងឡាយចូរច្រឡំគ្នា ចូរកុំបែកបាក់គ្នាដូចជាទឹកនោះ ។

**១៦_ឱភតចុម្ពដា** ស្ត្រីដែលគេដាក់ទំនួលចុះអំពីក្បាល គឺស្ត្រីអ្នករកឧសជាដើម ដែលបុរសណាមួយជួយដាក់ទំនួលអំពីក្បាល ហើយនាំយកទៅធ្វើជាភរិយា ។

**១៧-ទាសី ច ភរិយា ច** ស្ត្រីដែលជាទាសីផង ជាភរិយាផង គឺស្ត្រីជាទាសីរបស់របស់ណាមួយហើយបុរសនោះយកធ្វើជាភរិយា ។

**១៨-កម្មការី ច ភរិយា ច** ស្ត្រីដែលជាកូនឈ្នួលគេផង ភរិយាផង គឺស្ត្រីដែលចូលទៅនៅធ្វើការស៊ីឈ្នួលអោយគេ ហើយមានបុរសណាមួយ ឬក៏ដង្ហៅរបស់ខ្លួននោះទៅនៅរួមសង្វាសជាមួយដែលត្រូវការដោយភរិយារបស់ខ្លួន ។

**១៩-ធជាហដា** ស្ត្រីដែលសេនានាំកដោយទង់ជ័យ គឺស្ត្រីដែលសេនាដំឡើទង់ជ័យលើកទ័ពទៅច្បាំង ដណ្តើមដែនរបស់ស្តេចដទៃ ហើយគៀរយកមកហើយមានបុរសណាមួយយកធ្វើជាភរិយា ។

**២០-មុហុត្តិកា** ស្ត្រីដែលមានបុរសទៅភពប្រសប់តែមួយស្របក់ ៗ គឺស្ត្រីដែលជាសហាយស្មន់ របស់បុរសណាមួយ ។

ស្ត្រី ២០ ជំពូកនេះ ជាស្ត្រីមានកម្មសិទ្ធ គឺមានគេថែរក្សាហួងហែងបុរសដទៃកុំគប្បីប្រព្រឹត្តខុសក្នុងផ្លូវកាម ។

ពាក្យថ ១" ទុស្ត នឹងប្រពន្ធកូនអ្នកដទៃ " មានន័យថា បណ្តាមនុស្សទាំងអស់ក្នុងសកលលោក តែងមានការថែរក្សាហួងហែង ក្នុងផ្លូវកាមជានិច្ច មិនចង់អោយជនណាមួយប្រមាថ មើលងាយបៀតបៀនបំពៀរបំពាន រលោករលាំឈើនពើនឈ្លានពាន ប៉ះពាល់នូវកាម ដែលជាកម្មសិទ្ធរបស់ខ្លួន, ប្រសិនបើនរណាម្នាក់ហ៊ាន ប្រព្រឹត្តរំលោភដោយហេតុ

ណាមួយ គេតែមានវិប្បដិសារី សេចក្ដីក្ដៅក្រហាយ ចំពោះនរជននោះជាយ៉ាងក្រៃលែង គេតែងរកមធ្យោបាយ ដើម្បីទប់ទល់នឹងអ្នកនោះជាមិនខាន ។

អ្នកដែលហ៊ានប្រព្រឹត្តរំលោភទៅលើប្រពន្ធកូនដទៃ មានទោសច្រើនប្រការណាស់ គឺត្រូវអន្តរាយដោយឧបាយកល អ្នកដែលជាកម្មសិទ្ធរបស់កាម នោះជាដាច់ខាត បើមិនអន្តរាយដោយទ្រព្យសម្បត្តិ ក៏ត្រូវអន្តរាយដោយហេតុណាមួយ រហូតដល់អន្តរាយទាំងជីវិត ក៏សឹងមាន, ទីបំផុតត្រូវទទួលរងទុក្ខក្នុងអបាយណាមួយដោយពិតប្រាកដ ហេតុនោះជាប្រធាននៃសេចក្ដីវិនាស ដូចសេដ្ឋីបុត្ត ៤ នាក់ដែលពោលមកហើយពីខាងដើម ។

## សេចក្ដីសង្រួមក្នុងកាម

សេចក្ដីសង្រួមក្នុងកាម បានដល់កិរិយា ដែលមិនប្រព្រឹត្តល្មោភក្នុងកាម ធ្វើសេចក្ដីត្រេកអរ ក្នុងកាមតាមដែលមាននៅគុណខនេះ ចាត់ថាជាធមិសំខាន់ ដែលអាចគាំទ្រសីលសិក្ខាបទទី ៣ អោយគង់វង់មាំមួននិងជាគ្រឿងញ៉ាំងសេចក្ដីបរិសុទ្ធិ របស់បុរសស្ត្រីអោយភ្លឺស្វាង អ្នកដែលវៀរចាកកាម តែនៅប្រព្រឹត្តខ្លួនអោយជាមនុស្សល្មោភកាម ក៏ត្រូវចាត់ថាជាអ្នកមានមន្ទិល មិនជាអ្នកបរិសុទ្ធល្អ ។ សំរាប់បុរសកាលមានភរិយាហើយ ក៏ត្រេកអរពេញចិត្តតែក្នុងភរិយារបស់ខ្លួនមិនគួរទៅសម្លុពគប់

សម្ផស្ស និងស្ត្រីដទៃកាលខ្លួនមានហើយយ៉ាងណា ក៏គប្បីតាំងសេចក្តីឧស្សាហ៍ មើលចិញ្ចឹមទៅ ទោះបីក្រខ្សត់ អត់ឃ្លានយ៉ាងណា ក៏មិនលះបង់ចោលគ្នា នេះបានឈ្មោះថា ជាអ្នកតាំងនៅក្នុងសទាសន្តោស ប្រែថាត្រេកអរ តែក្នុងភរិយារបស់ខ្លួន អ្នកប្រតិបត្តិខ្លួនបានដូចរមែងជាទីគួរសរសើរ ទាំងជាទីស្រឡាញ់ និងជាទីទុកចិត្តរបស់មនុស្សដទៃផង ។ សំរាប់ស្ត្រីកាលមានស្វាមីហើយ ក៏ត្រេកអរតែក្នុងស្វាមីរបស់ខ្លួន មិនទៅស្មន្ធសម្ពន្ធករ នឹងប្រុសដទៃ សូម្បីស្វាមីរបស់ខ្លួនឹងដល់នូវសេចក្តីក្រខ្សត់ទុគិត យ៉ាងណាក៏ដោយ ក៏មិនសំដែងការជិនណាយ ឬមាក់ងាយ នៅតែស្មោះត្រង់ក្នុងស្វាមីរបស់ខ្លួន រមែងជាទីទំនុកបំរុងទុកចិត្តរបស់ស្វាមី នឹងជាសរសើររបស់ជនទូទៅ ។

ម្យ៉ាងទៀតប្រុសដែលមានភរិយាហើយ ឬមិនទាន់មានក្តី ហើយនៅសេពសម្ភព គប់នឹងស្រីដទៃ មានស្រីពេស្យា ផ្កាមាសជាដើម សូម្បីមិនចាត់ជាកាមេសុមិច្ឆាចារ ក៏ថាជាហេតុអោយបានទទួលសេចក្តីអន្តរាយច្រើនប្រការគឺ :

**ក**/ ត្រូវខូចទ្រព្យសម្បត្តិ ព្រោះការទំនុកបំរុងស្រីនោះ តាំងពីត្រូវចាយក្នុងការនាំដើរលេង និងបរិភោគ ដេកនៅជាដើម ទៅដែលជារឿងមិនគួរចំណាយ ។

**ខ**/ជាអណ្តូងកើតនៃរោគ បណ្តារោគទាំងអស់ រោគដែលកើតពីស្រីពេស្យា ដែលហៅថាកាមរោគ ទោះរាប់ថាជារោគសាហាវកំណាច ម្យ៉ាងអាចធ្វើអោយអវៈយវៈរាងកាយ វិកលវិការទៅបាន ក្នុងទីបំផុតក៏ដល់នូវសេចក្តីស្លាប់ បើមិនស្លាប់ រោគនោះអាចឆ្លងដល់ភរិយា និងកូនរបស់ខ្លួនធ្វើអោយភរិយា និងបុត្ររបស់ខ្លួន បានទទួលសេចក្តីទុក្ខទៅផង ។

**គ**/ ជិតចំពោះអន្តរាយ ក៏ធម្មតាស្រីពេស្យារមែងធ្វើសេចក្តីស្នេហាស្រលាញ់ប្រុសច្រើនគ្នា កាលប្រុសកើតមានសេចក្តីហួងហែង ក៏នឹងកើតចំលោះទាស់ទែងគ្នាខ្លះ ធ្វើអន្តរាយដល់រាងកាយគ្នាខ្លះ ចងអាឃាតព្យា-បាទគ្នាខ្លះ ។

សំរាប់ស្រ្តីដែលគ្មានស្វាមី ក៏មិនគប្បីទៅចងមេត្រីស្រឡាញ់ប្រុស ទោះជាប្រុសដែលច្បាប់មិនហាម ក៏មិនគួរព្រោះហេតុនាំអោយស្មុយអាសោចិ៍ ខូចកេរ្តិ៍ឈ្មោះអស់តម្លៃ ក្ស័យកិត្តិយសរបស់ស្រ្តី ជួនកាលអាចអស់ទ្រព្យអភ័ព្វខ្លួន ព្រោះចាញ់បោកបុរសក៏មាន ។ ទោសកំហូចខូចកំហុស ជ្រុះទ្រព្យ អភ័ព្វខ្លួនជួបជួន និងរោគខូចកិត្តិយស អស់តម្លៃព្រមទាំងសេចក្តីក្តៅក្រហាយស្តាយក្រោជាច្រើន ដូចបានសំដែងមកហើយនេះ ព្រោះតែមិនសង្រួម មិនសន្តោសក្នុងកាមជាហេតុ ។ ពិតមែនហើយកាមគុណមិនងាយមាននរណា នឹងលះបង់បាន ប៉ុន្តែទោះជាដូច្នោះ ក៏ត្រូវមានព្រំដែន មានស្វាមីភរិយាតាមលោកប្រវេណី ហើយបណ្តុះសេចក្តី

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រឡាញ់ស្មោះត្រង់តែនឹងស្វាមីភិរិយារបស់ខ្លួន កុំអោយរាលដាលពាលកាលស្រើបស្រាល គ្មានព្រំដែនហៅថាគ្មានសន្តោសអាចអោយទោសទុក្ខទណ្ឌច្រើនប្រការ ។

ហេតុនេះទើបលោកប្រៀនប្រដៅ អោយសង្រួមសន្តោសក្នុងកាមគុណ, កាលបើចិត្តសន្តោសសង្រួមក្នុងកាមបានហើយ ការរក្សាសីលសិក្ខាបទទីពក៏នឹងតាំងនៅបានរឹងមាំមួន ជួបជួនសេចក្តីសុខសាន្ត ក្នុងគ្រួសារផង មិនរលោះអស់ទ្រព្យ ខុសទំនងផង មិនខូចកេរ្តិ៍ឈ្មោះផង មិនកើតកាមរោគផ្សេងៗផង ។ ហេតុនេះសេចក្តីសង្រួម ឬសន្តោសក្នុងកាម ទើបលោករាប់ថា ជាកល្យាណធម៌ធ្វើអោយល្អ ឬធម៌សំរាប់មនុស្ស គប្បីអនុវត្តអោយសមស្រប ។

## រឿងព្រះយសត្ថេរ

អ្នកឃើញទោសក្នុងកាមគុណ ព្រះយសត្ថេរលោកជាបុត្រនៃនាងសុជាតា ដែលបានថ្វាយមធុយាសដល់ព្រះអង្គ, នៅក្នុងក្រុងពារាណសី ។ លោកមានគ្រឹះស្ថាន ៣ ខ្នងសំរាប់នៅក្នុងរដូវទាំងបី ។

វេលាយប់ថ្ងៃមួយ យសកុលបុត្រដេកលក់មុនទៅ ពួកស្រីបរិវារដេកលក់តាមក្រោយ ពន្លឺភ្លើងនៅភ្លឺស្វាង យសកុលបុត្រភ្ញាក់ឡើងមុនឃើញបរិវារកំពុងដេកលក់ មានអាការវិកល គឺនាងខ្លះពិលាធ្លាក់មកនៅនឹងក្លៀក, នាងខ្លះមានស្គរសម្ភោនៅនឹងក, នាងខ្លះរំសាយសក់,

Websites: WatKhemaraRatanaram.org or WatKhmers.org

នាងខ្លួហដេកហូរទឹកមាត់ នាងខ្លះតៀតដេកសង្កៀតធ្មេញ មមើមមាយផ្ដេសផ្ដាស, យសកុលបុត្រឃើញប្រាកដ ដូចជាសាកសព ដែលគេយកទៅចោលក្នុងព្រៃស្មសាន ។ យសកុលបុត្រឃើញដូច្នោះក៏កើតនិព្វិរាធុញទ្រាន់នឿយណាយ កើតសង្វេកក្នុងចិត្ត ហើយបន្លឺឧទានវាចាថា: ទីនេះរឹកវរណាស់ " ។ យសកុលបុត្រកាលបើនឹករំខានក្នុងចិត្ត ក៏ពាក់ស្បែកជើរចុះពីមាត់ទ្វារផ្ទះ ហើយចេញទៅតាមទ្វារស្រុក រួចសំដៅទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ពេលនោះបានជួបនឹងសាស្ដាដែលកំពុងយាងចង្រ្កមក្នុងឱកាសស្រឡះ ព្រះអង្គទ្រង់ឮសំឡេង យសកុលបុត្រពោលដូច្នោះហើយព្រះងង្គទ្រង់ត្រាស់ថា " ទីនេះមិនរឹកវរ ទីនេះឥតទាក់ទិន ចូរអ្នកចូលមកអង្គុយទីនេះចុះ តថាគតនឹងសំដែងធមិអោយអ្នកស្ដាប់ " ។

ព្រះសាស្ដាទ្រង់ប្រមើលមើលឃើញឧបនិស្ស័យចាស់ក្លារបស់យសកុលបុត្រដូច្នោះហើយ ទើបព្រះអង្គទ្រង់សំដែងនូវអនុបុព្វិកថា ដើម្បីដុះខាត់ចិត្តយសកុលបុត្រអោយឃ្លាតឆ្ងាយចាកសេចក្ដី តម្រេកក្នុងកាមឧបមាដូចជាសំពត់សស្អាតឥតមន្ទិល គួរទទួលទឹកច្រលក់ដូច្នោះឯង ។ បន្ទាប់មកទ្រង់សំដែងនូវអរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើម យសកុលបុត្រ បានសំរេចធម្មចក្ខុ "ភ្នែកឃើញធមិ " គឺសោតាបត្តិផល ។

និយាយពីសេដ្ឋី កាលបើដឹងថាបាត់ យសកុលបុត្រដូច្នោះហើយក៏ចេញទៅតាមរកបានជួបនឹងព្រះសាស្ដាព្រះអង្គសំដែងអនុបុព្វិកថា នឹង

អរិយសច្ចទាំង ៤ ដល់សេដ្ឋីជាបិតានៃយស ។ សេដ្ឋីកាលបើបានសំរេចធម្មចក្ខុហើយ បានក្រាបទូលសរសើរព្រះធម្មទេសនា ហើយបានថ្វាយខ្លួនជាឧបាសក គឺសូមដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក ជាឧបាសកមុនគេបង្អស់ក្នុងលោក ។ កាលបើសេដ្ឋីក្រាបថ្វាយបង្គំព្រះសាស្តា ត្រឡប់ទៅវិញហើយ ទើបយសកុលបុត្រក្រាបថ្វាយបង្គំទូលសុំឧបសម្ប័ទ ព្រះសម្ពុទ្ធបរមគ្រូទ្រង់ប្រទានអោយដោយវិធីឯហិភិក្ខុឧបសម្បទា ។

យសកុលបុត្រ និងសេដ្ឋីជាបិតា បានទទួលស្តាប់ព្រះធម្មទេសនាដែលព្រះអង្គទ្រង់សំដែង ឯមាតា និងភរិយាបានស្តាប់ព្រះធម្មទេសនា ដែលព្រះសាស្តាសំដែង គឺក្នុងពេលដែលព្រះសាស្តា និងព្រះយសស្តេចទៅដល់ផ្ទះសេដ្ឋីហើយ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថា និងអរិយសច្ចទាំង ៤ មានទុក្ខជាដើម ។ ឯមាតានិងភរិយា បានស្តាប់ធមិទេសនា ហើយបានថ្វាយខ្លួនជាឧបាសិកាក្នុងសាសនា គឺសូមដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកជាឧបាសិកា មុនគេបង្អស់ក្នុងលោក ។

**កាមុប្បាទាន** ប្រកាន់ខ្ជាប់ក្នុងកាមមាន ៨ យ៉ាងគឺ :

**១-យោ កាមច្ឆន្ទោ** សេចក្តីគាប់ចិត្តក្នុងកាម

**២-កាមរាគោ** សេចក្តីត្រេកអរក្នុងកាម

**៣-កាមនន្ទិ** សេចក្តីត្រេកអរក្នុងកាម

**៤-កាមតណ្ហា** សេចក្តីប្រាថ្នាក្នុងកាម

**៥-កាមសិនេហោ** សេចក្ដីជាប់ជំពាក់ក្នុងកាម
**៦-កាមបរិឡាហោ** ការជាប់វាក់វិនក្នុងកាម
**៧-កាមមុច្ឆា** ការជ្រប់ចិត្តនៅក្នុងកាម
**៨-កាមជ្ឈោសានំ** កិរិយាសញ្ជប់សញ្ជឹងនៅក្នុងកាម ។

## ទោសរបស់កាមគុណ

កាមេសុមិច្ឆាចារៈ បានខាងអំពើ ដែលប្រព្រឹត្តខុស ក្នុងកាមទាំង-ឡាយ បើជាបុរសបានខាងអំពើដែលលបលាក់ប្រព្រឹត្តមោះមិនគាប់ នឹងភរិយាអ្នកដទៃ, បើជាស្ត្រីបានខាងអំពើដែលកន្លងចិត្តស្វាមីរបស់ខ្លួន ទៅប្រព្រឹត្តមោះមិនគាប់ នឹងបុរសដទៃ ។ បណ្ដាមនុស្សក្នុងលោករមែងហួង-ហែងក្នុងកាមជាធម្មតា, បើបានអាស្រ័យនៅនឹងស្រីឯណានីមួយ ដែលដាច់ស្រេចថាជាប្រពន្ធរបស់គេហើយ, គេតែស្រឡាញ់ហួងហែងរក្សាទុកមិនចង់អោយប្រុសដទៃមកប្រព្រឹត្តល្មើសនឹងស្ត្រីនោះទេ ។

ម្យ៉ាងទៀត បើគេស្ងួនក្រងរក្សាស្រីឯណាដែលជាកូនរបស់គេដោយប៉ងថា និងរៀបចំទុកដាក់ អោយបុរសណាមួយដែលគេស្រឡាញ់ពេញចិត្តមកដល់ដណ្ដឹតតាមប្រវេណី, គេមិនចង់អោយបុរសដទៃទៅប្រព្រឹត្តល្មើសកន្លងប្រវេណីនោះឡើយ ។ បើមានបុរសណាម្នាក់ទៅលបលួចប្រព្រឹត្តល្មើសកន្លងប្រវេណី នឹងស្រីនោះបុរសនោះបានឈ្មោះថាធ្វើអោយគេពិបាកចិត្ត ជាហេតុនាំអោយខូចសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀង

របស់គេដរាបដល់ឈ្លោះប្រកែកជេរប្រទេច ផ្តាសារវាយដុំច្រំធាក់ ចាក់កាប់សម្លាប់គ្នាក៏មាន ។ ទោសដែលមិនឃើញ និងស្លាប់ ឮក្នុងបច្ចុប្បន្នក៏មានច្រើន បើទុកជាចេះលាក់បិទបាំង មិនអោយឃើញទោសក្នុងជាតិនេះ ក៏គង់តែឃើញទោសទៅក្នុងជាតិខាងមុខ គឺទៅរងទុក្ខក្នុងអបាយភូមិមាននរកជាដើមមិនខាន, ដូចព្រះនាងមល្លិកា សូមនាំនិទាននោះមសំដែងជាឧទាហរណ៍ដូចតទៅនេះ :

## " រឿង នាងមល្លិកា "

ព្រះនាងមល្លិកានោះ ជាព្រះទេពីព្រះបាទបសេនទិកោសល មហាក្សត្រក្រុងសាវត្ថី ព្រះនាងទ្រង់ប្រព្រឹត្តមោះមិនគាប់នឹង សុនខដែលស្និទ្ធស្នាល ។ កាលបើព្រះមហាក្សត្រទ្រង់ជ្រាបហើយត្រាស់សួរព្រះនាងក៏ក្រាបបង្គំទូលបំភ្លៃ សេចក្តីនោះត្រឡប់ជអោយមហាក្សត្រទ្រង់ជឿងថាព្រះនាងទ្រង់ស្មោះពិត ឥតប្រព្រឹត្តខុសទៅវិញ ។ ព្រះនាងមល្លិកានោះជាស្ត្រីមានសទ្ធាជឿព្រះពុទ្ធសាសនា បានធ្វើការកុសលជាច្រើនដែរត, តែក្នុងវេលាដែលនាងទៀតអស់ព្រះជន្ម មិនមាននឹកដល់ការកុសលទាំងនោះ នឹងតែអំពើដែលប្រព្រឹត្តល្មើស អំពើនោះក៏នាំព្រះនាងធ្លាក់ទៅកើតក្នុងនរកឈ្មោះអវិចីអស់ ៧ ថ្ងៃ គិតតាមថ្ងៃមនុស្សលោក ។

លុះរំដោះខ្លួនចាកទីនោះមក បានទៅកើតក្នុងឋានតុសិតដោយអំណាចកុសលដែលព្រះនាងធ្វើទុកជាច្រើន ។ នាំរឿងនោះមកដើម្បី

ពន្យល់អោយឃើញថា អំពើដែលប្រព្រឹត្តកាមេសុមិច្ឆាចារនោះ ទោះបីចេះលាក់បិទបាំង ឬកែខ្លួនអោយរួចទោសក្នុងជាតិនេះ ក៏គង់តែត្រូវទទួលទោសទៅក្នុងជាតិឯមុខមិនខាន ។

លុះរំដោះពីនរកមក ៗកើតជាសត្វ អោយគេក្រៀវពូជ ឬកើតជាមនុស្សខ្ទើយច្រើនជាតិ ។

ព្រោះហេតុដូច្នោះ អំពើដែលប្រព្រឹត្តកន្លងប្រវេណី នឹងស្ត្រីដែលគេហួងហែងថែរក្សាទើបឈ្មោះថា " បាប " ជាអំពើអាក្រក់មិនគួរធ្វើទេ ។

អ្នកប្រាជ្ញទាំងឡាយដែលជឿកម្ម និងផលរបស់កម្មលោកមិនប្រព្រឹត្តកន្លងប្រវេណី នឹងស្ត្រីដែលគេហួងហែងរក្សានោះឡើយ, លោកប្រព្រឹត្តសន្តោសត្រេកអរតែនឹងភរិយាស្វាមីរបស់ខ្លួន ។ មិនតែប៉ុណ្ណោះអ្នកប្រាជ្ញខ្លះ ច្រើនមិនគ្រប់គ្រាន់ ចំពោះកាមសមនឹងព្រះពុទ្ធដីកាត្រាស់ថា **កាមេ លោកម្ហិ ន អតិតិត្តិ,** សេចក្តីឆ្អែតដោយកាមទាំងឡាយ មិនមានក្នុងលោកឡើយ ។

**ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ** សេចក្តីឆ្អែតក្នុងកាមទាំងឡាយ ដោយភ្លៀងគឺកហាបណ មិនមានឡើយ ។ **នត្ថិ កាមា បរំ ទុក្ខំ** សេចក្តីទុក្ខក្រៅពីកាមមិនមាន ។

**កាមាទីនវៈ** ទោសរបស់កាម :

Websites: WatKhemaraRatanaram.org or WatKhmers.org

មនុស្សលោក្តី ឋានសួគិក្តី ដែលហៅថាទេវលោកក្តី លោកចាត់ជាកាមភព ។ ចិត្តរបស់មនុស្ស និងទេព្តា ក្នុងកាមភពនេះ សឹងត្រឡប់ត្រឡិន អន្ទោលអន្ទោកទៅមក១ តែនឹងរឿងកាម ។ ភូមិនៃចិត្តរបស់អ្នកកើតក្នុងកាមភព ដែលមិនទាន់បានលុះមគ្គផល ទើបលោកហៅថា កាមាវចរភូមិ ។ កាលសេចក្តីសុខក្នុងកាម ជាសុខដែលគួររីករាយចិត្តថ្លើមរបស់ពួកមនុស្ស ទេព្តាក្នុងកាមភព នេះទើបឃើញបានថា កំពូលនៃសេចក្តីប្រាថ្នា របស់អ្នកកើតក្នុងកាមភព មិនមានអ្វីអោយក្រៃលែងជាងកាមគឺចំណង់ ។ គួរពិចារណាពាក្យថា " កាម " អោយចូលចិត្តជាមុន កាមគឺ ចំណង់នោះលោកចែកជា ២ យ៉ាងគឺ **កិលេសកាម** កិលេសជាគ្រឿងចង១, **វត្ថុកាម** វត្ថុ ឬ អារម្មណ៍ជាគ្រឿងចង ១ ។

អ្នកដែលជួបសេចក្តីសុខយ៉ាងខ្ពស់ក្នុងកាមភព ក៏មិនមានអ្វីក្រៃលែងជាងសេចក្តីភ្លើតភ្លើន ត្រេកត្រអាល ស្រើបស្រាល ក្នុងអារម្មណ៍ដែលខ្លួនបំណងប៉ងប្រាថ្នា អារម្មណ៍នោះ គឺរបស់ដែលឃើញដោយភ្នែក១ ស្តាប់ដោយត្រចៀក១ ធុំក្លិនដោយច្រមុះ១, ដឹងជាតិដោយអណ្តាត១ ប៉ះពាល់ដល់ត្រូវដោយកាយ១ ហៅអោយខ្លី១ថា រូប សម្លេង ក្លិន រស សម្ផស្ស ។ សេចក្តីប្រាថ្នារបស់សត្វលោកដោយច្រើន ឬទាំងអស់ ក៏គឺជារបស់ខ្លួន មិនថាបុត្រ ឬស្វាមី រហូតដល់គ្រឿងប្រើប្រាស់ ក៏ចូលចិត្តតែល្អ១ ជាទីពេញភ្នែក សំឡេងដែលបានឮ ក៏ចូលចិត្តតែសំឡេងពីរោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ផ្អែមល្ហែម ក្លិនក៏ចូលចិត្តហិតថើប ផុំតែក្លិនក្រអូប រសក៏ចូលចិត្តតែឈ្ងុយឆ្ងាញ់ ឬប្លែកៗ ចំណែកសម្ផស្ស ក៏ចូលចិត្តតែរលីងរលោង រលើប ។ ការតែងតួស្អាតល្អប្រិមប្រិយ៍ ក៏ដើម្បីអោយត្រូវភ្នែក មនុស្សដទៃ ឬដើម្បីអួតសេចក្តីល្អដែលម្ចាស់ខ្លួនដឹងថាខ្លួន ក៏ល្អដែរដូចនោះជាដើម ។

តាមដែលពោលមកនេះ ក៏ល្មមឃើញបានដល់ ការដែលមនុស្សឬទេព្តាពិតៗ នាំគ្នាចូលចិត្តជក់ជោគ ជាប់ចង់ចំណង់ នឹងរូប សំឡេង ក្លិន រស សម្ផស្ស ដោះដៃមិនរួច ។ មនុស្សចង់ទៅកើតស្ថានសួគ៌ ក៏ដោយនឹកថាឋានសួគ៌មានអារម្មណ៍ល្អ លើសជាងមនុស្ស សូម្បីទេព្តាឯង ក៏មិនចង់ចេញចាកស្ថានសួគ៌ ព្រោះស្តាយរូប សំឡេង ក្លិន រស សម្ផស្សជាទិព្វ តែស្ថានសួគ៌ក្នុងជីវិតរបស់មនុស្ស ឬស្ថានសួគ៌ពិតៗរបស់ទេព្តាក្តី មានអ្វីដែលគង់វង់ស្ថិតស្ថេរខ្លះ ? អារម្មណ៍ផ្សេងៗ ដែលគិតថាជាសុខនោះ ក៏ត្រឹមតែមួយពោល មួយខណៈប៉ុណ្ណោះ ។

សូម្បីមិនវិនាសប្រាស់ព្រាត់ខ្ចាត់ខ្ចាយបាយនះ សូនទៅចាកយើងមុន យើងក៏គង់ត្រូវស្លាប់ចាកលអារម្មណ៍ទាំងនោះទៅមុន សេចក្តីសុខក្នុងលោក ជាសុខដែលបញ្ឆោតចិត្ត ព្រោះជាកាមសុខ គឺសុខព្រោះយើងចង់កាលរបស់នោះៗ ប្រែប្រួលទៅ ក៏ធ្វើអោយសោកសៅក្តៅក្រហាយតក់ក្រហល់បត់ប្រមល់ទល់ពុទ្ធោ ខ្វក់ខ្វល់ក្រៀមក្រំចិត្ត អ្នកដែលមានហើយមិនចេះល្មម ខំស្វែងរកមកបាននៅត្រូវកង្វល់ខ្លាច អន្តរាយទៅវិញ ។

សង្គ្រាមក្នុងកាមភពនេះ ទាំងដែលមានមកហើយទាំងដែលកំពុងមានហើយ នឹងមានតទៅ រមែងកើតព្រោះកាមទាំងអស់ ដូចនឹងឃើញបានថា ការតស៊ូដើម្បីដណ្តើមស្រ្តីរបស់បុរសប្រុសកម្លោះ ដែលជាហេតុដល់ស្លាប់ ឬត្រូវចុះទោសនោះ ក៏ព្រោះកាមជាហេតុ ការតស៊ូរវាងប្រទេស និងប្រទេស ដើម្បីសេចក្តីចំរើនរបស់ចំណែកខ្លួន ឬ ដើម្បីដណ្តើមសម្បត្តិវត្ថុ ឬឫទ្ធិអំណាចក៏មានកាមជាហេតុ ឬមិនដូច្នោះ ខំប្រឹងប្រែងស្វែងរក ទ្រព្យសម្បត្តិបានមកហើយ នៅមិនទាន់បានចាយវាយ ប្រើប្រាស់អោយសុខចិត្ត ទ្រព្យនោះក៏វិនាសទៅដោយចោរភ័យអគ្គិភ័យ ឧទកភ័យខ្លះល្មម នឹងរកសេចក្តីសុខ បានក៏ស្លាប់ចោលទៅ ។

ទេវតាទាំងឡាយ ដែលមានក្នុងច្បាប់ផ្សេងៗ ពណ៌នាទុក ក៏គ្រប់គ្រងសេចក្តីសុខទៅបានត្រឹមធ្វើសេចក្តីល្អ ទុកកាលអស់បុណ្យក៏ទៅកើតក្នុងទីដទៃតទៅ ខ្លះទៀតដែលធ្វើទុកទាំងល្អ ទាំងអាក្រក់ ផលសេចក្តីល្អនាំអោយកើតជាទេវតាមុន អស់កាលសេចក្តីល្អហើយ ផលរបស់សេចក្តីអាក្រក់ ក៏ស្ទួងនាំទៅកើតជានរកក៏មាន ។ កាមធ្វើអោយមនុស្សភ្លេចខ្លួនភ្លេចស្លាប់ ធ្វើអោយសុខមួយដង មួយយាមហើយ ធ្វើអោយទុក្ខច្រើន ព្រោះខ្លាចក្រែងរបស់ដែលខ្លួន ស្រឡាញ់នោះ ប្រែប្រួលវិនាស ឬផ្លាស់ដៃទៅជារបស់មនុស្សដទៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាមធ្វើអោយមនុស្សវង្វេងវង្វាន់ ភ័នច្រឡំ អោយឥច្ឆាឈ្នានិសគ្គា នឹងខ សំខាន់បំផុត គឺធ្វើអោយមនុស្សឃើញសុខក្នុងទុក្ខ ធ្វើអោយមនុស្ស វិលស្លាប់វិលកើតក្រខ្លះ មានខ្លះ ឡើងស្ថានសួគ៌ខ្លះ ជាតិរច្ឆានខ្លះ ជាមនុស្សខ្លះ មិនរួចទៅចាកសង្សារវដ្តបាន ។ កាលឋានៈ ឬសភាពតាម ពិតរបស់ឋានសួគ៌ កាមសុខទាំងរបស់មនុស្ស និងទេព្តា មិនមានសេចក្តី គង់វង់គត់មត់អ្វី មានហើយក៏ចូលជាគ្មាន មានហើយក៏យកជារបស់ខ្លួន មិនបានត្រូវស្លាប់ ឬ ចតុទាំងសម្បត្តិ គឺរូប សំឡេង ជាដើម, ទុកជារបស់ មនុស្សដទៃទៅ ដូចនេះកាមសុខជាសុខ ទាក់ទងដោយអាមិសគឺ ជំពាក់ ដោយគ្រឿងល្បួងលោមមានទុក្ខនៅច្រឡំ បល់មិនមែនជាសុខពិតឡើយ ។ ការបូជាយ័ញ្ញរបស់មនុស្សសម័យបូរាណ ដើម្បីអោយទេវតាចូលចិត្តក្តី ដើម្បីអោយជាទេវតាក្តី សុតតែមានបំណងប៉ងចំពោះកាមសុខ មានរូប សំឡេងជាដើម ព្រោះហេតុនោះបាន ជាលោកជដិលឧរុវេលកស្សបៈ ដែលពីដើមនិយមបូជាយ័ញ្ញសំដៅទៅស្ថានសួគ៌ ។

លុះមកដល់ព្រះពុទ្ធជាម្ចាស់ បានស្តាប់ធម៌ទេសនា កើតសទ្ធាជ្រះ-ថ្លានឹងព្រះសាស្តា ក៏លះចោលលទ្ធិនោះ ទើបប្រកាសដល់ប្រជុំជនមានព្រះ-បាទ ពិម្ពិសារជាប្រធានថា " យ័ញ្ញទាំងឡាយសរសើរ កាមមនុស្សស្រី យ៉ាងខ្ពស់ ព្រោះដូច្នោះលោកឃើញជាមន្ទិល ទើបលះចោលមកធ្វើតាម ឱវាទរបស់ព្រះពុទ្ធជាម្ចាស់ ដែលនាំអោយរកសេចក្តីស្ងប់ ដោយការចេញ

ចាកកាម ជាសេចក្តីសុខដែលហៅថា សន្តិសុខ ។ ដូចពោលមកនោះ ក៏ឃើញបានថាឋានសួគ៌ មិនមែនរបស់ល្អអ្វីណាស់ ព្រោះល្អមិនឃឹតយូរ ក្នុងដំណាលរបស់សាសនាផ្សេងៗឯង ក៏នៅមានទេវតាច្បាំងចាក់កាប់ ឥច្ឆាឬស្យាគ្នា ប្រណាំងប្រជែងដណ្តើមគ្នា ធ្វើជាម្ចាស់ធំ ព្រោះហេតុនោះ ព្រះពុទ្ធសាសនា មិនកាន់ឋានសួគ៌ជាដាច់ខាត ឬជាកំពូលបំណង់យ៉ាងខ្ពស់បំផុតឡើយ ។

កាលព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ត្រាស់រឿងទាន និងសីល ហើយពណ៌នាអានិសង្សរបស់ទាន សីលដោយលើកឋានសួគ៌ឡើងសំដែងអោយរីករាយចិត្ត ហើយទើបពណ៌នា ទោសរបស់កាម ដែលអោយឃើញថា សូម្បីសុខក្នុងឋានសួគ៌ ក៏មិនទៀងទាត់ ដូចពោកមកហើយនេះ ក្នុងលំដាប់តទៅ ព្រះអង្គទើបត្រាស់នេក្ខម្ម គឺការចេញចាកកាម ឬ អានិសង្សរបស់ការបួស ។

**នេក្ខម្មានិសំសៈ** អានិសង្សចេញចាកកាម

ការវិលត្រឡប់ស្លាប់កើត សោយសុខខ្លះ ទុក្ខខ្លះ និងដោយច្រើនសោយទុក្ខ ព្រោះមនុស្សធ្វើ សេចក្តីអាក្រក់ ច្រើនជាងសេចក្តីល្អ ផលនៃសេចក្តីអាក្រក់ទើបអោយ សេចក្តីទុក្ខផ្សេងៗ ដូចដែលឃើញរាល់ថ្ងៃនេះ ហៅថាវដ្តសង្សារ ប្រែថា "ការវិលត្រឡប់ក្នុងវង់មូល " ។ វង់មូលនោះដាសពាលទៅ ដោយសេចក្តីកើត សេចក្តីចាស់ និងសេចក្តីស្លាប់ ។ នរណា

នឹងពិសេសពិស្តារយ៉ាងណា បើនៅកិលេស តណ្ហាក៏មិនរួចពីវដ្តសង្សារ ទៅបានឡើយ ។ សត្វទូទៅទើបនាំគ្នាត្រាច់រង្គាត់ក្នុងវដ្តសង្សារ ដែលវិល តគ្នា ៣ យ៉ាងគឺ កិលេសជាហេតុអោយធ្វើកម្ម កម្មជាហេតុអោយកើត ផលរបស់កម្ម ហៅថាវិបាក វិបាកជាហេតុអោយកើតកិលេសហៅខ្លីៗថា **កិលេសវដ្ត១ កម្មវដ្ត១ វិបាកវដ្ត១ ៗ** ទាំង ៣ នេះជាប់ទាក់ ទងគ្នា វិលចុះវិលឡើងជាដរាប មិនចេះចប់មិនចេះហើយ មិនឈប់ឈរ មិនអស់ផុត មិនមានទីបំផុត ព្រោះការស្លាប់ហើយក៏វិលកើត និងចាស់ ឈឺស្លាប់តទៅទៀត កើតហើយក៏វិលជាបាវព្រាវខ្ញុំកំដររបស់រាងកាយ ដោយាការរកអាហារមកចិញ្ចឹម រកគ្រឿងស្លៀកពាក់ ទីសំណាក់ផាក់ អាស្រ័យ រហូតដល់ថ្នាំកែរោគ ចំណង់ចង់បានមកទំនុកបំរុង រាងកាយនេះ តាំងតែពីកើតរហូតដល់ស្លាប់ទៅ នឹងត្រូវក្តៅក្រហាយ កាលមាននរណា មកជេរស្តី តិះដៀលរាងកាយនេះដែលសន្មត់គ្នាហៅថា អ្នកនេះ នាងនេះ អញឯងជាដើម ។ កណ្តាលចំហាយកំដៅថ្ងៃ យ៉ាងខ្លាំង ឬកណ្តាលភ្លៀង ផ្គររន្ទះ ក៏ត្រូវទ្រាំធ្វើការ ដើម្បីចិញ្ចឹមរាងកាយនេះទុក ការងារសូម្បីជា បាវព្រាវ ខ្ញុំកំដរ ក៏ព្រមអត់ទ្រាំ ដើម្បីសេចក្តីឆ្អែត ព្រោះរបស់ជីវិតខ្លួន នឹងប្រពន្ធកូនជាដើម នេះសំដែងអោយឃើញថា មនុស្សសត្វទាំងឡាយ នាំគ្នាជាទាសៈ យ៉ាងទាបបំផុតរបស់រាងកាយនេះ តែរាងកាយក៏នៅតែ មិនគង់ចង់ទៀតទាត់ស្ថិតស្ថេរ ដូចសេចក្តីប្រាថ្នាហើយ ដល់កាលវារទី

បំផុត ក៏រលត់រលាយចោលសេចក្តី ស្តោកស្តាយ អាឡោះអាល័យ និងសង្វេគ ទុកដល់ម្ចាស់រាងកាយដទៃៗ ដែលមានជីវិតរស់នៅ ។ រាងកាយនេះមិនគង់វង់តែងតែវិលលិចចុះរុះទ្រុឌទ្រោម បែកធ្លាយពាយរបស់រលីងទៅហើយត្រូវផ្លាស់កំណើតកើតជាថ្មីទៀត ។ ជាតិខ្លះកើតជាមនុស្សជាតិខ្លះកើតជាសត្វតិរច្ឆាន ជាតិខ្លះកើតជាសេដ្ឋី គហបតីកុដុម្ពិក៍ ជាតិខ្លះកាឡកិណ្ណី កើតជាអ្នកសុំទាន គ្មានទីពឹង ព្រោះហេតុដូច្នេះ សេចក្តីសុខក្នុងវដ្តសង្សារ ដែលរកបានក្រជាងសេចក្តីទុក្ខ ។

មនុស្សជំពូកខ្លះ ដែលគិតឃើញដូច្នោះ ដូចព្រះពុទ្ធជាម្ចាស់គ្រានៅសោយកាមសុខសម្បត្តិ ឬ យសកុលបុត្រ មានមនុស្សបំរើដោយកាមគុណដ៏គួរសប្បាយភ្នែកសប្បាយចិត្ត មាននារីសុទ្ធតែក្រមុំ ច្រៀងរាំបំពេរដោយតូរ្យតន្ត្រី អោយរីករាយ ប្រាសាទ និងទ្រព្យសម្បត្តិ សម្បូណ៌ឥតខ្ចះតែលោកក៏មានវេលាមួយ ដែលនឹកឃើញរបស់ទាំងនេះ ដូចព្រៃខ្មោចឃើញនារីទាំងឡាយ ដែលដេកលក់នៅដេរដាសដូចសាកសព ។

សេចក្តីវិនាសត្រឡប់ទាំងនោះ ប្រៀបដូចសេចក្តីងងឹត បើរកផ្លូវអោយភ្លឺស្វាងបាន ក៏ប៉ុន្តែគ្មានឹងរកឃើញផ្លូវធ្វើអោយរួចទុក្ខបាន ។ ទើបលោកពោលថា : វត្ថុទាំងឡាយ រមែងមានជាគូគ្នា ឬ ផ្ទុយគ្នា គឺមានងងឹតមានភ្លឺ មានត្រជាក់ មានក្តៅ កាលបើមានទុក្ខ ក៏ត្រូវតែមានសុខមានកើតចាស់ឈឺស្លាប់ ក៏ត្រូវមានមិនកើត មិនចាស់មិនឈឺ មិនស្លាប់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះពុទ្ធទ្រង់មានព្រះតម្រិះដូចនេះ ទើបលះសម្បត្តិទាំងពួងចេញទៅបួស កាលជាអ្នកចេញចាកកាមទាំងឡាយ តាំងកាយនិងចិត្តបានហើយអប់រំចិត្ត និងបញ្ញាអោយចំរើនពេញទីក៏មាន លុះដល់នូវសេចក្តីជាអ្នកមិនវិលត្រឡប់ស្លាប់កើតទៀតតទៅ ព្រោះមិនមានកិលេសដែលជាហេតុអោយធ្វើកម្ម ឬសោយផលរបស់កម្មជាវង់វិល ដូចបានសំដែង មកហើយ ។ ការចេញបួស " បួស " ប្រែថា វៀរទូទៅ គឺវៀរចាកសេចក្តី អាក្រក់ផ្លូវកាយ វាចា ចិត្ត នឹងមិនទាក់ទង នឹងកាមគុណទៀត, ជាឧបាយដែលនឹងស្ងប់បានងាយ ជាងការគ្រប់គ្រងផ្ទះ ព្រោះការនៅគ្រប់គ្រងផ្ទះ មានការជំពាក់ទាក់ទិន ដោយចំណងផ្សេងៗ មានកូនប្រពន្ធទ្រព្យសម្បត្តិជាដើម ។ កាលជាអ្នកស្ងាត់ចាកកាមទាំងកាយចិត្តដោយការហ្វឹកហាត់ចិត្តអប់រំចិត្ត អោយកើតបញ្ញា តាមច្បាប់ដែលព្រះពុទ្ធជាម្ចាស់ជួប ប្រទះនិងបញ្ញត្ត ទុកហើយរមែងជាហេតុអោយត្រាស់ដឹងនូវអរិយសច្ច ទាំង ៤ ប្រការដែលជាធមិខ្ពស់បំផុត ផ្លូវព្រះពុទ្ធសាសនា ជាហេតុអោយរួចចាកវដ្តសង្សារ មិនត្រូវកើត ចាស់ ឈឺ ស្លាប់ តទៅទៀតឡើយ ។

ការសំដែងមកក្នុងគាថា ទី៩ នៃបរាភវសូត្រដែលមានសេចក្តីទាំងស្រុងថា : បុរសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួននឹងស្រីពេស្យា ទ្រុស្តនឹងប្រពន្ធកូនគេនានា ហេតុនោះទៅជានាំអោយវិនាស ។

ការសំដែងមកនេះក៏សន្មត់

ថាចប់តែប៉ុណ្ណោះ ឯវំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# **ធម្មទេសនា បរាសូត្រ**

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

សូមនមស្សការ ថ្វាយបង្គំចំពោះព្រះភគវន្តមុនី អរហន្តសម្មា-សម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

**ពុទ្ធោ មេ នាថោ** ព្រះពុទ្ធជាទីពឹងនៃខ្ញុំ

**ធម្មោ មេ នាថោ** ព្រះធម៌ជាទីពឹងនៃខ្ញុំ

**សង្ឃោ មេ នាថោ** ព្រះសង្ឃជាទីពឹងនៃខ្ញុំ ។

បន្ទាប់អំពីបទមនស្សការ ដោយសង្ខេបបែបខ្លីនេះទៅ ៖

ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកគាថាទី១០ នៃបរាភវ-សូត្រ មកសំដែងប្រកាសចែកជូន អធិប្បាយបកស្រាយ រំគាយសេចក្តីពន្យល់ន័យ ដែលមានមកក្នុងផ្ទៃនៃព្រះគាថា ដើម្បីជាទីសណ្តាប់នៃពុទ្ធមាមិកជន ទាំងឡាយដែលបានអញ្ជើញ មកជួបជុំប្រមូលផ្តុំ ត្រៀបត្រាប្រាថ្នា ត្រងត្រាប់ស្តាប់អត្ថរសនៃព្រះសទ្ធម្មវិសេសទេសនា ដែលខ្ញុំព្រះ-ករុណាអាត្មាភាព នឹងសំដែងដូចតទៅនេះ ៖

ទេវតាទូលសួរតទៅទៀតថា ៖

**ឥតិហេតំ វិជានាម នវមោ សោ បរាភវោ នសមំ**

**ភគវា ព្រូហិ កឹ បរាភតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៩ ទាន់ហន់ បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែង ឱ្យទាន វិនាសទី ១០ អ្វីជាប្រធាននាំសត្វឱ្យមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**អតីត យោព្វនោ បោសោ អានេតិ តិម្ពរុត្ថនិ**

**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យដែលចាស់ហួសពេកហើយមានតម្រេ ដោយក្តីតណ្ហានាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំអោយវិនាស ។

**អធិប្បាយ**

**គាថាទី១០**

ពាក្យថា **វយះ** ប្រែថា " វ័យ " បានសេចក្តី " ចាស់ " ចំណាស់ជាន់ , ជំនាន់ ឬថ្នាក់ ។

វ័យលោកចែកចេញជា ៣ យ៉ាងគឺ :

**១-បឋមវ័យ** ជំនាន់ទី១

**២-មជ្ឈិមវ័យ** ជំនាន់ទី២

**៣-បច្ឆិមវ័យ** ជំនាន់ទី៣ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បទបាលីលោកពោលថា :

បឋមំ  ន  បរាជិតោ  សិប្បំ

ទុតិយំ  ន  បរាជិតោ  ធនំ

តតិយំ  ន  បរាជិតោ  ធម្មំ

ចតុត្ថំ  កឹ  ករិស្សតិ ។

វ័យបឋមស្វែងរកវិជ្ជា វ័យទីពីរស្វែងរកធនធាន វ័យទី៣ស្វែងរកធមិបំរុងប្រាណ វ័យទី៤ក្បួនគ្មាននឹងធ្វើអ្វី ។

**សុភាសិតពោលថា :**

១-ពេលយប់អង្គុយពុំព្រមដេក អង្គុយធ្មេចភ្នែកប្រាំបួនខែ លុះដល់ថ្ងៃរះរស្មីព្រឹកព្រៃ ទើបប្រែក្រឡែរអង្គុយវិញ ។

២-ដេកផ្ងាចំនួន បួនខែពេញ ទើបប្រែផ្កាប់វិញគួរសង្ស័យ ពេលអរុណរះរស្មីព្រឹកព្រៃ ទើបប្រែក្រឡែរអង្គុយវិញ ។

៣-លុះយូរខែថ្ងៃ ផ្ទៃរៀបខ្លួន ចេះដើរជើងបួនមាំមួនមិញ ពេលពេញពន្លឺត្រង់ជ្រេវិញ ចេះដើរញាប់សេញតែជើងពីរ ។

៤-ស្ងួរសែងទន់ៗជិតព្រលប់ បែរជាត្រឡប់ផ្លាស់ស្ថានទី ចេះដើរជើងបីញ៉ូរឥន្ទ្រិយ ប្រលប់ពេញទីដេកលែងក្រោក ។

**ពន្យល់ន័យថា :**

១-ទារកដេកក្នុងផ្ទៃម្តាយប្រាំបួនខែ

Websites: WatKhemaraRatanaram.org or WatKhmers.org

២-សំរាលហើយដេកផ្ងារត្រាំមូត្រលាមក

៣-ទារកចេះក្រឡាប់

៤-ទារកចេះអង្គុយ

៥-ទារកចេះវារ

៦-កុមារ យុវជន មជ្ឈិម

៧-ដើរកាន់ឈើច្រត

៨-លាចាកលោក ។

**មួយបែបទៀតលោកពោលថា :**

ពីព្រលឹមដើរជើងបួន ថ្ងៃពេញសំនួន ដើរជើងពីរ រសៀលទន់ទាប ឈប់រកស៊ី ឈ្មោលញីរៀបស្មើរដើរជើងបី ។

បណ្ដាមនុស្សសត្វ ដែលបានឧប្បត្តិ ឡើងក្នុងលោក សន្និវាសនេះ សុទ្ធសឹងតែមានជីវិត គឺការរស់នៅ ឈ្មោះថារស់នៅក្នុងកាមភព ភពដែលនៅជាប់ជំពាក់វាក់វិនសាំញ៉ាំ ស្មុគស្មាញដោយអាស្រ័យកាម ។

**កាមសេចក្ដីប្រាថ្នាមាន ២ យ៉ាងគឺ:**

**១-កិលេសកាម** សេចក្ដីប្រាថ្នាប្រកបដោយចិត្តសៅហ្មង

**២-វត្ថុកាម** សេចក្ដីប្រាថ្នាព្រោះអាស្រ័យវត្ថុមានរូបជាដើម ។

**កិលេសកាម**

កិលេសគឺធម៌ ជាគ្រឿងសៅហ្មង ដែលប្រឡាក់ ដែលប៉ះពាល់ រីរឹងចិត្តហៅថា បរិយដ្ឋានកិលេស, សេចក្តីសៅហ្មងដែលដេកត្រាំនៅ រឿយៗ ក្នុងសន្តានហៅថា អនុសយកិលេស ។ ដូចជារាគៈ កាលបើកើត ឡើងរមែងញ៉ាំងចិត្តរបស់បុរសស្រ្តីអោយស្វែងរក, **ឥច្ឆា** គឺសេចក្តីប្រា-ថ្នា ជាហេតុនាំអោយចិត្តអន្ទះសាឆ្អែឆ្អា, **អសន្តុដ្ឋិ** គឺសេចក្តីមិន សន្តោសតាមមាន តាមបាន ជាហេតុនាំអោយចិត្ត មិនអោយស្គាល់ ប្រមាណ **ឥស្សា** គឺសេចក្តីច្រណែន ជាហេតុនាំអោយចិត្តដុកដាន់ចាល បាល់ទៅរកអ្នកដទៃ, **ខរតិ** គឺសេចក្តីមិនត្រេកអរចំពោះបុណ្យកុសល ដែលត្រូវបំពេញ ជាហេតុនាំចិត្តអោយក្តៅក្រហាយក្នុងកាលជាខាង ក្រោយ ។ កិលេសកាមទាំងឡាយមានរាគៈជាដើមដូចបានអធិប្បាយ មកនេះ កាលបើមានកម្លាំងក្លេវក្លា អាចគ្រប់សង្កត់ចិត្តជាកុសល បានទើបលោកហៅថា " បរិយុដ្ឋានកិលេស " កាលបើកើតឡើងក្នុងសន្តាន ដោយសេចក្តីសៅហ្មងដ៏ទន់ខ្សោយលោកហៅថា " អនុសយក្កិលេស " ។

## វត្ថុកាម

ពាក្យថា " វត្ថុ " ក្នុងទីនេះ បានដល់អារម្មណ៏ខាងក្រៅ ដែលជា គ្រឿងលលួងចិត្តអោយជាប់ជំពាក់អោយញៀនញ៉ម សំដៅយកកាម គុណទាំង ៥ គឺរូប សម្លេង ក្លិន រស សម្ផស្ស ។ កាមទាំងពីរយ៉ាង គឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

កិលេសកាម និងវត្ថុកាមនេះ ជាអញ្ញមញ្ញប្បច្ច័យ គឺការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមក ។

កាលបើកិលេសកាម មានកម្លាំងកើតឡើង ជាហេតុនាំអោយបុរសស្ត្រីស្វែងរកវត្ថុកាម, កាលបើវត្ថុជាទីត្រេកអរជាទីគាប់ចិត្ត ក៏កើតសោមនស្ស, តែបើវត្ថុមិនជាទីប្រាថ្នា មិនជាទីគាប់ចិត្ត ក៏កើតទោមនស្ស ។ បុរសស្ត្រីក្នុងលោកដែលត្រូវការ និងជម្រះចិត្តអោយបរិសុទ្ធផុតចាកកិលេស គប្បីញុំាង ឬកំចាត់ដោយឧបាយដ៏ល្អដូច្នេះ គឺកំចាត់រាគៈ ដោយអកុសលកម្មដ្ឋាន កំចាត់លោភដោយការបរិច្ចាគទាន, កំចាត់ឥច្ឆា និងអសន្តុដ្ឋី ដោយសេចក្តីសន្តោស, កំចាត់ឥស្សា និង **អរតិ** ដោយ **មុទិតា** គឺសេចក្តីរីករាយចំពោះ សេចក្តីសុខចំរើននៃអ្នដទៃ ។

ក្នុងបទថា : **អតីតេ យោព្វនេ** បានសេចក្តីថា បុរសដែលមានវ័យកន្លងទៅហើយ គឺបុរសចាស់ហួសពេក តែនៅមានជាប់ជំពាក់ញៀនញ៉ាម ប្រាថ្នាក្នុងកាមគឺ រូប សម្លេង ក្លិន រស សម្ផស្ស មិនចេះឆ្អែតឆ្អន់ធុញទ្រាន់នឿយណាយ នៅចង់សប្បាយហ៊ឺហា ហាក់លោតដូចបុរសនៅវ័យក្មេង ។ ចាស់ខ្លួ អ័ប្បឥតប្រាជ្ញា ខ្វះការពិចារណាបណ្តោយអោយលោកធម៌ទាំង ៨ យ៉ាង លុកលុយជិះជាន់ គ្របសង្កត់ញាំញី ក្នុងសន្តានចិត្តបាន ពាក្យគេតែងនិយាយថា " មនុស្សស៊ីជោរ" ចាស់ខ្លះទៀតអាយុជ្រុលហួសបើគេហៅថា " អន្ទិត " (បណ្ឌិត) ឬគេហៅថា លោកបងមួយ

ម៉ាត់គាត់សប្បាយរីករាយចិត្តណាស់ តាំងសើចក្អៀកៗ ចង់អស់អ៊ីអស់ទៅឥតគិត, របស់អ្វីដែលពិបាកមិនមាន គាត់ខំជួយរកទាល់តែមានទាល់តែបាន ។ លោកតែហៅថា អ៊ុំ ឬតា កុងដូច្នោះវិញ ច្បាស់ជាបញ្ចេញទឹកមុខកែញ្ញេវញ្ញូវ មិនចង់ទាំងស្ដីរក បើប្រាថ្នាទៅរករបស់អ្វីរបស់នោះមាន ក៏គាត់ថាគ្មានពីព្រោះមិនមានសប្បាយចិត្ត ។

ចាស់របៀបនេះឈ្មោះថា បណ្ដោយអោយលោកធម៌ជិះជាន់សង្កត់សង្កិនបាន, ឯលោកធម៌ប្រែថា ធម៌គ្របសង្កត់ចិត្តសត្វលោក, គឺសត្វលោកតែប្រព្រឹត្តទៅតាមធម៌នោះ ។

**លោកធម៌ ៨ យ៉ាងគឺ**

| | |
|---|---|
| **១.លោភោ** | មានលាភ |
| **២.អលោភោ** | មិនមានលាភ |
| **៣.យសោ** | មានយស |
| **៤.អយសោ** | មិនមានយស |
| **៥.បសំសា** | សេចក្ដីសរសើរ |
| **៦.និន្ទា** | សេចក្ដីនិន្ទា |
| **៧.សុខ** | សេចក្ដីសុខ |
| **៨.ទុក្ខ** | សេចក្ដីទុក្ខ |

បុរសដែលចាស់ជរាជ្រុលហើយនៅងប់ក្នុងកាម ត្រេកអរក្នុងកាម បណ្តោយអោយកាមញាំញីបានរមែងជួបប្រទះ នឹងសេចក្តីទុក្ខវេទនា សមដូចព្រះពុទ្ធភាសិតថា :

**កាមេ គិទ្ធា កាមរតា កាមេសុ អធិមុច្ឆិតា**

**នរា បាបានិ កត្វាន ឧបបជ្ជន្តិ ទុគ្គតឹ ។**

ពួកនរជនងប់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ងប់ចិត្តក្នុងកាមទាំង-ឡាយ ធ្វើបាបរមែងចូលដល់ទុគ្គតិ ។

ពួកនរជនដែលងប់ចិត្តក្នុងកាម គឺមានចិត្តទទឹកជោគញៀន-ញ៉ាម ក្នុងចំណង់ទាំងឡាយ មានរូប សម្លេង ក្លិន រស សម្ផស្ស ជាដើម ត្រេកអររីករាយពេញចិត្តស្អិតស្រឡាញ់ចាញ់ឥទ្ធិពល នៃចំណង់ងងុលងប់ ទន់ទោរធ្លាក់ចុះក្នុងជ្រោះចំណង់ទាំងឡាយ កាលបើចិត្តស្អុតចង់ញៀន-ញ៉ាម ងុលងប់ជាប់ជំពាក់ទាក់ទិនកាមទាំងឡាយ យ៉ាងនេះហើយរមែង ធ្វើអំពើបាបទាបថោកទាំងឡាយ ដោយកាយវាចាចិត្ត ត្បិតកាមទាញ ញាក់អោយប្រព្រឹត្តទៅឈប់ ដឹងបាបបុណ្យ គុណទោស កាលបើយ៉ាងនេះ លោកប្រាប់ថា នរជននោះ រមែងចូលដល់ទុគ្គតិគឺស្ទុះលិចចុះទៅក្នុងដំណើរ អាក្រក់ខាងបច្ចុប្បន្ន ពោលគឺមានទុក្ខទោសក្តៅក្រហាយ អន្តរាយក្នុង គ្រួសារ ខូចកេរ្តិ៍ឈ្មោះអស់តម្លៃ រកសេចក្តីចំរើនគ្មាន គឺធ្លាក់ចុះក្នុងទីទាប

ទុក្ខទោស ទាំងក្នុងអនាគតជាតិ គឺទៅកើតក្នុងអបាយភូមិ នរក ប្រេត អសុរកាយ តិរច្ឆាន ឬទៅកើតជាមនុស្សប្រកបទៅដោយគុណវិបត្តិ ។

## " រឿង តក្កបណ្ឌិត "

### ទោសកាមេសុមិច្ឆា ឬទោសនៃកាមគុណ

ព្វដ៏អតីតកាល ព្រះបរមពោធិសត្វរបស់យើង ជាតាបសនៅជាសុខ ក្នុងឈាននាបណ្ណសាលាទៀបឆ្នេរគង្គា ។ មានធីតារបស់សេដ្ឋីនៅក្នុងក្រុងពារាណសីឈ្មោះទុដ្ឋកុមារី ជាស្រីឆ្នាស់និងកាចឃោរឃៅក្រៃពេក បានជេរប្រទេចវាយពួកក្មេងកម្មករទាំងលាយគ្មានសំចៃដៃ ។ ថ្ងៃមួយពួកកម្មករទាំងនោះបានជេរប្រទេច ចាប់នាងយកទៅទំលាក់ក្នុងស្ទឹងគង្គា ។ ទុដ្ឋកុមារីនោះ ក៏អណ្តែតទៅតាមខ្សែទឹកស្រែកយំហ៊ូៗ ដល់ទៅកន្លែងក្បែរសាលាបរមពោធិសត្វ តាបសក្នុងពេលអាធ្រាតសន្ធប់បាត់ស្មារតី ។ តាបសក៏ស្រង់នាងពីទឹកដោយសេចក្តីអាណិតអាសូរ ហើយយកនាងទៅឆ្អើរដរាបដល់នាងមានស្មារតីឡើង ទើបអោយផ្លែឈើទុំខ្ចីបរិភោគ ក៏សួរថា នាងនៅក្នុងទីណា ? ចាស ! នៅក្នុងក្រុង ពារាណសីលោកតា! ។ នាងចូទៅឥឡូវទៅ ( តាបសពោលយ៉ាងនេះ ដោយខ្លាចនាងធ្វើទុកបុកម្ទិញម៉ិញមក់អោយផ្លុះធ្លាយសីលរបស់ខ្លួន ) ស្រីនោះគិតថា អញត្រូវប្រលោមលោមតាបសនេះ ដោយធ្វើអាការញ៉ៅមញ៉ង់ញ៉ៅញ៉ ញ៉េះញ៉ាក់ លុះត្រាតែមានតម្រេកស្នេហ៍ស្និទ្ធទប់អាត្មាមិនបាន ដោយកាមតណ្ហា បានខ្លួនជាគូ

Websites: WatKhemaraRatanaram.org or WatKhmers.org

សង្សារសិនទៅទាំងពីរនាក់ ។ តាបសទប់អាត្មាមិននឹង ដោយមេអសុភស្រស់ លងបន្ទាចបង្ហាញ អាការគួរអោយខ្លាច គួរសម្បើមក្រែពេក ក៏រលំខ្លួនទៅផ្តេកផ្តិតស្និទ្ធស្នេហា លុះត្រាតែធ្លាយក្នុងសីល មានឈានសាបសូន្យក៏នាំគ្នាទៅកាន់ស្រុកប្រទេសដែនជាមួយស្រីនោះ ហើយលក់ដូរខ្លាញ់បានប្រាក់បន្តិចបន្តួច គ្រាន់នឹងទិញស្បៀងអាហារចិញ្ចឹមអាជីពនៃគូសង្សារកំសត់របស់ខ្លួនតែរាប់ថ្ងៃ ។ ព្រោះហេតុនោះជនទាំងឡាយក៏កំណត់នាមធេយ្យតាបសតាមហេតុនោះថា : **តក្កបណ្ឌិត** ។ មនុស្សទាំងឡាយក៏អោយវត្ថុដល់តក្កបណ្ឌិតនោះ ហើយអោយកូនខ្ទមមួយគ្រាន់ជាទីជ្រកកោនឡើងទ្វារស្រុក ។ ថ្ងៃមួយពួកចោរចូលទៅប្លន់ស្រុកនោះ ហើយចាប់យកប្រពន្ធតក្កបណ្ឌិតទៅអោយមេរបស់ខ្លួន មេចោរក៏ទទួលយកស្រីនោះធ្វើជាគូកំណាន់ ។ នាងនោះចង់សំលាប់តក្កបណ្ឌិតណាស់ ក៏ធ្វើលិខិតមួយច្បាប់ផ្ញើរទៅប្រាប់នូវសេចក្តីដូចតទៅនេះ :

បពិត្រស្វាមីកំសត់, ឥឡូវនេះខ្លួនប្អូនមានទុក្ខយ៉ាងធ្ងន់ ដោយចោរទាំងឡាយចប់មកធ្វើជាស្រីកំណាន់របស់វា ប្រព្រឹត្តធ្វើកាមេសុមិច្ឆាចារឥតមានកោតក្រែងសោះ ហេតុនេះប្រុសបណ្តូលចិត្តប្អូន ត្រូវមកនាំយកប្អូនទៅវិញ ក្នុងពេលឆាប់ៗនេះកុំខាន ។ តក្កបណ្ឌិតក៏ទៅយ៉ាងរស់រាន់ ឯនាងនោះឃើញតក្កបណ្ឌិតមកដល់ ខ្សឹបប្រាប់ថាប្រសិនបើយើងទៅឥឡូវនេះសមចោរតាមចាប់ ហើយសំលាប់យើងមិនខាន ចាំរាត្រីកាលសឹមទៅ ,

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយអោយអង្គុយក្នុបន្ទប់មួយ ទើបទៅប្រាប់មេចោរដែលកំពុងស្រវឹងស្រា ក្នុងបេលល្ងាចថាប្តីខ្លួន មកនៅក្នុងបន្ទប់នោះឯណោះ ប្រុងប៉ុនប៉ងប្រមាថពាធជន្មលោក ។ ចោរស្ទុះទៅជាប់តក្កបណ្ឌិតចង ផ្តេកចុះហើយវាយតាមចិត្តក្តៅ ។ តក្កបណ្ឌិតចោរវាយយ៉ាងណាក៏មិនស្រែកយំឡើយ គ្រាន់តែពេលថា ស្រីទ្រុស្តមិត្ត មានសេចក្តីក្រោធផង មិនដឹងគុណគេផង ជាអ្នកញុះញង់ផង ។ ឯចោរបើស្រាស្វាងហើយ ក៏ប្រារព្ធវាយទៀត ។ តក្កបណ្ឌិតក៏ពោលតែពាក្យនោះ ។

ចោរគិតថា យី! គាត់នេះពោលតែពាក្យដដែលៗ ប្រហែលជាមានហេតុយ៉ាងណាទេដឹង ? ក៏សួរតាបស ៗ ប្រាប់ដំណើងទាំងអស់ហើយ គិតម្តងទៀត អើ ! ស្រីនេះកាឡកិណ្ណីអីម្លេះ អញសម្លាប់ចោលហើយមើលទៅមិនទុកទេ ! ក៏ដាសថា មកនាងអញនឹងសម្លាប់បុរសនោះ ហើយក៏ចេញទៅខាងក្រៅស្រុក បែរជាសម្លាប់ស្រីនោះវិញ ទើបនាំតក្កបណ្ឌិតទៅផ្ទះ សួរថាឥឡូវនេះអ្នកនិងទៅក្នុងទីណា ? ខ្ញុំនឹងបួសទៅនៅក្នុងព្រៃ ។ បើអ្នកបួសខ្ញុំក៏បួសដែរ ។ តក្កបណ្ឌិត និងមេចោរ ក៏បួសទាំងពីរនាក់ ខំចំរើណឈាន និង អភិញ្ញាអោយកើត លុះស្លាប់ទៅបានទៅកើតក្នុងព្រហ្មលោកនាយ ។

បុរសចាស់ជ្រុលហើយ នូវត្រេកអរចំពោះកាម រមែងជួបប្រទះនិងភ័យ និងសេចក្តីសោយដោយពិត សមដូចពុទ្ធភាសិតសំដែងថា :

**កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីភិតភ័យកើតអំពីកាម សេចក្តីសោយខ្សឹបខ្សួលកើតអំពីកាម បើកំចាត់បង់កាមចេញហើយ តើភ័យ និងសោក នឹងមានមកអំពីណា ? គឺឥតមានទេ ។

បុរសមានវ័យចាស់ជ្រុលទៅហើយ ប្រកបដោយអន្ធការ នូវមានតម្រេកដោយក្តីតណ្ហា ហើយទៅនាំយកស្រីក្មេងខ្ចីថនា ដូចទុំផ្លែទម្លាប់មកធ្វើជាភរិយា, ធម្មតាស្រីនៅវ័យក្មេង ច្រើនប្រកបដោយកាមរាគៈ គឺនូវប្រាថ្នាចង់បានល្អ ចង់ស្អាត ចង់សប្បាយហ៊ឹហា ចង់អោយគេអួត ចង់អោយគេសរសើរ មិនចេះឆ្អែត មិនចេះស្កប់ស្កល់គ្រប់គ្រាន់នៅក្នុងគ្រឿងតែងខ្លួនសោះ ត្រូវរមិលមើលតាំងពីបាទជើងរហូតដល់ចុងសក់, វ័យចាស់ណាស់ទៅហើយ មិនអាចផ្គាប់សេចក្តីប្រាថ្នារបស់ក្មេងបាន, បើផ្គាប់មិនបាន ភរិយាក្មេង តែងស្វែងរកស្វាមីទៀត ចុះក្នុងអត្ថថា ក្បត់ចិត្តស្វាមីចាស់ សមដូចនិទានរឿង **សេនកបណ្ឌិត** បុរសចាស់ មានប្រពន្ធក្រមុំដូចបានដុំភ្លើង ។ មានសេចក្តីដំណាលថា ៖

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គនាម **ជនកៈ** សោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វរបស់យើងសោយព្រះជាតិជាព្រាហ្មណ៍ទ្រង់ព្រះនាម **សេនកៈ** នៅក្នុងក្រុងពារាណសី

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះដែរ, បានទៅសិក្សាសិល្បសាស្ត្រនានា ក្នុងនរគតក្កសីលា ។ លុះត្រឡប់មកកាន់ស្រុកកំណើតព្រះអង្គវិញ ព្រះចៅក្នុងក្រុងនោះ ទ្រង់ព្រះរាជទាន់តំណែងជាអាមាត្យ និងយសដ៏ធំ ដល់ព្រះពោធិសត្វៗតែងឡើងគង់លើអសនៈដែល=ស្សរជនទាំងឡាយមានព្រះរាជាជាដើម បានប្រដាប់តាក់តែង សំដែងអត្ថ និងធមិរៀងរាល់ថ្ងៃពេញបូណ៌មី តាមលំអានព្រះពុទ្ធ ។ គ្រាក្រោយមកមានព្រាហ្មណ៍ចាស់ម្នាក់ ដើរសុំទានគេបានប្រាក់មួយពាន់គហាបណៈ យកទៅផ្ញើរ និងត្រកូលព្រាហ្មណ៍មួយ ហើយដើរទៅសុំទានតាមលំដាប់ហូរហែរ ។ ឯត្រកូលព្រាហ្មណ៍នោះ យកប្រាក់ទៅចាយទាល់តែអស់ ដល់ព្រាហ្មណ៍ចាស់ត្រឡប់មកវិញ រកប្រាក់សងវិញមិនបាន ក៏អោយកូនក្រមុំរបស់ខ្លួន ធ្វើជាភរិយាព្រាហ្មណ៍ចាស់ ៗ ឥតមានប្រកែកបន្តិចបន្តួចព្រមយកទៅនៅក្បែរក្រុងពារាណសី ។ ឯប្រពន្ធនៅក្មេងព្រាហ្មណ៍ជាប្តីចាស់ ម្លោះហើយនាងព្រាហ្មណ៍នោះមិនចេះឆ្អែតឆ្អន់ស្កប់ស្កល់ដោយមេថុនធម្មសោះ ទៅធ្វើមិច្ឆាចារ (សាហាយស្មន់) ជាមួយនឹងព្រាហ្មណ៍កំឡោះម្នាក់ដែលមានវ័យស្មើគ្នា ។ ថ្ងៃមួយនាងព្រាហ្មណីនិយាយទៅកាន់ព្រាហ្មណ៍ថា បពិត្រព្រាហ្មណ៍ ខ្ញុំមិនអាចធ្វើការងារក្នុងផ្ទះម្នាក់ឯងឈ្នះទេ អ្នកត្រូវទៅសុំប្រាក់គេ យកមកជួលខ្ញុំប្រុសឬស្រីម្នាក់ឱ្យខ្ញុំ ព្រាហ្មណ៍ចាស់ ដោយហេតុតែស្រឡាញ់ប្រពន្ធក្មេងក្រៃពេក ទុកជាយ៉ាងដូចម្តេចក៏ដោយឥតមានការយល់ទាស់ឡើង ទើបនិយាយថា ល្អហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

នាងត្រូវហើយញាប់មាត់ ហើយស្ពាយការុង ស្បែកសំរាប់ដាក់សត្តូវត្រាច់ម្ទីម្នាតាមច្រកល្ហក ស្រុកនិគមសុំទានគេបានប្រាក់ ៧០០ កហាបណៈ ដល់ត្រឡប់មកវិញ អង្គុយបរិភោគសត្តូវមាត់ផ្លូវក្បែរដើមឈើមានប្រហោងមួយដើម លុះបរិភោគរួចហើយ មិនបានចងមាត់ការុងដែលទុកត្រង់កន្លែងនោះ ដើរចុះទៅផឹកទឹកក្នុងស្ទឹង ។ កាលនោះមានពស់វែកក្របីមួយនៅក្នុងរូងប្រហោងឈើនោះ ធុំក្លិនសត្តូវ លូនចូលទៅក្នុងការុង ស៊ីសត្តូវទាល់តែឆ្អែត ហើយក៏ដេកសំងំស្ងៀមក្នុងទីនោះ ដល់ព្រាហ្មណ៍ត្រឡប់មកវិញមិនបានជាប់ភ្លឹកនឹកភ័យមើលនាយអាយ ក៏ចង់មាត់ការុងស្ពាយដើរតយង៉យ បានបន្ទិច ឬពាក្យទុក្ខទេវតាពោលថា ព្រាហ្មណ៍ក្នុងថ្ងៃនេះ បើអ្នកឈប់សំរាកត្រង់កណ្ដាលផ្លូវអ្នកឯងស្លាប់ បើដើរទៅដល់ផ្ទះប្រពន្ធអ្នកត្រូវស្លាប់ ។ ព្រាហ្មណ៍ឮដូច្នោះភិតភ័យអំពីសេចក្ដីស្លាប់ជាខ្លាំង យំបណ្ដើរដើរបណ្ដើរ បានមកដល់ក្រុងពារាណសី ឃើញពួកមហាជន ជាច្រើននាក់កាន់គ្រឿងក្រអូប នឹងផ្កាកំរងដើរទៅស្ដាប់ធម៌ព្រះពោធិសត្វ ព្រាហ្មណ៍ឃើញដូច្នោះ ទើបសួរដឹងហេតុសព្វគ្រប់ប្រការហើយគិតថា សេនកបណ្ឌិតជាធម្មកថិកមុខជាសំដែងធម៌ ត្រង់ណាមួយដើម្បីកំចាត់បង់សេចក្ដីសោករបស់អញបាន ដូច្នោះគួរតែអញទៅស្ដាប់ធម៌, លុះគិតហើយគាត់ដើរទៅជាមួយជនទាំងនោះ ដល់ហើយគាត់អង្គុយក្រោយពួកបរិស័ទទាំងអស់ ។ ព្រះពោធិសត្វឃើញដូច្នោះគិតថា ហេតុអ្វីទៅហ្ន៎ ! បានជាព្រាហ្មណ៍នេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

មានទឹកភ្នែកហូរចេញស្រោកយ៉ាងហ្នឹង ទើបសួរដំណើរដែលសោកនោះ ។ ព្រាហ្មណ៍បានប្រាប់តាមពាក្យ រុក្ខទេវតាពោល ហើយសួរថា បពិត្របណ្ឌិត ហេតុដូចម្ដេចបានជាខ្ញុំស្លាប់ ប្រពន្ធរបស់ខ្ញុំស្លាប់ ព្រះពោធិសត្វនឹងរំពឹង ឃើញដោយប្រាជ្ញាឈ្លាសវៃក្នុងឧបាយ ដឹងហេតុសព្វគ្រប់ហើយ ទើបសួរទៅព្រាហ្មណ៍ថា សត្វក្នុងការុងអ្នកមានទេ ? ព្រាហ្មណ៍ឆ្លើយថា បពិត្របណ្ឌិតមាន ចុះពីព្រឹកមិញអ្នកបរិភោគក្នុងទីណា ? បរិភោគទៀបគល់ឈើត្រង់ពាក់កណ្ដាលផ្លូវ ។ អ្នកបរិភោគរួចហើយ ចុះទៅផឹកទឹក, បានចងមាត់ការុងឬទេ ? មិនបានចងទេ ។ ព្រះពោធិសត្វពោលថា បើដូច្នោះមានពស់វែកក្របីមួយធុំក្លិន សត្វវចូលទៅក្នុងការុង, បើល្ងាចនេះអ្នកបរិភោគត្រង់កណ្ដាលផ្លូវ លូកយកសត្វវ មុខជាពស់ចឹកក្នុងស្លាប់ បើហួសទៅដល់ផ្ទះប្រពន្ធអ្នកលូកយកឥវ៉ាន់ក្នុងការុង ពស់ចឹកស្លាប់ ពាក្យដែលទេវតាពោល ព្រោះសំដៅយកហេតុហ្នឹងឯង, ដូច្នេះអ្នកត្រូវដាក់ការុងកណ្ដាលបរិស័ទស្រាយមាត់ រួចយកឈើគោះ មុខជាពស់លូនចេញ ។ ព្រាហ្មណ៍ធ្វើតាម ពស់ក៏លូនចេញមែន ហើយក៏ដកពពារធ្វើសំឡេងឮ សូរសុៗ ។

កាលនោះមានហ្មពស់ម្នាក់ យកពស់ទៅលែងចោលក្នុងព្រៃ ។ មនុស្សទាំងឡាយ បានឃើញហេតុអស្ចារ្យដូច្នោះ និយាយគ្នាថា ព្រះពោធិសត្វនេះ ទាយដូចជាព្រះសព្វញ្ញុពុទ្ធទើបនាំគ្នា លើកឡើងនូវសែននៃទង់ជ័យ

ផង ទះដៃផង ស្រែកអោយសាធុការពរផង ។ សំឡេងសាធុការពរដែលលាន់ឮរំពងឡើង ហាក់ដូចជាសំឡេងបែកមហាប្រថពី ។ គ្រានោះភ្លៀងរតន ៧ប្រការបង្អុរមក បូជាព្រះពោធិសត្វ ។ ឯព្រាហ្មណ៏ក៏យកគហាបណៈដែលខ្លួនបាន បូជាព្រះពោធិសត្វៗ មិនព្រមយកសោះ បែរជាបង្គាប់អោយជនអោយ ៣០០ គហាបណៈទៅព្រាហ្មណ៏ទៀត ដើម្បីបង្គ្រប់មួយពាន់គហាបណៈ ហើយសួរថា តើអ្នកណាប្រើអោយដើរសុំគេយ៉ាងនេះ? ព្រាហ្មណ៏ឆ្លើយថា បពិត្របណ្ឌិត ប្រពន្ធប្រើ ! ។ ប្រពន្ធចាស់ឬ ក្មេង ? បពិត្របណ្ឌិតនៅក្មេង ។ ព្រះពោធិសត្វពោលទៀតថា បើដូច្នោះប្រពន្ធរបស់អ្នក ធ្វើមិច្ឆាចារជាមួយនឹងព្រាហ្មណ៏ដទៃ ហើយបានជាវាប្រើអ្នកអោយដើរសុំគេ បើអ្នកយកគហាបណៈទាំងនេះទៅផ្ទះ មុខជាវាយកទៅអោយសាហាយ អ្នកត្រូវលាក់ទុកត្រង់ទីណាមួយ ក្រៅស្រុកសិន សឹមចូលទៅតែខ្លួនទទេចុះ ទើបបញ្ជូនព្រាហ្មណ៏អោយទៅដោយស្រួល ។ ព្រាហ្មណ៏បានទៅដល់ស្រុករបស់ខ្លួនហើយ ក៏លាក់ទុកនៅគហាបណៈទាំងនោះ វាដឹងដៃសាហាយអោយទៅ ពួនត្រង់សន្ទះទ្វារ ទើបសួរទៅព្រាហ្មណ៏ថា អ្នកបានប្រាក់ប៉ុន្មាន ? ព្រាហ្មណ៏ប្រាប់ថាបាន ១០០០ គហាបណៈតែអញដម្កល់ទុកត្រង់ទ្វារស្រុក មិនបានយកមកទេ ។ នាងព្រាហ្មណ៏ទៅប្រាប់សហាយៗ ទៅយកទាល់តែអស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

លុះព្រឹកឡើងព្រាហ្មណ៏ទៅយកគហាបណៈមិនឃើញសោះ ទើបទៅប្រាប់ដល់ពោធិសត្វម្តងទៀត ព្រះពោធិជ្រាបហេតុនេះសព្វគ្រប់ ក៏អោយស្បៀងគ្រប់គ្រាន់ចំនួន ៧ ថ្ងៃអោយព្រាហ្មណ៏ ហើយប្រាប់ឧបាយថាអ្នកត្រូវទៅអញ្ជើញព្រាហ្មណ៏ ១៤ នាក់ គឺ ៧ នាក់ ជាមិត្តខាងអ្នក ៧នាក់ទៀតជាមិត្តខាងប្រពន្ធ អោយបរិភោគតាំងពីថ្ងៃស្អែកតទៅ ក្នុងមួយថ្ងៃៗត្រូវបន្ថយម្នាក់រៀងរាល់ថ្ងៃ លុះដល់ថ្ងៃទី ៧ អញ្ជើញតែពីរនាក់គឺម្នាក់ខាងអ្នក និងម្នាក់ទៀតខាងប្រពន្ធ, បណ្តាព្រាហ្មណ៏ទាំងអស់នោះព្រាហ្មណ៏ណាត្រូវជាមិត្តប្រពន្ធអ្នកមកគ្រប់តាំង ៧ ថ្ងៃ ពុំដែលសោះខានអ្នកត្រូវប្រាប់ដល់ខ្ញុំ ។ ព្រាហ្មណ៏ធ្វើដូច្នោះ ក៏ឃើញមែន ទើបទៅប្រាប់ដល់ព្រះពោធិសត្វៗ អោយបុរសទាំងឡាយទៅចាប់ព្រាហ្មណ៏នោះមក ហើយសួរថា អ្នកឯងយកប្រាក់ ១០០០ គហាបណៈរបស់ព្រាហ្មណ៏នេះ អំពីគល់ឈើនេះ ឬទេ ? ព្រាហ្មណ៏ឆ្លើយថា បពិត្របណ្ឌិតខ្ញុំអត់យកទេ ។ ព្រះពោ-ធិសត្វប្រាប់ថា ខ្ញុំហ្នឹងហើយឈ្មោះ សេនកបណ្ឌិត អ្នកស្គាល់ទេ ឬ ? ព្រាហ្មណ៏ចោរ ឮឈ្មោះភ្លាមភិតភ័យជាខ្លាំង ទើបឆ្លើយប្រាប់ត្រង់ថាខ្ញុំយកមែន ឥឡូវនេះទុកត្រង់កន្លែងនោះ ។ ព្រះពោធិសត្វ ប្រើបុរសទាំងឡាយនាំព្រាហ្មណ៏នោះទៅធ្វើជាអាជ្ញារបស់ស្តេច ហើយអោយនិរទេសចេញពីនគរទៀត ទើបអោយប្រាក់ ១០០០ គហាបណៈជាមួយនឹងយតយ៉ាងធំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់ព្រាហ្មណ៍ចាស់ ហើយអោយនៅក្នុងសំណាក់របស់ព្រះអង្គទាំងពីរនាក់ប្ដីប្រពន្ធដរាបដល់អស់អាយុ ។

**សាធនៅ** សាធុសប្បុរសទាំងឡាយ! ព្រះលោកុត្តរមាចារ្យអនាវរណញ្ញាណ ព្រះអង្គសំដែងទុកមកថា ៖

ស្រីក្បត់ចិត្តប្ដីដោយហេតុ ៨ យ៉ាងគឺ ៖

**១_ទលិទ្ទតា** ព្រោះប្ដីជាអ្នកទាល់ក្រ

**២_អាតុរតា** ព្រោះប្ដីឈឺជានិច្ច

**៣_ជិណ្ណកតា** ព្រោះប្ដីចាស់ជរាគ្រាំគ្រា

**៤_សុរាសោណ្ឌតា** ព្រោះប្ដីជាមនុស្សផឹកស្រា

**៥_មន្ទតា** ព្រោះប្ដីជាមនុស្សល្ងង់ខ្លៅ

**៦_បមត្តតា** ព្រោះប្ដីជាមនុស្សប្រហែល

**៧_សព្វកិច្ចេសុ អវត្តនិកតា** ព្រោះប្ដីមិនប្រព្រឹត្តធ្វើកិច្ចការផ្សេងៗ

**៨_សព្វធនមនិប្បាទនា** ព្រោះប្ដីស្វែងរកទ្រព្យសម្បត្តិមិនបាន ។

បើស្វាមីប្រកបទៅដោយគុណវិបត្តិ ដូចពោលមកហើយនេះ ភរិយាច្រើនតែក្បត់ អាស្រ័យហេតុនេះជាអាទិ៍ បានជាព្រះមុនីនាថទ្រង់សំដែងទុកមានមកថា ចាស់បានភរិយាក្មេង ទុកដូចជាបានថ្នាំពិស សុភាពសិតសំស្រិតមួយកន្លែងពោលថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនភ្យាសេ វិសំ វិជ្ជា អជីណ្ណេ ភោជនំ**

**វិសំ, វិសម សភា នុត្តស្ស តរុណីវិសម ៥**

វិជ្ជាជាថ្នាំពិសនិមិត្ត ការមិនចាំប្រាកដ ភោជន ជាថ្នាំពិសនិមិត្តការមិនរលួយ ទីប្រជុំជាថ្នាំពិសមនុស្សក្រ ប្រពន្ធក្រមុំជាថ្នាំពិសដល់ស្វាមីចាស់ ។

វិទ្យាជាពាក្យសំស្ក្រឹត វិជ្ជាជាភាសាបាលី ប្រែមកមានន័យដូចគ្នាថា ចំណេះចេះដឹង ឬការចេះដឹង ។ បុរសស្រ្តីក្នុងលោកគប្បីស្វែងរកចំណេះវិជ្ជា អោយបានប្រចាំក្នុងខ្លួន ។ ភោជនាហារ គឺអាហារដែលយើងប្រាស្រ័យចូលទៅ ដើម្បីញ៉ាំងជីវិតិន្ទ្រិយអោយរស់នៅបាន, អាហារភោជននេះ មានគុណសម្បត្តិផង មានគុណវិបត្តិផង ។ បើយើងអាស្រ័យអោយល្មមប្រមាណ កុំតិចពេក កុំច្រើនពេក ឈ្មោះថាមានគុណសម្បត្តិ ,បើអាស្រ័យតិចពេកធ្វើអោយរហិតរហៃល្វើយ ប្រកបកិច្ចការអ្វីមិនកើត, អាស្រ័យច្រើនពេក ទៅជាហែលហល់ទ្រេលទ្រោល ក៏មិនស្រួលដែរ ជួនកាលទៅជាឆ្អឹតឆ្អល់ ច្រើនពេកជួនកាលធ្វើអោយចាក់ច្រាសផ្តាប់បង់ទាំងជីវិត ក៏សឹងមាន ឈ្មោះថាមានគុណវិបត្តិ ។

បុគ្គលអ័ប្បឥតប្រាជ្ញា គ្មានចំណេះវិជ្ជា គ្មានទ្រព្យសម្បត្តិ មិនមានយសស័ក្តិឋានៈ មុខតំណែង មុខនាទី ណាមួយមិនអាចចូលទៅកាន់សភាបានឡើយ ។ ក្នុងទីសន្និបាតដើម្បីប្រឹក្សា ដោះស្រាយនូវបញ្ហាកម្មអ្វីមួយ

ទាំងផ្នែកខាងពុទ្ធចក្រ ទាំងផ្នែករដ្ឋចក្រ ត្រូវការតែអ្នកមានប្រីជាបញ្ញាវិន្ទជាបណ្ឌិត អត្ថកោវិទជាដើម ។ ឯចំណែកបុគ្គលអត់មានប្រាជ្ញា មិនអាចចូលទៅកាន់ទីនោះបានឡើយ ។ ពីព្រោះទីប្រជុំទុកដូចជាថ្នាំពិស ដល់មនុស្សក្រកីគ្មានចំណេះ ។

ប្រពន្ធក្រមុំទុកដូចជាថ្នាំពិសដល់ស្វាមីចាស់ ដូចជាបានសំដែងមក ហើយពីខាងដើម ។

ពាក្យថា **តណ្ហា** ប្រែថា សេចក្ដីប្រាថ្នា, ការចង់បាន, សេចក្ដីអន្ទះអន្ទែង, បំរះនទៀល មកពីស័ព្ទដើមគឺ **តស** និង **ណ្ហា** និងអាឥត្ថិលិង្គ ។ សេចក្ដីស្រេកឃ្លាន, សេចក្ដីចង់, ចំណង់, ឬធម្មជាតិជាគ្រឿងញាំងសត្វអោយតក់ស្លុត បទវិគ្រោះថា **តាសេតិ ឯតាយាតិ** ជាតណ្ហា ។

តណ្ហាជាកិលេសធមិ ដែលតែងដេកត្រាំក្នុងសន្ដានចិត្តរបស់សត្វ ចែកជា ៣ យ៉ាងគឺ :

**១-កាមតណ្ហា** សេចក្ដីប្រាថ្នាក្នុងកាម

**២-ភវតណ្ហា** សេចក្ដីប្រាថ្នាក្នុងភព

**៣-វិភវតណ្ហា** សេចក្ដីប្រាថ្នាក្នុងប្រាសចាកភព, ប្រាថ្នាព្រះនិព្វាន មិនចាតជាតណ្ហាទេ ។

សេចក្តីប្រាថ្នារបស់បុគ្គលដែលប្រកបដោយ ឧត្តមគតិដែលផ្តោតដៅចំពោះ ទៅរកព្រះនិព្វាន តែមួយយ៉ាង មិនអាល័យមិនជាប់នៅក្នុងភព គឺជាសេចក្តីប្រាថ្នាដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីរំលត់ទុក្ខ ជាការជៀសវាងផុតអំពីតណ្ហា ទាំងព្រះនិព្វានក៏ជាគុណជាតិ មិនមានភព មិនមានខ្លួនប្រាណ ព្រោះហេតុនោះសេចក្តីប្រាថ្នាព្រះនិព្វាន លោកមិនចាត់ជាតណ្ហាឡើយ ។

ពុទ្ធបរិស័ទទាំងឡាយ ! សេចក្តីភិតភ័យក្តី, សេចក្តីសោកខ្សឹកខ្សួលក្តី, កើតមកពីតណ្ហា សមនឹងព្រះពុទ្ធដីកាថា :

**តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ**
**តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោកកើតពីតណ្ហា ភ័យកើតអំពីតណ្ហា បើកំចាត់បង់តណ្ហាបានហើយ តើសេចក្តីសោក ការភិតភ័យ នឹងមានមកពីណា ? គឺមិនមានទេ ! ។

ពុទ្ធដីកាក្នុងធម្មទ្ទិសធម៌ថា **ឩនោ លោកោ អតិត្តោ តណ្ហាទាសោ,** សត្វតែងមានសេចក្តីខ្វះខាត មិនចេះឆ្អែតឆ្អន់ គ្រប់គ្រាន់ គឺជាខ្ញុំកញ្ជះនៃតណ្ហា ។

សេចក្តីស្រឡាញ់តែងសំលាប់នូវសត្វលោក សមដូចរឿងនហាបិតបុត្ត សូមនាំនិទាននោះមកសំដែងជាឧទាហរណ៍ដូចតទៅនេះ : កាលកន្លងទៅហើយ មានខ្ទាន់ព្រះកេសម្នាក់នៅក្នុងក្រុងវេសាលី ជាអ្នកមាន

សទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ប្រកបកិច្ចការ ចិញ្ចឹមជីវិតដោយការកោរកាត់ព្រះកេសព្រះមស្សុរបស់ព្រះរាជា និងពួកស្រីស្នំរបស់ព្រះអង្គ ។ ថ្ងៃមួយខ្មាន់ព្រះកេសនោះ ទៅប្រកបកិច្ចការក្នុងព្រះរាជនិវេសន៍ បាននាំបុត្រទៅជាមួយផង ឯបុត្រនោះបានឃើញនាលិច្ឆវីរាជកុមារិកា ដែលប្រដាប់តាក់តែងដោយគ្រឿងអលង្ការ មានរូបឆោមល្អស្រស់ប្រិមប្រិយដូចជាស្រីទេពអប្សរ ក៏មានចិត្តប្រតិព័ទ្ធស្នេហា ចំពោះរាជកុមារិកានោះពន់ពេក ដោយអំណាចកិលេសតណ្ហាគ្រប់សង្កត់, លុះត្រឡប់ទៅផ្ទះវិញក៏ដេកអត់បាយអត់ទឹក នឹងរំពឹង ចំពោះតែរូបនាង កុមារិកាទើបប្រាប់ដល់បិតាថាបពិត្របិតា ! ខ្ញុំបើមិនបាននាង លិច្ឆវីរាជកុមារិកានោះមកធ្វើជាភរិយាទេ មុខជាស្លាប់ក្នុងទីនេះពុំខាន ។ បិតាក៏និយាយអង្វរថា ម្នាលកូនសម្លាញ់ឪពុក អ្នកជាមនុស្សថោកទាបដោយជាតិ និងគោត្រ ជាកូនរបស់ខ្មាន់ព្រះកេស មិនគួរធ្វើនូវឆន្ទរាគចំពោះហេតុដែលមិនមានជាវត្ថុបំណងមិនសមរម្យ និងកូនឯងទេ, ចាំបិតាទៅរកនាងកុមារិកាដែលមានជាតិនិងគោត្រស្មើគ្នាអោយ ។ ឯកូនរបស់នហាបិតនោះមិនតាមពាក្យសំដីរបស់បិតាឡើយ នៅតែមានចិត្តប្រតិព័ទ្ធស្រឡាញ់ចំពោះរូបនាងលិច្ឆវីរាជកុមារិកានោះជាខ្លាំងឡើងៗ ដរាបដល់មានរូបស្គាំស្គម ស្លាប់ក្នុងពេល

កុមារិកា នោះជាខ្លាំងឡើងៗ ដរាបដល់មានរូបស្គាំស្គម ស្លាប់ក្នុងពេល

នោះទៅ ។ តណ្ហាជាសំយោជនកិលេស ដែលរឹតរួតរុំហុំនូវសន្តានចិត្តរបស់

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្វលោក ដែលជាមូលដ្ឋាននាំអោយកើត សេចក្តីទាំងពួង ហើយរមែង គ្រប ឬក្រុងទុក្ខនៅសត្វ លោកអោយជាប់នៅក្នុងវដ្តទាំង ៣ យ៉ាងគឺ កិលេស វដ្តវិលវល់ព្រោះ វិបាករបស់កម្ម១, ធ្វើអោយសត្វស្ថិតនៅក្នុងត្រៃ ភពទាំង ៣ យ៉ាងគឺ កាមភព ភពជាកាមាវចរ១ រូបភព ភពជារូបាវ ចរ១ អរូបភព ភពជារូបាវចរ១ ។

ការអស់ទៅនៃតណ្ហា ទើបអស់នូវសេចក្តីទុក្ខគ្រប់យ៉ាង ព្រះពុទ្ធ ដីការត្រាស់សំដែងថា **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។** ការអស់ ទៅនៃតណ្ហា ឈ្មោះថា ឈ្នះទុក្ខទាំងពួង ។ **នត្ថិ តណ្ហាសមានទី** ស្ទឹងស្មើដោយតណ្ហាមិនមាន ។

ពាក្យថា **ភរិយា** សំដៅយកស្រ្តីដែលជាប្រពន្ធ ហើយជាសិទ្ធិ របស់បុរស ណាមួយដែលមានការហួងហែងថែរក្សា ឬស្រីដែលអាច ញ៉ាំងបុត្រអោយកើតបានស្រ្តីនោះឈ្មោះថាភរិយា ។

ភរិយាចែញចេញជា ៧ ពួកគឺ :

**១-វធកា ភរិយា** ភរិយាស្មើអ្នកសំលាប់

**២-ចោរា ភរិយា** ភរិយាស្មើដោយចោរ

**៣-អយ្យា ភរិយា** ភរិយាស្មើដោយម្ចាស់

**៤-មាតា ភរិយា** ភរិយា ស្មើដោយមាតា

**៥-ភគិនិភរិយា** ភរិយាស្មើ និងប្អូនស្រី

**៦-សខី ភរិយា** ភរិយាស្មើនឹងសម្លាញ់

**៧-ទាសី ភរិយា** ភរិយាស្មើនិងខ្ញុំបំរើ ។

ឯចំណែកខាងភស្តា ឬស្វាមីក៏ចែកចេញជា ៧ ពួកដូចជាភរិយាដែរ

ភរិយាស្មើដោយអ្នកសំលាប់, បានសេចក្ដីថា : ភរិយាដែលមានចិត្តមួះឆ្នាស់ កាចសាហាវ យង់ឃ្នង់ ឃោរឃៅ ច្រលើសបើស រកតែរឿងឈ្លោះប្រកែកជជែក និងស្វាមី ជេរប្រទេសផ្ដាសា ប្រមាថមើលងាយដោយការផ្សេងៗ ដើម្បីបានលែងលះគ្នា មានឱកាសល្អ និងបានទៅជួបសាហាយស្មន់ ឬ មានចិត្តមុះមុតលើកអាវុធសម្លាប់ស្វាមី ឬ ក៏ញុះញង់បញ្ចុះសង្រ្សារ សាហាយស្មន់ រកលេសសម្លាប់ក៏មាន ជួលអោយគេសម្លាប់ក៏មាន ដើម្បីបានទៅរស់នៅក្រោមដើមទ្រូងរបស់ស្វាមីថ្មី បានបំពេញកាមតណ្ហាតាមបំណង ប៉ុណ្ណោះជាដើមហៅថា **វធកាភរិយា ។**

ភរិយាស្មើដោយចោរ បានសេចក្ដីថា ភរិយាដែលខ្នះខ្នែងប្រឹងប្រែង រកទ្រព្យសម្បត្តិរួមសំបាច់ជាមួយស្វាមី ដល់មានចិត្តក្បត់ ក៏តាំងតែលួចជញ្ជូន ទ្រព្យសម្បត្តិដែលរកបានមកនោះ មិនអោយស្វាមីដឹង មិនអោយស្វាមីឃើញ ហើយផ្ដល់អោយសាហាយស្មន់ ដើម្បីចងចិត្ត ឬទាក់ចិត្តស្វាមីថ្មី ខ្លាចគេបែកចិត្ត ពីខ្លួនម្ល៉ោះហើយក៏ លួចលាក់ទ្រព្យសម្បត្តិនោះ អោយគេដើម្បីផ្គាប់កាមតណ្ហា ប៉ុណ្ណោះជាដើមហៅថា **ចោរា-ភរិយា ។**

ភរិយាស្មើដោយម្ចាស់ បានសេចក្តីថា : ភរិយាដែលគោរពកោតខ្លាចស្វាមីដូចរៀមច្បង មិនប្រមាថមើលងាយ មិនខ្ជះខ្ជាយចាយវាយទ្រព្យសម្បត្តិ ឥតសណ្តាប់ធ្នាប់ មិនមានចិត្តវិបល្លាស់ក្បត់ចិត្តស្វាមី ចេះស្តាប់បង្គាប់ស្វាមី រស់នៅប្រកបដោយ សុជីវធម៌ សីលធម៌, ភរិយាដែលមានប្រាជ្ញា ឧស្សាហ៍ មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង មានការទំនុកបំរុងផ្គត់ផ្គង់ថែរក្សាស្វាមី ដូចជាបងបង្កើត ។ ភរិយាដូចនេះ លុះច្យុតចាកអត្តភាពនេះទៅ រមែងទៅឧប្បត្តិក្នុងទេវលោក ដូចជានាងសាវត្ថីធីតា សូមនាំនិទាននោះមកសំដែងជាឧទាហរណ៍ ដូចតទៅ : គុណនៃការគោរពបំរើស្វាមីរបស់ខ្លួន ក្នុងពុទ្ធសម័យ កាលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ។ កាលនោះមានស្រីម្នាក់នៅក្នុងសាវត្ថីជាស្រីគ្រប់លក្ខណ៍ មានគំនិតមាយាទត្រឹមត្រូវ មិនផ្តេសផ្តាស់ ជាស្រីមានគំនិតត្រង់ និងស្វាមីរបស់ខ្លួន, តាំងតែពីពេលដែលមាតាបិតាបានផ្សំផ្គុំអោយមានគូរស្រករមក ពុំដែលមានសេចក្តីច្រណែន រិះគន់ដល់ស្វាមីម្តងណាឡើយ ខំផ្គត់ផ្គង់បំរើស្វាមីដូចជាមាតារក្សាបុត្រ ទោះបីស្វាមីនោះទៅប្រព្រឹត្តមិនគប្បី និងស្រីដទៃក៏នាងពុំដែលតូចចិត្ត អាក់អន់ចិត្តចំពោះស្វាមីឡើយ ។ ជាស្ត្រីមានប្រាជ្ញាជ្រៅជ្រះ មានគំនិតត្រង់ជានិច្ច ។ ក្នុងកាលបច្ឆិមវ័យនាងធ្វើមរណកាលទៅ បានទៅកើតក្នុងពិភពតាវត្តឹង្ស ស្ថិតនៅក្នុងវិមានមានកំពស់ ១២ យោជន៍ មានទេវបុត្រ ទេពធីតារាប់

ពាន់នាក់ជាបរិវារ មានអានុភាពក្រៀវក្លា ហោះហើរ ឰដ៏អាកាសលឿន ជ្រៀវជ្រៃ មានសំឡេងស្រួចពិរោះ ប្លែកគួរអោយចង់ស្តាប់ ។ ពួកទេវបុត្រ ទេវធីតាទាំងឡាយ ក្នុងឆកាមាសួគិទាំងអស់ស្រឡាញ់រាប់អាន ចូលចិត្តទៅលេងពេញ។ វិមានប្រាសាទរបស់នាង ឧបមាដូចជាសត្វបក្សី ពេញចិត្តនឹងដើមជ្រៃធំ ដែលបរិបូណ៌ដោយផ្កាផ្លែ និងស្លឹក ។ ថ្ងៃមួយព្រះ-មោគ្គល្លាន និមន្តទៅកាន់ស្ថានត្រៃត្រឹង្ស បានឃើញហ្វូងទេវតា កំពុងចោមរោមវិមានប្រាសាទនោះដូច្នោះ ហើយក៏និមន្តទៅជិត ។ ពួលទេវតាផ្អើមឈូឆរ, នាងទេពធីតាក៏ចុះទៅថ្វាយបង្គំ ទើបព្រះមោគ្គល្លានមានថេរដីកាសួរថា : ម្នាលនាងទេពធីតា អ្នកបរិបូណ៌ដោយទិព្វសិរី នាងបានធ្វើបុណ្យដូចម្តេចពីជាតិមុន បានជាកើតមកក្នុងទីនេះ មានទេវបុត្រ ទេពធីតារាប់អានច្រើនម្លេះ ? នាងប្រាប់ថា ខ្ញុំព្រះករុណាមិនបានធ្វើបុណ្យអ្វីទេ គ្រាន់តែគោរពបំរើស្វាមីតែប៉ុណ្ណោះ ក៏ថ្លែងប្រវត្តិរបស់ខ្លួនប្រាប់ដល់ព្រះ-មោគ្គល្លាន ដោយសព្វគ្រប់, លុះចប់ហើយព្រះមោគ្គល្លានក៏និមន្តហួសចេញទៅ ។

ភរិយាស្មើដោយមាតា បានសេចក្តីថា ភរិយាដែលគោរពកោតខ្លាចបំរើស្វាមី បីដូចបុត្រធីតាដែលបំរើមាតា មិនអោយមោះហ្មងឆ្គងត្រង់កិច្ចណាមួយមិនអោយរឱស្មានក្នុងការអ្វីមួយ, បុត្រធីតាបំរើមាតា យ៉ាង

ភរិយា ដែលមានចរិយាសម្បត្តិត្រឹមត្រូវល្អ ឬកពារថ្លៃថ្នូរ តែងគោរពបំរើស្វាមីរបស់ខ្លួនយ៉ាងនោះ ។

ភរិយាស្មើប្អូនស្រី បានសេចក្តីថា ភរិយាដែលគោរពដល់ស្វាមីប្រៀបឧបមាដូចជាប្អូនស្រី ធម្មតាប្អូនស្រីតែងជាទីស្រឡាញ់រាប់អានថ្នាក់ថ្នមរបស់បងប្រុស បងស្រីយ៉ាងណា ឯភរិយាក៏ថ្នាក់ថ្នមចំពោះស្វាមីរបស់ខ្លួនមិនអោយមានទាស់ខុសក៏យ៉ាងនោះដែរ ។

ភរិយាស្មើនឹងសម្លាញ់ បានសេចក្តីថា ភរិយាដែលស្រឡាញ់រាប់អានលើកមុខស្វាមី, ធម្មតាសម្លាញ់តែងជាទីស្រឡាញ់ ជាទីទុកចិត្ត ជាពំនឹង តែងរក្សាថ្នើមចំពោះគ្នា និងគ្នា ចេះជួយគ្នាក្នុងគ្រាកាលដែលមានអាសន្នអន់ក្រ មួយដងមួយកាលយ៉ាងណា ឯភរិយាក៏ស្រឡាញ់រាប់អានចំពោះស្វាមីយ៉ាងនោះដែរ ។

ភរិយាស្មើនឹងខ្ញុំកំដរ បានសេចក្តីថា ៖ ភរិយាដែលទុកស្វាមីដូចជាចៅហ្វាយនាយ គឺកិច្ចការអ្វីៗ ភរិយាត្រួតត្រាក្តោបក្តាប់ទាំងអស់ ឥតមានសិទ្ធិសេរីភាព ក្នុងកិច្ចការគ្រប់គ្រងទ្រព្យសម្បត្តិ ឬអ្វីៗ ទាំងអស់ ធម្មតាខ្ញុំបំរើតែងមិនមានសិទ្ធិ និងគ្រប់គ្រង់នូវទ្រព្យសម្បត្តិ ឬគ្រប់គ្រងកិច្ចការណាមួយ មានតែកម្លាំងខំធ្វើការបំរើគេ ផ្គាប់ផ្គន់គេ ឬផ្គាប់ផ្គន់នាយចៅហ្វាយធ្វើយ៉ាងណាអោយនាយចៅហ្វាយពេញចិត្ត ស្រឡាញ់រាប់អាន, ឯភរិយា ដែលទុកស្វាមីដូចជាចៅហ្វាយ ក៏យ៉ាងនោះឯង គឺអោយតែស្វាមី

Websites: WatKhemaraRatanaram.org or WatKhmers.org

ខំរកទ្រព្យសម្បត្តិបានមកអោយច្រើន តែគ្មានអំណាច និងចាត់ចែងរៀបចំយ៉ាងណា ៗនោះគ្មានសោះឡើយ ដូចសព្វថ្ងៃយើងក៏ឃើញហើយ ដូចពាក្យគេតែពោលថា " មនុស្សប្រុសខ្លាចប្រពន្ធ " ឬ "ស្វាមីខ្លាចប្រពន្ធ បានសេចក្តីថា ប្រពន្ធគេអាចគ្របសង្កត់បាន " ។

ឯចំណែកខាងស្វាមីវិញក៏មានន័យប្រហែលគ្នា និងភរិយាដែលបានសំដែងមកនេះឯង សូមអ្នកសិក្សាគប្បី យល់ន័យដូចបានពោលមកហើយខាងលើនេះ ។

**ភរិយា** ក្បត់ចិត្តស្វាមីដោយហេតុ ៩ យ៉ាងគឺ :

១.**អារាមគមនសីល** តែងដើរទៅលេងសួនច្បាររឿយៗ

២.**ឧយ្យានគមនសីលា** តែងដើរទៅលេងឧទ្យានរឿយៗ

៣.**នទីតិត្ថគមនសីលា** តែងដើរទៅលេងកំពង់ទឹករឿយៗ

៤.**ញាតិកុលគមនសីលា** តែងដើរទៅលេងត្រកូលនៃញាតិរឿយៗ

៥.**បរកុលគមនសីលា** តែងដើរទៅលេងត្រកូលដទៃរឿយៗ

៦.**អាភរណគមនសីលា** តែងដើរទៅលេងរកគ្រឿងតែងខ្លួនរឿយៗ

៧.**មជ្ជបាយិនី** តែងផឹកទឹកស្រវឹងរឿយៗ

៨.**តិត្ថិច្ឆិទ្ទេស្ស ឱលោកនី** ចូលចិត្តលបមើលតាមចន្លោះជញ្ជាំង

៩.**គាមទ្វារេ ឋិតសីលា** តែងដើរទៅឈរលេងក្បែរទ្វារភូមិនៃស្រុករឿយៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភរិយាដែលឧស្សាហ៍ដើរទៅលេងសួនច្បាររឿយៗតែងដើរទៅលែងក្នុងឧទ្យានរឿយៗ តែងដើរទៅកាន់កំពង់ទឹករឿយៗ, កន្លែងនោះជារមណីយដ្ឋាន ទីជាទីរីករាយនៃចិត្តៗ អាចភ្លើតភ្លើន បង្កើននូវកាមារម្មណ៍ ។ ភរិយាដើរទៅលេងត្រកូលជាញាតិរបស់ខ្លួនរឿយៗ ដើរទៅលេងត្រកូលនៃជនដទៃរឿយៗ កាលបើទៅញឹកៗញយៗ ជួបជុំគ្នាច្រើនតែងពោលនូវពាក្យញុំញង់ ពាក្យចាក់ដោត ហើយច្រើនតែនិយាយពីស្វាមីរបស់ខ្លួនយូរៗទៅបើសិន ជាស្វាមីនោះមិនជាទីស្រឡាញ់រាប់អាន ស្វាមីមិនជាទីពេញចិត្តរបស់ញាតិនៃខ្លួនផងនោះ រមែងនឹងនាំទៅផ្លូវខុស ធ្វើអោយគ្រាកចិត្តអំពីស្វាមីរបស់ខ្លួនដោយពិត ។

ភរិយាដែលលេងខ្លួន ហើយដើរទៅរកគ្រឿងតែងខ្លួនជាញឹកញយមកមិនល្អដែរ, ភរិយាដែលចេះសេពសុរាជារឿយៗ ក៏មិនប្រសើរដែរយូរៗទៅក៏គង់រករឿងឈ្លោះទាស់ទែងប្រកែកជជែកគ្នា យូរៈៗទៅក៏គង់តែលែងលះគ្នាមិនខាន ដោយហេតុយកស្រាជាត្រីមុខ ។ ស្ត្រីដែលធ្លាប់សំឡក់សំឡឹង លបលួចមើលគេឯង មានលបលួចមើលប្រុសឈ្មោលជាដើម នេះក៏ជាអំពើមិនគួរគប្បីសោះឡើយ ។ ឧស្សាហ៍ដើរទៅឈរក្បែរទ្វារនៃភូមិស្រុក ក៏មិនគួរគប្បីដែរ ពីព្រោះដើរលេង ឬទៅឈរលេងយូរៗទៅក៏នាំពយមានសតិអារម្មណ៍មិនល្អ ជាហេតុធ្វើអោយចិត្តនោះជក់ ឬខ្វូតទៅរកអារម្មណ៍ដែលនាំអោយចិត្ត វិបល្លាសយល់ខុស អាចធ្វើអោយ

ចិត្តនោះនឿយណាយ ចំពោះស្វាមីរបស់ខ្លួន ហើយងាកចិត្តចង់ទៅរកស្វាមីថ្មីទៀតយ៉ាងនេះ ឈ្មោះថាក្បត់ចិត្តចំពោះស្វាមី ។

## រឿង ចុឡធនុគ្គហបណ្ឌិត

### ភរិយាក្បត់ចិត្តស្វាមី

ក្នុងគម្ពីធម្មបទខុទ្ទកនិកាយ ព្រះបរមគ្រូទ្រង់សំដែងប្រារព្ធ និងភិក្ខុអផ្សុក១រូប នាំអតីតនិទាននោះមកដំណាលដូចតទៅនេះ :

ក្នុងអតីតកាលកន្លងទៅហើយ ចូឡធនុគ្គហបណ្ឌិត បានទៅសិក្សាសិល្បសាស្ត្រក្នុងសំណាក់អាចារ្យទិសាបាមោក្ខក្រុងតក្កសិលា ។

លុះចប់កិច្ចសិក្សាហើយ អាចារ្យផ្សំផ្គុំកូនស្រីរបស់ខ្លួនអោយជាភរិយា ។ កាលនោះ ចុឡធនុគ្គហបណ្ឌិតបានលាអាចារ្យជាបិតាក្មេកនាំភរិយាទៅកាន់ក្រុងពារាណសី ជាស្រុកដើមរបស់ខ្លួន នាំយកទាំងធ្នូ និងកូនស ៤៩ ដើមជាប់ទៅផង ។ លុះទៅដល់ពាក់កណ្តាលផ្លូវប្រទះនឹងចោរ ៥០ នាក់ ចោរទាំងនោះប្រយុទ្ធ និង ចុឡធនុគ្គហបណ្ឌិតដោយសេចក្តីអង់អាច ចុឡធនុគ្គហបណ្ឌិត បានបាញ់ចោរទាំងនោះស្លាប់អស់ ៤៩ នាក់ នៅសល់តែមេចោរមួយ ចុឡធនុគ្គហបណ្ឌិត ប្រវាជាប់មេចោរនោះបំណងនឹងសំលាប់អោយស្លាប់ទៀត ស្រែកហៅភរិយាអោយយកដាវ មកអោយខ្លួនតែភរិយាក្បត់មានចិត្តប្រតិព័ទ្ធចំពោះមេចោរ បានយកដាវមកហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហុចខាងផ្លែអោយទៅស្វាមី ខាងដងហុចទៅអោយចោរៗ ចាក់សម្លាប់ចុឡធនុគ្គហបណ្ឌិតស្លាប់ក្នុងទីនោះ ។

ភរិយារបស់ចុឡធនុគ្គហបណ្ឌិត កាលបើស្វាមីស្លាប់ហើយ ក៏យកមេចោរធ្វើជាស្វាមី មេចោរមានគំនិតថា : ស្រីនោះហ៊ានសម្លាប់ស្វាមីរបស់ខ្លួន បើរស់នៅជាមួយអញយូរទៅ គង់ថ្ងៃណា នឹងសម្លាប់អញចោលជាមិនខាន លុះគិតដូច្នោះ ហើយក៏សម្លាប់ស្ត្រីនោះចោលទៅ ។

ការសំដែងមកក្នុងគាថាទី ១០ នៃបរាភវសូត្រ ដែលមានសេចក្ដីថា :

បុរសមានវ័យដែលចាស់ហួសពេក ហើយមានតម្រេកដោយកាមតណ្ហា នាំយកស្រីក្មេងមកធ្វើជាភរិយា ហេតុនោះទៅនាំអោយវិនាស ។

ការសំដែងមកនេះ ក៏សន្មត់

ថា ចប់តែប៉ុណ្ណេះ ឯវ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសុត្ត

## នមោ តស្ស

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

**វិសុទ្ធិករុណាញាណំ ពុទ្ធំសម្ពុទ្ធបូជិតំ ធម្មំ សទ្ធម្ម-សម្ភូតំ វន្ទេ សង្ឃំ និរង្គណំ ។**

ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គមានព្រះហឫទ័យ ករុណាដល់សត្វដទៃ គឺថាទ្រង់បៀតបៀននូវកងទុក្ខដែលមានក្នុងសន្តាននៃសត្វដទៃ ដោយព្រះញាណ ពោលគឺព្រះអរហន្តមគ្គដ៏ម៉ត់ចង់ស្អាតចាក មន្ទិលគឺរាគាទិក្កិលេស ។ សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់គឺព្រះសម្ពុទ្ធបូជាហើយ ដែលកើតដោយអរិយជាតិ ព្រោះព្រះសទ្ធម្មជាអ្នកមិនមានដំណើរទៅកាន់ភាវៈទាបគឺកិលេសឡើយ ។

បន្ទាប់អំពីបទនមស្សការដោយសង្ខេប បែបខ្លីនេះទៅ ខ្ញុំព្រះ-ករុណាអាត្មាភាព សូមលើកយកគាថាទី ១១ នៃបរាភវសូត្រមកសំដែងប្រកាសចែកជូនដល់អស់លោកអ្នកសប្បុរសទាំងឡាយ ដែលបានអញ្ជើញមកជួបជុំក្នុងទីនេះ មានបំណងប៉ងនឹងក្រេប ជញ្ជក់នូវអត្ថរស នៃព្រះ-សទ្ធម្មវិសេសទេសនា ដើម្បីជាឧបនិស្ស័យវាសនា ប្រដាប់សតិបញ្ញា ស្មារតីតទៅអនាគតជាតិ ដូចសំដែងតទៅនេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

ទេវតាទូលសួរតទៅទៀតថា :

**ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ**
**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ ក្តីវិនាសនោះបើរាប់សង្គ្រោះវិនាសនោះឈ្មោះទី១០ ទាន់ហន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា :

**ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ឋបេតិតំ បរាភវតោ មុខំ ។**

បុរសតាំងស្ត្រីក្នុងលេងខ្ជះខ្ជាយ ឬ ស្ត្រីទាំងឡាយតាំងបុរសនោះដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំអោយវិនាស ។

## អធិប្បាយ

## គាថាទី១១

បុរសស្ត្រីក្នុងលោក មានឧដ្ឋានភាព គឺការខ្នះខ្នែងប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ បានមកហើយ ហើយដោយសមាជីវោ ហើយដែលនៅគ្រប់គ្រងផ្ទះ ត្រូវប្រកបទៅដោយគុណធម៌៤ យ៉ាងគឺ :

**១-សច្ច** សេចក្តីពិតត្រង់

Websites: WatKhemaraRatanaram.org or WatKhmers.org

**២-ទម** សេចក្ដីទូន្មានចិត្ត

**៣-ខន្តី** សេចក្ដីអត់ធន់

**៤-ចាគ** ការបរិច្ចាគទាន ។

**សច្ច** សេចក្ដីពិតត្រង់ ស្វាមីត្រូវមានសេចក្ដីពិត ត្រង់ដល់ភរិយា។ ក៏ត្រូវមានចិត្ត សេចក្ដីពិតត្រង់ដល់ស្វាមីវិញដែរ, ត្រូវមានទមៈ គឺការទូន្មានចិត្តគ្នា ទៅវិញទៅមក, ត្រូវមានខន្តី សេចក្ដីអត់ធន់ អត់ធ្មត់ដល់គ្នានិងគ្នា, ចាគ ត្រូវមានការបរិច្ចាគ ចំណាយទិញ សំលៀកបំពាក់ ដល់គ្នា និងគ្នា ។ កាលបើប្រព្រឹត្តតាមគុណធម៌ទាំង ៤ នេះ ទើបបានសេចក្ដីសុខក្នុងគ្រួសារឈ្មោះថាស្ថិតនៅក្នុង សុភមង្គល ។

បើខ្វះគុណធម៌ទាំង ៤ នេះ អ្នកនៅគ្រប់គ្រងផ្ទះ ពុំសូវបានសេចក្ដី សុខសេចក្ដីចំរើនទេ ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់សំដែងថា គ្រហស្ថអ្នកនៅគ្រប់គ្រងផ្ទះ រកទ្រព្យបានមកហើយត្រូវបែងចែកជាចំណែក ៤ យ៉ាង :

១-អោយសងបំណុលចាស់ បានដល់ការទំនុកបំរុងចិញ្ចឹមមាតាបិតា

២-បុលបំណុលថ្មី បានដល់ការទំនុកបំរុងចិញ្ចឹមកូន

៣-បោះទៅក្នុងជ្រោះជ្រៅ បានដល់ការចាយវាយប្រើប្រាស់ ក្នុងគ្រួសារ និងបង់ពន្ធដារជូនដល់រដ្ឋ ។

៤-កប់ទុកជាកំណប់ព្រេង បានដល់ធ្វើបុណ្យសន្សំទានសំរាប់ជីវិតទៅក្នុងបរលោក ។

កាលបើគ្រហស្ថ ចេះបែងទ្រព្យបានយ៉ាងនេះ រមែងបានសេចក្តីសុខចំរើន ដោយពិតប្រាកដ ។ មួយទៀតព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់សំដែងបញ្ជាក់ថា បុរសស្ត្រីក្នុងលោកនេះ ដែលអាចរស់នៅជាសុខនឹងគ្នា បានដោយមានសង្គហធម៌ គឺការសង្គ្រោះគ្នាទៅវិញទៅមក មាន ៤ យ៉ាងគឺ :

**១-ទាន** ការអោយ ឬបែងចែកនូវទេយ្យវត្ថុអោយដល់អ្នកដទៃ ។

**២-បិយវាចា** ពោលវាចាពីរោះជាទីស្រឡាញ់ ។

**៣-អត្ថចរិយា** ប្រព្រឹត្តនូវការជាប្រយោជន៍ ដល់អ្នកដទៃ ។

**៤-សមានត្តតា** ជាអ្នកតាំងខ្លួនស្មើមិនប្រកាន់ខ្លួន ។

គម្ពីរអង្គុត្តរនិកាយ ទុកនិបាត តាមលំអាន ព្រះពុទ្ធដីកាថា :

**ទ្វេមានិ ភិក្ខវេ ទានានិ ។**

**កតមានិទ្វេ ? អាមិសទានញ្ច ធម្មទានញ្ច ឯតានិ ខោ ភិក្ខវេ ទ្វេ ទានានិ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។**

ម្នាលភិក្ខុទាំងឡាយ ទានមាន ២ ប្រការ, ទានទាំងពីរប្រការតើដូចម្តេចខ្លះ ?

**ទានទាំង ២ ប្រការនោះគឺ :**

**១-អាមិសទាន** ការអោយអាមិសទាន

**២-ធម្មទាន** ការអោយធម៌ជាទាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្នាលភិក្ខុទាំងឡាយ ! បណ្តាទានទាំង ២ ប្រការនេះ ធម្មទាន ប្រសើរជាងអាមិសទាន ។

**ក/ទានៈ** ការអោយវត្ថុដែលគួរអោយដល់បុគ្គលដែលគួរអោយ ជាសេចក្តីសំដៅយករបស់ ពាក្យថាទានក្នុងទីនេះ ។ វត្ថុដែលគួរអោយនោះ គឺរបស់ដែលអ្នកអាចទទួលយក ទៅប្រើជាប្រយោជន៏ដល់ខ្លួនបានក្នុងផ្លូវ ដែលមិនខុស ដូចយ៉ាងសំពត់សាវអាវ ស្បៃទីសំណាក់ផាក់អាស្រ័យ អាហារបរិភោគ ថ្នាំកែរោគជាដើម ។ បើអោយថ្នាំកែរោគដល់មនុស្ស ដែលត្រូវការអាហារ ឬ អោយគ្រឿងស្លៀកពាក់ ដល់អ្នកដែលត្រូវការ ទីសំណាក់ផាក់អាស្រ័យ របស់នោះរមែងមិនជាប្រយោជន៏ ព្រោះខុស សេចក្តីត្រូវការរបស់អ្នកទទួល ឬ យើងអោយវត្ថុជាកំលាំងដល់ចោរជា មនុស្សបរោអាក្រក់ វានឹងនាំរបស់ដែលបានទទួលទៅប្រើក្នុងផ្លូវខុស របស់នោះទើបមិនជាទានវត្ថុ គឺរបស់ដែលមិនគួរអោយឡើយ ។

បុគ្គលដែលគួរអោយនោះ បែងចែកជា ៣ ប្រភេទគឺ មនុស្សកំសត់ ទុគិត វិកលវិការ ជាមនុស្សដែលគួរអោយអនុគ្រោះ ១ , មនុស្សដែលមាន ឋានៈស្មើៗនឹងយើង គួរអោយដោយឋានៈសង្គ្រោះចំពោះគ្នា នឹងគ្នា ១ មនុស្សដែលមានឧបការលើយើងដូចជា មាតាបិតា ឬមនុស្សដែលមាន គុណធម៌ខ្ពស់ ដូចភិក្ខុសាមណេរ ជាក្រុមសាមណៈ គួរអោយបូជាគុណ ១។ អោយដល់មនុស្សទុគិតជាការសំដែង សេចក្តីមេត្តា អាណិត អាសូរ ,

Websites: WatKhemaraRatanaram.org or WatKhmers.org

អោយដល់មនុស្សដែលមានឋានៈស្មើនឹងយើង ជាការសំដែងសេចក្ដីមេត្រីរាប់អាន អើពើដល់គ្នា និងគ្នា ជាការចងមិត្តទុក បានយ៉ាងល្អ, អោយដល់អ្នកគួរបូជា ដូចមាតាបិតា ជាការសំដែងសេចក្ដីកតញ្ញូកតវេទី ឬអោយដល់សមណៈ ក៏ជាការសំដែងសេចក្ដីគោរពក្នុងសីលធម៌ ដោយអោយកំលាំងដល់អ្នកប្រព្រឹត្តល្អ លះសិទ្ធិទាំងអស់ក្នុងផ្លូវលោក ចេញបួសប្រព្រឹត្តខ្លួន ក្នុងផ្លូវស្ងប់ ហើយទូន្មាន ប្រៀនប្រដៅសត្វលោកអោយស្ងប់ផង ។

ម្យ៉ាងទៀត ការអោយទានដែលមានផលានិសង្សច្រើននោះ ត្រូវប្រកបទៅដោយអង្គ ៣ គឺ ទានវត្ថុ មិនអាក្រក់ ជារបស់ដែលខ្លួនបរិភោគប្រើប្រាស់ និងជាធម្មលទ្ធវត្ថុ ធម្មិកវត្ថុ គឺរបស់ដែលបានមកដោយធម៌ កើតឡើងដោយធម៌ ប្រកបដោយធម៌ មិនជារបស់បានមកដោយទុច្ចរិត ឆបោក លួចប្លន់ ឆក់ដណ្ដើម សម្លាប់សម្លេះ អ្នកដទៃ១, អ្នកអោយតាំងចិត្ត អោយពេញចិត្ត អោយមែន២ អោយដោយសទ្ធាជាញាណ សម្បយុត្តអោយដោយមានហេតុផល ដល់ព្រមដោយចេតនា ទាំង ៣ កាលគឺបុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា មុនអោយកំពុងអោយ អោយរួចហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា ។

ការអោយដោយសទ្ធាជ្រះថ្លា មិនមែនអោយដោយសោះតែខានឬកញ្ជះកញ្ជោយ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរថា : **សទ្ធាយ ទានំ ទទតោ ឯវំបុញ្ញំ បវឌ្ឍតិ ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាយកអោយទាន ដោយសទ្ធាជ្រះថ្លា បុណ្យរមែងចំរើន ។

សាធុសប្បុរសទាំងឡាយ ! អ្នកមានទ្រព្យ មានសទ្ធា កុំថាឡើយ ដល់អ្នកមានទេយ្យវត្ថុ ច្រើនពោរពាស សូម្បីតែវត្ថុបន្តិចបន្តួច ដែលមានចិត្តជ្រះថ្លា ហើយបានចំណាយវត្ថុ នោះទៅជាទាន ក៏គង់បានផលានិសង្ឃច្រើន សមដូចរឿង នាងរាជគហទារិកា គុណនៃការប្រគេននំដល់ព្រះ-មោគ្គល្លាន មានសេចក្តីដំណាលថា ៖ កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ ។ កាលនោះមាននាងទារិកាម្នាក់ នៅក្នុងក្រុងរាជគ្រឹះ ជាកូនរបស់ឧបដ្ឋាកព្រះសាសនាដល់អាយុ ១៦ ឆ្នាំ មាតាបិតាបានរៀបចំឱ្យមានស្វាមី ហើយបញ្ជូនអោយទៅនៅខាងសំណាក់មាតាបិតាក្មេក ។ ឯមាតាបិតាក្មេកនោះ ជាមនុស្សមិច្ឆាទិដ្ឋិ មានចិត្តរបើងរឹងរូស មិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅបិណ្ឌបាតក្នុងភូមិនោះ, នាងជាកូនប្រសារបានឃើញហើយ ក៏ចុះទៅនិមន្តអោយឈប់នៅមុខផ្ទះរបស់ខ្លួន ទើបនាងទៅប្រាប់ដល់ម្តាយក្មេកៗនោះធ្វើជាមិនឮ គេចចុះពីផ្ទះទៅ ។ នាងដឹងហេតុនោះហើយ គិតពិចារណាថា ក្នុងផ្ទះនេះមានវត្ថុអ្វីល្មមប្រគេនលោក មានតែនំមួយដែលម្តាយគាត់ទុកពិសា ហើយយកនំនោះទៅកាត់ជាពីរចំណែក មួយចំណែកទុកជូនម្តាយ មួយចំណែកទៀតយកប្រគេនព្រះមហាមោគ្គល្លាន ៗ ធ្វើភត្តានុមោទនាហើយ ក៏និមន្តហួស

បាត់ទៅ ។ ម្តាយក្មេកបានឃើញព្រះមោគ្គល្លាន និមន្តចេញទៅផុតហើយ ក៏ឡើងទៅលើផ្ទះ ។ នាងទារិកាក៏ចូលទៅអង្គុយបត់ជើងលើកដៃប្រណម្យ ជូនបុណ្យដែលបានប្រគេននំនោះដល់ម្តាយក្មេកៗ ខឹងខ្លាំងណាស់ ក្រឡេក មើលទៅកៀនជញ្ជាំងឃើញអង្រែមួយ ក៏ចាប់អង្រែនោះសំពងកូនប្រសារ ត្រូវត្រង់ចង្កួយស្មា ស្លាប់ក្នុងពេលនោះទៅ ។ កូនប្រសារនោះក៏បានទៅ កើតក្នុងឋានតាវត្តឹង ។ ថ្ងៃមួយព្រះមហាមោគ្គល្លាននិមន្តទៅកាន់ឋានតាវ ត្តឹង្ស បានឃើញនាងទេពធីតាស្ថិតនៅក្នុងវិមានមាស មានស្រីទេពអប្សរ កំពុងចោមរោចបំរើ , លោកនិមន្តទៅក្បែរវិមាននោះ ។ នាងទេពធីតា បានឃើញហើយ មានសេចក្តីត្រេកអរណាស់នឹកថា ព្រះថេរនេះហើយ ដែលបានសង្គ្រោះដល់អញក្នុងជាតិមុន ក៏នាំបរិវារចុះទៅថ្វាយបង្គំ ។ ព្រះមហាមោគ្គល្លាន មានថេរដីការសួរប្រវត្តិរបស់នាងៗ បានរៀបរាប់ប្រ-គេនដោយសព្វគ្រប់ លោកក៏ត្រឡប់មកស្ថានមនុស្សវិញ នាំដំណឹងនោះ ទៅក្រាបទូលព្រះមានព្រះភាគៗទ្រង់ប្រារព្ធរឿងនោះ អោយជាហេតុ ហើយ ក៏សំដែងនូវអានិសង្សរបស់ទាន ជាភិយ្យោភាពក្នុងពេលនោះៗ ។

**២/បិយវាចា** ពោលពាក្យពិរោះ ជាទីស្រឡាញ់, បានសេចក្តី ថាវាចា គឺសម្តីទន់ភ្លន់ សម្តីផ្អែមល្ហែម សម្តីសុភាពរាបសា សម្តីប្រកប ដោយអត្ថន័យ សម្តីប្រកបដោយប្រយោជន៍ហៅបិយវាចា ។

**វាចាល្អប្រកបដោយអង្គ ៥ យ៉ាងគឺ :**

**១-កាលញ្ញូ** ពោលពាក្យតាមកាល

**២-បិយវាចា** ពោលពាក្យពិរោះ

**៤-អត្ថវាចា** ពោលពាក្យមានប្រយោជន៍

**៥-មនោសុចរិត** ពោលពាក្យមនោសុចរិត ។

បុរសស្ត្រីក្នុងលោក គប្បីលះបង់នូវគួថភាណី សម្ដីលាមក សម្ដីអាក្រក់ចេញ ហើយគប្បីពោលតែបិយវាចាសម្ដីជាស្រទ្បាញ់ ពេញចិត្ត សម្ដីគាប់ចិត្ត មុធុរវាចា សម្ដីទន់ភ្លន់ផ្អែមល្ហែមដូចទឹកឃ្មុំ ទោះបីបើនិយាយសុំអ្វី អំពីអ្នកណាមួយ របស់មិនមានសោះ ក៏គេអាចជួយរកទាល់តែបាន ឬ បើរបស់មានស្រាប់គេក៏អោយដោយភ្លាមៗ ដូចរឿងសេដ្ឋីបុត្ត ៤ នាក់ សូមនាំនិទាននោះមកសំដែងដូចតទៅនេះ គុណនៃបិយវាចា :

កាលកន្លងទៅហើយ មានសេដ្ឋីបុត្ត ៤ នាក់ នៅក្នុងពារាណសី ថ្ងៃមួយមានសេចក្ដីអផ្សុកអប្បាន្តយ៉ាងខ្លាំង ក៏បបួលគ្នាចេញពីគេហដ្ឋានរៀងៗខ្លួន ទៅអង្គុយកំសាន្តចិត្តក្នុងកន្លែងមួយស្រាប់តែឃើញ ព្រានម្រឹគម្នាក់បរទេសចេញមកពីព្រៃ ផ្ទុកពេញទៅដោយសាច់បក្សាបក្សី គ្រប់បែប ក៏និយាយសុំសាច់របស់ព្រានដោយបញ្ញាផ្សេងៈពីគ្នា ។

**សេដ្ឋីបុត្តទី១ ផ្ដើមនិយាយសុំថា :**

Websites: WatKhemaraRatanaram.org or WatKhmers.org

**អរេ លុទ្ទក ទេហិ មេ មំសខណ្ឌំ** នែ ! អាចចង្រៃព្រានម្រឹគឯង ចូរអោយសាច់ដុំមកអញ ។

ព្រានម្រឹគពោលគាថា ថា : **ផរុសាវតុ តេ វាចា មំសយាចនកោ អសិ, កិលោមសទិសី វាចា កិលោមំ សម្ម ទាមិ តេ ។** អ្នកជាបុគ្គលសុំនូវសាច់ ហើយប្រើសំដីឈ្លើយ ព្រហើនពេកណាស់, សម្តីអ្នកបែបស្មុគស្មាញដូចសាច់វាវ, ហ៎ ! សម្លាញ់យកសាច់វាវទៅចុះ ហើយក៏អោយសាច់វាវ ដែលឥតមានរស់ជាតិអ្វីដល់សេដ្ឋីបុត្តទី១នោះ ។

សេដ្ឋីបុត្តទី២ពោលថា :

**ជេដ្ឋភាតិក មំសខណ្ឌំ មេ ទេហិ,** បពិត្រអ្នកបង ចូរអ្នកបងអោយសាច់ដុំមកខ្ញុំ ។

ព្រានម្រឹគពោលគាថាតបថា :

**អង្គមេតំ មនុស្សានំ ភាតា លោកេ បវុច្ចតិ**
**អង្គស្ស សទិសី វាចា អង្គំ សម្ម ទទាមិ តេ ។**

ពាក្យថាបងនេះ ជាលោកវោហារបស់សាមញ្ញជនទូទៅទេតើ សម្តីអ្នកប្រាកសស្មើដោយអវយវៈ ហ៎! សម្លាញ់យកសាច់អវយវៈទៅចុះ ហើយអោយសាច់អវយវៈ ដល់សេដ្ឋីបុត្រទីពីរនោះ ។

សេដ្ឋីបុត្តី៣ ពោលសុំថា :

**តាត មំសខណ្ឌំ មេទេហិ,** ប៉ាៗប៉ា អោយសាច់ដុំមកខ្ញុំ ។ ព្រានក៏អោយសាច់ដ៏សមគួរដល់សម្តីនោះហើយពោលគាថាជាគំរប់៣ ថា :

**តាតតិ បុត្តោ វទមានោ កម្បេតិ ហទយំ បិតុ,**
**ហទយស្ស សទិសីវាចា ហទយំ សម្ម ទទាមិ តេ ។**

កូនហៅ ឪពុកថា ប៉ាៗ ដូច្នេះ រមែងញ៉ាំងបេះដូង ឪពុកអោយញាប់ញ័រ សម្តីអ្នកប្រាកដស្មើដោយបេះដូង ហ៎ ! សម្លាញ់យកសាច់ បេះដូងទៅចុះ ហើយអោយសាច់ឆ្ងាញ់ពិសាព្រម ទាំងសាច់បេះដូង ដល់សេដ្ឋីបុត្តទី ៣នោះ ។

សេដ្ឋីបុត្តទី ៤ ពោលសុំថា :

**សហាយ មំសខណ្ឌំ មេ ទេហិ ,** សម្លាញ់អ្នកអោយសាច់ដុំមកខ្ញុំ ។ ព្រានអោយសាច់ដុំដ៏សមគួរសមរម្យ ដល់សម្តីនោះ ហើយពោលគាថាជាគំរប់ ៤ ថា :

**យស្ស គាមេ សខា នត្ថិ យថារញ្ញំ តថេវ តំ**
**សព្វស្ស សទិសីវាចា សព្វំ សម្ម ទទាមិ តេ ,**

អ្នកណាគ្មានសម្លាញ់ក្នុងស្រុក ស្រុកអ្នកនោះដូចជាព្រៃស្ងាត់ជ្រងំ សម្តីអ្នកប្រាកដស្មើ ដូចសាច់ទាំងអស់ ហ៎! សម្លាញ់យកសាច់ទាំងអស់នោះទៅចុះ ហើយគាត់បរទេសដ៏ពេញដោយសាច់ទាំងអស់យកទៅអោយសេដ្ឋី

បុត្តទី៤នោះដល់ទីលំនៅ ។ សេដ្ឋីទី ៤នោះ កាលបើទទួលអំណោយសាច់ទាំងអស់របស់ព្រានម្រឹគហើយក៏យកគ្នាជាសម្លាញ់ ភ្ញៀនហើយអោយទៅប្រពន្ធមកនៅកណ្តាលសម្បត្តិ ដរាបដល់អស់ជីវិត មិនមានប្រេះឆាអ្វីដល់គ្នាឡើយ ។

ពុទ្ធបរិស័ទទាំងឡាយ ! គប្បីទម្លាប់ពោលតែសម្តីពីរោះពិសា សម្តីជាទីស្រឡាញ់ពេញចិត្ត ហើយត្រូវចៀសវាង នូវសម្តីមិនពិត មិនទៀងត្រង់ ពីព្រោះសម្តីមិនទៀងត្រង់ បើនិយាយសុំអ្វីពីអ្នកដទៃ បើរបស់មានគេប្រាប់ថាគ្មានទៅក៏សឹងមាន, ឬមានរបស់មានតែគេអោយក៏អោយតាមសម្តីរបស់យើងពោល លុះត្រាតែយើងពោលពាក្យទៀងត្រង់ ទើបយើងបានទទួលផលល្អ ដូចជាសេដ្ឋីបុត្ត ៣ នាក់ សូមនាំនិទាននោះមកបញ្ជាក់ បន្ថែមទៀតដូចតទៅនេះ :

កាលយូរលង់ណាស់មកហើយ មានសេដ្ឋីបុត្ត ៣ នាក់នៅក្នុងក្រុងពារាណសី ។ ជួនជាក្នុងនរគនោះ មានស្រះមួយដ៏ពោរពេញទៅដោយផ្កាឈូកក្រហមសរីកស្គុះស្គាយ គួរជាទីមនោរម្យក្រៃពេក ។ មានបុរសកំបុតច្រមុះម្នាក់ជាអ្នកថែរក្សា ។ ថ្ងៃមួយសេដ្ឋីបុត្តទាំង ៣ នាក់នោះចង់ប្រដាប់កាយដោយកម្រងផ្កា ហើយនឹងលេងមហោស្រព ក៏ចូលទៅរកបុរសកំបុតច្រមុះ ហើយគិតថាយើងនឹងពោលនូវគុណរបស់បុរសកំបុតច្រមុះនោះដោយពាក្យមិនពិត ហើយនិយាយសុំផ្ការៀងៗខ្លួន :

Websites: WatKhemaraRatanaram.org or WatKhmers.org

សេដ្ឋីបុត្តទី ១ពោលសុំដោយបទគាថា ថា :

**យថា កេសា ច មស្សុ ច ឆិន្នំ ឆិន្នំ វិរូហតិ**

**ឯវំ រូហតុ តេ នាសា ឫន្ទមំ ទេហិ យាចិតោ ៗ**

សក់ និងពុកមាត់ ដែលគេកាត់កោរហើយ រមែងដុះវិញយ៉ាងណា ច្រមុះអ្នកក៏ដុះវិញយ៉ាងនោះ ចូរអោយផ្កាឈូកដល់ខ្ញុំ ។

សេដ្ឋីបុត្តទី២ ពោលសុំថា :

**យថា សារទិកំ ពីជំ ខេត្តេ វុត្តំ វិរូហតិ**

**ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ ៗ**

ពូជដុះក្នុងសរទកាលដែលគេព្រោះក្នុងស្រែយ៉ាងណា ច្រមុះអ្នកក៏ដុះយ៉ាងនោះ ចូរអោយផ្កាឈូកដល់ខ្ញុំ ។

សេដ្ឋីបុត្តទី ៣ ពោលសុំថា :

**ឧភោបិ បលបន្តេ តេ អបិ បទានិ ទស្សតិ**

**វិជ្ជំ វា តេន វា វជ្ជំ នត្ថិ នាសាយ រូហនា**

**ទេហិ សម្ម បទុមានិ អហំបិ មេ តស្ស យាចិតោ ៗ**

សេដ្ឋីបុត្ត ២ នាក់ នោះពោលបញ្ឆោះ ដើម្បីអោយអ្នកអោយផ្កាឈូក តាមការពិតសេដ្ឋីបុត្រ នោះពោលក្តី មិនពោលក្តី ធម្មតាច្រមុះមិនល្បីថាដុះវិញឡើយ ! ម្នាលសម្លាញ់ខ្ញុំសុំផ្កាអ្នក ចូរអ្នកអោយផ្កាដល់ខ្ញុំ ។

បុរសកំបុតច្រមុះ ឬពាក្យនោះពោលតបថា សេដ្ឋីបុត្តទាំងពីរ នោះពោលពាក្យមុសាវាទ រកការពិតគ្មាន ឯសេដ្ឋីបុត្រទី ៣ ពោលតាមពិត ខ្ញុំនឹងអោយផ្កាដល់សេដ្ឋីទី៣ ហើយហុចអោយនូវបាច់ផ្កា ឈូកដ៏ធំដល់សេដ្ឋី បុត្រទី ៣ នោះ ។

**គ/អត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ ដល់ជនដទៃ, បាន សេចក្តីថា អ្នកប្រាជ្ញទាំងឡាយមានពុទ្ធាទិបណ្ឌិតជាដើម កាលព្រះអង្គ ប្រាថ្នា ដើម្បីអោយបានត្រាស់ដឹងជាសព្វញ្ញុពុទ្ធ ក៏ព្រះអង្គខំកសាងបារមី អស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប, ក្នុងការកសាងនេះព្រះអង្គ បំពេញនូវចរិយា ៣ យ៉ាងគឺ :

**១_លោកត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ដល់សត្វលោក ។

**២_ញាតត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ដល់ព្រះញាតិ ។

**៣_ពុទ្ធត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ តាមឋានៈនៃព្រះពុទ្ធ ។

ការប្រព្រឹត្តនៃព្រះសម្មាសម្ពុទ្ធ ជាប្រយោជន៍ដល់លោកគឺសត្តនិករ ទូទៅ ដូចជាព្រះអង្គក្រាលសំណាញ់ ប្រមើលមើលសត្វ លោកដោយពុទ្ធ បំណងថា សត្វណាដែលមានឧបនិស្ស័យ ចូលមកក្នុងសំណាញ់ញាណ ព្រះ-អង្គក៏ទ្រង់ស្តេចទៅសំដែងធម៌ប្រោស ដល់សត្វនោះ ម្យ៉ាងទៀតព្រះ-សម្មាសម្ពុទ្ធ កាលព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់ស្តេចត្រាច់ចរទៅកាន់ ស្រុកតូចធំ និគមរាជធានី សំដែងធម៌ប្រោសសត្វលោក ។

ដោយព្រះមហាករុណាទិគុណ ឥតរើសវណ្ណៈឋានៈ ឥតរើសជាតិ លុះមានកុលបុត្រអ្នកមានសទ្ធា ចេញចាកគេហដ្ឋាន ហើយបួសតាមព្រះ-អង្គបានសំរេចមគ្គដ៏សមគួរហើយ ព្រះអង្គក៏ចាត់ប្រើអោយទៅកាន់ទិសផ្សេងៗ ដើម្បីអោយប្រជានិករ ទទួលស្គាល់សាសនារបស់ព្រះអង្គ ។ ដូច្នេះហៅថា លោកត្ថចរិយា ។

ការប្រព្រឹត្តជាប្រយោជន៍ដល់ញាតិ បានដល់ព្រះហឫទ័យនៃព្រះ-សម្មាសម្ពុទ្ធ ដែលតែងគិតដល់ព្រះញាតិរបស់ព្រះអង្គ ដើម្បីសំដែងធម៌សង្គ្រោះ តាមឋានៈជាព្រះញាតិ ដើម្បីអោយពួកញាតិ មានសទ្ធាជ្រះថ្លាយល់ឃើញធម៌ពិត ដូចជាព្រះអង្គផង ។ ដូច្នេះហៅថា ញាតត្ថចរិយា ។

ការប្រព្រឹត្តបំពេញពុទ្ធកិច្ចរបស់ព្រះអង្គ ដើម្បីជាប្រយោជន៍ដល់វេនេយ្យសត្វតាមឋានៈនៃព្រះអង្គ ជាព្រះពុទ្ធ ដូចទ្រង់បញ្ញត្តិ សិក្ខាបទជាអាទិព្រហ្មចារ្យខ្លះ អភិសមាចារខ្លះ ដើម្បីទូន្មានព្រានប្រដៅពត់តម្រង់និស្ស័យសន្តានរបស់សត្តនិករ អោយមានរបៀបរៀបរយ អោយមានសេចក្ដីអៀនខ្មាស់ ក្នុងការប្រព្រឹត្តអាក្រក់ អោយមានចរិយាល្អ តាមសិក្ខាវិន័យរបស់ព្រះអង្គ អោយសមគួរដល់ឋានៈជាពុទ្ធសាវ័ក ពុទ្ធសាវិកា ការប្រព្រឹត្តអោយជាប្រយោជន៍ដល់ប្រជានិករ តាមបែបយ៉ាងរបស់ព្រះ-អង្គដូច្នោះចាត់ជាពុទ្ធត្ថចរិយា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឃ/សមានត្តតា** ជាអ្នកធ្វើខ្លួនស្មើ មិនប្រកាន់ខ្លួន, បានសេចក្ដីថា អ្នកមិនឆ្មើងកន្ទ្រើង, ឆ្មើងឆ្មៃ ធ្វើឫកក្រអឺតក្រទម ប្រកាន់អស្មិមានះ ប្រមាថមើលងាយអ្នកដទៃ ជាអ្នកប្រព្រឹត្តសមធម៌ ធ្វើខ្លួនស្មើ, មិនរបឹងរឹងរូស រឹងត្អឹង ដោយអាងហេតុទាំង ៣ យ៉ាង :

**១.ជាតិត្ថម្ភៈ** ការប្រកាន់ជាតិសាសន៍

**២.គោត្តត្ថម្ភៈ** ការប្រកាន់ពូជពង្ស

**៣.ធនត្ថម្ភៈ** ការប្រកាន់ទ្រព្យសម្បត្តិ ។

ការមិនប្រកាន់អាងដោយធម៌ ៣ យ៉ាងនេះឈ្មោះថា សមានត្តតា ភាពជាអ្នកធ្វើខ្លួនស្មើ ។

គុណធម៌ ៤ យ៉ាងដូចបានសំដែងមកហើយនោះ គឺតាំងពីទាន បិយវាចា អត្ថចរិយា សមានត្តតា ជាធម៌អាចញ៉ាំងអោយបានសុខចំរើនក្នុងគ្រួសារ នឹងជាគ្រឿងទាក់ទាញចិត្តរបស់អ្នកដទៃអោយរាប់អានខ្លួន ។

ម្យ៉ាងវិញទៀត ត្រកូលដែលមានទ្រព្យសម្បត្តិ ស្ដុកស្ដម្ភហើយតាំងនៅយូរមិនបាន ដោយស្ថានធម៌ ៤ យ៉ាងគឺ :

១-មិនស្វែងរករបស់ដែលបាត់ទៅហើយ

២-មិនជួសជុលរបស់ដែលគ្រាំគ្រា

៣-មិនដឹងប្រមាណក្នុងការចាយទ្រព្យធន

៤-តាំងបុរស ឬស្ត្រីទ្រុស្ដសីលជាមេផ្ទះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកដែលចង់អោយត្រកូលគង់វង់ នៅយឺនយូរ នោះត្រូវលះ ឬ វៀរចាកនូវធម៌បួនយ៉ាង នេះចេញពីខន្ធសន្ដាន អោយជ្រះស្រឡះ ពីសន្ដានចិត្ត, សូមទាញស្មារតីពុទ្ធបរិស័ទទាំងឡាយ ហើយគប្បីរលឹកដល់ពុទ្ធដីកាដែលមានសេចក្ដីប្រែនៃគាថាខាងដើមថា : បុរសតាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬស្ត្រីតាំងបុរសដែលលេងខ្ជះខ្ជាយ ដូចគ្នានោះអោយជាមេផ្ទះ កាលបើដូច្នោះជាហេតុនាំមកនូវសេចក្ដីវិនាស ។

អ្នកដែលមានបំណង និថែរក្សាទ្រព្យសម្បត្តិ អោយស្ថិតស្ថេរបានយឺនយូរ នោះត្រូវចេះវិធីរក្សា ឯវិធីរក្សានោះគឺ ត្រូវចេះស្វែងរករបស់ដែលបាត់បង់ទៅហើយ, ចេះជួសជុលរបស់ដែលចាស់គ្រាំគ្រា, ចេះបរិភោគនូវទ្រព្យធន អោយល្មមប្រមាណ, មិនគប្បីតាំងបុរស ឬស្ត្រីទ្រុស្តសីលអោយជាធំ ឬ ជាមេផ្ទះ ។

ទ្រព្យសម្បត្តិ ទោះជាវិញ្ញាណកទ្រព្យក្តី អវិញ្ញាណកទ្រព្យក្តី ដែលអាចគង់វង់នៅ ឬ ចំរើនឡើងបាន ក៏ដោយសារតែម្ចាស់ទ្រព្យនោះចេះរក្សា ចេះចាយ ចេះប្រើ ។

ឯការរក្សានោះ គប្បីកំណត់ដោយអាការដូច្នេះ គឺ ចេះទុកដាក់ , ចេះថ្នម,ចេះជួសជុល ថែមបំពេញ, ចេះស្ដាយ ចេះធ្វើអោយមានផលតទៅ ។

ត្រង់ពាក្យថា " ចេះទុកដាក់ " គឺចេះរកទីទុកដាក់ដ៏មាំមួន អោយឃ្លាតចាកភ័យផ្សេងៗ មានចោរភ័យជាដើម សូម្បីទុកដាក់ក្នុងផ្ទះសំបែង ក៏ត្រូវប្រយ័ត្នប្រយែងជានិច្ច នឹងទុកដាក់អោយសមគួរ តាមបែបបទរបស់ទ្រព្យ, ទ្រព្យណាដែលគួរដាក់ខាងក្រៅ ក៏ដាក់ខាងក្រៅ ទ្រព្យណាដែលគួរដាក់ខាងក្នុងអោយមានរបៀបរៀបរយ កុំចោលរាត់រាយ ដូចអ្នកខ្លះផ្ទះធំល្អ ទូលាយពេក តែមិនដឹងរបៀបរៀបចំទ្រព្យសម្បត្តិ ក៏ទៅជាចង្អៀតចង្អល់ស្មោកស្មេះ មិនល្អមើល ព្រោះទុកដាក់ផ្តេសផ្តាស់ ។

ត្រង់ពាក្យថា " ចេះថ្នម " គឺពួករបស់ដែលជាគ្រឿងធ្លាក់ដាច់ ឬចាស់គ្រាំគ្រាដូចសំពត់ជាដើម ក៏ចេះថែរក្សាអោយល្អ ពួករបស់ជាលោហធាតុ ដែលជាគ្រឿងធ្លាប់មានស្នឹមស្នារ ច្រេះចាប់ ដូចគ្រឿងដែក ឬស្ពាន់ជាដើម ដែលមិនទាន់ប្រើ ឬ ប្រើរួចហើយក៏ចេះទុកដាក់ បិទបាំងមិនអោយហាលក្តៅ ហាលភ្លៀង ដែលកំពុងប្រើ ក៏ឧស្សាហ៍ដុះខាត់ អោយបានល្អជានិច្ច, ពួករបស់ដែលជាគ្រឿងស្រួយ ដូចពែងប៉ាន់កែវជាដើម វេលានឹងចាប់កាន់ ក៏ចាប់កាន់ដោយថ្នមៗ ប្រយ័ត្នមិនអោយធ្លាក់ភ្លាត់របូត និងជូតសំអាតអោយស្អាតជាដរាប ។ ត្រង់ពាក្យថា " ចេះជួសជុលថែមបំពេញ គឺផ្ទះសំបែង ឬវត្ថុក្នុងផ្ទះ និងក្រៅផ្ទះដែលទ្រុឌទ្រោម ទ្រេតទ្រោត ក៏ជួសជុលទង់ទ្រ ក្រៅផ្ទះដែលល្អដូចប្រក្រតី គ្រឿងចក្រគ្រឿងម៉ាស៊ីន មាននាឡិកាជាដើម ដែលខូចក៏ចេះកែខ្លួនឯង ឬអោយគេកែ

អោយល្អដូចដើម, គ្រឿងឈើមាន តុ ទូ កៅអីជាដើម ដែលនៅថ្មី ក៏ឧស្សាហ៍បោសជូតសំអាតដុសខាត់ អោយល្អស្អាតជាដរាប, ដែលបាក់បែក ឬ ប្រឡាក់ប្រឡូស ក៏ជួសជុលដុសខាត់សំអាត អោយស្អាតល្អ ដូចប្រក្រតី ។

សមដូចព្រះពុទ្ធដីកាត្រាស់សំដែងថា :

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តគឺការរៀនសូត្រ មានការមិនស្វាធ្យាជាមន្ទិល, ផ្ទះមានការមិនជួសជុលជាមន្ទិល, សេចក្តីខ្ជិលជាមន្ទិលដល់ពណ៌សម្បុរ, សេចក្តីប្រហែលធ្វេសជាមន្ទិលដល់ការសិក្សា ។

ត្រង់ពាក្យថា : " ចេះស្តាយ " គឺរបស់ដែលមិនទាន់ខូច មិនគួរបណ្តោយអោយខូច ដែលខូចហើយតែជារបស់គួរប្រើប្រាស់បាន មិនគួរបោះបង់ចោល, តែកុំស្តាយជ្រុលពេក ដែលលាប់បញ្ចូលទៅក្នុងពួកកំណាញ់រហូតដល់មិនហ៊ានបរិភោគ ប្រើប្រាស់ស៊ីចាយនោះឡើយ, គប្បីចាយអោយសមតាមកម្លាំងទ្រព្យដែលរកបានមក ។

និទានដំណាលប្រាប់រឿងអ្នកកំណាញ់ជ្រុល :

មានសេដ្ឋីម្នាក់ ឈ្មោះអបុត្តកសេដ្ឋី ជាសេដ្ឋីឥតកូន មានទ្រព្យច្រើនតែជាមនុស្សកំណាញ់ជ្រុលពេក ស៊ូអត់ស៊ូឃ្លាន មិនហ៊ានចាយទ្រព្យ

សម្បត្តិបរិភោគប្រើប្រាស់ ធ្វើខ្លួនអោយ ថោកទាបដូចអ្នកក្រ, លុះស្លាប់នៅសម្បត្តិនោះធ្លាក់ទៅជាព្រះរាជទ្រព្យទាំងអស់ ។ ព្រះបាទបសេនទិកោសល ទ្រង់ស្តេចទៅគាល់ព្រះបរមសាស្តា ទូលរឿងនោះ, ព្រះអង្គក៏សំដែងពីបុព្វកម្មរបស់សេដ្ឋីនោះថា " ដែលបានជាសេដ្ឋី ព្រោះអំណាចទានដែលប្រើមនុស្សដាក់បាត្រ ព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី ដែលមានសម្បត្តិ ហើយមិនបានប្រយោជន៍ខ្លួន ព្រោះទោសនៃសេចក្តីកំណាញ់អំពីកាលក្រឡេកឃើញចង្ហាន់ដែល ខ្លួនបានអោយគេដាក់បាត្រនោះល្អក៏នឹងស្តាយថា : មិនគួរយកទៅប្រគេនលោកសោះ គួរទុកអោយខ្ញុំកំដរវិញ ល្អជាង " ។ កាលសេដ្ឋីនោះស្លាប់ទៅៗ ឆេះក្នុងមហារោរុវនរកព្រោះទោសសេចក្តីកំណាញ់ និងទោសសំលាប់ម្ចាស់ទ្រព្យយកសម្បត្តិគេ ។

ត្រង់ពាក្យថា " ចេះធ្វើអោយមានផលតទៅ " គឺដូចមានស្រែចំការបានធ្វើខ្លួនឯង ឬ អោយគេធ្វើ, មានប្រាក់កាស បានយកចេញមកចាយ ធ្វើដើមទុន ក្នុងការរកស៊ីទាំងពួង មានជំនួញជាដើម ។

ការចេះរក្សាទ្រព្យ ដូចពោលមកខាងលើនេះ ហៅថាការបរិបូណ៌ដោយការក្សា នេះជាធម៌មានអនុភាពដ៏សំខាន់ ខាងឯធ្វើទ្រព្យ ដែលកើតពីការប្រឹងប្រែងនោះ អោយគង់នៅយឺនយូរ នឹងអោយមានកំរៃចំរើនតទៅ ។

បុរសស្ត្រីក្នុងលោក កាលបើចេះវិធីរក្សា នូវទ្រព្យសម្បត្តិដូចបាន សំដែងមកហើយនោះ រមែងមានសេចក្តីសុខចំរើនកើតប្រយោជន៍ ប្រកបទៅដោយសុភមង្គល វិបុលសុខ មហាប្រសើរ សិរីសួស្តី ជោគជ័យក្នុងឆាកជីវិត ប្រព្រឹត្តទៅបានសមប្រកបរស់នៅបានដោយស្រួល មិនលំបាកវេទនា ព្រោះការខ្វះខាតនូវភោគសម្បត្តិ ។

សំដែងសារជាថ្មីបញ្ជាក់សេចក្តីឡើងវិញ :

មាតាបិតាជាអ្នកមានគុណូបការ តែងមានចិត្តអារម្មណ៍ ច្រើនយ៉ាងណាស់ ក្នុងការរៀបចំអោយកូនមានស្វាមី ភរិយានេះ, ជាពិសេសក្រែងកូនមិនបានសុខសាន្តជាមួយគ្នា ដរាបយាវជីវ៌ ទើបលោកខំរំលឹកទូន្មានអប់រំកូន តាំងពីនៅ លីវអោយរៀនច្បាប់ប្រុស ច្បាប់ស្រី តាមបុរាណនិយម និងច្បាប់សុជីវធម៌តាមគ្រួសារ តាមសម័យនិយមទៀត ។ ឯច្បាប់ទាំងអស់នោះ មានចំណុចសំខាន់តែម្យ៉ាង គឺអប់រំស្វាមីភរិយា អោយមានសេចក្តីសន្តោស ចេះគោរពស្តាប់ អត់ឱនគ្នាទៅវិញទៅមក កុំអោយឈ្លោះទាស់ទែងខ្វែងយោបល់គ្នា ។

មូលហេតុដែលនាំអោយឈ្លោះគ្នា រវាងស្វាមីភរិយា បើតាមការពិសោធន៍តាំងពីប្រេងនាយ ច្រើនបណ្តោកើតមកអំពីភរិយា ខ្វះលក្ខណៈជាស្រីមេផ្ទះ ។ ឯលក្ខណៈធំបំផុតរបស់ស្ត្រីមេផ្ទះ គឺសេចក្តីអត់ធន់ ។ ព្រោះធម្មជាតិបានបង្កើត ស្រីភេទមក ប្រកបដោយភាពទន់ខ្សោយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយសុភាពរាបសា មានរូបរាង អវយវៈទន់ភ្លន់ ស្លូតបូត សមរម្យ ជាជំរកដ៏ត្រជាក់ត្រជុំរបស់ជនក្នុងគ្រួសារ នឹងជាឱសថា ឬជាសាស្ត្រាចារ្យ ប្រចាំគ្រួសារ សំរាប់អប់រំ បន្ទោរបង់នូវកំហុស និងសេចក្តីក្តៅក្រហាយទុក្ខ ព្រួយរបស់ស្វាមី និងបុត្រធីតា ទើបមាននាមដ៏ឧត្តមជា " មេផ្ទះ " គឺជាមេ ជម្រកសំរាប់ស្វាមី បុត្រធីតា ជ្រកនៅបានសុខសាន្ត ។ ហេតុនេះស្ត្រីមេផ្ទះ ទាំងឡាយ ! ត្រូវមានសេចក្តីអត់ធន់ជាចាំបាច់ ដើម្បីរក្សាភាពធម្មជាតិ របស់ខ្លួន អោយមានប្រក្រតីរាបសា រីករាយ ល្អជានិច្ច លះបង់នូវសេចក្តី ក្រេវក្រោធ ប្រច័ណ្ឌប្រមាថមើលងាយ យកឈ្នះពីស្វាមីរបស់ខ្លួន ដែល ជាឧបស័គ្គចំពោះធម្មជាតិខ្លួននោះចេញ ។

ភាពល្អរីករាយដែលប្រកប ដោយសេចក្តីអត់ធន់នេះហើយ ជាអា- វុធរបស់ភរិយា គឺជាព្រនង់ទិព្វ យ៉ាងធំសំរាប់សំពង កំទេចចោលនូវអំពើ អាក្រក់របស់ស្វាមីអោយអន្តរធានបាត់បង់ទៅដោយស្វ័យប្រវត្តិ ។ ទោះ បីស្វាមីជាមនុស្សពាល ។

មាតាបិតា បាចារ្យប្រដៅមិនបានតាំងពីកំណើតមក ក៏ត្រូវតែបាក់ បបខ្លួបខ្លាច លះបង់អំពើអាក្រក់ ចោលខានមិនបាន, បើជាអ្នកខិលខូចខ្លាំង ដល់ប្រែចិត្តគំនិតល្អវិញ ច្រើនតែបន្ទោរបន្ទាបបន្ទន់ខ្លួនម្រក់ទឹកភ្នែក ថ្លៃកំហុសខ្លួនចំពោះភរិយា ទៀតដោយឥទ្ធិពល ព្រនង់ទិព្វនេះឯង ។ ប៉ុន្តែមានបុរសអស់សាច់ យ៉ាងគំរត់ខ្លះ ដែលព្រនង់ទិព្វនេះកែមិនឡើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាល់តែសោះ គឺមនុស្សខូចអាវ៉ាសែ មិនចិញ្ចឹមប្រពន្ធកូន ប្រព្រឹត្តអបាយ មុខ ឆបោកលួចទ្រព្យសម្បត្តិប្រពន្ធកូនទៅផ្លាញ់ ក្បត់គ្រួសារឯងនោះ ស្ត្រីជាភរិយាគប្បីលែងចោលអោយស្រឡះពីខ្លួន, ព្រោះការលះលែងបុរស ធុននេះ ដូចជាបន្ទោរបង់លាមកចោលក្នុងបង្គន់ដូច្នោះដែរ ។

ស្ត្រីមេផ្ទះដែលចេះអត់ធន់ មានសេចក្តីសន្តោស មិនចង់បានឈ្នះ ពីស្វាមី មានចរិយាល្អសមរម្យ សមហេតុផលនេះ ហើយហៅថា ស្ត្រីមាន លក្ខណ៍គឺជាស្ត្រីល្អ ។ សមនឹងបុរាណថា " ស្ត្រីល្អច្រើនចាញ់ប្តី ពាក្យអប្រិយ ចាញ់អាត្មា " ។ ស្ត្រីក្នុងទីនេះ មិនមែនល្អរូបទេ គឺល្អចរិយាមាយាទឆ្លាត វៃ ចេះអត់ធន់ មិនដែលយកឈ្នះប្តីដោយកំលាំងបាយ ព្រមចាញ់ដោយ ទឹកចិត្តដ៏រីករាយជានិច្ច ហើយអាចយកជ័យជំនះពីប្តី បានដោយសន្តិភាព ។ ត្រូវនឹងក្បួនឈ្នះ ដែលមានមកក្នុងលោកនីតិថា :

ឈ្នះអ្នកខ្ពង់ដោយត្រុនបន្ទន់ប្រាណ
ឈ្នះអ្នកក្លាហានដោយទំលាយ
ឈ្នះអ្នកខ្សោយដោយសម្លបាយ
ឈ្នះអ្នកស្មើកាយដោយព្យាយាម ។

ឯបុរសមានភេទខ្ពស់ នឹងកម្លាំងកាយខ្លាំងជាង ភេទស្រី ដូច្នេះស្ត្រី ជាភរិយាមិនអាចតតាំង យកជ័យជំនះពីស្វាមីខ្លួនដោយកម្លាំងកាយ មានការជេរប្រទេចផ្តាសា ខ្វារខ្វាំ ខាំក្តិច ប្រច័ណ្ឌ ឡូឡា ឡូងឡាង យំស្រែក នោះឡើយ ។

ឯការឃោរឃៅ កាចសាហាវជាដើមនោះ ជាលក្ខណៈរបស់ស្ត្រីខាតលក្ខណ៍ទេតើ ។

## " លក្ខណៈស្ត្រីខាតលក្ខណ៍ "

ធម្មតា ស្ត្រីខាតលក្ខណ៍ មានតែការឃោរឃៅ កាចសាហាវម្លេះឆ្នះ ប្រច័ណ្ឌប្តីជាចាំបាច់ មិនសូវគិតគូរពីទ្រព្យសម្បត្តិ មានការខ្ជះខ្ជាយចាយវាយឥតសណ្តាប់ធ្នាប់ ឬ គិតពីមានក្រ ល្អអាក្រក់ នឹងម្ហូបចំណីទេ, មានចិត្តនោះឯង ជោគជំជោរអៀចទៅដោយ កាមរាគមួយៗ រកតែរឿងប្រច័ណ្ឌប្តី បើប្តីទៅណាដល់ពេលត្រឡប់មកវិញ ក្នុងចិត្តពោរពុះកញ្ជ្រោលក្រឡេកចុងភ្នែក ដើមភ្នែក មើលសង្កេតរូបកាយ សំលៀកបំពាក់ប្តី ដើម្បីរកលេសចាប់ពិរុទ្ធ ចោទប្រកាន់ប្រច័ណ្ឌ បៀតបៀន នាំអោយមានរឿងហេតុក្តៅឆេះក្នុងគ្រួសារ ។

បើនរណា មានទាក់ទង និងប្តីខ្លួន លើប្តីប្រច័ណ្ឌ នឹងគេភ្លាមហើយដើរនិយាយហែកកេរ្តិ៍ប្តី សំអុយឈ្មោះប្តីប្រាប់គេឯង រហូតដល់អ្នកដែលជាខ្ញុំកញ្ជះ ក៏គេនិយាយប្រាប់ដែរ អោយធ្លាប់ស្គាល់មុខ ហ៊ាននិយាយមើលងាយប្តីពេញទីថា ៖ អាក្បាលខូច អាឆ្កែ អាក្បាលកញ្ចាស់ គំនិតដូចកូនក្មេង អារន្ទះបាញ់ប៉ុណ្ណោះជាដើម គឺថាជក់មាត់ល្អណាស់ គ្មានញញើតទេ និយាយមិនចង់ឈប់ភ្លេចពេលបាយទឹកអស់ ។

មានខ្លះទៀត និយាយផង យំផងថ្លែងអាការយ៉ាងថោកទាបប្រាប់គេឯងអោយជួយឈឺឆ្អាលខ្លួន ។ បើនិយាយទៅចំស្ត្រីខាងលក្ខណ៍ដូចគ្នានោះត្រូវដើងគ្នាមាំងតែម្តង តាំងបើឆាកបង្ខូចហែកកេរ្តិ៍ប្តីគេរៀង១ខ្លួនមួយឈុតទៅមួយឈុតមក ចេះតែជក់មាត់ទៅ១ កូនយំនៅចំពោះមុខក៏មិនព្រួយដែរ ។

ប៉ុន្តែបើនិយាយទៅចំស្ត្រីមានលក្ខណ៍ ដូចជាគេអាក្រាតកាយនៅខ្លួនទទេ អោយគេស្គាល់ច្បាស់ថា ជាស្រីល្មោភមេថុន ពោរពេញទៅដោយសេចក្តីស្រេកឃ្លានអន្ទះសា ខ្វាករទើបចេះតែខំប្រថែប្រច័ណ្ឌ ការពារទុកក្រែងមិនបានឆ្អែតស្កប់ស្កល់ ។ ព្រោះការប្រច័ណ្ឌនេះ ជានិមិត្តរូប ឬជាយីហោ នៃមហាកាមរាគ មានគោលបំណងបាញ់ឆ្ពោះទៅរកមេថុនផ្ទាល់ខ្លួនតែម្នាក់ឯង ។ គួរអោយអាម៉ាស់មុខណាស់ មិនគួរស្រីខាតលក្ខណ៍លាក់មុខ ប្រច័ណ្ឌ អោយគេស្គាល់យីហោអាសគ្រាម អាស្រូវបារាយនេះសោះ ជាពិសេសគួរខ្មាស់ចំពោះស្វាមីខ្លួន ឬកូនខ្លួនដែលដឹងក្តីហើយ ។

ហេតុដូច្នេះគួរស្រីមេផ្ទះ និងនារីជាអនាគតមេផ្ទះទាំងឡាយចៀសវាងនូវ តម្រាអាក្រក់នេះ អាចរុញច្រានស្វាមីអោយរឹតតែធ្លាក់ចុះទៅក្នុងអំពើមិនគាប់ចិត្តរបស់ខ្លួនថែមទៀត នាំអោយវិនាសអន្តរាយកេរ្តិ៍ក្រហាយវេទនា តែខ្លួនឯងទេ, ដូចគេបំពង់ផ្សែងដេញឃ្មុំ អោយហើរចោលសម្បុកដូច្នោះដែរ ។

# "លក្ខណៈបុរសខាតលក្ខណ៍"

ឯបុរសខាតលក្ខណ៏ ក៏មានអត្ថន័យដូចគ្នា នឹងស្រីខាតលក្ខណ៏ដែរ ព្រោះមានប្រុសខ្លះប្រច័ណ្ឌប្រពន្ធដូច្នោះដែរ ។ អាស្រ័យហេតុនេះគួរបុរសជាស្វាមី និងអ្នកកម្លោះជាអនាគតស្វាមី កុំត្រាប់តាមបុរសនេះឡើយ ។ ម្យ៉ាងទៀត បុរសជាស្វាមី ដែលមានភេទ និងកម្លាំងកាយខ្ពង់ខ្ពស់ ខ្លាំងពូកែ ពីធម្មតាជាតិមកនោះ ត្រូវកាន់ចរិយាមាយាទ អោយសមតាមឋានៈខ្លួនជាស្វាមីរបស់គេ កុំអាងកម្លាំងកាយវាយឬកខ្ពស់ ទល់មេឃ នឹងកុំអោយទាបពេកស្មើនឹងដីដរាបដល់ភរិយា គោរពប្រតិបត្តិបំពេញឋានៈជាស្ត្រីល្អផងពុំកើត ។

បុរសខ្លះ បន្ទាបខ្លួនអោយទាបថោកហួស ដល់ទៅធ្វើខ្ញុំកញ្ជះបាទជើងភរិយារបស់ខ្លួន បណ្តោយអោយភរិយាឡើងមានៈ មើលងាយដូចសត្វតិរច្ឆាន, ឯចំណុចសំខាន់របស់ស្វាមី ដែលត្រូវប្រព្រឹត្តកាន់អោយបានជានិច្ចនោះ គឺសេចក្តីសន្តោសចំពោះភរិយា, ត្រូវប្រៀបធៀបខ្លួនឯង លៃអោយមានតុល្យភាពជានិច្ច កុំអាងតែខ្លួនប្រុស ចេះតែប្រព្រឹត្តរមាំងរមៅកខ្មោកខ្មាកតាមអំពើចិត្ត រំលោភចំពោះភរិយានោះឡើយ ។

បើភរិយាជាស្ត្រីខាតលក្ខណ៏ ពាណកាចសាហាវ មាតាបិតាប្រដៅមិនបានហាមប្រាមននិឈ្នះ យើងត្រូវអប់រំដោយបទទី ៣ ក្នុងក្បួនដែលថា "ឈ្នះអ្នកខ្សោយ ដោយអោយសម្លបាយ " ។ ពាក្យថាអោយសម្លបាយនេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

គឺអោយទូទៅគ្រប់យ៉ាង តាំងពីអោយសម្លបាយ សំលៀកបំពាក់ មាសប្រាក់ រហូតដល់កិត្តិយស និងសេចក្ដីសរសើរជាដើម លៃសម្រួលតាមចរិតមនុស្ស ។ ធម្មតាអ្នកទន់ខ្សោយ ដូចជាស្ត្រី ដែលខ្សោយភេទជាដើម តែងចាលចាញ់នូវអំណាចគឺការអោយនេះឯង ។

ប៉ុន្តែមានភរិយាខ្លះ ដែលអាក្រក់ហួសហេតុ ដរាបដល់ផិតក្បត់ជាដើមនោះ សូម្បីអោយនគរសោយរាជ្យ ក៏មិនស្កប់ស្កល់ដែរ ។

ដូចសុភាសិតក្នុងលោកនីតិបង្គាប់ថា :

ស្រីណាមានប្រក្រតីពោលវិវាទ មានប្រមាថពោលនាំពាក្យឫស្យា ត្រេកបំណងអោយប្រុសគុណអាត្មា កិរិយាស្លូដាំប្រចាំប្ដី ។

ស៊ីបាយមុនប្ដីនៃអាត្មា ត្រេកយាត្រាផ្ទះគេពុំជួក្ដី ស្រីយ៉ាងនេះ បុរសក្នុងលោកិយ ទោះមានកូនមួយរយក្ដី គប្បីលែង ។

**បុច្ឆា** សួរថា បុរសស្ត្រីខាតលក្ខណ៍ និងពាក្យថា បុរសស្រីទ្រុស្តសីល តើមានសេចក្ដីផ្សេងគ្នា ឬដូចគ្នា ? ចូរអធិប្បាយ

**វិសជ្ជនា** ឆ្លើយថា : ផ្សេងគ្នា ដោយព្យញ្ជនៈ ឬដោយរូបស័ព្ទ ដូចគ្នាដោយសេចក្ដីអធិប្បាយថា បុរសស្ត្រីដែលលេងខ្វះខ្វាយ គឺបុរសស្ត្រីដែលខាតលក្ខណ៍ គឺបុរសស្ត្រីដែលទ្រុស្តសីលនោះឯង ។

**បុច្ឆា** សួរថា បុរសស្ត្រីខាតលក្ខណ៍ ឬ ទ្រុស្តសីល តើចាត់តាំងអោយធ្វើជាមេផ្ទះ មេគ្រួសារបាន ឬមិនបាន? ព្រោះហេតុអ្វី ? ចូរអធិប្បាយ

**វិសជ្ជនា** ឆ្លើយថា បុរសស្ត្រីខាតលក្ខណ៍ ឬទ្រុស្តសីល ព្រះសម្ពុទបរមគ្រូនៃយើង ព្រះអង្គមានញាណញ្ញេយ្យធមិដ៏ប្រពៃ ពិចារណាឃើញដោយប្រត្យក្សថា បុរសស្ត្រីរបៀបនេះ មិនអាចចាត់តាំងអោយធ្វេជាមេផ្ទះ បានឡើយ, ពីព្រោះបុរសស្ត្រីនេះ ជាអ្នកលេងខ្ជះខ្ជាយ ប្រព្រឹត្តអបាយមុខ គឺស្រី ស្រា ល្បែងភ្នាល់ល្បែងស៊ីសង សេពគប់មនុស្សអាក្រក់ យកធ្វើជាមិត្ត មិនមានវិន័យ មិនមានសីលធមិ សុជីវធមិ ធ្វើអោយខូចទំនៀមទំលាប់នៃមនុស្សជាតិ ខូចប្រពៃណីជាតិ រហូតដល់ខូចខាតទ្រព្យសម្បត្តិស្ថិតនៅក្នុងសេចក្តីអន្តរាយ ហាយនភាពទាបថោក ជាទីបំផុត, អាស្រ័យហេតុនេះហើយ ទើបព្រះសាស្តាទ្រង់សំដែងថា បើចាត់តាំងអោយធ្វើជាមេផ្ទះ មេគ្រួសារមិនបាន ដូចបានអធិប្បាយមកខាងលើនេះ ។

ការសំដែងមកក្នុងគាថាទី១១ នៃបរាភវសូត្រដែលមានសេចក្តីថា

បុរសតាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬស្ត្រីទាំងឡាយតាំងបុរសនោះ ដែលជាអ្នកលេងខ្ជះខ្ជាតដូច្នោះ អំពើទាំងនោះនាំអោយវិនាស ។

ការសំដែងមកនេះក៏សន្មត់ថា

ចប់តែប៉ុណ្ណេះឯង ឯវិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសុត្ត

## នមោ តស្ស

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## នមេ ពុទ្ធំ តិលោគ្គំ ញេយ្យ សាគរំ បារគុំ

## ភវាភវករំ ធម្មំ គណញ្ច គុណ សាគរំ ។

ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះពុទ្ធជាម្ចាស់ ព្រះអង្គជាបុគ្គលប្រសើរលើសសត្វក្នុងត្រៃលោក ព្រះអង្គមានញាណគឺ គុណសំរាប់ដឹងនូវញេយ្យធម៌ទាំងពួង ដ៏ជ្រាលជ្រៅ បីដូចសាគរធំ ព្រះអង្គមានដំណើរទៅដល់ហើយនៅត្រើយសាគរ គឺញាណនៃព្រះអង្គផង ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺគុណសំរាប់ទ្រង់នូវសត្វទាំងឡាយ ដែលជាអ្នកប្រតិបត្តិដ៏សមគួរ តាមពាក្យព្រានប្រដៅរបស់ព្រះសាស្តាជាម្ចាស់ មិនអោយធ្លាក់ចុះទៅក្នុងអបាយភូមិទាំងឡាយផង ។

**ភវាភវករំ** ជាគុណតែងធ្វើនៅកម្មភព គឺកុសលា កុសលចេតនា ២៩ មានកុសល ចេតនាជាដើម និងឧបបត្តិភាព គឺភពទាំង ២៩ មានកាមភពជាដើម ដែលកើតអំពីបច្ច័យគឺកម្មភព អោយវិនាសសាបសូន្យទៅផង, ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះអរិយសង្ឃ លោកមានគុណដ៏ជ្រាលជ្រៅបីដូជាសាគរផង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បន្ទាប់អំពីបទ នមស្សការនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមដកស្រង់លើកយកគាថាទី ១២ នៃបរាភវសូត្រមកអធិប្បាយបរិយាយរំគាយសេចក្តីពន្យល់ន័យ លាភត្រដាងចង្អុលបង្ហាញ រំលែកចែកជូនដល់អស់លោកជាពុទ្ធបរិស័ទទាំងឡាយ ដែលបានលះគេហដ្ឋាន ហើយសព្ទូរចូលមកសន្និបាត ជួបជុំប្រមូលផ្តុំកុះករ មីដេរដាសក្នុងទីនេះ ដោយបសាទសទ្ធាជ្រះថ្លា ក្នុងវរពុទ្ធសាសនាប្រាថ្នាបុណ្យកុសល ជាផលឧបនិស្ស័យ វាសនានាអនាគតកាលទៅឯមុខនោះ ខ្ញុំព្រះករុណា អាត្មាភាព និងបានចាត់ចែងសំដែងដូចតទៅនេះ ៖

ទេវតាទូលសួរតទៅទៀតថា ៖

**ឥតិហេតំ វិជានាម ឯកាទសមោ សោ បរាភវោ ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុ ដូច្នោះក្តីវិនាសនោះបើរាប់សង្គ្រោះវិនាសនោះឈ្មោះទី១១ ទាន់ហាន់បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបចំពោះទេវតាថា ៖

**អប្បំ ភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ, សោ ច រជ្ជំ បត្ថយតិ យំ បរាភវតោ មុខំ ។**

ជនណាកើតក្នុងត្រកូលក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំអោយដល់វិនាស ។

## អធិប្បាយ

## គាថាទី១២

ជាបឋមសូមសំដែងអំពីជម្ពូទ្វីប និងប្រជាជន

កាលពីក្នុងសម័យបុរាណ ជម្ពូទ្វីប លោកសំដែងចំពោះមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌា ក្នុងបច្ចុប្បន្ននេះទាំងមូល ដែលតាំងនៅទិសពាយ័ព្យ នៃប្រទេសកម្ពុជាយើង ហៅថាជម្ពូទ្វីប នោះលោកបែងចែកជា ២ ជាតិ គឺ :

**១.មិលក្ខជាតិ**

**២.អរិយជាតិ ។**

ពួកមិលក្ខជាតិនោះ មានសេចក្តីចេះដឹងតិចតួចស្តួចស្តើង ក្នុងច្បាប់រដ្ឋប្បវេណី និងក្នុងការគ្រប់គ្រងប្រទេសជាតិ មាតុភូមិ ។ ឯពួកអរិយជាតិ ជាអ្នកមានសេចក្តីចេះដឹងសិលសាស្ត្រ វិទ្យាការ នឹងមានឫទ្ធិអំណាចច្រើនជាងពួកមលិក្ខ ព្រោះហេតុដូច្នោះ ពួកអរិយកជាតិទើបនាំគ្នាលើកចុះមកអំពីផែនដីខាងជើងឆ្លងភ្នំហិមាល័យ មកលុកលុយ រុករានដេញពួកមិលក្ខ ដែលជាម្ចាស់ជម្ពូទ្វីបពីមុនមកអោយថយចុះ មកទិញខាងត្បូងបន្តិចម្តងៗ ហើយពួកអរិយកជាតិនោះ តាំងនៅភូមិលំនៅៗរៀងដរាបមក ។

# ជម្ពូទ្វីបបែកជាពីរអាណាខេត្តគឺ :

១-ខាងក្នុងហៅថា មជ្ឈិមជនបទ ឬមជ្ឈិមទេស ឬមធ្យមប្រទេស ប្រែថាប្រទេសកណ្តាល ។

២-ខាងក្រៅហៅថា បច្ចន្តជនបទ ឬ បច្ចន្តប្រទេស ប្រែថាប្រទេសចុងដែលឬស្រុកក្រៅ ។

មូលហេតុដែលចាត់ចែងជាពីរភាគនោះ ព្រោះពួកអរិយក ជាអ្នកចាត់ចែង គឺហៅកន្លែងដែលខ្លួននៅជា "មធ្យមប្រទេស " ហៅថាកន្លែងដែលពួកមិលក្ខទៅតាំងនៅថ្មីនោះថា បច្ចន្តជនបទ ។ អាណាខេត្តដែលបែងចែកដូច្នេះ ព្រោះមានការប្រែប្រួលផ្លាស់ប្តូរ តាមយុគសម័យ ដែលអ្នកគ្រប់គ្រងផ្សាយអំណាចច្រើន ឬតិចក្នុងមួយគ្រា ៗ ។

អាណាខេត្តនៃជម្ពូទ្វីប ក្នុងគ្រាពុទ្ធកាលប្រាកដតាមបាលីធម្មក្ខន្ធកក្នុងមហាវគ្គនៃព្រះវិន័យ ដូច្នេះគឺ :

**ក**/ទិសបូព៌ា ខាងក្នុងចាប់អំពីស្ទឹងមហាសាលនគរចូលមក ។

**ខ**/ទិសអគ្នេយ៍ ខាងក្នុងចាប់ទអំពីស្ទឹងសល្លវតីចូលមក ។

**គ**/ទិសទក្សិណ ខងក្នុងចាប់អំពីសេតកណ្ណិគមចូលមក ។

**ឃ**/ទិសឧត្តរ ខាងក្នុងចាប់ពីភ្នំ ឧសីរទ្ធជៈចូលមក ។

ក្រៅពីខេត្ត ដែលពោលខាងលើនេះ បច្ចន្តជនបទទាំងអស់ ។ មជ្ឈិមជនបទនោះ ជាទីនិយមរាប់អានមនុស្សក្នុងយុគនោះ ។ ព្រោះជាទី

តាំងនៃនគរធំៗ និងជាទីសម្បូរដោយអ្នកប្រាជ្ញរាជបណ្ឌិត និងលទ្ធិសាសនាផ្សេងៗ ។

ក្នុងបាលីឧបោសថសូត្រតិកនិបាតអង្គុត្តរនិកាយ បែងជម្ពូទ្វីបជាមហាជនមាន ១៦ គឺ :

**អង្គៈ មគធៈ កាសី កោសល វជ្ជី មល្ល អរិយ វង្ស កុរុ បញ្ចាល មច្ឆៈ សុរសេន អស្សកៈ អវន្តី គន្ធារៈ កម្ពោជ ។**

មានសំដែងក្នុងព្រះសូត្រដទៃ មិនត្រូវនឹងឈ្មោះខាងលើ ៥ ជនបទទៀតគឺ **សក្កៈ កោលិយ ភគ្គៈ វិទេហ អង្គុត្តរាម** រួមជា ២១ រាជាខ្លះ អធិបតីខ្លះ និងមានអំណាចសិទ្ធិដាច់ខាត តែមានឯងខ្លះដោយសាមគ្គីធម៌ខ្លះ ប្រហែលនឹងមហាជនរដ្ឋ ឬសាធារណរដ្ឋ (រេពុយព្លិច) ក្នុងបច្ចុប្បន្ននេះខ្លះ ។

ប្រជាជនក្នុងជម្ពូទ្វីបបែងជា ៤ ពួក ហៅថាវណ្ណៈ ៤ គឺ

**១-ក្សត្រិយ** មានមុខងារខាងផ្លូវគ្រប់គ្រងប្រទេស ត្រូវសិក្សាវិជ្ជាខាងយុទ្ធវិធី ។

**២-ព្រាហ្មណ៍** មានមុខងារខាងបង្ហាត់ បង្រៀនព្រមទាំងធ្វើវិធីផ្សេងៗត្រូវសិក្សាខាងផ្លូវសាសនា និងវិជ្ជាផ្សេងៗ

**៣-វេស្ស** មានមុខងារខាងធ្វើស្រែចំការ និងការលក់ដូរ ត្រូវសិក្សាវិជ្ជាខាងសិល្បកម្ម កសិកម្ម និងពាណិជ្ជកម្ម ។

**៤-សុទ្ទៈ** មានទាទីខាងផ្លូវស៊ីឈ្នួល ជួលព័ទ្ធធ្វើការអោយគេ ត្រូវសិក្សាវិជ្ជាក្នុងការងារ ដែលស៊ីឈ្នួល ដែលធ្វើដោយកំលាំងកាយ ។ វណ្ណៈទាំងអស់គឺទាំង ៤ពួកនេះ មានស័ក្តិខ្ពស់ទាបជាងគ្នា ជាលំដាប់មក, តែរវាងក្សត្រិយ៍ និងព្រាហ្មណ៍ ប្រកាន់ថាខ្លួនជាមនុស្សជាន់ខ្ពស់បំផុតដូចគ្នា រង្កៀសវណ្ណៈ ដទៃមិនរួមរស់នឹងវណ្ណដទៃ ក្សត្រក្តី, ព្រាហ្មណ៍ក្តី លើកតំកើងរាប់អានតែពួកខ្លួនប៉ុណ្ណោះពួកដទៃ ទោះបីជាក្សត្រតែគោត្រផ្សេងគ្នាក៏រង្កៀសដែរ, មនុស្សផ្សេងវណ្ណៈដូចព្រាហ្មណ៍ទៅរួមរស់នឹងសុទ្ទៈ ជាស្វាមីភរិយា កើតបុត្រមក បុត្រនោះគេហៅថា ជាមនុស្សចណ្ឌាលជាមនុស្សថោកទាប មិនមាននរណារាប់អានគប់រកឡើយ ។

ការសិក្សារបស់វណ្ណៈទាំង ៤ រមែងប្រព្រឹត្តទៅតាមនាទី របស់វណ្ណៈដូចពោលមកហើយ ។ ក្នុងយុគនោះ មនុស្សចូលចិត្តសិក្សាធម្មសាស្ត្រជាងវិជ្ជាដទៃៗ ជាម្ចាស់ទិដ្ឋិមានយោបល់ឃើញផ្សេងគ្នា រួមអោយខ្លីមកនៅត្រឹមតែ ២ ពួកគឺ :

ពួកទី១ : ប្រកាន់ថា ស្លាប់ហើយត្រូវតែកើតទៀត ជនជំពូកនេះចែកចេញជា ២ ទៀតគឺ :

ក/ធ្លាប់កើតជាយ៉ាងណា ស្លាប់ហើយ ក៏កើតយ៉ាងនោះដដែល ។

ខ/ស្លាប់ហើយត្រូវកើតទៀតជាធម្មតា តែមិនដឹងថា ទៅកើតជាអ្វីពិតប្រាកដ ។

ជំពូកទី ២ : យល់ឃើញថា សត្វស្លាប់ហើយ ក៏សូន្យសោះអស់កើតឡើង ជនជំពូកនេះក៏ចែកចេញជាពីរដែរ គឺ :

ក/យល់ឃើញថាសូន្យទាំងអស់

ខ/យល់ឃើញថាសូន្យខ្លះ មិនសូន្យខ្លះ ។

ជនទាំង ២ ពួកនេះ ដូចបានពោលមកហើយ នូវប្រារព្ធសុខទុក្ខផ្សេងគ្នាទៀត គឺ :

១/សុខទុក្ខ មិនមានហេតុ សត្វនិងបានសុខ ឬបានទុក្ខក៏បានឯង ៗ ។

២/សុខទុក្ខ មានហេតុសត្វបានសុខបានទុក្ខ ក៏ព្រោះមានហេតុណាមួយបណ្ដាលឡើង ។

ជនពីរពួកនេះនៅយល់ឃើញប្លែកគ្នា ជាពួកទៀតគឺ :

ក/យល់ឃើញថា សុខទុក្ខ កើតឡើងព្រោះហេតុខាងក្នុងគឺកម្ម ។

ខ/យល់ឃើញថា សុខទុក្ខកើតឡើងព្រោះហេតុខាងក្រៅ មានទេវតាជាអ្នកបណ្ដាល កាលជនទាំងឡាយ មានយោបល់យល់ឃើញផ្សេងៗគ្នាដូច្នោះ ទើបប្រព្រឹត្តតាមសេចក្ដីយល់ឃើញរបស់ខ្លួនៗ ដែលចែកចេញជា ៩ ពួកគឺ :

**ក**/ពួកដែលប្រកាន់ថា ស្លាប់ហើយកើតឡើងទៀត យល់ឃើញថាប្រព្រឹត្តយ៉ាងណា ការបានទៅកើតក្នុងឋានសួគ៌ ក៏ប្រព្រឹត្តយ៉ាងនោះ ។

ខ/ពួកដែលប្រកាន់ថាស្លាប់ ហើយសូន្យ ក៏ប្រព្រឹត្តយកតែរូបខ្លួនក្នុងបច្ចុប្បន្នតែប៉ុណ្ណោះ ។

គ/ពួកដែលប្រកាន់ថាសុខទុក្ខកើតព្រោះហេតុតែកម្ម ក៏វៀរចាកកម្មដែលអាក្រក់ធ្វើកម្មដែលជាកម្មល្អ តាមសេចក្ដីចូលចិត្តរបស់ខ្លួន ។

ឃ/ពួកដែលប្រកាន់ថា សុខទុក្ខកើតឡើង ព្រោះហេតុខាងក្រៅ ដូចទេវតា អ្នកតាព្រហ្ម យមយក្ស អារក្ស ខ្មោច បណ្ដាលឡើងជាដើម ក៏ប្រកបហេតុនោះៗ មានបួងសួង បន់ស្រន់ សែនព្រេន អោយវត្ថុស័ក្តិសិទ្ធិទាំងនោះ អោយជួយខ្លួនជាដើម ។

ការដែលមនុស្សមានសេចក្ដីយល់ឃើញ ផ្សេងគ្នាដូច្នេះ ក៏ព្រោះមានគណាចារ្យ ប្រដៅលិទ្ធសាសនាផ្សេងៗគ្នា ។

ម្យ៉ាងទៀត អ្នកដែលជាគណាចារ្យ ក្នុងយុគនោះបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ ស្មើនឹងស្ដេចផែនដី ឬជាងស្ដេចផែនដីទៀតផង ។

មនុស្សក្នុងវណ្ណៈទាំង ៤ បានកាន់តាមលទ្ធិព្រាហ្មណ៍ ដែលប្រដៅមនុស្សអោយប្រព្រឹត្តតាម គម្ពីរត្រៃវេទ ឬវេទាង្គ ប្រដៅថា លោកធាតុមានទេពតាសាង និងមានទេវតាចាំលោក ធាតុនោះៗ ដូច ដី ទឹក ភ្លើង ខ្យល់ សុទ្ធតែ មានទេព្តា ជាម្ចាស់ផ្សេងគ្នា ។

ព្រោះហេតុដូច្នោះ នរណាប្រាថ្នាយ៉ាងណា ត្រូវបួងសួងបន់ស្រន់ធ្វើពលីការដល់ទេវតាជាអ្នកប្រសិទ្ធិអោយ ។ វិធីប្រតិបត្តិដើម្បីសុវត្ថិមង្គល

ដែលទេវតាជាអ្នកប្រសិទ្ធិអោយនោះ មានដើមថា ដុតភ្លើងហើយ បួងសួងបន់ស្រន់ ឬប្រព្រឹត្តតបគឺ ឆ្អើរកិលេស ដោយការទូន្មានកាយ ដូចឈររនិងដើរជាវត្ត និងអង្គុយមិនដេក បរិភោគតែផ្លែឈើ មិនបរិភោគបាយជាដើម ។ គេប្រកាន់ថា បើអស់ជីវិត ព្រោះប្រព្រឹត្តតបៈនោះហើយ ទេវតាឃើញសេចក្តីព្យាយាមក៏នឹង ប្រសិទ្ធិពរអោយតាមប្រាថ្នា ។ ព្រះបរមសាស្តាមហាបុរសយើង ទ្រង់ឧប្បត្តិឡើងក្នុងពួកអរិយដែលនៅក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ដែលសក្កៈ ខត្តិយត្រកូល សាក្យជាតិ គោតមគោត្រជាព្រះរាជឱរសរបស់ព្រះបាទសិរីសុទ្ធោទនៈ នឹងនាងសិរីមហាមាយាកាលមុន ពុទ្ធសករាជ ៨០ ឆ្នាំ ។

## សេចក្តីនៃគាថា ខាងដើមថា :

នរណាដែលកើតក្នុងត្រកូលក្សត្រ តែជាអ្នកក្សត់ទ្រព្យសម្បត្តិគ្មានធនធាន មានចិត្តប្រាថ្នាចង់បានជាធំ គឺចង់សោយរាជ្យ ជាស្តេចគ្រប់គ្រងផែនដី ត្រួតត្រាត្រាលើប្រជានុរាស្ត្រ នោះជាប្រធាននៃសេចក្តីវិនាសដោយពិត ។ ពីព្រោះការសោយរាជ្យជាស្តេច ត្រូវប្រកបទៅដោយភោគសម្បត្តិ ស្តុកស្តម្ភ ហើយត្រូវប្រកបដោយគុណធម៌ ១០ ប្រការទៀតដែលយើងធ្លាប់ចេះមក ហើយហៅថា ទសពិតរាជធម៌ ធម៌របស់ស្តេច ១០ ប្រការ ។

## ទសពិធរាជធម៌ ១០ យ៉ាងគឺ :

**១-ទាន** ទ្រង់អោយទាន

**២-សីល** ទ្រង់រក្សាសីល

**៣-បរិច្ចាគ** ទ្រង់ចំណាយព្រះរាជទ្រព្យ

**៤-អាជ្ជវៈ** ទ្រង់មានអធ្យាស្រ័យទន់ភ្លន់

**៥-មទ្ទវៈ** ទ្រង់មានអធ្យាស្រ័យទន់ភ្លន់

**៦-តបៈ** ទ្រង់មានព្យាយាមលះសេចក្ដីអាក្រក់

**៧-អក្កោធៈ** ទ្រង់មិនក្រោធ

**៨-អវិហឹសា** ទ្រង់មិនបៀតបៀន ចងគំនុំព្យាបាទអ្នកដទៃ

**៩-ខន្តិ** ទ្រង់កាន់ព្រះទ័យអត់ធ្មត់

**១០-អវិរោធ** ទ្រង់មិនរំលោភខុសច្បាប់ ។

**ទានៈ** ប្រែថា ការអោយ ឬអំណោយ អោយនូវវត្ថុអ្វីក៏ដោយ ល្មមតែអ្នកទទួលយកទៅបរិភោគ ឬ ប្រើប្រាស់បាន ហៅថា ទាន គឺ ការអោយ ។

### ការចែកចេកជា ២ យ៉ាងគឺ :

**១-សាធារណទាន** ការអោយទូទៅ មិនចំពោះថាអ្នកនេះអ្នកនោះ ។

**២-អសាធារណទាន** ការអោយមិនទូទៅ គឺអោយចំពោះតែម្នាក់ៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ការអោយទូទៅ ដូចជាអ្នកមានទ្រព្យធន មានសទ្ធាជ្រះថ្លា បំពេញបុណ្យកុសលអ្វីមួយ, ឬបានអោយដល់សមណៈ ព្រាហ្មណ៏ព្រឹទ្ធ, កបណៈ អ្នកកំព្រា, អទ្ធិក អ្នកដើរផ្លូវឆ្ងាយ, វណិព្វក អ្នកពោលសរសើរ ហើយទើបសូម, យាចក អ្នកសុំត្រង់ៗតែម្តង គឺសុទ្ធតែអ្នកកំសត់ ទុគិត ដែលត្រូវអោយៗ ដោយមិនចំពោះយ៉ាងនេះ ឬ ដូចជាព្រះរាជាទ្រង់ចំណាយព្រះរាជាទ្រព្យដោយដល់ប្រជារាស្ត្រអ្នកប្រក្រតី មិនចំពោះអ្នកណាម្នាក់ ប៉ុណ្ណោះជាដើមហៅថា **សាធារណទាន** ការអោយទូទៅយ៉ាងនេះបានផលច្រើនជាង អសាធារណទាន ។

ឯអសាធារណទាន ដូចជាមាតាបិតាអោយនូវវត្ថុ មានសំពត់ស្លៀក អាវពាក់ជាដើមដល់បុត្រធីតា ឬ ញាតិការបងប្អូន សាច់សាលោហិត ដោយចំពោះយ៉ាងនេះហៅថា **អសាធារណទាន**, ម្យ៉ាងទៀត ដូចជាទាយកទាយិកា អោយដល់ភិក្ខុអង្គនេះ អង្គនោះឬសាមណេរអង្គនេះ អង្គនោះ តាមដែលខ្លួនពេញចិត្ត ។ ប៉ុណ្ណោះជាដើម ហៅថា អសាធារណទាន ។

ការអោយទាន សូម្បីទេយ្យវត្ថុ បន្តិចបន្តួច ចិត្តជ្រះថ្លាបរិសុទ្ធ ក៏បានទទួលផលសមតាមសេចក្តីប្រាថ្នាមិនខាន, សមដូចរឿងនាងទុគ្គតធីតា (បាយក្តាំង១ ដុំរបស់ស្រីមានភ័ព្វ មានតម្លៃកាត់មិនបាន) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

មានសេចក្តីដំណាលថា ៖ កាលពីព្រះសម្ពុទ្ធទ្រង់គង់ក្នុងវត្តវេឡុវ័ន មានត្រកូលមួយនៅក្នុងក្រុងរាជគ្រឹះ កើតអហិវាតរោគ ស្លាប់អស់នៅសល់តែកូនស្រីមួយ ។ នាងធីតានោះ កាលបើមាតាបិតាបង ប្រុសស្រីស្លាប់អស់ហើយ ក៏រត់ចុះពីផ្ទះ ទៅជ្រកកោន នៅក្រោមសំយាបផ្ទះរបស់ជនដទៃ, មនុស្សទាំងឡាយបានឃើញធីតាកំសត់នោះ ក៏មានចិត្តមេត្តាករុណាអោយបាយកក បាយក្តាំង ដែលសល់ពីខ្លួនបរិភោគអោយដល់នាងតែរាល់ៗថ្ងៃ ។ ថ្ងៃមួយព្រះមហាកសបត្ថេរ លោកចេញពីនិរោធសមាបត្តិបានរំពឹងពិចារណារកបុគ្គលដែលគួរទៅជួបសង្គ្រោះ ក៏បានឃើញនាងទុគ្គតធីតានោះ ហើយបានជ្រាបដោយសព្វគ្រប់ បើអាត្មាអញទៅដល់ នាងទុគ្គតធីតា នឹងអោយបាយក្តាំងដល់អាត្មាអញពុំខាន កាលបើអោយដូច្នោះហើយនាងនឹងបានទៅកើតក្នុងឋានសួគ៌ពិតប្រាកដ ។

ម្យ៉ាងទៀតនាងនេះត្រូវជាមាតារបស់អាត្មាអញ ក្នុងជាតិជាគំរប់បី រាប់អំពីជាតិនេះទៅ ។ ព្រះមហាកស្សបត្ថេរ បានជ្រាបដូច្នេះហើយក៏យកបាត្រនិមន្ត សំដៅទៅទីដែលនាងទុគ្គតធីតា នោះនៅអាស្រ័យ ។ លំដាប់នោះ សក្កទេវរាជ ព្រះចៅស្ថានត្រៃត្រឹង្ស បានជ្រាបហេតុនោះហើយ ក៏និមិត្តខ្លួនមាណព កាន់អាហារទិព្វ ដើរទៅស្ទាត់មុខព្រះមហាកស្សបត្ថេរ ៗ បានជ្រាបថាសក្កទេវរាជមកថ្លែងដូច្នោះ ក៏មានថេរដីកាហាមឃាត់ថា មហារាជកុំប្លន់យកសម្បត្តិរបស់ទុគ្គតធីតាឡើយ សូមព្រះ-

អង្គចៀសចេញទៅ ។ សក្កទេវរាជ ក៏វិលត្រឡប់ទៅទេវលោកវិញ ។ ព្រះមហាកស្សបត្ថេរ បាននិមន្តទៅឈរក្នុងទីចំពោះមុខនាងទុគ្គតធីតា ។ គិតថាព្រះថេរនេះលោកមកប្រោសអញហើយតើ ! អញចំជាស្ត្រីមានលាភប្រសើរណាស់ ។

សេចក្ដីជ្រះថ្លារបស់នាង ក្នុងពេលនោះក៏កើតឡើង ពេញបរិបូណ៌ផ្សាយដល់ព្រឺស្បែកព្រឺរោម នាងបានយកបាយក្ដាំងៗ ដុំដែលនៅក្នុងអំបែងទៅដាក់បាត្រព្រះមហាកស្សបត្ថេរៗ កាលបើបានបាយក្ដាំង ហើយក៏ងាកមើលនាយអាយ បំរុងនឹងរកកន្លែងឆាន់ ។ ពួកមហាជនបានឃើញអាការនោះ ហើយនាំគ្នាក្រាលអាសនប្រគេន លុះឆាន់រួចក៏ធ្វើភត្តានុមោទនាថា ម្នាលនាងកំសត់ ! កាលពីជាតិមុននាងត្រូវជាមាតាបង្កើតរបស់អាត្មាក្នុងជាតិទី ៣ ចាប់អំពីជាតិនេះទៅ ។ នាងទុគ្គតធីតា បានឮដូច្នោះហើយក៏រីងរឹតតែជ្រះថ្លារីករាយ ជាភិយ្យោភាព, បន្ទាប់មកនាងក៏ធ្វើមរណកាលទៅ បានទៅកើតក្នុងស្ថាននិម្មានរតីទេវលោក បរិបូណ៌ដោយទិព្វសេរី ខ្ពាត់ផុតសេចក្ដីទាល់ក្រគ្រប់យ៉ាង ។

**សីល** រក្សាកាយវាចាអោយរៀបរយ សីលជាគុណជាតិ ញុំាងអ្នកដែលរក្សាអោយបានសេចក្ដីសុខ សេចក្ដីចំរើន ចៀសរួចអំពីចតុរាបាយហើយបានទទួលការត្រជាក់កាយ សប្បាយចិត្ត ទាំងក្នុងលោកនេះ នឹងបរលោក ។ **បុច្ឆា អ្វីជាតួសីល ?**

Websites: WatKhemaraRatanaram.org or WatKhmers.org

**វិសជ្ជនា** ចេតនាជាតួសីល ។ សមដូចពុទ្ធភាសិតថា **ចេតនាហំ ភិក្ខវេ សីលំ វទាមិ** ។ ម្នាលភិក្ខុទាំងឡាយតថាគត ពោលថា ចេតនាជាតួសីល ។

ចេតនា នាំអោយកើតសីលបានដល់វិរតីការវៀរ ៣ យ៉ាងគឺ :

**១~សម្បត្តិវិរតិ** វៀរដោយការដល់ព្រម

**២~សមាទានវិរតិ** វៀរដោយបានសមាទាន

**៣~សមុច្ឆេទវិរតិ** វៀរដោយដាច់ខាត ។

សម្បត្តិវិរតិ វៀរចំពោះវត្ថុដែលដល់ព្រម គឺសត្វ ដែលល្មមសំលាប់ ក៏មិនសម្លាប់ក៏មិនសម្លាប់ ទ្រព្យគេគួរលួចមកបាន ក៏មិនលួច ប្រពន្ធកូនគេគួរ នឹងប្រព្រឹត្តកាមេបាន ក៏មិនប្រព្រឹត្ត សម្តីឯណាដែលល្មមកុហក ក៏មិននិយាយ សុរាល្មមផឹកកើត ក៏ឈប់មិនផឹក, វត្ថុទាំង ៥ មុខនេះដល់ព្រមចំពោះមុខហើយ ក៏មិនប្រព្រឹត្តអោយកន្លង ខ្លាចក្រែងមានពៀរវេរាទៅខាងមុខដូច្នេះឈ្មោះថាសម្បត្តិវិរតិ ។

សមាទានវិរតិ វៀរដោយបានសមាទាន អំពីសំណាក់ភិក្ខុសាមណេរ ឬគ្រហស្ថដែលគេបានសមាទានមុនហើយ សមាទានតអំពីគេមក បើជួបប្រទះ នឹងបញ្ចវេរាទាំង ៥ ណាមួយ ក៏មិនប្រព្រឹត្តកន្លងខ្លាចដាច់សីល ដូច្នេះឈ្មោះថា សមាទានវិរតិចេតនា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សមុច្ឆេទវិរតិ វៀរដោយផ្តាច់បង់នូវកិលេស ជាមួយអរិយមគ្គ ដែលកើតឡើងសីល ក៏កើតជាមួយគ្នា ក្នុងពេលនោះកិលេសក៏អស់ទៅ ដូច្នេះឈ្មោះថា សមុច្ឆេទវិរតិ ។

ចេតនាដែលនាំអោយកើតសីលឡើង ដោយអាស្រ័យធម៌ ២ ប្រការគឺ :

**១-ហិរិ** សេចក្តីខ្មាស់បាប

**២-ឱត្តប្បៈ** សេចក្តីកោតក្រែងខ្លាចបាប ។

**សីលដាច់ដោយហេតុ ២ យ៉ាងគឺ :**

**១-សាវជ្ជោ** ដាច់មានទោសដោយការប្រព្រឹត្ត កន្លងនូវសិក្ខាបទណាមួយ ។

**២-អនាវជ្ជោ** ដាច់ដោយមិនមានទោសគឺស្លាប់ ។

**សីលមាន ៤ យ៉ាងគឺ :**

**១-និច្ចសីល** បានដល់សីល ៥

**២-ឧបោសថសីល** បានដល់សីល ៨

**៤-អតិរេកសីល** បានដល់សីល ១០

**៥-ចតុប្បារិសុទ្ធិសីល** សីល ៤ របស់ភិក្ខុ ។

គុណនៃការរក្សាសីល ៥ និងចំរើនអាការ ៣២ ប្រការ ។ មានសេចក្តីដំណាលថា :

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុង ឥសិបតនមិគទាយវ័ន នាក្រុងពារាណសី ។ ជាមួយភិក្ខុសង្ឃច្រើនរយអង្គ ។ កាលនោះក្នុងក្រុងពារាណសី មានធីតាមួយរូបឈ្មោះរបស់ការី កំពុងអង្គុយរកចៃអោយមាតាក្នុងផ្ទះ បានឃើញភិក្ខុសង្ឃចូលទៅបិណ្ឌបាត ក៏និយាយប្រាប់មាតាថា បពិត្រអ្នកម្តាយ ភិក្ខុសង្ឃដែលគង់នៅក្នុងព្រៃ ឥសិបតនមិគទា-យវ័ន បានចូលមកបិណ្ឌបាត ក្នុងភូមិរបស់យើង ភិក្ខុទាំងនោះនៅក្មេងៗ កំពុងពេញកម្លោះ មានរូបស្អាតផូរផង់ល្អ ហេតុដូចម្តេចបានជានាំគ្នាបួសដើរសុំគេយ៉ាងនេះ លោកមានប្រាថ្នាដូចម្តេច ? មាតានិយាយប្រាប់ថា លោកបួសយកបុណ្យ កុំសួរអីគិតតែពីរកចៃទៅ ។ ក្នុងពេលនោះមានឧបាសកម្នាក់សំរេចដល់សោតាបត្តិផល កំពុងដើរនៅមុខផ្ទះ បានឮនាងព្រាហ្មណី និយាយនិងកូនក្រមុំដូច្នោះ ក៏ឡើងទៅលើផ្ទះនោះ ។ នាងព្រាហ្មណី និងកូនក្រមុំបានឃើញឧបាសកឡើងទៅលើផ្ទះរបស់ខ្លួនដូច្នោះ ហើយក៏រៀបចំអាសនអោយអង្គុយ, ទើបនាងបេសការីធីតាជាកូន សួរឧបាសកថា បពិត្រលោកអ៊ុំ ភិក្ខុសង្ឃដែលបិណ្ឌបាតអម្បាញ់មិញនេះ នៅក្មេងៗ កំពុងពេញកំលោះ មានរូបរាងស្អាតបាត អង្គខ្លះៗប្រហែលជាកូនគហបតីសេដ្ឋី ឬក៏ព្រះរាជបុត្ររបស់ក្សត្រអង្គណាមួយក៏មិន? លោកគិតឃើញដូចម្តេច បានជាទៅបួសៗប្រាថ្នាអ្វី ? ខ្ញុំសង្ស័យណាស់ ។ ឧបាសកប្រាប់ថា ម្នាលនាងក្រមុំ ភិក្ខុសង្ឃទាំងអស់នេះ លោកប្រាថ្នា

អោយរួចចាកទុក្ខក្នុងវដ្តសង្សារ ព្រោះលោកពិចារណាឃើញច្បាស់នូវទោសរបស់វត្ថុកាម និងកិលេសកាម នឹងឃើញច្បាស់នូវអានិសង្សរបស់បព្វជ្ជា ព្រោះបព្វជ្ជាមានគុណខ្ពង់ខ្ពស់បំផុត អាចធ្វើអោយសត្វឆាប់រួចចាកពីការកើត ចាស់ ឈឺ ស្លាប់បាន, សំដែងដូច្នេះហើយក៏សរសើរអំពីត្រៃសរណគមន៍ និងសីល ៥ តទៅទៀត លុះចប់ហើយនាងបេសការីធីតាសួរឧបាសកនោះទៀតថា លោកអ៊ុំ ! យើងខ្ញុំដល់ត្រៃសរណគមន៍ហើយរក្សាសីល ៥ តើបានអានិសង្សដូចលោកអ៊ុំមានប្រសាសន៍ដែរឬទេ ? ឧបាសកឆ្លើយថា ប្រសើរវិសេសណាស់នាង ! ព្រោះធម៌របស់ព្រះសម្ពុទ្ធមិនរើសថាក្មេងចាស់ទេ ។ នាងក៏សុំសមាទានសីល ៥ អំពីបាសកនោះហើយសួរថាកិច្ចដទៃ ក្រៅពីនេះមានច្រើនណាស់ ប៉ុន្តែនាងចូរពិចារណានឹងទ្វត្តិំសាការកម្មដ្ឋានជានិច្ចរាល់ថ្ងៃចុះ ដើម្បីអោយបានអានិសង្សច្រើន ។ ឧបាសកបានពន្យល់អាការ ៣២ ប្រការ និងវិធីពិចារណាដោយពិស្តារហើយក៏លានាងទាំងពីររូបទៅគេហដ្ឋានរបស់ខ្លួនវិញទៅ, ឯនាងបេសការីធីតាកូនក្រមុំរបស់នាងព្រាហ្មណីនោះ ជាស្ត្រីមានឧបនិស្ស័យចាស់ក្លាគ្រាន់តែបានពិចារណានូវអាការ ៣២ ប្រការ ក្នុងថ្ងៃនោះ ក៏បានសំរេចដល់សោតាបត្តិផល ។

ក្នុងកាលជាខាងក្រោយមក នាងស់អាយុដ៏បានទៅកើតក្នុងវិមានកែវពិទូរ្យកំពស់ ៣០ យោជន៍នាឋានត្រៃត្រឹង្ស បានជាអគ្គមហេសី

របស់ព្រះឥន្ទ្រាធិរាជ នាងមានស្រីទេពអប្សរមួយសែនជាបរិវារ មានពន្លឺរស្មីផ្សាយចេញអំពីការដ៏រុងរឿង ដូចជាពន្លឺព្រះច័ន្ទ បរិបូណ៌ដោយ ទិព្វសិរីស្ថិតនៅក្នុងទេវលោក ជាសុខក្សេមក្សាន្ត ។

បុគ្គលអ្នកបរិបូណ៌ដោយសីលតែងបានសេចក្តី ត្រជាក់ចិត្តជាថ្នាក់ៗឡើងទៅ ដូចព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ទេសនា សរសើរអានិសង្សសីលថា ៈ សីលមានប្រយោជន៍អោយកើតសំវរៈ ការសង្រួមៗ មានប្រ-យោជន៍មិនអោយមានវិប្បដិសារី សេចក្តីក្តៅក្រហាយចិត្ត, ការមិនមានវិប្បដិសារីមានប្រយោជន៍ អោយកើតបាមោជ្ជ សេចក្តីរីករាយចិត្តៗ មានប្រយោជន៍អោយកើតបីតិ សេចក្តីឆ្អែតចិត្តៗ មានប្រយោជន៍អោយកើតបស្សទ្ធិ សេចក្តីស្ងប់ចិត្តៗ មានប្រយោជន៍អោយកើតសុខ សេចក្តីស្រួលចិត្តៗ មានប្រយោជន៍អោយកើតសមាធិ សេចក្តីដំកល់ចិត្តមាំទាំងក្នុងកុសលធម៌ៗ មានប្រយោជន៍អោយកើត **យថាភូតញ្ញាណទស្សនៈ** សេចក្តីយល់ឃើញ ដឹងច្បាស់នូវសភាវធម៌ទាំងពួងតាមសភាវពិត ។ មានប្រយោជន៍អោយកើតនិព្វិទា សេចក្តីនឿយណាយក្នុងសត្វ និងសង្ខារៗ មានប្រយោជន៍អោយកើតវិរាគៈ សេចក្តីប្រាសចាកតម្រេកៗ មានប្រយោជន៍អោយកើតវិមុត្តិ សេចក្តីរួចផុតស្រឡះចាកកិលេសៗ មានប្រយោជន៍អោយកើតវិមុត្តិញ្ញាណទស្សនៈ សេចក្តីយល់ឃើញដឹងច្បាស់ថា បានវិមុត្តិៗ មានប្រយោជន៍អោយបានអនុទាបរិនិព្វាន ការរំលត់ទុក្ខដោយអស់សេចក្តីប្រកាន់មាំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្យ៉ាងទៀតព្រះអង្គទ្រង់សំដែងថា : **ឥជ្ឈតិ ហិ ភិក្ខវេ សីលវតោ ចេតោ បណិធិ,** ម្នាលភិក្ខុទាំងឡាយ ! សេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្ត អ្នកមានសីល រមែងបានសំរេចដូចបំណង ។ ព្រោះអាស្រ័យពុទ្ធភាសិតដូច្នេះ បានជាក្នុងទីបំផុតនៃការសមាទានសីល លោកអ្នកអោយសីល តែងសំដែងអានិសង្សសីលប្រាប់អ្នកសមាទានសីល ហើយទូន្មានអោយអប់រំអោយដុសខាត់សម្អាតសីលថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សត្វទាំងឡាយបានសុគតិព្រោះសីល បានភោគសម្ប័ទក៏ព្រោះសីល បានរំលត់ទុក្ខក៏ព្រោះសីល ហេតុនោះអ្នកមានសីល គប្បីជំរះសីលអោយបរិសុទ្ធចុះ ។

**បរិច្ចាគ** ការបរិច្ចាគ គឺលះបង់នូវមច្ឆិរិយ សេចក្តីកំណាញ់ស្វិតស្វាញ គបណៈ អទ្ធិកៈ វិណិព្វកៈ យាចនៈ អ្នកកំសត់ទុគ៌តអត់ឃ្លាន ។

**អាជ្ជវៈ** មានចិត្តទៀងទាត់ត្រឹមត្រង់ មិនវៀចវេរ ចំពោះអ្នកនៅក្រោមអាណាព្យាបាល ព្រមទាំងប្រជាជនទូទៅគ្រប់ជាន់ថ្នាក់ ។

**មទ្ទវៈ** ទ្រង់មានអធ្យាស្រ័យ ស្លូតបូត សុភាពរាបសារ សមរម្យទន់ភ្លន់ ផ្អែមល្ហែម មិនឆេវឆាវកាចសាហាវ ខុសលក្ខណៈ ជាអ្នកគ្រប់គ្រងប្រជារាស្ត្រទូទៅ ។

**តបៈ** ទ្រង់មានវិរិយភាពព្យាយាម លះបង់សេចក្តីអាក្រក់ ដែលកើតឡើងហើយ និងព្យាយាមការពារនូវអំពើអាក្រក់ណាមួយ ដែលបំរុងនិងកើតឡើងដោយត្រៃទ្វារ មានកាយទ្វារជាដើម ។

**អវិរោធនៈ** ទ្រង់មិនក្រោធពិរោធ មិនសមហេតុផល ត្រូវមានការពិចារណា ពិសោធន៏ពិនិត្យពិច័យ នូវកិច្ចការអោយល្អិតល្អន់ ទើបចាត់វិធានការ, កុំចេះតែជឿអ្នកនៅក្រោមបញ្ជាមានការច្រណែនឈ្នានិសចាក់រុក ឆ្កឹះឆ្កៀល ព្រោះប្រាថ្នាបុណ្យស័ក្តិខ្ពង់ខ្ពស់ ។ ការច្រណែនជាពូជនៃពៀរក្នុងលោក ដូចជារឿងបញ្ចបក្ខី សូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

កាលពីបឋមកប្បនេះ មានសត្វបក្សី ៥ គឺ ហង, គ្រុឌ, សេក, ក្អែក, មៀម ។ សត្វទាំង ៥ នេះជាប្រមុខរបស់សត្វបក្សីទាំងឡាយក្នុងពេលនោះ ឯសត្វទាំង ៥ នេះមានសមត្ថភាពស្មើៗគ្នា ពុំមានសត្វណាគោរពស្តាប់បង្គាប់សត្វណាឡើយ ទោះបីមានសត្វសាហាវមកបៀតបៀនបក្សីណាមួយ ក៏គ្មានសត្វណាការពារមើលគ្នីគ្នាឡើយ, កោលាហល ក៏កើតឡើង ដល់បក្សីទាំងឡាយនោះរាល់ពេលវេលា ។ ថ្ងៃមួយពួកបក្សីចាស់ៗបានហើរទៅប្រជុំគ្នាលើដុំថ្មនៅសិលាមួយខ្ពស់ បានព្រឹក្សាគ្នាថាយើងគួររើសបក្សីណាមួយ ដែលអង់អាចអោយធ្វើជាស្តេចគ្រាន់បានជាទីគោរព និងមើលការខុសត្រូវ ដើម្បីអោយមានសន្តិភាពក្នុងបក្សីយើង ។

បក្សីចាស់ដទៃទៀតនិយាយឡើងថា បើដូច្នោះគួរយើងទៅប្រមូលបក្សីទាំងអស់គ្រប់ភេទ អោយមកកាន់ទីនេះ ហើយយើងត្រូវរើសបក្សី ៥ រូបដែលមានសមត្ថភាពល្អ អោយធ្វើជាបេក្ខបក្សី ទើបយើងរើសយកតែមួយរូប អោយធ្វើជាស្តេចទើបគួរ និយាយហើយក៏ទៅហៅបក្សីទាំងអស់អោយមកប្រជុំគ្នានៅលើដុំមនោសិលានោះ, ដល់មកជួបជុំបក្សីចាស់ ១ រូប និយាយប្រកាសថា បណ្តាបក្សីទាំងអស់នេះយើងរើសយកបក្សី ៥ រូប គឺ ហង្ស ១ គ្រុឌ១ សេក១ ក្អែក១ មៀម១ អោយធ្វើជាបេក្ខបក្សី តើអ្នកទាំងអស់គ្នាគួរយកបក្សីណាអោយធ្វើជាស្តេច ? ។

ពេលនោះមានសត្វខ្លែងស្រាក់ចាស់មួយឆ្លើយឡើងថា គួរតែតាំងសត្វមៀមអោយធ្វើជាស្តេចរបស់បក្សីទាំងអស់, ព្រោះមៀមជាសត្វអស់អាច មានភ្នែកក៏ធំល្អ អាចមើលការខុសត្រូវបានច្រើនជំពូក មានសំឡេងក៏ពិរោះ ហើយជាអ្នកឆ្លៀសវៃ ឆ្លៀវឆ្លាតផង ។ ពួកបក្សីទាំងឡាយក៏ព្រមអនុម័តិគ្នា បានបន្លឺសំឡេងអឺងកងឡើងថាស្រួលហើយៗ ។ កាលនោះមានសត្វក្អែកចាស់មួយប្រាថ្នាចង់សោយរាជ្យ ក៏ស្រែកបញ្ចេញមតិជំទាស់ឡើងថា សត្វមៀមនេះជាកោសិយគោត្រ មានជាតិថោកទាបទាសអប្រិយ, តែថាបើញាតិទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំៗ នឹងនិយាយអោយស្តាប់ ។ បក្សីទាំងអស់បើកឱកាសអោយក្អែកៗនិយាយថាតាមមតិរបស់ខ្ញុំមិនគួរអោយមៀមធ្វើជាស្តេចត្រួតត្រា រក្សាសុខទុក្ខរបស់យើង

ទាំងឡាយទេ ព្រោះមៀមនេះ មានមុខក្រញូវអាក្រក់ ពេកណាស់ បើតាមលក្ខណៈក្បួនចាស់ទំនាយថា មុខមិនទទួលភ្ញៀវ មិនទាន់ខឹងផង មុខដូចជាខឹងទៅហើយ បើយ៉ាងនេះ តើបក្សីណានឹងហ៊ានចូលទៅប្រា-ស្រ័យការផងបាន, មិនគួរតាំងអោយធ្វើជាស្តេចឡើយ ។ បក្សីទាំងឡាយក៏ទទួលព្រមតាមក្អែក បានបន្លឺសំឡេងគឹកកងថាមែនហើយៗអោយធ្វើស្តេចមិនកើតទេ ព្រោះក្អែកអាក្រក់ណាស់ ។ បន្ទាប់មកនោះមានសត្វត្មាតចាស់មួយស្រែកបញ្ចេញមតិឡើងថា តាមទំនៀមបុរាណបុគ្គលណាឈ្លាសវៃអាចចាប់ពុរុទ្ធរបស់ជនជាធំបាន ដោយសមហេតុសមផលតាមគន្លងច្បាប់ត្រូវតាំងអ្នកនោះអោយធ្វើជាធំវិញ, ហេតុនេះត្រូវតែយើងតាំងក្អែកអោយធ្វើជាស្តេច ព្រោះជាសត្វក្លៀវក្លា ហើយវាងវៃល្មមជាប្រមុខរបស់យើង ។

បក្សីទាំងឡាយ ក៏បន្លឺសំឡេងគឹកកងឡើង ពាក្យរបស់ត្មាតនេះត្រឹមត្រូវណាស់ គួរយើងតាំងក្អែកអោយធ្វើជាស្តេចចុះ ។ ពេលនោះមៀមពុំសុខចិត្ត បានសុំឱកាសនិយាយ បក្សីទាំងឡាយក៏ព្រម បើកឱកាសអោយទើបមៀមស្រែកនិយាយឡើងថា ពាក្យដែលត្មាតនិយាយនោះត្រូវតាមច្បាប់បុរាណហើយ ប៉ុន្តែក្អែកនេះមិនគួរសមតាមច្បាប់នោះទេ ព្រោះមានអតីតនិទានដំណាលថា : សត្វក្អែកជាចណ្ឌាលគោត្រ អាក្រក់ថោកទាបបំផុតជាអ្នកមានទោសកំហុសក្បត់ផែនដី ត្រូវរាជការកាត់ទោសយកទៅ

ដុតទាំងរស់ ប៉ុន្តែវារត់រួចបានជាខ្មៅក្រខ្វក់យ៉ាងនេះ, បើអ្នកមានទោសកំហុសដល់ម្លឹង តើអោយធ្វើជាធំដូចម្ដេចកើត ។ បក្សីទាំងឡាយបានបន្លឺសំឡេងគឹកកងឡើងថា ពាក្យរបស់មៀមនេះត្រូវណាស់ ព្រោះអ្នកមានទោសកំហុស បុរាណមិនដែលអោយជាធំទេបើដូច្នេះ យើងត្រូវរើសបក្សីដទៃទៀត ។ ក្អែកបានស្ដាប់ពាក្យនោះ ក៏ខឹងច្រឡោតមហិមា ទើបស្រែកឡើងថា ម្នាលក្អែកគ្នាយើងទាំងឡាយ អញវិនាសហើយៗព្រោះតែអាមៀមមុខខ្មោច មុខដូចគេខមនេះឯង ។ ឯសត្វមៀមបានឮថាមុខខ្មោច មុខដូចគេខមដូច្នេះ ក៏ខឹងច្រឡោតស្រែកឡើងថា ម្នាលមៀមគ្នាយើងទាំងឡាយ អញវិនាសហើយៗព្រោះតែអាក្អែកចណ្ឌាលមានទោសឧក្រិដ្ឋ គេដុតទាំងរស់នេះឯង ។ សត្វទាំងពីក្រុមនេះ ក៏ឈ្លោះទាស់ទែងប្រចឹកគ្នាជាខ្លាំង, ពួកបក្សីទាំងឡាយនាំគ្នាបណ្ដេញចេញ ពីទីប្រជុំសត្វទាំងពីរក្រុម ក៏ហើរចេញទៅប្រចឹកគ្នាខាងក្រៅទៀត ហើយចងគំនំនឹងគ្នាអស់មួយកប្ប ។ សត្វទាំងពីរក្រុមក៏មានពៀរនឹងគ្នារហូតមកដល់ក្នុងកាលឥឡូវនេះ ។ កាលបើសត្វទាំងពីរក្រុមចេញផុតហើយ បក្សីទាំង-ឡាយ ក៏បើកពេលប្រជុំម្ដងទៀត, ពេលនោះមានបក្សីចាស់មួយរូបនិយាយឡើងថា យើងគួរយកសត្វគ្រុឌអោយធ្វើជាស្ដេចចុះ ព្រោះជាសត្វមានកំលាំងជាសត្វនានា លុះនិយាយចប់ហើយ មានសេកចាស់ ១ ជាបណ្ឌិតបាននិយាយប្រកាសថា សត្វគ្រុឌមានកំលាំងខ្លាំងជាងសត្វនានា

មែនហើយ ប៉ុន្តែខ្វះបញ្ញាសម្បត្តិ និងចរិយាសម្បត្តិ បើសត្វហង្សទើបគួរជាង ព្រោះសត្វបរិបូណ៌ដោយរូបសម្បត្តិ បញ្ញាសម្បត្តិ ចរិយាសម្បត្តិ និងគុណសម្បត្តិ ជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ល្មមធ្វើជាស្តេចបាន ។ ពួកបក្សីទាំងឡាយមានត្រុឌជាដើម បានទទួលព្រមមតិរបស់សេកក៏បន្លឺសំឡេងគឹកកងឡើង សាធុៗសមរម្យហើយ ទើបសន្មត់តាំងសត្វហង្សអោយធ្វើជាស្តេចបក្សតាំងពីពេលកាលនោះមក ។

**អវិហឹសា** ទ្រង់មិនគំនុំ ចងអាឃាតព្យាបាទ បៀតបៀនដល់ប្រជារាស្ត្រ គឺមានព្រះទ័យស្រណោះអាណិតអាសូរករុណាដល់ប្រជាជនគ្រប់ជាន់ថ្នាក់ គ្រប់វណ្ណៈ គ្រប់ប្រភេទ ។

**ខន្តិ** ទ្រង់មានព្រះទ័យអត់ធ្មត់ មិនក្រោធច្រឡោតតូងតាងចំពោះហេតុដែលមិនគួរក្រោធ ។

ខន្តីសេចក្តីអត់ធន់បើពោលដោយបរិយាយលោកចែកចេញជា ៣យ៉ាងគឺ :

១-អត់ធន់ចំពោះសេចក្តីទុក្ខ ដែលនាំអោយកើតលោភ

២-អត់ធន់ចំពោះសេចក្តីទុក្ខដែលនាំអោយកើតទោស

៣-អត់ធន់ចំពោះសេចក្តីទុក្ខ ដែលនាំអោយកើតមោហៈ ។

ឯអត់ធន់ចំពោះសេចក្តីទុក្ខ ដែលនាំអោយកើតលោភៈនោះ គឺអត់ធន់ ទ្រាំនឹងចំណង់ដែលកើតឡើងក្នុងទ្វារទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។

ការអត់ទ្រាំ គឺការមិនប្រព្រឹត្តទុច្ចរិតផ្សេងៗតាមចំណង់ ក្នុងទ្វារទាំង ៦ នោះឯង ។ មនុស្សដែលមិនចេះអត់ទ្រាំ និងសេចក្ដីលោភតែងលួចប្លន់ឆកដណ្ដើម បំបាក់ប្រវញ្ចទ្រព្យសម្បត្តិរបស់គេ ដែលនាំអោយត្រូវទោសទណ្ឌកម្មផ្សេងៗ មានជាប់គុកច្រវ៉ាក់ជាដើម ។ មនុស្សដែលចេះអត់ទ្រាមង មិនរវះរវាម រលោរលាំ និងចំណង់ផ្សេងៗតែងបាន ប្រកបដោយសេចក្ដីសុខចំរើន, ការចេះអត់ទ្រាំ នឹងសេចក្ដីទុក្ខ ដែលនាំអោយកើតរាគៈ ក៏គួរសង្គ្រោះ ចូលក្នុងខន្តីនេះដែរ ។ ឯសេចក្ដីអត់ធន់ និងសេចក្ដីទុក្ខដែលនាំអោយកើតទោសនោះគឺ ការអត់ទ្រាំ នឹងពាក្យបរម្បវ៉ាផ្សេងៗ ឬចំពោះអក្កោសវត្ថុ ដែលបុគ្គលដទៃស្ដីថាត្មះតិះដៀល ឬ អត់ទ្រាំនឹងអំពើបៀតបៀនរបស់បុគ្គលដទៃ ដែលនាំអោយកើតទោសៈ ក៏ឈ្មោះថាខន្តី ។

ឯសេចក្ដីអត់ទ្រាំ និងសេចក្ដីទុក្ខ ដែលនាំអោយកើតមោហៈ នោះគឺអត់ទ្រាំនឹងទុក្ខវេទនា ផ្សេងៗ ដែលកើតឡើងក្នុងកាយនឹងចិត្ត ហើយមិនលុះក្នុងអំណាចទុក្ខវេទនានោះ ហើយប្រព្រឹត្តទុច្ចរិតឡើយ, សូម្បីអត់ទ្រាំ និងទុក្ខវេទនា ក្នុងវេលាឈឺផ្ដាត់ ដែលនាំអោយមានសតិសម្បជញ្ញៈសេចក្ដីរលឹក និងសេចក្ដីដឹងខ្លួន ក៏ឈ្មោះជាខន្តី ។

បណ្ដាសេចក្ដីអត់ទ្រាំទាំង ៣ យ៉ាងនេះ សេចក្ដីអត់ទ្រាំ និងសេចក្ដីទុក្ខដែលនាំអោយកើត លោភៈ មោហៈ ជាខន្តី ដោយបរិយាយ

ចំណែកសេចក្តីអត់ទ្រាំ និងសេចក្តីទុក្ខដែលនាំអោយកើតទោសៈ សេចក្តីប្រទូស្តទើបជាខន្តីដោយត្រង់ លោកហៅថា អធិវាសនខន្តី ។

អធិវាសនខន្តី មានអានិសង្សច្រើនយ៉ាងណាស់ មានដើមថា :

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលា ធម្មា ខន្ត្យា យេវ វឌ្ឍន្តិ តេ ។**

សេចក្តីអត់ធន់ ជាហេតុជាទីតាំងនៃគុណ គឺសីល និងសមាធិទាំង-ឡាយ ធមិជាកុសលទាំងអស់នោះ តែចំរើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខនតិ ខន្តិកោ ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫស គល់នៃបាបទាំងអស់ បុគ្គលអ្នកអត់ធនឈ្មោះថាជាអ្នកជីកគាស់រំលើងនូវឫស គល់នៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាហេតុជាដើម ។

**ខន្តិ ធីរស្ស លង្ការោ ខន្តិតបោ តបស្សិនោ**

**ខន្តិ ពលំ វយតីនំ ខន្តិ ហិតសុខាវហា ។**

សេចក្តីអត់ធន់ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ជាគ្រឿងដុតបង់នូវបាបរបស់អ្នកមានតបៈធមិ សេចក្តីអត់ធន់ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ជាអ្នកមានមិត្តសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ ។

**អត្តនោបិ បរេសញ្ច អត្ថាវហោ ច ខន្តិកោ**
**សគ្គមោក្ខគមំ មគ្គំ អារូឡ្ហោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំង-ឡាយទៀតផង អ្នកអត់ធន់ជាអ្នកឡើយកាន់ផ្លូវជាទីទៅកាន់ស្ថានសួគ៌ និងព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**
**បរមាយ ច បូជាយ ជិនំ បូ ជេតិ ខន្តិកោ ។**

អ្នកអត់ធន់ឈ្មោះថាជាអ្នកធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ឈ្មោះថា បូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្ដម ។

អដ្ឋកថាធម្មបទសំដែងរឿងនាងឧត្ដរាដោយពិស្ដារ តែក្នុងទីនេះសូមនិទានដោយសង្ខេបដូចតទៅ :

នាងឧត្ដរា ជាឧបាសិកា អ្នកបានសំរេចសោតាតាំងពីក្មេងនាងជាធីតារបស់បុណ្ណសេដ្ឋី ជាភរិយារបស់រាជគ្គហសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះដែលជាមនុស្សមិច្ឆាទិដ្ឋិ ។ តាំងពីថ្ងៃដែលនាងទៅនៅក្នុងផ្ទះស្វាមី មិន

មានឱកាស និងបរិច្ចាគទាន នាងក៏បានជួលនាងសិរិមាជាស្ត្រីផ្កាមាស អោយមកបំរើស្វាមីរបស់នាង ហើយនាងចេញទៅធ្វើការកុសលតាមប្រាថ្នា ។

ឯនាងសិរិមាផ្កាមាស កាលបើបានមកនៅជាមួយនឹងស្វាមី ឧត្តរាត្រឹមតែកន្លះខែ ក៏កំរើកចិត្តគិតចង់ដណ្តើមយកឋានៈជាផ្ទះ បានប្រទូស្តនិងឧត្តរា មានប្រការផ្សេងៗដរាបដល់ប្រើមនុស្សអោយយកទឹកក្តៅកំពុងពុះ ស្រោចចុះទៅលើនាងឧត្តរា ដែលកំពុងតែចាត់ចែងចង្ហាន់ប្រគេនព្រះសង្ឃ តែនាងឧត្តរា មានខន្តី មិនក្រោធខឹង បន្តិចបន្តួចសោះទឹកក្តៅក៏ត្រឡប់ជាត្រជាក់ដូចទឹកធម្មតា ។ នាងសិរិមា ដឹងខ្លួនថាមានទោសក៏ចូលទៅស្មាលាទោស នឹងនាងឧត្តរាៗក៏ចូលទៅគាល់ព្រះដ៏មានបុណ្យក្រាបបង្គំទូលរឿងនោះ ។ ព្រះអង្គទ្រង់ប្រទានធម្មទេសនាទូន្មានថា:

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ,**

**ជិនេ កទរិយំ ទានេន សច្ចេន អលិក វាទិនំ ។**

បុគ្គលគប្បីឈ្នះសេចក្តីក្រោធ (របស់គេ) បានដោយសេចក្តីមិនល្អ (របស់គេ) បានដោយសេចក្តីល្អ (របស់ខ្លួន) គប្បីឈ្នះមនុស្សដែលហៃនិយាយ ឡេះឡោះបាន ដោយនិយាយពាក្យពិតទៅរក ។

អ្នកមានអធិវាសនខន្តី តែងបានអានិសង្ស ៥ យ៉ាងគឺ :

Websites: WatKhemaraRatanaram.org or WatKhmers.org

**១-បិយោមនាបោ** អ្នកអត់ធន់តែងបានជាទីស្រឡាញ់ពេញចិត្តរបស់ជនជាច្រើន ។

**២-ន ទេវពហុលោ** មិនមានពៀរច្រើន

**៣-ន វជ្ជពហុលោ** មិនមានទោសច្រើន

**៤-អសម្មុឡ្ហោ** មិនវង្វេងស្មារតីមរណៈ

**៥-សុគតិ** ទម្លាយខន្ធទៅបានកើតក្នុងឋានសួគ៌ ។

**អវិរោធ** ទ្រង់មិនប្រព្រឹត្តរំលោភខុសច្បាប់ មុននឹងបញ្ជាកិច្ចការអ្វីៗ ទ្រង់តែងធ្វើការ ពិចារណាអោយល្អិតល្អន់ជាមុន ឃើញថាកិច្ចការនោះ ជាប្រយោជន៍ដល់ប្រទេសជាតិ មាតុភូមិ ទើបចាត់ការអោយទទួលបញ្ជា ធ្វើនូវកិច្ចការនោះៗ ។ ទ្រង់បើកសេរីភាពគ្រប់យ៉ាងដល់ប្រជាជន មិនបិទសិទ្ធិសេរីភាពប្រជាជន ចំពោះកិច្ចការណា ដែលមិនជំទាស់នឹងច្បាប់រដ្ឋ ។

ធមិទាំង ១០ យ៉ាងដូចបានសំដែងមកហើយនោះហៅថា **ទស-ពិធរាជធម៌** ជាធមិសំរាប់ស្តេចផែនដី កាន់អោយបានខ្ជាប់ខ្ជួនមាំមួន ទើបឈ្មោះថាស្តេចប្រកបទៅដោយធមិ ។

នរជនណាដែលកើតនៅក្នុងត្រកូលក្សត្រ តែខ្សត់ទ្រព្យសម្បត្តិ ហើយមានសេចក្តីប្រាថ្នាធំ គឺចង់បានជាស្តេចសោយរាជ្យ ដើម្បីបានអំណាចគ្រប់គ្រងនគរទាំងមូល ហើយមិនមានទ្រព្យសម្បត្តិស្តុកស្តម្ភ នឹង

Websites: WatKhemaraRatanaram.org  or  WatKhmers.org

គុណធមិទាំង ១០ ខាងលើនេះ នោជាប្រធាននៃសេចក្ដីវិនាសដោយពិតប្រាកដ ។

ការសំដែងមក ក្នុងគាថាទី១២ ដែលមានសេចក្ដីថា ជនណាកើតក្នុងត្រកូលក្សត្រ អ្នកក្សត្រសម្បត្តិ ហើយប្រាថ្នាធំ ចង់បានជាស្ដេចសោយរាជ្យស្កុកស្ដម្ភហេតុនោះ នឹងនាំអោយដល់វិនាស ។

ការសំដែងមកនេះ ក៏សន្មត់ថា

ចប់តែប៉ុណ្ណេះឯង ឯវិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មទេសនា បរាភវសុត្រ

## នមោ តស្ស

## ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## នមត្ថុ រតនត្តយស្ស វន្ទាមិ ។

ខ្ញុំព្រះករុណា សូមនមស្សការថ្វាយបង្គំ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធអង្គនោះព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

លំដាប់បន្ទាប់អំពីបទមនស្ការ ដោយសង្ខេបនេះទៅ ខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកព្រះពុទ្ធដីកា បញ្ជាក់ទៅលើព្រះគាថាទាំង ១២ ខាងដើមមានបទបាលីថា **ឯតេ បរាភវេ លោកេ** ប៉ុណ្ណោះជាដើម, ដើម្បីប្រកាសចែកជូនដល់អស់លោកយាយ លោកតា ព្រឹទ្ធាចារ្យ សប្បុរសផងទាំងឡាយ ដែលបានមកសន្និបាទជួបជុំក្នុងឧបោសថគារ នេះដើម្បីជាទីសណ្តាប់ ជាគ្រឿងភ្ញាក់កំណើតកើតគំនិត នឹងជាគ្រឿងប្រដាប់សតិស្មារតីដោយសង្ខិតន័យសង្ខេបខ្លីដូចសេចក្តីទៅនេះ :

បន្ទាប់អំពីនេះទៅ សូមលើកយកព្រះពុទ្ធដីកា បញ្ជាក់ទៅលើព្រះ-គាថាខាងដើម ។

ព្រះពុទ្ធដីកាសង្កត់ធ្ងន់ បញ្ជាក់ទៅលើ ព្រះគាថាទាំង ១២ ខាងដើមដែលមានបទបាលីថា :

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**
**អរិយោ ទស្សនសម្បន្នោ សលោកំ ភជតេសិវំ ។**

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចំរើន ។

## អធិប្បាយ

បទថា **បណ្ឌិតោ** ប្រែថា បណ្ឌិត, ពាក្យថាបណ្ឌិតបានសេចក្តីថាអ្នកប្រាជ្ញ, អ្នកមានប្រាជ្ញា អ្នកមានប្រីជា, បានដល់អ្នកដែលទទួលការសិក្សារៀនសូត្រចេះចាំ ច្រើនមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ទាំងផ្លូវលោក ទាំងផ្លូវសាសនា, ជាគ្រហស្ថក៏មាន បព្វជិតក៏មាន, បុរសក៏មាន, ស្រ្តីក៏មាន, ចាស់ក៏មាន, ក្មេងក៏មាន, អោយតែអ្នកណាមួយបានទទួលការសិក្សាច្រើនមានឧត្តមគតិល្អ មានចំណេះវិជ្ជាចេះចាំជ្រៅជ្រះប៉ុណ្ណោះជាដើមហៅថា " បណ្ឌិត " ។

ម្យ៉ាងទៀត បុរសមិនមែនសុទ្ធតែបណ្ឌិតទេ, ឯស្រ្តីបើបានសិក្សាសូត្ររៀន មានចំណេះវិជ្ជាខ្ពង់ខ្ពស់ ក៏ហៅថាបណ្ឌិតបានដែរ ។ សេចក្តីនេះសមដូចព្រះពុទ្ធដីកា ដែលមានមកក្នុងគម្ពីរខុទ្ទនិកាយជាតកអដ្ឋកនិបាត ទ្រង់ត្រាស់សំដែងថា :

**នហិ សព្វេសុ ឋានេ បុរិសា ហោតិ បណ្ឌិតោ**
**ឥត្ថីបិ បណ្ឌិតោ ហោតិ តត្ថ តត្ថ វិចក្ខណា ។**

Websites: WatKhemaraRatanaram.org or WatKhmers.org

បុរសមិនមែនសុទ្ធតែជាបណ្ឌិត ក្នុងទីសព្វអន្លើទេ ឯស្ត្រីបើមានប្រាជ្ញាក្នុងទីនោះក៏ហៅថាបណ្ឌិតបាន ។

មែនពិត ! បុរស ឬ មនុស្សប្រុសក៏មិនមែនសុទ្ធតែជាបណ្ឌិតក្នុងទីសព្វអន្លើទេ បើមនុស្សប្រុសមិនបាន ទទួលការសិក្សាអប់រំ ការសេពគប់រាប់រកនឹងបណ្ឌិតបុរសនោះ ក៏ជាមនុស្សល្ងង់ខ្លៅ មិនហៅថាបណ្ឌិត បានឡើយ, ទោះបីមានភេទជាបុរសក៏ដោយ ។ មួយយ៉ាងទៀត សូម្បីបានទទួលការសិក្សាអប់រំហើយ តែក៏មិនមែនចេះអ្វីសព្វគ្រប់ ប៉ិនប្រសប់សព្វអន្លើ គ្មានសេសសល់ក្នុង បញ្ហាផ្សេងៗនោះដែរ គង់មានខ្វះត្រង់ចន្លោះខ្លះមិនខាន, ហេតុនេះបុរសមិនមែនសុទ្ធតែបណ្ឌិតក្នុងទីសព្វអន្លើទេ ស្ត្រីភេទក៏ដោយ បើបានទទួលការសិក្សាអប់រំនូវចំណេះវិជ្ជាទាំងឡាយក៏រមែងកើតប្រាជ្ញាការឈ្លាសវៃក្នុងបញ្ហាផ្សេងៗបាន បើបានសិក្សាអប់រំច្រើនក៏អាចមានប្រាជ្ញាឆ្នើមពូកែ ជាងបុរសផងក៏មាន បើយ៉ាងនេះ ស្ត្រីក៏ជាបណ្ឌិត គឺអ្នកប្រាជ្ញបានដែរ មិនចាំបាច់តែភេទបុរសនោះឡើយ ។

ព្រះពុទ្ធដីកា សំដែងបំភ្លឺតាមការពិត ព្រោះមានមនុស្សខ្លះសំគាល់មានតែបុរសជាភេទខ្លាំងទេ ដែលអាចប្រែកាយក្លាយខ្លួនជាបណ្ឌិតនៅក្នុងប្រាជ្ញាវែងឆ្ងាយបាន ហើយជូនកាលប្រមាថកាតទានស្ត្រីភេទ ទូទៅថែមទៀត, តែសេចក្តីពិតវិញ ស្រីដែលគេនិយមថា ជាភេទទន់ខ្សោយក៏ដោយ បើបានទទួលការសិក្សា អប់រំនូវសិល្បសាស្ត្រវិជ្ជាទាំងឡាយ ក៏រមែងចំរើន

កើនបញ្ញា ការយល់ជ្រៅជ្រៅឆ្ងាយ ស្គាល់យល់កលកិច្ចការទាំងឡាយ ក្លាយជាបណ្ឌិតបានដែរ គឺបុរសក្តី ស្ត្រីក្តី បើបានទទួលការអប់រំសិក្សា សូត្ររៀនច្រើន ក៏អាចក្លាយជាបណ្ឌិតបានដូចគ្នា, បុរសក្តី ស្ត្រីក្តី បើមិនបានទទួលការអប់រំទេ ក៏ជាមនុស្សល្ងង់ខ្លៅដូចគ្នានោះឯង ។

ដូច្នេះ បុរសមិនត្រូវមើលងាយស្រីភេទ ថាគ្មានអ្នកប្រាជ្ញនោះឡើយ, ស្ត្រីក៏មិនត្រូវអស់សង្ឃឹម គិតស្មានថាខ្លួនមិនអាចទៅជាបណ្ឌិតអ្នកប្រាជ្ញបាន ព្រោះតែភេទស្រីនោះឡើយ ព្រោះការសិក្សាអប់រំ អាចធ្វើមនុស្សទោះស្ត្រីក្តី ប្រុសក្តី រហូតដល់មនុស្សខ្ទើយទៅទៀត ក៏អោយទៅជាអ្នកប្រាជ្ញបានបុរសស្ត្រី ដែលអាចក្លាយខ្លួនទៅជាបណ្ឌិតបាន ត្រូវប្រកបដោយគុណធម៌ ៤ យ៉ាង :

សមដូចគាថាព័ន្ធដែលលោកពោលទុកមកថា : អ្នករៀនរឿងព្រះត្រៃបិដក ថ្លៃតាមចំនួនប្រកបដោយអង្គ ៤ គឺ សុ-ចិ-បុ-លិ-ចាំ **សុ** ប្រែថាប្រឹងចាំស្តាប់គេ **ចិ** រិះរេគិតចំណាំ **បុ** អោយសាកសួរសាំ **លិ** អោយចាំកត់ត្រាទុក ។

សុ-ចិ-បុ-លិ **ឥមិ សម្បន្នោ ពហុំ សោ បណ្ឌិតោ ភវេ,** បើបរិបូណ៌ ឬដល់ព្រមដោយគុណធម៌ ៤ យ៉ាងនេះ អាចទៅជាបណ្ឌិតបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សុ-ចិ-បុ-លិ-**ទិនិម្មុត្តោ កថំ សោ បណ្ឌិតោភវេ,** បើរួចផុត ឬមិនមានគុណធម៌ ៤ យ៉ាងនេះមិនគប្បីទៅជាបណ្ឌិតបាត (រៀនដល់ចាស់ក៏មិនចេះ) ។

នរជនណាដែលមានប្រាជ្ញារាប់ថាជាបណ្ឌិត បើមានស្ថិតនៅទីណាហើយ ទោះបីមានភ័យ ឬទុក្ខលំបាកយ៉ាងណាក៏លោកអាចជួយដោះស្រាយបាន សមដូចព្រះពុទ្ធដីកាត្រាស់ថា :

**បណ្ឌិតោ ច វិយន្នោ ចវិតាវី ច វិចក្ខណោ**
**ខិប្បំ មោចេតិ អត្តានំ មាភាយិត្ថាគមិស្សតិ ។**

អ្នកមានប្រាជ្ញាឆ្នើមជាបណ្ឌិតវាងវៃបំភ្លឺហេតុផល គង់ដោះខ្លួនបានភ្លាម អ្នកទាំងឡាយកុំភ័យឡើយ លោកមុខជានិងមក ។

ព្រះពុទ្ធដីកាខាងលើនេះ ពោលសរសើរគុណសម្បត្តិសមត្ថភាពរបស់បណ្ឌិតដែលឋិតនៅក្នុងប្រាជ្ញវាងវៃយល់ន័យហេតុផល អាចជួយពួកបរិវារអោយចាកគ្រោះថ្នាក់, អ្នកមានប្រាជ្ញាឆ្នើម គឺអ្នកមានការដឹងស្គាល់យល់ហេតុផលសេចក្តីទុក្ខ នឹងសេចក្តីសុខ ស្គាល់ឬសគល់ប្រព្រឹត្តការណ៍ ឬផលវិបាកដែលកើតឡើងមកពីអ្វី គប្បីដោះស្រាយយ៉ាងណា គឺប្រាជ្ញាយល់ជ្រៅដៅឆ្ងាយ ស្គាល់ឧបាយយ៉ាងល្អិតល្អន់ ជននោះជាបណ្ឌិតគំនិតទូលាយ ប៉ិនប្រសប់ ឈ្លាសវៃយល់ន័យព្រឹត្តការណ៍ដោយជុំវិញ បើមានភ័យវិបត្តិគ្រោះថ្នាក់អ្វីមួយ កើតឡើងចំពោះសង្គមក្រុមពួករបស់

ខ្លួនបណ្ឌិតវាងវៃនោះ អាចទម្លុះទម្លាយ ស្រាយវិបត្តិ កំចាត់គ្រោះថ្នាក់នោះដោយអាចបំភ្លឺហេតុផលពួកក្រុមថា ត្រូវធ្វើយ៉ាងណា ឬក៏ពន្យល់សត្រូវអោយស្រុះស្រួលយ៉ាងណា ឬអោយធ្លាក់ក្នុងកលឧបាយយ៉ាងណា ដែលអាចដោះខ្លួន និងពួកក្រុមអោយរួចចាកភ័យ វិបត្តិនោះៗបានភ្លាមទាន់ពេលវេលា ។ ដូច្នោះព្រះពុទ្ធដីកានេះ អោយមានសេចក្តីសង្ឃឹមថា បើមានមេដឹងនាំប្រកបដោយប្រាជ្ញាឆ្នើមវាងវៃ ហើយកើតភ័យវិបត្តិណាមួយឡើយ ដូចជាលោកមិននៅ ក៏មិនត្រូវភ័យស្លុតពេកទេ លោកមុខជាមកជួយដោះស្រាយកែកុនភ័យវិបត្តិ អោយខ្វាត់ចាកពីពួកក្រុមបានមិនខានឡើយ ។

ជនជាបណ្ឌិតតែងតាំងចិត្ត មុតមាំចំពោះកិច្ចការ ឬបញ្ហាកម្មណាដែលកើតឡើង គេក៏ទទួលដឹងឮថា ជាមនុស្សចេះដឹងពិបាកមែន ឯមនុស្សល្ងង់ខ្លៅទេដែលច្រើនតែនៅវក់វីក្នុងកាម ។ សមដូចព្រះពុទ្ធដីកាថា :

**បណ្ឌិតោតិ សមញ្ញាតោ ឯកចរិយំ អធិដ្ឋិតោ អថាបិ មេថុនេ យុត្តោ មន្ទោវ បរិកិស្សតិ ។** អ្នកតាំងចិត្តប្រព្រឹត្តខ្លួនជាមនុស្សឯក គេដឹងព្រមគ្នាថាជាបណ្ឌិត, ចំណែកអ្នកខ្លៅវក់វីក្នុងមេថុនរមែងសៅហ្មង ។

អ្នកតាំងចិត្តប្រព្រឹត្តខ្លួនអោយខ្ជាប់ខ្ជួនក្នុងកុសលធម៌ សុចរិតបិតនៅក្នុងការកសាងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ បង្កើនគុណធម៌

សេចក្តីល្អអោយលូតលាស់ដុះដាល ចំរើនឡើងក្នុងកាយវាចាចិត្ត ដែលប្រព្រឹត្តទៅរាល់ថ្ងៃ ជំរុះបន្ថយសេចក្តីអាក្រក់ គុណវិបត្តិ អោយខ្ចាត់របេះទៅពីត្រៃទ្វារជាលំដាប់ ។ អ្នកនោះឯងជាមនុស្សឯក គឺមនុស្សទី ១ ឬមនុស្សលេខមួយ ព្រោះអាចស្ទួយជួយខ្លួនអោយឃ្លាតចាកទុច្ចរិត ទុក្ខវិបត្តិមួយ ក្នុងជីវិតស្ថិតនៅក្នុងលក្ខណជាគំរូ តទៅអាចជាកំពូលមនុស្សមេដឹងនាំមនុស្ស ប្រធានមនុស្សក្នុងសង្គម ក្រុមណាមួយ អាចជួយអ្នកដទៃបានសេចក្តីសុខ, មនុស្សតាំងចិត្តប្រព្រឹត្តខ្លួននាំអោយមនុស្សទាំងឡាយដឹងព្រមគ្នាថា ជាមនុស្សបណ្ឌិត, អ្នកប្រាជ្ញ, សប្បុរស, អាចារ្យ ដែលជានាមដ៏មានតំលៃតាមសេចក្តីប្រព្រឹត្តរបស់ខ្លួន ។

ចំណែកអ្នកខ្លៅ អប្បឥតប្រាជ្ញា មិនយល់ថាអ្វីជាប្រយោជន៍ យល់ត្រូវថាខុសៗថាជាត្រូវ, យល់បុណ្យថាបាបៗថាបុណ្យ, យល់សុខថាជាទុក្ខៗថាជាសុខ យល់ដៅទៅរកមេថុន សេវនកិច្ចតែម្យ៉ាងថាជាគ្រឿងសំខាន់ ហើយជក់វក់ចិត្តស្អិតជោកតែក្នុងផ្លូវមេថុន ទុកជាស្ថានសួគ៌ប្រចាំចិត្ត រមែងស្ថិតនៅក្នុងសេចក្តីហ្មងដោយអកុសលធម៌ ទាំងឡាយក្លាយទៅជាមនុស្សថោកទាប បាបចង្រៃ ជាមេរោគសំរាប់សង្គមមនុស្ស ។

## បណ្ឌិតត្រូវប្រកបដោយអង្គ ៤ យ៉ាង

**១_អត្តសិទ្ធិ** បរិសុទ្ធដោយខ្លួនឯង

**២_បរសុទ្ធិ** ញុំាងអ្នកដទៃអោយបរិសុទ្ធ

Websites: WatKhemaraRatanaram.org or WatKhmers.org

**៣-កតញ្ញូ** ដឹងនូវឧបការគុណ

**៤-សង្គហ** សង្គ្រោះទូទៅ ។

**អ្នកប្រាជ្ញប្រកបដោយអង្គ ៤ យ៉ាង**

**១-សុតៈ** ស្តាប់

**២-ចិន្តៈ** គិត

**៣-បុច្ឆ** សាកសួរ

**៤-លិខិត** សរសេរកត់ចំណាំ

សំដែងដោយលោកវោហាអ្នកប្រាជ្ញត្រូវប្រកបដោយកត្តា ៦ យ៉ាងគឺ

១-ចេះពាក្យពេចន៍

២-ចេះឃ្លាឃ្លោង

៣-ចេះខ្លឹមសារ

៤-ចេះជម្រៅក្នុងខ្លឹមសារ

៥-ចេះទំនាក់ទំនងពីខ្លឹមសារមួយទៅខ្លឹមសារមួយទៀត

៦-មានការអត់អាចស្វាហាប (និតិសម្បទាមិនតក់ស្លុត) ។

ជនជាបណ្ឌិតលោកតែទូន្មានខ្លួនលោក ប្រដៅខ្លួនលោក ធ្វើខ្លួនរបស់លោកអោយបានបរិសុទ្ធជាមុន បើលោកប្រៀនប្រដៅហ្វឹកហ្វឺនខ្លួនលោកអោយល្អយ៉ាងណា លោកតែងប្រដៅដាស់តឿនអ្នកដទៃ ក៏យ៉ាងនេះដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ឌិតលោកដឹងនូវឧបការគុណ ចំពោះអ្នកដទៃដែលបានធ្វើមកតើលោករួចហើយ លោកមិនដែលលុបគុណតែងប្រកបទៅដោយមេត្តាករុណា អាណិតអាសូរ ជួយសង្គ្រោះអ្នកដទៃ ដែលបានដល់នូវសេចក្តីទុក្ខលំបាកចំពោះហេតុការផ្សេងៗ ។

លោកតែងដឹកនាំពន្យល់បង្ហាត់បង្ហាញ អោយអ្នកដទៃបំពេញនូវសេចក្តីល្អ មានដឹងនាំអោយចេះអោយទានរក្សាសីល ចំរើនមេត្តាភាវនា ដូចជាព្រះបរមគ្រូដែលនៅជាពោធិសត្វនៅឡើយ សូម្បីនៅជាសត្វក៏ដោយតែងតែដឹកនាំអោយគេបំពេញសេចក្តីល្អ ដូចជារឿងសសបណ្ឌិតសូមនាំនិទាននោះមកសំដែងដូចតទៅនេះ :

## បើមានបំណងធំ គួរកំសាន្តជីវិតនិងទ្រព្យ

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិជាសត្វទន្សាយ នៅអាស្រ័យក្នុងដងព្រៃមួយ, ក្នុងព្រៃនោះមានសត្វ១, ចចក១, ភេ១, ជាសម្លាញ់នឹងគ្នា បាននៅរួមជាមួយនឹងនទន្សាយ សុទ្ធតែជាបណ្ឌិត គឺសត្វចេះដឹង តែងនាំគ្នាស្វែងរកអាហារគោចរ ស្ថានរៀងៗខ្លួនដល់ពេលល្ងាចទើបមកជួបជុំគ្នា ។ ចំណែកសសបណ្ឌិត គឺទន្សាយតែងពន្យល់ធម៌ដល់សត្វទាំងបីថា អ្នករាល់គ្នាត្រូវធ្វើទាន រក្សាសីល ធ្វើឧបោសថកម្មកុំខាន ។ សត្វទាំងបីក៏ព្រមទទួលប្រតិបត្តិ តាមឱវាទរបស់

ទន្សាយគ្រប់ៗគ្នា ។ ថ្ងៃមួយទន្សាយក្រឡេកមើលទៅ ឰដ៏អាកាសបាន ឃើញព្រះច័ន្ទរះពេញវង់ ភ្លឺស្វាងទែងក្នុងនភាល័យ ក៏ដឹងច្បាស់ ស្អែក នេះជាថ្ងៃឧបោសថ ទើបហៅសត្វទាំងបីមកប្រាប់ថា នែ! សម្លាញ់ស្អែក នេះជាថ្ងៃឧបោសថ អ្នកទាំងអស់គ្នាត្រូវរក្សាឧបោសថហើយ អោយទាន ផង ព្រោះការរក្សាសីលហើយអោយទាន តែងបានផលច្រើន ។ សត្វទាំង បីនោះ ព្រមទទួលធ្វើតាម លុះព្រឹកឡើងគេ បានកំណត់សីលក្នុងចិត្តហើយ ក៏ត្រាច់ទៅរកចំណីក្បែរឆ្នេរគង្គានទី បានឃើត្រីឆ្អិន ៧ ដែលព្រាន សន្ទូចដោតជាចង្កោម កប់ទុកក្នុងគំនរខ្សាច់ ក៏បន្លឺនូវសំឡេងបីចងថា ត្រី នេះមានម្ចាស់ឬទេ ? កាលបើមិនឃើញម្ចាស់ហើយ ក៏ពាំត្រីនោះទៅទុក ក្នុងលំនៅរបស់ខ្លួនរង់ចាំការគួរនិងបរិភោគ ក៏ដេកពិចារណាសីលរបស់ ខ្លួនទៅ ។ ឯចចកចេញទៅរកអាហារ បានប្រទះឃើញសាច់ទន្សាយឆ្អើរ មួយចង្កាក់ និងទធិមួយដប ដែលអ្នកស្រែដាក់ក្នុងខ្ទមក៏ស្រែកបន្លឺ បីដង ថារបស់នេះមានម្ចាស់ឬទេ ? កាលបើមិនឃើញម្ចាស់ហើយ ក៏ពាំយក ទៅទុកក្នុងលំនៅរបស់ខ្លួន រង់ចាំការគួរ និងបរិភោគ , ក៏ដេកពិចារណា សីលរបស់ខ្លួនទៅ ។

ឯស្វាក៏បានចូលទៅក្នុងព្រៃរកបេះបានផ្លែស្វាយទុំមួយ យកទៅ ទុកក្នុងលំនៅរបស់ខ្លួន រង់ចាំការគួរនឹងបរិភោគ ក៏ដេកពិចារណាមើល សីលរបស់ខ្លួនទៅ ។

ឯទន្សាយបណ្ឌិតបានគិតថា ចាំដល់ពេលស្រួលអញចេញទៅស៊ីស្មៅ ប៉ុន្តែបើមានស្មូមយាចកមកកាន់ សំណាក់អញៗគ្មានអ្វីអោយទេ សូម្បីតែអង្ករ នឹងល្ងក៏គ្មានដែរ, បើប្រសិនជាមានស្មូមយាចកមកសុំមែន អញអោយសរីរៈរបស់អញទាំងមូលនេះជាទាន ។ ដោយតេជះគុណសីល និងទាន ចេតនារបស់ទន្សាយបណ្ឌិត ដែលកើតមានក្នុងចិត្ត ក៏ក្តៅដល់អសនៈរបស់សកទេវរាជ ។ លំដាប់នោះសកទេវរាជបានពិចារណាជ្រាបហេតុសព្វគ្រប់ហើយ ទើបទ្រង់ល្បងមើលសីល និងទានរបស់ទន្សាយបណ្ឌិត ក៏និមិត្តខ្លួនជាព្រាហ្មណ៍ចាស់ ដើរចូលទៅកន្លែងភេជាមុន, ភេបានឃើញឥន្ទព្រាហ្មណ៍នោះហើយ ក៏សួរថា ការអញ្ជើញមកមានការអ្វី ? ឥន្ទព្រាហ្មណ៍ប្រាប់ថា ខ្ញុំមកនេះប្រាថ្នានឹងរកអាហារប្រសិនជាបានបន្តិចបន្តួច ខ្ញុំបរិភោគហើយ នឹងរក្សាសីលនៅក្នុងទីនេះ ភេឆ្លើយថាប្រពៃហើយលោកតា ថ្ងៃនេះខ្ញុំបានត្រីឆ្អិន ៧ ដែរ សូមលោកតាពិសារចុះ ។ ឥន្ទព្រាហ្មណ៍ទទួលផ្ញើទុកហើយ ក៏ហួសទៅលំនៅចចកទៀត ។ ចចកបានឃើញក៏និយាយរាក់ទាក់ នឹងឥន្ទព្រាហ្មណ៍លោកតាថ្ងៃនេះខ្ញុំបាន សាច់ទន្សងឆ្អើរមួយចង្កាក់ និងទធិមួយដប សូមលោកតាពិសារហើយនៅធ្វើសមណៈធម៌ក្នុងទីនេះចុះ, ឥន្ទព្រាហ្មណ៍គ្រាន់តែនិយាយ ទទួលអំណរហើយ ហួសទៅលំនៅរបស់ស្វាទៀត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្វាបានឃើញហើយ ក៏និយាយរាក់ទាក់គួរសមនិងឥន្ទព្រាហ្មណ៍ថា ថ្ងៃនេះខ្ញុំមានតែស្វាយទុំមួយ និងទឹកត្រជាក់ទេ សូមអញ្ជើញតាពិសារហើយ នៅធ្វើសមណៈធម៌ក្រោមម្លប់ឈើជាទីរីករាយនេះចុះ ។ ឥន្ទព្រាហ្មណ៍ គ្រាន់តែរាក់ទាក់ទទួលអំណរហើយ ហួសទៅលំនៅទន្សាយបណ្ឌិតទៀត ។ លុះទៅដល់ហើយក៏និយាយរៀបរាប់អំពីសេចក្តីត្រូវការចង់បរិ-ភោគអាហារ និងនៅរក្សាឧបោសថសីលប្រាប់ដល់ទន្សាយបណ្ឌិត ។ ឯទន្សាយបណ្ឌិតបានឮដូច្នោះហើយ ក៏និយាយថា តាព្រាហ្មណ៍អើយ! ការអញ្ជើញមកកាន់សំណាក់ខ្ញុំប្រពៃណាស់ហើយ ខ្ញុំនឹងបានអោយទានដែលខ្ញុំមិនធ្លាប់បានអោយ ប៉ុន្តែបើលោកតាជាអ្នករក្សាសីល តមមិនធ្វើបាណាតិបាត ចូរតាទៅរកឧសបង្កាត់ភ្លើងហើយ មកប្រាប់ដល់ខ្ញុំៗនឹងលោតទំលាក់ខ្លួនត្រង់រងើកភ្លើងនោះ បើសាច់របស់ខ្ញុំឆ្អិនល្មមហើយ សូមលោកតាពិសារហើយ ធ្វើសមណៈធម៌ចុះ ។

វេលានោះឥន្ទព្រាហ្មណ៍បានភ្លើងដោយឫទ្ធិរបស់ខ្លួន ឆេះសន្ធោសន្ធៅហើយ មកប្រាប់ដល់ទន្សាយបណ្ឌិតៗក៏ដើរទៅឈរជិតគំនរភ្លើងនោះនិយាយថា ប្រសិនបើមានសត្វល្អិតជ្រកនៅត្រង់ចន្លោះរោមរបស់យើង សុំកុំអោយស្លាប់, រលាស់ខ្លួន ៣ ដងហើយ ក៏លោតទៅក្នុងគំនរភ្លើងដោយចិត្តរីករាយដូចជារាជហង្ស ចុះទំលើគំនរផ្កាឈូកក្រហមគួរអស្ចារ្យពេលណាស់ សូម្បីតែរោមមួយក៏មិនឆេះឡើយ ត្រជាក់ដូចលោតចូលទៅក្នុង

គំនរទឹកសន្សើម ។ លំដាប់នោះ ទន្សាយបណ្ឌិតសួរឥន្ទព្រាហ្មណ៍ថា តាអើយ ! ភ្លើងនេះត្រជាក់ម្ល៉េះ ? ឥន្ទព្រាហ្មណ៍ឆ្លើយថា ចៅអើយ ! តាមិនមែនជាព្រាហ្មណ៍ទេ គឺជាព្រះឥន្ទ ខ្ញុំមកនេះដោយចង់ល្បងមើលសីលនិងទានរបស់អ្នកទេតើ ! ។ ទន្សាយបណ្ឌិតបានបន្លឺសីហនាទតបថា បពិត្រទេវរាជ ! កុំថាឡើយព្រះអង្គម្ចាស់ឯង បើទុកជាលោកសន្និវាសទាំងមូល មកចង់ល្បងមើលទានរបស់ខ្ញុំ ក៏ដោយត្រង់របស់អ្វីដែលខ្ញុំមិនចង់អោយនោះគ្មានទេ ។ លំដាប់នោះសក្កទេវរាជពោលថា ៖ ម្នាលទន្សាយបណ្ឌិត ! គុណរបស់អ្នកចូរតាំងនៅអស់មួយកប្ប កុំអោយរលត់បាត់ឡើយ, ទើបចាប់ផ្ទាំងភ្នំ ដោយតេជានុភាពច្របាច់ពូតយកជ័រទៅគូសជារូបទន្សាយភ្ជាប់ និងមណ្ឌលព្រះច័ន្ទ ដោយត្រឡប់ទៅកាន់ទេវលោកវិញ ។

ឯសត្វទាំង ៤ ក៏នាំគ្នារក្សាសុច្ចរិតធម៌ ដរាបដល់អស់អាយុ បានទៅកើតទេវលោកទាំងអស់គ្នា ។

ជាតកនេះព្រះអង្គត្រាស់ថា ភេក្ខុងកាលនោះគឺ ជាអានន្ទ, ចចកគឺមោគ្គល្លាន, ស្វាគឺសារីបុត្រ, ព្រះឥន្ទគឺអានុរុទ្ធ, ទន្សាយបណ្ឌិតគឺព្រះអង្គតថាគត ។

នាំនិទាននេះដើម្បីបញ្ជាក់អោយឃើញច្បាស់ កុំថាឡើយព្រះអង្គមានជាតិជាមនុស្ស សូម្បីតែយោនយកកំណើតកើតជាសត្វ ក៏ព្រះអង្គមិន

បោះបង់នូវអង្គរបស់បណ្ឌិតនោះឡើយ ដូចរឿងសសបណ្ឌិត ដែលបានសំដែងមកនេះ ។

បណ្ឌិតអ្នកប្រាជ្ញមានប្រាជ្ញា១កើតដោយធម៌ ៣ យ៉ាងគឺ :

**១.សុតាមយបញ្ញា** ប្រាជ្ញាកើតអំពីការស្តាប់

**២.ចិន្តាមយបញ្ញា** ប្រាជ្ញាកើតអំពីការគិត

**៣.ភាវនាមយបញ្ញា** ប្រាជ្ញាកើតអំពីការទន្ទេញ ។

**បញ្ញាវុឌ្ឍិធម៌** ធម៌ជាគ្រឿងចំរើនប្រាជ្ញាមាន ៤ យ៉ាងគឺ :

**១.សប្បុរិសូបសំសេវ** សេពគប់សប្បុរស

**២.សទ្ធម្មស្សវន** ស្តាប់ពាក្យព្រានប្រដៅរបស់លោក ។

**៣.យោនិសោមនសិការ** ត្រិះរិះអោយស្គាល់របស់ល្អ ឬអាក្រក់ដោយឧបាយនៃប្រាជ្ញា ។

**៤.ធម្មានុធម្មប្បដិបត្តិ** ប្រតិបត្តិធម៌ដ៏សមគួរដែលបានត្រិះរិះឃើញហើយ ។

បណ្ឌិតកាលបើស្វែងរកទ្រព្យបានហើយ មិនអោបក្រសោបនូវទ្រព្យនោះទុក អោយទៅជាអាសារ ឥតការនោះទេ លោកតែងគិតប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ សេចក្តីនេះសមនិងព្រះពុទ្ធដីកាដែលមានមកក្នុងខុទ្ទកនិកាយជាតក ឆក្កនិបាតថា :

**ធីរោ ភោគេ អធិគម្ម សង្គណ្ហាតិ ចញ្ញាត ភេ តេន សោ កិត្តី បប្បោតិ បេច្ច សគ្គេ បមោទតិ ៗ**

អ្នកមានប្រាជ្ញាបានភោគៈ ហើយរមែងសង្គ្រោះពួកញាតិ ព្រោះការសង្គ្រោះនោះ គេរមែងបានកេរ្តិ៍ឈ្មោះទៅខាងមុខ រមែងរីករាយក្នុងឋានសួគ៌ ។

អ្នកមានប្រាជ្ញា គឺអ្នកមានប្រាជ្ញាឈ្លាសវៃ យល់ន័យទូលំទូលាយ កាលបើប្រកបមុខរបរ ចំរើនកើនផលកើតភោគៈ គឺទ្រព្យសម្បត្តិហើយ ក្រៅពីចិញ្ចឹមខ្លួន និងគ្រួសារក៏ រមែងសង្គ្រោះបែងរំលែក ចែកចាយជាញាតិមិត្រជិតខាង តាមសមត្ថភាពដែលអាចសង្គ្រោះបាន មិនព្រងើយកន្តើយចំពោះញាតិ មិត្តទាំងឡាយ ព្រោះការសង្គ្រោះនោះ មិនមែនឥតផលឡើយ គេរមែងបានកេរ្តិ៍ឈ្មោះពីរោះល្បី មានសិរីក្នុងក្នុងគ្រប់ទីកន្លែង កាលបើមានកេរ្តិ៍ឈ្មោះពិរោះល្អថា ជាជនសប្បុរសមានមេត្តាប្រណីមនុស្សទាំងឡាយ ក៏ស្រឡាញ់គោរពរាប់អាន ជួយរក្សាការពារដោយវិធីផ្សេងៗ អោយបានសុខសាន្តវែងឆ្ងាយ នាំអោយកើតសេចក្តីសុខសប្បាយរីករាយចិត្ត មិនតែប៉ុណ្ណោះទេ អ្នកមានប្រាជ្ញា ចេះសង្គ្រោះញាតិនោះទៅខាងមុខគឺ កាលបើស្លាប់ទៅរមែងរីករាយក្នុងឋានសួគ៌ទៀត ព្រោះកន្លែងសុខសប្បាយរីករាយឋានសួគ៌នេះ សម្រាប់ទទួលតែមនុស្សមានចិត្តបុណ្យ សុទ្ធវិទាន មានសប្បុរធម៌ កាលនៅជាមនុស្សលោកនេះឯង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ឌិត លោកមិនប្រព្រឹត្តអាក្រក់ ដោយកាយវាចាចិត្តឡើយ ព្រោះតែប្រាថ្នា សេចក្តីសុខចំពោះខ្លួន ប្រសិនបើជាជួបប្រទះនូវសេចក្តីទុក្ខ ក៏លោកមិនបោះបង់នូវព្រះធម៌ ព្រោះហេតុតែអគតិនោះឡើយ ។

សេចក្តីនេះសមនឹងព្រះពុទ្ធដីកា ដែលមានមកក្នុងជាតកដ្ឋកថាថា :

**នបណ្ឌិតោ អត្តសុខស្ស ហេតុ បាបានិ កម្មានិ**

**សមាចរន្តិ ទុក្ខេន ផុដ្ឋា ខលិតាបិ សន្តា ឆន្ទាយ**

**ទោសា ន ជហន្តិ ធម្មំ ។**

ពួកបណ្ឌិតរមែងមិនប្រព្រឹត្តបាបកម្ម ព្រោះហេតុនៃសេចក្តីសុខដើម្បីខ្លួន, ពួកសប្បុរសដែលសេចក្តីទុក្ខពាល់ត្រូវ ទោះបីភ្លាំងភ្លាត់ក៏មិនលះបង់ធម៌ព្រោះឆន្ទាគតិ និងទោសាគតិ ។

ពួកបណ្ឌិត គឺពួកជនដែលស្គាល់នូវហេតុផល នូវអំពើអ្វីជាប្រ-យោជន៍ អ្វីដែលមិនមែនជាប្រយោជន៍រមែងវៀរចាក ងាកចេញនូវអំពើដែលមិនមែនជាប្រយោជន៍ខ្លួន មិនមែនប្រយោជន៍ជនដទៃ ហេតុនេះពួកបណ្ឌិតមិនប្រព្រឹត្តបាបកម្ម គឺ អំពើបាបទាបថោកទាំងឡាយដោយកាយវាចា ចិត្ត បើទោះជាអំពើបាបនោះ ជាមធ្យោបាយអោយខ្លួនបានជួបជួននឹងទ្រព្យសម្បត្តិ លាភផល ជោគជ័យ ដែលរាប់ថាជា សេចក្តីសុខមួយដងមួយកាល ដើម្បីខ្លួនក៏ដោយ ព្រោះលោកស្គាល់យល់ច្បាស់ថា បាបកម្មជាភ្លើង ជាថ្នាំពិសពុល ពុំមែនជាផ្លូវអោយកើតសេចក្តីសុខ ត្រជាក់ត្រជុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចំពោះខ្លួនពិតប្រាកដទេ គឺជាអំពើហុចផលផ្តល់សេចក្តីទុក្ខក្តៅក្រហាយស្តាយក្រោយមិនខាន ហេតុនេះ "ពួកបណ្ឌិតរមែងមិនប្រព្រឹត្តបាបកម្មព្រោះហេតុនៃសេចក្តីសុខដើម្បីខ្លួន " ។

ជាពិសេសទៅទៀតពួកបណ្ឌិតជាអ្នកមានកាយ វាចា ចិត្ត ស្ងប់ចាកទុច្ចរិត បាប កម្ម ទាំងឡាយនោះមានសេចក្តីទុក្ខពាល់ត្រូវ ដូចជាការត្រូវឥទ្ធិពលណាមួយ បង្ខិតបង្ខំ ថាបើមិនធ្វើបាបកម្ម ទុច្ចរិតអយុត្តិធម៌នោះៗទេ ខ្លួននឹងត្រូវធ្លាក់ចុះក្នុងភ័យវិបត្តិ ទោសទណ្ឌកម្ម ត្រូវខូចយសវិនាសទ្រព្យស្លាប់ជីវិត ឬ ត្រូវគេយកគ្រួសារជាទីស្រឡាញ់ទៅប្រហារជីវិតជាដើម, សេចក្តីទុក្ខមកពាល់ត្រូវយ៉ាងនេះជាដើមក្តី ក៏សប្បុរស ឬបណ្ឌិតមិនព្រមលះបង់ធម៌ គឺសុច្ចរិត យុត្តិធម៌ឡើយ គឺសុខចិត្តលះបង់ទ្រព្យលះបង់គ្រួសារ លះបង់ជីវិត ដើម្បីរក្សាសុច្ចរិតធម៌វិញ, ប៉ុន្តែបើបែរជាភ្លាំងភ្លាត់ប្រព្រឹត្តបាបកម្ម ព្រោះឥទ្ធិពលអ្នកមានអំណាចណាមួយ បង្ខិតបង្ខំអោយនិយាយ អោយធ្វើទុច្ចរិតបាបកម្ម ក៏មិនមែនធ្វើព្រោះស្រឡាញ់ពេញចិត្តស្ម័គ្រធ្វើ ឬ ព្រោះកំហឹង, ការស្អប់ខ្ពើម ដែលហៅថា ឆន្ទាគតិនិងទោសាគតិនោះឡើយ គឺធ្វើដោយទើសទាល់ ធ្វើដោយអចេតនាធ្វើព្រោះឥទ្ធិពលណាមួយ បង្ខិតបង្ខំប៉ុណ្ណោះ ព្រោះបណ្ឌិតតែងស្រឡាញ់សុច្ចរិតយុត្តិធម៌យ៉ាងក្រៃលែង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# "រឿង ពគ្គបណ្ឌិត "

## មានមកក្នុងលោកនេយ្យជាតក

អ្នកប្រាជ្ញគួរធ្វើល្ងង់ ក្នុងកាលខ្លះ ដើម្បីសន្តិភាព ។ ក្នុងអវសរដែលកន្លងទៅហើយ មានកូនបក្សីបី គឺកូនក្អែក កូនសារិកា កូនកុក នៅអាស្រ័យក្នុងសំបុកលើមែកព្រឹក្សាជិតៗគ្នា ។

សម័យនោះមានថ្មើរព្រៃបីនាក់, នៅក្នុងដែនកម្ពោជៈ បាននាំគ្នាចរចូលទៅក្នុងព្រៃដើម្បីចាប់ម្រឹគ ។ ថ្មើរព្រៃទាំងបីនាក់ខំស្វែងរកម្រឹគអស់មួយថ្ងៃ ពុំបានជួបប្រទះសោះ ដល់ពេលល្ងាចជិតត្រឡប់មកផ្ទះវិញបានឃើញកូនបក្សីបី ដែលនៅក្នុងសំបុកជិតៗគ្នានោះ ក៏ចាប់យកមួយៗម្នាក់មកចិញ្ចឹម ។

ឯថ្មើរព្រៃទាំងបីរូបនោះ មានសេចក្តីស្រឡាញ់ចំពោះកូនបក្សីទាំងបីហាក់ដូចជាកូនបង្កើត, បានគិតគ្នាថា យើងខំចិញ្ចឹមរក្សាបង្រៀនអោយមានបែបបទល្អ ហើយយកទៅថ្វាយស្តេចជាគ្រឿងបណ្ណាការ ។ ថ្មើរព្រៃម្នាក់ដែលចិញ្ចឹមកូនក្អែក ខំបង្ហាត់អោយចេះពង់ចេះរាំ ចេះក្រាបសំពះ ឯក្អែកជាសត្វមានគំនិតខ្លី ក៏ចេះតែខំធ្វើតាម ដរាបដល់ចេះពង់ ចេះរាំ ចេះក្រាបសំពះ ដូចបំណងរបស់ម្ចាស់ ។

ថ្មើរព្រៃម្នាក់ទៀត ដែលចិញ្ចឹមកូនសារិកា ក៏បង្ហាត់បង្ហាញអោយរៀននិយាយ ភាសាមនុស្ស, សារិកាជាសត្វមានគំនិតខ្លី ក៏ខំប្រឹងនិយាយតាមដរាបដល់ចេះនិយាយ ជាមួយនឹងមនុស្សបាន ។

ឯផ្ទើរព្រៃម្នាក់ទៀត ដែលចិញ្ចឹមកូនកុក ក៏ខំបង្ហាត់បង្រៀនកុកនោះ អោយបានដូចបំណងរបស់ខ្លួន ប៉ុន្តែកុកជាបណ្ឌិតមានគំនិតវែងបានគិតថា អញមិនគួរធ្វើជាអ្នកចេះរាំ ចេះនិយាយ ចេះក្រាបសំពះ តាមឱវាទរបស់ផ្ទើរព្រៃ ទុច្ចរិតនេះទេ បើអញធ្វើជាអ្នកចេះដឹង មុខជាផ្ទើរព្រៃនេះ ដាក់ក្នុងទ្រុងដរាបដល់អស់ជីវិត, លុះគិតដូច្នេះហើយ ក៏មិនអើពើនិងឱវាទរបស់ផ្ទើរព្រៃ ជាម្ចាស់ឡើយ បើគេបង្ខំខ្លាំងគ្រាន់តែស្រែកក្រកៗប៉ុណ្ណោះ ។ ថ្ងៃមួយផ្ទើរព្រៃទាំងនោះ បានយកកូនបក្សីទាំងបី ទៅថ្វាយស្ដេច, ព្រះរាជាបានទតឃើញកូនបក្សីនោះហើយ ទ្រង់មានព្រះតម្រាស់ថា : ម្នាលព្រានកូនក្ងោកនេះមានគុណវិសេស ដូចម្ដេចខ្លះ ? អ្នកម្ចាស់ក្ងោកក្រាបទូលថា បពិត្រព្រះសម្មតិទេព ក្ងោកនេះចេះរាំចេះពង់ ចេះក្រាបថ្វាយបង្គំ ក៏ប្រើក្ងោកនោះ អោយថ្វាយបង្គំព្រះរាជា លុះក្ងោកនោះថ្វាយបង្គំហើយ អ្នកម្ចាស់ក្ងោកធ្វើភ្លេង ដោយមាត់របស់ខ្លួន ក្ងោកក៏ពង់ពេន ររាំតាមតាមភ្លេងនោះ ។ ព្រះរាជាបានទតឃើញដូច្នោះទ្រង់សព្វព្រះរាជហឫទ័យណាស់ ក៏ត្រាស់បង្គាប់អោយអាមាត្យចងទុកក្បែរទីនោះទៅ ។ ទ្រង់សួរទៅអ្នកចិញ្ចឹមសារិកាទៀត, អ្នកចិញ្ចឹមសារិកាក្រាបទូលថាបពិត្រមហារាជ ! សារិកានេះចេះនិយាយថ្វាយព្រះរាជាព្រះសណ្ដាប់ភស្ដាកូនសារិកានោះ ហើយទ្រង់សព្វព្រះរាជហឫទ័យ ក៏បង្គាប់អាមាត្យអោយចងទុកក្បែរសត្វក្ងោក ។ ទើបត្រាស់សួរទៅអ្នកចិញ្ចឹមកុកទៀត

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកចិញ្ចឹមកុកក្រាបទូលថា បពិត្រព្រះសម្មតិទេព កុកនេះជាសត្វល្ងង់បំផុត ទោះបីទូលព្រះបង្គំខំបង្ហាត់បង្ហាញយ៉ាងណា ក៏ពុំចេះដឹងអ្វីសោះ ចេះត្រឹមតែស្រែកក្រក។ប៉ុណ្ណោះ ។

កុកបណ្ឌិតកាលបើម្ចាស់របស់ខ្លួនទូលព្រះរាជដូច្នោះហើយ ក៏ស្រែកឡើងក្រក។ ។ លំដាប់នោះព្រះរាជាទ្រង់ព្រះសំរួលយ៉ាងខ្លាំង ទើបបង្គាប់អាមាត្យថា ឯងយកកុកនេះទៅលែងទៅ កុំទុកព្រោះវាល្ងង់ណាស់ មិនចេះនិយាយស្ដីនឹងគេទេ ។ កុកបណ្ឌិតកាលបើអាមាត្យលែងហើយ ក៏ហើរទៅទុំលើកំពូលប្រាសាទ សូត្របទគាថាជាភាសាមនុស្សថា :

**ពកោ្ខ បណ្ឌិតោ រាជ ភាសកញ្ចេវ មានុសំ**

**មយូរា សាលិកាចេវ ពហូ ញាណពន្ធនា ។**

បពិត្រមហារាជ ខ្ញុំជាកុកមានប្រាជ្ញា ម្ចាស់ខ្ញុំព្រះអង្គអោយនិយាយ ខ្ញុំមិននិយាយឡើយ ដើម្បីដោះខ្លួនអោយរួចពីចំណង, ឯក្ងោកនិងសារិកាជាអ្នកចេះដឹងច្រើន ក៏ជាប់ចំណងច្រើន ។

ព្រះរាជាទ្រង់បន្លឺនូវព្រះសូរសីហនាទថា សាធុ។ អ្នកជាបណ្ឌិតមានប្រាជ្ញាមែន ។ កុកបណ្ឌិត ក៏ហើរទៅតាមវត្ថុបំណងរបស់ខ្លួនដោយសួស្ដី ។ លំដាប់នោះព្រះរាជាទ្រង់ទតឃើញក្ងោក និងសារិកា ដែលជាប់ចំណង មានមុខក្រៀមក្រម ស្រងូតស្រងាត់ ក៏ត្រាស់បង្គាប់អាមាត្យអោយដោះលែងទៅ ។

បណ្ឌិតគឺសុធីរជន អ្នកមានប្រាជ្ញា តែងមានសង្គហធម៌ សង្គ្រោះចំពោះមនុស្សសត្វទូទៅ ឥតរើសមុខ ដូចជាអម្ពបណ្ឌិត ដែលមានក្នុងអម្ពជាតក ជាតកដ្ឋកថា ទ្រង់សំដែងថា ៖ សេចក្តីសង្គ្រោះ ជាមហាស្នេហ៍ពូកែផុតលោក ។ សេចក្តីដំណាលថា ៖

ក្នុងអតីតកាលកន្លងទៅហើយមាន ព្រះរាជាមួយព្រះអង្គព្រះនាមព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិជាព្រាហ្មណ៍ នៅក្បែរផ្លូវឧត្តរទិសនៃក្រុងនោះ លុះចំរើនវ័យធំឡើង ចេញចាកគេហដ្ឋានចូលបួសជាតាបស មានពួកតាបស ៥០០ រូប ជាបរិវារ ស្នាក់នៅក្បែរជើងភ្នំហិមាល័យ ។ គ្រានោះទឹកក្នុងជ្រោះភ្នំក្នុងស្ទឹងត្រពាំងបឹងបួរ អូរ ព្រែក រីងស្ងួតអស់ឥតសល់ សត្វម្រឹគបក្សាបក្សីដែលអាស្រ័យនៅក្នុងព្រៃហិមាល័យទាំងប៉ុន្មាន កើតសេចក្តីក្តៅក្រហាយ ដោយស្រេកទឹកជាខ្លាំង ។ តាបសបានឃើញសត្វទាំងនោះមានទុក្ខវេទនាដូច្នោះហើយ មានតាបសមួយរូបបានកាប់រំលំដើមឈើ១ដើម ចោលលង់ធ្វើជាស្នូក ហើយទៅដងទឹកដែលលោកអាចទៅដងបានយកមកដាក់ក្នុងស្នូកនោះទុកបំរុងអោយសត្វទាំងឡាយផឹក ។ ពួកសត្វទាំងឡាយក៏នាំគ្នាផឹកទាំងហ្វូង១ឥតឈប់ឈរ ទាល់តែតាបសអស់ឱកាសនិងចេញទៅស្វែងរកផ្លែឈើមកឆាន់ខ្លួនឯង ។ តាបសនោះលោកមិនអើពើនឹង សេចក្តីស្រេកឃ្លានរបស់ខ្លួនឡើយ លោកខំតែដងទឹកមកចាក់ក្នុង

ស្នូកអោយសត្វទាំងនោះផឹកទាល់តែបាត់ស្រេក ព្រោះលោកជាអ្នកមាន សេចក្តីសង្គ្រោះចំពោះសត្វទាំងឡាយឥតរើសមុខ ។

ពួកសត្វទាំងនោះកាលបើបានឃើញតាបស មានសេចក្តីសង្គ្រោះ ដល់ខ្លួន ក៏គិតគ្នាថាយើងរាល់គ្នា ត្រូវតបស្នងសងគុណតាបស នេះគ្រប់ៗ គ្នាកុំខាន យើងត្រូវព្រមព្រៀងគ្នាយ៉ាងនេះ គឺត្រូវយកផ្លែឈើ មើមឈើ មកគ្រប់ៗគ្នាក្នុងវេលាដែលមកផឹកទឹកនៅទីនេះ ដើម្បីប្រគេនតាបស ។

សត្វទាំងអស់ក៏ព្រមព្រៀងគ្នា ក្នុងវេលាដែលមកផឹកទឹកបាននាំ ផ្លែស្វាយ និងផ្លែឈើមើមឈើផ្សេងៗ មកប្រគេនតាបសរាល់ថ្ងៃ ទាល់តែ ផ្លែឈើ មើមឈើនោះ សម្បូរពោរពាស ក្នុងគម្ពីរប្រាប់ថាបើផ្ទុកជារទេះ បាន ២៥០០ រទេះ ក្នុងមួយថ្ងៃៗពួកតាបសទាំង ៥០០ រូបឆាន់ឆ្អែតស្កប់ ស្កល់នៅសល់ពោរពោសពេញអាស្រម ។

ព្រះពោធិសត្វដែលជាប្រធាននៃតាបសទាំង ៥០០ រូប បានឃើញ អស្ចារ្យដូច្នោះហើយ ក៏បន្លឺនូវវាចាប្រកាសថា គុណគឺសេចក្តីល្អរបស់បុគ្គល តែម្នាក់ដែលមានសេចក្តីសង្គ្រោះ អាចបណ្តាលអោយកើត ចំណីអាហារ ដល់ពួកគណៈបរិភោគឆ្អែតស្កប់ស្កល់បាន ព្រោះហេតុនោះអ្នកទាំងឡាយ ត្រូវតាំងព្យាយាមមាំមួនក្នុងការបំពេញសង្គហធម៌ ស្វែងរកប្រយោជន៍ ចំពោះសាធារណជន កុំខ្ជិលគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនយកចិត្តទុក ដាក់អើពើ និងប្រយោជន៍របស់សាធារណជនឡើយ ។

នរជនប្រុសស្រីចង់បានសេចក្តីសុខចំរើន នឹងសេចក្តីថ្លៃថ្នូរ គប្បីសេពគប់ និងបណ្ឌិត សេចក្តីនេះសមដូចពុទ្ធភាសិតក្នុងគម្ពីរ ខុទ្ទកនិកាយ ធម្មបទទ្រង់សំដែងថា :

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហវាទឹ**

**មេធាវិំ តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភជមានស្ស**

**សេយ្យោ ហោតិ ន បាបិយោ ។**

ឃើញបណ្ឌិតបែបណា អ្នកមានប្រក្រតីចង្អុល ប្រាប់ទោសដូចអ្នកចង្អុលប្រាប់កំណប់ទ្រព្យអោយអ្នកមានប្រក្រតីពោលផ្ទុយផ្ទាល់មានបញ្ញា, គប្បីគប់រកបណ្ឌិតបែបនោះ កាលបើគប់រកបណ្ឌិតបែបនោះ រមែងប្រសើរបំផុត មិនថោកទាបឡើយ ។

ព្រះពុទ្ធដីកា មួយកន្លែងទៀតក្នុងខុទ្ទកនិកាយ ថេរគាថាទ្រង់សំដែងថា :

**បិសុណេនច កោធនេន**

**មច្ឆរិនា ច វិភូតិ នន្ទិនា**

**សខិតំ ន ករេយ្យ បណ្ឌិតោ**

**បាបោ កាបុរិសេន សង្គមោ ។**

បណ្ឌិតគប្បីធ្វើសខិភាព និងជនដែលពោលពាក្យញុះញង់ ជនក្រោធ ជនកំណាញ់ នឹងជនដែលភ្លើតភ្លើនក្នុងសម្បត្តិ ព្រោះថាការមោគម និងមនុស្សអាក្រក់ជាសេចក្តីថោកទាប ។

បណ្ឌិតអ្នកមានប្រាជ្ញាយល់ឃើញដោយប្រត្យក្សថា អំពើទុច្ចរិតប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត តែងនាំមកនូវសេចក្តីទុក្ខលំបាកក្នុងលោកនេះ និងលោកខាងមុខ ។ អំពើសុច្ចរិតប្រព្រឹត្តល្អ ដោយកាយវាចចិត្ត តែងនាំមកនូវសេចក្តីសុខចំរើន សិរីសួស្តី សុភមង្គល ទាំងក្នុងលោកនេះ ទាំងលោកខាងមុខ, ហើយបានគេចខ្លួនចាកអំពើអាក្រក់គ្រប់ជំពូក ប្រព្រឹត្តអំពើល្អ ព្រមទាំងនិយាយដឹកនាំអោយ អ្នកដែលជឿតាមប្រព្រឹត្តតាមឈមមុខ ទៅរកសេចក្តីសុខចំរើន បានគ្រប់ទិវារាត្រីកាល ។

**សេចក្តីឧបមានៃប្រាជ្ញារបស់មនុស្សក្នុងលោកនេះ មាន ៤ យ៉ាងគឺ:**

**១-បាសាណលេខូបមា** ឧបមាដូចជាបុគ្គលគូសថ្ម

**២-បឋមវិលេខូបមា** ឧបមាដូចជាបុគ្គលគូសផែនដី

**៣-ឧទកលេខូបមា** ឧបមាដូចជាបុគ្គលគូសទឹក

**៤-អាកាសលេខូបមា** ឧបមាដូចជាបុគ្គលគូសអាកាស ។

អាស្រ័យហេតុហ្នឹងហើយ បានជាជនជាបណ្ឌិត មិនមែនមានច្រើនទូទៅទេ សមដូចសុភាសិតថា : ជនជាបណ្ឌិតកម្ររកបាន ជនពាលសា-មាន្យច្រានចោលមិនអស់ ។

សុភាសិតក្នុងលោកនីតិថា :

បណ្ឌិតពិតមិនលះព្យាយាម

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាតិខ្លឹមច័ន្ទន៍ ទោះស្វិតក្រៀមក្រញង់ មិនលះបង់ក្លិនខ្លឹមដ៏បវរ អំពៅទោះនៅក្នុងយន្តសរ មិនបោះបង់រស់ផ្អែមឆ្ងាញ់បាន ។ ជាតិខ្លានោះតូចដូចម្ដេចម្ដា មិនបង់ក្រឡាអុជតាមប្រាណ ជាតិឆ្មាទោះណាខ្សោយប៉ុន្មានមិនបានលះបង់ការរហ័ស ជាតិប្រាជ្ញទោះបីមានទុក្ខលំបាក មិនចាកចោលការឧស្សាហ៍ណាស់ សាងសុខសួស្ដីដល់ក្មេងចាស់ ប្រកាសកេរ្តិ៍ឈ្មោះពីរោះឆ្ងាយ ។

**នៅក្នុងមង្គលសូត្រត្រង់មង្គលទី២ មានបទបាលីថា :**

**បណ្ឌិតានញ្ច សេវនា** មានអត្ថន័យថា កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ជាមង្គលដ៏ឧត្តម ។

មានអត្ថាធិប្បាយថា បណ្ឌិតទាំងឡាយក្នុងលោកមានពុទ្ធាទិបណ្ឌិតជាដើម ទោះបីលោកនៅជាបុថុជ្ជននៅឡើយក្ដី លោកមានសន្ដានចិត្តបរិសុទ្ធផុតចាកកិលេសហើយក្ដី លោកមិនដែលកាត់បង់នូវប្រយោជន៍ខ្លួនឯងនិងប្រយោជន៍អ្នកដទៃឡើយ, លោកតែងប្រកបដោយ **ហិរិ** និង **ឱត្តប្បៈ** ប្រមទាំងមាន **សទ្ធា សីល ចាគ សុត បញ្ញា** លោកតែងធ្វើប្រយោជន៍ ៣ ប្រការគឺ ប្រយោជន៍ជាតិនេះ ជាតិខាងមុខ និងប្រ-យោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន ។ បុគ្គលដែលចូលទៅសេពគប់និងពុទ្ធាទិបណ្ឌិតជាដើមនោះ រមែងបានផលប្រយោជន៍ដូចរឿង **ឧបតិស្សៈ** និង **កោលិតៈ** ទាំងពីរនាក់ជាសម្លាញ់ និងគ្នាបានចូលទៅសិក្សាក្នុងសំណាក់

Websites: WatKhemaraRatanaram.org or WatKhmers.org

អាចារ្យឈ្មោះ **សញ្ជ័យ** លុះឃើញលទ្ធិធម៌របស់អាចារ្យនោះមិនបានខ្លឹមសារ ក៏លាអាចារ្យដើម្បីបំបែកគ្នា ដើម្បីស្វែងរកឯកសារធម៌ ឯឧបតិស្ស ដើរទៅកាន់ក្រុងរាជគ្រឹះ បានជួបនឹងព្រះអស្សជិត្ថេរ ដែលទើបនឹងបួសថ្មីៗផង ហើយសាកសួររកបំណងធម៌ថា មានទីបំផុតត្រឹមណា និងសួររកព្រះសាស្តាចារ្យថាវ៉ាទដូចម្តេច ?

គ្រានោះអស្សជិត្ថេរ បានពោលថា :

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ តេសញ្ច យោ និរោធោ ច ឯវំ មហាសមណោ ។**

ធម៌ទាំងឡាយឯណា មានហេតុជាដែន កើតឡើងព្រះតថាគតសំដែងនូវហេតុនៃធម៌ទាំងឡាយនោះផង ពោលនូវការរំលត់ និងឧបាយជាគ្រឿងរលត់ នៃធម៌ទាំងឡាយនោះផង ព្រះមហាសមណៈជាគ្រូ អាគ្រូមានវ៉ាទយ៉ាងនេហជាប្រក្រតី ។

ឯឧបតិស្ស មាណពគ្រាន់តែបានស្តាប់ប៉ុណ្ណោះ ក៏បានសំរេចសោតាបត្តិផល ហើយថ្វាយបង្គំលា ព្រះអស្សជិត្ថេរ ទៅសំដែងធម៌នេះប្រាប់ដល់កោលិតៈជាសម្លាញ់ៗនោះស្តាប់ហើយបានសោតាបត្តិផលដូចគ្នា ក៏នាំគ្នាចូលទៅបួសជាឯហិបព្វជ្ជា ក្នុងព្រះពុទ្ធសាសនា, គ្រាក្រោយមកក៏បានសំរេចព្រះអរហត្ត ។ ឧបតិស្ស គឺព្រះសារីបុត្តត្ថេរ បានឋានៈជាអគ្គសាវ៉កទី១ នៃព្រះពុទ្ធជាម្ចាស់ ឯកោលិតៈ គឺព្រះមោគ្គល្លានត្ថេរ បានជាអគ្គ

Websites: WatKhemaraRatanaram.org or WatKhmers.org

សាវ័កទី២ នៃព្រះពុទ្ធជាម្ចាស់របស់យើងដែរ ។ ការសេពគប់ និងបណ្ឌិត ពិតជាដល់នូវសេចក្ដីចំរើនយ៉ាងនេះឯង ។

ការសំដែងមកក្នុងព្រះពុទ្ធដីកាបញ្ជាក់ថា

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ អរិយោ ទស្សនសម្បន្នោ សលោកំ ភជតេសិវំ ៗ**

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចំរើន ។

ធម្មទេសនា ដែលបានសំដែងមកនេះ ក៏សម្មត់ថាចប់តែប៉ុណ្ណេះ សមគួរដល់កាល នឹងវេលា ឯវំ ។

**(ចប់ធម្មទេសនា បរាភវសូត្រ)**



អធិប្បាយ
បរាភវសូត្រ
ចំណាំធម៌ទេសនា
ព.ស. ២៥៤៧ – គ.ស. ២០០៣